# សីលត្ថទីបនី

រៀបរៀងដោយ

**ជាតិធរោ ហ៊ាត ឈាហំ**

ប្រធានការិយាល័យពុទ្ធិកបណ្ឌិតសភា

ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា
នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

ព.ស.២៥៥៧

គ.ស.២០១៣

| | |
|---|---|
| ឈ្មោះរបស់សៀវភៅ | សីលត្ថទីបនី |
| រៀបរៀងដោយ | ជោតិវរោ ហ៊ិត ណាហំ ប្រធានការិយាល័យ |
| | ពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា |
| ត្រួតពិនិត្យដោយ | លោកគ្រូ ធម្មានន្ទ រ៉ាន់ ចាន់សាវ៉ែន |
| | អគ្គលេខាធិការពុទ្ធិកបណ្ឌិតសភា |
| | លោកគ្រូ ហួយ វណ្ណថន, លោក ស៊ុន សុផាន |
| អ្នកវាយកុំព្យូទ័រ | ដោយសីលវតី សុវណ្ណ ចិន្តា |
| កាលបរិច្ឆេទ | ថ្ងៃ ៨ កើត ខែអស្សុជ បញ្ចស័ក ព.ស.២៥៥៧ |
| | ត្រូវនឹងថ្ងៃសុក្រ ទី ១១ ខែ តុលា ឆ្នាំ ២០១៣ |


Printed for free distribution by

**The Corporate Body of the Buddha Educational Foundation**

11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.

Tel: 886-2-23951198 , Fax: 886-2-23913415

Email: overseas@budaedu.org

Website:http://www.budaedu.org

Mobile Web: m.budaedu.org



**This book is strictly for free distribution, it is not to be sold.**

សម្រាប់ចែកជាធម្មទាន

# អារម្ភកថា

*សៀវភៅនេះ កើតឡើងដោយបានប្រមូលអត្ថបទ ព្រះធម៌វិន័យ ដែលមាននៅក្នុងព្រះត្រៃបិដក ព្រះអដ្ឋកថា និងព្រះដីកានានា គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ មានព្រះត្រៃបិដក, សមន្តប្បាសាទិកា អដ្ឋកថាវិនយបិដក, សម្មោហវិនោទនី អដ្ឋកថាអភិធម្មបិដក, មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ, សទ្ធម្មប្បកាសិនី អដ្ឋកថាខុទ្ទកនិកាយ, បរមត្ថទីបនី អដ្ឋកថាខុទ្ទកនិកាយ, សុមង្គលវិលាសិនី អដ្ឋកថាទីឃនិកាយ, សីលក្ខន្ធវគ្គអភិនវដីកា, សារត្ថទីបនីដីកា, វិមតិវិនោទនីដីកា និងសៀវភៅព្រះត្រៃសរណគមន៍ ដែលរៀបរៀងដោយលោកគ្រូ* ***ធម្មានន្ទ*** *ជាដើម បានដកស្រង់យកសេចក្ដី ដែលជាប់ទាក់ទងនិងព្រះត្រៃសរណគមន៍ សីល សិក្ខាបទជាដើម ជាវត្ថុចាំបាច់សម្រាប់គ្រហស្ថទាំងឡាយ ក្នុងការសមាទានសិក្ខាបទ ដើម្បីរក្សាសីលឲ្យបានបរិសុទ្ធល្អ ប្រសិនបើមិនបានសិក្សាព្រះបរិយត្តិឲ្យបានល្អទេ ការរក្សាសីលក៏មិនអាចឲ្យបរិសុទ្ធបានឡើយ ។ អត្ថបទ ដែលដកស្រង់សរសេរទុកក្នុងសៀវភៅនេះ ខ្ញុំបានដាក់ឈ្មោះ សៀវភៅនេះថា* ***“សីលត្ថទីបនី”*** *បំភ្លឺអត្ថរបស់សីល ។*

*សៀវភៅនេះ ដើម្បីជាប្រយោជន៍ដល់ពុទ្ធសាសនិកទាំងឡាយ ដែលប្រាថ្នាក្នុងការសិក្សា រៀនសូត្រ ជាពិសេសសម្រាប់អ្នកសមាទាននូវសីលទាំងឡាយ មានអ្នកសមាទានសីល ៥-៨-១០-និង កម្មបថ១០ ជាដើម ។*

*ដោយអំណាចនៃការព្យាយាមសរសេរសៀវភៅនេះ សូមឧទ្ទិសបុណ្យកុសលដែលកើតអំពីធម្មទាននេះ ជូនដល់លោកអ្នកមានគុណទាំងឡាយ មាន លោកតា* ***ពៅ*** *លោកយាយ* ***ជា ហ៊ិន់*** *លោកតា* ***ចេង*** *លោកយាយ* ***អ៊ិន់****, លោកឪពុក* ***ពៅ ហ៊ិត*** *និងញាតិរបស់អ្នកគ្រូ* ***ធម្មរក្ខិតា*** *ព្រមទាំងញាតិក្នុងសង្សារវដ្ដទាំងអស់ និងសូមជូនបុណ្យកុសលនេះ ដល់លោកម្ដាយរបស់ខ្ញុំ គឺឧបាសិកា* ***ចេង ស្រ៊ាង*** *និងបងប្អូនទាំងអស់ ព្រមទាំងសូមជូនដល់លោក* ***បណ្ឌិត កុល ផេង*** *និងឧបាសិកា* ***កុល គឹមផល្លា*** *លោកគ្រូ* ***ធម្មានន្ទ*** *លោកគ្រូ* ***ចាន់ ហ៊្សួរ*** *លោកគ្រូ* ***ហួយ វ៉ាន់ថន*** *អ្នកគ្រូ* ***ធម្មរក្ខិតា*** *និងសហការីទាំងអស់ ព្រមទាំងពុទ្ធបរិស័ទទាំងក្នុងនិងក្រៅប្រទេស និងសព្វសត្វទាំងអស់ សូមអនុមោទនា ដោយសទ្ធាជ្រះថ្លា យកនូវបុណ្យកុសលដែលកើតអំពីធម្មទាននេះ ឲ្យបានស្មើៗគ្នា ។*

# សន្លឹកប្រាប់មាតិកា

**មាតិកា** **ទំព័រ**


បទសរភញ្ញ........................................................................................១

ធម៌នមស្ការ .....................................................................................២

រតនត្តយបូជា.....................................................................................២

ពុទ្ធរតនប្បណាម...............................................................................២

ធម្មរតនប្បណាម...............................................................................៦

សង្ឃរតនប្បណាម.............................................................................៩

បារមីទាំង៣០..................................................................................១៤

ធាតុចេតិយនមក្ការគាថា..................................................................១៧

នមស្ការស្នាមព្រះពុទ្ធបាទ..................................................................១៩

មហាបុរិសលក្ខណៈ ៣២ ប្រការ............................................................២១

បាទវន្ទនា.........................................................................................២៣

នមស្ការស្នាមព្រះបាទដែលប្រដាប់ដោយមង្គល១០៨...............................២៣

សច្ចកិរិយាខាងក្រោយធ្វើបទនមស្ការ...................................................២៥

ប្រកាសដោយសេចក្តីឧបមា...............................................................២៦

វិធីសមាទាននិច្ចសីល........................................................................២៨

វិធីសមាទានឧបោសថសីល.................................................................៣៥

ការសមាទានឧបោសថមានអង្គ ៣.........................................................៣៨

វិធីសមាទានបាដិហារិយុបោសថសីល....................................................៤៣

វិធីអធិដ្ឋានបាដិហារិយុបោសថ............................................................៤៦

វិធីសមាទានអាជីវដ្ឋមកសីល...............................................................៤៧

វិធីអធិដ្ឋានទសង្គសីល......................................................................................៥៥
វិធីសមាទានកម្មបថ១០.......................................................................................៥៥
វិធីអធិដ្ឋានទសកម្មបថង្គសីល............................................................................៥៩
វិធីសមាទានឯកជ្ឈ:..............................................................................................៦០
វិធីសមាទានសីល ១០ ជាឯកជ្ឈសមាទាន.............................................................៦៦
វិនិច្ឆ័យព្រះត្រៃសរណគមន៍.................................................................................៦៩
ពណ៌នាព្រះត្រៃសរណគមន៍...................................................................................៧០
សរណគមន៍ និងជល់សរណគមន៍..........................................................................៧១
សរណគមន៍ដាច់ មិនដាច់ និងផល........................................................................៧២
កំណត់សេចក្ដីប្លែកគ្នារបស់សិក្ខាបទទូទៅ.............................................................៧៣
ពោលដោយសមាទាន............................................................................................៧៩
ពោលដោយវិរតិ...................................................................................................៨១
ឧបោសថកាលសង្ខេប...........................................................................................៨៥
បាដិហារិកបក្ខឧបោសថ.......................................................................................៨៧
ពណ៌នាសេចក្ដីនៃសិក្ខាបទដោយសង្ខេបសិន.........................................................៨៨
អ្នកទ្រុស្តសីល និងអលជ្ជីសម្រាប់គ្រហស្ថសីល ៥..................................................៩១
សីលពិសេសរបស់យាវាសទាំងឡាយ....................................................................៩៣
អាជីវដ្ឋមកសីល និងអ្នករក្សាបញ្ចសីលផ្សេងគ្នា....................................................៩៣
ចែកសីលដោយនិច្ចសីល និងអនិច្ចសីល...............................................................៩៤
ចែកសីលដោយចារិត្តសីល និងវារិត្តសីល.............................................................៩៥
លក្ខណៈ រស និងបដិក្ខេបធម៌..............................................................................៩៥
អធិប្បាយសិក្ខាបទអាជីវដ្ឋមកសីល.....................................................................៩៦
រឿងឧបោសថកម្ម.................................................................................................៩៧

ស្ត្រីរក្សាឧបោសថមានបំណងផលផ្សេងៗគ្នា.....................................៩៧
ពណ៌នាឧបោសថ ៣ ប្រភេទ.................................................................៩៩
ពណ៌នាសេចក្ដីនៃសិក្ខាបទ...............................................................១២០

## បាណាតិបាតសិក្ខាបទ១

អធិប្បាយសិក្ខាបទ ១០.....................................................................១២៤
អធិប្បាយឱកាសដែលបញ្ជាឲ្យធ្វើការសម្លាប់.............................................១២៧
អធិប្បាយអាវុធជាគ្រឿងដៃប្រើឲ្យសម្លាប់..................................................១២៨
អធិប្បាយឥរិយាបថដែលបញ្ជាឲ្យធ្វើការសម្លាប់........................................១២៨
អធិប្បាយកិរិយាវិសេស.....................................................................១២៨
និស្សគ្គិយប្រយោគ...........................................................................១២៩
ថាវរប្រយោគ.................................................................................១២៩
មតិរបស់ព្រះថេរៈពីររូបក្នុងការជីករណ្ដៅ.................................................១៣២
ពោលដោយការដាក់អន្ទាក់របស់ភិក្ខុ......................................................១៣៤
វិជ្ជាមយប្រយោគ.............................................................................១៣៥
ឥទ្ធិមយប្រយោគ..............................................................................១៣៥
បាណាតិបាត មានអង្គ ៥...................................................................១៣៥
បាណាតិបាតមានទោស.......................................................................១៣៦
បាណាតិបាតមានទោស.......................................................................១៣៧

## អទិន្នាទានសិក្ខាបទទី២

នានាបញ្ចកៈពួកទី ១ មាន ៥ .............................................................១៤៤
ឯកកណ្ឌបញ្ចកពួកទី ២ នោះមាន ៥ យ៉ាង..............................................១៤៥
សាហត្ថិកបញ្ចកៈពួកទី ៣ មានអវហារ ៥ ................................................១៤៥

បុព្វបយោគបញ្ចកៈពួកទី ៤ មាន ៥ ..................................................១៤៦
ថេយ្យាវហារបញ្ចកៈពួកទី ៥ មាន ៥ ...............................................១៤៧
អធិប្បាយឱកាសបរិកប្ប.....................................................................១៤៩
អទិន្នាទានមានទោសច្រើន..................................................................១៥១
អទិន្នាទាននេះមានអង្គ ៥ ..................................................................១៥៤


## កាមេសុមិច្ឆាចារសិក្ខាបទទី៣


កាមេសុ មិច្ឆាចារសិក្ខាបទទី៣..........................................................១៥៦


## អព្រហ្មចរិយសិក្ខាបទទី៣


អព្រហ្មចរិយសិក្ខាបទទី៣.....................................................................១៦៦
អព្រហ្មចរិយៈនេះមានអង្គ ៤ ...............................................................១៦៨


## មុសាវាទសិក្ខាបទទី៤


មុសាវាទសិក្ខាបទទី ៤.......................................................................១៧២
មុសាវាទសិក្ខាបទមានអង្គ ៤...............................................................១៧៩


## សុរាមេរយសិក្ខាបទទី៥


សុរាមេរយសិក្ខាបទទី៥......................................................................១៨១
សិក្ខាបទនេះមានអង្គ ៤ .....................................................................១៩១


## វិកាលភោជនសិក្ខាបទទី៦


វិកាលភោជនសិក្ខាបទទី៦....................................................................១៩៣
សិក្ខាបទនេះមានអង្គ ៣ .....................................................................២០៣

## នច្ចគីតវាទិតវិសូកទស្សនសិក្ខាបទទី ៧

នច្ចគីតវាទិតវិសូកទស្សនសិក្ខាបទទី ៧.............................................................២០៥
សិក្ខាបទនេះមានអង្គ ៣ ............................................................................២១១

## មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា សិក្ខាបទទី៨

មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា សិក្ខាបទទី៨.............................២១៤
សិក្ខាបទនេះមានអង្គ ៣ ............................................................................២១៨

## ឧច្ចាសយនមហាសយនា សិក្ខាបទទី៩

ឧច្ចាសយនមហាសយនា សិក្ខាបទទី ៩.............................................................២១៩
ទ្រង់អនុញ្ញាតតាំងមាន ៤ យ៉ាង ..................................................................២២២
សិក្ខាបទនេះមានអង្គ ៣ ............................................................................២២៦

## ជាតរូបរជតប្បដិគ្គហណា សិក្ខាបទទី១០

ជាតរូបរជតប្បដិគ្គហណា សិក្ខាបទទី១០........................................................២២៨
សិក្ខាបទនេះមានអង្គ ៣ គឺ.........................................................................២៣៦

## អកុសលកម្មបថ១០

អកុសលកម្មបថ១០.....................................................................................២៤០
កាយកម្ម ៣ យ៉ាង.....................................................................................២៤០
វចីកម្ម ៤ យ៉ាង.......................................................................................២៤១
មនោកម្ម ៣ យ៉ាង.....................................................................................២៤១

## បិសុណាវាចាសិក្ខាបទទី ៥

បិសុណាវាចាសិក្ខាបទទី ៥..........................................................................២៤២

អង្គនៃបិសុណាវាចាមាន ៤ ........................................................................២៤៣
ចែកបិសុណាវាចាដោយអប្បសាវជ្ជៈ និងមហាសាវជ្ជៈ.........................................២៤៥

## ផរុសវាចាសិក្ខាបទទី៦

ផរុសវាចាសិក្ខាបទទី ៦.........................................................................២៤៦
អង្គនៃផរុសវាចាមាន ៣ ........................................................................២៤៧
អក្កោសវត្ថុ ១០.....................................................................................២៤៩
វាចាសម្រាប់ជេរ មាន ១០ យ៉ាង.............................................................២៤៩
ប្រយោគនៃផរុសវាចាមាន ២ យ៉ាង...........................................................២៥១
ចែកផរុសវាចាដោយអប្បសាវជ្ជៈ និងមហាសាវជ្ជៈ..........................................២៥១

## សម្ផប្បលាបសិក្ខាបទទី៧

សម្ផប្បលាបសិក្ខាបទទី៧........................................................................២៥២
អង្គនៃសម្ផប្បលាបមាន ២ យ៉ាង...............................................................២៥៣
សម្ផប្បលាបៈដែលជាអប្បសាវជ្ជៈ និងមហាសាវជ្ជៈ..........................................២៥៧
វាចាមាន ៤ យ៉ាង....................................................................................២៥៨
អធិប្បាយមនោកម្ម ៣...............................................................................២៥៩

## អភិជ្ឈាសិក្ខាបទទី៨

អភិជ្ឈាសិក្ខាបទទី៨...............................................................................២៥៩
លោកៈមាន ២ យ៉ាងគឺ :............................................................................២៥៩
អង្គអភិជ្ឈាមាន ២ យ៉ាង...........................................................................២៦០

## ព្យាបាទសិក្ខាបទទី៩

ព្យាបាទសិក្ខាបទទី៩........................................២៦២
អង្គនៃព្យាបាទមាន ២ យ៉ាង........................................២៦២
ទោសរបស់ព្យាបាទដែលជាមហាសាវជ្ជៈ និងអប្បសាវជ្ជៈ........................................២៦៣

## មិច្ឆាទិដ្ឋិសិក្ខាបទទី១០

មិច្ឆាទិដ្ឋិសិក្ខាបទទី១០........................................២៦៤
អង្គនៃមិច្ឆាទិដ្ឋិមាន ២ យ៉ាង........................................២៦៤
និយតមិច្ឆាទិដ្ឋិមាន ៣ យ៉ាង ........................................២៦៥
សេចក្តីក្នុងនិយតមិច្ឆាទិដ្ឋិនៃទិដ្ឋិទាំង ៣........................................២៧០
អំពីនិយតមិច្ឆាទិដ្ឋិ ៣........................................២៧១
ដែលបានឈ្មោះថាមិច្ឆត្តនិយតៈ........................................២៧១
អំពីការកើតឡើងនៃទុច្ចរិតផ្សេងៗ ដោយអាស្រ័យមនោទុច្ចរិតជាហេតុ........................................២៧៤
អធិប្បាយក្នុងបាលី ៨........................................២៧៤
អំពីឈ្មោះថាទុច្ចរិតផ្សេងៗ ដែលមិនគ្រប់អង្គ........................................២៧៨
អំពីវិធីរាប់ចំនួនទុច្ចរិតដោយពិស្តារ........................................២៨០
ការចែកអកុសលកម្មបថ ១០ ជា ៥ យ៉ាង ពោលដោយអង្គធម៌ជាដើម........................................២៨៦
បញ្ហាកម្មរបស់សីល........................................២៩០
សំវរៈ ៥ យ៉ាង........................................២៩១
អត្ថរបស់សីល........................................២៩២
លក្ខណៈ, រស, បច្ចុប្បដ្ឋាន, បទដ្ឋាន នៃសីល........................................២៩៣
រស របស់សីល........................................២៩៣
បច្ចុប្បដ្ឋាន និងបទដ្ឋាន........................................២៩៤

អានិសង្សរបស់សីល..........២៩៤
ពោលអំពីឧបាសកវគ្គ..........២៩៦
ពោលអំពីបុគ្គលបានជាឧបាសក..........៣០៣
ពោលអំពីអានិសង្សសីល..........៣១៥
ថេរគាថា..........៣២១
ទុស្សីលសូត្រ..........៣៣១
អធិប្បាយព្រះសទ្ធម្ម ៣ យ៉ាង..........៣៣៣
ប្រយោជន៍នៃវិន័យជាដើម..........៣៣៥
ធម៌បួសសម្រាប់សីលវតី គ្នាច្រើន..........៣៣៨
ធម៌បួសសម្រាប់សីលវតី ម្នាក់ឯង..........៣៣៨
ធម៌បួសសម្រាប់សីលវន្ត គ្នាច្រើន..........៣៣៨
ធម៌បួសសម្រាប់សីលវន្ត ម្នាក់ឯង..........៣៣៩
ការសូត្រផ្សាយមេត្តាចិត្ត..........៣៤០

សូម សីលត្ថទីបនី នេះ បានជាប្រយោជន៍ដល់ពុទ្ធបរិស័ទគ្រប់គ្នា

ដែលជាប្រាថ្នាក្នុងព្រះសទ្ធម្ម !

## ចិរំ កម្ពុជរដ្ឋេ តិដ្ឋតុ សទ្ធម្មោ

សូមព្រះសទ្ធម្មតាំងនៅក្នុងកម្ពុរដ្ឋអស់កាលជាយូរអង្វែង !

# បទសរភញ្ញ

សូមថ្វាយបង្គំ-ព្រះសម្ពុទ្ធ　　ប្រសើរបំផុត-ក្នុងលោកា
ជាគ្រូនៃមនុស្ស-និងទេវតា　　ទ្រង់ត្រាស់ទេសនា-ប្រដៅសត្វ
ចង្អុលឲ្យដើរ-ផ្លូវកណ្តាល　　មាគ៌ាត្រៃកាល-អាចកម្ចាត់
ទុក្ខភ័យចង្រៃ-ឲ្យខ្ចាយបាត់　　អាចកាត់សង្សា-រៈទុក្ខបាន ។
សាសនាព្រះអង្គ-នៅសព្វថ្ងៃ　　សត្វមាននិស្ស័យ-ពីបូរាណ
ប្រឹងរៀនប្រឹងស្តាប់-ចេះចាំបាន　　កាន់តាមលម្អាន-បានក្តីសុខ
ឥតមានសុខណា-ស្មើក្តីស្ងប់　　បញ្ចប់ត្រឹមសុខ-ឃ្លាតចាកទុក្ខ
តាំងពីលោកនេះ-តទៅមុខ　　ក្តីសុខនឹងមាន-ព្រោះធម៌ស្ងប់ ។
ខ្ញុំសូមបង្គំ-ឆ្ពោះព្រះធម៌　　ព្រះសង្ឃបវរ-ទាំងគ្រប់សព្វ
រួមជាត្រៃរត្ន-គួរគោរព　　ជាម្ចប់ត្រជាក់-នៃលោកា
ព្រះរូបព្រះធាតុ-នៃព្រះពុទ្ធ　　វិសុទ្ធតាងអង្គ-ព្រះសាស្តា
សូមគុណត្រៃរត្ន-ជួយខេមរា　　ឲ្យបានសុខា-តរៀងទៅ ។

## ធម៌នមស្ការ

## រតនត្តយបូជា

ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ មាតា-បិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ។

*ប្រែថា ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះ{ពុទ្ធ / ធម៌ / សង្ឃ}ជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយមានទៀន និងធូបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយមានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។*

## ពុទ្ធរតនប្បណាម

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

*(សូត្រ ៣ ដង)*

*ប្រែថា រីកិរិយានមស្ការថ្វាយបង្គំ នៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។*

*(ក្រាបថ្វាយបង្គំម្តង)*

យោ សន្និសិន្នោ វរពោធិមូលេ

មារំ សសេនំ មហាតឹ វិជេយ្យា

សម្ពោធិមាគច្ឆិ អនន្តញាណោ

លោកុត្តមោ តំ បណមាមិ ពុទ្ធំ ។

*ប្រែថា* ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើននូវព្រះអានាបានស្សតិកម្មដ្ឋាន
លើរតនបល្ល័ង្កក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជ
ព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ
មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណា
សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

យេ ច ពុទ្ធា អតីតា ច　　　យេ ច ពុទ្ធា អនាគតា

បច្ចុប្បន្នា ច យេ ពុទ្ធា　　　អហំ វន្ទាមិ សព្វទា ។

*ប្រែថា* ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វាន
កន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែល
នឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធ
ទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្ទកប្បនេះក្តី
ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយ
នោះគ្រប់កាលទាំងពួង ។

(ក្រាបថ្វាយបង្គំម្តង)

**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ**[1] ។

*ប្រែថា* **ឥតិបិ សោ ភគវា អរហំ** *ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោល គឺកិលេសព្រមទាំងវាសនា គឺកាយបយោគ និងវចីបយោគ*

**សម្មាសម្ពុទ្ធោ** *ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅ ព្រះអង្គឡើយ*

**វិជ្ជាចរណសម្បន្នោ** *ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ ដោយវិជ្ជា ៣*[2] *និងវិជ្ជា ៨*[3] *និងចរណៈ ១៥*[4]

**សុគតោ** *ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន*

**លោកវិទូ** *ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក*

---

*១. អង្គុត្តរនិកាយ ឆក្កនិបាត ត្រង់អាហុនេយ្យវគ្គ ៤៦/១២, វិសុទ្ធិមគ្គភាគ១/៤៣២*

*២. ម.មូ.២២/២១៧ វិជ្ជា៣ គឺ ១បុព្វេនិវាសានុស្សតិញ្ញាណ ២-ចុតូបបាតញ្ញាណ ៣-អាសវក្ខយញ្ញាណ*

*៣.វិជ្ជា៨ គឺវិជ្ជា ៣ ខាងដើម និងវិបស្សនាញាណ១ មនោមយិទ្ធិ១ ឥទ្ធិវិធិ១ ទិព្វសោត១ ចេតោបរិញ្ញាណ១*

*៤. ម.ម.២៣/៤៣ ចរណៈ១៥ គឺ ១-សីល ២-ជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ៣-ជាអ្នកស្គាល់ប្រមាណក្នុងភោជន ៤-ជាអ្នកប្រកបនូវសេចក្តីភ្ញាក់រឭក ៥-សទ្ធា ៦-ហិរិ ៧-ឱត្តប្បៈ ៨-ពហុសូត្រ ៩-វិរិយៈ ១០-សតិ ១១-បញ្ញា ១២-បឋមជ្ឈាន ១៣-ទុតិយជ្ឈាន ១៤-តតិយជ្ឈាន ១៥-ចតុត្ថជ្ឈាន ។*

**អនុត្តរោ** *ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរ ដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន*

**បុរិសទម្មសារថិ** *ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គ ជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន*

**សត្ថា ទេវមនុស្សានំ** *ទ្រង់ព្រះនាមថា សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ*

**ពុទ្ធោ** *ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញុំាងអ្នកដទៃឲ្យត្រាស់ដឹងផង*

**ភគវា** *ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ចាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។*

*(ក្រាបថ្វាយបង្គំម្តង)*

*រួចហើយត្រូវប្រកាសប្តេជ្ញាខ្លួនចំពោះព្រះពុទ្ធគុណថា៖*

**នត្ថិ មេ សរណំ អញ្ញំ      ពុទ្ធោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន      ហោតុ មេ ជយមង្គលំ។**

*<u>ប្រែថា</u>* **នត្ថិ មេ សរណំ អញ្ញំ** *វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណា មិនមានឡើយ* **ពុទ្ធោ មេ សរណំ វរំ** *មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹងទីរឭកដ៏ប្រសើរបស់ខ្ញុំព្រះករុណា* **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** *សូមសិរីសួស្តីជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។*

*(ក្រាបថ្វាយបង្គំម្តង)*

*រួចហើយត្រូវសូមខមាទោសនឹងព្រះពុទ្ធគុណដូច្នេះថា៖*

**ឧត្តមង្គេន វន្ទេហំ　　　　ចាទបំសុំ វរុត្តមំ**

**ពុទ្ធេ យោ ខលិតោ ទោសោ　　ពុទ្ធោ ខមតុ តំ មមំ ។**

*ប្រែថា* **ឧត្តមង្គេន វន្ទេហំ ចាទបំសុំ វរុត្តមំ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវល្អងធូលីព្រះបាទនៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈដ៏ឧត្តមគឺត្បូង* **ពុទ្ធេ យោ ខលិតោ ទោសោ** *ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់* **ពុទ្ធោ ខមតុ តំ មមំ** *សូមព្រះពុទ្ធជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។*

*(ក្រាបថ្វាយបង្គំម្តង)*

**ធម្មរតនប្បណាម**

អដ្ឋង្គិកាវិយបថោ ជនានំ

មោក្ខប្បវេសាយ ឧជូ ច មគ្គោ

ធម្មោ អយំ សន្តិករោ បណីតោ

និយ្យានិកោ តំ បនមាមិ ធម្មំ ។

*ប្រែថា ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញុំាងជនដែលប្រាថ្នានូវព្រះនិព្វាន ឲ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះ ជាធម៌ធ្វើឲ្យត្រជាក់រម្ងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញុំាងសត្វឲ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះ ដោយគោរព ។*

*(ក្រាបថ្វាយបង្គំម្តង)*

**យេ ច ធម្មា អតីតា ច　　យេ ច ធម្មា អនាគតា**

**បច្ចុប្បន្នា ច យេ ធម្មា　　អហំ វន្ទាមិ សព្វទា ។**

*<u>ប្រែថា</u> ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធដែលនឹងមានមកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះ គ្រប់កាលទាំងពួង ។*

*(ក្រាបថ្វាយបង្គំមួយ)*

***គួរបង្អោនកាយវាចា ហើយតាំងចិត្តរឭកដល់ព្រះធម្មគុណថា៖***

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ**[៥] ។

*<u>ប្រែថា</u>* **ស្វាក្ខាតោ ភគវតា ធម្មោ** *ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌ គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយល្អ*

**ធម្មោ** *ព្រះនព្វលោកុត្តរធម៌មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១*

**សន្ទិដ្ឋិកោ** *ជាធម៌គឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញពិត ដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹង ដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង*

**អកាលិកោ** *ជាធម៌ឲ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គ កើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ*

---

*៥ អង្គុត្តរនិកាយ ឆក្កនិបាត ត្រង់អាហុនេយ្យវគ្គ ៤៦/១៣, វិសុទ្ធិមគ្គភាគ១/៤៦៧*

**ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថា បើព្រះអរិយបុគ្គលដែលបាន សម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន

**ឱបនយិកោ** ជាធម៌គឺព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយ អំណាចនៃភាវនា

**បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គល ជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

(ក្រាបថ្វាយបង្គំម្ដង)

*ប្រកាសប្ដេជ្ញាខ្លួនដោយពាក្យសច្ចៈថា៖*

**នត្ថិ មេ សរណំ អញ្ញំ　　ធម្មោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន　　ហោតុ មេ ជយមង្គលំ។**

<u>ប្រែថា</u> **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណា មិនមាន ឡើយ

**ធម្មោ មេ សរណំ វរំ** មានតែព្រះធម៌ជាម្ចាស់ ជាទីពឹង ទីរឭកដ៏ប្រសើរ របស់ខ្ញុំ ព្រះករុណា

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្ដី ជយមង្គលចូរមាន ដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

(ក្រាបថ្វាយបង្គំម្ដង)

*រួចហើយត្រូវសូមខមាទោសនឹងព្រះធម្មគុណថា៖*

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ**

**ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ ។**

*ប្រែថា* **ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរ មានពីរប្រការ គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តម គឺត្បូង*

**ធម្មេ យោ ខលិតោ ទោសោ** *ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះធម៌ជាម្ចាស់*

**ធម្មោ ខមតុ តំ មមំ** *សូមព្រះធម៌ជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។*

*(ក្រាបថ្វាយបង្គំម្តង)*

## សង្ឃរតនប្បណាម

**សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ**

**សន្តិន្ទ្រិយោ សព្វមលប្បហីនោ**

**គុណេហិនេកេហិ សមិទ្ធិបត្តោ**

**អនាសវោ តំ បណមាមិ សង្ឃំ ។**

*ប្រែថា ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយរម្ងាប់ហើយ មានមន្ទិលគឺរាគាទិក្កិលេសទាំងពួងបន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយនូវកិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះអរិយសង្ឃនោះ ដោយគោរព ។*

*(ក្រាបថ្វាយបង្គំម្តង)*

យេ ច សង្ឃា អតីតា ច   យេ ច សង្ឃា អនាគតា

បច្ចុប្បន្នា ច យេ សង្ឃា    អហំ វន្ទាមិ សព្វទា ។

ប្រែថា ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផលកន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃ នឹងបានសម្រេចមគ្គ និងផលក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផលក្នុងកាលជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយនោះ គ្រប់កាលទាំងពួង។

(ក្រាបថ្វាយបង្គំម្តង)

រួចហើយគប្បីតាំងចិត្តរឭកដល់ព្រះសង្ឃគុណដោយបង្អោនកាយវាចាថា៖

សុបដិបន្នោ  ភគវតោ   សាវកសង្ឃោ

ឧជុបដិបន្នោ  ភគវតោ   សាវកសង្ឃោ

ញាយបដិបន្នោ ភគវតោ  សាវកសង្ឃោ

សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ

**យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិ-ករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ**[៦] ។

*ប្រែថា* **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌*

**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា*

**ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ថានក្សេមផុតចាកទុក្ខទាំងពួង*

**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា*

**យទិទំ ចត្តារិ បុរិសយុគានិ** *ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយមាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផលជាគូ ១ សកទាគាមិមគ្គ និងសកទាគាមិផលជាគូ ១ អនាគាមិមគ្គ និងអនាគាមិផលជាគូ ១ អរហត្តមគ្គ និងអរហត្តផលជាគូ ១*

---

*៦- បិដក៤៦/៦ ភិក្ខុប្រកបដោយធម៌៦ យ៉ាង ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកគួរបូជា។ល។ ជាបុញ្ញក្ខេត្ត ដ៏ប្រសើរបស់សត្វលោក គឺ:១-ភិក្ខុប្រកបដោយសទ្ធិន្ទ្រិយ ២-វីរិយិន្ទ្រិយ ៣-សតិន្ទ្រិយ ៤-សមាធិន្ទ្រិយ ៥-បញ្ញិន្ទ្រិយ ៦-បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។ វិសុទ្ធិមគ្គភាគ១/៤៧៩ ។*

**អដ្ឋ បុរិសបុគ្គលា** *បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺ ព្រះសង្ឃដែលបាន សម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល១ អនាគាមិមគ្គ១ អនាគាមិផល១ អរហត្តមគ្គ១ អរហត្តផល១*

**ឯស ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃទាំងនុ៎ះ ជាសង្ឃសាវ័ក នៃព្រះដ៏មាន ព្រះភាគ*

**អាហុនេយ្យោ** *លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមាន សីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា*

**បាហុនេយ្យោ** *លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែង ដើម្បី ញាតិ និងមិត្រ ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា*

**ទក្ខិណេយ្យោ** *លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្ម និងផលនៃកម្ម ហើយបូជា*

**អញ្ជលិករណីយោ** *លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ*

**អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** *លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យ នៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន ។*

*(ក្រាបថ្វាយបង្គំម្តង)*

*តទៅគប្បីប្រកាសបេ្តជ្ញាខ្លួនចំពោះព្រះសង្ឃគុណថា ៖*

**ឥត្ថិ មេ សរណំ អញ្ញំ　　　សង្ឃោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន　　　　　ហោតុ មេ ជយមង្គលំ ។**

<u>*ប្រែថា*</u> **នត្ថិ មេ សរណំ អញ្ញំ** *វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណា មិនមានឡើយ*

**សង្ឃោ មេ សរណំ វរំ** *មានតែព្រះសង្ឃជាម្ចាស់ ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា*

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** *សូមសិរីសួស្តី ជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។*

*រួចហើយត្រូវសូមខមាទោសនឹងព្រះសង្ឃគុណថា ៖*

**ឧត្តមង្គេន វន្ទេហំ　　សង្ឃញ្ច ទុវិធោត្តមំ**

**សង្ឃេ យោ ខលិតោ ទោសោ　សង្ឃោ ខមតុ តំ មមំ ។**

<u>*ប្រែថា*</u> **ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរ មានពីរប្រការ គឺព្រះសម្មតិសង្ឃ និងព្រះអរិយសង្ឃ ដោយអវយវៈដ៏ឧត្តមគឺត្បូង*

**សង្ឃេ យោ ខលិតោ ទោសោ** *ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះសង្ឃជាម្ចាស់*

**សង្ឃោ ខមតុ តំ មមំ** *សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា។*

*(ក្រាបថ្វាយបង្គំម្តង)*

## បារមីទាំង៣០

**ឥតិបិ ទានបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយទានបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ទានឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយទានឧបបារមី មែនព្រោះហេតុដូច្នេះ។*

**ឥតិបិ ទានបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយទានបរមត្ថបារមី មែនព្រោះហេតុដូច្នេះ។*

**ឥតិបិ សីលបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសីលបារមី មែនព្រោះហេតុដូច្នេះ។*

**ឥតិបិ សីលឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសីលឧបបារមី មែនព្រោះហេតុដូច្នេះ។*

**ឥតិបិ សីលបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសីលបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ នេក្ខម្មបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយនេក្ខម្មបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ នេក្ខម្មឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយនេក្ខម្មឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ នេក្ខម្មបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយនេក្ខម្មបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ បញ្ញាបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយបញ្ញាបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ បញ្ញាឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយបញ្ញាឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ បញ្ញាបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយបញ្ញាបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ វិរិយបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយវិរិយបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ វិរិយឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយវិរិយឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ វិរិយបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយវិរិយបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ខន្តិបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយខន្តីបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ខន្តិឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយខន្តីឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ខន្តិបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយខន្តីបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ សច្ចុចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសច្ចបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ សច្ចុឧបចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសច្ចឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ សច្ចុបរមត្ថចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសច្ចបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ អធិដ្ឋានចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយអធិដ្ឋានបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ អធិដ្ឋានឧបចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយអធិដ្ឋានឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ អធិដ្ឋានបរមត្ថចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគ-អង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយអធិដ្ឋានបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ មេត្តាចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយមេត្តាបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ មេត្តាឧបចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយមេត្តាឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ មេត្តាបរមត្ថចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយមេត្តាបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ឧបេក្ខាចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយឧបេក្ខាបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ឧបេក្ខាឧបចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយឧបេក្ខាឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ឧបេក្ខាបរមត្ថចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយឧបេក្ខាបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ទសចារមិសម្បន្នោ ទសឧបចារមិសម្បន្នោ ទសបរមត្ថចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបារមី១០ បរិបូណ៌ហើយ ដោយឧបបារមី១០ បរិបូណ៌ហើយដោយបរមត្ថបារមី១០ មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ សមត្តឹសចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបារមីទាំង៣០ មែនព្រោះហេតុដូច្នេះ ។*

## ធាតុចេតិយនមក្ការគាថា

១. មហាគោតមោ ជិនវរោ កុសិនារម្ហិ និព្វុតោ
ធាតុវិត្ថារិកំ អាសិ តេសុ តេសុ បទេសតោ។

*ខ្ញុំសូមបង្គំ ប្រណម្យអភិវាទ សារីរិកធាតុ ព្រះមហាគោតម*
*ដែលទ្រង់និព្វាន ក្រោមសាលព្រឹក្សធំ ជិតបុរីរម្យ ក្រុងកុសិនារា ។*
*កិរិយាផ្សាយនូវ ព្រះធាតុនានា ផ្សេងៗពីគ្នា ក្នុងទីទាំងឡាយ*
*ខ្ញុំសូមបង្គំ ប្រណម្យក្រាបថ្វាយ ព្រះធាតុទាំងឡាយ គ្រប់ទីនោះៗ ។*

២. ឧណ្ហីសំ ចតស្សោ ទាឋា អក្ខកា ទ្វេ ច ធាតុយោ
អសម្ភិន្នា ឥមា សត្ត សេសា ភិន្នា វ ធាតុយោ ។

*ព្រះសារីរិកធាតុ ល្អស្អាតទាំងឡាយ ដែលមិនបែកសោះ ប្រាំពីរព្រះអង្គ*
*គឺព្រះឧណ្ហី- សធាតុបញ្ចុង(១) មានមួយព្រះអង្គ នៅគង់ល្អស្អាត*
*និងព្រះទាឋា(២) សារីរិកធាតុ ទាំង៤ អង្គស្អាត គ្មានឃ្លាតបែកចេញ*
*ព្រះអក្ខកធាតុ(៣) នៅស្អាតពេញលេញ គ្មានបែកបាក់ចេញ ទាំងពីរព្រះអង្គ*
*ព្រះសារីរិកធាតុ ភ្លឺស្អាតត្រចង់ ប្រាំពីរព្រះអង្គ គង់នៅទាំងអស់*
*ព្រះសារីរិកធាតុ ដ៏សេសពីនោះ បែកចេញចំពោះ ចំណែកធំតូច ។*

៣. មហន្តា មុគ្គមត្តា[៤] ច មជ្ឈិមា ភិន្នតណ្ឌុលា
ខុទ្ទកា សាសបមត្តា ច នានាវណ្ណា ច ធាតុយោ ។

*ឯព្រះបរមធាតុ មានខ្នាតបីយ៉ាង លោកបានពោលអាង ទុកជាលំដាប់*
*ព្រះធាតុខ្នាតធំ ទំហំប៉ុនគ្រាប់ សណ្តែកបាយកាប់ កាត់មួយកំណាត់*
*ព្រះធាតុកណ្តាល ដូចកាលគេកាត់ ប៉ុនមួយកំណាត់ នៃគ្រាប់អង្ករ*
*ព្រះធាតុខ្នាតតូច ល្អិតល្អបវរ លោកបានព្យាករ ថាប៉ុនគ្រាប់ស្ពៃ ។*

៤. មហន្តា សុវណ្ណវណ្ណា ច មុត្តវណ្ណា ច មជ្ឈិមា
ខុទ្ទកា មកុលវណ្ណា ច សោឡស ទោណមត្តិកា ។

*ព្រះសារីរិកធាតុ នៃព្រះភគវា មានពណ៌ផ្សេងគ្នា ទាំងបីវិលាស*
*ព្រះធាតុខ្នាតធំ មានពណ៌ដូចមាស ពន្លឺឱភាស វិសេសពេកក្លាត់ ។*
*ព្រះធាតុកណ្តាល វិលាសដូចរ័តន៍ មុក្តាប្រាកដ ស្មើរចាប់ប្រឡំ*
*ព្រះធាតុខ្នាតតូច ដូចផ្កាម្ទេះសម ពណ៌សស្រគាំ ក្រពុំស្រស់ស្អាត*

---

*១- ឆ្អឹងថ្ងាស ។ ២- ព្រះចង្កូមកែវ ។ ៣- ឆ្អឹងដងកាំបិត ។ (៤) កន្លែងខ្លះ មុគ្គមាសាវ. ខ្លះថា ភិន្នមុត្តា ។*

សរុបព្រះធាតុ  នៃព្រះសាស្តា  លោកបានពោលថា  បើគិតតាមខ្នាត
ដប់ប្រាំមួយនាឡិ  មិនបាត់បង់ខាត  បែងចែកជាខ្នាត  ចំនួនមួយទោណ ។

## ៥. មហន្តា បញ្ច នាឡិយោ  នាឡិយោ បញ្ច មជ្ឈិមា
## ខុទ្ទកា ឆ នាឡី ចេវ  ឯតា សព្វាបិ ធាតុយោ ។

ព្រះបរមធាតុ  មុនីនាថសាស្តា  ទាំងអស់នោះណា  បែកជាតូចធំ
លោកបានពោលទុក  ថាមានទំហំ  មានតូចមានធំ  មានខ្នាតកណ្តាល ។
ព្រះធាតុខ្នាតធំ  ចំនួនប្រាំនាឡិ  ព្រះធាតុកណ្តាល  ប្រាំនាឡិប្រាកដ
ព្រះធាតុខ្នាតតូច  ប្រាំមួយនាឡិគត់  តាមលោកកំណត់  បីយ៉ាងដូច្នេះ ។

## ៦. អហំ វន្ទាមិ ទូរតោ

ខ្ញុំសូមលើកហត្ថ ផ្គងនមស្ការ  ព្រះធាតុនោះណា អំពីចម្ងាយ
ឧណ្ហីសាក្ខកធាតុទាំងឡាយ  ប្រណម្យដោយកាយ និងវាចាចិត្ត ។
ព្រះទាឋធាតុ និងធាតុដទៃ  នៃព្រះជិនស្រី ស្ថិតនៅឆ្ងាយជិត
ខ្ញុំសូមនមស្ការ ដោយត្បូងខ្ញុំពិត  ផ្តោះព្រះវិជិត- មារនោះហោង ។

### នមស្ការស្នាមព្រះពុទ្ធបាទ

វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ
តិលោកកេតុំ តិភវេកនាថំ
យោ លោកសេដ្ឋោ សកលំ កិលេសំ
ជេត្វាន ពោធេសិ ជនំ អនន្តំ ។

ព្រះសម្មាសម្ពុទ្ធឯណា ព្រះអង្គប្រសើរក្នុងលោក ទ្រង់កាត់បង់នូវ
កិលេសទាំងអស់បានហើយ ញុំាងជនជាអនន្តឲ្យត្រាស់ដឹងហើយ

*ខ្ញុំសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គឆ្លងផុតអំពីប្រាំងនៃកតពហើយ ព្រះអង្គជាទង់ជ័យនៃត្រៃលោក មានតែព្រះអង្គមួយ ជាទីពឹងនៃសព្វសត្វក្នុងត្រៃភព ។*

**យំ នម្មទាយ នទិយា បុលិនេ ច តីរេ**

**យំ សច្ចពន្ធគិរិកេ សុមនាចលគ្គេ**

**យំ តត្ថ យោនកបុរេ មុនិនោ ច ចាទំ**

**តំ ចាទលញ្ឆនមហំ សិរសា នមាមិ ។**

*ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើផ្ទូរខ្សាច់ទៀបឆ្នេរនៃស្ទឹងឈ្មោះនម្មទា ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុក) លើភ្នំសច្ចពន្ធ និងលើភ្នំសុមនកូដ ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) ក្នុងយោនកបុរី ខ្ញុំសូមក្រាបថ្វាយបង្គំ ដោយត្បូង ចំពោះទៅព្រះបាទនិងស្នាមព្រះបាទទាំងនោះនៃព្រះសក្យមុនី ។*

**សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ យោនកបុរេ នម្មទាយ នទិយា បញ្ច ចាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ ។**

*ខ្ញុំសូមនមស្ការអំពីចម្ងាយនូវស្ថានដែលមានព្រះបាទដ៏ប្រសើរ៥ កន្លែង គឺ:*

*១-ស្ថានលើភ្នំសុវណ្ណមាលិក:*

*២-លើភ្នំសុវណ្ណបព៌ត*

*៣-លើភ្នំសុមនកូដ*

*៤-ក្នុងយោនកបុរី*

*៥-ក្បែរស្ទឹងនម្មទា ។*

## មហាបុរិសលក្ខណៈ ៣២ ប្រការ

១. យោ បុព្វេ កតបុញ្ញត្តា សុប្បតិដ្ឋិតបាទកោ
ចក្កង្កិតបទោ ទីឃ- បណ្ហិអង្គុលិព្រហ្មុជុ ។

*ព្រះមហាមុនីព្រះអង្គទ្រង់បំពេញបុណ្យក្នុងកាលមុន ទើប
មានផ្ទៃព្រះបាទទាំងគូរាបស្មើល្អ ប្រដាប់ដោយចក្រ កែង
ព្រះបាទវែង ម្រាមព្រះហស្តវែង និងម្រាមព្រះបាទវែង
ព្រះកាយត្រង់ដូចជាកាយនៃព្រហ្ម ។*

២. សត្តុស្សទោ មុទុតលុ- ណជាលហត្ថបាទកោ
ឧស្សង្ខុបាទគ្គលោមោ ចេ- ណិជង្ឃោ សុខុមច្ឆវិ ។

*មានព្រះមំសៈគឺសាច់ ៧ អន្លើដោយបរិបូណ៌ (គឺខ្នងព្រះ
ហស្ត ២, ខ្នងព្រះបាទ ២, ព្រះអង្សា ២, ព្រះសូរង ១)
ផ្ទៃព្រះហស្តនិងផ្ទៃព្រះបាទដ៏ទន់ល្មើយ មានប្រទាក់ក្រឡា
ដូចជាសំណាញ់ មានព្រះបាទដូចជាអណ្តែតឡើងខាងលើ
មានព្រះលោមាមានចុង-ងឡើងលើ មានព្រះជង្ឃាគឺស្មង
រៀវមូលត្រសូល មានព្រះឆវីល្អិតផូរផង់រលីងស្រិល ។*

៣. សុវណ្ណវណ្ណោ កោសម្ហិ ឱហិតវត្ថគុយ្ហកោ
និគ្រោធបរិមណ្ឌល- ដ្ឋិតជានុបរាមាសោ ។

*មានស្បែកសម្បុរថ្លៃ (លឿងភ្លឺអន្ទង់) ដូចជាសម្បុរនៃមាស
មានព្រះអង្គាវយវៈដែលត្រូវលាក់កំបាំងដោយសំពត់ស្ថិត
នៅក្នុងស្រោម មានទ្រង់ទ្រាយព្រះកាយ ដូចជាបរិមណ្ឌល
នៃដើមជ្រៃ កាលបើទ្រង់ឈរ មិនបាច់ឱនព្រះអង្គចុះ អាច
ស្ទាបអង្អែលព្រះជានុបាន ។*

៤.សីហកាយ-ចិតន្តរំស- សមវដ្ដខន្ធកោ
រសគ្គសគ្គី នីលនេត្ត- គោបខុមោណ្ណ្ហីសសីសកោ។

*មានព្រះកាយពាក់កណ្ដាលខាងលើ ដូចជាកាយនៃរាជសីហ៍ មានព្រះបិដ្ឋិ គឺខ្នងដ៏ពេញបរិបូណ៌ មានព្រះស្ធមូលសម មានព្រះប្រសាទ គឺសរសៃល្អិតឆ្មារដ៏លើសលែង សម្រាប់ទទួលរសអាហារ មានព្រះនេត្រខៀវស្រស់ មានដួងព្រះនេត្រដូចជាភ្នែកនៃកូនគោ មានព្រះសិរ្ស ហាក់ដូចជាប្រដាប់ដោយក្បាំងមកុដស្រេចស្រាប់ ។*

៥.ឯកេកលោមឧណ្ណ្ហី ច តាលីសាវិរឡទន្តកោ
បហូតជិវ្ហាព្រហ្មស្សរោ ហោតិ សីហហនុបិ ច ។

*មានព្រះលោមាតែ ១ សរសៃ ៗ គឺក្នុងរណ្ដៅរោម ១ មាន រោម ១ មានព្រះឧណ្ណាលោម គឺរោមប្រជុំចិញ្ចើម មានពណ៌សក្បុស មានព្រះទន្ត ៤០ គត់ មានព្រះជិវ្ហាដ៏ធំវែង មានព្រះសូរស័ព្ទ ដូចជាសំឡេងនៃព្រហ្មមានព្រះហនុកា ដូចជាចង្កានៃរាជសីហ៍ ។*

៦.សមទន្តសុក្កទាឋោ ឥតិ ទ្វត្តឹសលក្ខណោ
តំ មុនិន្ទំ មហាបុញ្ញំ វន្ទាមិ បុរិសុត្តមំ ។

*មានព្រះទន្តជិតស្និទ្ធល្អ មានព្រះទាឋា គឺចង្កូមកែវទាំង ៤ សស្អាត ព្រះសម្ពុទ្ធទ្រង់មានបុរិសលក្ខណៈ ៣២ ប្រការ យ៉ាងនេះ ខ្ញុំសូមនមស្ការនូវព្រះសម្ពុទ្ធ ដែលជាធំជាងអ្នកប្រាជ្ញ ដែលជាអ្នកមានបុណ្យដ៏ធំ ជាបុរសដ៏ឧត្តម ។*

## បាទវន្ទនា

## នមស្ការស្នាមព្រះបាទ

## ដែលប្រដាប់ដោយមង្គល ១០៨

**បាទេសុ យស្ស ជាតានិ ទ្វេ ចក្កានិ សកម្មតោ**

**នានាការេហិ បុណ្ណានិ វន្ទេ តំ បុរិសុត្តមំ ។**

*កងចក្កទាំងឡាយពីរ ដែលបរិបូណ៌ដោយលក្ខណៈផ្សេងៗ ប្រាកដ ហើយដោយកម្មរបស់ខ្លួន ក្នុងស្នាមព្រះបាទរបស់ព្រះមហាបុរស អង្គណា ខ្ញុំព្រះករុណាសូមនមស្ការនូវមហាបុរសអង្គនោះ ។*

**សត្តិ ច សិរិវច្ឆោ ច នន្ទិយាវដ្ដមេវ ច**

**សោវត្ថិកោ វដំសោ ច វឌ្ឍមានញ្ច បីឋកំ ។**

*រូបលំពែង រូបផ្ទះកំពូល រូបផ្កាចន្ទ រូបសវត្ថិកៈ រូបផ្កាឈើក្រង លើសីសៈ រូបថាសដាក់គ្រឿងសំណែន រូបតាំងមាស ។*

**អង្កុសញ្ច បាសាទោ តោរណំ ឆត្តមេវ ច**

**ខគ្គោ ច តាលវណ្ដញ្ច មោរហត្ថកវីជនី ។**

*រូបកង្វេរ រូបប្រាសាទ រូបសសរបង្គោល រូបឆត្រ រូបព្រះខ័ន រូបផ្លិតស្លឹកត្នោត រូបផ្លិតកន្ទុយក្ងោក ។*

**ឧណ្ហីសំ មណិ បត្តញ្ច ទាមំ នីលុប្បលំ តថា**

**រត្តសេតុប្បលញ្ចេវ បទុមំ បុណ្ឌរិកំ តថា ។**

*រូបក្បាំង រូបកែវមណី រូបបាត្រ រូបក្លួងផ្កាឈើ រូបព្រលឹតខៀវ រូបព្រលឹតក្រហម រូបព្រលឹតស រូបផ្កាឈូកក្រហម រូបផ្កាឈូកស ។*

**បុណ្ណឃដោ បុណ្ណបាតិ　　សមុទ្ទោ ចក្កវាឡកំ**

**ហិមវា សិនេរុ ចេវ　　សុរិយោ ចន្ទិមា តថា ។**

*រូបឆ្នាំងដាក់ទឹកពេញ រូបថាសដាក់ទឹកពេញ រូបមហាសមុទ្រ*
*រូបភ្នំចក្កវាឡ រូបភ្នំហិមពាន្ត រូបភ្នំសិនេរុ រូបព្រះអាទិត្យ រូបព្រះចន្ទ ។*

**នក្ខត្តា ចតុរោ ទីបា　　ទ្វិសហស្សបរិត្តកា**

**ចក្កវត្តិ សេតសង្ខោ　　មច្ឆានំ យុគឡំ តថា ។**

*រូបផ្កាយនក្ខត្តឫក្ស រូបទ្វីបធំទាំង ៤ និងរូបទ្វីបតូច ២,០០០*
*រូបស្តេចចក្រពត្តិ រូបស័ង្ខស រូបត្រីគូ ។*

**ចក្កំ សត្ត មហាគង្គា　　មហាសេលា មហាសរា**

**សុបណ្ណកោ សុសុមារោ　　ធជោ បដាកមេវ ច ។**

*រូបកងចក្ក រូបស្ទឹងធំ ៧ ខ្សែ រូបភ្នំទាំង ៧ រូបស្រះធំទាំង ៧ រូប*
*ស្តេចគ្រុឌ រូបក្រពើ រូបទង់ជ័យ រូបទង់ជ្រុង ។*

**បាដង្គី វាលវីជនី　　កេលាសបព្វតោ តថា**

**សីហរាជា ព្យគ្ឃរាជា　　វលាហោ ច ឧបោសថោ ។**

*រូបវហ៍ រូបផ្លិតកន្ទុយចាមរី រូបភ្នំកៃលាស រូបស្តេចរាជសីហ៍ រូប*
*ស្តេចខ្លាធំ រូបស្តេចសេះវលាហកៈ រូបស្តេចដំរីឧបោសថ ។*

**វាសុកី នាគរាជា ច　　ហំសោ ច ឧសភោ តថា**

**ឯរាវណោ មករោ ច　　ហរិនាវា ចតុម្មុខា ។**

*រូបស្តេចនាគវាសុកី រូបស្តេចហង្ស រូបស្តេចគោឧសភ រូបដំរីឯរាវណ៍*
*រូបមករ រូបសំពៅមាសមុខបួន ។*

សវច្ចកា តថា តាវី　　កិន្នរោ កិន្នរីបិ ច

ករវីកោ មយូរោ ច　　កោញ្ចរាជា តថេវ ច ។

*រូបមេគោជោះ រូបកិន្នរ រូបកិន្នរី រូបសត្វករវិក រូបស្តេចសត្វក្ងោក*
*រូបស្តេចសត្វគ្រៀល ។*

ចក្កវាកនិជោ ចេវ　　ជីវញ្ជីវកនាមកោ

ច កាមាវចរា ទេវា　　ព្រហ្មលោកា ច សោឡស។

*រូបស្តេចសត្វចក្រពាក រូបស្តេចសត្វព្រហីត រូបទេវលោក ៦ ជាន់*
*រូបព្រហ្មលោក ១៦ ជាន់ ។*

ឯតានដ្ឋុត្តរសតំ　　លក្ខណានិ មហេសិនោ

ចាទេសុ យស្ស ទិស្សន្តេ　　វន្ទេ តំ បុរិសុត្តមំ ។

*លក្ខណៈ ១០៨ ទាំងនេះ រមែងប្រាកដក្នុងស្នាមព្រះបាទរបស់*
*ព្រះពុទ្ធអង្គណា ខ្ញុំសូមនមស្ការនូវព្រះពុទ្ធដែលជាបុរសដ៏ឧត្តមអង្គនោះ ។*

## សច្ចកិរិយាខាងក្រោយធ្វើបទនមស្ការ

នមក្ការានុភាវេន　　ហន្ត្វា សព្វេ ឧបទ្ទវា

អនេកា អន្តរាយាបិ　　វិនស្សន្តុ អសេសតោ ។

*ដោយអានុភាពនៃកិរិយានមស្ការថ្វាយបង្គំ សូមឲ្យកម្ចាត់បង់នូវឧបទ្រព*
*ទាំងឡាយទាំងពួង ទាំងសេចក្តីអន្តរាយទាំងឡាយជាអនេក*
*ក៏ចូលឲ្យវិនាសទៅ កុំបីមានសេសសល់ឡើយ ។*

**ធម៌នមស្ការដោយសង្ខេបចប់**

## ប្រកាសដោយសេចក្ដីឧបមា

ឥឡូវនេះ នឹងពោលអធិប្បាយពាក្យដែលពោលប្រកាសព្រះរតនត្រ័យនោះ ដោយសេចក្ដីឧបមាទាំងឡាយ ក៏ក្នុងពាក្យនោះ **ព្រះពុទ្ធ** ប្រៀបដូចព្រះច័ន្ទពេញបូណ៌មី **ព្រះធម៌** ប្រៀបដូចរង្វង់រស្មីរបស់ព្រះច័ន្ទ **ព្រះសង្ឃ** ប្រៀបដូចលោកដែលក្ដីចិញ្ចាច ដោយរស្មីរបស់ព្រះច័ន្ទពេញបូណ៌មីដែលធ្វើឲ្យកើតឡើង **ព្រះពុទ្ធ** ប្រៀបដូចព្រះអាទិត្យមានពន្លឺដ៏ស្រទន់ **ព្រះធម៌** ប្រៀបដូចខ្សែរស្មីរបស់ព្រះអាទិត្យនោះ **ព្រះសង្ឃ** ប្រៀបដូចលោកដែលព្រះអាទិត្យកម្ចាត់ងងឹតហើយ ។ **ព្រះពុទ្ធ** ប្រៀបដូចមនុស្សដុតព្រៃ **ព្រះធម៌** ជាគ្រឿងដុតព្រៃគឺកិលេស ប្រៀបដូចភ្លើងឆេះព្រៃ **ព្រះសង្ឃ** ដែលជាបុញ្ញក្ខេត្ត ព្រោះដុតកិលេសអស់ហើយ ប្រៀបដូចភូមិភាគ ដែលជាខេត្តស្រែព្រោះដុតព្រៃអស់ហើយ ។ **ព្រះពុទ្ធ** ប្រៀបដូចភ្លៀងធំធ្លាក់ **ព្រះធម៌** ប្រៀបដូចទឹកភ្លៀង **ព្រះសង្ឃ** អ្នករំងាប់លម្អងកិលេស ប្រៀបដូចជនបទដែលរំងាប់លម្អងធូលី ព្រោះទឹកភ្លៀងធ្លាក់ ។ **ព្រះពុទ្ធ** ប្រៀបដូចសារថីដ៏ល្អ **ព្រះធម៌** ប្រៀបដូចឧបាយហ្វឹកហាត់សេះអាជានេយ្យ **ព្រះសង្ឃ** ប្រៀបដូចហ្វូងសេះអាជានេយ្យ ដែលហ្វឹកហាត់មកល្អហើយ ។ **ព្រះពុទ្ធ** ប្រៀបដូចសាលពេទ្យ (ពេទ្យវះកាត់) ព្រោះព្រះអង្គដកកូនសរគឺទិដ្ឋិអស់ហើយ **ព្រះធម៌** ប្រៀបដូចឧបាយដែលដកកូនសរចេញបាន **ព្រះសង្ឃ** ប្រៀបដូចអ្នកដកកូនសរគឺទិដ្ឋិចេញហើយ ប្រៀបដូចជនដែលត្រូវដកកូនសចេញហើយ ។ ម្យ៉ាងទៀត **ព្រះពុទ្ធ** ប្រៀបដូចចក្ខុពេទ្យ ព្រោះព្រះអង្គទ្រង់បកនូវភ្នែក គឺមោហៈចេញបានហើយ **ព្រះធម៌** ប្រៀបដូចឧបាយជាគ្រឿងបកនូវភ្នែក គឺមោហៈ **ព្រះសង្ឃ** អ្នកមានផ្ទៃភ្នែកបកហើយ អ្នកមានដួងភ្នែកគឺញាណ ដែលថ្លាស្អាត ប្រៀបដូចជនដែលបកផ្ទៃភ្នែកមានដួងភ្នែកថ្លាស្អាត ។ ម្យ៉ាងទៀត **ព្រះពុទ្ធ** ប្រៀបដូចពេទ្យដ៏ឆ្លាតព្រោះព្រះអង្គអាចកម្ចាត់ព្យាធិគឺកិលេសព្រមទាំងអនុស័យចេញបាន **ព្រះធម៌** ប្រៀបដូចថ្នាំដែលផ្សំត្រូវហើយ **ព្រះសង្ឃ** អ្នកមានព្យាធិគឺកិលេស និងអនុស័យដែលរំងាប់ហើយ ប្រៀបដូចពួកជនដែលព្យាធិរំងាប់ហើយ ព្រោះប្រកបដោយថ្នាំ ។ ម្យ៉ាងទៀត **ព្រះពុទ្ធ** ប្រៀបដូចអ្នកចង្អុលបង្ហាញផ្លូវ **ព្រះធម៌** ប្រៀបដូចផ្លូវល្អ ឬទីរួចផុតចាកភ័យ **ព្រះសង្ឃ**

ប្រៀបដូចអ្នកដើរផ្លូវ ដល់កន្លែងដែលរួចផុតចាកភ័យ **ព្រះពុទ្ធ** ប្រៀបដូចនាយទូកដ៏ល្អ **ព្រះធម៌** ប្រៀបដូចទូក **ព្រះសង្ឃ** ប្រៀបដូចជនអ្នកដើរដល់ច្រាំង ។ **ព្រះពុទ្ធ** ប្រៀបដូចព្រៃហេមពាន្ត **ព្រះធម៌** ប្រៀបដូចឱសថថ្នាំដែលកើតអំពីព្រៃហេមពាន្ត **ព្រះសង្ឃ** ប្រៀបដូចជនមិនមានរោគព្រោះប្រើថ្នាំ ។ **ព្រះពុទ្ធ** ប្រៀបដូចអ្នកប្រទានទ្រព្យ **ព្រះធម៌** ប្រៀបដូចទ្រព្យ **ព្រះសង្ឃ** អ្នកបានអរិយទ្រព្យដោយប្រពៃ ប្រៀបដូចជនអ្នកបានទ្រព្យតាមដែលប្រាថ្នា ។ **ព្រះពុទ្ធ** ប្រៀបដូចអ្នកបង្ហាញរណ្តៅទ្រព្យ **ព្រះធម៌** ប្រៀបដូចរណ្តៅទ្រព្យ **ព្រះសង្ឃ** ប្រៀបដូចជនអ្នកបានរណ្តៅទ្រព្យ ។

ម្យ៉ាងទៀត **ព្រះពុទ្ធ** ជាវីរបុរស ប្រៀបដូចអ្នកប្រទានអភ័យ **ព្រះធម៌** ប្រៀបដូចមិនមានភ័យ **ព្រះសង្ឃ** អ្នកកន្លងភ័យគ្រប់យ៉ាង ប្រៀបដូចជនអ្នកមិនមានភ័យ **ព្រះពុទ្ធ** ប្រៀបដូចជាមិត្តល្អ **ព្រះធម៌** ប្រៀបដូចពាក្យប្រៀនប្រដៅដែលមានប្រយោជន៍ **ព្រះសង្ឃ** ប្រៀបដូចជនអ្នកប្រសព្វប្រយោជន៍ ដល់ខ្លួនព្រោះប្រកបដោយប្រយោជន៍ **ព្រះពុទ្ធ** ប្រៀបដូចបឹងកើតទ្រព្យ **ព្រះធម៌** ប្រៀបដូចទ្រព្យដែលមានសារៈ **ព្រះសង្ឃ** ប្រៀបដូចជាអ្នកប្រើទ្រព្យដែលជាសារៈ **ព្រះពុទ្ធ** ប្រៀបដូចអ្នកងូតទឹកឲ្យរាជកុមារ **ព្រះធម៌** ប្រៀបដូចទឹកដែលងូតរហូតសីសៈ **ព្រះសង្ឃ** អ្នកងូតទឹកល្អហើយដោយទឹកគឺព្រះសទ្ធម្ម ប្រៀបដូចពួករាជកុមារងូតទឹកល្អហើយ ។ **ព្រះពុទ្ធ** ប្រៀបដូចអ្នកធ្វើគ្រឿងប្រដាប់ **ព្រះធម៌** ប្រៀបដូចគ្រឿងប្រដាប់ **ព្រះសង្ឃ** អ្នកប្រដាប់ដោយព្រះសទ្ធម្ម ប្រៀបដូចពួករាជឱរសដែលទ្រទ្រង់ប្រដាប់ហើយ ។ **ព្រះពុទ្ធ** ប្រៀបដូចដើមច័ន្ទន៍ **ព្រះធម៌** ប្រៀបដូចក្លិនដែលកើតអំពីដើមច័ន្ទន៍នោះ **ព្រះសង្ឃ** អ្នករំងាប់សេចក្តីក្តៅបានអស់ហើយ ព្រោះឧបភោគប្រើព្រះសទ្ធម្ម ប្រៀបដូចជនអ្នកប្រដាប់គ្រឿងតាក់តែងកាយរំងាប់សេចក្តីក្តៅ ព្រោះប្រើខ្លឹមច័ន្ទន៍ ។ **ព្រះពុទ្ធ** ប្រៀបដូចបិតាប្រគល់ទឹកអម្រឹតដោយធម៌ **ព្រះធម៌** ប្រៀបដូចទឹកអម្រឹត **ព្រះសង្ឃ** អ្នកបន្តទឹកអម្រឹតគឺព្រះសទ្ធម្ម ប្រៀបដូចពួកបុត្រអ្នកបន្តទឹកអម្រឹត ។ **ព្រះពុទ្ធ** ប្រៀបដូចផ្កាបទុមដែលរីក **ព្រះធម៌** ប្រៀបដូចទឹកដមដែលកើតអំពីផ្កាបទុមដែលរីកនោះ **ព្រះសង្ឃ** ប្រៀប

*ដូចពួកកូមារ ដែលជញ្ជក់ទឹកដមនោះ ។ គប្បីប្រកាសព្រះរតនត្រ័យនោះ ដោយសេចក្ដីឧបមាទាំងឡាយដូចពោលមកនេះឯង ។*

*ចាកអំពី បរមត្ថជោតិកា អដ្ឋកថាខុទ្ទកនិកាយ ខុទ្ទកបាឋៈ*

## វិធីសមាទាននិច្ចសីល

*ពុទ្ធសាសនិកជនដែលបានដល់ព្រះត្រៃសរណគមន៍ បានឡើងនាមបញ្ញត្តិ ជាឧបាសក ឬឧបាសិកាហើយ កាលបើនឹងសមាទាននូវនិច្ចសីល គឺសីល ៥ ជា* **បច្ចេកសមាទាន** *អំពីបុគ្គលដទៃ គឺភិក្ខុឬសាមណេរនោះ គប្បីសូធ្យនមស្ការថ្វាយបង្គំ រឭកដល់គុណព្រះរតនត្រ័យ ដោយសង្ខេបជាមុន រួចហើយត្រូវសូមនូវនិច្ចសីល ព្រមទាំងព្រះត្រៃ-សរណគមន៍ចំពោះនឹងភិក្ខុឬសាមណេរ ដែលខ្លួននឹងសមាទានដូច្នេះថា ៖*

ឱកាស { អហំ / មយំ } ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច

សីលានិ { យាចាមិ / យាចាម } ទុតិយម្បិ { អហំ / មយំ } ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ

តិសរណេន សហ បញ្ច សីលានិ { យាចាមិ / យាចាម } តតិយម្បិ { អហំ / មយំ } ភន្តេ

វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ { យាចាមិ ។ / យាចាម ។ }

*<u>ប្រែថា</u> សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ ។ សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយសូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង ។ ឬនឹងសូមថា ៖*

ឱកាស { អហំ / មយំ } ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ

បញ្ចង្គសមន្នាគតំ និច្ចសីលំ { យាចាមិ / យាចាម } អនុគ្គហំ កត្វា សីលំ ទេថ

{មេ / នោ} ភន្តេ, ទុតិយម្បិ {អហំ / មយំ} ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន

សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ {យាចាមិ / យាចាម} អនុគ្គហំ កត្វា សីលំ ទេថ

{មេ / នោ} ភន្តេ, តតិយម្បិ {អហំ / មយំ} ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន

សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ {យាចាមិ ។ / យាចាម ។}

*<u>ប្រែថា</u> សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ។ សូមនូវនិច្ចសីល ប្រកបព្រមដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះឲ្យនូវសីលដល់ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ ។ សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះឲ្យនូវសីលដល់ ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ, ។*

*(សូមដូច្នេះក៏បាន តាមសេចក្តីពេញចិត្តរបស់អ្នកសូម)។*

បើអ្នកសមាទានតែម្នាក់ត្រូវថា **អហំ** ថា **យាចាមិ** ត្រង់ប្រែ ត្រូវថា "ខ្ញុំព្រះករុណា" សូមថា **មេ** ត្រង់ប្រែ ត្រូវថា "ដល់ខ្ញុំព្រះករុណា" បើគ្នាច្រើនតាំងពី ពីរនាក់ឡើងទៅ **មយំ** ថា **យាចាម** ក៏បាន ត្រង់ប្រែ ត្រូវថា "ខ្ញុំព្រះករុណាទាំងឡាយ" សូមថា **នោ** ត្រង់ប្រែ ត្រូវថា "ដល់ខ្ញុំព្រះករុណាទាំងឡាយ" តែថាបើគ្នាច្រើនហើយ សូធ្យសូមព្រមគ្នានោះ នឹងសូធ្យសូមថា **អហំ** ថា **យាចាមិ** ថា **មេ** ក៏បាន ព្រោះសូធ្យសូមទាំងអស់គ្នា លុះសូមដូច្នេះរួចហើយ លោកអ្នកឲ្យសីល លោកសូធ្យ **នមោ ៣** ចប់ ហើយលោកឲ្យព្រះត្រៃ-សរណគមន៍ និងនិច្ចសីល អ្នកសមាទាន ត្រូវទទួលថាតាមលោក ដោយបញ្ចេញវចីភេទឲ្យច្បាស់លាស់ កុំទទួលខ្សឹបៗ ។

លោកសូធ្យថា: **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។**

(ត្រូវសូធ្យ ៣ ដង)

<u>ប្រែថា</u> រីកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

**ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរឭក ។

**ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹងទីរឭក ។

**សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ។

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។*

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។*

**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរឭក ជាគម្រប់បីដងផង ។*

**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹងទីរឭក ជាគម្រប់បីដងផង ។*

**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹងទីរឭក ជាគម្រប់បីដងផង ។*

***ហើយលោកពោលថា ៖***

**តិសរណគ្គហណំ បរិបុណ្ណំ ។**

*ប្រែថា កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍បរិបូណ៌តែប៉ុណ្ណោះ ។*

***ឧបាសក និងឧបាសិកាត្រូវទទួលថា ៖***

**អាម ភន្តេ ។**

*ប្រែថា ព្រះករុណាលោកម្ចាស់ ។*

***លោកឲ្យនិច្ចសីលជាបច្ចេកសមាទានថា ៖***

**១- បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ** *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាធ្វើសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។*

**២–អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ** *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យដោយកាយ ឬដោយវាចា ។*

**៣–កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ** *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។*

**៤–មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ** *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យកុហក ។*

**៥– សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទគឺចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។*

***រួចហើយលោកឲ្យសីល លោកពោលដាស់តឿនក្រើនរំឭកថា៖***

**ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ ។**

*ប្រែថា អ្នក / អ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៥ នេះ ឲ្យប្រពៃ ត្រូវរក្សាឲ្យល្អអស់កាលជានិច្ច ដោយសេចក្ដីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។*

***បើអ្នកសមាទានតែម្នាក់ ត្រូវថា "អ្នក" បើគ្នាច្រើនត្រូវថា "អ្នកទាំងឡាយ" ។***

***អ្នកសមាទានត្រូវទទួលថា៖***

**អាម ភន្តេ ។**

*ប្រែថា ព្រះករុណាលោកម្ចាស់ ។*

*ហើយលោកសម្តែងអានិសង្សសីលឲ្យស្តាប់តទៅទៀតថា៖*

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**

**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។**

*សត្វទាំងឡាយទៅកាន់ស្ថានសួគ៌បាន ក៏ព្រោះសីល សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខគឺព្រះនិព្វានក៏ព្រោះសីល ព្រោះហេតុនោះ បុគ្គលជាសប្បុរសគប្បីជម្រះនូវសីល ឲ្យបរិសុទ្ធកុំឲ្យសៅហ្មងឡើយ ។*

*អ្នកសមាទានត្រូវទទួលថា* **សាធុ** *(ប្រពៃហើយ) ។*

**ចប់វិធីសមាទាននិច្ចសីល**

**ជាបច្ចេកសមាទាន**

## វិធីសមាទានឧបោសថសីល

ឧបាសក ឧបាសិកា ជាអ្នករក្សានូវឧបោសថសីល កាលបើដល់ថ្ងៃជិតនឹងរក្សានូវឧបោសថសីល គឺថ្ងៃមុន ១ ថ្ងៃ ដែលកំណត់ថាព្រឹកឡើងនឹងរក្សានូវឧបោសថសីលនោះ គប្បីចាត់ចែងការងារដែលគួរនឹងចាត់ចែង មានវិធីចាត់ចែងនូវអាហារជាដើម ដែលជាការងារគឺខ្លួននឹងត្រូវធ្វើ ឬនឹងត្រូវប្រើឲ្យគេធ្វើក្នុងថ្ងៃស្អែក គឺក្នុងថ្ងៃឧបោសថកាលឲ្យហើយក្នុងថ្ងៃនោះមុន តែកុំចាត់ចែងការងារដែលមិនប្រកបដោយធម៌ ដែលជាការងារគឺខ្លួនជាឧបាសក ឧបាសិកា មិនគួរនឹងចាត់ចែងនោះឡើយ លុះដល់ព្រឹកឡើងជាថ្ងៃឧបោសថកាលត្រូវរក្សានូវឧបោសថសីល គប្បីភ្ញាក់ឡើង អំពីព្រលឹម ហើយខ្ពុរមាត់ ជម្រះធ្មេញឲ្យស្អាត រួចហើយ បើតម្ពារុណ (អរុណពណ៌ក្រហមមានហើយ) គប្បីសមាទាននូវឧបោសថសីលក្នុងវេលានោះ ក៏ជាការប្រពៃ បើឃើញថា នឹងសមាទានពេលនោះ មិនទាន់ទេ គប្បីកំណត់នូវឧបោសថកាល គឺកាលជាទីរក្សានូវឧបោសថសីលក្នុង ១ ថ្ងៃ ១ យប់នោះ ដោយបញ្ចេញវាចា អធិដ្ឋានថា៖

**អជ្ជ ឧបោសថោ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ { ឧបោសថិកោ / ឧបោសថិកា } ភវិស្សាមិ ។**

<u>ប្រែថា</u> ថ្ងៃនេះជាថ្ងៃត្រូវរក្សានូវឧបោសថសីល ខ្ញុំនឹងជាអ្នករក្សានូវឧបោសថសីលអស់ថ្ងៃនេះ និងយប់នេះ ។

បើឧបាសក ត្រូវថា **ឧបោសថិកោ** បើឧបាសិកា ត្រូវថា **ឧបោសថិកា** ។

បើមិនចេះបាលី នឹងអធិដ្ឋានតាមភាសារបស់ខ្លួនៗ ក៏គួរដោយពិត លុះអធិដ្ឋានកំណត់កាលដូច្នេះរួចហើយ ត្រូវតាំងវិរតិចេតនា វៀរចាកសីលភេទ គឺហេតុដែលជាទីទម្លាយនូវសីលនោះៗ ឲ្យគ្រប់សិក្ខាបទទាំង ៨ កាលបើបានអធិដ្ឋានដូច្នេះរួចហើយ តអំពីពេល

នោះមក គប្បីសមាទាននូវឧបោសថសីលអំពីបុគ្គលដទៃ មានភិក្ខុជាដើម តាមកាលដ៏គួរចុះ បើទុកជាដល់ពេលព្រះអាទិត្យរះខ្ពស់ឡើងប្រមាណពេញពន្លឺធំ ទើបបានសមាទានក្តី ក៏ឈ្មោះថា បានសមាទានដោយប្រពៃ ឈ្មោះថាបានរក្សានូវឧបោសថសីលពេញ កាលកំណត់ ១ ថ្ងៃ ១ យប់ ដោយបរិបូណ៌ ព្រោះអ្នកសមាទានបានធ្វើនូវឧបោសថកាល មិនឲ្យខ្វះខាត ទាំងវិរតិចេតនាសោត ក៏កើតបរិបូណ៌ក្នុងសន្តាន នឹងបានផលានិសង្សច្រើន ។ ដើម្បីឲ្យកាន់តែជាក់ច្បាស់ ខ្ញុំបាទសូមលើកយកសេចក្តីដែលមានមកក្នុងអដ្ឋកថា មកបញ្ជាក់បន្ថែមទៀតដូច្នេះថា៖

អដ្ឋកថាឧបោសថសូត្រ បានពោលថា បុគ្គលអ្នករក្សាឧបោសថសីលនោះ គប្បីតាំងចិត្តថា "ព្រឹកនេះយើងនឹងរក្សាឧបោសថ" ហើយពិនិត្យមើលការធ្វើអាហារ ជាដើមសិននៅក្នុងថ្ងៃនេះតែម្តង ដោយនិយាយថា ពួកលោកគប្បីធ្វើវត្ថុនេះ និងវត្ថុនេះ ។ ក្នុងថ្ងៃឧបោសថ គប្បីបញ្ចេញវាចាសមាទានអដ្ឋឧបោសថ ក្នុងសំណាក់ភិក្ខុ ឬសាមណេរ របស់ឧបាសក ឬឧបាសិកា អ្នកដឹងនិងលក្ខណៈរបស់សីល ១០ អំពីព្រឹក ។ តែការមិនដឹងព្រះបាលី គប្បីអធិដ្ឋានថា "អាត្មាអញអធិដ្ឋាន ឧបោសថដែលព្រះពុទ្ធជាម្ចាស់ទ្រង់បញ្ញត្តិទុក ។ ការមិនបានអ្នកដទៃ គប្បីអធិដ្ឋានដោយខ្លួនឯងក៏បាន, តែគួរធ្វើការបញ្ចេញវាចាដោយពិត ។ ការរក្សាឧបោសថ មិនគួរចាត់ចែងការងារ ដែលជាប់ជាមួយការបៀតបៀនអ្នកដទៃ គួរធ្វើការរាប់អាយុ និងវ័យឲ្យកាលកន្លងទៅ ។ ម្យ៉ាងទៀត គប្បីជាអ្នកប្រៀបបានទៅនឹងភិក្ខុអ្នកមានកត្តជាប្រចាំ បានអាហារក្នុងផ្ទះបរិភោគហើយ គប្បីទៅកាន់វិហារស្តាប់ព្រះធម៌ ឬមនសិការៈ បណ្តាអារម្មណ៍ ៣៨ អារម្មណ៍ណានីមួយ ។ ក្នុងដីកាឧបោសថសូត្រនោះ បានពោលថា ចាប់ផ្តើមអំពីការសមាទានសីល អ្នករក្សាឧបោសថ មិនគួរធ្វើកិច្ចអ្វីៗ យ៉ាងដទៃឡើយ គួរធ្វើកាលកន្លងទៅ ដោយការស្តាប់ព្រះធម៌ ឬមនសិការកម្មដ្ឋាន ព្រោះហេតុនោះព្រះអដ្ឋកថាចារ្យ ទើបពោលថា **តស្មាន ឧបវសន្តេ។ល។ វិហារេ គន្តព្វំ។** ក្នុងពីរបទថា **វាចំ ភិន្ទិត្វា** គប្បីជ្រាបវិនិច្ឆ័យដូចនេះ៖ អ្នករក្សាឧបោសថ គប្បីកំណត់កាលថា "អាត្មា

អញនឹងរក្សាឧបោសថ រហូតថ្ងៃនេះ និងយប់នេះ" ហើយធ្វើដោយរួមគ្នាដោយអំណាចអង្គឧបោសថថា អាត្មាអញសមាទានសិក្ខាបទ ៨ ហើយធ្វើការបញ្ចេញវាចា សមាទានអង្គឧបោសថ ចំពោះអង្គតាមបាលីយ៉ាងនេះថា : **បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ។ ល ។ ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ** តែការមិនដឹងព្រះបាលី គប្បីសមាទានដោយភាសារបស់ខ្លួន ឬដោយអំណាចអធិដ្ឋានដោយរួមគ្នាថា "អាត្មាអញអធិដ្ឋានឧបោសថសីល ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តិទុកហើយ" ។ ការមិនបានអ្នកដទៃ គប្បីអធិដ្ឋានខ្លួនឯងក៏បាន ។ ពិតណាស់សីលរបស់ឧបាសកដែលបុគ្គលអ្នករក្សាឧបោសថ សមាទានដោយខ្លួនឯងក្តី សមាទានក្នុងសំណាក់ដទៃក្តី ក៏ឈ្មោះថា សមាទានហើយ សមាទានជឯកជ្ឈសមាទានក្តី សមាទានជាបច្ចេកសមាទានក្តី ក៏ជាការសមាទានដូចគ្នា ។

<u>សួរថា</u> សេចក្តីផ្សេងគ្នាយ៉ាងណា?

<u>ឆ្លើយថា</u> ការសមាទានជាឯកជ្ឈៈរួមគ្នា វិរតិមានតែមួយយ៉ាងប៉ុណ្ណោះ ចេតនាក៏មានមួយដូចគ្នា ។ តែវិរតិ និងចេតនានោះ ធ្វើកិច្ចរបស់វិរតិ និងចេតនាទាំងអស់ ព្រោះហេតុនោះ សិក្ខាបទទាំងអស់ចាត់ថា ដែលអ្នករក្សាឧបោសថសមាទានហើយដោយពិតដោយការសមាទានរួមគ្នាសូម្បីនោះ មួយទៀតការសមាទានជាបច្ចេកវិរតិ និងចេតនាក៏ផ្សេងៗ គ្នា រមែងកើតឡើងតាមមុខនាទី ដោយអំណាចកិច្ច ។ ក៏ក្នុងការសមាទានគ្រប់យ៉ាង គួរធ្វើបញ្ចេញវាចាដោយពិត ។

## ការសមាទានឧបោសថមានអង្គ ៣

**១–ចេតនា** *(គឺតាំងចេតនាវៀរចាកសិក្ខាបទដែលខ្លួនបានសមាទានហើយ*

**២–បញ្ចេញវាចា** *(គឺគប្បីពោលឲ្យច្បាស់ៗ)*

**៣–កាលនៃឧបោសថ** *(គឺកាលបកតិឧបោសថក្នុងថ្ងៃណា បដិជាគរឧបោសថក្នុងថ្ងៃណាជាដើម ។*

*បើមិនគ្រប់អង្គទាំង ៣ នេះទេ មិនឡើងជាឧបោសថឡើយ ។*

*កាលបើឧបាសក ឧបាសិកា នឹងសមាទាននូវឧបោសថសីលប្រកបព្រមដោយអង្គ ៨ ជាបច្ចេកសមាទានអំពីបុគ្គលដទៃ គឺភិក្ខុ ឬសាមណេរនោះ គប្បីសូធ្យនមស្ការថ្វាយបង្គំរឭកដល់គុណព្រះរតនត្រ័យដោយសង្ខេបជាមុន រួចហើយត្រូវសូមនូវឧបោសថសីលព្រមទាំងព្រះត្រៃសរណគមន៍ ចំពោះភិក្ខុ ឬសាមណេរដែលខ្លួន នឹងសមាទាននោះថា ៖*

**ឱកាស {អហំ / មយំ} ភន្តេ វិសុំ វិសុំ រក្ខណត្ថាយ តិសរណេន សហ អដ្ឋ**

**សីលានិ {យាចាមិ / យាចាម} ទុតិយម្បិ {អហំ / មយំ} ភន្តេ វិសុំ វិសុំ រក្ខណត្ថាយ**

**តិសរណេន សហ អដ្ឋ សីលានិ {យាចាមិ / យាចាម} តតិយម្បិ {អហំ / មយំ} ភន្តេ**

វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ { យាចាមិ ។ / យាចាម ។ }

*ប្រែថា* *សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ ។ សូមនូវសីលទាំងឡាយ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលទាំងឡាយ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង ។ ឬនឹងសូមថា ៖*

ឱកាស { អហំ / មយំ } ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ

អដ្ឋង្គសមន្នាគតំ ឧបោសថំ { យាចាមិ / យាចាម } អនុគ្គហំ កត្វា សីលំ ទេថ

{ មេ / នោ } ភន្តេ, ទុតិយម្បិ { អហំ / មយំ } ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន

សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ { យាចាមិ / យាចាម } អនុគ្គហំ កត្វា សីលំ ទេថ

{មេ / នោ} ភន្តេ, តតិយម្បិ {អហំ / មយំ} ភន្តេ វិសុំ វិសុំ រក្ខណត្ថាយ តិសរណេន

សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ {យាចាមិ ។ / យាចាម ។}

*<u>ប្រែថា</u> សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ។ សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗ គ្នា, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឲ្យនូវសីលដល់ ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ ។ សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តី អនុគ្រោះឲ្យនូវសីលដល់ ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ ។*

***សូមដូច្នេះក៏បាន តាមសេចក្តីពេញចិត្តរបស់អ្នកសូម ។ សេចក្តីអធិប្បាយអំពីអ្នកសូមតែម្នាក់ និងច្រើននាក់នោះ ដូចគ្នា នឹងវិធីសូមនូវនិច្ចសីលខាងដើម ។***

*រួចហើយលោកអ្នកឲ្យសីល លោកតាំងនមោ ៣ ចប់ហើយ ឲ្យព្រះត្រៃសរណគមន៍ អ្នកសមាទានត្រូវទទួលថាតាមលោក ដូចវិធីសមាទាននិច្ចសីល ខាងដើមរួចហើយ លោកឲ្យនូវឧបោសថសីល ជាបច្ចេកសមាទានថា៖*

**១– បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

*ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ។*

២– អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ ។

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យដោយកាយ ឬវាចា ។

៣– អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ ។

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម ។

៤– មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ ។

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យកុហក ។

៥– សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ។

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។

៦– វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ ។

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាបរិភោគនូវភោជនីយាហារក្នុងកាលខុស ។

៧– នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ។

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយារាំ និងច្រៀង និងប្រគំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ និងទ្រទ្រង់ និង ប្រដាប់តាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាប ផ្សេងៗ ។

**៨–ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ។**

*ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកទីសេនាសនៈ ដ៏ខ្ពង់ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។*

***រួចហើយអ្នកសមាទានសូធ្យកំណត់ឧបោសថថា៖***

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ។**

*ប្រែថា ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ដ៏ប្រកបព្រមដោយអង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តទុកហើយនេះ ដើម្បីនឹងរក្សាឲ្យបរិបូណ៌ប្រពៃ អស់កាលកំណត់ថ្ងៃនេះ និងយប់នេះ សូមកុសលចូរជាឧបនិស្ស័យ ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ពួដ៏អនាគតទៅឯមុខនោះហោង ។*

***បាលីនេះគ្រាន់តែជាពាក្យសម្រាប់ពោលកំណត់កាលឲ្យដឹងថា ឧបោសថសីល ទាំង ៨ សិក្ខាបទនេះ អ្នកសមាទានត្រូវរក្សាតែត្រឹម ១ ថ្ងៃ ១ យប់នោះប៉ុណ្ណោះ ហេតុនោះ បើអ្នកសមាទានបានចេះដឹងច្បាស់ប្រាកដ ក្នុងឧបោសថកាលហើយ មិនបាច់សូធ្យក៏បាន តែបើទុកជាចេះដឹងច្បាស់ប្រាកដហើយ នឹងសូធ្យបាលីនេះ ព្រមទាំងសេចក្ដីប្រែផងនោះ ក៏ជាការប្រពៃណាស់ ជាហេតុនាំឲ្យរឹតតែចេះស្ទាត់ប្រាកដទាំងអស់គ្នាឡើង ។***

*រួចហើយ លោកអ្នកឲ្យសីល លោកពោលដាស់តឿនក្រើនរំឭកថា ៖*

**ឥមានិ អដ្ឋ សិក្ខាបទានិ ឧបោសថសីលវសេន ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ។**

*ប្រែថា អ្នកទាំងឡាយគប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៨ នេះឲ្យប្រពៃ ត្រូវរក្សាឲ្យល្អ ដោយអំណាចនៃឧបោសថសីល អស់កាលកំណត់ត្រឹម ១ ថ្ងៃ ១ យប់នេះ ដោយសេចក្ដីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។*

***អ្នកសមាទានត្រូវទទួលថា៖***

**អាម ភន្តេ** ។ *ប្រែថា ព្រះករុណាលោកម្ចាស់ ។*

*រួចហើយលោកពោលអានិសង្សរបស់សីលដូចមុន ។*

*អ្នកសមាទានត្រូវទទួលថា* **សាធុ** *(ប្រពៃហើយ)*

**វិធីសមាទានបដិហារិយបោសថសីល**

| | | |
|---|---|---|
| ឱកាស | អហំ<br><br>មយំ | ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ |

| | | |
|---|---|---|
| អដ្ឋង្គសមន្នាគតំ បាដិហារិយុបោសថំ | យាចាមិ<br><br>យាចាម | អនុគ្គហំ កត្វា សីលំ ទេថ |

| | | | | |
|---|---|---|---|---|
| មេ<br><br>នោ | ភន្តេ, ទុតិយម្បិ | អហំ<br><br>មយំ | ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ |

| | | |
|---|---|---|
| អដ្ឋង្គសមន្នាគតំ បាដិហារិយុបោសថំ | យាចាមិ<br><br>យាចាម | អនុគ្គហំ កត្វា សីលំ ទេថ |

| | | | |
|---|---|---|---|
| មេ<br><br>នោ | ភន្តេ, តតិយម្បិ | អហំ<br><br>មយំ | ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន |

| | |
|---|---|
| សហ អដ្ឋង្គសមន្នាគតំ បាដិហារិយុបោសថំ | យាចាមិ ។<br><br>យាចាម ។ |

*ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ, សូមនូវបាដិហារិយឧបោសថសីល ប្រកបព្រមដោយអង្គ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗ គ្នា, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឲ្យនូវសីលដល់ ខ្ញុំព្រះករុណា, ខ្ញុំព្រះករុណាទាំងឡាយ, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា, ខ្ញុំព្រះករុណាទាំងឡាយ ។ សូមនូវបាដិហារិយ-ឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗ គ្នា ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឲ្យនូវសីលដល់ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ ។*

*រួចហើយលោកអ្នកឲ្យសីល លោកតាំង នមោ ៣ ចប់ ហើយឲ្យព្រះត្រៃ-សរណគមន៍ អ្នកសមាទានត្រូវទទួលថាតាមលោក ដូចវិធីសមាទាននិច្ចសីលខាងដើម រួចហើយលោកឲ្យនូវបាដិហារិយឧបោសថសីល ជាបច្ចេកសមាទានថា៖*

១– បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ។

២– អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ ។

៣– អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ ។

៤– មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ ។

៥– សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ។

៦– វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ ។

៧– នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌន-វិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ។

**៨- ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

*ខ្ញុំមិនបានលើកសេចក្តីប្រែមកទេ ពីព្រោះមានសេចក្តីប្រែដូចឧបោសថដែរ*

*រួចហើយអ្នកសមាទានសូធ្យកំណត់បាដិហារិយឧបោសថថា៖*

**ឥមំ អដ្ឋង្គសមន្នាគតំ ចាដិហារិយុបោសថំ តេមាសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ។**

*ប្រែថា* ខ្ញុំព្រះករុណា សូមសមាទាននូវបាដិហារិយឧបោសថសីល ដ៏ប្រកបព្រម ដោយអង្គ ៨ ដើម្បីនឹងរក្សាឲ្យបរិបូណ៌ប្រពៃអស់កាលកំណត់ ៣ ខែ សូមកុសលចូរជាឧបនិស្ស័យ ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ក្នុងអនាគតទៅឯមុខនោះហោង ។

*រួចហើយ លោកអ្នកឲ្យសីល លោកពោលដាស់តឿនក្រើនរំឭកថា ៖*

**ឥមានិ អដ្ឋ សិក្ខាបទានិ ចាដិហារិយុបោសថសីលវសេន តេមាសំ សាធុកំ កត្វា អប្បមាទេន សម្មា រក្ខិតព្វំ ។**

*ប្រែថា* អ្នកទាំងឡាយគប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៨ នេះឲ្យប្រពៃ ត្រូវរក្សាឲ្យល្អ ដោយអំណាចនៃបាដិហារិយឧបោសថសីល អស់កាលកំណត់ ៣ ខែ ដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

*អ្នកសមាទានត្រូវទទួលថា៖*

**អាម ភន្តេ** ។ *ប្រែថា ព្រះករុណាលោកម្ចាស់ ។*

*រួចហើយលោកពោលអានិសង្សរបស់សីលថា៖*

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**

**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។**

*(សេចក្តីប្រែដូចមុន)*

*អ្នកសមាទានត្រូវទទួលថា* **សាធុ** *(ប្រពៃហើយ)*

## **វិធីអធិដ្ឋានបាដិហារិយុបោសថ**

តេមាសំ ចាដិហារិយុបោសថំ អធិដ្ឋាមិ ។

*<u>ប្រែថា</u> អាត្មាអញអធិដ្ឋាននូវបាដិហារិយឧបោសថសីលអស់កំណត់ ៣ ខែ ។*

*ប្រសិនបើឧបាសក ឧបាសិកាមានបំណងចង់រក្សាច្រើនខែឡើងទៅឬតិចចុះគប្បីផ្លាស់បាលីត្រង់ពាក្យថា* **តេមាសំ** *តាមតម្រូវការចុះ ដូចមានពាក្យថា :*

**អឌ្ឍមាសំ** *កន្លះខែ,* **ឯកមាសំ** *១ខែ,* **ទ្វិមាសំ** *២ខែ,* **តេមាសំ** *៣ខែ,* **ចតុមាសំ** *៤ខែ,* **បញ្ចមាសំ** *៥ខែ,* **ឆមាសំ** *៦ខែ,* **សត្តមាសំ** *៧ខែ,* **អដ្ឋមាសំ** *៨ខែ,* **នវមាសំ** *៩ខែ,* **ឯកសំវច្ឆរំ** *១០ខែ ។*

**វិធីសមាទាន**

**បាដិហារិយុបោសថ ចប់**

## វិធីសមាទាន

## អាជីវដ្ឋមកសីល

*ឯវិធីសមាទានអាជីវដ្ឋមកសីល មិនខុសអំពីនិច្ចសីលប៉ុន្មានទេ ដែលខុសនោះ ខុសតែបាលីត្រង់ពាក្យថា* បញ្ចង្គសមន្នាគតំ និច្ចសីលំ *ចំណែកឯវិធីសមាទានអាជីវដ្ឋមកសីល ពោលថា* អដ្ឋង្គសមន្នាគតំ អាជីវដ្ឋមកសីលំ *ដូចមានវិធីសមាទានថា៖*

ឱកាស {អហំ / មយំ} ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ

អដ្ឋង្គសមន្នាគតំ អាជីវដ្ឋមកសីលំ {យាចាមិ / យាចាម} អនុគ្គហំ កត្វា សីលំ ទេថ

{មេ / នោ} ភន្តេ, ទុតិយម្បិ {អហំ / មយំ} ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន

សហ អដ្ឋង្គសមន្នាគតំ អាជីវដ្ឋមកសីលំ {យាចាមិ / យាចាម} អនុគ្គហំ កត្វា

សីលំ ទេថ {មេ / នោ} ភន្តេ, តតិយម្បិ {អហំ / មយំ} ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន

សហ អដ្ឋង្គសមន្នាគតំ អាជីវដ្ឋមកសីលំ { យាចាមិ ។ / យាចាម ។ }

ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ។ សូមនូវអាជីវដ្ឋមកសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឲ្យនូវសីលដល់ ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ ។ សូមនូវអាជីវដ្ឋមក-សីលប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗ គ្នា ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តី អនុគ្រោះឲ្យនូវសីលដល់ ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ ។

*រួចហើយលោកអ្នកឲ្យសីល លោកតាំង នមោ ៣ ចប់ ហើយឲ្យព្រះត្រៃ-សរណគមន៍ អ្នកសមាទានត្រូវទទួលថាតាមលោក ដូចវិធីសមាទាននិច្ចសីលខាងដើម រួចហើយលោកឲ្យនូវអាជីវដ្ឋមកសីល ជាបច្ចេកសមាទានថា៖*

១-បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ

២-អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ

៣-កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ

៤-មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ

៥-បិសុណាវាចា វេរមណី សិក្ខាបទំ សមាទិយាមិ

៦–ជរូសវាចា វេរមណី សិក្ខាបទំ សមាទិយាមិ

៧–សម្ផប្បលាបា វេរមណី សិក្ខាបទំ សមាទិយាមិ

៨–មិច្ឆាអាជីវា វេរមណី សិក្ខាបទំ សមាទិយាមិ[៨] ។

*រួចហើយលោកឲ្យសីល លោកពោលជាសំនៀងគ្រើនរំឭកថា៖*

ឥមានិ អដ្ឋ សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ ។

*ប្រែថា អ្នក ។ អ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៨ នេះ ឲ្យប្រពៃ ត្រូវរក្សាឲ្យល្អអស់កាលជានិច្ច ដោយសេចក្ដីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។*

*លោកពោលជាសំនៀងគ្រើនរំឭក ដោយន័យម្យ៉ាងទៀតថា៖*

តិសរណេន សហ អាជីវដ្ឋមកសីលំ សាធុកំ កត្វា អប្បមាទេន សម្បាទេថ ។

*បើអ្នកសមាទានតែម្នាក់ ត្រូវថា "អ្នក" បើគ្នាច្រើនត្រូវថា "អ្នកទាំងឡាយ" ។*

*អ្នកសមាទានត្រូវទទួលថា៖*

អាម ភន្តេ ។ *ប្រែថា ព្រះករុណាលោកម្ចាស់ ។*

*រួចហើយលោកពោលអានិសង្សរបស់សីលថា៖*

---

*៨ ព្រះអង្គទ្រង់សំដែងថា ម្នាលភិក្ខុទាំងឡាយ ជំនួញ ៥ យ៉ាងនេះ ឧបាសកមិនគួរធ្វើឡើយ ។*

**១ សត្ថវណិជ្ជា** *គឺការជួញគ្រឿងសស្ត្រាវុធ* **២ សត្តវណិជ្ជា** *ការជួញមនុស្ស* **៣ មំសវណិជ្ជា** *ការជួញ(សត្វដែលគេសម្លាប់យក)សាច់* **៤ មជ្ជវណិជ្ជា** *ការជួញគ្រឿងស្រវឹង* **៥ វិសវណិជ្ជា** *ការជួញថ្នាំពិស ។ ម្នាលភិក្ខុទាំងឡាយ ជំនួញ ៥ យ៉ាងនេះឯង ឧបាសកមិនគួរធ្វើឡើយ ។*

*បាកគម្ពីរអង្គុត្តរនិកាយ បញ្ចកនិបាត ត្រង់ឧបាសកវគ្គ វណិជ្ជសូត្រទី៧ បិដក៤៥ ទំព័រ១៦០*

**សីលេន សុគតឹ យន្តិ          សីលេន ភោគសម្បទា**

**សីលេន និព្វុតឹ យន្តិ          តស្មា សីលំ វិសោធយេ ។**

*(សេចក្តីប្រែដូចមុន)*

*អ្នកសមាទានត្រូវទទួលថា* **សាធុ** *(ប្រពៃហើយ)*

**អដ្ឋង្គសមន្នាគតំ អាជីវដ្ឋមកសីលំ អធិដ្ឋាមិ ។**

*អាត្មាអញអធិដ្ឋាននូវអាជីវដ្ឋមកសីលប្រកបព្រមដោយអង្គ ៨ ។*

## វិធីសមាទានសីល ១០

*វិធីសមាទានសីល ១០ ជាបច្ចេកសមាទាន ឧបាសក ឧបាសិកា ត្រូវសូត្រសូម សមាទានដូច្នេះថា៖*

ឱកាស { អហំ / មយំ } ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ ទស

សីលានិ { យាចាមិ / យាចាម } ទុតិយម្បិ { អហំ / មយំ } ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ

តិសរណេន សហ ទស សីលានិ { យាចាមិ / យាចាម } តតិយម្បិ { អហំ / មយំ } ភន្តេ

វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ ទស សីលានិ { យាចាមិ ។ / យាចាម ។ }

*<u>ប្រែថា</u> សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ, សូមនូវសីលទាំងឡាយ ១០ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលទាំងឡាយ ១០ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង ។*

***ឬឧបាសក ឧបាសិកា សូមសមាទាននូវសីល ១០ យ៉ាងដូច្នេះថា៖***

ឧកាស { អហំ / មយំ } ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ

ទសង្គសមន្នាគតំ ទសសីលំ { យាចាមិ / យាចាម } អនុគ្គហំ កត្វា សីលំ ទេថ

{ មេ / នោ } ភន្តេ, ទុតិយម្បិ { អហំ / មយំ } ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន

សហ ទសង្គសមន្នាគតំ ទសសីលំ { យាចាមិ / យាចាម } អនុគ្គហំ កត្វា សីលំ ទេថ

មេ / នោ ភន្តេ, តតិយម្បិ អហំ / មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន

សហ ទសង្គសមន្នាគតំ ទសសីលំ យាចាមិ ។ / យាចាម ។

*<u>ប្រែថា</u> សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ, សូមនូវទសសីល ប្រកបព្រមដោយអង្គ ១០ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗ គ្នា, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឲ្យនូវសីលដល់ ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ ។ សូមនូវទសសីល ប្រកបព្រមដោយអង្គ ១០ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗ គ្នា ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តី អនុគ្រោះឲ្យនូវសីលដល់ ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ ។*

***រួចហើយលោកអ្នកឲ្យសីល លោកតាំង នមោ ៣ ចប់ ហើយឲ្យព្រះត្រៃសរណគមន៍ អ្នកសមាទានត្រូវទទួលថាតាមលោក ដូចវិធីសមាទាននិច្ចសីលខាងដើម រួចហើយលោកឲ្យនូវទសសីល ជាបច្ចេកសមាទានថា៖***

**១- បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

*ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ។*

២- អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ។

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយា
កាន់យកនូវវត្ថុ ដែលគេមិនបានឲ្យដោយកាយ ឬវាចា ។

៣- អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ ។

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយា
ប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម ។

៤- មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ ។

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយា
ពោលនូវពាក្យកុហក ។

៥- សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ។

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ហេតុជា
ទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។

៦- វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយា
បរិភោគនូវភោជនីយាហារក្នុងកាលខុស ។

៧- នច្ចគីតវាទិតវិសូកទស្សនា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយារាំ
និងច្រៀង និងប្រគំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ ។

៨- មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី
សិក្ខាបទំ សមាទិយាមិ ។

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយា

*ទ្រទ្រង់ និងប្រដាប់តាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។*

**៩- ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ**

*ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ទីសេនាសនៈដ៏ខ្ពង់ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។*

**១០- ជាតរូបរជតប្បដិគ្គហណា វេរមណី សិក្ខាបទំ សមាទិយាមិ**

*ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាទទួលកាន់យកនូវមាស និងប្រាក់ដោយខ្លួនឯង ឬប្រើគេឲ្យទទួលកាន់យក ឬមួយត្រេកអរចំពោះមាស និងប្រាក់ដែលគេទុកដាក់ដើម្បីខ្លួន ។*

*ហើយលោកពោលជួរទេះ ៣ ដងថា ៖*

**ឥមានិ ទស សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន សម្បាទេតព្វំ ។**

*ប្រែថា* *អ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ១០ នេះ ឲ្យប្រពៃ ត្រូវរក្សាឲ្យល្អ ដោយសេចក្ដីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។*

***អ្នកសមាទានត្រូវទទួលថា:*** **អាម ភន្តេ** *ប្រែថា ព្រះករុណាលោកម្ចាស់ ។*

***រួចហើយលោកពោលអានិសង្សរបស់សីលថា៖***

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**

**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។**

*(សេចក្ដីប្រែដូចមុន)*

*អ្នកសមាទានត្រូវទទួលថា* **សាធុ** *(ប្រពៃហើយ)*

**ចប់វិធីសមាទានសិក្ខាបទ ១០**

**ជាបច្ចេកសមាទាន**

## វិធីអធិដ្ឋានទសង្គសីល

ទសង្គសីលំ អធិដ្ឋាមិ ។

*ប្រែថា អាត្មាអញអធិដ្ឋាននូវទសង្គសីល ។*

## វិធីសមាទានកម្មបថ១០

*វិធីសមាទានកម្មបថ ១០ មិនខុសពីសមាទានសីល ១០ ប៉ុន្មានទេ សមាទានបែបទីមួយដូចគ្នា ឯវិធីសមាទានបែបទីពីរខុសគ្នាដូច្នេះ ថា ៖*

ឱកាស {អហំ / មយំ} ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ

ទសកម្មបថង្គសមន្នាគតំ ទសសីលំ {យាចាមិ / យាចាម} អនុគ្គហំ កត្វា សីលំ ទេថ

{មេ / នោ} ភន្តេ, ទុតិយម្បិ {អហំ / មយំ} ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ

ទសកម្មបថង្គសមន្នាគតំ ទសសីលំ {យាចាមិ / យាចាម} អនុគ្គហំ កត្វា សីលំ ទេថ

{មេ / នោ} ភន្តេ , តតិយម្បិ {អហំ / មយំ} ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន

**សហ ទសកម្មបថង្គសមន្នាគតំ ទសសីលំ**

**យាចាមិ ។**

**យាចាម ។**

*ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ, សូមនូវទសសីល ប្រកបព្រមដោយអង្គកម្មបថ ១០ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗ គ្នា, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្ដីអនុគ្រោះឲ្យនូវសីលដល់ ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ ។ សូមនូវទសសីល ប្រកបព្រមដោយអង្គកម្មបថ ១០ មួយអន្លើដោយ ព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗ គ្នា ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្ដីអនុគ្រោះឲ្យនូវសីលដល់ ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ ។*

***រួចហើយលោកអ្នកឲ្យសីល លោកតាំង នមោ ៣ ចប់ ហើយឲ្យព្រះត្រៃ-សរណគមន៍ អ្នកសមាទានត្រូវទទួលថាតាមលោក ដូចវិធីសមាទាននិច្ចសីលខាងដើម រួចហើយលោកឲ្យនូវទសកម្មបថង្គសីល[៩] ជាបច្ចេកសមាទានថា៖***

**១-បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ**

**២-អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ**

*៩ អដ្ឋកថា បបញ្ចសូទនី មជ្ឈិមនិកាយ មូលបណ្ណាសក ចូឡយមកវគ្គ ត្រង់សាលេយ្យកសូត្រទី១ បានពោលថា កុសលកម្មបទ១០ ជាតួសីល ។ ដូច្នេះទើបខ្ញុំបាទរៀបពិធីសមាទាន កុសលកម្មបទ១០នេះ ងាយស្រួលដល់ឧបាសក ឧបាសិកា ដែលមានបំណងក្នុងការសមាទាន ។*

៣-កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ

៤-មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ

៥-បិសុណាវាចា វេរមណី សិក្ខាបទំ សមាទិយាមិ

៦-ផរុសវាចា វេរមណី សិក្ខាបទំ សមាទិយាមិ

៧-សម្ផប្បលាបា វេរមណី សិក្ខាបទំ សមាទិយាមិ

៨-អភិជ្ឈា វេរមណី សិក្ខាបទំ សមាទិយាមិ

៩-ព្យាបាទា វេរមណី សិក្ខាបទំ សមាទិយាមិ

១០-មិច្ឆាទិដ្ឋិយា វេរមណី សិក្ខាបទំ សមាទិយាមិ ។

*សូត្រសមាទាននូវសិក្ខាបទបាលីផង សម្រាយផងក៏បានរឹងរឹតតែប្រសើរ ដូចមានបាលី និងប្រែសូត្រខាងក្រោមនេះស្រាប់ ។*

១- បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ *ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។*

២- អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ *ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀចាក កិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យដោយកាយឬដោយវាចា ។*

៣- កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ *ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។*

៤- មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យកុហក ។*

៥- បិសុណាវាចា វេរមណី សិក្ខាបទំ សមាទិយាមិ *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យញុះញង់ បំបែកបំបាក់អ្នកដទៃ ។*

៦- ផរុសវាចា វេរមណី សិក្ខាបទំ សមាទិយាមិ *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម ។*

៧- សម្ផប្បលាបា វេរមណី សិក្ខាបទំ សមាទិយាមិ *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។*

៨- អភិជ្ឈា វេរមណី សិក្ខាបទំ សមាទិយាមិ *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាមានចិត្តគិតសម្លឹងរំពៃ ចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបម្រុងនឹងឲ្យបានមកជាទ្រព្យរបស់ខ្លួន ។*

៩- ព្យាបាទា វេរមណី សិក្ខាបទំ សមាទិយាមិ *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាមានចិត្តចងគំនុំគុំគួន គិតប៉ងនឹងឲ្យអ្នកដទៃ ដល់នូវសេចក្តីវិនាស ។*

១០- មិច្ឆាទិដ្ឋិយា វេរមណី សិក្ខាបទំ សមាទិយាមិ *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក គំនិតយល់ឃើញខុស ។*

*ហើយលោកពោលដូច្នេះ ៣ ដងថា ៖*

ឥមានិ ទស សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន សម្មា-

រក្ខិតព្វំ ។

*ប្រែថា* អ្នកទាំងឡាយគប្បីធ្វើនូវសិក្ខាបទទាំងឡាយ ១០ នេះ ឲ្យប្រពៃ ត្រូវរក្សាឲ្យល្អ ដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

***អ្នកសមាទានត្រូវទទួលថា:***

អាម ភន្តេ ។

*ប្រែថា ព្រះករុណាលោកម្ចាស់ ។*

***រួចហើយលោកពោលអានិសង្សរបស់សីលថា៖***

សីលេន សុគតី យន្តិ សីលេន ភោគសម្បទា

សីលេន និព្វុតី យន្តិ តស្មា សីលំ វិសោធយេ ។

*(សេចក្តីប្រែដូចមុន)*

*អ្នកសមាទានត្រូវទទួលថា* **សាធុ** *(ប្រពៃហើយ) ។*

## វិធីអធិដ្ឋានទសកម្មបថង្គសីល

ទសកម្មបថង្គសីលំ អធិដ្ឋាមិ ។

*ប្រែថា អាត្មាអញអធិដ្ឋាននូវទសកម្មបថង្គសីល (គឺកម្មបថ១០) ។*

**ចប់វិធីសមាទានសិក្ខាបទ ១០**

**បែបកម្មបថ**

## វិធីសមាទានឯកជ្ឈៈ

*បើឧបាសក ឧបាសិកា ទឹងសមាទាននិច្ចសីល ជាឯកជ្ឈសមាទាន ព្រមទាំងព្រះត្រៃសរណគមន៍ផងនោះ ត្រូវសូមដូច្នេះថា៖*

ឱកាស { អហំ / មយំ } ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ ឯកជ្ឈំ កត្វា

បញ្ចង្គសមន្នាគតំ និច្ចសីលំ { យាចាមិ / យាចាម } អនុគ្គហំ កត្វា សីលំ ទេថ

{ មេ / នោ } ភន្តេ, ទុតិយម្បិ { អហំ / មយំ } ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន

សហ ឯកជ្ឈំ កត្វា បញ្ចង្គសមន្នាគតំ និច្ចសីលំ { យាចាមិ / យាចាម } អនុគ្គហំ កត្វា

សីលំ ទេថ { មេ / នោ } ភន្តេ, តតិយម្បិ { អហំ / មយំ } ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ

តិសរណេន សហ ឯកជ្ឈំ កត្វា បញ្ចង្គសមន្នាគតំ និច្ចសីលំ { យាចាមិ ។ / យាចាម ។ }

*<u>ប្រែថា</u> សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ, សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ ធ្វើឲ្យជាឯកជ្ឈៈគឺសមាទានរួបតែម្តង មួយអន្លើដោយព្រះត្រៃសរណគមន៍, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឲ្យនូវសីលដល់ ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ ។ សូមនូវនិច្ចសីល ប្រកបព្រមដោយអង្គ ៥ ធ្វើឲ្យជាឯកជ្ឈៈ គឺសមាទានរួបតែម្តង មួយអន្លើដោយព្រះត្រៃសរណគមន៍ ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឲ្យនូវសីលដល់ ខ្ញុំព្រះករុណា។ ខ្ញុំព្រះករុណាទាំងឡាយ ។*

***រួចលោកអ្នកឲ្យសីល លោកតាំង នមោ ៣ ចប់រួចហើយ លោកឲ្យព្រះត្រៃ-សរណគមន៍ រួចប្រាប់អំពីកិច្ចកាន់យកនូវព្រះត្រៃសរណគមន៍ ដូចក្នុងវិធីបច្ចេក-សមាទានខាងដើម រួចហើយលោកឲ្យនិច្ចសីលជាឯកជ្ឈសមាទានថា ៖***

**បញ្ចង្គសមន្នាគតំ និច្ចសីលំ សមាទិយាមិ ។**

*<u>ប្រែថា</u> ខ្ញុំព្រះករុណា សូមសមាទាននូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ ។*

***អ្នកសមាទានត្រូវទទួលថាតាមលោក ឬលោកនឹងឲ្យថា៖***

**បញ្ច សីលានិ សមាទិយាមិ ។**

*<u>ប្រែថា</u> ខ្ញុំព្រះករុណា សូមសមាទាននូវសីលទាំងឡាយ ៥ ដូច្នេះក៏បាន ។*

***អ្នកសមាទានត្រូវទទួលថាតាមលោក រួចហើយលោកពោលដាស់តឿនក្រើនរំឭកថា៖***

**ឥមំ បញ្ចង្គសមន្នាគតំ និច្ចសីលំ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ ។**

<u>ប្រែថា</u> អ្នក ។ អ្នកទាំងឡាយ ។ គប្បីធ្វើនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ នេះ ឲ្យប្រពៃ ត្រូវរក្សាឲ្យល្អអស់កាលជានិច្ច ដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែស ឡើយ ។

*អ្នកសមាទានត្រូវទទួលថា:*

អាម ភន្តេ (ព្រះករុណាលោកម្ចាស់) ។

*រួចហើយ លោកសម្តែងអានិសង្សសីលឲ្យស្តាប់តទៅទៀត ដូចក្នុងវិធីបច្ចេក-សមាទានខាងដើម ។*

*សមាទានតែប៉ុណ្ណេះ ក៏ជាការស្រេច ឥតមានសូត្យញែក ឈ្មោះសិក្ខាបទទាំង ៥ រាយមួយម្តងៗ ដូចបច្ចេកសមាទាននោះឡើយ សមាទានតែប៉ុណ្ណេះហើយ ត្រូវរក្សា ដោយតាំងវិរតិចេតនាវៀរចាកឲ្យគ្រប់សិក្ខាបទក្នុងនិច្ចសីលទាំង ៥ ដែលខ្លួនបានចេះ ចាំស្ទាត់ហើយនោះទៅ ។*

*បើឧបាសក ឧបាសិកា នឹងសមាទានឧបោសថសីលជា **ឯកជ្ឈសមាទាន** ព្រមទាំងព្រះត្រៃសរណគមន៍ផងនោះ ត្រូវសូមដូច្នេះថា៖*

ឧកាស {អហំ / មយំ} ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ ឯកជ្ឈំ កត្វា

អដ្ឋង្គសមន្នាគតំ ឧបោសថំ {យាចាមិ / យាចាម} អនុគ្គហំ កត្វា សីលំ ទេថ

{មេ / នោ} ភន្តេ, ទុតិយម្បិ {អហំ / មយំ} ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន

យាចាមិ

សហ ឯកជ្ឈំ កត្វា អដ្ឋង្គសមន្នាគតំ ឧបោសថំ អនុគ្គហំ កត្វា

យាចាម

មេ / អហំ

សីលំ ទេថ ភន្តេ , តតិយម្បិ ភន្តេ វិសុំ វិសុំ រក្ខណត្ថាយ

នោ / មយំ

យាចាមិ។

តិសរណេន សហ ឯកជ្ឈំ កត្វា អដ្ឋង្គសមន្នាគតំ ឧបោសថំ

យាចាម ។

*<u>ប្រែថា</u> សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ។ សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ ធ្វើឲ្យជាឯកជ្ឈៈ គឺសមាទានរួបតែម្តង មួយអន្លើដោយព្រះត្រៃសរណគមន៍, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះឲ្យនូវសីលដល់ ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ ។ សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ ធ្វើឲ្យជាឯកជ្ឈៈ គឺសមាទានរួបតែម្តង មួយអន្លើដោយព្រះត្រៃសរណគមន៍ ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឲ្យនូវសីលដល់ ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ ។*

***រួចលោកអ្នកឲ្យសីល លោកតាំង នមោ ៣ ចប់ ហើយឲ្យព្រះត្រៃសរណគមន៍ រួចប្រាប់អំពីកិច្ចកាន់យកនូវព្រះត្រៃសរណគមន៍ដូចន័យមុន រួចហើយលោកឲ្យឧបោសថសីលជា ឯកជ្ឈសមាទាន ថា ៖***

**អដ្ឋង្គសមន្នាគតំ ឧបោសថំ សមាទិយាមិ ។**

*ប្រែថា* ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីលប្រកបព្រមដោយអង្គ ៨ ។

*អ្នកសមាទាន ត្រូវទទួលថាតាមលោក ឬ លោកនឹងឲ្យថា ៖*

**អដ្ឋ សីលានិ សមាទិយាមិ ។**

*ប្រែថា* ខ្ញុំព្រះករុណា សូមសមាទាននូវសីលទាំងឡាយ ៨ ។ ដូច្នេះក៏បាន ។

*អ្នកសមាទាន ត្រូវទទួលថាតាមលោក រួចហើយអ្នកសមាទានសូត្រកំណត់ឧបោសថកាលថា៖*

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ។**

*ប្រែថា* ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ដ៏ប្រកបព្រមដោយ អង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តទុកហើយនេះ ដើម្បីនឹងរក្សាឲ្យបរិបូណ៌ប្រពៃ អស់កាលកំណត់ថ្ងៃនេះ និងយប់នេះ សូមកុសលចូរជាឧបនិស្ស័យ ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ក្នុងអនាគតទៅឯមុខនោះហោង ។

*រួចហើយលោកពោលដាស់តឿនក្រើនរំឭកថា ៖*

**ឥមំ អដ្ឋង្គសមន្នាគតំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ ។**

*ប្រែថា* អ្នក ។ អ្នកទាំងឡាយ ។ គប្បីធ្វើនូវឧបោសថសីល ប្រកបព្រមដោយ អង្គ ៨ នេះ ដោយប្រពៃ ត្រូវរក្សាឲ្យល្អអស់កាលកំណត់ត្រឹម ១ ថ្ងៃ ១ យប់នេះ ដោយសេចក្តីមិនប្រមាទ គឺថាកុំធ្វេសប្រហែសឡើយ ។

*អ្នកសមាទានត្រូវទទួលថា:*

**អាម ភន្តេ** (ព្រះករុណាលោកម្ចាស់) ។

រួចហើយលោកសម្តែងអានិសង្សសីលឲ្យស្តាប់តទៅទៀត ដូចន័យមុន ។

សមាទានតែប៉ុណ្ណេះ ក៏ជាការស្រេច ឥតមានសូធ្យញែក ឈ្មោះសិក្ខាបទទាំង ៨ រាយមួយម្តងៗ ដូចបច្ចេកសមាទាននោះឡើយ, សមាទានតែប៉ុណ្ណេះហើយ ត្រូវរក្សាដោយតាំងវិរតិចេតនាវៀរចាក ឲ្យគ្រប់សិក្ខាបទទាំង ៨ ក្នុងឧបោសថសីលដែលខ្លួនបានចេះចាំស្ទាត់ហើយនោះទៅ ។

## វិធីសមាទានសីល ១០

### ជាឯកជ្ឈសមាទាន

*បើឧបាសក ឧបាសិកា ទឹងសមាទានទសសីល ជាឯកជ្ឈសមាទាន ព្រមទាំងព្រះត្រៃសរណគមន៍ផងនោះ ត្រូវសូមដូច្នេះថា៖*

ឱកាស {អហំ / មយំ} ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ ឯកជ្ឈំ កត្វា ទសង្គសមន្នាគតំ ទសសីលំ {យាចាមិ / យាចាម} អនុគ្គហំ កត្វា សីលំ ទេថ {មេ / នោ} ភន្តេ, ទុតិយម្បិ {អហំ / មយំ} ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ ឯកជ្ឈំ កត្វា ទសង្គសមន្នាគតំ ទសសីលំ {យាចាមិ / យាចាម} អនុគ្គហំ កត្វា សីលំ ទេថ {មេ / នោ} ភន្តេ , តតិយម្បិ {អហំ / មយំ} ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ ឯកជ្ឈំ កត្វា ទសង្គសមន្នាគតំ ទសសីលំ {យាចាមិ ។ / យាចាម ។}

*ប្រែថា* សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ, សូមនូវទសសីលប្រកបព្រមដោយអង្គ ១០ ធ្វើឲ្យជាឯកជ្ឈៈគឺសមាទានរួបតែម្តង មួយអន្លើ ដោយព្រះត្រៃសរណគមន៍, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តី អនុគ្រោះឲ្យនូវសីលដល់ ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាទាំងឡាយ ។ សូមនូវទសសីល ប្រកបព្រមដោយអង្គ ១០ ធ្វើឲ្យជាឯកជ្ឈៈ គឺសមាទានរួបតែម្តង មួយអន្លើដោយ ព្រះត្រៃសរណគមន៍ ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តី អនុគ្រោះ ឲ្យនូវសីលដល់ ខ្ញុំព្រះករុណា។ ខ្ញុំព្រះករុណាទាំងឡាយ ។

***រួចលោកអ្នកឲ្យសីល លោកតាំង នមោ ៣ ចប់រួចហើយ លោកឲ្យព្រះត្រៃ-សរណគមន៍ រួចប្រាប់អំពីកិច្ចកាន់យកនូវព្រះត្រៃសរណគមន៍ ដូចក្នុងវិធីបច្ចេក-សមាទានខាងដើម រួចហើយលោកឲ្យទសសីលជាឯកជ្ឈសមាទានថា ៖***

**ទសង្គសមន្នាគតំ ទសសីលំ សមាទិយាមិ ។**

*ប្រែថា* ខ្ញុំព្រះករុណា សូមសមាទាននូវទសសីលប្រកបព្រមដោយអង្គ ១០ ។

***អ្នកសមាទានត្រូវទទួលថាតាមលោក ឬលោកនឹងឲ្យថា:***

**ទស សីលានិ សមាទិយាមិ ។**

*ប្រែថា* ខ្ញុំព្រះករុណា សូមសមាទាននូវសីលទាំងឡាយ ១០ ។ ដូច្នេះក៏បាន ។

***អ្នកសមាទាន ត្រូវទទួលថាតាមលោក រួចហើយលោកពោលដាស់តឿនក្រើនរំឭកថា :***

**ឥមំ ទសង្គសមន្នាគតំ ទសសីលំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ ។**

*ប្រែថា* អ្នក ។ អ្នកទាំងឡាយ៊ គប្បីធ្វើនូវទសសីលប្រកបព្រមដោយអង្គ ១០ នេះឲ្យប្រពៃ ដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

***អ្នកសមាទានត្រូវទទួលថា:***

**អាម ភន្តេ** (ព្រះករុណាលោកម្ចាស់) ។

***រួចហើយ លោកសម្តែងអានិសង្សសីលឲ្យស្តាប់តទៅទៀត ដូចក្នុងវិធីបច្ចេកសមាទានខាងដើម ។***

**សមាទានតែប៉ុណ្ណេះ ក៏ជាការស្រេច ឥតមានសូធ្យញែក ឈ្មោះសិក្ខាបទទាំង ១០ រាយមួយម្តងៗ ដូចបច្ចេកសមាទាននោះឡើយ សមាទានតែប៉ុណ្ណេះហើយ ត្រូវរក្សាដោយតាំងវិរតិចេតនាវៀរចាកឲ្យគ្រប់សិក្ខាបទក្នុងទសសីលទាំង ១០ ដែលខ្លួនបានចេះចាំស្ទាត់ហើយនោះចុះ ។**

សូម្បីឧបាសក ឧបាសិកា នឹងអធិដ្ឋាននិច្ចសីល ឧបោសថសីល ឬទសសីល ដោយខ្លួនឯងក្តី ក៏គប្បីបញ្ចេញវចីភេទអធិដ្ឋានតាមបែបជាបច្ចេក: ឬ ជាឯកជ្ឈសមាទាន ដូចបានពោលមកហើយនោះចុះ ។

គ្រង់វិធីដែលលោកសម្តែងអានិសង្សសីល ឲ្យអ្នកសមាទានស្តាប់នោះ បើលោកអ្នកឲ្យសីល លោកឈ្លាសចេះចាំច្រើន ហើយអាចនឹងសម្តែងក្នុងពេលនោះបាន ក៏គួរនឹងសម្តែងតាមន័យប្លែកៗ ដោយអាងលើព្រះពុទ្ធភាសិតឲ្យអ្នកសមាទានស្តាប់នោះ ក៏ជាការប្រពៃក្រៃពេក, អ្នកសមាទានបានស្តាប់ហើយ ក៏នឹងកើតមានសេចក្តីជ្រះថ្លា ព្រមទាំងចម្រើនសតិបញ្ញាដោយក្រៃលែងឡើងទៀត ហើយនឹងមានផលានិសង្សច្រើន ដល់លោកអ្នកឲ្យសីលនឹងអ្នកសមាទាន ។

## វិនិច្ឆ័យព្រះត្រៃសរណគមន៍

*សួរថា ព្រះត្រៃសរណគមន៍នរណាជាអ្នកពោល ?*

*ឆ្លើយថា ព្រះត្រៃសរណគមន៍ព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ពោល មិនមែនសាវ័ក មិនមែនឥសី មិនមែនទេវតាជាអ្នកពោលឡើយ ។*

*សួរថា: ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ពោលនៅក្នុងទីណា ?*

*ឆ្លើយថា ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ពោលនៅក្នុងឥសិបតនមិគទាយវ័នក្រុងពារាណសី។*

*សួរថា ព្រះអង្គទ្រង់ពោលកាលណា ?*

*ឆ្លើយថា ព្រះអង្គទ្រង់ពោលកាលយសកុលបុត្រសម្រេចព្រះអរហត្តផល ព្រមទាំងសម្លាញ់ទាំងឡាយកាលដែលមានព្រះអរហន្ត ៦១ អង្គធ្វើការសម្តែងធម៌ក្នុងលោក ដើម្បីប្រយោជន៍ជាសុខដល់មហាជនច្រើនគ្នា ។*

*សួរថា ព្រះអង្គទ្រង់ពោលព្រោះហេតុអ្វី ?*

*ឆ្លើយថា ព្រះអង្គទ្រង់ពោលដើម្បីបព្វជ្ជា នឹងឧបសម្បទា ដូចយ៉ាងដែលព្រះអង្គទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ក៏ឯឧបសម្បទាបេក្ខៈ ដែលភិក្ខុគប្បីឲ្យបព្វជ្ជា នឹងឧបសម្បទាយ៉ាងនេះ មុនដំបូងកោរសក់ពុកមាត់ ឲ្យស្លៀកដណ្តប់ សំពត់កាសាវៈធៀងស្មាម្ខាងហើយថ្វាយបង្គំបាទាភិក្ខុទាំងឡាយ អង្គុយច្រហោង ផ្គងអញ្ជលី គប្បីបង្រៀនឲ្យពោលតាមយ៉ាងនេះថា :*

**ពុទ្ធំ សរណំ គច្ឆាមិ**

**ធម្មំ សរណំ គច្ឆាមិ**

**សង្ឃំ សរណំ គច្ឆាមិ។**

## ពណ៌នាព្រះត្រៃសរណគមន៍

ឥឡូវនេះ ខ្ញុំព្រះករុណានឹងពណ៌នាពាក្យថា ព្រះពុទ្ធ ការដល់សរណៈ នឹងរឿង បុគ្គលអ្នកដល់សរណៈក្នុងពាក្យនោះ មនុស្សពិសេសឈ្មោះថា ព្រះពុទ្ធ ព្រោះបញ្ញត្តិ អាស្រ័យខន្ធសន្តានដែលត្រូវអប់រំដោយការសម្រេចអនុត្តរវិមោក្ខ ដែលជានិមិត្តនៃញាណ ដែលអ្វីៗរារាំងមិនបាន ឬព្រោះបញ្ញត្តិអាស្រ័យការត្រាស់ដឹងសច្ចធម៌ ដោយខ្លួនឯង ដ៏ក្រៃលែង ដែលជាបទដ្ឋាននៃព្រះសព្វញ្ញុតញ្ញាណ ដូចលោកពោលទុកថា៖ ព្រះដ៏មាន ព្រះភាគអង្គណាទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមាន គ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ទ្រង់ត្រាស់ដឹងសច្ចធម៌ទាំងឡាយដែលមិនបានស្ដាប់ មកអំពីមុន ទ្រង់សម្រេចនូវសព្វញ្ញុតញ្ញាណ ក្នុងធម៌ទាំងឡាយនោះ នឹងភាពជាអ្នកជំនាញ ក្នុងពលៈទាំងឡាយ ព្រះដ៏មានព្រះភាគអង្គនោះ ឈ្មោះថា ពុទ្ធៈ ។

តែកាលពោលព្យញ្ជនៈ គប្បីជ្រាបដោយន័យជាដើមយ៉ាងនេះថា ឈ្មោះថា ពុទ្ធៈ ព្រោះព្រះអង្គជាអ្នកត្រាស់ដឹង ឈ្មោះថា ពុទ្ធៈ ព្រោះអត្ថដូចម្ដេច ? ឈ្មោះថា ពុទ្ធៈ ព្រោះអត្ថថាត្រាស់ដឹងនូវសច្ចធម៌ទាំងឡាយ ។ ឈ្មោះថា ពុទ្ធៈ ដោយអត្ថថា ព្រះអង្គ ដាស់ពពួកសត្វឲ្យភ្ញាក់ ។ ឈ្មោះថា ពុទ្ធៈ ដោយអត្ថថា ព្រោះព្រះអង្គទ្រង់ឃើញគ្រប់ យ៉ាង ។ ឈ្មោះថា ពុទ្ធៈ ព្រោះព្រះអង្គទ្រង់ត្រាស់ដឹងដោយខ្លួនឯង ឥតមានអ្នកដទៃ ធ្វើឲ្យត្រាស់ដឹង ។ ឈ្មោះថា ពុទ្ធៈ ព្រោះរីកហើយ ។ ឈ្មោះថា ពុទ្ធៈ ព្រោះព្រះអង្គ ជាអ្នកមិនមានឧបក្កិលេស ។ ឈ្មោះថា ពុទ្ធៈ ព្រោះព្រះអង្គ មិនមានរាគៈឡើយ ។ ឈ្មោះថា ពុទ្ធៈ ព្រោះព្រះអង្គមិនមានទោសៈឡើយ ។ ឈ្មោះថា ពុទ្ធៈ ព្រោះព្រះអង្គ មិនមានមោហៈឡើយ ។ ឈ្មោះថា ពុទ្ធៈ ព្រោះព្រះអង្គប្រាសចាកកិលេសមិនមានសល់ ។ ឈ្មោះថា ពុទ្ធៈ ព្រោះព្រះអង្គមានដំណើរជា ឯកាយនមគ្គ ។ ឈ្មោះថា ពុទ្ធៈ ព្រោះ ព្រះអង្គត្រាស់ដឹងក៏ក្រៃលែង នូវអនុត្តរសម្មាសម្ពោធិញ្ញាណដោយព្រះអង្គឯង ។ ឈ្មោះថា ពុទ្ធៈ ព្រោះព្រះអង្គ ទ្រង់ដឹង ទ្រង់កម្ចាត់ហេតុការណ៍ដែលមិនបានដឹងអស់ហើយ ។

ព្រះនាមថា **ពុទ្ធ:** នេះមិនមែនព្រះជននី (មាតា) ដាក់ឲ្យ មិនមែនព្រះជនក (បិតា) ដាក់ឲ្យ មិនមែនជេដ្ឋាភាតា (បងប្រុស) ដាក់ឲ្យ មិនមែនជេដ្ឋកគនី (បងស្រី) ដាក់ឲ្យ មិនមែនអាមាត្យដាក់ឲ្យ មិនមែនសាលោហិតដាក់ឲ្យ មិនមែនសមណព្រាហ្មណ៍ដាក់ឲ្យ មិនមែនទេវតាដាក់ឲ្យ ព្រះនាមនេះរបស់ព្រះសម្មាសម្ពុទ្ធ មានចំណែកខាងចុងនៃការរួចផុតចាកកិលេស បញ្ញត្តិគឺព្រះពុទ្ធ ព្រះអង្គធ្វើឲ្យជាក់ច្បាស់ ព្រមជាមួយនឹងព្រះអង្គបាននូវសព្វញ្ញុតញ្ញាណ ។

## សរណគមន៍ និងដល់សរណគមន៍

ឥឡូវនេះ ខ្ញុំបាទនឹងពណ៌នាអំពីសរណគមន៍ ជាដើមដូចតទៅនេះ ។ ព្រះរតនត្រ័យដែលឈ្មោះថា **សរណ:** ព្រោះកម្ចាត់ អធិប្បាយថា ប្របាច់ទម្លាយ នាំចេញ រំលត់ភ័យគឺសេចក្តីខ្លាច សេចក្តីតក់ស្លុត ទុក្ខ ទុគ្គតិ សេចក្តីសៅហ្មង ដោយការដល់សរណ: នោះឯង របស់មនុស្សទាំងឡាយដែលដល់សរណគមន៍ ។ម្យ៉ាងទៀត ព្រះពុទ្ធជាម្ចាស់ឈ្មោះថា**សរណ:** ព្រោះកម្ចាត់ភ័យរបស់សត្វទាំងឡាយ ដោយការឲ្យចូលដល់វត្ថុ ដែលជាប្រយោជន៍ នឹងនាំចេញនូវវត្ថុដែលមិនជាប្រយោជន៍ ។ ព្រះធម៌ឈ្មោះថា **សរណ:** ព្រោះញុំាងសត្វឲ្យឆ្លងផុតកន្តារៈគឺភព នឹងឲ្យថ្វាវីកកាយនៃចិត្ត ។ ព្រះសង្ឃឈ្មោះថា **សរណ:** ព្រោះមនុស្សទាំងឡាយ ធ្វើសក្ការៈសូម្បីបន្តិចបន្តួច ត្រឡប់ឲ្យផលសម្បូរដ៏លើស ព្រោះហេតុនោះ ព្រះរតនត្រ័យនោះ ទើបឈ្មោះថា សរណ: ដូចបរិយាយមកយ៉ាងនេះ ។

ចិត្តុប្បាទដែលកើតសេចក្តីជ្រះថ្លាក្នុងព្រះរតនត្រ័យនោះ នឹងសេចក្តីគោរពក្នុងព្រះរតនត្រ័យនោះ កម្ចាត់ទម្លាយកិលេសបានប្រព្រឹត្តទៅដោយអាការៈ គឺការមានព្រះរតនត្រ័យនោះជាទីពឹងឬមិនមានអ្នកដទៃជាបច្ច័យ ឈ្មោះថា **សរណគមន៍** ។ សត្វអ្នកបរិបូរណ៍ដោយចិត្តុប្បាទនោះ រមែងដល់នូវព្រះរតនត្រ័យនោះជា **សរណ:** អធិប្បាយថារមែងដល់នូវព្រះរតនត្រ័យដោយចិត្តុប្បាទ ដែលមានប្រការដូចពោលហើយថា នេះជា

សរណៈរបស់ខ្ញុំ នេះជាគ្រឿងនាំមុខរបស់ខ្ញុំ ។ បុគ្គលកាលនឹងដល់ រមែងដល់ដោយវិធីសមាទាន ដូចយ៉ាងនាយពាណិជពីរនាក់ឈ្មោះថា តបុស្សៈ និងភល្លិកៈ ជាដើមថា៖

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងពីរនាក់ សូមដល់នូវព្រះពុទ្ធ ព្រះធម៌ ជាទីពឹង សូមចាំទុកថាខ្ញុំព្រះអង្គជាឧបាសកចាប់អំពីថ្ងៃនេះតទៅ ដូច្នេះក៏បានការដល់វិធីព្រមធ្វើសិស្ស ។ ដូចព្រះមហាកស្សបៈជាដើមថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគជាសាស្តាបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវកដូច្នេះក៏បាន ។

ការដល់ដោយវិធីបង្អោនខ្លួនទៅក្នុងព្រះរតនត្រ័យនោះ ដូចព្រហ្មាយុព្រាហ្មណ៍ជាដើម សេចក្តីបាលីថា កាលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះ ព្រហ្មាយុព្រាហ្មណ៍ ក៏ក្រោកចាកអាសនៈធ្វើសំពត់ឆៀងស្មាម្ខាង ធ្វើអញ្ជលីឡើងបែរទៅផ្លូវចំពោះព្រះដ៏មានព្រះភាគប្រថាប់ បន្លឺឧទាន ៣ ដងថា :

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** ដូច្នេះក៏បាន ។

ការដល់ដោយវិធីប្រគល់ខ្លួន ដូចយោគីបុគ្គលអ្នកខ្វល់ខ្វាយ ក្នុងកម្មដ្ឋានក៏បានការដល់ដោយវិស័យ ដោយកិច្ចច្រើនវិធីដូចវិធី កម្ចាត់ឧបក្កិលេស ដោយការដល់សរណគមន៍ដូចព្រះអរិយបុគ្គលទាំងឡាយក៏បាន ។

## សរណគមន៍ដាច់ មិនដាច់ និងផល

ឥឡូវនេះ នឹងពណ៌នាមានការដាច់ព្រះត្រៃសរណគមន៍ជាដើមដូចតទៅ៖

ការដាច់ព្រះត្រៃសរណគមន៍ របស់បុគ្គលអ្នកដល់សរណគមន៍យ៉ាងនេះ មាន ២ យ៉ាង គឺមានទោស និងមិនមានទោស ការដាច់ព្រះត្រៃសរណគមន៍ ព្រោះការស្លាប់ ឈ្មោះថាមិនមានទោស, ការដាច់ព្រះត្រៃសរណគមន៍ ព្រោះវិលទៅកាន់សាសនាដទៃ និងប្រព្រឹត្ត

ខុសក្នុងសាសនានោះ ឈ្មោះថា មានទោស ។ ការដាច់ទាំងពីរយ៉ាងនេះ រមែងមានដល់បុថុជ្ជនទាំងឡាយប៉ុណ្ណោះ សរណៈរបស់បុថុជ្ជនទាំងឡាយ រមែងឈ្មោះថា សៅហ្មង ព្រោះប្រព្រឹត្តទៅដោយសេចក្តីមិនដឹង សេចក្តីមិនដឹង សេចក្តីសង្ស័យ និងសេចក្តីយល់ខុស និងព្រោះប្រព្រឹត្តមិនអើពើជាដើមក្នុងព្រះពុទ្ធគុណទាំងឡាយ ចំណែកព្រះអរិយបុគ្គល មិនមានសរណៈដាច់ទេ និងមិនមានសរណៈសៅហ្មងទេ ដូចព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកដល់ព្រមទិដ្ឋិ (សម្មាទិដ្ឋិ) នឹងវិលទៅរាប់រកសាសនាដទៃ មិនមែនឋានៈ មិនមែនឱកាសទេ ចំណែកពួកបុថុជ្ជននៅមិនទាន់ដល់ការដាច់សរណគមន៍ ដរាបណាដរាបនោះ ក៏នៅឈ្មោះថាជាអ្នកមានសរណៈមិនដាច់ ការដាច់សរណៈរបស់បុថុជ្ជនទាំងឡាយនោះ រមែងមានទោស មានសេចក្តីសៅហ្មង នឹងអំណោយផលដែលមិនគួរប្រាថ្នា ការដាច់សរណៈមិនមានទោសក៏មិនមានផល ព្រោះមិនមានវិបាក ។ ចំណែកការមិនដាច់សរណៈ ពោលដោយផល ក៏រមែងអំណោយផលដែលគួរប្រាថ្នា តែម្យ៉ាង ដូចព្រះអង្គទ្រង់ត្រាស់ថា ជនណាមួយដល់នូវព្រះពុទ្ធជាទីពឹង ជនទាំងឡាយនោះ លុះលះលោកនេះទៅហើយ ក៏នឹងមិនទៅកាន់អបាយភូមិ រមែងទៅសោយសុខក្នុងទេវលោកដូច្នេះ ។

នៅក្នុងបរមត្ថជោតិកាអដ្ឋកថាខុទ្ទកនិកាយខុទ្ទកបាឋ :

## កំណត់សេចក្តីប្លែកគ្នារបស់សិក្ខាបទទូទៅ

បណ្តាសិក្ខាបទទាំងឡាយនោះ សិក្ខាបទ ៥ ជាសិក្ខាបទខាងដើម ទូទៅទាំងឧបាសក ឧបាសិកា ព្រមទាំងសាមណេរទាំងឡាយដោយជានិច្ចសីល ចំពោះឧបោសថសីល របស់ឧបាសក ឧបាសិកា ព្រោះរួមសិក្ខាបទទី ៧ និងទី ៨ ចូលជាអង្គជាមួយគ្នា សិក្ខាបទទាំងឡាយនោះ ក៏ទូទៅជាមួយសាមណេរទាំងឡាយ ចំណែកសិក្ខាបទជាតរូបជាសិក្ខាបទពិសេសសម្រាប់សាមណេរទាំងឡាយប៉ុណ្ណោះ ។

គប្បីជ្រាបកំណត់ដោយសេចក្តីប្លែកគ្នា របស់សិក្ខាបទទូទៅដូចពោលមកនេះ គប្បីកំណត់**បកតិវជ្ជៈ** និង**បណ្ណត្តិវជ្ជៈ**យ៉ាងនេះ គឺបណ្តាសិក្ខាបទ ៥ ខាងដើម កំណត់ដោយ

ចេតនាវៀរចាក ជា **បកតិវជ្ជៈ** មានបាណាតិបាតជាដើម ព្រោះមានកុសលចិត្ត ជាសមុដ្ឋានមួយចំណែក សិក្ខាបទក្រៅពីនោះ គឺសិក្ខាបទ ៥ ខាងចុង កំណត់ដោយចេតនាវៀរចាក ជា **បណ្ណត្តិវជ្ជៈ** ។

នៅក្នុងអដ្ឋកថា **សម្មោហវិនោទនី** អដ្ឋកថាព្រះអភិធម្មត្រង់សិក្ខាបទវិភង្គថា៖

**សិក្ខាបទានីតិ សិក្ខិតព្វបទានិ សិក្ខាកោដ្ឋាសាតិ អត្ថោ ។ អបិច ឧបរិ អាគតា សព្វេបិ កុសលា ធម្មា សិក្ខិតព្វតោ សិក្ខា បញ្ចសុ បន សីលង្គេសុ យង្កិញ្ចិ អង្គំ តាសំ សិក្ខានំ បតិដ្ឋានដ្ឋេន បទន្តិ សិក្ខានំ បទត្តាបិ សិក្ខាបទានិ។**

ពាក្យថា **សិក្ខាបទានិ** <u>ប្រែថា</u> សិក្ខាបទទាំងឡាយបានដល់បទដែលកុលបុត្រទាំងឡាយគប្បីសិក្សា អធិប្បាយថា សិក្ខាបទនេះជាចំណែកមួយនៃសិក្ខា ( សិក្ខាគឺ សីល សមាធិ បញ្ញា ) ។ ម្យ៉ាងទៀត កុសលធម៌ទាំងឡាយ ដែលមានមកហើយ ក្នុងខាងលើ ឈ្មោះថា **សិក្ខា** ព្រោះជាធម៌ដែលកុលបុត្រគប្បីសិក្សា ក៏បណ្តាអង្គសីលទាំង ៥ អង្គ សីលណាមួយ ឈ្មោះថា **បទ** ព្រោះអត្ថថា ជាទីអាស្រ័យរបស់សិក្ខាទាំងឡាយ (ព្រោះហេតុនោះ) អង្គនៃសីលទាំងឡាយនោះ ទើបឈ្មោះថា **សិក្ខាបទ** ព្រោះចំណែកមួយនៃសិក្ខា ។

នៅក្នុងអដ្ឋកថា **បរមត្ថជោតិកា** អដ្ឋកថា ខុទ្ទកនិកាយ ខុទ្ទកបាឋៈ ពន្យល់ថា ក្នុងបទទាំងឡាយនោះ គប្បីជ្រាបដោយព្យញ្ជនៈមុន ឈ្មោះថា **វេរមណី** ព្រោះវៀរចាក លះបង់ គឺធ្វើឲ្យអស់ទីបំផុត ឲ្យដល់ភាពមិនមាន ។ មួយទៀត បុគ្គលរមែងវៀរចាក

ដោយចេតនាធ្វើនោះ ហេតុនោះ ចេតនានោះ ទើបឈ្មោះថា **វេរមណី** ព្រោះយកវិអក្សរជាវេអក្សរ ។ ដោយហេតុនោះឯង ក្នុងពាក្យនេះ ពុទ្ធបរិស័ទនាំគ្នាសូត្រ ២ យ៉ាងថា **វេរមណី សិក្ខាបទំ, វិរមណី សិក្ខាបទំ ។** ឈ្មោះថា **សិក្ខា** ព្រោះដែលបុគ្គលគប្បីសិក្សា ។ ឈ្មោះថា **បទ** ព្រោះជាគ្រឿង ដល់បទនៃសិក្ខាបទនៃសិក្ខា ឈ្មោះថា **សិក្ខាបទ** អធិប្បាយថា ឧបាយជាគ្រឿងដល់សិក្ខា ។ ម្យ៉ាងទៀត លោកអធិប្បាយថា ជាមូល ជាទីអាស្រ័យ ជាទីតាំង ។ សិក្ខាបទគឺចេតនាវៀរចាក ឈ្មោះថា **វេរមណីសិក្ខាបទ** ឬ **វិរមណីសិក្ខាបទ** តាមន័យទាំងពីរ ។ ខ្ញុំព្រះករុណា សូមសមាទានដោយប្រពៃ ឈ្មោះថា **សមាទិយាមិ** លោកអធិប្បាយថា ខ្ញុំព្រះករុណា សូមសមាទានដោយប្រាថ្នា មិនប្រព្រឹត្តកន្លង ព្រោះជាអ្នកធ្វើសិក្ខាបទ មិនឲ្យធ្លុះ មិនឲ្យដាច់ មិនឲ្យពព្រុស មិនឲ្យពពាល ។

តែកាលពោលដោយអត្ថបទថា វេរមណី បានដល់វិរតិ ចេតនាវៀរចាក ប្រកបដោយចិត្តជាកាមាវចរកុសល ។ វិរតិរបស់បុគ្គលអ្នកវៀរចាកបាណាតិបាត លោកពោលទុកក្នុងវិភង្គដោយន័យជាដើមយ៉ាងនេះថា ចេតនាលះ ចេតនាវៀរចាក វៀរ លែង លះវៀរ មិនធ្វើ មិនប្រព្រឹត្ត មិនកន្លង មិនល្មើសខេត្តដែន ។

បទថា **សិក្ខា** បានដល់សិក្ខា ៣ គឺ **អធិសីលសិក្ខា អធិចិត្តសិក្ខា អធិ-បញ្ញាសិក្ខា ។** តែក្នុងទីនេះ សីលគឺសម្បត្តិ វិរតិវិបស្សនា ចំណែកលោកិយ រូបជ្ឈាន និងអរូបជ្ឈាន និងអរិយមគ្គ លោកប្រាថ្នាថាសិក្ខា ក្នុងបទថាសិក្ខានេះ ។

នៅក្នុងសម្មោហវិនោទនីសម្តែងថា៖

**ឥទានិ ឯតេសុ សិក្ខាបទេសុ ញាណសមុត្តេជនត្ថំ ឥមេសំ បាណាតិបាតាទីនំ ធម្មតោ កោដ្ឋាសតោ អារម្មណតោ វេទនាតោ មូលតោ កម្មតោ សាវជ្ជតោ បយោគតោ ច វិនិច្ឆយោ វេទិតព្វោ ។**

ឥឡូវនេះ ដើម្បីសេចក្ដីដំរុញញាណក្នុងសិក្ខាបទទាំងឡាយនេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យនូវសិក្ខាបទទាំងឡាយមានបាណាតិបាតជាដើមនេះ ដោយ**ធម្ម:** ដោយ **កោដ្ឋាស:** ដោយ**អារម្មណ៍** ដោយ**វេទនា** ដោយ**មូល** ដោយ**កម្ម** ដោយ**សាវជ្ជ:** ដោយ**បយោគ:** ។

ពាក្យថា **កោដ្ឋាស** បានដល់ ជាកម្មបថសូម្បីទាំង ៧

ពាក្យថា **អារម្មណ៍** បានដល់ បាណាតិបាតមានជីវិតិន្ទ្រិយជាអារម្មណ៍ ។

**អទិន្នាទាន** មានសត្វជាអារម្មណ៍ ឬមានសង្ខារជាអារម្មណ៍ ។

**មិច្ឆាចារ:** ការប្រព្រឹត្តខុស មានស្រីប្រុសជាអារម្មណ៍ ។

**មុសាវាទ** មានសត្វជាអារម្មណ៍ ឬមានសង្ខារជាអារម្មណ៍ ។

ការផឹកទឹកស្រវឹង មានសង្ខារជាអារម្មណ៍ ពោលដោយវេទនា **បាណាតិបាត** ជាទុក្ខវេទនា ។ **អទិន្នាទាន** មានវេទនា ៣ មែនពិត អទិន្នាទាននោះ ជាសុខវេទនា ដល់អ្នកត្រេកអរ កាន់យកវត្ថុដែលម្ចាស់គេមិនបានឲ្យ ទុក្ខវេទនាព្រោះបុគ្គលអ្នកកាន់យកវត្ថុនោះមានសេចក្ដីខ្លាច ជាអទុក្ខមសុខវេទនា ដល់បុគ្គលអ្នកព្រងើយកាន់យក ។ **មិច្ឆាចារ:** ជាសុខវេទនា ឬអទុក្ខមសុខវេទនា ។ **មុសាវាទ** មានវេទនា ៣ ដូច **អទិន្នាទាន** ។ ការផឹកសុរា ជាសុខវេទនាកណ្ដាល (សុខមជ្ឈត្តវេទនា) ។ ពោល

ដោយ **មូល** បាណាតិបាត មានទោសៈ និងមោហៈ ជាមូល ។ អទិន្នាទាន គ្រាខ្លះមានលោភៈ មោហៈ ជាមូល គ្រាខ្លះមានទោសៈ មោហៈ ជាមូល ។ **មិច្ឆាចារៈ** មានលោភៈ មោហៈ ជាមូល ។ **មុសាវាទ** គ្រាខ្លះមាន លោភៈ មោហៈ ជាមូល គ្រាខ្លះមាន ទោសៈ មោហៈ ជាមូល ។ ការផឹកទឹកស្រវឹង មានលោភៈ មោហៈ ជាមូល ។ ពោលដោយ **កម្ម** មុសាវាទ ជាវចីកម្ម សិក្ខាបទដ៏សេស ជាកាយកម្មប៉ុណ្ណោះ ។ ពោលដោយ **ខណ្ឌៈ** (ដាច់) លោកពោលទុក នៅក្នុងអដ្ឋកថា **សម្មោហវិនោទនី** ដែលថា **ខណ្ឌតោតិ គហដ្ឋា យំ យំ វិតក្កមន្តិ ។ តំ តទេវ ខណ្ឌំ ហោតិ ភិជ្ជតិ អវសេសំ ន ភិជ្ជតិ ។ កស្មា ? គហដ្ឋា ហិ អនិពទ្ធសីលា ហោន្តិ យំ យំ សក្កោន្តិ តំ តទេវ គោបេន្តិ ។**

ពួកគ្រហស្ថទាំងឡាយ បានប្រព្រឹត្តកន្លងនូវសិក្ខាបទណាៗ ក៏រមែងដាច់ខូចបែកធ្លាយ នូវសិក្ខាបទនោះៗប៉ុណ្ណោះ ឯសិក្ខាបទដ៏សេសអំពីនោះ មិនដាច់ខូចបែកធ្លាយទេ ។ ព្រោះហេតុអ្វី ? ព្រោះថា គ្រហស្ថទាំងឡាយ ជាអនិពទ្ធសីល គឺថាសីលមិនជាប់គ្នាដោយភេទ ខ្លួនជាគ្រហស្ថ ឬកម្មពន្ធជាប់ដោយកម្មណាមួយឡើយ បើគ្រហស្ថអាចរក្សាគ្រប់គ្រងនូវសិក្ខាបទណាៗប៉ុន្មាន ក៏ថែរក្សានូវសិក្ខាបទនោះៗ ប៉ុណ្ណោះទៅ ។

**សាមណេរានំ បន ឯកស្មិម្បិ វិតក្កមន្តេ សព្វានិបិ ភិជ្ជន្តិយេវ ។ ន កេវលញ្ច ឯតានិ សេសសីលានិបិ ភិជ្ជន្តិយេវ ។ តេសំ បន វិតក្កមោ**

**ទណ្ឌកម្មវត្ថុកោ "បុន ឯវរូបំ ន ករិស្សាមី " តិ ទណ្ឌកម្មេ កតេ សីលំ បរិបុណ្ណំ ហោតិ ។**

*តែចំណែកសិក្ខាបទរបស់សាមណេរទាំងឡាយវិញ ការប្រព្រឹត្តកន្លងនូវសិក្ខាបទ សូម្បីតែមួយសិក្ខាបទ សិក្ខាបទទាំងឡាយឯទៀតទាំងអស់ក៏រមែងដាច់ខូច បែកធ្លាយទាំងអស់ ។ ក៏ការប្រព្រឹត្តកន្លងនូវសីលរបស់សាមណេរទាំងឡាយនោះ មានវត្ថុជាទណ្ឌកម្ម ហើយកាលសាមណេរទាំងឡាយនោះធ្វើទណ្ឌកម្មហើយសង្រួមថា អាត្មាអញមិនធ្វើនូវកម្ម មានសភាពយ៉ាងនេះទៀតទេ សីលក៏កើតឡើងវិញពេញបរិបូណ៌ ដូចខាងដើម ។*

*នៅក្នុង* **បរមត្ថជោតិកា** *លោកពន្យល់ត្រង់ខណ្ឌៈដាច់នេះថា* **សាមណេរា-នញ្ហិ ឯកស្មឹ ភិន្នេ សព្វានិបិ ភិន្នានិ ហោន្តិ។ ចារាជិកដ្ឋានិយានិ ហិ តានិ តេសំ, យន្តំ វិតក្កន្តិ ហោតិ, តេនេវ កម្មពន្ធោ ។** *សម្រាប់សាមណេរទាំងឡាយ កាលសិក្ខាបទណាមួយដាច់ គ្រប់សិក្ខាបទទាំងអស់ រមែងបែកធ្លាយដែរ ព្រោះថាសិក្ខាបទរបស់សាមណេរទាំងឡាយនោះ ជាឋាន ជាទីតាំងនៃបារាជិក សាមណេរទាំងឡាយ ដោយសិក្ខាបទដែលសាមណេរប្រព្រឹត្តកន្លងល្មើសនោះ ជាកម្មពន្ធគឺកម្មជាប់ទាក់ទងគ្នា ។*

*តែសម្រាប់គ្រហស្ថទាំងឡាយ ការប្រព្រឹត្តកន្លងនូវសិក្ខាបទណាៗក៏រមែងខូច បែកធ្លាយតែសិក្ខាបទនោះៗប៉ុណ្ណោះ ព្រោះសីលរបស់គ្រហស្ថទាំងឡាយនោះ មានអង្គ ៥ រមែងនឹងសម្បូរទៀតដោយសមាទានសីលនោះប៉ុណ្ណោះ ។ តែអាចារ្យ មួយពួកពោលថា បណ្តាសីលគ្រហស្ថទាំងឡាយ ដែលសមាទានមួយៗ សីលមួយដាច់ ដាច់ត្រឹមតែសីលនោះប៉ុណ្ណោះ តែបណ្តាសីលគ្រហស្ថទាំងឡាយ សមាទានរួមគ្នាយ៉ាងនេះថា ខ្ញុំសូមសមាទាននូវសីលទាំងឡាយ ៥ ដូច្នេះ សូម្បីសិក្ខាបទមួយដាច់ សិក្ខាបទទាំងឡាយដ៏សេសរមែងខូចបែកធ្លាយផងដែរ ។ ព្រោះហេតុអ្វី ? ព្រោះសីលដែលសមាទានមិនដាច់គ្នា កាល*

គ្រហស្ថទាំងឡាយប្រព្រឹត្តកន្លងល្មើសនោះឯង ក៏ជាកម្មពន្ធ គឺកម្មជាប់ទាក់ទងគ្នា ។ នៅក្នុងគម្ពីរសុមង្គលវិលាសិនី អដ្ឋកថា កូដទន្តសូត្រ ពោលថា៖

**យោ បញ្ច សិក្ខាបទានិ ឯកតោ គណ្ហាតិ, តស្ស ឯកស្មឹ ភិន្នេ សព្វានិបិ ភិន្នានិ ហោន្តិ ។ យោ ឯកេកំ គណ្ហាតិ, សោ យំ វីតិក្កមតិ, តទេវ ភិជ្ជតិ ។** បុគ្គលណា សមាទាននូវសិក្ខាបទទាំងឡាយ ៥ ( ជាឯកជ្ឈសមាទាន) ជាមួយគ្នា សីលរបស់បុគ្គលនោះ បែកធ្លាយមួយសិក្ខាបទ សូម្បីសិក្ខាបទទាំងឡាយទាំងពួង ក៏រមែងបែកធ្លាយទាំងអស់ ។ បុគ្គលណាសមាទានម្តងមួយៗ បុគ្គលនោះប្រព្រឹត្តនូវសិក្ខាបទណាៗ រមែងបែកធ្លាយតែសិក្ខាបទនោះប៉ុណ្ណោះ ។ ក្នុងខនេះ គប្បីជ្រាបវិនិច្ឆ័យ សូម្បីដោយការដាច់ដោយប្រការយ៉ាងនេះឯង ។

## ពោលដោយសមាទាន

នៅក្នុងព្រះអដ្ឋកថា បរមត្ថជោតិកា លោកសម្តែងថា ៖

**អាទានតោតិ បាណាតិបាតាទិតោ វេរមណី សិក្ខាបទានិ បេតានិ សាមណេរេន ភិក្ខុស្ស សន្តិកេ សមាទិន្នានេវ សមាទិន្នានិ ហោន្តិ ។** សិក្ខាបទទាំងឡាយនេះមាន បាណាតិបាតា វេរមណី សិក្ខាបទជាដើម សាមណេរទាំងឡាយសមាទានក្នុងសំណាក់ភិក្ខុប៉ុណ្ណោះ ទើបជាការសមាទាន ចំណែកឧបាសក ឧបាសិកាទាំងឡាយសមាទានខ្លួនឯងក៏បាន សមាទានក្នុងសំណាក់អ្នកដទៃក៏បាន ក៏ជាការសមាទានហើយៗសមាទានរួមគ្នាក្តី សមាទានបែកគ្នាក្តី ឈ្មោះថាបានសមាទានហើយ តើផ្សេងគ្នាយ៉ាងណា បុគ្គលសមាទានរួមគ្នា មានវិរតិមួយ មានចេតនាមួយប៉ុណ្ណោះ តែប្រាកដជាវិរតិនិងចេនានោះ មានដល់ ៥ ដោយអំណាចកិច្ចគឺមុខ ។ ចំណែកបុគ្គលដែលសមាទាន

*បែកគ្នា គប្បីជ្រាបថា មានវិរតិ ៥ ចេតនានោះមានដល់ ៥ ក្នុងសេចក្ដីនេះគប្បីជ្រាប វិនិច្ឆ័យក្នុងការសមាទានដោយប្រការយ៉ាងនេះ ។ នៅក្នុង **សម្មោហវិនោទនី** អដ្ឋកថាព្រះអភិធម្មបិដក វិភង្គបញ្ជាក់ថា៖*

**សមាទានតោតិ សយមេវ "បញ្ច សិលានិ អធិដ្ឋានមីតិ អធិដ្ឋហន្តេនបិ បាដិយេក្កំ បាដិយេក្កំ សមាទិយន្តេនបិ សមាទិន្នានិ ហោន្តិ អញ្ញស្ស សន្តិកេ និសីទិត្វា "បញ្ច សីលានិ សមាទិយាមី "តិ សមាទិយន្តេនបិ បាដិយេក្កំ បាដិយេក្កំ សមាទិយន្តេនបិ សមាទិន្នានេវ ហោន្តិ ។**

*ពោលដោយសមាទាន កាលគ្រហស្ថទាំងឡាយតាំងអធិដ្ឋានថា* **បញ្ច សីលានិ អធិដ្ឋាមិ** *អាត្មាអញអធិដ្ឋាននូវសីលទាំងឡាយប្រកបដោយអង្គ ៥ ដោយខ្លួនឯងតែម្ដង ដូច្នេះក្ដី កាលបើតាំងវាចាសមាទានកាន់យកនូវសិក្ខាបទទាំងឡាយមួយៗ ជាលំដាប់ដោយខ្លួនឯងតែម្ដងក្ដី រមែងឈ្មោះថា សមាទានដោយខ្លួនឯងស្រេចហើយដូចគ្នា ។*

*កាលសមាទានកាន់យកដោយការចូលទៅអង្គុយក្នុងសំណាក់អ្នកដទៃ ហើយតាំងវាចាសមាទានថា* **បញ្ច សីលានិ សមាទិយាមិ** *អាត្មាអញសមាទាននូវសីលប្រកបដោយអង្គ ៥ ដូច្នេះក៏បាន កាលបើតាំងសមាទានកាន់យកនូវសិក្ខាបទទាំងឡាយមួយៗជាលំដាប់ក៏បាន (យ៉ាងនេះបានឈ្មោះថាសមាទានកាន់យកអំពីសំណាក់អ្នកដទៃ) ។*

*នៅក្នុង **បរមត្ថទីបនី** អដ្ឋកថាខុទ្ទកនិកាយ ឥតិវុត្តកៈពោលថា៖*

**សមាទានតោ អញ្ញស្ស គរុដ្ឋានិយស្ស សន្តិកេ តំ អលភន្តេន សយមេវ បញ្ច សីលានិ ឯកជ្ឈំ បាដិយេក្កំ វា សមាទាយន្តេន**

**សមាទិន្នានិ យោន្តិ** ។ ត្រង់ពាក្យបាលីថា“ សមាទានតោ ”នេះ លោកសេចក្ដីថា គ្រហស្ថកាលបើរកបុគ្គលជាទីគោរពមិនបាន គឺថាមិនបានចូលទៅកាន់ទីជិតក្នុងសំណាក់បុគ្គលដទៃដែលគួរជាទីគោរពនោះមិនបានទេ នឹងតាំងសមាទាននូវបញ្ចសីល ជា **ឯកជ្ឈៈ** ឬជា **បច្ចេកៈ** ដោយខ្លួនឯងក៏បាន សិក្ខាបទទាំងឡាយបាន ឈ្មោះថា សមាទានហើយ ។

## ពោលដោយវិរតិ

មាននៅក្នុង **បរមត្ថទីបនី** អដ្ឋកថាខុទ្ទកនិកាយ ឥតិវុត្តកៈ ពោលថា វិរតិរបស់បុគ្គលអ្នកវៀរចាកបាណាតិបាតជាដើម ដែលប្រកបដោយកុសលចិត្ត ដែលលោកពោលទុកយ៉ាងនេះថា (ក្នុងសម័យនោះ វិរតិនោះ) បានដល់ការលះ វៀរចាកបាណាតិបាត ដូច្នេះពោលដោយប្រភេទមាន ៣ យ៉ាងគឺ **សម្បត្តិវិរតិ១ សមាទានវិរតិ១ សមុច្ឆេទវិរតិ១**[១០] បណ្ដាវិរតិទាំង ៣ យ៉ាងនោះ វិរតិដែលកើតឡើងដល់អ្នកមិនបានសមាទានសិក្ខាបទមកពីមុន តែពិចារណាឃើញ ជាតិ វ័យ និងភាពជាពហូស្សូតជាដើមរបស់ខ្លួន ហើយមិនប្រព្រឹត្តកន្លង ដោយគិតថា រឿងនេះមិនសមគួរដល់យើងធ្វើដូច្នេះ ឈ្មោះថា **សម្បត្តិវិរតិ** ។ ចំណែក វិរតិដែលកើតឡើងដល់អ្នសមាទាននូវសិក្ខាបទមកពីមុន ហើយសូម្បីលះបង់ជីវិត របស់ខ្លួនដែលមានគុណតម្លៃក្រៃលែងជាងសិក្ខាបទនោះ ក៏មិនប្រព្រឹត្តកន្លងល្មើសវត្ថុ ព្រោះសមាទាននូវសិក្ខាបទទុក ឈ្មោះថា **សមាទានវិរតិ** ។

---

១០ **បបញ្ចសូទនី** អដ្ឋកថា មជ្ឈិមនិកាយ មូលបណ្ណាសក ត្រង់មូលបរិយាយវគ្គ សម្មាទិដ្ឋិសូត្រ **សារត្ថប្បកាសិនី** អដ្ឋកថា សំយុត្តនិកាយ និទានវគ្គ ទសកម្មបថវគ្គទី៣ ត្រង់ទសកម្មបថសូត្រទី ៥

តែវិរតិដែលសម្បយុត្តដោយអរិយមគ្គ ឈ្មោះថា **សមុច្ឆេទវិរតិ** សូម្បីផ្តើមទូវសេចក្តីគិតឡើងថា អញនឹងសម្លាប់សត្វក៏មិនកើតឡើងដល់ព្រះអរិយបុគ្គលទាំងឡាយឡើយ ។

**អដ្ឋកថា ទីឃនិកាយ** បានពោលថា ការវៀរចាកនោះមានបីយ៉ាង គឺ **សម្បត្តវិរតិ សមាទានវិរតិ សេតុឃាតវិរតិ** បណ្តាវិរតិទាំងបីនោះ បុគ្គលណាសូម្បីមិនបានទទួលសិក្ខាបទឡើយ តែរលឹកដល់ជាតិ គោត្រ ត្រកូល និងប្រទេសជាដើមរបស់ខ្លួន ម្យ៉ាងថា ការធ្វើនេះ មិនសមគួរដល់យើង ដូច្នេះហើយ មិនធ្វើបាណាតិបាតជាដើម ជៀសវាងវត្ថុដែលមកដល់សូម្បីចំពោះមុខ វៀរចាកវត្ថុនោះ ការវិរតិនោះ របស់បុគ្គលនោះ គប្បីជ្រាបថាជា **សម្បត្តវិរតិ** ។ ចំណែក វិរតិរបស់បុគ្គលអ្នកទទួលសិក្ខាបទយ៉ាងនេះថា រាប់ចាប់តាំងពីពេលនេះជាដើមទៅ យើងនឹងមិនសម្លាប់សត្វ សូម្បីព្រោះហេតុនៃជីវិតក្តី យើងនឹងវៀរចាកបាណាតិបាតក្តី យើងសូមសមាទាន ការវៀរចាកក្តី គប្បីជ្រាបថាជា **សមាទានវិរតិ** ។ ចំណែកការវៀរដែលសម្បយុត្តដោយមគ្គ របស់ព្រះអរិយសាវក ឈ្មោះថា **សេតុឃាតវិរតិ** ។ ក្នុងវិរតិបីយ៉ាងនោះ ២វិរតិដំបូង ធ្វើវត្ថុមានជីវិតិន្ទ្រិយជាដើម ដែលនឹងគប្បីល្មើស ដោយអំណាចការដាក់ចុះនូវអាជ្ញាជាដើមឲ្យជាអារម្មណ៍ វិរតិ១ក្រោយនេះ មានព្រះនិព្វានជាអារម្មណ៍ ។

ក៏ក្នុងវិរតិទាំងនេះ អ្នកបានទទួលសិក្ខាបទទាំង ៥ រួមគ្នា កាលសិក្ខាបទមួយបែកធ្លាយសិក្ខាបទរបស់បុគ្គលនោះ រមែងបែកធ្លាយទៅទាំងអស់ ។ បុគ្គលណាទទួលសិក្ខាបទម្តងមួយៗ បុគ្គលនោះកន្លងល្មើសសិក្ខាបទណាមួយបែកធ្លាយ តែសិក្ខាបទនោះប៉ុណ្ណោះ ។ ចំណែកសម្រាប់សេតុឃាតវិរតិនេះ ឈ្មោះថាការបែកធ្លាយមិនមានឡើយ ។ ព្រោះអរិយសាវករមែងមិនសម្លាប់សត្វ សូម្បីព្រោះហេតុនៃជីវិត ទាំងមិនផឹកទឹកស្រវឹងផង ។

*សូម្បីបើជនទាំងឡាយ ផ្សំស្រា និងទឹកដោះលាយគ្នាហើយ យកទៅចាក់ចូលក្នុងមាត់របស់ព្រះអរិយសាវ័កនោះ ទឹកដោះប៉ុណ្ណោះចូលទៅ ស្រាមិនចូលទៅទេ ។*

*គប្បីជ្រាបថា* **សម្បត្តវិរតិ**[១១] *ដូចវិរតិដែលកើតឡើងដល់ចក្កនឧបាសកនៅកោះសីហឡ:ដូច្នេះ ៖*

*បានឮថា ក្នុងវេលាចក្កនឧបាសកនៅកំលោះ រោគបានកើតឡើងដល់មាតា ។ ឯពេទ្យប្រាប់ថា គួរបានសាច់ទន្សាយស្រស់ទើបគួរ ។ លំដាប់នោះបងប្រុសរបស់គេប្រើនាយចក្កនៈ ទៅដោយបញ្ជាថា ប្អូនប្រុសចូលទៅកាន់ស្រែចុះ ។ គេទៅកាន់ស្រែនោះហើយ ក្នុងសម័យនោះ មានសត្វទន្សាយមួយ មកដើម្បីស៊ីដង្ហើមស្រូវ ។ ទន្សាយនោះឃើញនាយចក្កនៈនោះដើរចូលទៅ ទើបបោលទៅដោយរហ័ស ត្រូវវល្លិព្រៃជាប់ខ្លួនហើយក៏ស្រែកឮសំឡេងក្រិៗ ។ នាយចក្កនៈទៅតាមសំឡេងនោះ ក៏ចាប់សត្វទន្សាយនោះបាន ហើយទើបគិតថា យើងនឹងផ្សំថ្នាំឲ្យមាតា ។ តែគេគិតតទៅទៀតថា ខដែលយើងសម្លាប់សត្វមានជីវិត ព្រោះហេតុនៃជីវិតរបស់មាតា មិនគួរដល់យើងទេ ។ ពេលនោះគេទើបដោះលែងសត្វទន្សាយនោះ ដោយពោលពាក្យថា ឯងចូរទៅ ចូរស៊ីស្មៅ និងផឹកទឹកជាមួយពួកសត្វទន្សាយដទៃក្នុងព្រៃចុះ គេត្រឡប់ទៅផ្ទះវិញ ត្រូវបងប្រុសសួរថាប្អូនប្រុសបានសត្វទន្សាយហើយឬ? គេទើបប្រាប់សេចក្ដីដែលប្រព្រឹត្តទៅនោះ ដូច្នេះទើបបងប្រុសជេរនាយចក្កនៈនោះ គេទៅរកមាតាឈរពោលពាក្យសច្ចៈថា តាំងតែវេលាដែលខ្ញុំកើតមកហើយដឹងក្ដីពេលណា ខ្ញុំមិនដែលសម្លាប់សត្វឡើយ ។ ទាន់ពេលនោះឯងមាតារបស់គេក៏បានជាប្រាសចាករោគភ្លាម ។ អ្នកសមាទានបែបនេះ ឈ្មោះថា* **សម្បត្តវិរតិ។**

*១១ បាកគម្ពីរសារត្ថបកាសិនី អដ្ឋកថា សំយុត្តនិកាយ និទានវគ្គ ត្រង់ទសកម្មបទវគ្គទី៣*

គប្បីជ្រាបថា **សមាទានវិរតិ** ដូចវិរតិដែលកើតឡើងដល់ឧបាសកពួកអ្នកនៅជិតភ្នំឈ្មោះ ឧត្តរវឌ្ឍមានៈ ដូច្នោះ ៖

បានឮថា ឧបាសកនោះ ទទួលសិក្ខាបទក្នុងសំណាក់របស់បិង្គលពុទ្ធរក្ខិតត្ថេរៈ ដែលនៅក្នុងអម្ពរិយវិហារ ហើយទៅភ្ជួរស្រែ គ្រានោះគោរបស់គាត់បានបាត់ទៅ ឧបាសកកាលស្វែងរកគោនោះ បានឡើងទៅកាន់ភ្នំឈ្មោះ ឧត្តរវឌ្ឍមានៈ ពស់ធំមួយ បានចឹកឧបាសកនោះ ឧបាសកនោះគិតថា នឹងកាត់ក្បាលដោយកាំបិតនេះ គិតទៀតថា ខដែលយើងទទួលសិក្ខាបទក្នុងសំណាក់គ្រូដែលគួរសរសើរ ហើយគប្បីទម្លាយចេញ មិនសមគួរដល់ យើងទេ ។ ពេលដែលគិតយ៉ាងនេះហើយ រហូតដល់ទៅ ៣ ដង ទើបដាច់ចិត្តថា យើងសុខចិត្តដាច់ជីវិត តែយើងមិនព្រមលះបង់ សិក្ខាបទឡើយ ហើយបោះកាំបិតចោលទៅក្នុងព្រៃ ពស់ធំនោះស្រាប់តែវាលូនចេញបាតទៅ ទាន់ពេលនោះដូចគ្នា ។ ការសមាទានបែបនេះឈ្មោះថា **សមាទានវិរតិ**។

**ពោលដោយវិរតិ ចប់**

## ឧបោសថកាលសង្ខេប

ឧបោសថកម្មរបស់ឧបាសក ឧបាសិកា បើពោលដោយកាលដែលជាទីរក្សានូវឧបោសថសីលនោះ មានពីរប្រការគឺ **បកតិឧបោសថ ១ បដិជាគរឧបោសថ ១** ។ ឧបោសថកម្ម ដែលប្រព្រឹត្តទៅដោយប្រក្រតី គឺឧបោសថកម្មដែលអ្នកប្រាជ្ញទាំងឡាយលោកធ្វើមកហើយអំពីដើម ឈ្មោះថា "**បកតិឧបោសថ**" ឧបោសថកម្មនៃបុគ្គលភ្ញាក់រឭករឿយៗ គឺរឭកដល់ឧបោសថសីលដែលជាកុសលគឺខ្លួនត្រូវសន្សំឈ្មោះថា "**បដិជាគរ-ឧបោសថ**" ។

ឯកាលនៃ**បកតិឧបោសថ**នោះ ក្នុង ១ ខែ មាន ៨ ថ្ងៃ គឺថ្ងៃចំណែកខាង សុក្កបក្ខ (ខ្នើត) ៤ ថ្ងៃ, ខាងកាឡបក្ខ (រនោច) ៤ ថ្ងៃ , ខាងខ្នើតគឺ ថ្ងៃ ៥ កើត ៨ កើត ១៤ កើត ១៥ កើត , ខាងរនោច គឺ ថ្ងៃ ៥ រោច ៨ រោច ១៤ រោច ១៥ រោច បើខែខ្វះត្រង់ថ្ងៃ ១៤ រោច ថយមក ១៣ រោចវិញ ត្រង់ថ្ងៃ ១៥ រោច ថយមក ១៤ រោចវិញ ក្នុង ១ ខែ មានកាលនៃបកតិឧបោសថ ៨ ថ្ងៃ ដូច្នេះ ។

កាលនៃ**បដិជាគរឧបោសថ**នោះ ក្នុង ១ ខែមាន ១១ ថ្ងៃ គឺខាងខ្នើតមាន ៥ ថ្ងៃ, ខាងរនោចមាន ៦ ថ្ងៃ , ខាងខ្នើតគឺ ថ្ងៃ ៤ កើត ៦ កើត ៧ កើត ៩ កើត ១៣ កើត , ខាងរនោច គឺ ថ្ងៃ ១ រោច ៤ រោច ៦ រោច ៧ រោច ៩ រោច ១៣ រោច បើខែខ្វះត្រង់ថ្ងៃ ១៣ រោច ថយមក ១២ រោចវិញ, ថ្ងៃទាំង ១១ ក្នុងខែមួយៗ នេះ ជាថ្ងៃខាងដើម និងខាងចុងនៃ **បកតិឧបោសថ** ឬថាជា ថ្ងៃអមនៃ**បកតិឧបោសថ** គឺជាកាលនៃ**បដិជាគរឧបោសថ** ។

ថ្ងៃឯទៀត ក្រៅអំពី**បកតិឧបោសថ** និង**បដិជាគរឧបោសថ**នោះ មាន ១១ ថ្ងៃ គឺខាងខ្នើតមាន ៦ ថ្ងៃ, ខាងរនោចមាន ៥ ថ្ងៃ , ខាងខ្នើតគឺ ថ្ងៃ ១ កើត ២ កើត ៣ កើត ១០ កើត ១១ កើត ១២ កើត, ខាងរនោច គឺ ថ្ងៃ ២ រោច ៣ រោច ១០ រោច ១១ រោច ១២ រោច,

*បើខែខ្វះ មានតែ ១០ ថ្ងៃ ព្រោះត្រង់ ១២ រោច ទុក ជាថ្ងៃ**បដិជាគរឧបោសថ**, ថ្ងៃទាំង ១១ ឬ ១០ នេះ មិនមែនជាកាលនៃឧបោសថ ណាមួយឡើយ គ្រប់ៗខែទាំងអស់[១២] ។*

*នឹងអធិប្បាយពីកិច្ចដែលនឹងធ្វើនូវ ឧបោសថកម្ម គឺ **បកតិឧបោសថ** និង **បដិជាគរឧបោសថ** ជាសេចក្តីខ្លីៗបន្តិច គ្រាន់ជាទីចំណាំសម្គាល់របស់ឧបាសក ឧបាសិកាទាំងឡាយក្នុងព្រះពុទ្ធសាសនា, ឯ**បកតិឧបោសថកម្ម**នោះ គឺឧបោសថសីលដែលឧបាសក ឧបាសិកាត្រូវទទួលសមាទានកាន់រក្សានូវសិក្ខាបទទាំង ៨ ក្នុងថ្ងៃបកតិឧបោសថកាល កំណត់ត្រឹមតែ១ថ្ងៃ១យប់ តាមលំដាប់កាលនៃបកតិឧបោសថនោះ, ឯបដិជាគរឧបោសថនោះ គឺឧបោសថសីលដែលឧបាសក ឧបាសិកា ត្រូវដុសខាត់សម្អាតចិត្ត នឹករឭកដល់សិក្ខាបទទាំង ៨ ដែលជាអង្គនៃ ឧបោសថសីល តែឧបាសក ឧបាសិកា មិនត្រូវសមាទានឡើយ គ្រាន់តែបណ្តោះចិត្តឲ្យឃ្លាតឆ្ងាយអំពីកាមគុណ ៥ ហើយបម្រុងចាំដំណើរនៃឧបោសថសីល គឺគ្រាន់តែតាំងចិត្ត វៀរគ្រប់សិក្ខាបទទាំង ៨ មានបាណាតិបាតជាដើម ដូចជារក្សានូវឧបោសថសីល ក្នុងថ្ងៃបកតិឧបោសថកាលនោះដែរ, ប្លែកគ្នាតែមិនសមាទាន និងសមាទានប៉ុណ្ណោះ គឺ ថាបដិជាគរឧបោសថនោះ មិនមានសមាទានទេ គ្រាន់តែតាំងចិត្តវៀរគ្រប់សិក្ខាបទដែលត្រូវវៀរអស់ថ្ងៃ១ យប់១ ជាកំណត់, ឯបកតិឧបោសថសីលនោះ ត្រូវសមាទានទទួលកាន់យកនូវសិក្ខាបទទាំង ៨ រក្សាអស់ថ្ងៃ១ យប់១ នោះដែរ, វេលាដល់គ្រប់កំណត់កាលបកតិឧបោសថសីលថយទៅហើយ ត្រូវតាំងចិត្តជូនដំណើរនៃឧបោសថសីលនោះអស់ថ្ងៃ១ យប់១ទៀត គឺតាំងចិត្តវៀរគ្រប់សិក្ខាបទទាំង ៨ តែមិនបាច់ទទួលសមាទានទេ គឺគ្រាន់តែញ៉ាំងចិត្តឲ្យប្រព្រឹត្តទៅតាមបកតិឧបោសថសីល ដែលខ្លួនទទួលសមាទានអំពីថ្ងៃម្សិលប៉ុណ្ណោះឯង ។*

***ឯបកតិឧបោសថកាលនោះ*** *កាលព្រះសម្មាសម្ពុទ្ធគង់ធរមាននៅឡើយ ព្រះអង្គសម្តែងទុកថា ក្នុង ១ ខែ មាន ៦ ថ្ងៃ គឺ ខាងខ្នើត ៣ ថ្ងៃ ខាងរនោច ៣ ថ្ងៃ គឺត្រង់ថ្ងៃ ៨*

---

*១២. បាកគម្ពីរមង្គលត្ថទីបនី ភាគ៣*

កើត ៨ រោច ហៅថា **“អដ្ឋមីឧបោសថ”**, ១៤ កើត ១៤ រោច ហៅថា**“ចាតុទ្ទសីឧបោសថ”**, ១៥ កើត ១៥ រោច ហៅថា **“បណ្ណរសីឧបោសថ”**, បើខែខ្វះត្រង់ ១៥ រោច ត្រូវថយចុះមកថ្ងៃ ១៤ រោចវិញ, លុះដល់ព្រះអង្គចូលបរិនិព្វានទៅបាន ៣ ខែ ព្រះអរហន្ត ទាំងឡាយ ៥០០ ព្រះអង្គមានព្រះមហាកស្សបត្ថេរជាដើម លោកប្រជុំគ្នាធ្វើបឋមសង្គាយនាផ្ទៀងផ្ទាត់ធម៌វិន័យ លោកយល់ឃើញថា នៅរយាលថ្ងៃខាងដើមនោះពេកណាស់, ទើបលោកលើកយកថ្ងៃ ៥ កើត ៥ រោច មកកំណត់ទុកជាថ្ងៃ បកតិឧបោសថផង រួមគ្នាជាឧបោសថកាល ក្នុង ១ ខែៗ មាន ៨ ថ្ងៃៗ ព្រោះត្រង់ថ្ងៃ ៥ កើត ៥ រោច ជាថ្ងៃឧបោសថកាល ដែរហៅថា **“បញ្ចមីឧបោសថ”** ។

## បាដិហារិកបក្ខឧបោសថ

ចំណែកខែក្នុងរដូវភ្លៀង ៤ ខែ ចាត់ជាកាលរបស់ជនអ្នកធ្វើបាដិហារិកបក្ខនោះ ព្រោះហេតុនោះ ក្នុង**អដ្ឋកថា** រាជសូត្រ បានពោលទុកថា “ឧបោសថរក្សាអស់ ៣ ខែ ក្នុងខាងក្នុងរដូវភ្លៀង ឈ្មោថា **បាដិហារិកបក្ខ**, ប្រសិនបើមិនអាចរក្សា ៣ ខែ សូម្បីនោះ ឧបោសថរក្សាអស់ ១ ខែ ក្នុងរវាងថ្ងៃបវារណាទាំង ២ ឈ្មោះថា **បាដិហារិកបក្ខ** ។ កាលមិនអាចរក្សាបាន ១ ខែសូម្បីនោះ កន្លះខែចាប់ផ្ដើមអំពីថ្ងៃបវារណាដើម ក៏ឈ្មោះថា **បាដិហារិកបក្ខ**”។ ដីការាជសូត្រ ពោលថា “ឧបោសថរក្សាប្រចាំ ឈ្មោះថា **បាដិហារិកបក្ខ** ព្រោះនឹងត្រូវនាំទៅតាមលំដាប់ គឺព្រោះយើង នឹងត្រូវឲ្យប្រព្រឹត្តទៅគ្រប់ៗឆ្នាំ”[១៣] ។

ពាក្យថា គ្រហស្ថ ប្រែថា អ្នកគ្រប់គ្រងផ្ទះ ដូចវចនត្ថៈថា គហេតិដ្ឋតីតិ=គហដ្ឋោ បុគ្គលណានៅក្នុងផ្ទះ ដូច្នោះ បុគ្គលនោះ ឈ្មោះថា គហដ្ឋៈ ។

---

១៣. បាកគម្ពីរមង្គលត្ថទីបនី ភាគ៣

សម្រាប់គ្រហស្ថសីលនោះ ត្រូវមានការសមាទានផង បើសមាទានត្រឹមតែត្រៃសរណគមន៍ នៅមិនទាន់ហៅថា គ្រហស្ថមានសីលទេ ហៅបានត្រឹមតែអ្នកមានត្រៃសរណគមន៍ប៉ុណ្ណោះ ។ អ្នកទ្រុស្តសីល និងអលជ្ជី ។

## ពណ៌នាសេចក្តីនៃសិក្ខាបទដោយសង្ខេបសិន

នៅក្នុង សម្មោហវិនោទនី ត្រង់សិក្ខាបទវិភង្គពន្យល់ថា៖

**បាណាតិបាតាតិ បាណស្ស អតិបាតា ឃាតនា មរណាតិ អត្ថោ ។ វេរមណីតិ វិរតិ ។**

ពាក្យថា **បាណាតិបាតា** បានដល់ការញុាំងជីវិតសត្វឲ្យធ្លាក់ចុះកន្លងគឺ សម្លាប់សត្វ ។ ពាក្យថា **វេរមណី** បានដល់ការវៀរចាក ។

**អទិន្នាទានាតិ អទិន្នស្ស អាទានា បរបរិគ្គហិតស្ស ហរណាតិ អត្ថោ ។** ពាក្យថា **អទិន្នាទានា** បានដល់ការកាន់យករបស់អ្នកដទៃដែលគេមិនបានឲ្យ អធិប្បាយថា បានដល់ការនាំយកវត្ថុដោយបុគ្គលដទៃហួងហែងរក្សា ។

**អព្រហ្មចរិយន្តិ អសេដ្ឋចរិយំ, ទ្វយទ្វយសមាបត្តិ មេថុនបដិសេវនា កាយទ្វារប្បវត្តា អសទ្ធម្មបដិសេវនដ្ឋានវិតក្កមចេតនា អព្រហ្មចរិយំ ។** ពាក្យថា **អព្រហ្មចរិយំ** បានដល់ការប្រព្រឹត្តមិនប្រសើរ ។ ចេតនាជាហេតុល្មើស ឋានៈ គឺការសេពមេថុនធម្ម ប្រព្រឹត្តទៅតាមកាយទ្វារ ដោយការសេពមេថុនជាគូៗ ឈ្មោះថា **អព្រហ្មចរិយៈ** ។

**កាមេសូតិ វត្ថុកាមេសុ ។ មិច្ឆាចារោតិ កិលេសកាមវសេន លាមកាចារោ ។** *ពាក្យថា* **កាមេសុ** *បានដល់វត្ថុកាមទាំងឡាយ ។ ពាក្យថា* **មិច្ឆាចារោ** *បានដល់ការប្រព្រឹត្តលាមក ដោយអំណាចកិលេសកាម ។*

**មុសាវាទាតិ អភូតវាទតោ ។** *ពាក្យថា* **មុសាវាទ** *បានដល់ វៀរចាក ពាក្យពិត ។*

**សុរាតិ បិដ្ឋសុរា បូវសុរា ឱទនសុរា កិណ្ណបក្ខិត្តា សម្ភារ-សំយុត្តាតិ បញ្ច សុរា ។** *ដែលហៅថា សុរា បានដល់សុរា ៥ ប្រភេទគឺ :*

**១-បិដ្ឋសុរា** *សុរាធ្វើដោយម្សៅ*

**២-បូវសុរា** *សុរាធ្វើដោយនំ*

**៣-ឱទនសុរា** *សុរាធ្វើ ដោយបាយ*

**៤-កិណ្ណបក្ខិត្តាសុរា** *ដែលគេដាក់ពូជសុរា*

**៥-សម្ភារសំយុត្តា** *សុរាដែលប្រកបព្រម ដោយគ្រឿងផ្សំផ្សេងៗ ។*

**មេរយន្តិ បុប្ផាសវោ ផលាសវោ គុឡាសវោ មធ្វាសវោ សម្ភារ-សំយុត្តោតិ បញ្ច អាសវា ។** *ដែលហៅថា មេរ័យ បានដល់មេរ័យ ៥ ប្រភេទគឺ :*

**១-បុប្ផាសវោ** *ទឹកត្រាំដែលគេធ្វើដោយផ្កាឈើ*

**២-ផលាសវោ** *ទឹកត្រាំ ដែលគេធ្វើដោយផ្លែឈើ*

**៣–គុឡាសវោ** *ទឹកត្រាំដែលគេធ្វើដោយទឹកអំពៅ*

**៤–មធ្វាសវោ** *ទឹកត្រាំដែលគេធ្វើដោយផ្លែចន្ទន៍ ឬគេធ្វើដោយទឹកឃ្មុំ*

**៥–សម្ភារសំយុត្តោ** *ទឹកត្រាំដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ ។*

**តទុភយម្បិ មទនីយដ្ឋេន មជ្ជំ ។ យាយ ចេតនាយ តំ បិវន្តិ សា បមាទការណត្តា បមាទដ្ឋានំ តស្មា សុរាមេរយមជ្ជប្បមាទដ្ឋានា ។**

*សុរានិងមេរ័យសូម្បីទាំងពីរនោះឈ្មោះថា* **មជ្ជៈ** *ព្រោះអត្ថថា ជាទីតាំងនៃសេចក្តីស្រវឹង ។ បុគ្គលទាំងឡាយរមែងផឹកសុរាឬមេរ័យនោះ ដោយចេតនាណា ចេតនានោះឈ្មោះថាជាទីតាំងនៃសេចក្តីប្រមាទ ព្រោះជាហេតុនាំឲ្យវង្វេងកាន់ ព្រោះហេតុនោះទីតាំងនៃសេចក្តីប្រមាទនោះ ទើបឈ្មោះថា រមែងមានព្រោះការផឹកទឹកស្រវឹង គឺសុរានិងមេរ័យ ។*

**វិកាលភោជនា** *គឺការបរិភោគភោជនាហារក្នុងកាលខុស ។*

**នច្ចគីតវិសូកទស្សនា** *គឺ* **នច្ច** *រាំ* **គីត** *ច្រៀង* **វិសូកទស្សនា** *មើលល្បែងដែលជាសត្រូវដល់កុសលធម៌ ។*

**មាលាគន្ធវិលេបនធារណាបណ្ឌនវិភូសនដ្ឋានា** *គឺ* **មាលា** *បានដល់ផ្កាឈើប្រភេទយ៉ាងណាមួយ ។ ពាក្យថា* **វិលេបន** *បានដល់របស់យ៉ាងណាមួយដែលគេចាត់ដើម្បីលាបលនកាយ ក្រៅពីនេះរបស់ក្រអូបមានលម្អិតខ្លឹមចន្ទន៍ជាដើមគ្រប់យ៉ាង ឈ្មោះថា* **គន្ធៈ។** *របស់ក្រអូបគ្រប់យ៉ាង ប្រើតាក់តែងប្រដាប់កាយមិនគួរ តែប្រើជាថ្នាំគួរ ។*

**ឧច្ចាសយនមហាសយនា** *គឺ* **ឧច្ចាសយនៈ** *ទីសេនាសនៈខ្ពស់ហួសប្រមាណ* **មហាសយនា** *ទីសេនាសនៈដ៏ប្រសើរ ទីដេកដែលជាអកប្បិយៈ និងគ្រឿងកម្រាលដែលជាអកប្បិយៈ ។*

**ជាតរូបរជតប្បដិគ្គហណា** *គឺពាក្យថា* **ជាតរូប** *បានដល់មាស ពាក្យថា* **រជតៈ** *បានដល់កហាបណៈ គឺរបស់ណាមួយ មានមាសកលោហៈ មាសកឈើនិងមាសកៈ ជ័ជ័រជាដើម ឬរបស់ណាដែលគេចាយវាយក្នុងប្រទេសនោះៗ ។ មាស និងប្រាក់ទាំងអស់នោះ ឈ្មោះថា* **ជាតរូប** ។ *ការទទួលយកនូវមាស និងប្រាក់នោះ ឈ្មោះថា* **បដិគ្គហណាៈ** *ការទទួល ។*

## អ្នកទ្រុស្តសីល និងអលជ្ជីសម្រាប់គ្រហស្ថសីល ៥

*អ្នកវៀរចាកការសម្លាប់សត្វជាដើម រហូតដល់ការវៀរចាកការផឹក សុរាមេរ័យ ជាទីបំផុតទាំងអស់នេះ ជាសីលប្រចាំសម្រាប់គ្រហស្ថទូទៅមិនរើសជាតិ វណ្ណៈ ជាន់ថ្នាក់និងសាសនាណាឡើយ ដូច្នោះបើអ្នកណាមានការវៀរ មិនប្រព្រឹត្តកន្លង ក៏បានឈ្មោះថាអ្នកនោះតាំងខ្លួននៅក្នុងគហដ្ឋសីល ។ បើអ្នកណាមិនមានការវៀរចាក ហើយបានប្រព្រឹត្តកន្លងសិក្ខាបទណាមួយ ឬទាំង ៥ សិក្ខាបទ អ្នកនោះឈ្មោះថា ជា***អ្នកទ្រុស្តសីល** *។ សម្រាប់គ្រហស្ថ ជា* **អលជ្ជី** *គឺគ្រហស្ថណាចូលចិត្តនិយាយពាក្យ ញុះញង់ ស៊កសៀត* **(បិសុណវាចា)** *ពោលពាក្យ ជេរប្រទេច***(ផរុសវាចា)** *ពោលពាក្យរោយរាយឥតប្រយោជន៍* **(សម្ផប្បលាប)** *ចូលចិត្តគិត លោភ សម្លឹងចង់បានរបស់គេ***(អភិជ្ឈា)** *និងគំនុំប្រទូសរ៉ាយគេ* **(ព្យាបាទ)** *ទាំងនេះក្តី និងជាអ្នកមិនពេញចិត្តបដិបត្តិ តាមមុខនាទីរបស់ខ្លួន តាមពាក្យប្រៀនប្រដៅរបស់ព្រះដ៏មានព្រះភាគដែលទ្រង់សម្តែងទុកក្នុង* **សិង្គាលោវាទសូត្រ នៅក្នុង**

***សុត្តន្តបាដិកវគ្គបាលី*** គឺ មិនបដិបត្តិតាមនាទី រវាង មាតាបិតា និងបុត្រ, ស្វាមី និងភរិយា, គ្រូ និងសិស្ស, ចៅហ្វាយនាយ និងខ្ញុំបម្រើ, មិត្ត និងមិត្ត, គ្រហស្ថ និងបព្វជិត, បើគ្រហស្ថនោះ មិន កំណត់ថា បុរស ឬស្ត្រី ជាតិ សាសនាអ្វីក៏ដោយ បើមិនមានសីលធម៌ ដូចពោលមកខាង លើនេះទេ ក៏បាន ឈ្មោះថា អ្នកនុះជា ***អលជ្ជី*** ។ តែបើគ្រហស្ថណា មិនចូលចិត្ត និយាយពាក្យ បិសុណវាចា ផរុសវាចា សម្ផប្បលាប មិនចូលចិត្តគិតរឿង អភិជ្ឈា ព្យាបាទ មានសេចក្តីត្រេកអរបដិបត្តិតាមនាទី គឺរវាង មាតាបិតា និងបុត្រ ស្វាមី និង ភរិយាជាដើមក្តី គ្រហស្ថនុះ ឈ្មោះថា ជា ***លជ្ជីបុគ្គល*** (បុគ្គលមានសេចក្តីខ្មាស) ។

ការសមាទានសីល ៥, សីល ៨ បែបជាអាជីវដ្ឋមក , សីល ៨ បែបជាឧបោសថ សីល ១០ ទាំងបួនប្រការ ដូចពោលមកនេះ បើអ្នកណា សមាទានសិក្ខាបទរួមគ្នា ហើយប្រព្រឹត្តកន្លងនូវសិក្ខាបទណាមួយ ក៏បានឈ្មោះថា ការរក្សាសីល ៥ សីល ៨ សីល ៨ សីល ១០ របស់អ្នកនុះ ត្រូវដាច់ព្រមគ្នាទាំងអស់ ត្រូវសមាទានសីលនោះ សាជាថ្មី ទាំងអស់មកវិញ ។ ចំណែកអ្នកសមាទានរាយមួយម្តងៗនោះ បើប្រព្រឹត្តកន្លងសិក្ខាបទ ណាមួយ ក៏ដាច់តែសិក្ខាបទនោះប៉ុណ្ណោះ ឯសិក្ខាបទដទៃៗ នៅគង់វង្សដដែលមិនដាច់ ឡើយ ដូច្នោះត្រូវសមាទានជាថ្មី ចំពោះតែសិក្ខាបទណាដែលដាច់ប៉ុណ្ណោះ ។

ម្យ៉ាងទៀត ការសមាទានរបស់អ្នកនោះ ឈ្មោះថា សីលបានតាំងទុកក្នុងចិត្ត ហើយ សមាទានតែម្តង ការសមាទានរបស់អ្នកនោះ ឈ្មោះថា សីលបានតាំង នៅរហូត តាមពេលដែលកំណត់ទុក ដូចជាអ្នកសមាទានសីល ៥ ឬសីល ៨ កំណត់ទុក ១ ត្រៃមាស ឬ ១ ខែ ឬ ១ បក្ខ ឬក៏ ១ សប្តាហ៍ក្តី ឬ ១ថ្ងៃ ១យប់ក្តី ទីបំផុតត្រឹមតែ កន្លះថ្ងៃក្តី កាលអធិដ្ឋានចិត្ត កំណត់ទុកដូច្នេះហើយ ក៏សមាទានសីលនោះទៅ ការ សមាទាននោះត្រូវតាំង ឈ្មោះថា ចប់ត្រឹមនោះឯង ។

សីល ៥ នេះជានិច្ចសីលរបស់យាវាសទាំងឡាយ ដូច្នេះអ្នកសមាទានក្តី មិនបានសមាទានក្តី ត្រូវតែរក្សាឲ្យជាប់ជាប្រក្រតី ដើម្បីធ្វើឲ្យជាអ្នកមានសីល ទោះបីមាន

អ្នកណា អះអាងថា ខ្ញុំមិនសមាទានសីល ៥ ទេ ដូច្នេះអ្នកនោះមិនរក្សា ក៏មិនមានទោស ក្នុងពាក្យនិយាយដូច្នេះ គ្រាន់តែជាពាក្យបញ្ជាក់ឲ្យអ្នកដទៃដឹងថា ខ្ញុំមិនចូលចិត្តសីល ៥ ប៉ុណ្ណោះ ថាជានិច្ចសីលរបស់ឃរាវាសទាំងឡាយប៉ុណ្ណោះ អ្នកនោះមិនខុសពីអ្នកទ្រុស្ត សីលទេ ចំណែកអ្នកសមាទានសីល ៥ ហើយរក្សានោះ បានប្រយោជន៍ច្រើនមួយ ជាន់ទៀត ពោលគឺក្រោយពីមានបញ្ចសីលកុសលហើយ នៅមានសមាទានកុសល កើតឡើងថែមទៀត ដោយហេតុនេះពុទ្ធសាសនិកជនទាំងឡាយ ទើបមានការនិយមការ សមាទានសីល ៥ ជាប់មករហូតដល់សព្វថ្ងៃនេះ។

## សីលពិសេសរបស់ឃរាវាសទាំងឡាយ

ការរក្សាសីលរបស់ឃរាវាសទាំងឡាយនោះ ក្រៅពីសីល ៥ សីល ៨ នៅមានសីល ផ្សេងៗទៀត ដែលអាចរក្សាបានដូចជា ៖ **អាជីវដ្ឋមកសីល** បានដល់ការវៀរចាក កាយទុច្ចរិត ៣ វចីទុច្ចរិត ៤ និងមិច្ឆាអាជីវៈ ១ ទាំងប្រាំបីនេះ ហៅថា អាជីវដ្ឋមកសីល ។ **ទសង្គសីល** បានដល់សិក្ខាបទ ១០ ដែលសាមណេររក្សានោះឯង និងកម្មបថ ១០ ។

## អាជីវដ្ឋមកសីល និងអ្នករក្សាបញ្ចសីលផ្សេងគ្នា

អាជីវដ្ឋមកសីលនេះ ក្នុង**វិសុទ្ធិមគ្គ** អដ្ឋកថា លោកហៅថា អាទិព្រហ្មចរិយកសីល សីលជាខាងដើមរបស់មគ្គព្រហ្មចរិយៈ មានន័យថា អាជីវដ្ឋមកសីលនេះ ជាបាទនៃការឲ្យ បានសម្រេចមគ្គផល ។

ម្យ៉ាងទៀតឃរាវាសទាំងឡាយ ដែលសមាទានអាជីវដ្ឋមកសីល ឬមិនបាន សមាទានក្តី បើមានការប្រព្រឹត្តកន្លងសិក្ខាបទណាមួយ ត្រូវមានទោសដូចគ្នា និងការ ប្រព្រឹត្តកន្លងបញ្ចសីល ក្នុងសីល ២ យ៉ាងនោះ បើអ្នកណារក្សាបញ្ចសីលជាប់ជានិច្ច

អ្នកនោះឈ្មោះថា អ្នកសប្បុរសធម្មតា បើរក្សាអាជីវដ្ឋមកសីលជាប់ជានិច្ច អ្នកនោះបាន ឈ្មោះថា ជាអ្នកសប្បុរសដ៏ពិសេស ។

## ចែកសីលដោយនិច្ចសីល និងអនិច្ចសីល

**និច្ចសីល** មានន័យថា សីលឯណា កាលធ្វើពិធីកម្មនោះចប់សម្រេចចុះ ក៏ដល់ព្រមដោយសីលនោះផង ដោយមិនបាច់មានការសមាទានថែមទៀតទេ អ្នកនោះត្រូវរក្សាសីលនោះឲ្យជាប់ជានិច្ច ចាប់ពីត្រឹមនោះទៅ បើមិនរក្សាត្រូវមានទោស សីលនោះឯង ឈ្មោះថា និច្ចសីល ។

**អនិច្ចសីល** មានន័យថា សីលឯណា បើមិនរក្សា ក៏មិនមានទោស តែបើមានបំណងចង់រក្សា ត្រូវតែសមាទានសីលនោះជាមុនសិន ដូច្នេះសីលនោះ ឈ្មោះថាអនិច្ចសីល ។

**និច្ចសីល** គឺសិក្ខាបទ ២២៧ និង ៣៣១ ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងទុកក្នុងភិក្ខុបាតិមោក្ខ និងភិក្ខុនីបាតិមោក្ខ ជានិច្ចសីលរបស់ភិក្ខុ ភិក្ខុនី ទសង្គសីល និងសេខិយ-សិក្ខាបទ ៧៥ នោះ ជានិច្ចសីលរបស់សាមណេរ ឧបោសថសីល ជានិច្ចសីលរបស់បណ្ឌរង្គឧបាសក ឧបាសិកា (ឧបាសក និងឧបាសិកាស្លៀកពាក់ស ហៅម្យ៉ាងទៀតថា តាជី ដូនជី) និងរបស់តាបសទាំងឡាយ សីល ៥ ជានិច្ចសីល របស់គ្រហស្ថទាំងឡាយ ។

**អនិច្ចសីល** គឺ ការប្រព្រឹត្តធុតង្គ ក្នុងធុតង្គទាំង ១៣ នេះជាអនិច្ចសីល របស់ភិក្ខុ ភិក្ខុនី សាមណេរ ការប្រព្រឹត្តធុតង្គយ៉ាងណាមួយ និងទសង្គសីលនោះ ជាអនិច្ចសីល របស់បណ្ឌរង្គបព្វជិត និងតាបសទាំងឡាយ ។

## ចែកសីលដោយចារិត្តសីល និងវារិត្តសីល

**ចារិត្តសីល** មានន័យថា មិនប្រព្រឹត្តក៏មិនមានទោស តែបើបានប្រព្រឹត្តល្អ មានប្រយោជន៍ច្រើន បានដល់អនិច្ចសីល ដូចដែលបានពោលមកហើយនោះឯង ។

**វារិត្តសីល** មានន័យថា បើសីលនេះត្រូវមានការប្រព្រឹត្តជាប់ជានិច្ច បើមិនប្រព្រឹត្តត្រូវមានទោស បានដល់និច្ចសីលនោះឯង ។

## លក្ខណៈ រស និងបដិក្ខេបធម៌

**១-បតិដ្ឋានលក្ខណំ** ជាទីតាំង នៃកុសលធម៌ទាំងពួងជា លក្ខណៈ ។

**២-ទុស្សីល្យវិទ្ធំសនរសំ** មានការកម្ចាត់បង់អ្នកទ្រុស្តសីលជាកិច្ច ។

**៣- សោចេយ្យបច្ចុបដ្ឋានំ** មានសេចក្តីបរិសុទ្ធកាយ និងវាចា ជាអាការប្រាកដ ។

**៤-ហិរោត្តប្បបទដ្ឋានំ** មានហិរិ ឱត្តប្បៈ ជាហេតុជិត ។

**១- បដិបក្ខេបធម្ម** ធម៌ដែលត្រូវប្រហារដោយសីលកុសល បានដល់ទោសៈដែលទាក់ទងដោយការប្រទូស្តរ៉ាយ ។

**២- អនុញ្ញាតធម្ម** ធម៌ដែលបានអនុញ្ញាតពីសីលឲ្យកើតឡើង នោះបានដល់អទោសៈ គឺសេចក្តីមិនប្រទូស្តរ៉ាយ ។

**៣- ឧប្បាទេតព្វធម្ម** ធម៌ដែលសីលធ្វើឲ្យកើតឡើង បានដល់មគ្គ ៣ ផល ៣ ខាងក្រោម (សំដៅយកអំណាចរបស់សីល ដែលជា ឧបត្ថម្ភកសត្តិ) ។

*សមដូចព្រះពុទ្ធឃោសាចារ្យ បានសម្តែងទុកក្នុងខន្ធវគ្គសំយុត្ត អដ្ឋកថា ថា* **"ទាន-សីលូបនិស្សយា ហិ តយោ មគ្គេ ច ផលានិ ចាបេន្តិ ភាវនូបនិស្សយោ អរហត្តំ ចាបេន្តិ"** *ប្រែថា "មហាកុសលដែលមានទាន សីល ជាឧបនិស្ស័យឲ្យកើតមគ្គថ្នាក់ទាប ៣ ផលថ្នាក់ទាប ៣ មហាកុសលដែលមានភាវនាជាឧបនិស្ស័យ រមែងឲ្យសម្រេចព្រះអរហត្តមគ្គ អរហត្តផល ។*

## អធិប្បាយសិក្ខាបទអាជីវដ្ឋមកសីល

*នៅក្នុងអាជីវដ្ឋមកសីលនេះ បានដល់កាយកម្ម ៣ វចីកម្ម ៤ និងអាជីវៈ១ ជាគម្រប់ ៨ ។ ខ្ញុំសូមលើកតែអាជីវសិក្ខាបទមកអធិប្បាយជាមុនសិន ។*

*គម្ពីរ**អង្គុត្តរនិកាយ** បញ្ចកនិបាត ត្រង់ឧបាសកវគ្គ វណិជ្ជសូត្រទី៧ បិដក៤៥ ទំព័រ១៦០ ព្រះអង្គទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ ជំនួញ ៥ យ៉ាងនេះ ឧបាសកមិនគួរធ្វើឡើយ ។*

**១-សត្ថវណិជ្ជា** *គឺការជួញគ្រឿងសស្ត្រាវុធ*

**២-សត្តវណិជ្ជា** *ការជួញមនុស្ស*

**៣-មំសវណិជ្ជា** *ការជួញ (សត្វដែលគេសម្លាប់យក)សាច់*

**៤-មជ្ជវណិជ្ជា** *ការជួញគ្រឿងស្រវឹង*

**៥-វិសវណិជ្ជា** *ការជួញថ្នាំពិស ។*

*ម្នាលភិក្ខុទាំងឡាយ ជំនួញ ៥ យ៉ាងនេះឯង ឧបាសកមិនគួរធ្វើឡើយ ។* **មនោរថ-បូរណី** *អដ្ឋកថា អំ. បញ្ចកនិបាត ត្រង់ឧបាសកវគ្គ វណិជ្ជសូត្រទី៧ បានពោលថា៖ ពាក្យថា:*

**វណិជ្ជា** បានដល់ធ្វើជំនួញ ។ ពាក្យថា **ឧបាសិកោឩ** បានដល់អ្នកដល់សរណៈ៣ ។ ពាក្យថា **សត្ថវណិជ្ជា** បានដល់ឲ្យគេធ្វើអាវុធ ហើយក៏លក់អាវុធ ។ ពាក្យថា **សត្តវណិជ្ជា** បានដល់លក់មនុស្ស ។ ពាក្យថា **មំសវណិជ្ជា** បានដល់ចិញ្ចឹមជ្រូក និងម្រឹគជាដើមលក់ ។ ពាក្យថា **មជ្ជវណិជ្ជា** បានដល់ឲ្យគេធ្វើរបស់ស្រវឹងយ៉ាងណានីមួយ ហើយក៏លក់របស់ស្រវឹង ។ ពាក្យថា **វិសវណិជ្ជា** បានដល់ឲ្យគេធ្វើថ្នាំពិសហើយក៏លក់ថ្នាំពិសនោះ ។ ការធ្វើដោយខ្លួនឯង ការបបួលអ្នកដទៃឲ្យធ្វើការជំនួញនេះទាំងអស់ ក៏មិនគួរដោយប្រការដូច្នេះ ។ ចំណែកសិក្ខាបទដ៏សេស គប្បីមើលក្នុងនិច្ចសីល និងកម្មបថ១០ ចុះ ។

## រឿងឧបោសថកម្ម

ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តបុព្វារាម ទ្រង់ប្រារព្ធឧបោសថកម្ម របស់ឧបាសិកាទាំងឡាយមាននាងវិសាខាជាដើម ត្រាស់ព្រះធម៌ទេសានានេះថា៖

**"យថា ទណ្ឌេន គោបាលោ"** ជាដើម ។

## ស្ត្រីរក្សាឧបោសថមានបំណងផលផ្សេងៗគ្នា

បានស្ដាប់មកក្នុងថ្ងៃឧបោសថមួយ ស្ត្រីប្រមាណ ៥០០ នាក់ ក្នុងនគរសាវត្ថី ជាអ្នករក្សាឧបោសថ បានទៅកាន់ព្រះវិហារ ។ នាងវិសាខាចូលទៅរកស្ត្រីចាស់ៗ ក្នុងចំនួនស្ត្រី ៥០០ នាក់នោះ ហើយសួរថា "នែព្រះម៉ែម្ចាស់ទាំងឡាយ ពួកនាងរក្សាឧបោសថដើម្បីអ្វី?" "កាលស្ត្រីចាស់ៗទាំងនោះប្រាប់ថា ពួកនាងខ្ញុំប្រាថ្នាទិព្វសម្បត្តិ ទើបរក្សាឧបោសថ" ។ សួរពួកស្ត្រីវ័យកណ្ដាល, កាលពួកស្ត្រីទាំងនោះ ប្រាប់ថា"ពួកនាងខ្ញុំរក្សាឧបោសថ ក៏ដើម្បីត្រូវការផុតចាកការនៅជាមួយស្ត្រីរួមស្វាមី" ។ សួរពួកស្ត្រីពេញវ័យៗ ។ កាលពួក

គេប្រាប់ថា "ពួកនាងខ្ញុំរក្សាឧបោសថ ដើម្បីត្រូវការបានបុត្រប្រុសក្នុងការមានគភ៌គ្រាដំបូង" ។ សួរពួកស្ត្រីវ័យជំទង់ៗ កាលពួកគេប្រាប់ថា "ពួកនាងខ្ញុំរក្សាឧបោសថ ដើម្បីត្រូវការទៅកាន់ត្រកូលប្តី ក្នុងវ័យក្រមុំៗ" ។ **ឧបាសិកាវិសាខា** បានស្តាប់ពាក្យសូម្បីតាំងអស់របស់ស្ត្រីទាំងនោះហើយ ក៏នាំពួកគេទៅកាន់សំណាក់ព្រះសាស្តា ក្រាបទូល(សេចក្តីបំណង របស់ស្ត្រីទាំងនោះ) តាមលំដាប់ ។

ព្រះសាស្តាទ្រង់ស្តាប់ពាក្យនោះហើយត្រាស់ថា "វិសាខា ធម្មតាសភាវធម៌ទាំងឡាយមានជាតិជាដើម របស់សត្វទាំងនេះ ប្រៀបដូចនាយគោបាលដែលមានដំបងក្នុងដៃ ។ ជាតិបញ្ជូនសព្វសត្វទៅកាន់សំណាក់ជរា ជរាបញ្ជូនទៅកាន់សំណាក់ព្យាធិ ព្យាធិបញ្ជូនទៅកាន់សំណាក់មរណៈ មរណៈរមែងកាត់ជីវិត ដូចបុគ្គលកាត់ដើមឈើដោយពូថៅ ។ បើដូច្នោះ សត្វទាំងអស់ ឈ្មោះថា ប្រាថ្នាវិវដ្ត (គឺព្រះនិព្វាន) រមែងមិនមាន ។ វល់តែប្រាថ្នាវដ្តប៉ុណ្ណោះ" ។ ដូចនេះហើយ ការទឹងទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់គាថា នេះថា៖

**យថា ទណ្ឌេន គោបាលោ គាវោ បាជេតិ គោចរំ**

**ឯវំ ជរា ច មច្ចុ ច អាយុំ បាជេន្តិ បាណិនំ។**

នាយគោបាល រមែងកៀងគោទាំងឡាយទៅកាន់ទីគោចរដោយដំបងឈើ
យ៉ាងណា, ជរា និងមច្ចុរមែងកៀងអាយុរបស់សត្វទាំងឡាយទៅ
ក៏ដូច្នោះដែរ ។

បណ្តាបទទាំងនោះ បទថា **បាជេតិ** សេចក្តីថា នាយគោបាលអ្នកឆ្លាត ការពារគោទាំងឡាយ ចូលទៅកាន់រវាងភ្លឺស្រែដោយដំបងឈើ វាយដោយដំបងឈើនោះៗឯង នាំទៅហើយ ឈ្មោះថា រមែង(កៀងគោទាំងឡាយ) ទៅកាន់ទីរកស៊ីដែលមានស្មៅ និងទឹកបានងាយ ។

ពីបទថា **អាយុំ ចាជេន្តិ** សេចក្ដីថា រមែងកាត់ឥន្ទ្រិយគឺជីវិត គឺរមែងញ៉ាំង ជីវិតិន្ទ្រិយឲ្យអស់ទៅ ។ ក្នុងព្រះគាថានេះ មានពាក្យឧបមាឧបមេយ្យដូច្នេះថា គឺជរា និងមច្ចុ ប្រៀបដូចនាយគោបាល, ឥន្ទ្រិយគឺជីវិត ប្រៀបដូចហ្វូងគោ មរណៈ ប្រៀបដូចស្ថានទីរកស៊ី ។ បណ្ដាសភាវធម៌ទាំងនោះ ជាតិបញ្ជូនឥន្ទ្រិយគឺជីវិត របស់សត្វទាំងឡាយទៅកាន់សំណាក់ជរា ជរាបញ្ជូនទៅកាន់សំណាក់ព្យាធិ ព្យាធិបញ្ជូនទៅកាន់សំណាក់មរណៈ, មរណៈនោះឯងកាត់ (ជីវិតិន្ទ្រិយរបស់សត្វទាំងឡាយ)ទៅ ដូចបុគ្គលកាត់ដើមឈើដោយពូថៅ ដូច្នេះ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចាកខុទ្ទកនិកាយ គាថាធម្មបទ ត្រង់ទណ្ឌវគ្គ

## ពណ៌នាឧបោសថ ៣ ប្រភេទ

ឧបោសថដែលប្រៀបដោយនាយគង្វាលគោ ព្រោះមានសេចក្ដីវិតក្កថា នឹងមិនបរិសុទ្ធិ ឈ្មោះថា **គោបាលកឧបោសថ**។

ឧបោសថគឺការរក្សារបស់ពួកនិគ្រន្ថទាំងឡាយឈ្មោះថា **និគណ្ឋឧបោសថ**។

ឧបោសថគឺការរក្សារបស់ព្រះអរិយទាំងឡាយឈ្មោះថា **អរិយឧបោសថ**។

ពិតណាស់ នាយគង្វាលគោទទួលគោមករក្សា ព្រោះតម្លៃឈ្នួលរាល់ថ្ងៃ ដោយកំណត់ទុកថា ៥ ថ្ងៃ ១០ ថ្ងៃ កន្លះខែ ១ ខែ ៦ ខែ ឬ ១ ឆ្នាំ ពេលដល់គ្រប់កំណត់ហើយ ទើបប្រាប់ដល់ម្ចាស់គោ ដើម្បីគិតថ្ងៃឈ្នួល យ៉ាងនេះទើប ឈ្មោះថា **គោបាលកុបោសថោ** ។ ព្រោះតែមានវិតក្កមិនបរិសុទ្ធិ ទើបនៅក្នុងឋានៈ នៃគោបាលក

ឧបោសថប៉ុណ្ណោះ ការរក្សាយ៉ាងនេះ មិនមានផលច្រើន បទថា **ន មហប្ផលោ** សេចក្តីថា មិនមានផលច្រើន ព្រោះផលគឺវិបាក ។ មិនមានអានិសង្សច្រើន បទថា **ន មហានិសំសោ** សេចក្តីថា ឈ្មោះថា មិនមានអានិសង្សច្រើន ព្រោះអានិសង្ស គឺវិបាក ។ មិនមានពន្លឺច្រើន បទថា **ន មហាជុតិកោ** សេចក្តីថា មិនមានពន្លឺច្រើន ព្រោះពន្លឺ គឺវិបាក ។ មិនផ្សាយទៅ បទថា **ន មហាវិប្ផារោ** សេចក្តីថា ឈ្មោះថា មិនផ្សាយទៅច្រើន ព្រោះកាលផ្សាយទៅនៃវិបាកមិនមានច្រើន ។

ចំណែកអ្នករក្សា **និគណ្ឋឧបោសថ** គប្បីជ្រាបថា មិនមានផលឡើយ ។

<u>សួរថា</u> ព្រោះហេតុអ្វី ព្រះដ៏មានព្រះភាគ ទើបត្រាស់ពាក្យនេះទុកថា ចិត្តសៅហ្មងហើយ ?

<u>ឆ្លើយថា</u> ព្រោះថា ឧបោសថ ដែលអ្នកមានចិត្តបរិសុទ្ធិរក្សាហើយ មានផលច្រើន ជាការដែលព្រះអង្គទ្រង់អនុញ្ញាតហើយ ព្រោះទ្រង់សម្តែងទុកថា ឧបោសថដែលអ្នកមានចិត្តសៅហ្មងរក្សាហើយ រមែងមិនមានផលច្រើន ។ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគជាម្ចាស់ បានត្រាស់ពាក្យនេះទុក ដើម្បីទ្រង់សម្តែងកម្មដ្ឋានដែលជាហេតុឲ្យចិត្តបរិសុទ្ធិ គឺកម្មដ្ឋានដែលជាហេតុជម្រះចិត្ត ។ ដូចមាន បាលីថា **តថាគតំ អនុស្សរតិ** សេចក្តីថា រលឹកដល់ព្រះគុណរបស់ព្រះតថាគត ដោយហេតុ ៨ ប្រការ ។ ក៏ក្នុងពាក្យថា **តថាគតំ អនុស្សរតិ** នេះ លោកសង្គ្រោះយកព្រះពុទ្ធគុណទាំងអស់ ទាំងដែលជាលោកិយ និងលោកុត្តរៈ ទុកដោយពាក្យថា **ឥតិបិ សោ ភគវា** ដែលមានសេចក្តីអធិប្បាយថា ព្រោះសីលសូម្បីនេះ ព្រះដ៏មានព្រះភាគជាម្ចាស់អង្គនោះ ព្រោះសមាធិសូម្បីនេះ ព្រះដ៏មានព្រះភាគជាម្ចាស់អង្គនោះ ទ្រង់សម្តែងគុណដែលជាចំណែកព្រះអង្គ

ប៉ុណ្ណោះ ដោយមានពាក្យជាដើមថា **អរហំ** ដូចនេះ ។ ពាក្យថា **តថាគតំ អនុស្សរតោ ចិត្តំ បសីទតិ** សេចក្តីថា កាលបុគ្គលរលឹកដល់ព្រះគុណរបស់ព្រះតថាគត ទាំងដែលជាលោកិយៈ និង លោកុត្តរៈ ចិត្តុប្បាទរមែងថ្លាផង់ ។

ពិតណាស់ ព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះ ដោយមានព្រះពុទ្ធបំណងថា បើប្រដាប់គ្រឿងប្រដាប់ទុកលើក្បាលមិនស្អាត អ្នកលេងសិល្បៈរមែងមិនស្អាត តែបើប្រដាប់គ្រឿង ប្រដាប់ទុកលើក្បាលស្អាត អ្នកលេងសិល្បៈរមែងស្អាត ។ យ៉ាងណាមិញ អ្នករក្សាឧបោសថ មានចិត្តសៅហ្មង អធិដ្ឋានអង្គឧបោសថហើយរក្សា នឹងមិនមានផលច្រើន តែថាអ្នករក្សាឧបោសថ ដែលមានចិត្តស្អាតថ្លាផង់ អធិដ្ឋានអង្គឧបោសថហើយរក្សារមែងមានផលច្រើន ។

ពាក្យថា **បាណាតិបាត** បានដល់ការសម្លាប់សត្វ ។

ពាក្យថា **បហាយ** សេចក្តីថា លះភាពទ្រុស្តសីល ពោលគឺចេតនាជាហេតុសម្លាប់សត្វនោះ ។

ពាក្យថា **បដិវិរតោ** សេចក្តីថាវៀរ គឺវៀរចាកភាពជាអ្នកទ្រុស្តសីលនោះ តាំងតែវេលាដែលលះបានហើយ ។

បទថា **និហិតទណ្ឌោ និហិតសត្ថោ** មានអធិប្បាយថា ទាំងចោលដំបងឈើទាំងចោលសស្ត្រា ព្រោះមិនកាន់ដំបងឈើ ឬសស្ត្រាប្រព្រឹត្តទៅដើម្បីសម្លាប់អ្នកដទៃ ។ វៀរដំបងឈើចេញហើយ ឧបករណ៍ដ៏សេសទាំងអស់ គប្បីជ្រាបថា ឈ្មោះថាសស្ត្រា ក្នុងបទថា **និហិតទណ្ឌោ និហិតសត្ថោ** នេះ ព្រោះញ៉ាំងសត្វទាំងឡាយឲ្យវិនាស ។ ចំណែក កាលដែលភិក្ខុកាន់ឈើច្រត់ មនុស្សចាស់ ឈើស្ទួចសម្រាប់ជម្រះធ្មេញ ឬកន្ត្រៃ មិនមែនដើម្បីត្រូវការសម្លាប់អ្នកដទៃ ព្រោះដូច្នោះ ភិក្ខុទាំងនោះចាត់ថា ដាក់ចុះនូវដំបង

ឈើហើយ ដាក់ចុះនូវសស្ត្រាហើយដូចគ្នា ។ ពាក្យថា **លជ្ជី** សេចក្តីថា ប្រកបដោយសេចក្តីខ្មាស មានសេចក្តីរង្កៀសបាប ជាលក្ខណៈ ។ ពាក្យថា **ទយាបន្នោ** សេចក្តីថា សូម្បីដល់ការអាណិត គឺសេចក្តីជាអ្នកមានមេត្តាចិត្ត ។ ពាក្យថា **សព្វបាណភូតហិតា-នុកម្បី** សេចក្តីថា អនុគ្រោះសត្វមានជីវិតទាំងពួង ដោយប្រយោជន៍ដល់ការទំនុកបម្រុង អធិប្បាយថា មានចិត្តអនុគ្រោះពពួកសត្វមានជីវិតទាំងពួង ព្រោះភាពជាអ្នកមានចិត្តអាណិតនោះឯង ។ ពាក្យថា **អរហតំ អនុករោមិ** សេចក្តីថា ការដើរតាមក្រោយ អ្នកដើរទៅខាងមុខ ឈ្មោះថាដើរតាមយ៉ាងណា សូម្បីយើងក៏ដូច្នោះ ដើម្បីបំពេញគុណគឺសេចក្តីល្អនេះ តាមខាងក្រោយដែលព្រះអរហន្តទាំងឡាយ លោកបំពេញមកមុន ឈ្មោះថាចម្រើនតាមស្នាមនៃព្រះអរហន្តទាំងនោះ។ ពាក្យថា **ឧបោសថោ ច មេ ឧបវុត្ថោ** សេចក្តីថា ការដែលយើងធ្វើយ៉ាងនេះ នឹងជាការឈ្មោះថា ចម្រើនតាម ព្រះអរហន្តផងនឹងឈ្មោះថា ជាការរក្សាឧបោសថផង ។

ការកាន់យកវត្ថុដែលម្ចាស់មិនបានឲ្យ គឺដែលអ្នកដទៃហួងហែង ឈ្មោះថា **អទិន្នា-ទាន** អធិប្បាយថា បានដល់ការលួច គឺការងាររបស់ចោរ ។ ឈ្មោះថា **ទិន្នាទាយី** ព្រោះកាន់យកសូម្បីដោយចិត្តចំពោះរបស់ដែលគេឲ្យ ។ ឈ្មោះថា **ថេនៈ** ព្រោះលួច ឈ្មោះថា **អថេន** ព្រោះមិនលួច ឈ្មោះថា ជាអ្នកស្អាត ព្រោះមិនលួចនោះឯង ។ ពាក្យថា **អត្តនា** បានដល់មានអត្តភាព លោកអធិប្បាយថា ធ្វើអត្តភាពដែលមិនលួចឲ្យស្អាតហើយ ។

បទថា **អព្រហ្មចរិយំ** បានដល់ការប្រព្រឹត្តដែលមិនប្រសើរ ។ ឈ្មោះថា **ព្រហ្មចារី** ព្រោះប្រព្រឹត្តធម៌ដ៏ប្រសើរ គឺអាចារៈដ៏ខ្ពង់ខ្ពស់ ។ ពាក្យថា **អាចារី** សេចក្តីថា ឈ្មោះថា មានអាចារៈអាក្រក់ ព្រោះមិនប្រព្រឹត្តធម៌ដ៏ប្រសើរ ។ ពាក្យថា **មេថុនា** បានដល់អសទ្ធម្ម ដែលរាប់ថាជាមេថុន ព្រោះការសេពដោយធម៌ដែលមាន ឈ្មោះថា **មេថុន** ព្រោះធ្វើឲ្យកិលេសរំខានចិត្ត ពោលគឺរាគៈ ។ ពាក្យថា **គាមធម្មា** បានដល់ធម៌របស់អ្នកស្រុក ។

បទថា **មុសាវាទា** សេចក្តីថា ការនិយាយឡេះឡោះ គឺនិយាយពាក្យឥតប្រយោជន៍ ឈ្មោះថា **សច្ចវាទី** ព្រោះនិយាយពាក្យពិត ។ ឈ្មោះថា **សច្ចសន្ធា** ព្រោះបន្តសច្ចៈ ដោយសច្ចៈ អធិប្បាយថា មិននិយាយកុហកក្នុងចន្លោះៗ ។ ព្រោះថា បុគ្គលខ្លះ ពេលខ្លះនិយាយកុហក ពេលខ្លះនិយាយពិត បុគ្គលនោះ ឈ្មោះថា មិនបន្តសច្ចៈ ដោយសច្ចៈ ព្រោះមានមុសាវាទមកឃាំង ។ ព្រោះដូច្នោះ បុគ្គលនោះ ទើបមិនឈ្មោះថា មានសច្ចៈជាប់តគ្នា ។ តែបុគ្គលទាំងនេះ មានឈ្មោះថា បន្តពាក្យពិតដោយពាក្យពិត តែម្យ៉ាង ដោយមិនព្រមនិយាយកុហក សូម្បីព្រោះហេតុនៃជីវិត ព្រោះដូច្នោះទើបឈ្មោះថា មានសច្ចៈជាប់តគ្នា ។ ពាក្យថា **ថេតា** ប្រែថា មាំទាំ អធិប្បាយថា មានពាក្យសម្តីមាំទាំ ។ បុគ្គលណាមួយ ជាអ្នកមិនមានពាក្យសម្តីមាំទាំ ប្រៀបបីដូច កំណាត់សំពត់ ឬក៏បង្គោលដែលបោះទុកលើគំនរអង្កាម និងប្រៀបបីដូចផ្លែឃ្លោកដែលដាក់ទុកលើខ្នងសេះ តែបុគ្គលម្នាក់ទៀត មានពាក្យសម្តីមាំទាំ ប្រៀបបីដូចស្នាមចារឹកអក្សរលើផែនថ្ម និងប្រៀបបីដូចសសរថ្ម ដែលគេបោះទុកយ៉ាងមាំ សូម្បីនឹងយកដាវមកកាត់ក្បាលក៏មិនព្រមនិយាយជាពាក្យពីរ ។ បុគ្គលនេះឈ្មោះថា **ថេត ។** មានពាក្យសម្តីមាំទាំ ។ ពាក្យថា **បច្ចយិកា** បានដល់ការដាក់ចិត្តបាន អធិប្បាយថា ជឿកាន់បាន ព្រោះបុគ្គលខ្លះ ជឿកាន់យកមិនបាន

គឺកាលត្រូវគេសួរថា ពាក្យនេះបុគ្គលណានិយាយ តបថាបុគ្គលនោះនិយាយ ក៏សូម្បីមានអ្នកដែលគេនិយាយថា កុំជឿពាក្យនិយាយរបស់បុគ្គលនោះ តែបុគ្គលម្នាក់ទៀត និយាយគួរឲ្យជឿកាន់យកបាន គឺកាលត្រូវគេសួរថា ពាក្យនេះ បុគ្គលណានិយាយ ក៏តបថាបុគ្គលនោះនិយាយ ក៏នឹងសូម្បីការទទួលរងថា បើបុគ្គលនោះនិយាយ ១-នេះក៏កាន់យកជាប្រមាណបាន ឥឡូវនេះមិនមាន ១-ដែលនឹងត្រូវជំទាស់ ពាក្យនេះជាយ៉ាងនេះយ៉ាងនោះ ។ បុគ្គលនេះហៅថា ជាទីទុកចិត្តបាន ។ ពាក្យថា **អវិសំ វាទកោ លោកស្ស** មានអធិប្បាយថា មិននិយាយបោកប្រាស ព្រោះនិយាយតែពាក្យពិតប៉ុណ្ណោះ ។

ហេតុនៃសេចក្ដីប្រមាទ ពោលគឺចេតនាដែលផឹកទឹកស្រវឹង គឺសុរានិងមេរ័យ ឈ្មោះថា **សុរាមេរយមជ្ជបមាទដ្ឋាន។**

បទថា **ឯកភត្តិកា** សេចក្ដីថា អាហារមាន ២ វេលា គឺអាហារដែលនឹង ត្រូវទទួលទានក្នុងវេលាព្រឹក ១ អាហារដែលនឹងត្រូវទទួលទានក្នុងវេលាល្ងាច ១ បណ្ដាអាហារទាំងពីរយ៉ាងនោះ អាហារដែលទទួលទានក្នុងវេលាព្រឹក កំណត់ដោយវេលាខាងក្នុងថ្ងៃត្រង់ ចំណែកអាហារដែលទទួលទានក្នុងវេលាល្ងាចក្រៅនេះ កំណត់ដោយវេលាថ្ងៃជ្រេទៅ រហូតដល់អរុណរះឡើង ។ ព្រោះដូច្នោះក្នុងវេលាខាងក្នុងថ្ងៃត្រង់ សូម្បីនឹងទទួលទាន ១០ ដង ក៏ឈ្មោះថា មានការទទួលទានអាហារវេលាមួយ ។ ព្រះដ៏មានព្រះភាគត្រាស់ទុកថា **ឯកភត្តិកា** ទ្រង់សំដៅដល់ ការទទួលទានអាហារខាងក្នុងវេលាថ្ងៃត្រង់ ។ ការទទួលទានអាហារក្នុងវេលាកណ្ដាលយប់ ឈ្មោះថា **រាត្តិ** បុគ្គលអ្នកវៀរចាកការទទួលទានអាហារក្នុងវេលាកណ្ដាលយប់នោះ ព្រោះដូច្នោះទើបឈ្មោះថា **រត្តូបរតា ។** ការទទួលទានអាហារក្នុងវេលាថ្ងៃជ្រេទៅ រហូតដល់វេលាព្រះអាទិត្យលិចចុះ ឈ្មោះថា

ការ ទទួលទានអាហារក្នុងវេលាវិកាល បុគ្គលឈ្មោះថា វៀរចាកវិកាលភោជន ព្រោះវៀរចាកទទួលទានអាហារក្នុងវេលាវិកាលនោះ ។

ការមើលដែលឈ្មោះថា ជាសត្រូវដល់កុសលធម៌គឺជាសត្រូវ ព្រោះអនុលោមតាមពាក្យប្រៀនប្រដៅមិនបាន (ជំទាស់នឹងសាសនា) ព្រោះដូច្នោះទើប ឈ្មោះថា **វិសូក–ទស្សនៈ** ការរាំ ការច្រៀង ការប្រគុំតន្ត្រី សូម្បីដោយអំណាច នៃការរាំដោយខ្លួនឯង និងការឲ្យអ្នកដទៃរាំជាដើម និងការមើល ការរាំជាដើម ដែលប្រព្រឹត្តទៅហើយ ដោយហោចទៅ សូម្បីដោយអំណាចនៃការរាំរបស់សត្វទាំងឡាយជាដើម ដែលជាសត្រូវដល់កុសលធម៌ ព្រោះដូច្នោះ ទើបឈ្មោះថា **នច្ចគីតវាទិតវិសូកទស្សនៈ** ។ ក៏ការប្រកបការរាំជាដើម ដោយខ្លួនឯងក្តី ការឲ្យអ្នកដទៃប្រកបក្តី ការមើលការរាំជាដើម ដែលគេប្រកបហើយក្តី មិនគួរដល់ភិក្ខុ ភិក្ខុនីឡើយ (ដោយហោចទៅសូម្បីឧបាសក ឧបាសិកាអ្នករក្សាសីល ៨ ) ។

ក្នុងបណ្តាមាលាជាដើម ផ្កាឈើយ៉ាងណាមួយ ឈ្មោះថា **មាលា** ។ គន្ធជាតិយ៉ាងណាមួយ ឈ្មោះថា របស់ក្រអូប ។ គ្រឿងលាបស្បែក ឈ្មោះថា **វិលេបន** ។ ក្នុងបណ្តាវត្ថុទាំងនោះ ការប្រដាប់កាយ ឈ្មោះថា ទ្រទ្រង់ ។ ការសម្អាងកាយ ឈ្មោះថាតាក់តែង ។ ការត្រេកអរដោយរបស់ក្រអូបក្តី ដោយគ្រឿងលាបក្តី ឈ្មោះថា គ្រឿងប្រដាប់កាយ ។ ហេតុនោះព្រះដ៏មានព្រះភាគទើបត្រាស់ថា **ឋាន** អធិប្បាយថាព្រោះដូច្នោះ មហាជនធ្វើការទ្រទ្រង់ផ្កាឈើ ជាដើមដោយចេតនាគឺភាព ជាអ្នកទ្រុស្តសីលយ៉ាងណា ព្រះអរហន្តទាំងឡាយជាអ្នកវៀរចាកចេតនាទ្រុស្តសីលនោះ ។

ទីអង្គុយ ទីដេក ហួសប្រមាណហៅថា **ឧច្ចាសយន ។** គ្រឿងកម្រាលដែលជា អកប្បិយ (មិនសមគួរ) ឈ្មោះថា **មហាសយន** អធិប្បាយថា ព្រះអរហន្តទាំងឡាយ ជាអ្នកវៀរចាកទីអង្គុយ ទីដេកខ្ពស់ និងទីអង្គុយ ទីដេកដ៏ប្រសើរនោះ ។ ពាក្យថា **បហុតរត្តរតនានំ**សេចក្តីថា ប្រកបដោយរតនៈ ពោលគឺកែវច្រើនប្រការ ។

ពាក្យថា **កលំ នាគ្ឃតិ សោលសឹ** សេចក្តីថា បែងចែកបុណ្យក្នុងការរក្សា ឧបោសថ រហូតមួយថ្ងៃមួយយប់ ចែកជា ១៦ ចំណែកហើយ សម្បត្តិស្តេចចក្រពត្តិ នៅ មានតម្លៃមិនដល់មួយចំណែក នៃ ១៦ ចំណែកនោះ អធិប្បាយថាផលវិបាករបស់ចំណែក ទី ១៦ របស់ឧបោសថមួយយប់ ច្រើនជាងសម្បត្តិស្តេចចក្រពត្តិទៅទៀត ។

*អង្គុត្តរនិកាយ តិកនិបាត បិដក៤១/២៥៩ បានសម្តែងអំពីឧបោសថផ្សេងទៀតថា៖*

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងប្រាសាទរបស់មិគារមាតា ក្នុងវត្ត បុព្វារាម ទៀបក្រុងសាវត្ថី ។ គ្រានោះ ថ្ងៃនោះជាថ្ងៃឧបោសថសីល នាងវិសាខាមិគារមាតា ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះនាងវិសាខាមិគារមាតា អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគបានត្រាស់ដូច្នេះថា ម្នាលនាងវិសាខា ចុះនាងមកពីណាទាំងថ្ងៃម៉្លេះ ។ នាងវិសាខាក្រាបបង្គំទូលថា ថ្ងៃនេះខ្ញុំម្ចាស់រក្សាឧបោសថព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ត្រាស់ថា ម្នាលនាងវិសាខា ឧបោសថ នេះមាន ៣ យ៉ាង ។ ឧបោសថ ៣ យ៉ាងតើដូចម្តេច ។ គឺ **គោបាលកុបោសថៈ** (ឧបោសថរបស់គង្វាលគោ)១ **និគណ្ឋុបោសថៈ** (ឧបោសថ របស់និគ្រណ្ឋ)១ **អរិយុបោសថៈ** (ឧបោសថរបស់ព្រះអរិយៈ)១ ។ ម្នាលនាងវិសាខា ចុះ **គោបាលកុបោសថៈ** តើដូចម្តេច ។ ម្នាលនាងវិសាខាដូចគង្វាលគោ ប្រគល់គោទាំង ឡាយ ដល់អ្នកម្ចាស់គោ ក្នុងវេលាល្ងាចរួចហើយ គិតរំពឹងដូច្នេះថា ថ្ងៃនេះគោទាំងឡាយ

ត្រាច់រកស៊ីក្នុងទីឯណោះៗ ផឹកទឹកក្នុងទីឯណោះៗ ស្អែកនេះ គោទាំងឡាយនឹងត្រាច់ទៅរកស៊ីក្នុងទីឯណោះៗ នឹងផឹកទឹកក្នុងទីឯណោះៗ យ៉ាងណាមិញ ។ ម្នាលនាងវិសាខា បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នករក្សាឧបោសថសីលហើយ គិតជញ្ជឹង ដូច្នេះថាក្នុងថ្ងៃនេះ អាត្មាអញបានទំពាស៊ី នូវខាទនីយៈនេះផងៗ អាត្មាអញបានបរិភោគនូវភោជនីយៈនេះផងៗ ស្អែកនេះ អាត្មាអញនឹងទំពាស៊ីនូវខាទនីយៈនេះផងៗ នឹងបរិភោគនូវខាទនីយៈនេះផងៗ បុគ្គលនោះ មានចិត្តប្រកបដោយអភិជ្ឈា តែងញុំាងថ្ងៃឲ្យប្រព្រឹត្តកន្លងទៅ ដោយលោភៈនោះក៏យ៉ាងនោះឯង ។ ម្នាលនាងវិសាខា យ៉ាងនេះឯងឈ្មោះថា **គោបាលកុបោសថៈ ។**

ម្នាលនាងវិសាខា គោបាលកុបោសថ ដែលបុគ្គលរក្សាយ៉ាងនេះ ជាឧបោសថ មិនមានផលច្រើន មិនមានអានិសង្សច្រើន មិនមានសេចក្តីរុងរឿងច្រើន មិនផ្សាយផលច្រើនទេ ។ ម្នាលនាងវិសាខា ចុះ **និគណ្ឋុបោសថៈ** តើដូចម្តេច ។ ម្នាលនាងវិសាខា មានពួកសមណៈហៅថា **និគណ្ឋៈ** សមណៈអម្បាលនោះ តែងដឹកនាំសាវកយ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកចូរមកឲ្យសត្វទាំងឡាយណា មាននៅក្នុងទិសខាងកើតខាង នាយពី១០០យោជន៍ទៅ អ្នកចូរដាក់អាជ្ញា (សម្លាប់) សត្វអម្បាលនោះចុះ សត្វ ទាំងឡាយណា មាននៅក្នុងទិសខាងលិច ខាងនាយពី ១០០ យោជន៍ទៅ អ្នកចូរដាក់អាជ្ញាក្នុងសត្វអម្បាលនោះចុះ សត្វទាំងឡាយណា មាននៅក្នុងទិសខាងជើង ខាងនាយពី១០០ យោជន៍ទៅអ្នកចូរដាក់អាជ្ញាក្នុងសត្វអម្បាលនោះចុះ សត្វទាំងឡាយណា មាននៅក្នុងទិសខាងត្បូង ខាងនាយពី ១០០ យោជន៍ទៅ អ្នកចូរដាក់អាជ្ញា ក្នុងសត្វអម្បាលនោះចុះ ។ ពួកនិគ្រណ្ឋ តែងដឹកនាំសាវកឲ្យអាណិត អនុគ្រោះចំពោះពួកសត្វខ្លះ តែងដឹកនាំសាវក មិនឲ្យអាណិត មិនឲ្យអនុគ្រោះចំពោះពួកសត្វខ្លះ ។ ក្នុងថ្ងៃឧបោសថនោះ គេតែងដឹកនាំសាវកយ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកចូរមកអាយ អ្នកចូរស្រាតសំពត់ឲ្យអស់ ហើយពោលយ៉ាងនេះថា អាត្មាអញ មិនទាក់ទាមនឹងនរណាៗ ក្នុងទីណាៗ នឹងមានកង្វល់ក្នុងរបស់អ្វីៗ ក្នុងទីណាៗ

ក៏មិនមានដល់អាត្មាអញឡើយ តែមាតាបិតារបស់គេក៏ដឹងថា នេះបុត្ររបស់អញ ទាំងខ្លួនគេក៏ដឹងថា នេះមាតាបិតារបស់អញ បុត្រភរិយារបស់គេក៏ដឹងថា នេះជាស្វាមីរបស់អញ ទាំងខ្លួនគេក៏ដឹងថា នេះជាបុត្រ ភរិយារបស់អញ ពួកបុរសជាទាសកម្មកររបស់គេក៏ដឹងថា នេះជាម្ចាស់របស់អញ ទាំងខ្លួនគេក៏ដឹងថា នេះជាពួកបុរសដែលជាទាសកម្មកររបស់អញ (សាវកទាំងនោះ) ត្រូវគេដឹកនាំក្នុងសច្ចៈដូច្នេះ ក្នុងសម័យណា (អ្នកដឹកនាំ) ឈ្មោះថាដឹកនាំក្នុងមុសាវាទ ក្នុងសម័យនោះ ។ តថាគតពោលថា ពាក្យដឹកនាំនេះជាពាក្យមុសាវាទរបស់គេ ។ លុះកន្លងរាត្រីនោះហើយ គេបរិភោគភោគៈទាំងអម្បាលនោះ ដែលម្ចាស់គេមិនបានឲ្យ ។ តថាគតពោលថា ការបរិភោគនេះ ជាអទិន្នាទានរបស់គេ ។ ម្នាលនាងវិសាខា យ៉ាងនេះឯង ឈ្មោះថា **និគណ្ឋុបោសថ** ។ ម្នាលនាងវិសាខា និគណ្ឋុបោសថដែលគេរក្សាយ៉ាងនេះ ជាឧបោសថមិនមានផលច្រើន មិនមានអានិសង្សច្រើន មិនមានសេចក្តីរុងរឿងច្រើន មិនផ្សាយផលច្រើនទេ ។ ម្នាលនាងវិសាខា ចុះ **អរិយុបោសថ** តើដូចម្តេច ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមតើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ តែងរឭករឿយៗនូវព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាក សេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ព្រះអង្គមានដំណើរល្អ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាសារថី អ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ កាលអរិយសាវកនោះកំពុងរឭកនូវព្រះតថាគត ចិត្តរមែងជ្រះថ្លា សេចក្តីរីករាយ រមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។

ម្នាលនាងវិសាខា ដូចការជម្រះក្បាលដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការជម្រះក្បាល ដែលមិនស្អាតឲ្យស្អាតបាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា ការអាស្រ័យកាក (កន្ទួត ព្រៃ)ផង អាស្រ័យដីផង អាស្រ័យទឹកផង អាស្រ័យសេចក្តីព្យាយាមដ៏សមគួរដល់កិច្ចនោះ ដោយសេចក្តីព្យាយាម យ៉ាងនេះ យ៉ាងណាមិញ ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមក៏យ៉ាងនោះដែរ ។ ម្នាលនាងវិសាខា ចុះការ ធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់ ដោយសេចក្តីព្យាយាមតើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវក ក្នុងធម្មវិន័យនេះ តែងរឭករឿយៗនូវព្រះតថាគតថា ព្រះដ៏មានព្រះភាគ អង្គនោះ ។ ប ។ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ កាលអរិយសាវកនោះ កំពុងរឭករឿយៗ នូវព្រះតថាគត ចិត្តរមែងជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។

ម្នាលនាងវិសាខា អរិយសាវកនេះហៅថា រក្សា **ព្រហ្មុបោសថ** (ឧបោសថរបស់ព្រហ្ម) នៅរួមនឹងព្រហ្មចិត្តរបស់គេប្រារព្ធចំពោះព្រហ្ម រមែងជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមយ៉ាងនេះ ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ តែងរឭករឿយៗ នូវព្រះធម៌ដែលថា ព្រះធម៌ដែលព្រះដ៏មានព្រះភាគត្រាស់ប្រពៃហើយ ជាធម៌ដែលបុគ្គលប្រតិបត្តិ គប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរហៅអ្នកដទៃឲ្យចូលមកមើលបាន ជាធម៌គួរបង្អោនចូលមកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជន គប្បីដឹងចំពោះខ្លួន ។ កាលអរិយសាវកនោះ កំពុងរឭកនូវព្រះធម៌

ចិត្តរមែងជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា ដូចការជម្រះកាយដែលមិនស្អាត រមែងឲ្យស្អាតបាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការជម្រះកាយដែលមិនស្អាត រមែងឲ្យស្អាតបានដោយសេចក្តីព្យាយាមតើដូចម្តេច ។ ម្នាលនាងវិសាខា ការអាស្រ័យដុំលម្អិតសម្រាប់ជម្រះកាយផង អាស្រ័យលម្អិតសម្រាប់ងូតផង អាស្រ័យទឹកផង អាស្រ័យសេចក្តីព្យាយាមដ៏សមគួរដល់កិច្ចនោះរបស់បុរសផង ទើបធ្វើការជម្រះកាយ ដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្តីព្យាយាមយ៉ាងនេះ យ៉ាងណាមិញ ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមយ៉ាងនោះដែរ ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ តែងរឭករឿយៗ នូវព្រះធម៌ថា ព្រះធម៌ដែលព្រះដ៏មានព្រះភាគត្រាស់ទុកប្រពៃហើយ ។ បេ ។ ជាធម៌ដែលវិញ្ញូជនទាំងឡាយគប្បីដឹងចំពោះខ្លួន ។ កាលអរិយសាវកនោះ កំពុងរឭកនូវព្រះធម៌ ចិត្តរមែងជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះក៏លះបង់ចេញបាន ។

ម្នាលនាងវិសាខា អរិយសាវកនោះ ហៅថា រក្សា **ធម្មុបោសថ** នៅរួមដោយធម៌ ចិត្តរបស់អរិយសាវកនោះ ប្រារព្ធចំពោះព្រះធម៌ រមែងជ្រះថ្លា សេចក្តីរីករាយ ក៏រមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះក៏លះបង់ចេញបាន ។

ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមយ៉ាងនេះ ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមតើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ តែងរឭករឿយៗនូវព្រះសង្ឃថា ពួកសាវកនៃព្រះដ៏មានព្រះភាគ

ប្រតិបត្តិប្រពៃហើយ ពួកសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិត្រង់ហើយ ពួកសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិសមគួរហើយ គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា ពួកសាវកណាបើរាប់ជាគូនៃបុរសបាន ៤ គូ បើរាប់រៀងជាបុរសបុគ្គល មាន ៨ ពួក សាវកនៃព្រះដ៏មានព្រះភាគនុ៎ះ គួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលនាំមកអំពីចម្ងាយហើយបូជា គួរទទួលនូវអាគន្តុកទាន គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលីកម្ម ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។ កាលអរិយសាវកនោះ កំពុងរឭករឿយៗនូវព្រះសង្ឃ ចិត្តរមែងជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះក៏លះបង់បាន ។ ម្នាលនាងវិសាខា ដូចការធ្វើសំពត់ដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការធ្វើសំពត់ដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា ព្រោះអាស្រ័យចំហាយផង អាស្រ័យទឹកក្បុងផង អាស្រ័យអាចម៍គោផង អាស្រ័យទឹកផង អាស្រ័យសេចក្តីព្យាយាមដ៏សមគួរដល់កិច្ចនោះ របស់បុរសផង ទើបធ្វើសំពត់ដែលមិនស្អាតឲ្យស្អាតបាន ដោយសេចក្តីព្យាយាមយ៉ាងនេះ យ៉ាងណាមិញ ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមក៏យ៉ាងនោះឯង ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ រមែងរឭករឿយៗ នូវព្រះសង្ឃថា ពួកសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិប្រពៃហើយ... ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។ កាលព្រះអរិយសាវកនោះ កំពុងរឭករឿយៗនូវព្រះសង្ឃ ចិត្តក៏ជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា អរិយសាវកនេះហៅថា រក្សា **សង្ឃុបោសថ** នៅរួមជាមួយនឹងព្រះសង្ឃ ចិត្តរបស់អរិយសាវកនោះ ប្រារព្ធចំពោះព្រះសង្ឃ រមែងជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវក

នោះ ក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមយ៉ាងនេះឯង ។

ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ រឭករឿយៗ នូវសីលរបស់ខ្លួន ជាសីលមិនដាច់ មិនធ្លុះធ្លាយ មិនពព្រុស មិនពពាល ជាសីលអ្នកជា ជាសីលដែលវិញ្ញូជនសរសើរហើយ ជាសីលមិនប៉ះពាល់ដោយតណ្ហា និងទិដ្ឋិ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ កាលអរិយសាវកនោះ កំពុងរឭករឿយៗនូវសីល ចិត្តក៏ជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា ដូចការដុសខាត់កញ្ចក់ដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការដុសខាត់កញ្ចក់ដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា ព្រោះអាស្រ័យប្រេងផង អាស្រ័យផេះផង អាស្រ័យប្រាសផង អាស្រ័យសេចក្តីព្យាយាមដ៏សមគួរដល់កិច្ចនោះរបស់បុរសផង ទើបដុសខាត់កញ្ចក់ ដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្តីព្យាយាម យ៉ាងណាមិញ ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមក៏យ៉ាងនោះឯង ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវក ក្នុងធម្មវិន័យនេះ រឭករឿយៗនូវសីលរបស់ខ្លួន ដែលជាសីលមិនដាច់ មិនធ្លុះធ្លាយ... ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ កាលអរិយសាវកនោះ កំពុងរឭករឿយៗនូវសីល ចិត្តក៏រមែងជ្រះថ្លា សេចក្តីរីករាយ ក៏កើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា អរិយសាវកនេះ ហៅថា រក្សា **សីលុបោសថ** នៅរួមដោយសីល មួយទៀត ចិត្តរបស់អរិយសាវកនោះ ប្រារព្ធចំពោះសីលក៏ជ្រះថ្លា សេចក្តីរីករាយ ក៏រមែងកើតឡើង

ឧបក្កិលេស ទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមយ៉ាងនេះឯង ។

ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវក ក្នុងធម្មវិន័យនេះ រឭករឿយៗនូវទេវតាទាំងឡាយថា ពួកទេវតាជាន់ចាតុម្មហារាជិកៈក៏មាន ពួកទេវតាជាន់តាវត្តិង្សក៏មាន ពួកទេវតាជាន់យាមៈក៏មាន ពួកទេវតាជាន់តុសិតក៏មាន ពួកទេវតាជាន់និម្មានរតីក៏មាន ពួកទេវតាជាន់បរនិម្មិតវសវត្តីក៏មាន ពួកទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្មក៏មាន ពួកទេវតាជាន់ខ្ពស់ឡើងទៅទៀតក៏មាន ទេវតាទាំងឡាយអម្បាលនោះ ប្រកបដោយសទ្ធា មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ សទ្ធាមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ទេវតាទាំងឡាយអម្បាលនោះ ប្រកបដោយសីលមានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ សីលមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយសុតៈមានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានមកកើតក្នុងភពនោះ សុតៈមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយចាគៈ មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ ចាគៈមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយបញ្ញាមានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ បញ្ញាមានភាពដូច្នោះរបស់អាត្មាអញក៏មាន ។ កាលអរិយសាវកនោះ រឭករឿយៗនូវ**សទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា** របស់ខ្លួននិងរបស់ទេវតាទាំងឡាយអម្បាលនោះ ចិត្តក៏ជ្រះថ្លា សេចក្តីរីករាយក៏កើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា ដូចការជុសខាត់មាស ដែល

សៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការជុសខាត់មាស ដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា ព្រោះអាស្រ័យបាវមាសផង អាស្រ័យដីប្រៃផង អាស្រ័យរង្គផង អាស្រ័យស្នប់នឹងដង្កាប់ផង អាស្រ័យសេចក្តីព្យាយាមដ៏សមគួរដល់កិច្ចនោះរបស់បុរសផង ទើបជុសខាត់មាស ដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមយ៉ាងនេះ ។ យ៉ាងណាមិញ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមក៏ដូច្នោះយ៉ាងនោះឯង ។

ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវក ក្នុងធម្មវិន័យនេះ តែងរឭករឿយៗនូវទេវតាថា ពួកទេវតាជាន់ចាតុម្មហារាជិកៈក៏មាន ពួកទេវតាជាន់តាវត្តិង្សក៏មាន ។ បេ ។ ពួកទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្មក៏មាន ពួកទេវតាជាន់ខ្ពស់ឡើងទៅទៀតក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយសទ្ធា មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ សទ្ធាមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយ សុតៈ... ដោយចាគៈ... ដោយបញ្ញា... មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ បញ្ញាមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ។ កាលអរិយសាវកនោះ រឭករឿយៗនូវ**សទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា** របស់ខ្លួននឹងរបស់ទេវតាទាំងនោះ ចិត្តក៏ជ្រះថ្លា សេចក្តីរីករាយក៏កើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា អរិយសាវកនេះ ហៅថា **ទេវតូបោសថៈ** នៅរួម ជាមួយនឹងពួកទេវតាមួយទៀតចិត្តរបស់អរិយសាវកនោះ ប្រារព្ធទេវតាក៏ជ្រះថ្លា សេចក្តីរីករាយក៏កើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមយ៉ាងនេះឯង ។

ម្នាលនាងវិសាខា អរិយសាវកនោះ តែងពិចារណាឃើញដូច្នេះថា ព្រះអរហន្ត ទាំងឡាយ លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿង សស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប ប្រកបដោយសេចក្តីអាណិត ជាអ្នកអនុគ្រោះ ដោយប្រយោជន៍ ចំពោះសព្វសត្វដែលមានជីវិត ដរាបដល់អស់ជីវិត ឯអាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានសស្ត្រាដាក់ចុះ ហើយ មានសេចក្តីខ្មាសបាប ប្រកបដោយសេចក្តីអាណិត ជាអ្នកអនុគ្រោះដោយប្រយោជន៍ ចំពោះសព្វសត្វដែលមានជីវិត អស់យប់នេះនឹងថ្ងៃនេះដែរ អាត្មាអញឈ្មោះថាធ្វើតាម ព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថា អាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែរបស់ដែលគេឲ្យ ប្រាថ្នាយកតែរបស់ដែលគេឲ្យ មានខ្លួនមិនលួច ស្អាតរហូតអស់ ១ ជីវិត អាត្មាអញ ក្នុងថ្ងៃនេះ ក៏លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែរបស់ដែលគេឲ្យ ប្រាថ្នាយក តែរបស់ដែលគេឲ្យ មានខ្លួនមិនលួច ស្អាតនៅអស់ថ្ងៃនេះ និងយប់នេះដែរ អាត្មាអញ ឈ្មោះថា ធ្វើតាមព្រះអហរន្តទាំងឡាយផង ឧបោសថឈ្មោះថា អាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ លះបង់អព្រហ្មចរិយៈ ជាព្រហ្មចារីបុគ្គល ជាអ្នកប្រព្រឹត្តឆ្ងាយចាក (អព្រហ្មចរិយៈ) វៀរចាកមេថុន ដែលជាធម៌របស់អ្នកស្រុក អាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់អព្រហ្មចរិយៈ ជាព្រហ្មចារីបុគ្គល ជាអ្នកប្រព្រឹត្តឆ្ងាយចាក (អព្រហ្មចរិយៈ) វៀរចាកមេថុនដែលជាធម៌របស់ អ្នកស្រុកអស់ថ្ងៃនេះ និងយប់នេះដែរ អាត្មាអញឈ្មោះថាធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថ ឈ្មោះថា អាត្មាអញបាន រក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ លះបង់នូវមុសាវាទ វៀរចាកមុសាវាទ និយាយតែពាក្យពិត តភ្ជាប់តែពាក្យពិត មានពាក្យខ្ជាប់ខ្ជួន មានពាក្យគួរជឿ មិនពោល បង្កាច់សត្វលោក រហូតអស់មួយជីវិត អាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់នូវមុសាវាទ វៀរចាក មុសាវាទ និយាយតែពាក្យពិត តភ្ជាប់តែពាក្យពិត មានពាក្យខ្ជាប់ខ្ជួន មានពាក្យគួរជឿ មិន ពោលបង្កាច់សត្វលោក អស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញឈ្មោះថា ធ្វើតាមព្រះអរហន្ត ទាំងឡាយផង ឧបោសថឈ្មោះថាអាត្មាអញរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្ត

ទាំងឡាយ លះបង់ការក្រេបផឹកនូវទឹកស្រវឹងគឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ រហូតអស់មួយជីវិត ឯអាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់ការក្រេបផឹកនូវទឹកស្រវឹងគឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ វៀរចាកការក្រេបផឹកនូវទឹកស្រវឹងគឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទថ្ងៃនេះ និងយប់នេះដែរ អាត្មាអញឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថាអាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ បរិភោគភត្តតែម្តង វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគខុសកាល រហូតអស់មួយជីវិត អាត្មាអញក្នុងថ្ងៃនេះក៏បរិភោគភត្តតែម្តង វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគខុសកាល អស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថ ឈ្មោះថា អាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ វៀរចាកការមើលនូវរបាំ និងការស្តាប់នូវចម្រៀងនិងភ្លេងប្រគំ ដែលជាសត្រូវដល់កុសលធម៌ និងការទ្រទ្រង់ប្រដាប់ស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប គ្រឿងលាបផ្សេងៗ អាត្មាអញក្នុងថ្ងៃនេះ ក៏វៀរចាកការមើលរបាំ និងការស្តាប់ចម្រៀង និងភ្លេង ប្រគំ ដែលជាសត្រូវដល់កុសលធម៌ និងការទ្រទ្រង់ប្រដាប់ ស្អិតស្អាងរាងកាយ ដោយផ្កាកម្រងនិងគ្រឿងក្រអូប គ្រឿងលាបផ្សេងៗ អស់ថ្ងៃនេះ និងយប់នេះដែរ អាត្មាអញឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថៈឈ្មោះថា អាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ លះបង់ទីដេក ទីអង្គុយដ៏ខ្ពស់ និងទីដេកទីអង្គុយដ៏ប្រសើរ វៀរស្រឡះចាកទីដេកទីអង្គុយដ៏ខ្ពស់ និងទីដេកទីអង្គុយដ៏ប្រសើរ សម្រេចទីដេកដ៏ទាប លើគ្រែតូច លើកម្រាលស្មៅក្តី រហូតអស់មួយជីវិត អាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់ទីដេក ទីអង្គុយដ៏ខ្ពស់ និងទីដេក ទីអង្គុយដ៏ប្រសើរ វៀរស្រឡះចាកទីដេក ទីអង្គុយដ៏ខ្ពស់ និងទីដេកទីអង្គុយដ៏ប្រសើរ សម្រេចទីដេកដ៏ទាប លើគ្រែតូច លើកម្រាលស្មៅក្តី អស់ថ្ងៃនេះ និងយប់នេះដែរ អាត្មាអញឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថា អាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ម្នាលនាងវិសាខា យ៉ាងនេះឈ្មោះថា **អរិយុបោសថ** ម្នាលនាងវិសាខា អរិយឧបោសថដែលបុគ្គលរក្សាយ៉ាងនេះ តែងមាន

ផលច្រើន មានអានិសង្សច្រើន មានសេចក្ដីរុងរឿងច្រើន ផ្សាយផលទៅច្រើន ។ មានផលច្រើនយ៉ាងណា មានអានិសង្សច្រើនយ៉ាងណា មានសេចក្ដីរុងរឿងច្រើនយ៉ាងណា ផ្សាយផលទៅច្រើនយ៉ាងណា ។ ម្នាលនាងវិសាខា ប្រៀបដូចបុគ្គលណាមួយ គប្បីគ្រងរាជសម្បត្តិ ជាឥស្សរិយាធិបតីនៃមហាជនបទទាំង ១៦ នេះ ដែលមានរតនៈ ៧ ប្រការដ៏ច្រើន មហាជនបទទាំង ១៦ គឺអង្គៈ មគធៈ កាសី កោសល វជ្ជី មល្លៈ ចេតីវង្សៈ កុរុ បញ្ចាលៈ មច្ឆៈ សុរសេនៈ អស្សកៈ អវន្តី គន្ធារៈ កម្ពោជៈ រាជសម្បត្តិរបស់បុគ្គលនុ៎ះ មានតម្លៃមិនស្មើចំណិតទី ១៦ ៗ លើក នៃឧបោសថៈប្រកបដោយអង្គ ៨ ឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលនាងវិសាខា រាជសម្បត្តិជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្ដីសុខទិព្វ (ឃើញថា) ស្ដើងស្ដួចណាស់ ។ ម្នាលនាងវិសាខា ៥០ ឆ្នាំរបស់មនុស្សជាមួយថ្ងៃ មួយយប់របស់ពួកទេវតាជាន់ចាតុម្មហារាជិកៈ រាប់តាមរាត្រីនោះ ៣០ រាត្រីជាមួយខែ រាប់ តាមខែនោះ ១២ ខែ ជាមួយឆ្នាំ រាប់តាមឆ្នាំនោះ ៥០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់ ចាតុម្មហារាជិកៈ ។ ម្នាលនាងវិសាខាហេតុនុ៎ះ រមែងមានប្រាកដត្រង់ពាក្យថា ស្ត្រី ឬបុរសពួកខ្លះក្នុងលោកនេះ រក្សាឧបោសថប្រកបដោយអង្គ ៨ ហើយ លុះដល់រំលាងកាយស្លាប់ទៅ ទៅកើតរួមជាមួយនឹងពួកទេវតាជាន់ចាតុម្មហារាជិកៈ ។ ម្នាលនាងវិសាខា ដែលថារាជសម្បត្តិ ជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្ដីសុខទិព្វ (ឃើញថា) ស្ដើងស្ដួច នេះតថាគតពោលសំដៅយក ត្រង់ហេតុនុ៎ះឯង ។ ម្នាលនាងវិសាខា ១០០ ឆ្នាំ របស់មនុស្ស ជាមួយថ្ងៃ មួយយប់របស់ទេវតាជាន់តាវត្តិង្សរាប់តាមរាត្រីនោះ ៣០ រាត្រីជា ១ ខែ រាប់តាមខែនោះ ១២ ខែ ជា ១ ឆ្នាំ រាប់តាមឆ្នាំនោះ ១០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់តាវត្តិង្ស ។ ម្នាលនាងវិសាខា ហេតុនុ៎ះ រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រីឬបុរសពួកខ្លះក្នុងលោកនេះ រក្សាឧបោសថប្រកបដោយអង្គ ៨ ហើយ លុះដល់រំលាងកាយស្លាប់ទៅ ទៅកើតរួមជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ។ ម្នាលនាងវិសាខា ដែលថារាជសម្បត្តិ ជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្ដីសុខទិព្វ (ឃើញថា) ស្ដើងស្ដួច នេះតថាគតពោលសំដៅយកត្រង់ហេតុនុ៎ះឯង ។ ម្នាលនាងវិសាខា ២០០ ឆ្នាំរបស់មនុស្ស ជាមួយថ្ងៃ មួយយប់របស់ពួកទេវតាជាន់យាមៈ រាប់តាមរាត្រីនោះ

៣០ រាត្រីជា ១ ខែ រាប់តាមខែនោះ ១២ ខែ ជា ១ ឆ្នាំ រាប់តាមឆ្នាំនោះ ២០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់យាមៈ ។ ម្នាលនាងវិសាខា ហេតុនុ៎ះ រមែងមានប្រាកដ ត្រង់ពាក្យថាស្ត្រី ឬបុរសពួកខ្លះក្នុងលោកនេះ រក្សានូវឧបោសថប្រកបដោយអង្គ ៨ ហើយលុះដល់រំលាងកាយស្លាប់ទៅ ទៅកើតរួមជាមួយនឹងពួកទេវតា ជាន់យាមៈ ។ ម្នាលនាងវិសាខា ដែលថារាជសម្បត្តិជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខទិព្វ (ឃើញថា) ស្តើងស្តួច នេះតថាគតពោលសំដៅយកត្រង់ហេតុ នុ៎ះឯង ។ ម្នាលនាងវិសាខា ៤០០ ឆ្នាំរបស់មនុស្ស ជាមួយថ្ងៃ មួយយប់របស់ពួកទេវតាជាន់តុសិត រាប់តាមរាត្រីនោះ ៣០ រាត្រីជា ១ ខែ រាប់តាមខែនោះ ១២ ខែ ជា ១ ឆ្នាំ រាប់តាមឆ្នាំ ៤០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់តុសិត ។ ម្នាលនាងវិសាខា ហេតុនុ៎ះ រមែងមានប្រាកដត្រង់ពាក្យថា ស្ត្រី ឬបុរសពួកខ្លះក្នុងលោកនេះ រក្សានូវឧបោសថប្រកបដោយអង្គ ៨ ហើយលុះដល់រំលាង កាយស្លាប់ទៅ ទៅកើតរួមជាមួយនឹងពួកទេវតាជាន់តុសិត ។ ម្នាលនាងវិសាខា ដែលថារាជសម្បត្តិជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខទិព្វ (ឃើញថា) ស្តើងស្តួច នេះតថាគតពោលសំដៅយកត្រង់ហេតុនុ៎ះឯង ។ ម្នាលនាងវិសាខា ៨០០ឆ្នាំរបស់មនុស្ស ជាមួយថ្ងៃ មួយយប់របស់ពួកទេវតាជាន់និម្មានរតី រាប់តាមរាត្រី នោះ ៣០ រាត្រី ជា ១ ខែ រាប់តាមខែនោះ ១២ ខែ ជា ១ ឆ្នាំ រាប់តាមឆ្នាំនោះ ៨០០០ឆ្នាំទិព្វ ជាប្រមាណ នៃអាយុរបស់ពួកទេវតាជាន់និម្មានរតី ។ ម្នាលនាងវិសាខា ហេតុនុ៎ះ រមែងមានប្រាកដត្រង់ពាក្យថា ស្ត្រី ឬបុរសពួកខ្លះក្នុងលោកនេះ រក្សានូវឧបោសថប្រកបដោយអង្គ ៨ ហើយ លុះដល់រំលាងកាយស្លាប់ទៅ ទៅកើតរួមជាមួយនឹងពួកទេវតាជាន់និម្មានរតី ។ ម្នាលនាងវិសាខា ដែលថារាជសម្បត្តិ ជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខ (ឃើញថា) ស្តើងស្តួច នេះតថាគតពោលសំដៅ យកត្រង់ហេតុនុ៎ះឯង ។ ម្នាលនាងវិសាខា ១.៦០០ ឆ្នាំ របស់មនុស្សជាមួយយប់ មួយថ្ងៃរបស់ពួកទេវតា ជាន់បរនិម្មិតវសវត្តី រាប់តាមរាត្រីនោះ ៣០ រាត្រី ជា ១ ខែ រាប់តាមខែនោះ ១២ ខែ ជា ១ ឆ្នាំ រាប់តាមឆ្នាំនោះ ១៦០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់បរនិម្មិតវសវត្តី ។ ម្នាលនាង-វិសាខាហេតុនុ៎ះ រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ រក្សានូវ

ឧបោសថ ប្រកបដោយអង្គ ៨ ហើយលុះដល់រំលោងកាយស្លាប់ទៅ ទៅកើតរួមជាមួយនឹងពួកទេវតា ជាន់បរនិម្មិតវសវត្តី ។ ម្នាលនាងវិសាខា ដែលថារាជសម្បត្តិ ជារបស់មនុស្សប្រៀបធៀប នឹងសេចក្តីសុខទិព្វ (ឃើញថា) ស្តើងស្តួច នេះតថាគតពោលសំដៅយកត្រង់ហេតុនុ៎ះឯង ។

បុរសឬស្ត្រីមិនគប្បីសម្លាប់សត្វ ១ មិនគប្បីលួចយកទ្រព្យដែលម្ចាស់គេមិនបានឲ្យ១ គប្បីវៀរចាកមេថុន ដែលមិនមែនជាសេចក្តីប្រព្រឹត្តដ៏ប្រសើរ ១ មិនគប្បីនិយាយកុហក ១ មិនគប្បីក្រេបផឹកនូវទឹកស្រវឹង ១ មិនគប្បីបរិភោគភោជនក្នុងវេលារាត្រី និងភោជនក្នុងវេលាខុសកាល ១ មិនគប្បីទ្រទ្រង់កម្រងផ្កា មិនគប្បីប្រើប្រាស់គ្រឿងក្រអូប ១ គប្បីដេកលើគ្រែ (ដែលត្រូវប្រមាណ) ឬកម្រាលដែលក្រាលផ្ទាល់នឹងផែនដី ១ (បណ្ឌិតទាំងឡាយពោលសរសើរ) ឧបោសថប្រកបដោយអង្គ ៨ នុ៎ះ ដែលព្រះពុទ្ធទ្រង់ដល់នូវទីបំផុតនៃទុក្ខទ្រង់ប្រកាសទុកហើយ ។ ព្រះចន្ទ្រ និងព្រះអាទិត្យទាំងពីរមានរស្មីដ៏រុងរឿង ភ្លឺចុះផ្សាយចេញទៅ អស់ទីមាន កំណត់ត្រឹមណា មួយទៀតព្រះចន្ទ្រ និងព្រះអាទិត្យ មាននាទីកម្ចាត់បង់នូវងងឹត មានដំណើរទៅក្នុងអាកាស ចាំងពន្លឺសព្វទិស តែងបំភ្លឺក្នុងផ្ទៃមេឃ ទ្រព្យណាមួយ ដែលមាននៅក្នុងចន្លោះនុ៎ះ គឺកែវមុក្តា កែវមណី កែវពៃទូរ្យដ៏ល្អ មួយវិញទៀត ដែលហៅថា មាសសិង្គី មាសកាញ្ចនៈ មាសជាតរូប និងមាសហដកៈ ទ្រព្យទាំងអម្បាលនោះ (មានតម្លៃ) មិនដល់នូវចំណិតទី ១៦ ៗ លើកនៃឧបោសថប្រកបដោយអង្គ ៨ ឡើយ ដូចពួកផ្កាយទាំងអស់ (ភ្លឺ) មិនដល់ពន្លឺព្រះចន្ទ្រឡើយ ព្រោះហេតុនោះ ស្ត្រីបុរសដែលជាអ្នកមានសីល បានរក្សាឧបោសថប្រកបដោយអង្គ ៨ ធ្វើបុណ្យទាំងឡាយ ដែលមានសុខជាកម្រៃ ជាអ្នកមិនត្រូវគេតិះដៀល តែងទៅកើតក្នុងស្ថានសួគ៌ ។

## វិធីសមាទាន

## និងរឿងឧបោសថកម្មចប់

## ពណ៌នាសេចក្ដីនៃសិក្ខាបទ

*នៅក្នុង* **សម្មោហវិនោទនី** *ត្រង់សិក្ខាបទវិភង្គ ពន្យល់ថា ៖*

**បាណាតិបាតាតិ បាណស្ស អតិបាតា ឃាតនា មារណាតិ អត្ថោ ។ វេរមណីតិ វិរតិ ។**

*ពាក្យថា* **បាណាតិបាតា** *បានដល់ការញ៉ាំងជីវិតសត្វឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។ ពាក្យថា* **វេរមណី** *បានដល់ការវៀរចាក ។* **អទិន្នាទានាតិ អទិន្នស្ស អាទានា បរបរិគ្គហិតស្ស ហរណាតិ អត្ថោ ។** *ពាក្យថា* **អទិន្នាទានា** *បានដល់ការកាន់យករបស់អ្នកដទៃដែលគេមិនបានឲ្យ អធិប្បាយថា បានដល់ការនាំយកវត្ថុដែលបុគ្គលដទៃហួងហែងរក្សា ។* **អព្រហ្មចរិយន្តិ អសេដ្ឋចរិយំ, ទ្វយទ្វយសមាបត្តិ មេថុនបដិសេវនា កាយទ្វារប្បវត្តា អសទ្ធម្មបដិសេវនដ្ឋានវិតិក្កមចេតនា អព្រហ្មចរិយំ ។** *ពាក្យថា* **អព្រហ្មចរិយំ** *បានដល់ការប្រព្រឹត្តមិនប្រសើរ ។ ចេតនាជាហេតុល្មើស ឋានៈគឺជាការសេពមេថុនធម្ម ប្រព្រឹត្តទៅតាមកាយទ្វារដោយការសេពមេថុនជាគូៗ ឈ្មោះថា* **អព្រហ្មចរិយៈ** *។*

**កាមេសូតិ វត្ថុកាមេសុ ។ មិច្ឆាចារាតិ កិលេសកាមវសេន លាមកាចារា ។** *ពាក្យថា* **កាមេសុ** *បានដល់វត្ថុកាមទាំងឡាយ ។ ពាក្យថា* **មិច្ឆាចារា**

*បានដល់ការប្រព្រឹត្តលាមក ដោយអំណាចកិលេសកាម ។* **មុសាវាទាតិ អភូតវាទ-តោ។** *ពាក្យថា* **មុសាវាទ** *បានដល់វៀរចាកពាក្យពិត ។*

**សុរាតិ បិដ្ឋសុរា បូវសុរា ឱទនសុរា កិណ្ណបក្ខិត្តា សម្ភារសំយុត្តាតិ បញ្ច សុរា ។** *ដែលហៅថា សុរាបានដល់សុរា ៥ ប្រភេទគឺ :*

**១-បិដ្ឋសុរា** *សុរាធ្វើដោយម្សៅ*

**២-បូវសុរា** *សុរាធ្វើដោយនំ*

**៣-ឱទនសុរា** *សុរាធ្វើដោយបាយ*

**៤-កិណ្ណបក្ខិត្តាសុរា** *ដែលគេដាក់ពូជសុរា*

**៥-សម្ភារសំយុត្តា** *សុរាដែលប្រកបព្រមដោយ គ្រឿងផ្សំផ្សេងៗ ។*

**មេរយន្តិ បុប្ផាសវោ ផលាសវោ គុឡាសវោ មធ្វាសវោ សម្ភារ-សំយុត្តោតិ បញ្ច អាសវា។** *ដែលហៅថា មេរ័យ បានដល់មេរ័យ ៥ ប្រភេទគឺ :*

**១-បុប្ផាសវោ** *ទឹកស្រាំដែលគេធ្វើដោយផ្កាឈើ*

**២-ផលាសវោ** *ទឹកស្រាំដែលគេធ្វើដោយផ្លែឈើ*

**៣-គុឡាសវោ** *ទឹកស្រាំដែលគេធ្វើដោយទឹកអំពៅ*

**៤-មធ្វាសវោ** *ទឹកស្រាំដែលគេធ្វើដោយផ្លែចន្ទន៍ ឬគេធ្វើដោយទឹកឃ្មុំ*

**៥-សម្ភារសំយុត្តោ** *ទឹកត្រាំដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ ។*

**តទុភយម្បិ មទនីយដ្ឋេន មជ្ជំ ។ យាយ ចេតនាយ តំ បិវន្តិ សាបមាទការណត្តា បមាទដ្ឋានំ តស្មា សុរាមេរយមជ្ជបមាទដ្ឋានា ។** *សុរានិងមេរ័យសូម្បីទាំងពីរនោះ ឈ្មោះថា* **មជ្ជៈ** *ព្រោះអត្ថថា ជាទីតាំងនៃសេចក្ដីស្រវឹង ។ មនុស្សទាំងឡាយរមែងផឹកសុរាឬមេរ័យនោះ ដោយចេតនាណា ចេតនានោះ ឈ្មោះថា ជាទីតាំងនៃសេចក្ដីប្រមាទ ព្រោះជាហេតុនាំឲ្យវង្វេងកាន់ ព្រោះហេតុនោះទីតាំងនៃសេចក្ដីប្រមាទនោះ ទើបឈ្មោះថា វមែងមានព្រោះការផឹកទឹកស្រវឹង គឺសុរានិងមេរ័យ ។*

**វិកាលភោជនា** *គឺការបរិភោគភោជនាហារក្នុងកាលខុស ។* **នច្ចគិតវិសូក-ទស្សនា** *គឺ* **នច្ច** *រាំ* **គីត** *ច្រៀង* **វិសូកទស្សនា** *ល្បែងដែលជាសត្រូវដល់កុសលធម៌ ។* **មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា** *គឺ* **មាលា** *បានដល់ផ្កាឈើ ប្រភេទយ៉ាងណាមួយ ពាក្យថា* **វិលេបន** *បានដល់របស់យ៉ាងណាមួយដែលគេចាត់ដើម្បីលាបលនកាយ ក្រៅពីនេះ របស់ក្រអូបមានលម្អិតខ្លឹមចន្ទន៍ជាដើមគ្រប់យ៉ាង ឈ្មោះថា* **គន្ធៈ** *។ របស់ក្រអូបគ្រប់យ៉ាង ប្រើតាក់តែងប្រដាប់មិនគួរ តែប្រើជាថ្នាំគួរ ។*

**ឧច្ចាសយនមហាសយនា** *គឺ* **ឧច្ចាសយនៈ** *ទីសេនាសនៈខ្ពស់ហួសប្រមាណ* **មហាសយនា** *ទីសេនាសនៈដ៏ប្រសើរ ទីដេកដែលជាអកប្បិយៈ ។ និងគ្រឿងកម្រាលដែលជាអកប្បិយៈ ។*

**ជាតរូបរជតិប្បដិគ្គហណា** *គឺពាក្យថា* **ជាតរូប** *បានដល់មាស ពាក្យថា* **រជតៈ** *បានដល់កហាបនៈ គឺរបស់ណាមួយ មានមាសកលោហៈ មាសកឈើ និងមាសកជ័រជាដើម ឬរបស់ណាដែលគេចាយវាយក្នុងប្រទេសនោះៗ ។ មាស និងប្រាក់ទាំងអស់នោះ ឈ្មោះថា* **ជាតរូប** *។ ការទទួលយកនូវមាសនិងប្រាក់នោះ ឈ្មោះថា* **បដិគ្គហណៈ** *ការទទួល ។*

**ពណ៌នាសេចក្តីនៃសិក្ខាបទចប់**

## អធិប្បាយសិក្ខាបទ ១០

**១- បាណាតិបាតា** *វេធកចេតនាដែលក្លែងសម្លាប់សត្វមានជីវិតឲ្យស្លាប់នោះ ប្រមាណសំណុំរូបសត្វតិរច្ឆានយ៉ាងតូច មានស្រមោចជាទីបំផុត យ៉ាងធំប៉ុនដំរី សម្លាប់មនុស្ស និងអមនុស្ស មានព្រះឥន្ទ ព្រះព្រហ្មជាដើម សុទ្ធតែជាច់ខូចបែកធ្លាយនូវបាណាតិបាតសិក្ខាបទទាំងអស់ ។*

*បើសម្លាប់មាតា បិតា និងព្រះអរហន្តដែលហៅថា មាតុឃាត បិតុឃាត អរហន្តឃាត នោះមានទោស ២ ជាន់គឺជាន់ទី ១ ដាច់ខូចសិក្ខាបទបាណាតិបាត ជាន់ទី ២ ត្រូវទោសអនន្តរិយកម្ម ។ ដោយទោសច្រើន បណ្តាសត្វមានជីវិត ដែលវៀរចាកគុណធម៌ មានសត្វតិរច្ឆានជាដើម បាណាតិបាតឈ្មោះថា មានទោសតិច ព្រោះសត្វតូចៗ ឈ្មោះថាមានទោសច្រើន ព្រោះសត្វធំៗ ព្រោះហេតុអ្វី? ព្រោះថាប្រយោគធំ (សេចក្តីព្យាយាមច្រើន) សូម្បីកាលមានប្រយោគស្មើគ្នាឈ្មោះថា មានទោសច្រើន ព្រោះវត្ថុធំ ។*

*ចំណែកបណ្តាសត្វមានជីវិត ដែលមានគុណធម៌មានមនុស្សជាដើម បាណាតិបាតឈ្មោះថា មានទោសតិច ក៏ព្រោះមនុស្សមានគុណធម៌តិច ឈ្មោះថា មានទោសច្រើន ព្រោះមនុស្សមានគុណធម៌ច្រើន តែកាលមានខ្លួន និងគុណធម៌ស្មើគ្នា គប្បីជ្រាបថា មានទោសតិច ព្រោះកិលេស និងសេចក្តីព្យាយាមដ៏ទន់ខ្សោយ នឹងមានទោសច្រើន ព្រោះកិលេសនិងសេចក្តីព្យាយាមដ៏ខ្លាំងក្លា សូម្បីក្នុងសិក្ខាបទដ៏សេស ក៏មានន័យនេះដូចគ្នា ។*

***បាណាតិបាតនេះបើពោលទៅតាមប្រយោគ នៃព្យាយាមសម្លាប់នោះមាន ៦ គឺ :***

សាហត្ថិកបយោគ អាណត្តិកបយោគ និស្សគ្គិយបយោគ ថាវរបយោគ វិជ្ជាមយបយោគ ឥទ្ធិមយបយាគ ។

*បណ្ដាប្រយោគទាំងឡាយនោះ ការប្រហារដោយកាយ ឬរបស់ជាប់ទាក់ទង ដោយកាយ ឈ្មោះថា* **សាហត្ថិកបយោគ** *សាហត្ថិកប្រយោគនោះ បែកចេញជាពីរ គឺ សាហត្ថិកប្រយោគចំពោះ និងសាហត្ថិកប្រយោគមិនចំពោះ ។ ក្នុង* **សាហត្ថិកបយោគ** *ទាំងពីរនោះ ចំពោះសាហត្ថិកប្រយោគ ចំពោះបុគ្គលរមែងជាកម្មពន្ធគឺកម្មជាប់គ្នា ព្រោះសេចក្ដីស្លាប់របស់មនុស្ស ដែលចំពោះប្រហារប៉ុណ្ណោះ ។ ក្នុងសាហត្ថិកប្រយោគ មិនចំពោះ យ៉ាងនេះថា អ្នកណាមួយចូរស្លាប់ចុះដូច្នេះក្ដី បុគ្គលរមែងជាកម្មពន្ធ ព្រោះសេចក្ដីស្លាប់របស់បុគ្គលណាមួយ ដោយការប្រហារជាបច្ច័យ ។ម្យ៉ាងទៀត សូម្បីដោយសាហត្ថិកប្រយោគទាំងពីរ គេល្មមត្រូវប្រហារ ក៏ស្លាប់ ឬស្លាប់ដោយរោគនោះជាខាងក្រោយ បុគ្គលក៏រមែងជាកម្មពន្ធ គឺកម្មមានចំណងតគ្នា ខណៈដែលត្រូវគេប្រហារប៉ុណ្ណោះ តែកាលបុគ្គលប្រហារដោយប្រាថ្នានឹងឲ្យស្លាប់ តែគេមិនស្លាប់ដោយប្រហារនោះ ត្រឡប់គិតប្រហារគេទៀត ប្រសិនបើ សូម្បីខាងក្រោយគេស្លាប់ដោយគ្រាប្រហារជាដំបូង បុគ្គលក៏រមែងកម្មពន្ធក្នុងវេលានោះប៉ុណ្ណោះ បើថាគេស្លាប់ដោយការប្រហារគ្រាទីពីរ ក៏មិនជាបាណាតិបាត សូម្បីកាលគេស្លាប់ ដោយសាហត្ថិកប្រយោគទាំងពីរ បុគ្គលក៏រមែងជាកម្មពន្ធដោយការប្រហារគ្រាដំបូងប៉ុណ្ណោះ កាលគេមិនស្លាប់ដោយសាហត្ថិកប្រយោគ ទាំងពីរក៏មិនជាបាណាតិបាតឡើយ ។ សូម្បីមនុស្សច្រើនប្រហារមនុស្សមួយនាក់ ក៏មានកម្មពន្ធ ន័យយ៉ាងនេះ សូម្បីក្នុងកម្មពន្ធរមែងមានដល់មនុស្សដែលប្រហារគេស្លាប់ប៉ុណ្ណោះ ។*

*ការបញ្ជាឲ្យគេធ្វើ ឈ្មោះថា* **អាណត្តិកបយោគ** *ក្នុងអាណត្តិកប្រយោគនេះ គប្បីជ្រាបថា ជាកម្មពន្ធ ដោយន័យដូចពោលទុកក្នុងសាហត្ថិកប្រយោគនោះឯង ក្នុងអាណត្តិកប្រយោគនោះ គប្បីជ្រាបថា មានកំណត់ទុក ៦ យ៉ាងគឺ* **វត្ថុ ១ កាល ១ ឱកាស ១ អាវុធ ១ ឥរិយាបថ ១ កិរិយាវិសេស ១** *ការកំណត់ ៦ យ៉ាងនោះ សត្វមានជីវិត*

គប្បីចាំទុកថា **វត្ថុ** ។ វេលាព្រឹក វេលាល្ងាចជាដើម នឹងវេលា រសៀល វេលាធំជាដើម គប្បីចាំទុកថា **កាល** ។ ស្រុក និគម ព្រៃ ប្រកផ្លូវបែក ដូច្នេះជាដើម គប្បីចាំទុកថា **ឱកាស** ។ **អាវុធ** ជាដើមយ៉ាងនេះ គឺដាវ ធ្នូ ឬលំពែង។ ការឈរ ឬការអង្គុយរបស់មនុស្សអ្នកត្រូវសម្លាប់ នឹងមនុស្សស្លាប់ដូចពោលមកនេះជាដើម គប្បីចាំទុកថា **ឥរិយាបថ** ។ ការចាក់ ការកាត់ ការធ្វើឲ្យដាច់ ឬក្រងសក់ គប្បីចាំទុកថា **កិរិយាវិសេស** ។ ប្រសិនថាមនុស្សត្រូវគេ បញ្ជាឲ្យសម្លាប់អ្នកណា ធ្វើវត្ថុឲ្យឃ្លៀងឃ្លាត (សម្លាប់ខុសមនុស្សអ្នកបញ្ជា) ទៅសម្លាប់មនុស្សដទៃក្រៅចាកអ្នកនោះសោត អ្នកបញ្ជាក៏មិនត្រូវចំណងដោយកម្ម បើគេមិនធ្វើវត្ថុឃ្លៀងឃ្លាត សម្លាប់មិនខុសមនុស្ស អ្នកទាំងពីរក៏ត្រូវចំណងដោយកម្ម គឺអ្នកបញ្ជាឲ្យទៅសម្លាប់ អ្នកទទួលក៏សម្លាប់អ្នកនោះ ។

នៅក្នុងព្រះអដ្ឋកថា សមន្តប្បាសាទិកាត្រង់ តតិយបារាជិកត្រង់ **អាណត្តិក-បយោគ** កំណត់៦ យ៉ាង មាន **វត្ថុ កាល ឱកាស អាវុធ ឥរិយាបថ** និង**កិរិយាវិសេស** ។

ប្រសិនបើ ភិក្ខុអ្នកទទួលបញ្ជាធ្វើឲ្យវត្ថុភ្លាត់ទៅបែរទៅសម្លាប់មនុស្សដទៃ ផ្សេងពីបុគ្គលអ្នកបញ្ជាឲ្យសម្លាប់ ឬត្រូវបញ្ជាថា លោកត្រូវប្រហារខាងមុខសម្លាប់ឲ្យស្លាប់ បែរទៅប្រហារខាងក្រោយឬខាងៗ ឬត្រង់អវយវៈណាមួយឲ្យស្លាប់ទៅ ចំណងផ្លូវកម្មរមែងមិនមានដល់អ្នកបញ្ជា ចំណងផ្លូវកម្មរមែងមានដល់ភិក្ខុអ្នកទទួលបញ្ជាប៉ុណ្ណោះ ។ ម្យ៉ាងទៀត ភិក្ខុអ្នកទទួលបញ្ជាមិនធ្វើវត្ថុឲ្យភ្លាត់ទៅសម្លាប់អ្នកនោះតាមបញ្ជាទុក ចំណងផ្លូវកម្មរមែងមានដល់លោកទាំងពីររូប គឺអ្នកបញ្ជាក្នុងខណៈដែលបញ្ជា អ្នកទទួលក្នុងខណៈដែលប្រហារ ។

ចំណែក **កាល** មានវិនិច្ឆ័យដូច្នេះ ភិក្ខុរូបណាបានទទួលពាក្យបញ្ជាថា លោកចូរសម្លាប់ឲ្យស្លាប់ក្នុងវេលាព្រឹក មិនកំណត់ថ្ងៃណាថាថ្ងៃនេះ ឬព្រឹកនេះ ភិក្ខុអ្នកទទួលបញ្ជានោះ សម្លាប់គេស្លាប់វេលាព្រឹកក្នុងកាលណាមួយ ការខុសសង្កេត រមែងមិនមាន ។ ចំណែកភិក្ខុរូបណាបានបញ្ជាទុកថា លោកចូរសម្លាប់ឲ្យស្លាប់ព្រឹកថ្ងៃនេះ ភិក្ខុអ្នកទទួលបញ្ជាសម្លាប់គេស្លាប់ក្នុងវេលាថ្ងៃត្រង់ ឬវេលាល្ងាច ឬវេលាព្រឹកថ្ងៃស្អែក រមែងខុសសង្កេត សម្រាប់ភិក្ខុអ្នកបញ្ជាមិនមានកម្មពន្ធគឺចំណងផ្លូវកម្ម ។ សូម្បីក្នុងកាលភិក្ខុព្យាយាមនឹងសម្លាប់ក្នុងវេលាព្រឹក តែក្លាយទៅជាថ្ងៃត្រង់ទៅវិញ ក៏មានន័យដូចគ្នា បណ្ឌិតគប្បីជ្រាបត្រូវសង្កេតខុសសង្កេតក្នុងប្រភេទកាលទាំងពួង ដោយន័យនេះ ។

## អធិប្បាយឱកាសដែលបញ្ជាឱ្យធ្វើការសម្លាប់

ពោលដោយ **ឱកាស** មានវិនិច្ឆ័យដូច្នេះ ភិក្ខុរូបណាត្រូវបញ្ជាថា លោកចូរសម្លាប់បុគ្គលនោះ អ្នកឈរនៅក្នុងស្រុកឲ្យស្លាប់ តែភិក្ខុអ្នកទទួលបញ្ជានោះ សម្លាប់បុគ្គលនោះស្លាប់ក្នុងទីណាមួយ រមែងមិនខុសសង្កេត ។ ចំណែកភិក្ខុរូបណាបញ្ជាទុកថា ចូរសម្លាប់ឲ្យស្លាប់ក្នុងស្រុកប៉ុណ្ណោះ តែភិក្ខុអ្នកទទួលបញ្ជានោះ សម្លាប់គេស្លាប់ក្នុងព្រៃ មួយទៀតភិក្ខុបញ្ជាថា ចូរសម្លាប់ឲ្យស្លាប់ក្នុងព្រៃ តែលោកសម្លាប់គេស្លាប់ក្នុងស្រុក ភិក្ខុបញ្ជាថា ចូរសម្លាប់ក្នុងព្រៃ តែលោកសម្លាប់គេស្លាប់ត្រង់ទ្វារក្នុងស្រុក សម្លាប់គេស្លាប់ត្រង់កណ្តាលផ្ទះ រមែងខុសសង្កេតទាំងអស់ បណ្ឌិតគប្បីជ្រាបការត្រូវសង្កេត និងការខុសសង្កេត នៃសេចក្តីផ្សេងគ្នា ក្នុងឱកាសទាំងពួងដោយន័យយ៉ាងនេះឯង ។

## អធិប្បាយអាវុធជាគ្រឿងដៃប្រើឱ្យសម្លាប់

ពោលដោយ **អាវុធ** មានវិនិច្ឆ័យដូច្នេះ ភិក្ខុរូបណាបញ្ជាថា លោកចូរយកអាវុធសម្លាប់ឲ្យស្លាប់ មិនបានកំណត់ទុកថា ដាវ ឬកូនសរ ភិក្ខុអ្នកទទួលបញ្ជានោះ យកអាវុធប្រភេទណាមួយឲ្យស្លាប់ រមែងមិនខុសសង្កេត ចំណែកភិក្ខុរូបណាបញ្ជាថា ចូរប្រើដាវសម្លាប់ តែភិក្ខុអ្នកទទួលបញ្ជានោះ ប្រើកូនសរសម្លាប់ ឬបញ្ជាថា ចូរយកដាវពុះក្បាលនេះឲ្យសម្លាប់ អ្នកទទួលបញ្ជាប្រើដាវពុះក្បាលដទៃសម្លាប់ ឬបញ្ជាថា ចូរយកមុខដាវមួយនេះប៉ុណ្ណោះសម្លាប់ តែភិក្ខុអ្នកទទួលបញ្ជា ប្រើមុខដាវក្រៅពីនោះសម្លាប់ ឬប្រើបាតដៃ ឬប្រើទីងចំពុះមាត់ ឬប្រើដងដាវសម្លាប់ រមែងខុសសង្កេត បណ្ឌិតគប្បីជ្រាបការត្រូវសង្កេត និងការខុសសង្កេត ក្នុងសេចក្តីផ្សេងគ្នានៃអាវុធទាំងពួង ដោយន័យនេះ ។

## អធិប្បាយឥរិយាបថដែលបញ្ជាឱ្យធ្វើការសម្លាប់

ពោលដោយ **ឥរិយាបថ** មានវិនិច្ឆ័យដូច្នេះ ភិក្ខុរូបណាបញ្ជាថា លោកចូរសម្លាប់បុគ្គលនោះ ដែលកំពុងដើរឲ្យស្លាប់ តែភិក្ខុអ្នកទទួលបញ្ជានោះ សម្លាប់បុគ្គលអ្នកកំពុងដើរទៅស្លាប់ រមែងមិនខុសសង្កេត ។ កាលបើភិក្ខុបញ្ជាថា លោកចូរសម្លាប់បុគ្គលអ្នកកំពុងដើរទៅប៉ុណ្ណោះឲ្យស្លាប់ តែភិក្ខុអ្នកទទួលបញ្ជា សម្លាប់បុគ្គលអ្នកអង្គុយឲ្យស្លាប់ ឬភិក្ខុអ្នកបញ្ជាបញ្ជាក់ថា លោកចូរសម្លាប់បុគ្គលអ្នកអង្គុយប៉ុណ្ណោះឲ្យស្លាប់ តែភិក្ខុអ្នកទទួលសម្លាប់បុគ្គលអ្នកកំពុងដើរឲ្យស្លាប់ រមែងខុសសង្កេត បណ្ឌិតគប្បីជ្រាបសេចក្តីត្រូវសង្កេត និងខុសសង្កេតក្នុងសេចក្តីផ្សេងគ្នានៃឥរិយាបថទាំងពួង ដោយន័យនេះ ។

## អធិប្បាយកិរិយាវិសេស

ពោលដោយ **កិរិយាវិសេស** មានវិនិច្ឆ័យដូច្នេះ ភិក្ខុរូបណាបញ្ជាថា លោកចូរចាក់ឲ្យស្លាប់ ភិក្ខុអ្នកទទួលបញ្ជានោះចាក់ឲ្យស្លាប់ រមែងមិនខុសសង្កេត ។ ចំណែកភិក្ខុ

រូបណាបញ្ជាថា លោកចូរចាក់ឲ្យស្លាប់ តែភិក្ខុអ្នកទទួលបញ្ជានោះ កាត់ឲ្យស្លាប់តែម្តង រមែងខុសសង្កេត ។ បណ្ឌិតគប្បីជ្រាបសេចក្តីត្រូវសង្កេត ខុសសង្កេតក្នុងសេចក្តីផ្សេងគ្នានៃកិរិយាវិសេសទាំងពួង ដោយន័យយ៉ាងនេះ ។

*នេះជាសេចក្តីពន្យល់ក្នុងអដ្ឋកថាព្រះវិន័យឈ្មោះសមន្តបាសាទិកា ។*

## និស្សគ្គិយប្រយោគ

ការចោលដោយគ្រឿងប្រហារកាយ ឬរបស់ជាប់ដោយកាយ បំណងសម្លាប់សត្វដែលនៅក្នុងទីឆ្ងាយ ហើយបាញ់ពួយគ្រវែងចោលទៅនូវហរណវត្ថុទាំងឡាយមាន ធ្នូ ស្នា លំពែង យន្ត និងដុំថ្មជាដើម ឈ្មោះថា និស្សគ្គិយប្រយោគ ។ សូម្បីនិស្សគ្គិយប្រយោគនោះ ក៏ចែកចេញជាពីរយ៉ាងដូចគ្នា គឺនិស្សគ្គិយប្រយោគចំពោះ និងមិនចំពោះ ។

## ថាវរប្រយោគ

ការជីកអណ្តូង អន្ទង់ និងកិរិយាបង្កប់សស្ត្រាវុធ និងលាយថ្នាំពិសដាក់ក្នុងបឹងឬស្រះជាដើមឲ្យអ្នកដទៃដើរមកធ្លាក់ពុលស្លាប់ក្តី និងគន្លឹះយន្តជាដើម ដើម្បីធ្វើឲ្យគេស្លាប់ឈ្មោះថា **ថាវរបយោគ** ។ សូម្បីថាវរប្រយោគនោះ ក៏ចែកចេញជាពីរ គឺថាវរប្រយោគចំពោះ និងមិនចំពោះ ។ ក៏ក្នុងសេចក្តីនេះជាកម្មពន្ធគឺចំណងដោយកម្ម គប្បីជ្រាបតាមន័យពោលហើយនោះឯង តែសេចក្តីប្លែកគ្នាមានយ៉ាងដូច្នេះ កាលមនុស្សរកជំឡូង ធ្វើរណ្តៅជាដើមជិតៗ ឬធ្វើរណ្តៅទទេក្តី ប្រសិនបើគេស្លាប់ ព្រោះរណ្តៅជាដើមនោះជាបច្ច័យជាកម្មពន្ធ គឺចំណងដោយកម្ម (រមែងដាច់បាណាតិបាត) ដល់អ្នករកជំឡូង ។ ម្យ៉ាងទៀតកាលមនុស្សនោះ ឬមនុស្សដទៃលុបរណ្តៅនោះចេញហើយ ធ្វើផ្ទៃដីឲ្យស្មើ ឬមនុស្សបោសសំរាមកើបសំរាម (យកទៅចាក់ក្នុងរណ្តៅនោះ) ឬមនុស្សជីកជំឡូងធ្វើរណ្តៅទុក កាលភ្លៀងធ្លាក់ភក់ (ទៅក្នុងរណ្តៅនោះ) មនុស្សចុះទៅស្លាប់ក្នុងភក់នោះ ក៏ជា

កម្មពន្ធ ចំណងដោយកម្ម គឺរមែងដាច់បាណាតិបាត ដល់មនុស្សរកជំឡួងនោះ ក៏ប្រសិនបើថា មនុស្សដែលបានជំឡួង ឬមនុស្សដទៃធ្វើរណ្តៅនោះឲ្យទទឹង ឬជ្រៅជាងដើម មនុស្សធ្លាក់ស្លាប់ ព្រោះរណ្តៅទទឹង ឬជម្រៅនោះ ជាកម្មពន្ធ ចំណងដោយកម្មជាប់តគ្នា គឺរមែងដាច់បាណាតិបាត មានដល់មនុស្សពីរនាក់ ។

*សេចក្តីនេះលោកពន្យល់នៅក្នុងព្រះអដ្ឋកថា បរមត្ថជោតិកា ។*

***ដើម្បីសេចក្តីជាក់ច្បាស់ត្រង់ថាវប្រយោគនេះ ខ្ញុំបាទនឹងបញ្ជាក់សេចក្តីនេះ ដែលមាននៅក្នុងព្រះគម្ពីរព្រះវិន័យ ឈ្មោះសមន្តបាសាទិកា តតិយបារាជិក ដូចតទៅនេះ ៖***

ភិក្ខុជីករណ្តៅចំពោះមនុស្សណាខ្វះ ដោយតាំងចិត្តថា អ្នកមានឈ្មោះនេះនឹងធ្លាក់ទៅស្លាប់ក្នុងទីដែលអ្នកនោះត្រាច់ទៅតែម្នាក់ឯង ។ មុនដំបូង បើជីកជាតបបរី ជាទុក្កដគ្រប់ៗប្រយោគដល់ភិក្ខុអ្នកជីក ព្រោះជាប្រយោគនៃបាណាតិបាត។ ជាថុល្លច្ច័យ ព្រោះបង្កឲ្យកើតទុក្ខដល់មនុស្សដែលខ្ទនជីក ចំពោះទុក្ខនោះ ជាបារាជិក ព្រោះគេស្លាប់ ។ កាលអ្នកទទៃសូម្បីធ្លាក់ស្លាប់មិនជាអាបត្តិ ។ បើជីកមិនចំពោះដោយគិតថា អ្នកណាមួយនឹងស្លាប់ ជាបាណាតិបាតតាមចំនួនសត្វដែលធ្លាក់ស្លាប់ ជាអនន្តរិយកម្ម ព្រោះវត្ថុនៃអនន្តរិយកម្ម ជាថុល្លច្ច័យ និងបាចិត្តិយ ព្រោះវត្ថុនៃថុល្លច្ច័យ និងបាចិត្តិយ ។ សួរថា ចេតនាក្នុងការជីករណ្តៅនោះមានច្រើន ជាបារាជិកចេតនាណា ? ឆ្លើយថា លោកពោលទុកក្នុងមហាអដ្ឋកថាមុនថា កាលភិក្ខុជីករណ្តៅដោយចំណែកជ្រៅ ដោយចំណែកវែង និងទទឹងបានប្រមាណ(ខ្នាត) ហើយប្រមូលផ្ទុំទុក ប្រើបន្ទីសម្រាប់ដាក់អាចម៍ដីកើបឡើង ចេតនាដែលញ៉ាំងអត្តឲ្យសម្រេចជាហេតុឲ្យតាំងឡើងមានដូចគ្នាជាមួយផលក្នុងលំដាប់នៃមគ្គ បើសូម្បីកន្លងទៅរហូតដល់មួយរយឆ្នាំ និងមានសត្វធ្លាក់ស្លាប់ប្រាកដ ជាបារាជិកដោយចេតនាជាហេតុឲ្យតាំងឡើងនោះឯង ។ ចំណែកក្នុងមហាបច្ចរីនិងសង្ខេបអដ្ឋកថា លោកពោលទុកថា កាលភិក្ខុប្រើចបប្រហារសូម្បីតែម្តង បុគ្គលនឹងធ្លាក់ត្រង់រណ្តៅនោះស្លាប់ បើមានអ្នកណាភ្លាត់ធ្លាក់ចុះត្រង់រណ្តៅនោះស្លាប់ ជាបារាជិកដូចគ្នា ។ ចំណែកពួកព្រះថេរៈ អ្នកជំនាញក្នុងព្រះសូត្រនៅកាន់យកចេតនាជាហេតុឲ្យតាំងឡើង (ជាគោល) ។

ភិក្ខុមួយរូបជីករណ្តៅ ហើយបញ្ជាភិក្ខុមួយរូបដទៃថា លោកចូរនាំមនុស្ស ឈ្មោះនោះមក ហើយប្រានឲ្យធ្លាក់ស្លាប់ក្នុងរណ្តៅនេះ ។ ភិក្ខុដទៃនោះ ញុំាងអ្នកនោះឲ្យធ្លាក់ស្លាប់ ជាបារាជិកទាំងពីររូប ។ ញុំាងអ្នកដទៃឲ្យធ្លាក់ស្លាប់ ខ្លួនឯងធ្លាក់ទៅស្លាប់ មនុស្សដទៃធ្លាក់ស្លាប់តាមធម្មតារបស់ខ្លួន ក្នុងគ្រប់ករណីខុសសង្កេត ភិក្ខុអ្នកបញ្ជាខាងដើមនោះរួចខ្លួនទៅ ។ សូម្បីក្នុងរណ្តៅដែលភិក្ខុជីកទុកដោយគិតថា ភិក្ខុឈ្មោះនោះ ចូរនាំមនុស្សឈ្មោះនោះមកឲ្យ (ធ្លាក់) ស្លាប់ក្នុងរណ្តៅនេះ មានន័យនេះដូចគ្នា ។ ភិក្ខុជីកទុកដោយគិតថា មនុស្សទាំងឡាយចង់នឹងស្លាប់ និងស្លាប់ក្នុង រណ្តៅនេះចុះ ជាបារាជិក ព្រោះមនុស្សម្នាក់ស្លាប់ជាកងអកុសល ព្រោះមនុស្ស ច្រើននាក់ស្លាប់ ។ ជាថុល្លច្ច័យ និងបាចិត្តិយ ព្រោះវត្ថុនៃថុល្លច្ច័យ និងបាចិត្តិយ ។ ភិក្ខុជីកទុកដោយគិតថា ជនណាមួយមានសេចក្តីប្រាថ្នានឹងសម្លាប់គេឲ្យស្លាប់ និង ប្រានជនទាំងឡាយនោះ ឲ្យធ្លាក់ស្លាប់ក្នុងរណ្តៅនេះចុះ ដូច្នេះ ។ ពួកគេប្រានឲ្យធ្លាក់ស្លាប់ក្នុងរណ្តៅនោះ ។ កាលស្លាប់មនុស្សម្នាក់ ជាបារាជិក ។ កាលស្លាប់មនុស្សច្រើននាក់ជាកងអកុសល ។ ជាអនន្តរិយកម្មជាដើម ព្រោះវត្ថុនៃអនន្តរិយកម្មជាដើម ។ ព្រះអរហន្តទាំងឡាយក៏សង្គ្រោះចូលក្នុងន័យនេះផង ។ តែន័យដំបូង កិរិយាដែលព្រះអរហន្តទាំងឡាយនឹងធ្លាក់ទៅ ព្រោះជាអ្នកប្រាថ្នានឹងស្លាប់រមែងមិនមាន ព្រោះហេតុនោះ ព្រះអរហន្តទាំងឡាយ លោកទើបមិនសង្គ្រោះចូលផង ។ សូម្បីក្នុងន័យទីពីរ កាលបុគ្គលធ្លាក់ទៅស្លាប់តាមធម្មតារបស់ខ្លួន រមែងមានការខុសសង្កេត ។ ភិក្ខុគិតថា ជនណាមួយនឹងប្រានមនុស្សមានពៀររបស់ខ្លួនឲ្យធ្លាក់ស្លាប់ក្នុងរណ្តៅនេះ ហើយជីកទុក ។ នឹងពួកជនមានពៀរនឹងគ្នាក៏ប្រានមនុស្សមានពៀរឲ្យធ្លាក់ស្លាប់ក្នុងរណ្តៅនោះ កាលត្រូវសម្លាប់ស្លាប់មួយនាក់ជាបារាជិក កាលត្រូវសម្លាប់ស្លាប់មនុស្សច្រើននាក់ ជាកងអកុសល កាលមាតាបិតាឬព្រះអរហន្តត្រូវជនអ្នកមានពៀរនាំមកសម្លាប់ឲ្យស្លាប់ក្នុងរណ្តៅនេះ ជាអនន្តរិយកម្ម កាលមាតាជាដើមនោះស្លាប់តាមធម្មតារបស់ខ្លួន រមែងខុសសង្កេត ។

ចំណែកភិក្ខុរូបណាជីកទុក មិនចំពោះដោយប្រការទាំងពួងយ៉ាងនេះថា ជនណាមួយអ្នកចង់នឹងស្លាប់ក្តី មិនចង់នឹងស្លាប់ក្តី អ្នកប្រាថ្នានឹងសម្លាប់គេក្តី មិនប្រាថ្នា នឹងសម្លាប់គេក្តី

នឹងធ្លាក់ទៅស្លាប់ ឬត្រូវប្រាទឲ្យធ្លាក់ស្លាប់ក្នុងរណ្ដៅនេះ ភិក្ខុនោះរមែងត្រូវកម្ម ត្រូវអាបត្តិតាមសមគួរ ព្រោះសេចក្ដីស្លាប់របស់បុគ្គលអ្នកត្រូវស្លាប់នោះៗ ។ បើស្ត្រីមានគភ៌ធ្លាក់ទៅស្លាប់ទាំងកូនក្នុងផ្ទៃ ជាបាណាតិបាត ២ បន្ថែមទៀត ។ ចំពោះសត្វអ្នកនៅក្នុងគភ៌ប៉ុណ្ណោះវិនាសទៅ ជាបាណាតិបាតមួយ សត្វកើតក្នុងគភ៌មិនវិនាស តែមាតាស្លាប់ ជាបាណាតិបាតដូចគ្នា ។ មនុស្សត្រូវពួកចោរដេញតាមធ្លាក់ទៅស្លាប់ ជាបារាជិកដល់ភិក្ខុអ្នកជីករណ្ដៅដូចគ្នា។ ពួកចោរនាំអ្នកធ្លាក់ក្នុងរណ្ដៅនោះ នាំចេញទៅក្រៅ ហើយសម្លាប់ឲ្យស្លាប់ ជាបារាជិកដូចគ្នា ។ <u>សួរថា</u> ព្រោះហេតុអ្វី <u>ឆ្លើយថា</u> គេត្រូវពួកចោរចាប់បាន ព្រោះប្រយោគដែលធ្លាក់ទៅក្នុងរណ្ដៅនោះ ។ អ្នកដែលធ្លាក់ទៅក្នុងរណ្ដៅនោះ ។ ចេញចាករណ្ដៅបានហើយស្លាប់ទៅដោយការឈឺចាប់នោះឯង ជាបារាជិកដូចគ្នា ។ គ្រាកន្លងហួសច្រើនឆ្នាំហើយទើបស្លាប់ ព្រោះសេចក្ដីឈឺចាប់នោះឯងកម្រើកឡើងទៀត ជាបារាជិកដូចគ្នា ។ រោគប្រភេទដទៃកើតប្រៀតឡើងដល់បុគ្គលអ្នកឈឺនោះ ដោយរោគដែលកើតឡើង ព្រោះមានការធ្លាក់ទៅក្នុងរណ្ដៅនោះ ជាបច្ច័យនោះឯង តែរោគកើតឡើង ព្រោះរណ្ដៅជារបស់មានកម្លាំងខ្លាំងជាង សូម្បីកាលបុគ្គលនោះស្លាប់ ព្រោះរោគដែលកើតឡើងនោះ ភិក្ខុអ្នកជីករណ្ដៅរមែងមិនផុតពីអាបត្តិ ។ បើរោគកើតឡើងខាងក្រោយ ជារបស់មានកម្លាំងខ្លាំងសោតកាលអ្នកនោះស្លាប់ ព្រោះរោគដែលកើតឡើងខាងក្រោយ លោករមែងរួចខ្លួន ។ កាលអ្នកនោះស្លាប់ ដោយរោគទាំងពីរប្រភេទ រមែងមិនផុតពីអាបត្តិ។ មនុស្សអ្នកកើតក្នុងរណ្ដៅគ្រាកាលកើតហើយ មិនអាចនឹងឡើងបានក៏ស្លាប់ទៅ ជាបារាជិកដូចគ្នា ។

## មតិរបស់ព្រះថេរៈពីររូបក្នុងការជីករណ្ដៅ

ព្រះឧបតិស្សត្ថេរៈ ពោលថាកាលយក្ខជាដើមធ្លាក់ទៅស្លាប់ក្នុងរណ្ដៅ ដែលភិក្ខុជីកទុកចំពោះមនុស្ស មិនជាអាបត្តិ ។ មនុស្សជាដើម សូម្បីស្លាប់ក្នុងរណ្ដៅដែលភិក្ខុជីកទុកចំពោះយក្ខជាដើម ក៏ន័យនេះ ។ តែជាទុក្កដតែម្ដង ដល់ភិក្ខុអ្នកជីករណ្ដៅ ចំពោះយក្ស

ជាដើម ព្រោះការជីកខ្វះ ព្រោះបង្កទុក្ខឲ្យកើតឡើងដល់យក្សជាដើមនោះខ្វះ ព្រោះ(យក្សជាដើម)ស្លាប់ ជាថុល្លច្ច័យ ឬបាចិត្តិយ តាមអំណាចវត្ថុតែម្តង ។ សត្វធ្លាក់ក្នុងរណ្តៅដែលភិក្ខុជីកទុកមិនបានចំពោះ ដោយរូបយក្សឬរូបប្រេតស្លាប់ទៅ ដោយរូបសត្វតិរច្ឆាន ក៏រូបដែលធ្លាក់ទៅរមែងជាប្រមាណ ព្រោះហេតុនោះ ទើបជាថុល្លច្ច័យ ។

ព្រះបុស្សទេវថេរៈ ពោលថារូបដែលស្លាប់ជាប្រមាណ ព្រោះហេតុនោះ ទើបជាបាចិត្តិយៈ សូម្បីក្នុងសត្វធ្លាក់ទៅដោយរូបសត្វតិរច្ឆាន ហើយស្លាប់ដោយរូបយក្ស និងរូបប្រេត មានន័យនេះដូចគ្នា ។ ភិក្ខុជីករណ្តៅលក់ ឬឲ្យទទេនូវរណ្តៅដល់ភិក្ខុដទៃ ភិក្ខុនោះនៅតែត្រូវអាបត្តិ ព្រោះជាកម្មពន្ធ គឺចំណងផ្លូវកម្ម ព្រោះមានអ្នកស្លាប់ជាបច្ច័យ អ្នកដែលបានរណ្តៅទៅមិនមានទោស ។ ភិក្ខុអ្នកបានរណ្តៅគិតថា រណ្តៅយ៉ាងនេះ សត្វអ្នកធ្លាក់ទៅនៅអាចឡើងបាន នឹងមិនវិនាស នឹងឡើងបានងាយ ទើបធ្វើរណ្តៅនោះឲ្យជ្រៅចុះទៅ ឬឲ្យរាក់ឡើង ឲ្យវែងចេញទៅ ឬឲ្យខ្លីវែងចេញទៅ ឬឲ្យខ្លីចូលមក ឲ្យទទឹងចេញទៅ ឬឲ្យបង្អៀតចូលទៅ ត្រូវអាបត្តិ ជាកម្មពន្ធ គឺចំណងផ្លូវកម្ម សូម្បីទាំងពីររូប ។ កាលកើតវិប្បដិសារីឡើងថា មនុស្ស សត្វនឹងធ្លាក់ស្លាប់ច្រើន ទើបលុបរណ្តៅឲ្យពេញដោយដី ។ បើសត្វណាៗ នៅធ្លាក់ទៅក្នុងដីស្លាប់បាន សូម្បីលុបឲ្យពេញហើយក៏មិនផុត (ពីអាបត្តិ) ។ កាលភ្លៀងធ្លាក់ មានភក់ សូម្បីកាលសត្វណាៗ ជាប់ស្លាប់ក្នុងរណ្តៅភក់នោះ ដើមឈើរលំក្តី ខ្យល់ផាត់ក្តី ទឹកភ្លៀងធ្លាក់ក្តី បាក់ដីចូលទៅ ឬពួកជីកផែនដីដើម្បីដំឡូង ជីកជារណ្តៅគ្រលុកទុកក្នុងទីនោះ បើសត្វណាៗជាប់ ឬធ្លាក់ទៅស្លាប់ក្នុងរណ្តៅនោះ ភិក្ខុអ្នកជាខាងដើមនៅមិនផុត (ពីអាបត្តិ) ។ តែក្នុងឱកាសនោះ ភិក្ខុអ្នកធ្វើបឹង ឬស្រះឈូក អធិដ្ឋានឲ្យប្រតិស្ឋានចេតិយ ដាំដើមពោធិ៍ ឬឲ្យសាងវត្ត ឬឲ្យធ្វើផ្លូវរទេះ ហើយទើបផុតពីអាបត្តិបាន។ សូម្បីក្នុងកាលណា ដើមឈើជាដើម ក្នុងរណ្តៅដែលត្រូវលុបពេញធ្វើឲ្យណែនហើយឫសចាក់ជាប់គ្នា កើតជាជាតបឋវី សូម្បីក្នុងកាលនោះ ក៏ផុតពី អាបត្តិបាន ។ បើសូម្បីស្ទឹងហូរមកលុបគ្របរណ្តៅចេញអស់ហើយ សូម្បីយ៉ាងនោះ ទើបផុតពីអាបត្តិបាន ។

## ពោលដោយការដាក់អន្ទាក់របស់ភិក្ខុ

គប្បីជ្រាបវិនិច្ឆ័យ សូម្បីក្នុងអន្ទាក់ជាដើម ដែលអនុលោមដល់រណ្តៅនោះឯង ដូចតទៅនេះ ភិក្ខុរូបណាដាក់អន្ទាក់ទុកមុន ដោយគិតថា សត្វទាំងឡាយនឹងជាប់ក្នុងអន្ទាក់នេះស្លាប់ កាលអន្ទាក់នោះផុតពីដៃ គប្បីជ្រាបថា ជាបារាជិក អនន្តរិយកម្ម ថុល្លច្ច័យ និងបាចិត្តិយ ដល់ភិក្ខុរូបនោះប្រាកដ ដោយអំណាចសត្វដែលជាប់ (អន្ទាក់)។

***ក្នុងអន្ទាក់ដែលភិក្ខុធ្វើចំពោះទុកមានវិនិច្ឆ័យដូច្នេះ៖***

អន្ទាក់ដែលភិក្ខុដាក់ទុកចំពោះសត្វទាំងឡាយដទៃអំពីសត្វនោះមកជាប់ មិនជាអាបត្តិ។ កាលភិក្ខុចំណាយអន្ទាក់ទៅដោយតម្លៃ ឬឲ្យទទេក៏ដោយ កម្មពន្ធគឺ ចំណងកម្ម រមែងមានដល់ភិក្ខុខាងដើមដូចគ្នា ។ បើភិក្ខុបានអន្ទាក់ទៅដាក់អន្ទាក់ ខុសទីដែលបានដាក់ ឬឃើញសត្វដើរទៅខាងៗ ទើបធ្វើរបងឃាំង ត្រូវសត្វចូលទៅត្រង់មុខ ឬដោតដងអន្ទាក់ឲ្យរឹង ឬចងខ្សែអន្ទាក់ទុកឲ្យមាំឡើង ឬដុំដែកទុកឲ្យមាំ ។ លោកទាំងពីររូប មិនផុត(ពីអាបត្តិ) ។ បើកាលកើតសេចក្តីក្តៅក្រហាយឡើង លោករុះអន្ទាក់ឲ្យរបូតចេញហើយចៀសចេញទៅ ។ មនុស្សដទៃជួបឃើញអន្ទាក់ដែលរូសចេញហើយនោះ យកទៅដាក់ទុកទៀត សត្វទាំងឡាយដែលជាប់(អន្ទាក់) ហើយស្លាប់ទៅ ភិក្ខុអ្នកជាខាងដើម មិនផុតពីអាបត្តិ ។ តែបើដងអន្ទាក់ដែលអ្នកខាងដើមមិនបានធ្វើទុកខ្លួនឯង តែដាក់ទុកក្នុងទីដែលខ្លួនទទួលមក រមែងផុតពីអាបត្តិ លោកកាច់ដងអន្ទាក់ដែលកើតក្នុងស្ថាននោះចេញ រមែងផុតពីអាបត្តិ ។ តែសូម្បីកាលលោករក្សាទុក ឈើដងអន្ទាក់ដែលខ្លួនធ្វើខ្លួនឯងទុក រមែងមិនផុតពីអាបត្តិ ។ មែនពិតបើភិក្ខុរូបដទៃ កាន់យកឈើដងអន្ទាក់នោះទៅ ដាក់អន្ទាក់ទុកទៀតសោត កាលសត្វទាំងឡាយស្លាប់ទៅ ព្រោះមានការដាក់អន្ទាក់នោះជាបច្ច័យ ភិក្ខុអ្នកខាងដើម រមែងមិនផុតពីអាបត្តិ បើលោកដុតដងអន្ទាក់នោះ ធ្វើឲ្យជាដុតភ្លើងហើយ បោះបង់ទៅ សូម្បីកាលសត្វទាំងឡាយ បានការប្រហារដោយដុតភ្លើងនោះស្លាប់ទៅ រមែងមិនផុតពីអាបត្តិ ។ តែដុតធ្វើឲ្យវិនាសហើយ ដោយប្រការទាំងពួង រមែងផុតពីអាបត្តិ ។ លោកដាក់សូម្បីខ្សែអន្ទាក់ដែលមនុស្សដទៃវេញរួចហើយ ទុកក្នុងទីដែលខ្លួនទទួលមក រមែងផុត (ពីអាបត្តិ)

លោកបានខ្សែមកហើយ ត្រូវជាផ្ទួនដែលគេវិញទុកចេញហើយ (ឬ) ធ្វើខ្សែដែលខ្លួនបានថ្មីមកហើយ វិញទុកឲ្យជាចំណិតតូច ចំណិតធំ រមែងផុតពីអាបត្តិ ។ តែកាលលោកបើរក្សាខ្សែដែលខ្លួនឯងនាំមកអំពីព្រៃ វិញទុករមែងរួចផុត ។ តែដុត ឬវិនាស ដោយប្រការទាំងពួងរមែងផុតពីអាបត្តិ ។

*សេចក្តីពណ៌នាទាំងអស់មកនេះ ជាប់ទាក់ទងនឹងព្រះភិក្ខុ និងសាមណេរព្រម ទាំងឧបាសក និងឧបាសិកាទើបខ្ញុំបាទលើកដាក់ក្នុងសៀវភៅនេះ តាមសេចក្តីនៃព្រះអដ្ឋកថាឈ្មោះ សមន្តប្បាសាទិកា តតិយបារាជិក ។*

## វិជ្ជាមយប្រយោគ

ព្យាយាមសម្លាប់អ្នកដទៃ សត្វដទៃដោយកិរិយាពាយមន្តអាគមផ្សេងៗ នឹងគុណវិសេសទាំងឡាយ មានអាបធ្មប់ជាដើម ដើម្បីឲ្យអ្នកដទៃស្លាប់ បើគេស្លាប់ដោយប្រយោគនោះៗ ជាប់ខ្ទូចបាណាតិបាត ។

## ឥទ្ធិមយប្រយោគ

បើខ្លួនមានឥទ្ធិ ឫទ្ធិ ដូចជាឫទ្ធិនាគ ឫទ្ធិគ្រុឌ ឬ ឫទ្ធិយក្ស ទេវតា ឬឫទ្ធិ មហាក្សត្រជាដើម បើចង់ឲ្យអ្នកណាស្លាប់ អ្នកនោះក៏ស្លាប់ដោយនូវឫទ្ធិនោះដូចបំណង រមែងជាប់ខ្ទូចបាណាតិបាត ។ ប្រយោគទាំងឡាយ ៦ នេះ បើចង់ជាក់ច្បាស់ ចូរមើលនៅក្នុងព្រះអដ្ឋកថា ព្រះវិន័យឈ្មោះសមន្តប្បសាទិកា ត្រង់តតិយបារាជិកចុះ នឹងមានពិស្តារ ។

## បាណាតិបាត មានអង្គ ៥

**១- បាណោ** *សត្វមានជីវិត ។*

**២-បាណសញ្ញិតា** *សេចក្តីដឹងថាសត្វមានជីវិត ។*

**៣– វធកចិត្តំ** *គិតនឹងសម្លាប់ ។*

**៤– ឧបក្កមោ** *ព្យាយាមនឹងសម្លាប់ ។*

**៥– តេន មរណំ** *សត្វស្លាប់ដោយព្យាយាមនោះ ។*

*បាណាតិបាតនេះ ជាសភាវៈ ជាសាណត្តិកៈ មានសមុដ្ឋាន ៣ គឺ :*

**កាយចិត្តតោ** *ទោសកើតឡើងអំពីកាយ និងចិត្ត*

**កាយវាចាចិត្តតោ** *ទោសកើតឡើងអំពីកាយវាចា និងចិត្ត*

**វាចាចិត្តតោ** *ទោសកើតឡើងអំពីវាចា និងចិត្ត ។*

*ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម វចីកម្ម ជាអកុសលចិត្ត ជាធម្មៈ ជាកោដ្ឋាសៈ មានជីវិតិន្ទ្រិយ របស់សត្វដែលត្រូវសម្លាប់នោះ ជាអារម្មណ៍ មានទុក្ខវេទនាមួយ មានមូលពីរ គឺទោសមូល១ មោហមូល១ ជាអនិពន្ធសីល ជាសមាទាន មានវិរតិ ៣ ណាមួយ ជាវត្ថុកាម និង កិលេសកាម*

*អនាបជ្ជនៈ ហេតុដែលមិនត្រូវទោសមាន ៦ យ៉ាងគឺ :*

*មិនក្លែង ១ មិនដឹង ១ មិនប្រាថ្នានឹងសម្លាប់ ១ មនុស្សឆ្កួត ១ មនុស្សមានចិត្តរវើរវាយ ១ ជាមនុស្សមានទុក្ខវេទនាគ្របសង្កត់ ១ ។ មានគុណបំណាច់ ឲ្យលះនូវទោសៈ មានផល២ គឺផលចំពោះសិក្ខាបទ ១ ផលចំពោះសីល ១ ។*

## បាណាតិបាតមានទោស

*នៅក្នុងសម្មោហវិនោទនី អដ្ឋកថា ព្រះអភិធម្មបិដកវិភង្គ លោកបានសម្តែងទោសបាណាតិបាតជាភាសាបាលីថា:* **សាវជ្ជតោ បាណាតិបាតោ អត្ថិ អប្បសាវជ្ជោ**

អត្ថិ មហាសាវជ្ជោ ។ តថា អទិន្នាទានាទីនិ ។ តេសំ នានាករណំ ហេដ្ឋា ធម្មិតមេវ ។

*ពោលដោយទោស បាណាតិបាតមានទោសតិចក៏មាន មានទោសច្រើនក៏មាន ។ សិក្ខាបទទាំងឡាយ មានអទិន្នាទានជាដើម ក៏យ៉ាងនោះដែរ ។ ហេតុផ្សេងគ្នានៃសិក្ខាបទទាំងឡាយ លោកសម្តែងទុកខាងក្រោយនោះឯង ។*

## បាណាតិបាតមានទោស

១–កុន្ថកិបិល្លិកស្ស ហិ វធោ អប្បសាវជ្ជោ *ការសម្លាប់សត្វល្អិត តូចៗ ដូចស្រមោចខ្មៅឈ្មោះថា មានទោសតិច*

តតោ មហត្តរស្ស មហាសាវជ្ជោ *សម្លាប់ សត្វដូច្នោះ តែធំជាង មានទោសច្រើនជាង*

សោបិ អប្បសាវជ្ជោ តតោ មហន្តតរាយ សកុណិកាយ មហាសាវជ្ជោ *សម្លាប់សត្វប្រភេទជាប់ទាក់ទងដោយបក្សីធំជាងនោះ មានទោសច្រើនជាងនោះ សម្លាប់ប្រភេទសត្វសកុណាធំជាងនោះ មានទោសច្រើនជាងនោះ ។*

តតោ គោធាយ *សម្លាប់សត្វទន្សងមានទោសច្រើនជាងនោះ*

តតោ សសកស្ស *សម្លាប់សត្វទន្សាយមានទោសច្រើនជាងនោះ*

តតោ មិគស្ស *សម្លាប់សត្វម្រឹគមានទោសច្រើនជាងនោះ*

តតោ គវយស្ស *សម្លាប់គោមានទោសច្រើនជាងនោះ*

**តតោ អស្សស្ស** *សម្រាប់សត្វសេះមានទោសច្រើនជាងនោះ*

**តតោ  ហត្ថិស្ស វធោ មហាសាវជ្ជោ** *សម្រាប់ដំរីមានទោសច្រើន*

*ជាងនោះ*

**តតោ ទុស្សីលមនុស្សស្ស** *សម្រាប់មនុស្សទ្រុស្តសីល   មានទោសច្រើន*

*ជាងនោះ*

**តតោ គោរូបសីលកមនុស្សស្ស** *សម្រាប់មនុស្សអ្នកមានប្រក្រតី  ប្រព្រឹត្តដូចគោ*

*មានទោសច្រើនជាងនោះ*

**តតោ សរណាគតស្ស** *សម្រាប់មនុស្សអ្នកដល់ត្រៃសរណគមន៍*

*មានទោសច្រើនជាងនោះ*

**តតោ បញ្ចសិក្ខាបទិស្ស** *សម្រាប់មនុស្សអ្នកតាំងនៅក្នុងសីល ៥ មាន*

*ទោសច្រើនជាងនោះ*

**តតោ សាមណេរស្ស** *សម្រាប់សាមណេរមានទោសច្រើនជាងនោះ*

**តតោ បុថុជ្ជនភិក្ខុនោ** *សម្រាប់ភិក្ខុជាបុថុជ្ជនមានទោសច្រើនជាងនោះ*

**តតោ សោតាបន្នស្ស** *សម្រាប់សោតាបន្នមានទោសច្រើនជាងនោះ*

**តតោ សកទាគាមិស្ស** *សម្រាប់សកទាគាមីមានទោសច្រើនជាងនោះ*

**តតោ អនាគាមិស្ស** *សម្រាប់អនាគាមីមានទោសច្រើនជាងនោះ*

**តតោ ចិណ្ណាសវស្ស វធោ អតិមហាសាវជ្ជោយេវ** *សម្ងាប់*

*ព្រះខីណាស្រពមានទោសច្រើនមហាក្រៃលែង ។*

*នៅក្នុង**បរមត្ថទីបនី** អដ្ឋកថា ខុទ្ទកនិកាយ ឥតិវុត្តកៈ ត្រង់បុត្តសូត្រ ពន្យល់ថា : បាណាតិបាតនេះ ឈ្មោះថា មានទោសតិច ព្រោះសត្វតិរច្ឆានជាដើម ដែលប្រាសចាកគុណ ជាសត្វដែលមានជីវិតតូចៗ ។ ឈ្មោះថា មានទោសច្រើន ព្រោះសត្វ មានជីវិតធំ ។ ព្រោះហេតុអ្វី ? ព្រោះមានប្រយោគធំ សូម្បីកាលមានប្រយោគប៉ុណ្ណោះ បាណាតិបាត ឈ្មោះថា មានទោសច្រើន ព្រោះមានវត្ថុធំជាច្រើន ។ បណ្តាមនុស្សជាដើម ជាអ្នកមានគុណធម៌ ព្រោះអ្នកមានគុណធម៌តិច បាណាតិបាត មានទោសតិច ព្រោះអ្នកមានគុណធម៌ច្រើនក៏មានទោសច្រើន តែកាលរាងកាយនិងគុណធម៌ស្មើគ្នា បាណាតិបាត ឈ្មោះថា មានទោសតិច ព្រោះកិលេស និងសេចក្តីទន់ខ្សោយ មានទោសច្រើន ព្រោះកិលេស និងសេចក្តីព្យាយាមខ្លាំងក្លា ម្យ៉ាងទៀត ក្នុងរឿងនៃបាណាតិបាតនេះ ការដែលបាណាតិបាត មានទោសច្រើន ព្រោះមានប្រយោគនិងវត្ថុធំជាដើម គប្បីជ្រាបដោយមានចេតនាកើតឡើង ព្រោះបច្ច័យទាំងនោះ មានកម្លាំង ។ ប្រយោគធំដែលបានព្រោះចេតនាដែលជាតួឲ្យសម្រេច ក៏ញុំាងកិច្ចរបស់ខ្លួនឲ្យសម្រេច ដោយអំណាចប្រយោគតាមដែលខ្លួនប្រាថ្នាឲ្យសម្រេច ដោយចាប់ហ័ស នឹងបានសេវនៈ ដោយជវនៈទាំងឡាយ ដែលប្រព្រឹត្តទៅច្រើនដង គ្រាខ្លះ កាលប្រយោគស្មើគ្នាទាំងក្នុងសត្វដែលមានជីវិតតូច និងធំសូម្បីមានចេតនារបស់អ្នកសម្លាប់សត្វធំមានកម្លាំងខ្លាំងជាង នឹងកើតឡើងព្រោះដូច្នោះ សូម្បីវត្ថុជារបស់ធំទើបជាហេតុនៃចេតនាមានកម្លាំងជាង ដូច្នេះទាំងពីរយ៉ាងនេះ ទើបជាបាណាតិបាតមានទោសច្រើន ដោយការៈដែលចេតនាមានកម្លាំងខ្លាំងនោះឯង ។ ម្យ៉ាងទៀត កាលសត្វនឹងត្រូវស្លាប់មានគុណធម៌ច្រើន បាណាតិបាតនោះមានទោសច្រើន គប្បីឃើញថា សូម្បីចេតនាមិនជាឧបការៈដល់ការញុំាងខេត្តពិសេសឲ្យសម្រេច ជាចេតនាមានកម្លាំង និងខ្លាំងក្លាជាង នឹងកើតឡើងដូចចេតនាជាឧបការៈដែលប្រព្រឹត្តទៅហើយក្នុងសត្វដែលនឹងសម្លាប់នោះ ព្រោះ*

ហេតុនោះ កាលបច្ច័យទាំងឡាយ មានប្រយោគនិងវត្ថុជាដើមមិនធំ គប្បីជ្រាបសេចក្តីដែលបាណាតិបាតមានទោសច្រើន ដោយអំណាចចេតនាមានកម្លាំង ព្រោះបច្ច័យទាំងឡាយមានភាព ជាអ្នកមានគុណធម៌ច្រើនជាដើមនោះឯង ។ នៅក្នុង **បរមត្ថជោតិកា** អដ្ឋកថា ខុទ្ទកនិកាយ ខុទ្ទកបាឋៈ និងមាននៅក្នុង **បរមត្ថទីបនី** អដ្ឋកថា ខុទ្ទកនិកាយ ឥតិវុត្តកៈ ត្រង់បុត្តសូត្រ បានសម្តែងផលការមិនធ្វើបាណាតិបាតមាន ២៣ យ៉ាងគឺ ៖

**១–អង្គបច្ចង្គសមន្នតា** បូរបូណ៌ដោយអវយវៈ តូច ធំ (មានរាងកាយល្អ សមទ្រង់មិនវិកលវិការ) ។

**២–អារោហបរិណាហសម្បត្តិ** ប្រកបដោយរាងកាយខ្ពស់ ហើយសមទ្រង់ ។

**៣–ជវនសម្បត្តិ** ជាមនុស្សសម្បូណ៌ដោយការវាងវៃល្អ ។

**៤–សុបតិដ្ឋិតបាទតា** ភាពជាមនុស្សមានជើងតាំងនៅស៊ប់ល្អ ។

**៥–ចារុតា** ភាពជាមនុស្សមានសេចក្តីជ្រះថ្លារុងរឿងផង ។

**៦–មុទុតា** ភាពជាមនុស្សទន់ភ្លន់គួរសមផង ។

**៧–សុចិតា** ភាពជាមនុស្សស្អាតល្អផង ។

**៨–សុខិតា** ភាពជាមនុស្សជួបប្រទះនឹងសុខច្រើន ។

**៩–សូរតា** ភាពជាមនុស្សក្លៀវក្លា (ក្នុងបរិស័ទ) ផង ។

**១០–មហព្វលតា** ភាពជាមនុស្សមានកម្លាំងច្រើនណាស់ផង ។

**១១-វិសដ្ឋវចនតា ( វិស្សត្ថវចនតា )** *ភាពជាមនុស្សមានវាចាពីរោះក្បោះក្បាយផង ។*

**១២-សត្តានំ បិយមនាបតា** *ភាពជាមនុស្ស ដែលគេស្រលាញ់ ពេញចិត្តរបស់សត្វទាំងឡាយ ។*

**១៣-អភិជ្ជបរិសតា (អភេជ្ជបរិសតា)** *ភាពជាមនុស្សមានបរិស័ទ មិនបែកបាក់ពីខ្លួនផង ។*

**១៤-អជម្ពិតា** *ភាពជាមនុស្សមិនតក់ស្លុតភ័យខ្លាចអ្វីផង។*

**១៥-ទុប្បធំសិតា** *ពួកសឹកសត្រូវប្រទូស្តមិនបានផង ។*

**១៦-បរូបក្កាមេន អមរណតា** *ជាមនុស្សមិនស្លាប់ ដោយសេចក្តីព្យាយាមនៃអ្នកដទៃឡើយ ។*

**១៧-មហាបរិវារតា ( អនន្តបរិវារតា )** *ជាមនុស្ស មានបរិវារច្រើនគ្មានទីបំផុត ។*

**១៨-សុវណ្ណតា** *ភាពជាមនុស្សមានសម្បុរដូចមាស (សុរូបតា) ភាពជាមនុស្សមានរូបល្អស្រស់ផង ។*

**១៩-សុសណ្ឋានតា** *ភាពជាមនុស្សមានទ្រង់ទ្រាយល្អផង ។*

**២០-អប្បាពធតា** *ភាពជាមនុស្សមានជំងឺតិចផង ។*

**២១-អសោកតា (អសោកិតា)** *ភាពជាមនុស្សមិនខូចចិត្តដោយសោកឡើយ ។*

២២-បិយមនាបេហិ អវិប្បយោគតា បិយេហិ មនាបេហិ សទ្ធិំអវិប្បយោគតា *មិនបានព្រាត់ប្រាសនិរាសចោលសត្វ ព្រមទាំងសង្ខារដែលជាទីស្រលាញ់ និងជាទីគាប់ចិត្តផង ។*

២៣-ទីឃាយុកតា (ទីឃាភាយុតា) *ភាពជាមនុស្ស មានអាយុវែងទៅតាមកាល។*

**បាណាតិបាតសិក្ខាបទទី ១ ចប់**

## អទិន្នាទានសិក្ខាបទទី២

២– *អទិន្នាទានា : នៅក្នុង* ***សទ្ធម្មប្បកាសិនី*** *អដ្ឋកថា ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ពន្យល់ពាក្យអទិន្នាទានថា ពាក្យថា* ***អទិន្នា*** *បានដល់របស់ដែលគេមិនបានឲ្យ គឺរបស់ដែលមនុស្សដទៃហួងហែងរក្សា ។ មនុស្សដទៃបានទទួលរបស់ដែលខ្លួនធ្វើតាមសេចក្ដីប្រាថ្នាជាអ្នកមិនគួរបានទទួលអាជ្ញា នឹងមិនគួរតិះដៀលក្នុងវត្ថុណា កាលវត្ថុនោះ មានមនុស្សដទៃហួងហែង ខ្លួនក៏ដឹងថាមនុស្សដទៃហួងហែង ថេយ្យចេតនាដែលក្លែងលួចប្រព្រឹត្តទៅក្នុងទ្វារណាមួយ មានកាយទ្វារ វចីទ្វារ ដែលតាំងឡើងដោយសេចក្ដីព្យាយាម ដែលនឹងកាន់យករបស់នោះ ឈ្មោះថា* **អទិន្នាទាន** ។

*នៅក្នុង* ***បរមត្ថទីបនី*** *អដ្ឋកថា ខុទ្ទកនិកាយ ឥតិវុត្តកៈ ពន្យល់ថា : ការកាន់យករបស់ដែលគេមិនបានឲ្យ ឈ្មោះថា* **អទិន្នាទាន** *។ លោកពោលអធិប្បាយទុកថា ការនាំយករបស់អ្នកដទៃទៅ គឺការលួចបានដល់ភាពជាចោរ ។ បណ្ដាបទទាំងនោះ បទថា* **អទិន្នំ** *បានដល់របស់ដែលអ្នកដទៃហួងហែងថែរក្សា ។ មនុស្សដទៃ ដល់ភាពជាអ្នកធ្វើតាមពេញចិត្តក្នុងរបស់អ្នកដទៃហួងហែងយ៉ាងណា (សូម្បី)មិនគួរ បានទទួលទោសទណ្ឌ និងមិនត្រូវតិះដៀល* **ថេយ្យចេតនា** *របស់អ្នកដែលមានសេចក្ដីសម្គាល់ក្នុងវត្ថុរបស់អ្នកដទៃហួងហែងនោះថា ជារបស់អ្នកដទៃហួងហែង ញុំាងសេចក្ដីព្យាយាមកាន់យករបស់នោះឲ្យតាំងឡើង ឈ្មោះថា* **អទិន្នាទាន**។

*លោកបានសម្ដែងទុកអំពីអវហារការលួចនេះនៅក្នុង សមន្តប្បសាទិកាភាគ ២ ទំព័រ ២១៦ ត្រង់ទុតិយបារាជិកវណ្ណនាថា* **បញ្ច បញ្ចកានិ នាម នានាភណ្ឌបញ្ចកំ**

ឯកកភណ្ឌបញ្ចកំ សាហត្ថិកបញ្ចកំ បុព្វប្បយោគបញ្ចកំ ថេយ្យាវហារ-បញ្ចកំ ។

*ឈ្មោះថា បញ្ចកៈ៥ គឺនានាភណ្ឌបញ្ចកៈពួក១ ឯកកភណ្ឌបញ្ចកៈពួក១ សាហត្ថិក-បញ្ចកៈពួក១ បុព្វប្បយោគបញ្ចកៈពួក១ ថេយ្យាវហារបញ្ចកៈពួក១ ។ ប្រភេទនៃការលួចទាំងអស់មាន ២៥ ចាត់ជា ៥ ពួកយ៉ាងនេះឯង ។*

## នានាបញ្ចកៈពួកទី ១ មាន ៥ គឺ

**១- អទិយេយ្យ** *អ្នកលួចបានចោទប្រកាន់យកទ្រព្យគេមានស្រែ ចម្ការ ជាដើម តែម្ចាស់ទ្រព្យគេកាត់អាល័យ ខ្លួនឯងអ្នកលួចក៏ដាក់ធុរៈ ថាអញមិនឲ្យវិញទេ ដាច់ខ្លួចអទិន្នាទានសិក្ខាបទ ។*

**២- ហរេយ្យ** *អ្នកលួចបាននាំទៅនូវភណ្ឌៈរបស់អ្នកដទៃ ដោយមានថេយ្យចិត្តញ៉ាំងវត្ថុដែលនៅលើក្បាល លើក លើស្មា លើចង្កេះ ឲ្យឃ្លាតផុតចាកទីឋាន ប៉ុនចម្រៀកសក់ ក៏ដាច់ខ្លួច អទិន្នាទានសិក្ខាបទ ។*

**៣- អវហរេយ្យ** *អ្នកលួចបានយកទ្រព្យគេ ដែលគេផ្ញើទុកនឹងខ្លួនដល់ម្ចាស់គេមកទារ មិនឲ្យទៅគេ តែម្ចាស់គេដាច់អាល័យ ក៏ដាច់ខ្លួច អទិន្នាទានសិក្ខាបទ ។*

**៤- ឥរិយាបថំ វិកោបេយ្យ** *អ្នកលួចយកបានទ្រព្យគេ យកទាំងម្ចាស់ទ្រព្យទៅផង តែនាំទៅឲ្យផុតជំហានជាគម្រប់ពីរ ក៏ដាច់ខ្លួច អទិន្នាទានសិក្ខាបទ ។*

**៥- ឋានាចាវេយ្យ** *អ្នកលួចបានយកទ្រព្យគេដែលនៅលើគោក នាំយកទៅឲ្យឃ្លាតចាកទីប៉ុនចម្រៀកសក់ ក៏ដាច់អទិន្នាទានសិក្ខាបទ ។*

**ឯកភណ្ឌបញ្ចកពួកទី ២ នោះមាន ៥ យ៉ាងគឺ**

១- **អតិយេយ្យ** *អ្នកលួចបានចោទខ្ញុំកំដរ និងសត្វចិញ្ចឹមរបស់គេ ដាច់ខូចអទិន្នាទានសិក្ខាបទ ។*

២- **ហារេយ្យ** *អ្នកលួចបានជួយនាំទៅនូវខ្ញុំកំដរនិងសត្វចិញ្ចឹមរបស់គេ ហើយមានថេយ្យចិត្ត ក៏លួចយកទៅតែម្តង ដាច់ខូចអទិន្នាទានសិក្ខាបទ ។*

៣- **អវហារេយ្យ** *អ្នកលួចបានប្រវញ្ចយកខ្ញុំកំដរនិងសត្វចិញ្ចឹម របស់គេដែលគេផ្ញើទុកនឹងខ្លួន ដាច់ខូច អទិន្នាទានសិក្ខាបទ ។*

៤- **ឥរិយាបថំ វិកោបេយ្យ** *អ្នកលួចមានថេយ្យចិត្តធ្វើ ឥរិយាបថនៃខ្ញុំកំដរនិងសត្វចិញ្ចឹមរបស់គេ ឲ្យកម្រើកដាច់ខូច អទិន្នាទានសិក្ខាបទ ។*

៥- **ឋានា ចាវេយ្យ** *អ្នកលួចមានថេយ្យចិត្តធ្វើខ្ញុំកំដរ និងសត្វចិញ្ចឹមរបស់គេឲ្យឃ្លាតចាកទី ដាច់ខូច អទិន្នានទានសិក្ខាបទ ។*

*នានាភណ្ឌបញ្ចកៈពួកទី ១ នោះ លោកសំដៅយកវត្ថុដែលមានវិញ្ញាណ និងវត្ថុដែលឥតវិញ្ញាណ ចំណែកខាងឯកភណ្ឌបញ្ចកៈពួកទីពីរ សំដៅយកវត្ថុដែលមានវិញ្ញាណប៉ុណ្ណោះ ។*

**សាហត្ថិកបញ្ចកៈពួកទី ៣ មានអវហារ ៥ គឺ**

១- **សាហត្ថិកៈ** *អ្នកលួចកាន់យកដោយដៃខ្លួនឯង ដាច់ខូចអទិន្នាទានសិក្ខាបទ ។*

២- **អាណត្តិកៈ** *អ្នកលួចបានប្រើបង្គាប់អ្នកដទៃឲ្យលួចទ្រព្យគេ បើអ្នកដទៃលួចបានមកតាមបង្គាប់ដាច់ខូច អទិន្នាទានសិក្ខាបទ ។*

**៣– និស្សគ្គិយ** អ្នកលួចបានទ្រព្យគេ ដោយបោះរំលងទីមានរបង និងទ្វារជាដើម ឬរត់រំលងគយព្រះរាជធានី ដាច់ខ្លួច អទិន្នាទានសិក្ខាបទ ។

**៤– អត្ថសាធកៈ** អ្នកលួចញុំាងប្រយោជន៍ឲ្យសម្រេចជាមុន អំពីកិរិយាលួច គឺបង្គាប់អ្នកដទៃថា អ្នកណាលួចរបស់នៃជនឯណោះបាន ក្នុងកាលណាចូរលួច ក្នុងកាលនោះចុះ ប្រសិនបើអ្នកដទៃលួចបានមែន ខ្លួនអ្នកបង្គាប់ដាច់ខ្លួច អទិន្នាទានសិក្ខាបទ ។

**៥– ធុរនិក្ខេបៈ** អ្នកលួចបានលួចទ្រព្យគេសម្រេចដោយការដាក់ធុរៈ ដូចលួច ចោទប្រកាន់យកដីជាដើម ឬរបស់ផ្ញើទុកនឹងខ្លួន ពុំនោះសោត របស់ដែលខ្លួនបានខ្ចីគេមក បើខ្លួនដាក់ធុរៈថា អញមិនឲ្យ ឯម្ចាស់ទ្រព្យក៏គេដាច់អាល័យ ដាច់ខ្លួច អទិន្នាទានសិក្ខាបទ ។

## បុព្វបយោគបញ្ចកៈពួកទី ៤ មាន ៥ គឺ :

**១– បុព្វបយោគៈ** ប្រកបក្នុងខាងដើម ។

**២– សហប្បយោគៈ** អ្នកលួចបានលួចទ្រព្យគេ ដោយព្យាយាមខ្លួនឯង មានបង្ខិតបង្គោលព្រំឲ្យចូលទៅក្នុងទីស្រែចម្ការជាដើម ចំនួនទីប៉ុនចុងសក់ ដាច់ខ្លួចអទិន្នាទានសិក្ខាបទ ។

**៣– សំវិធាវហារ** អ្នកលួចបបួលគ្នាទៅលួចទ្រព្យគេ បើអ្នកណាមួយ លួចបានមកក៏ដាច់ខ្លួច អទិន្នាទានសិក្ខាបទ ។

**៤– សង្កេតកម្ម** អ្នកលួចប្រើអ្នកដទៃឲ្យទៅលួចទ្រព្យគេ ដោយកំណត់កាល មានវេលាព្រឹកជាដើម បើអ្នកដទៃលួចបានមែនត្រូវតាមកំណត់ កាលដែលប្រើបង្គាប់នោះ ដាច់ខ្លួចអទិន្នាទានសិក្ខាបទ ។

**៤- និមិត្តកម្ម** ការធ្វើនិមិត្តអ្នកលួចគិតនឹងលួចទ្រព្យគេ ដោយធ្វើនិមិត្តកម្ម មានកិរិយាប៉ព្រិចភ្នែក និងកិរិយាញាក់មុខជាដើម ដើម្បីឲ្យសញ្ញាដល់អ្នកដែលខ្លួនប្រើឲ្យទៅលួច បើអ្នកនោះ លួចបានមកតាមសញ្ញានោះមែន ដាច់ខ្លួច អទិន្នាទានសិក្ខាបទ ។

## ថេយ្យាវហារបញ្ចកៈពួកទី ៥ មាន ៥ គឺ

**១- ថេយ្យាវហារ:** អ្នកលួចបានលបកាត់ជញ្ជាំងជាដើម ហើយលបចូល លួចរបស់គេក្តី បោកប្រាស់យករបស់គេក្តីដោយរង្វាស់រង្វាល់ខ្វះ ឬលើស និងកហាបណៈក្លែងក្លាយជាដើម ដាច់ខ្លួចអទិន្នាទានសិក្ខាបទ ។

**២- បសយ្ហាវហារ:** អ្នកលួចកំហែងសន្ធត់សន្ធិន ប្លន់ ឬ ឆក់ដណ្តើមយកទ្រព្យរបស់អ្នកដទៃ ដាច់ខ្លួច អទិន្នាទានសិក្ខាបទ ។

**៣- បរិកប្បាវហារ:** អ្នកលួចទ្រព្យគេដោយកិរិយាកំណត់ទុក កិរិយាកំណត់ក្នុងទីនេះមាន ២ យ៉ាងគឺ ភណ្ឌបរិកប្ប: កំណត់ដោយទ្រព្យ ១ ឱកាស បរិកប្ប: កំណត់ដោយឱកាស ១

ខ្ញុំបាទនឹងពន្យល់អំពីភណ្ឌបរិកប្ប: ឱកាស បរិកប្ប: កំណត់ដោយទ្រព្យតាមសេចក្តីដែលមានមកក្នុងសមន្តប្បាសាទិកា ដូចតទៅ : ឯកំណត់ទ្រព្យនោះ ដូចជាខ្លួនអ្នកលួចមានសេចក្តីត្រូវការដោយសំពត់សាដក ទើបចូលទៅខាងក្នុងបន្ទប់ ដោយតាំងចិត្តថា បើនឹងជាសំពត់សាដក យើងនឹងកាន់យក បើនឹងជាអំបោះ យើងនឹងមិនកាន់យក ហើយកាន់យកការុងក្នុងទីងងឹត ។ បើការុងនោះមានសំពត់សាដក ដាច់ខ្លួចអទិន្នាទានក្នុងខណៈលើកឡើងនោះឯង ។ បើមានអំបោះនៅរក្សា ។ លោកនាំយកទៅខាងក្រៅ ទើបដឹងខ្លួនថាជាអំបោះ ទើបនាំមកដាក់ទុកកន្លែងដើមវិញ នៅរក្សាដូចគ្នា គឺមិនដាច់ខ្លួចអទិន្នាទាន ។ សូម្បីដឹងថា ជាអំបោះហើយ ដើរទៅដោយគិតថាបានវត្ថុណា ក៏កាន់យកវត្ថុនោះ គប្បីដាច់

អទិន្នាទានដោយជំហានជើង ។ ដាក់ទុកលើផែនដីហើយកាន់យក ដាច់អទិន្នាទានក្នុងខណៈលើកឡើង ។ លោកត្រូវម្ចាស់របស់ដេញតាមស្រែកថាចោរៗ ទើបលះបង់ហើយទើបចៀសចេញទៅនៅរក្សា គឺអត់ទាន់ត្រូវទោសអ្វីឡើយ ។ ពួកម្ចាស់របស់ជួបហើយកាន់យកការកាន់យក យ៉ាងនោះជាការល្អ បើមនុស្សដទៃកាន់យកជាភណ្ឌទេយ្យ គឺខ្លួនត្រូវសងគេ ។ តែបើម្ចាស់របស់ត្រឡប់ទៅហើយ លោកឃើញរបស់នោះខ្លួនឯង ដោយគិតថា របស់នេះយើងនាំមកឥឡូវនេះ ជារបស់យើង ដូច្នេះនៅរក្សា គឺមិនទាន់ត្រូវទោស តែជាភណ្ឌទេយ្យ គឺខ្លួនត្រូវសងគេ ។ សូម្បីកាលកំណត់សម្គាល់ទុកហើយកាន់យក ដោយន័យជាដើមថា បើនឹងជាអំបោះ យើងនឹងកាន់យក បើនឹងជាសំពត់សាដក យើងនឹងមិនកាន់យក បើជាទឹកដោះថ្លា យើងនឹងកាន់យក បើជាប្រេងយើងនឹងកាន់យក ដូច្នេះក៏មានន័យដូចគ្នា ។

ចំណែកនៅក្នុងអដ្ឋកថាមហាបច្ចរីជាដើម លោកពោលទុកថា សូម្បីមានសេចក្តីត្រូវការដោយសាដក កាន់យកការុងសំពត់សាដកនោះឯងចេញទៅដាក់ទុកខាងក្រៅ បើកចេញហើយឃើញថា នេះជាសំពត់សាដក ហើយទៅគប្បីពិន័យ ដោយការលើកជើងឡើងនោះឯង ។ នៅក្នុងអដ្ឋកថាមហាបច្ចរីជាដើមនេះ ការកំណត់រមែងប្រាកដ ព្រោះអ្នកលួចបានសម្គាល់កំណត់វត្ថុទុកថា បើនឹងជាសំពត់សាដក យើងនឹងកាន់យក **បរិកប្បាវហារ** មិនប្រាកដព្រោះឃើញ ទើបលួច តែក្នុង មហាអដ្ឋកថា លោកពិន័យអវហារដល់អ្នកលួចលើកឡើងនូវភណ្ឌៈដែលកំណត់ទុក ខ្លួននៅមិនបានឃើញក៏ដោយចុះ តែក៏គង់តាំងនៅក្នុងភាពជារបស់ខ្លួនកំណត់ទុកនោះឯង ។ ព្រោះហេតុនោះ **បរិកប្បាវហារ** ទើបប្រាកដក្នុងមហាអដ្ឋកថានោះ ។ អវហារដែលពោលទុកក្នុង មហាអដ្ឋកថានោះ សមដូចព្រះបាលីថា **តំ មញ្ញមានោ តំ អវហរិ** សម្គាល់ថា ជាវត្ថុនោះ លួចវត្ថុនោះ ដូច្នេះឯង។ បណ្តាបរិកប្បៈទាំងពីរ ការកំណត់ណា ដែលប្រព្រឹត្តទៅដោយន័យជាដើមថា បើនឹងជាសំពត់យើងនឹងកាន់យក ដូច្នេះការកំណត់នេះឈ្មោះថា **ភណ្ឌបរិកប្បៈ** ។

## អធិប្បាយឱកាសបរិកប្ប

កំណត់ឱកាសនោះ ដូចជាអ្នកលួចចូលទៅកាន់បរិវេណរបស់អ្នកដទៃ ឬផ្ទះរបស់ត្រកូល ឬរោងដែលគេធ្វើការងារក្នុងព្រៃក្តី ហើយអង្គុយនៅក្នុងទីនោះ ដោយការសន្ទនាប្រាស្រ័យគ្នា សម្លឹងមើលបរិក្ខារដែលជាទីតាំងនៃសេចក្តីលោភខ្លះ ក៏ឯកាលសម្លឹងមើលជួបឃើញហើយ ទើបធ្វើការកំណត់ដោយស្ពានមានទ្វារយ៉មុខ ខាងក្នុងប្រាសាទបរិវេណស៊ុមទ្វារ និងគល់ឈើជាដើម ហើយកំណត់ទុកថា បើពួកម្ចាស់ទ្រព្យឃើញអញត្រង់ទីឱកាសនេះ អញនឹងធ្វើហាក់ដូចជាចាប់កាន់មើល នឹងសងឲ្យដល់គេទាំងនោះវិញ បើពួកគេមិនឃើញសោត យើងនឹងលួចយកដូច្នេះ ។ លុះមកាន់យកទ្រព្យនោះកន្លងហួសដែនកំណត់ទុកនោះឯង ជាច់ខូច អទិន្នាទានសិក្ខាបទ ។ បើអ្នកលួចកំណត់ដែនឧបចារៈទុកដើរតម្រង់មុខទៅផ្ទះនោះឯង មនសិការៈព្រះកម្មដ្ឋានជាដើមក្តី បញ្ជូនចិត្តទៅផ្លូវដទៃក្តី ឈានកន្លងដែនឧបចារៈទៅដោយទាំងមិនមានសតិ ជាភណ្ឌទេយ្យជាសំណាង ។ សូម្បីអ្នកលួចនោះ ទៅទីនោះហើយ ចោរ ដំរី សត្វសាហាវ ឬមហាមេឃតាំងឡើង និងអ្នកនោះឈានកន្លងស្ពាននោះ ដោយរហ័ស ព្រោះប្រាថ្នាឲ្យរួចផុតពីឧបទ្ទវៈនោះ ជាភណ្ឌទេយ្យដូចគ្នា ។ ក្នុងពាក្យនេះ អាចារ្យពួកខ្លះពោលថា ព្រោះក្នុងខាងដើមនោះឯង អ្នកលួចកាន់យកដោយថេយ្យចិត្ត ព្រោះហេតុនោះទើបរក្សា មិនបានគឺមិនរួចផុតពីទោស ។ នេះជាន័យមានមកក្នុងមហាអដ្ឋកថាសិន ។ ចំណែកក្នុងមហាបច្ចរី លោកពោលទុកថា សូម្បីបើអ្នកលួចនោះឡើងជិះដំរី ឬសេះខាងក្នុងដែនកំណត់នោះហើយនៅមិនបរដំរី ឬសេះទៅដោយខ្លួនឯង ទាំងមិនប្រើអ្នកដទៃបរទៅ សូម្បីកាលហួសកំណត់ដែនទៅ រមែងភណ្ឌទេយ្យ គឺត្រូវសងគេប៉ុណ្ណោះ ។

ក្នុងបរិកប្បទាំង ២ យ៉ាងនេះ ការកំណត់ដែលប្រព្រឹត្តទៅថា បើម្ចាស់ទ្រព្យឃើញអញក្នុងឱកាសនេះ អញនឹងធ្វើហាក់ដូចជាចាប់កាន់មើល នឹងសងឲ្យដល់ម្ចាស់គេទាំងនោះវិញ នេះឈ្មោះថា **ឱកាសបរិកប្បៈ** ។ អវហារដែលកំណត់ទុក ហើយកាន់យកដោយ

អំណាចនៃកំណត់សូម្បីទាំង ២ នោះ ដូចពណ៌នាមកយ៉ាងនេះ ឈ្មោះថា **បរិកប្បាវហារ** ។ អវហារដែលកំណត់ទុកហើយកាន់យកដោយអំណាចនៃកំណត់ សូម្បីទាំង ២ នោះ ដូចពណ៌នាមកយ៉ាងនេះ ឈ្មោះថា **បរិកប្បាវហារ** ។

**៤– បដិច្ឆន្នាវហារ** ចំណែកការបិទបាំងទុកហើយលួច ឈ្មោះថា **បដិច្ឆន្នាវហារ** ។ បដិច្ឆន្នាវហារនោះ គប្បីជ្រាបយ៉ាងនេះ ក៏បុគ្គលណា កាលពួកមនុស្សកំពុងលេង ឬកំពុងចូលទៅក្នុងសួនជាដើម ឃើញគ្រឿងអលង្ការដែលគេដោះទុក គិតថា បើយើងនឹងឱនចុះកាន់យក ពួកមនុស្សនឹងដឹងថាអ្នកនេះកាន់យកអ្វី ? ហើយបៀតបៀនយើង ទើបយកដី ឬស្លឹកឈើបិទបាំងទុកដោយធ្វើក្នុងចិត្តថា ខាងក្រោយនឹងកាន់យក ដូច្នេះត្រឹមប៉ុណ្ណោះ ការលើកឡើងនូវរបស់នោះ នៅមិនមានដល់អ្នកលួចនោះ ព្រោះហេតុនោះទើបនៅមិនជាអវហារ ។ តែកាលណា ពួកមនុស្សទាំងឡាយនោះ ប្រាថ្នាចូលទៅខាងក្នុងស្រុក សូម្បីស្វែងរករបស់នោះមិនឃើញ គិតថា ឥឡូវនេះ យប់ងងឹតហើយ ព្រឹកស្អែកទើបយើងនឹងដឹង ហើយក៏ទៅទាំងអាល័យនោះឯង ។ កាលអ្នកបិទបាំងទុកលើកវត្ថុរបស់នោះឡើង ដាច់ខូចអទិន្នាទានសិក្ខាបទក្នុងខណៈលើកឡើង តែកាលអ្នកបិទបាំងទុកកាន់យកក្នុងវេលាដែលបិទបាំងទុកហើយនោះឯង ដោយសកសញ្ញាថា ជារបស់យើង ឬដោយបង្សុកូលសញ្ញាថា ឥឡូវនេះ មនុស្សទាំងឡាយនោះទៅហើយ ពួកគេបានបោះបង់ចោលរបស់នេះហើយ ជាភណ្ឌទេយ្យ ។ កាលមនុស្សទាំងឡាយនោះសូម្បីមកក្នុងថ្ងៃទីពីរ ពិនិត្យរកមើល ហើយក៏មិនឃើញ ទើបធ្វើការដាក់ធុរៈត្រឡប់ទៅវត្ថុរបស់ដែលគេកាន់យកហើយ ក៏ជាភណ្ឌទេយ្យដូចគ្នា ។ ព្រោះហេតុអ្វី ? ព្រោះថា ពួកគេមិនឃើញវត្ថុរបស់ដោយសេចក្ដីព្យាយាមរបស់អ្នកនោះ ។ មួយវិញទៀតបុគ្គលណាជួបឃើញវត្ថុរបស់ដូច្នោះ ដែលតាំងនៅក្នុងទីដើមនោះឯង មិនបានបិទបាំងទុក តែមានថេយ្យចិត្ត យកជើងជាន់ឲ្យចូលទៅក្នុងភក់

ឬក្នុងខ្សាច់ ល្មមកណ្ដាលនោះ ដែលអ្នកជាន់ចូលទៅហើយប៉ុណ្ណោះ ក៏ដាច់ខួច អទិន្នាទានសិក្ខាបទ ។

**៥– កុសាវហារ** ការផ្លាស់ប្ដូរស្លាកហើយកាន់យកទៅ លោកហៅថា **កុសាវហារ** សូម្បីកុសាវហារនោះ គប្បីជ្រាបដូច្នេះ បុគ្គលណាកាលមនុស្សទាំងឡាយ ចាត់ចែងឆ្នោតស្លាក ដែលគេធ្វើដោយបន្ទះឫស្សី ឬស្លឹកត្នោត គេសរសេរឈ្មោះអ្នកនេះអ្នកនោះទុកហើយ គេដាក់សំពត់នៅពីក្រោម ស្លាកនៅពីលើឲ្យជាចំណែកៗចែកគ្នា ខ្លួនមានប្រាថ្នានឹងលើកយកចំណែករបស់អ្នកដទៃ ដែលមានតម្លៃតិច និងតម្លៃច្រើន និងតម្លៃស្មើគ្នា ដែលទុកនៅជិតចំណែករបស់ខ្លួន ចំណែកខ្លួនចង់ទម្លាក់ស្លាកដែលគេដាក់លើចំណែករបស់ខ្លួន ទៅលើចំណែកអ្នកដទៃ ហើយរើហូតលើកឡើងប៉ុណ្ណោះ មិនទាន់ទៅជាអ្វីនៅឡើយទេ ដល់ទម្លាក់ទៅលើចំណែកអ្នកដទៃ ក៏មិនទាន់ជាអ្វីដែរ ។ ត្រាតែស្លាកខ្លួនធ្លាក់ទៅលើស្លាកគេ ហើយខ្លួនរើហូតយកស្លាកគេអំពីចំណែករបស់គេឲ្យខិត ឬឃ្លាតចាកទីតែបន្តិចប៉ុណ្ណោះ ដាច់ខួច អទិន្នាទានសិក្ខាបទ ក្នុងខណៈដែលរើហូតឡើង ។ ន័យមួយទៀត បើខ្លួនចង់ទាញយកស្លាកគេទម្លាក់មកក្នុងស្លាកខ្លួន ហើយរើហូតយកស្លាកអំពីចំណែកគេមុនដំបូង ក្នុងខណៈដែលរើលើមិនទាន់ជាអ្វីទេ ដល់រើយកស្លាកខ្លួនអំពីចំណែកខ្លួនទៅវិញ ក៏នៅមិនទាន់ជាអ្វីដែរ ត្រាតែដាក់ស្លាកខ្លួននោះ ទៅក្នុងចំណែកអ្នកដទៃ គ្រាន់តែដាច់ផុតអំពីដៃភ្លាម ដាច់ខួច អទិន្នាទានសិក្ខាបទភ្លាមក្នុងកាលនោះឯង ។

## អទិន្នាទានមានទោសច្រើន

នៅក្នុង**សម្មោហវិនោទនី** អដ្ឋកថា ព្រះអភិធម្មត្រង់សិក្ខាបទវិភង្គ បានសម្ដែងទោសអទិន្នាទានថា ៖

**ទុស្សីលស្ស សន្តកេ អប្បសាវជ្ជំ** *ការកាន់យកទ្រព្យរបស់បុគ្គលទ្រុស្តសីល ឈ្មោះថា មានទោសតិច*

**តតោ គោរូបសីលកស្ស សន្តកេ មហាសាវជ្ជំ** *ការកាន់យកទ្រព្យរបស់បុគ្គលប្រព្រឹត្តដូចជាគោ ឈ្មោះថា មានទោសច្រើនជាងនោះ*

**តតោ សរណាគតស្ស** *ការកាន់យកទ្រព្យរបស់បុគ្គលអ្នកដល់ត្រៃសរណគមន៍ ឈ្មោះថា មានទោសច្រើនជាងនោះ*

**តតោ បញ្ចសិក្ខាបទិកស្ស** *ការកាន់យកទ្រព្យរបស់បុគ្គលអ្នកមាន សីល ៥ មានទោសច្រើនជាងនោះ ។*

**សាមណេរស្ស** *ការកាន់យកទ្រព្យរបស់សាមណេរ ឈ្មោះថាមានទោសច្រើនជាង*

**បុថុជ្ជនភិក្ខុនោ** *ការកាន់យកទ្រព្យរបស់ភិក្ខុជាបុថុជ្ជន ឈ្មោះថាមានទោសច្រើនជាង*

**សោតាបន្នស្ស** *ការកាន់យកទ្រព្យរបស់ព្រះសោតាបន្ន ឈ្មោះថាមានទោសច្រើនជាង*

**សកទាគាមិស្ស** *ការកាន់យកទ្រព្យរបស់ព្រះសកទាគាមី ឈ្មោះថា មានទោសច្រើនជាង*

**តតោ អនាគាមិស្ស សន្តកេ មហាសាវជ្ជំ** *ការកាន់យកទ្រព្យរបស់ព្រះអនាគាមី ឈ្មោះថា មានទោសច្រើន*

**តតោ ខីណាសវស្សសន្តកេ អតិមហាសាវជ្ជំយេវ** *ការកាន់យកទ្រព្យរបស់ព្រះខីណាស្រព ឈ្មោះថា មានទោសក្រៃលែងបំផុត ។*

*នៅក្នុង* ***បរមត្ថទីបនី*** *អដ្ឋកថា ខុទ្ទកនិកាយ ឥតិវុត្តកៈ បានសម្ដែងទោសអទិន្នាទានថា ៖ អទិន្នាទាន ឈ្មោះថា មានទោសតិច ព្រោះរបស់អ្នកដទៃអាក្រក់ (តម្លៃតិច) ឈ្មោះថា មានទោសច្រើន ព្រោះរបស់អ្នកដទៃប្រណីត (តម្លៃច្រើន) ព្រោះហេតុអ្វី ? ព្រោះវត្ថុប្រណីត ឈ្មោះថា មានទោសតិច ព្រោះរបស់អ្នកដទៃតិច ឈ្មោះថា មានទោសច្រើន ព្រោះរបស់អ្នកដទៃច្រើន ក៏ដូចគ្នាយ៉ាងនេះ ។ ព្រោះហេតុអ្វី ? ព្រោះវត្ថុធំ និងព្រោះប្រយោគធំ តែកាលមានវត្ថុស្មើគ្នា អទិន្នាទាន ឈ្មោះថា មានទោសច្រើន ព្រោះវត្ថុរបស់អ្នកមានគុណធម៌ខ្ពស់ ឈ្មោះថា មានទោសតិច ព្រោះវត្ថុរបស់អ្នកមានគុណធម៌ទាបជាងអ្នកមានគុណធម៌ខ្ពស់នោះៗ ដោយសំដៅយកគុណធម៌ដ៏ខ្ពស់នោះៗជាកេណ្ឌ តែកាលវត្ថុនឹងគុណធម៌មិនប៉ុនគ្នា អទិន្នាទាន ឈ្មោះថា មានទោសតិច ព្រោះកិលេស និងប្រយោគទន់ខ្សោយ ឈ្មោះថា មានទោសច្រើន ព្រោះកិលេស និងប្រយោគជារបស់ខ្លាំងក្លា ។*

*ផលចំពោះសិក្ខាបទនេះ ក្នុងអទិន្នាទានសិក្ខាបទ មានសម្ដែងនៅក្នុង* ***បរមត្ថទីបនី*** *អដ្ឋកថា ខុទ្ទកនិកាយ និងបរមត្ថជោតិកា អដ្ឋកថា ខុទ្ទកនិកាយ ខុទ្ទកបាឋៈ មាន ១១ យ៉ាងគឺ ៖*

**១- មហទ្ធនតា** *ភាពជាមនុស្សមានទ្រព្យច្រើនផង ។*

**២- បហូតធនធញ្ញតា (មហាធនធញ្ញតា)** *ជាមនុស្សមានរបស់របរ និងធញ្ញាហារដ៏សម្បូណ៌កុះករ ។*

**៣- អនន្តភោគតា** *ជាមនុស្សរកទ្រព្យបានដោយមិនទើសទាល់ដល់ទីបំផុត ។*

**៤- អនុប្បន្នភោគុប្បត្តិតា** *ភោគទ្រព្យមិនទាន់កើត ក៏កើតឡើងបាន ។*

**៥- ឧប្បន្នភោគថាវរតា (ចិរភោគតា)** *ភោគទ្រព្យកើតឡើងហើយ ក៏តាំងនៅខ្ជាប់ខ្ជួនមិនខូចខាត ។*

**៦- ឥច្ចិតានំ ភោគានំ ទិប្បំ បដិលាភោ (ឥច្ចិតានំ លាភានំ ទិប្បដិ-លាភិតា)** *រកទ្រព្យរបស់ដែលប្រាថ្នាបានឆាប់រហ័ស ( មិនលំបាក ) ។*

**៧- អសាធារណភោគតា** *មានទ្រព្យសម្បត្តិមិនខ្វាត់ខ្វាយអន្តរាយដោយរាជភ័យ ចោរភ័យ ឧទកភ័យ អគ្គិភ័យ ឬញាតិធបោកឡើយ ។*

**៨- អសាធារណធនបដិលាភតា** *រកទ្រព្យបានមកហើយ មិនបានខ្ជះខ្ជាយ សាយកាយទៅផ្តេសផ្តាសឡើយ ។*

**៩- លោកុត្តរធនបដិលាភតា** *សមរម្យជាអ្នកបានទូវលោកកុត្តរទ្រព្យទៀតផង ។*

**១០-នត្ថិភាវស្ស អជានតា អសវនតា (នត្ថិភាវស្ស អជាននតា)** *ភាពជាអ្នកមិនធ្លាប់ដឹង មិនធ្លាប់ឮដោយគ្រាន់តែពាក្យថាគ្មាន ( នោះឡើយ ) ។*

**១១-សុខវិហារិតា** *ទៅនៅកន្លែងណាក៏ជួបប្រទះតែនឹងសុខ ។*

### អទិន្នាទានេះមានអង្គ ៥ គឺ

**១- បរបរិគ្គហិតំ** *ទ្រព្យដែលមានម្ចាស់គេហួងហែងរក្សា*

**២- បរបរិគ្គហិតសញ្ញិតា** *សេចក្តីដឹងថាទ្រព្យដែលម្ចាស់គេហួងហែងរក្សា*

**៣- ថេយ្យចិត្តំ** *ចិត្តគិតនឹងលួច*

**៤- ឧបក្កមោ** *ព្យាយាមនឹងលួចដោយអាការៈយ៉ាងណាមួយ*

**៥- តេន ហរណំ** *លួចបានមកដោយព្យាយាមនោះ ។*

អទិន្នាទាននេះ ជាសភាវៈ ជាសាណត្តិកៈ មានសមុដ្ឋាន ៣ គឺ **កាយចិត្តតោ** ទោសកើតឡើងអំពីកាយនិងចិត្ត ១ **វាចាចិត្តតោ** ទោសកើតឡើងអំពីវាចា និងចិត្ត ១ **កាយវាចាចិត្តតោ** ទោសកើតឡើងអំពីកាយវាចាចិត្ត ១ ។ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម ជាវចីកម្ម ជាអកុសលចិត្ត ជាធម្មៈ ជាកោដ្ឋសៈ មានសង្ខារជាអារម្មណ៍ មានវេទនាបីណាមួយ មានមូលពីរ លោភមោហមូល១ ទោសមោហមូល១ ជាអនិពទ្ធសីល ជាសមាទាន មានវិរតី៣ណាមួយ ជាវត្ថុកាម និងកិលេសកាម អនាបជនៈ ។ ហេតុមិនត្រូវទោសមាន៧ យ៉ាងគឺ :

១-កាន់យកដោយប្រឡំ សម្គាល់ថាជារបស់ខ្លួន

២-កាន់យកដោយសេចក្តីស្និទ្ធស្នាលនឹងគ្នា

៣-កាន់យកដោយរបស់ខ្ចី

៤-កាន់យករបស់ពួកប្រេតហួងហែងរក្សា

៥-កាន់យករបស់សត្វតិរច្ឆានហួងហែងរក្សា

៦-កាន់យកដោយសម្គាល់ថា ជារបស់រើសបាន

៧-ជាមនុស្សឆ្កួត ។

**អទិន្នាទានសិក្ខាបទទី ២ ចប់**

# កាមេសុ មិច្ឆាចារសិក្ខាបទទី៣

*មុននឹងខ្ញុំបាទ សរសេររៀបចំអព្រហ្មចរិយសិក្ខាបទនោះ សូមរៀបចំជាក្រង នូវកាមេសុ មិច្ឆាចារសិក្ខាបទ ជាមុនដូចតទៅនេះ ៖*

*នៅក្នុង* **សទ្ធម្មបកាសិនី** *អដ្ឋកថា ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លោកពន្យល់ពាក្យកាមេសុ មិច្ឆាចារៈថា បទថា* **កាមេសុ** *បានដល់ការប្រព្រឹត្តក្នុងមេថុន ។ បទថា* **មិច្ឆាចារោ** *បានដល់ប្រព្រឹត្តលាមក ដែលគួរត្រូវតិះដៀល តែដោយលក្ខណៈចេតនាដែលប្រព្រឹត្តកន្លងឋានៈស្ត្រីដែលមិនគួរប្រព្រឹត្តដោយកាយទ្វារ ជាអ្នកប្រាថ្នាប្រព្រឹត្តអាក្រក់ អសទ្ធម្ម ឈ្មោះថា* **កាមេសុមិច្ឆាចារ** *។ សូម្បីនៅក្នុង* ***បរមត្ថទីបនី*** *និងអដ្ឋកថាខុទ្ទកនិកាយ ឥតិវុត្តកៈ មានសេចក្តីពន្យល់ដូចគ្នា ។*

**កាមេសុ មិច្ឆាចារៈ** *កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។ បានដល់ មេថុន-សមាចារ ២ យ៉ាងគឺ* **សទារសន្តោសៈ** *សេចក្តីសន្តោសត្រេកអរនឹងកិរិយារបស់ខ្លួនដែលមានច្បាប់អនុញ្ញាតតាមបវេណី ១*

**បរទារគមនៈ** *កិរិយាគប់រកនូវកិរិយានៃបុគ្គលដទៃ ដែលច្បាប់ហាមឃាត់ ទាំងពីរនេះ ហៅថា កាម ព្រោះសត្វតែងប្រាថ្នា ។*

*នៅក្នុងគម្ពីរ* **មហាវគ្គដីកា** *ឈ្មោះលីនត្ថប្បកាសិនីត្រង់ សង្គីតិសូត្រ បានសម្តែងថា៖* **មេថុនសមាចារេសូតិ សទារសន្តោសបរទាគមនវសេន ទ្វីសុ មេថុនសមាចារេសុ ។ តេបិ ហិ កាមេតព្វតោ កាមា នាម ។ មេថុនស្ស**

វត្ថុភូតេសុ សត្តេសុ ។ មិច្ឆាចារោតិ គារយ្ហាចារោ ។ គារយ្ហតា ចស្ស ឯកន្តនិហីនតាយ ឯវាតិ អាហ ឯកន្តនិន្ទិតោ លាមកាចារោតិ ។ អសទ្ធម្មាធិប្បាយេនាតិ អសទ្ធម្មសេវនាធិប្បាយេនាតិ ។ *បទថា* មេថុន–**សមាចារេសុ** *បានដល់ក្នុងមេថុនសមាចារ ២ យ៉ាងគឺ* **សទារសន្តោសៈ** *សេចក្ដីសន្តោសត្រេកអរដោយភរិយារបស់ខ្លួន ១* **បរទារគមនៈ** *សេចក្ដីត្រេកអរដោយភរិយាបុគ្គលដទៃ១ ។ ក៏ក្នុងមេថុនសមាចារ២ យ៉ាងនោះ ឈ្មោះថា* **កាមៈ** *ព្រោះជាធម៌ដែលបុគ្គលគប្បីប្រាថ្នា ។ ក្នុងជំពូកសត្វដែលជាវត្ថុនៃមេថុន ។ អាចារៈដែលបណ្ឌិតគប្បីតិះដៀល ឈ្មោះថា* **មិច្ឆាចារៈ** *។ មិច្ឆាចារៈនោះ ឈ្មោះថាគួរតិះដៀល ព្រោះធម៌អាក្រក់ដោយចំណែកមួយប៉ុណ្ណោះ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យទើបពោលថា អាចារៈដ៏អាក្រក់ដែលបណ្ឌិត តិះដៀលដោយចំណែកមួយដូច្នេះ ។ បទថា* **អសទ្ធម្មាធិប្បាយេន** *គឺដោយអធិប្បាយក្នុងកាលដែលសេពមេថុនធម្ម ។ នៅក្នុង* **សទ្ធម្មប្បកាសិនី** *អដ្ឋកថា ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ បានពន្យល់អំពីស្ត្រីដែលជា អគមនីយដ្ឋាន របស់បុរស គឺស្ត្រីដែលបុរសមិនគួរគប់រក ដោយអសទ្ធម្មនោះមាន ២០ គឺ ៖*

**១–មាតុរក្ខិតា** *ស្ត្រីដែលមានមាតាគេគ្រប់គ្រងរក្សា*

**២–បិតុរក្ខិតា** *ស្ត្រីដែលមានបិតាគេគ្រប់គ្រងរក្សា*

**៣–មាតាបិតុរក្ខិតា** *ស្ត្រីដែលមានមាតាបិតាគេគ្រប់គ្រងរក្សា*

**៤–ភាតុរក្ខិតា** *ស្ត្រីដែលមានបងប្រុស ឬប្អូនប្រុសគេគ្រប់គ្រងរក្សា*

**៥–ភគិនីរក្ខិតា** ស្ត្រីដែលមានបងស្រី ឬប្អូនស្រីគេគ្រប់គ្រងរក្សា

**៦–ញាតិរក្ខិតា** ស្ត្រីដែលមានញាតិគេគ្រប់គ្រងរក្សា

**៧–គោត្តរក្ខិតា** ស្ត្រីដែលមានបុគ្គលមានគោត្រជាមួយគ្នា ឬមានជាតិវង្សជាមួយគ្នាគេគ្រប់គ្រងរក្សា

**៨–ធម្មរក្ខិតា** ស្ត្រីដែលបព្វជិតពួកណាមួយអ្នកប្រព្រឹត្តធម៌ត្រឹមត្រូវ គេគ្រប់គ្រងរក្សា

**៩–សារក្ខា** ស្ត្រីដែលប្រកបដោយកិរិយារក្សា គឺស្ត្រីដែលមានស្វាមីហើយ ឬមានគេប្រកាន់ទុកហើយ

**១០–សបរិទណ្ឌា** ស្ត្រីដែលប្រកបដោយអាជ្ញា គឺស្ត្រីដែលព្រះរាជាដាក់រាជអាជ្ញាមិនឲ្យនរណាប្រព្រឹត្តកន្លងតាមអំពើចិត្ត ឬមិនឲ្យបុរសណាមួយទៅប្រព្រឹត្តកន្លង

**១១–ធនក្កីតា** ស្ត្រីដែលគេទិញ ឬលោះដោយទ្រព្យទោះតិចក្តី ច្រើនក្តីយកមកធ្វើជាភរិយា ឬត្រឹមតែលោះមកប៉ុណ្ណោះ គេមិនបានដល់ទៅធ្វើជាភរិយាក៏ដោយ

**១២–ឆន្ទវាសិនី** ស្ត្រីដែលរត់តាមទៅនៅធ្វើជាភរិយារបស់បុរស ដោយសេចក្តីពេញចិត្តរបស់ខ្លួន ហើយបុរសគេទទួលព្រមផង

**១៣–ភោគវាសិនី** ស្ត្រីដែលទៅនៅធ្វើជាភរិយារបស់បុរស ព្រោះតែភោគៈ គឺស្ត្រីដែលបានភោគយ៉ាងច្រើន ដោយហោចត្រឹមតែអង្រែ ឬត្បាល់ជាដើម អំពីបុរសណាក៏ទៅនៅធ្វើជាភរិយារបស់បុរសនោះ

**១៤-បដវាសិនី** ស្ត្រីដែលទៅនៅធ្វើជាភរិយារបស់បុរស ព្រោះតែសំពត់គឺស្ត្រីក្រខ្សត់ ដែលគ្រាន់តែសំពត់ស្លៀក ឬសំពត់ដណ្ដប់ក៏ក្រដែរ ទើបសុខចិត្តចូលទៅធ្វើជាភរិយាគេ

**១៥-ឱទបត្តកិនី** ស្ត្រីដែលគេផ្គោបដៃជាមួយបុរសជ្រលក់ទៅក្នុងពានទឹក ឬផ្តិលទឹកមួយ ហើយគេពោលថា អ្នកទាំងឡាយចូរព្រមព្រៀងគ្នា ចូរកុំបែកបាក់គ្នា ឲ្យដូចជាទឹកនេះ គឺស្ត្រីដែលគេផ្សំផ្គុំឲ្យជាភរិយារបស់បុរសដោយវិធីបែបនេះ

**១៦-ឱភតចុម្ភជា** ស្ត្រីដែលគេដាក់ទ្រនូលចុះអំពីក្បាល គឺស្ត្រីរកឧសជាដើម ដែលបុរសណាមួយគេជួយដាក់ទ្រនូលអំពីក្បាលហើយនាំយកទៅធ្វើជាភរិយាគេ

**១៧-ទាសី ច ភរិយា ច** ស្ត្រីដែលជាទាសីគេផង ជាភរិយាគេផង គឺស្ត្រីដែលជាទាសីរបស់បុរសណាមួយ ហើយបុរសនោះយកធ្វើជាភរិយា

**១៨-កម្មការី ច ភរិយា ច** ស្ត្រីដែលជាកូនឈ្នួលគេផង ជាភរិយាគេផង គឺស្ត្រីដែលចូលទៅនៅធ្វើការស៊ីឈ្នួលឲ្យគេ ហើយមានបុរសណាមួយ ឬជន្មៅរបស់ខ្លួននោះទៅសម្រេចយកវាសធម៌ជាមួយ លែងត្រូវការដោយភរិយារបស់ខ្លួន

**១៩-ធជាហដា** ស្ត្រីដែលសេនានាំមកដោយទង់ជ័យ គឺស្ត្រីដែលសេនាដំឡើងទង់ជ័យលើកទ័ពទៅច្បាំងដណ្ដើមដែនស្ដេចដទៃ កៀរយកបានមកហើយ បុរសណាមួយយកធ្វើជាភរិយាគេទៅ

**២០-មុហុត្តិកា** ស្ត្រីដែលមានបុរសកប់ប្រសព្វតែមួយស្របក់ៗ ជាស្ត្រីដែលជាសាហាយស្មន់របស់បុរសណាមួយ ។

*ស្ត្រីទាំង ២០ ជំពូកដូចពោលមកហើយនេះ គប្បីដឹងថា សុទ្ធតែជាអគមនីយដ្ឋាន របស់បុរស គឺថាសុទ្ធតែបុរសមិនគួរគប់រក ដោយអសទ្ធម្មទាំងអស់ បើបុរសទៅគប់រកដោយអសទ្ធម្ម ចាត់ជាមិច្ឆាចារៈ ដាច់ខ្ទបសិក្ខាបទហ្នឹងឯង ។*

*ស្ត្រី ២០ ជំពូក មានស្ត្រីដែលមាតាគ្រប់គ្រងរក្សាជាដើម ឈ្មោះថា អគមនីយដ្ឋាន របស់បុរសទាំងឡាយក្នុងបទថា* **អគមនីយដ្ឋានវិតក្កមចេតនា** *នោះ ។*

*នៅក្នុង* ***អនុដីកាវិមតិវិនោទនី*** *ត្រង់សញ្ចរិត្តសិក្ខាបទ ភាគ ១ ទំព័រ ៣៤១ លោកទើបពោលទុកថា* **បុរិសា ហិ បរេហិ យេហិ កេហិចិ គោបិតំ ឥត្ថឹ គន្តុំ ន លភន្តិ ឥត្ថិយោ បន កេនចិ បុរិសេន ភរិយាភាវេន គហិតាវ បុរិសន្តរំ គន្តុំ ន លភន្តិ។**

*មែនពិត បុរសទាំងឡាយរមែងមិនបានដើម្បីនឹងដល់កន្ទងនូវស្ត្រី ដែលអ្នកណាមួយគ្រប់គ្រងរក្សាទុក ដោយថាពួកស្ត្រីដែលបុរសណាមួយ កាន់យកដោយភាពជាភរិយាប៉ុណ្ណោះ មិនបានដើម្បីនឹងដល់បុរសដទៃ ( ប្រព្រឹត្តកន្លង ) ។*

*នៅក្នុង មង្គលត្ថទីបនីភាគ ២ ទំព័រ ៥២ បានសម្តែងបញ្ជាក់ទៀតថា:* **តស្មា តេសំ មាតុរក្ខិតាទីសុ អដ្ឋសុគតានំ មិច្ឆាចារោ ហោតិយេវ មាតាទីហិ យថា បុរិសេន សទ្ធឹ សំវាសំ ន កប្បេន្តិ តថា រក្ខិតត្តា ។ ធនញ្ញាសុ ទ្វាទសសុ គតានំ បរេហិ វារិតេ អត្តនោ អសន្តកេ ឋានេ បវិដ្ឋត្តា មិច្ឆាចារោ ។**

*ព្រោះហេតុនោះ បុរសទាំងឡាយនោះទៅប្រព្រឹត្តដល់ក្នុងស្ត្រី ៨ ជំពូក មានស្ត្រីដែលមាតាគ្រប់គ្រងរក្សាជាដើម ទើបជាមិច្ឆាចារៈដោយពិត ព្រោះស្ត្រីទាំងឡាយនោះ ដែលមានអ្នកគ្រប់គ្រងទាំងឡាយមានមាតាជាដើមរក្សាគ្រប់គ្រង ដោយប្រការដែលស្ត្រីនោះនឹង*

*សម្រេចនៅរួមជាមួយបុរសមិនបាន ។ បុរសទៅប្រព្រឹត្តក្នុងស្ត្រី ១២ ជំពូកក្រៅអំពីស្ត្រី ៨ ជំពូកនោះ ជាមិច្ឆាចារៈ (ដូចគ្នា) ព្រោះចូលទៅក្នុងឋានៈ ដែលមិនមែនរបស់ៗខ្លួន ដែលជនទាំងឡាយដទៃហាមហើយ ។* ***នៅក្នុងសារត្ថទីបនីដីកាភាគ*** *៣ ទំព័រ ៤៥ លោកពោលទុកថា:* **ឥតរាសំ មាតុរក្ខិតាទីនំ អដ្ឋន្នំ បុរិសន្តរគមនេ នត្ថិ មិច្ឆាចារោ តាសំ អស្សាមិកភាវតោ ។ យា ហិ សាមិកស្ស សន្តកំ ផស្សំ ថេនេត្វា បរេសំ អភិរតឹ ឧប្បាទេន្តិ តាសំ មិច្ឆាចារោ ។ ន ច មាតាទយោ តាសំ ផស្សេ ឥស្សរា ។**

*ចំណែកស្ត្រី ៨ ជំពូកក្រៅអំពីនេះ មានស្ត្រីដែលមាតាគ្រប់គ្រងរក្សាជាដើម មិនឈ្មោះថា ជាមិច្ឆាចារៈ ក្នុងព្រោះដល់បុរសដទៃ ព្រោះភាវៈនៃស្ត្រីទាំងឡាយនោះ ជាអ្នកមិនមានស្វាមី ។ មែនពិតស្ត្រីទាំងឡាយនោះ លួចនូវផស្សៈជារបស់ស្វាមី ញ៉ាំងការអភិរម្យឲ្យកើតឡើងដល់បុរសដទៃទាំងឡាយ (ព្រោះហេតុនោះ) ស្ត្រីទាំងឡាយនោះ ទើបឈ្មោះថាមិច្ឆាចារៈ ។ ម្យ៉ាងទៀត អ្នកគ្រប់គ្រងរក្សាទាំងឡាយ មានមាតាជាដើម រមែងមិនជាឥស្សរៈលើផស្សៈនៃស្ត្រីទាំងឡាយ ។*

**មាតាទយោ ហិ ន អត្តនោ ផស្សានុភវនត្ថំ តា រក្ខន្តិ កេវលំ អនាចារំ និសេធេន្តា បុរិសន្តរគមនំ តាសំ វារេន្តិ ។**

*មែនពិត អ្នកគ្រប់គ្រងរក្សាទាំងឡាយមានមាតាជាដើម រមែងមិនរក្សាស្ត្រីទាំងនោះទុកដើម្បីអានុភាពនៃផស្សៈរបស់ខ្លួន មិនមែនតែប៉ុណ្ណោះ អ្នកគ្រប់គ្រងរក្សាទាំងឡាយការពារនូវអនាចារ ទើបហាមការដល់បុរសដទៃនៃស្ត្រីទាំងឡាយនោះ ។* **បុរិសស្ស បន ឯតេសុ អដ្ឋសុបិ ហោតិយេវ មិច្ឆាចារោ មាតាទីហិ យថា បុរិសេន សទ្ធិំ**

**សំវាសំ ន កប្បេន្តិ តថា រក្ខិត្តតា បរេសំ រក្ខិតគោបិតំ ផស្សំ ថេនេត្វា ជុជ្ជភាវគោ** ។ *ចំណែកសូម្បីស្ត្រីទាំងឡាយ ៨ ជំពូកនោះ រមែងជាមិច្ឆាចារៈនៃបុរសមែនពិត (ព្រោះថាស្ត្រីទាំងឡាយនោះ) មានអ្នកគ្រប់គ្រងទាំងឡាយមានមាតាជាដើម មិនគប្បីសម្រេចនូវការរួមដោយបុរសយ៉ាងណា ព្រោះមានអ្នករក្សាគ្រប់គ្រងយ៉ាងនោះ (ព្រោះហេតុនោះ ទើបជាមិច្ឆាចារៈដោយស្ត្រីទាំងឡាយនោះ) ដែលត្រូវបុរសលួចនូវផស្សៈនៃជនទាំងឡាយដទៃគ្រប់គ្រងរក្សាហើយ ។*

*សេចក្តីទាំងអស់នេះ មានមកក្នុង**សារត្ថទីបនីដីកា** សញ្ចរិត្តសិក្ខាបទ ។ ខ្ញុំបាទសូមបញ្ជាក់ថែមទៀតថាស្ត្រី ៨ ជំពូក មានមាតុរក្ខិតាជាដើម បើបុរសណាប្រព្រឹត្តអសទ្ធម្មជាមួយ ដាច់កាមេសុ មិច្ឆាចារៈតែបុរសនោះប៉ុណ្ណោះ ចំណែកស្ត្រី ៨ ជំពូកនោះមិនដាច់សិក្ខាបទហ្នឹងទេ ។ តែចំពោះស្ត្រីមាន**សារក្ខា**ជាដើម បើប្រព្រឹត្តអសទ្ធម្មជាមួយអ្នកដទៃខ្លួនដ៏ដាច់កាមេសុ មិច្ឆាចារសិក្ខាបទហ្នឹងដែរ ។*

*សិក្ខាបទនេះមានអង្គ ៤ គឺ*

**១-អគមនីយវត្ថុ** *វត្ថុដែលមិនគួរគប់រកគឺស្ត្រីដែលមានគេគ្រប់គ្រងរក្សា ឬបុរសដែលមិនមែនជាស្វាមីរបស់ខ្លួន*

**២-តស្មិំ សេវនចិត្តំ** *ចិត្តចង់សេពក្នុងវត្ថុដែលមិនគួរគប់រកនោះ*

**៣- សេវនប្បយោគោ** *ព្យាយាមនឹងសេព*

**៤-មគ្គេន មគ្គប្បដិបត្តិអធិវាសនំ** *បានជ្រលក់ឬញ៉ាំងមគ្គនឹងមគ្គឲ្យដល់គ្នា ។*

*ខ្ញុំបាទសូមបញ្ជាក់អង្គនេះបន្តិចទៀតតាមគម្ពីរ **សីលក្ខន្ធវគ្គអភិនវដីកា** ឈ្មោះថាសាធុវិលាសិនី នៅក្នុងទីឃនិកាយ ពន្យល់ចេញពីអដ្ឋកថាឈ្មោះ**សុមង្គលវិលាសនី** ត្រង់ព្រហ្មជាលសូត្រឈ្មោះ ព្រហ្មជាលដីកាថា៖*

*អាចារ្យពួកខ្លះ ពោលថា កាលញុំាងមគ្គនឹងមគ្គឲ្យដល់គ្នា ហើយឈប់នៅ ព្រោះត្រូវស្ត្រីបង្ខំ រមែងមិនជាមិច្ឆាចារៈ ព្រោះមិនមានសេចក្តីព្យាយាមជាប់គ្នា (បន្តគ្នា) ក្នុងកាលសេពដែលកើតឡើងមុន ។ អាចារ្យមួយពួកទៀតពោលថា កាលចិត្តគិតនឹងសេព មានសេចក្តីព្យាយាមមិនមាន មិនជាប្រមាណដោយច្រើន ស្ត្រីមិនមានព្យាយាមក្នុងកាលសេព កាលមានសភាពយ៉ាងនោះ សូម្បីស្ត្រីមានចិត្តគិតនឹងសេពកើតឡើង មិនជាមិច្ឆាចារៈ ព្រោះមិនមានសេចក្តីព្យាយាមក្នុងកាលសេព ។ ព្រោះហេតុនោះ គប្បីឃើញសន្និដ្ឋានថា អង្គទី ៤ លោកពោលទុកដោយឧក្រិដ្ឋដោយអំណាចបុរស ដូច្នេះដោយប្រាថ្នាថា កាលកាន់យកសេចក្តីដទៃក្នុងវេលាស្ត្រីធ្វើប្រមុខបុរស សូម្បីបុរសក៏មិនជាមិច្ឆាចារៈ ព្រោះមិនមានសេចក្តីព្យាយាមក្នុងកាលសេព ។ ក៏ក្នុងអធិការណ៍នេះនៃអង្គកាមេសុ មិច្ឆាចារៈ មានសន្និដ្ឋានដូច្នេះ៖*

*មិច្ឆាចារដែលប្រព្រឹត្តទៅតាមពេញចិត្តរបស់ខ្លួនមានអង្គ ៣ ឲ្យប្រព្រឹត្តទៅដោយពលការណ៍ក៏មានអង្គ ៣ ។ ព្រោះហេតុនោះ គប្បីឃើញថាមានអង្គ ៤ ព្រោះកាន់យកដោយមិនមានចំណែកដ៏សេស ។*

**កាមេសុ មិច្ឆាចារៈ** *នេះ ជាសភាវៈ ជាអនាណត្តិកៈ មានសមុដ្ឋាន ១ គឺ* **កាយចិត្តតោ** *ទោសកើតឡើងអំពីកាយ និងចិត្ត ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាអកុសលចិត្ត ជាធម្មៈ ជាកោសដ្ឋាសៈ មានសង្ខារជាអារម្មណ៍ មានវេទនាពីរ គឺសុខវេទនាខ្លះ ជួនជាអទុក្ខមសុខវេទនាខ្លះ មានមូលពីរ គឺលោភមូល និងមោហមូល ជាអនិពន្ធសីល ជាសមាទាន មានវិរតិបីណាមួយ ជាវត្ថុកាម និងកិលេសកាម*

**អនាបត្តិៈ** *ហេតុដែលមិនត្រូវទោសមាន ៤ យ៉ាង គឺមិនដឹងខ្លួន ១ ឆ្កួត ១ មានចិត្តរវើរវាយ ១ មានទុក្ខវេទនាគ្របសង្កត់ ១ ។ មិនត្រេកអរ ១ ផង រួមជា ៥ ។*

**កាមេសុ មិច្ឆាចារ:** *មានទោស នៅក្នុង* **សម្មោហវិនោទនី** *អដ្ឋកថា ព្រះអភិធម្ម ត្រង់សិក្ខាបទវិភង្គសម្តែងទោសថា ៖*

**មិច្ឆាចារោបិ ទុស្សីលាយ ឥត្ថិយា វិតក្កមេ អប្បសាវជ្ជោ** *សូម្បី ប្រព្រឹត្តខុសឈានកន្ទង់ក្នុងស្ត្រីទ្រុស្តសីលមានទោសតិច*

**តតោ គោរូបសីលកាយ មហាសាវជ្ជោ** *ប្រព្រឹត្តខុស បុគ្គលអ្នកប្រព្រឹត្ត ដូចយ៉ាងគោមានទោសច្រើនជាងនោះ*

**តតោ សរណាគតាយ** *ប្រព្រឹត្តខុសក្នុងបុគ្គលអ្នកដល់ព្រះសរណគមន៍ មាន ទោសច្រើនជាងនោះ*

**បញ្ចសិក្ខាបទិកាយ** *ប្រព្រឹត្តខុសក្នុងបុគ្គលអ្នកតាំងនៅក្នុងសីល ៥ មានទោស ច្រើនយ៉ាង*

**សាមណេរិយា** *ប្រព្រឹត្តខុសក្នុងសាមណេរី មានទោសច្រើនជាងនោះ*

**បុថុជ្ជនភិក្ខុនិយា** *ប្រព្រឹត្តខុសក្នុងភិក្ខុនីបុថុជ្ជន មានទោសច្រើនជាងនោះ*

**សោតាបន្នាយ** *ប្រព្រឹត្តខុសក្នុងភិក្ខុនីជាសោតាបន្ន មានទោសច្រើនជាងនោះ*

**សកទាគាមិនិយា** *ប្រព្រឹត្តខុសក្នុងភិក្ខុនីជាសកទាគាមី មានទោសច្រើនជាងនោះ*

**តតោ អនាគាមិនិយា វិតក្កមនេ មហាសាវជ្ជោ** *ប្រព្រឹត្តខុសក្នុងភិក្ខុនី ជាអនាគាមី មានទោសច្រើនជាងនោះ*

**ខីណាសវាយ បន ភិក្ខុនិយា ឯកន្តមហាសាវជ្ជោវ** *ចំណែកខាងការ ប្រព្រឹត្តខុសក្នុងភិក្ខុនីដែលជាព្រះខីណាស្រព មានទោសកំពូលក្រៃលែង ។*

*នៅក្នុង* **បរមត្ថទីបនី** *អដ្ឋកថា ខុទ្ទកនិកាយ ឥតិវុត្តកៈ បានសម្តែងទោស កាមេសុ មិច្ឆាចារៈថា៖*

*មិច្ឆាចារៈនោះ ឈ្មោះថាមានទោសតិច ព្រោះអគមនីយដ្ឋាន ដែលវៀរចាកគុណធម៌ សេចក្តីល្អមានសីលជាដើម ឈ្មោះថា មានទោសច្រើន ព្រោះដល់ព្រមដោយគុណ សេចក្តីល្អ មានសីលជាដើម ម្យ៉ាងទៀត សូម្បីក្នុងអគមនីយដ្ឋាន ដែលប្រាសចាកគុណ គឺសេចក្តីល្អ មិច្ឆាចារៈរបស់អ្នកប្រព្រឹត្តខុស ព្រោះ (ចាប់) បង្ខំជាដើម ក៏មានទោសច្រើន ។ តែឈ្មោះថា មានទោសតិច ព្រោះមនុស្សទាំងពីររួមឆន្ទៈគ្នា ។*

*កាលមនុស្សទាំងពីរនោះរួមឆន្ទៈគ្នា* **កាមេសុ មិច្ឆាចារ** *ឈ្មោះថា មានទោសតិច ព្រោះ កិលេស និងសេចក្តីព្យាយាមតិច ។*

*ឯផលចំពោះសិក្ខាបទ* **កាមេសុ មិច្ឆាចារៈ** *នេះ គប្បីដឹងតាម អដ្ឋកថា បរមត្ថទី-បនីចុះថា* **យស្មា បន មិច្ឆាចារោ វេរមណិយា ផលានិបិ ឯតេ្វ អន្តោគធា តស្មា អព្រហ្មចរិយា វេរមណិយា ។** *ពោលថា : ឯផលទាំងឡាយ របស់ ការវៀរចាក កាមេសុ មិច្ឆាចារៈ ជាផលធ្លាក់ចុះមកក្នុងផ្ទៃនៃអព្រហ្មចរិយៈនោះឯង ព្រោះហេតុផលរបស់ កាមេសុ មិច្ឆាចារៈយ៉ាងណា ព្រោះហេតុផលអព្រហ្មចរិយាក៏យ៉ាង នោះដែរ ។*

**កាមេសុ មិច្ឆាចារសិក្ខាបទទី៣ចប់**

## អព្រហ្មចរិយសិក្ខាបទទី៣

*អព្រហ្មចរិយៈ កិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរគឺសេពមេថុនធម្ម*

*នៅក្នុង* **មនោរថបូរណី** *អដ្ឋកថា អង្គុត្តរនិកាយ តិកនិបាត ត្រង់ឧបោសថសូត្រ បានពន្យល់ពាក្យ អព្រហ្មចរិយាថា៖*

*បទថា* **អព្រហ្មចរិយំ** *បានដល់ការប្រព្រឹត្តនូវធម៌មិនប្រសើរ ។ ឈ្មោះថា* **ព្រហ្មចារី** *ព្រោះប្រព្រឹត្តនូវធម៌ប្រសើរ គឺអាចារៈ ដ៏ខ្ពង់ខ្ពស់ ។ បទថា* **អាចារី** *ឈ្មោះថា អាចារៈដ៏អាក្រក់ ព្រោះប្រព្រឹត្តនូវធម៌មិនប្រសើរ ។ បទថា* **មេថុនា** *បានដល់អសទ្ធម្ម ដែលដល់ការរាប់ថា មេថុន ព្រោះជាធម៌រួមគ្នាជាគូៗ ដែលបាននាមថា* **មេថុន** *ព្រោះ លាយគ្នាដោយកិលេសគ្របសង្កត់ចិត្តគឺរាគៈ ។*

*នៅក្នុងព្រះវិនយបិដក* ***មហាវិភង្គ*** *ត្រង់បារាជិកកណ្ឌសិក្ខាបទ ទី ១ បានពន្យល់ពាក្យ មេថុនធម្មថា ៖*

**មេថុនធម្មោ នាម យោ សោ អសទ្ធម្មោ គាមធម្មោ វសលធម្មោ ទុដ្ឋុល្លំ ឱទកន្តិកំ រហស្សំ ទ្វយំទ្វយសមាបត្តិ ឯសោ មេថុនធម្មោ នាម ។**

*ធម៌ដែលហៅថា* **មេថុន** *នោះគឺធម៌ដែលជារបស់អសប្បុរស ធម៌របស់អ្នកស្រុក ធម៌ របស់មនុស្សថោកទាប ឬអំពើអាក្រក់ មានកិច្ចដោយទឹកជាទីបំផុត អំពើដែលជនពីរនាក់ តែងរួបរួមគ្នាក្នុងទីកំបាំង នេះឯងហៅថា* **មេថុនធម្ម។**

**បដិសេវតិ ឆាម យោ និមិត្តេន និមិត្តំ អង្គជាតេន អង្គជាតំ អន្តមសោ តិលផលមត្តំបិ បវេសេតិ ឯសោ បដិវេសតិ ឆាម ។**

*បុគ្គលណាឲ្យនិមិត្តខ្លួនចូលទៅនិមិត្តគេ ឲ្យអង្គកំណើតខ្លួន ចូលទៅដោយអង្គកំណើតគេ ដោយហោចទៅសូម្បីអស់ទីត្រឹមតែមួយគ្រាប់ល្ង បុគ្គលនោះហៅថាសេព ។*

*ក៏ការប្រព្រឹត្តខុសក្នុងអព្រហ្មចរិយនេះ ដោយការប្រព្រឹត្តក្នុងទ្វារមគ្គ ៣០ ទ្វារមគ្គណាមួយនោះ រមែងដាច់ខូច អព្រហ្មចរិយសិក្ខាបទហ្នឹងឯង ។*

*ឯទ្វារមគ្គទាំង ៣០ នោះចែកជាទ្វារមគ្គរបស់មនុស្ស ១០ ទ្វារមគ្គអមនុស្ស ១០ ទ្វារមគ្គសត្វតិរច្ឆាន ១០ រួមជា ៣០ ។*

*ទ្វារមគ្គមនុស្សស្រី មាន ៣ គឺ* **វច្ចមគ្គ ១បស្សាវមគ្គ ១ មុខមគ្គ១ ។**

*ទ្វារមគ្គមនុស្សប្រុស មាន ២ គឺ* **វច្ចមគ្គ១មុខមគ្គ ១។**

*ទ្វារមគ្គមនុស្សខ្ទើយ មាន ២ គឺ* **វច្ចមគ្គ ១ មុខមគ្គ ១ ។**

*ទ្វារមគ្គមនុស្សឧភតោព្យញ្ជនកៈ មាន ៣ គឺ* **វច្ចមគ្គ ១ បស្សាវមគ្គ ១មុខមគ្គ ១។**

*ទ្វារមគ្គអមនុស្សស្រី មាន ៣ គឺ* **វច្ចមគ្គ ១បស្សាវមគ្គ ១ មុខមគ្គ ។**

*ទ្វារមគ្គអមនុស្សប្រុស មាន ២ គឺ* **វច្ចមគ្គ១មុខមគ្គ១។**

*ទ្វារមគ្គអមនុស្សខ្ទើយ មាន ២ គឺ* **វច្ចមគ្គ ១ មុខមគ្គ ១ ។**

*ទ្វារមគ្គអមនុស្សឧភតោព្យញ្ជនកៈមាន ៣ គឺ* **វច្ចមគ្គ ១ បស្សាវមគ្គ ១មុខមគ្គ ១។**

*ទ្វារមគ្គសត្វតិរច្ឆានញី មាន ៣ គឺ* **វច្ចមគ្គ ១បស្សាវមគ្គ ១ មុខមគ្គ ។**

*ទ្វារមគ្គសត្តតិវដ្ឋានឈ្មោល មាន ២ គឺ* **វច្ចមគ្គ ១ មុខមគ្គ ១។**

*ទ្វារមគ្គសត្តតិវដ្ឋានទ្វីយ មាន២ គឺ* **វច្ចមគ្គ ១ មុខមគ្គ ១ ។**

*ទ្វារមគ្គសត្តតិវដ្ឋានឧកតោព្យញ្ជនកៈមាន៣ គឺ***វច្ចមគ្គ ១ បស្សាវមគ្គ ១មុខមគ្គ ១។**

*ទ្វារមគ្គទាំង ៣០ នេះ ជាទីទម្លាយនៃសីល ។*

*ពាក្យថា* **វច្ចមគ្គ** *ទ្វារធំ* **បស្សាវមគ្គ** *ទ្វារតូច* **មុខមគ្គ** *ទ្វារមាត់ ។*

## អព្រហ្មចរិយៈនេះមានអង្គ ៤ គឺ

**១– ភេទនវត្ថុ** *វត្ថុជាទីទម្លាយនូវសីលគឺទ្វារមគ្គទាំង ៣០ ទ្វារណាមួយ*

**២– សេវនចិត្តំ** *ចិត្តគិតនឹងសេព*

**៣– តជ្ជោវាយាមោ** *ព្យាយាមនឹងសេពនូវមេថុនធម្មនោះ*

**៤– មគ្គេន មគ្គប្បដិបាទនំ** *ញុំាំងមគ្គ និងមគ្គឲ្យជល់គ្នា*

*អព្រហ្មចរិយៈនេះ ជាសភាវៈ ជាអនាណត្តិកៈ មានសមុដ្ឋាន ១ គឺ កាយចិត្តតោទោសកើតឡើងអំពីកាយ និងចិត្ត ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម ជាអកុសលចិត្ត ជាធម្មៈ ជាកោដ្ឋាសៈ មានសង្ខារណាមួយក្នុងរូបធម៌ ជាអារម្មណ៍ (សង្ខារជាអារម្មណ៍) មានវេទនាពីរ គឺសុខវេទនាខ្លះ ជួនជាអទុក្ខមសុខវេទនាខ្លះ មានមូលពីរគឺ លោភមូល និងមោហមូល ជាអនិពទ្ធសីល ជាសមាទាន មានវិរតិ ៣ ណាមួយ ជាវត្ថុកាម និងកិលេសកាម ។*

**អនាបជ្ជន:** *ហេតុដែលមិនត្រូវទោសមាន ៤ យ៉ាង គឺ:*

**១–អជានន្តស្ស** *មិនដឹងខ្លួន*

**២–ឧម្មត្តកស្ស** *ឆ្កួត*

**៣–ខិត្តចិត្តស្ស** *មានចិត្តរវើរវាយ*

**៤–វេទនដ្ដស្ស** *វេទនាគ្របសង្កត់ ។ មិនត្រេកអរ ១ ផង ជាគម្រប់ ៥ ។*

*ចំពោះទោសក្នុងអព្រហ្មចរិយៈនេះ បណ្ឌិតទាំងឡាយ គប្បីជ្រាបតាមការមេសុមិច្ឆាចារៈនោះ ដូចខ្ញុំបាទពណ៌នាមកហើយនោះឯង ។*

*ផលចំពោះសិក្ខាបទនោះ ក្នុងព្រហ្មចរិយសិក្ខាបទទីបីនេះមាន ១៧ យ៉ាងដែលលោកពោលទុកនៅក្នុង* **បរមត្ថជោតិកា** *អដ្ឋកថា ខុទ្ទកនិកាយ ខុទ្ទកបាឋៈ និង នៅក្នុង* **បរមត្ថទីបនី** *អដ្ឋកថា ខុទ្ទកនិកាយ ឥតិវុត្តកៈ សម្ដែងថា មាន ១៧ យ៉ាងគឺ៖*

**១– វិគតបច្ចត្ថិកតា** *ភាពជាអ្នកមិនមានសឹកសត្រូវ*

**២– សព្វសត្តានំ បិយមនាបតា (សព្វជនស្ស បិយតា)** *ភាពជាទីស្រលាញ់ពេញចិត្តរបស់សត្វទាំងឡាយ ឬជនទាំងឡាយ*

**៣– អន្នបានវត្ថច្ឆាទនាទីនំ លាភិតា** *ភាពជាអ្នកមានប្រក្រតីបានរបស់ផ្សេងៗមាន បាយ ទឹក សំពត់ និងវត្ថុគ្រឿងបិទបាំង* **(អន្នបានវត្ថសយនាទីនំ បដិលាភតា)** *ភាពជាអ្នករកបាយទឹកសំពត់ស្លៀកដណ្ដប់ និងទីកន្លែងដេកនៅបានដោយងាយ*

**៤– សុខសុបនតា (សុខសយនតា)** *ដល់ដេកទៅលក់ជាសុខស្រួល*

៥- សុខបដិពុជ្ឈនតា *ការភ្ញាក់ឡើងវិញ ជាសុខស្រួល ឬសុខសប្បាយ*

៦- អចាយភយវិមោក្ខោ (អចាយភយវិនិមុត្តតា) *ការរួចផុតចាកភ័យក្នុងអបាយ*

៧- ឥត្ថីភាវនបុំសកភាវាធំ អភព្វតា (ឥត្ថិភាវប្បដិលាភស្ស វា នបុំសកភាវប្បដិពភស្សវា អភព្វតា) *មិនគួរដល់ការកើតជាស្រី ឬខ្ទើយឡើយ*

៨- អកោធនតា *ជាមនុស្សមិនងាយនឹងខឹងក្ដាមៗ*

៩- សច្ចការិតា (សក្កច្ចការិតា) *ភាពជាអ្នកមានប្រក្រតីធ្វើអ្វីៗសុទ្ធតែមានរបៀបរៀបរយល្អ*

១០- អមង្កុភូតតា *មិនមានសេចក្ដីអៀនខ្មាស គឺក្លាហានក្នុងជំនុំបរិស័ទ*

១១- អាភាជនសុខតា *ជាអ្នកមានសេចក្ដីសុខដោយការទទួលអញ្ជើញ*

១២- បរិបុណ្ណិន្ទ្រិយតា *មានឥន្ទ្រិយពេញលេញល្អ*

១៣- និរាសង្កតា *មិនមានអ្នកណាមួយរង្កៀសបាន*

១៤- អប្បោស្សុក្កតា *មានសេចក្ដីខ្វល់ខ្វាយតិចក្នុងអំពើឥតប្រយោជន៍*

១៥- សុខវិហារតា *ទៅនៅទីកន្លែងណាក៏ជួបប្រទះតែសេចក្ដីសុខ*

១៦- អកុតោភយតា *មិនមានភ័យមកអំពីណា*

១៧- បិយ វិប្បយោគភាវោ (បិយវិប្បយោគភាវេនា) *មិនមាន*

*ការព្រាត់ប្រាសចាករបស់ជាទីស្រលាញ់ជាទីពេញចិត្តឡើយ*

**អព្រហ្មចរិយសិក្ខាបទនឹ៣ ចប់**

# មុសាវាទសិក្ខាបទទី ៤

**មុសាវាទ:** កិរិយាពោលនូវពាក្យកុហក ។ នៅក្នុង **បរមត្ថជោតិកា** បានពន្យល់ពីមុសាវាទថា : ក្នុងពាក្យថា **មុសាវាទោ** នេះ បទថា **មុសា** បានដល់វចីប្រយោគ ឬកាយប្រយោគដែលបំបាត់នូវប្រយោជន៍របស់បុគ្គលដទៃ ប្រាថ្នានឹងឲ្យឃៀងឃ្លាតចាកសេចក្តីពិតជាប្រធាន មិច្ឆាចេតនាដែលនឹងនិយាយខុស ធ្វើខុសរបស់បុគ្គលនោះ ដោយប្រាថ្នានឹងឲ្យអ្នកដទៃយល់ខុស ជាសមុដ្ឋាននៃកាយប្រយោគ និងវចីប្រយោគដែលនឹងធ្វើឲ្យអ្នកដទៃយល់ខុស ប្រព្រឹត្តទៅតាមកាយទ្វារ និងវចីទ្វារណាមួយ ឈ្មោះថា **មុសាវាទ**។

នៅក្នុង **សទ្ធម្មបកាសិនី** អដ្ឋកថា ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ បានពន្យល់ពាក្យមុសាវាទនេះថា ៖

បទថា **មុសា** បានដល់ វចីប្រយោគ ឬកាយប្រយោគ ដែលបំបាត់នូវប្រយោជន៍របស់អ្នកដែលប្រាថ្នានឹងនិយាយឲ្យខុស ។ ចេតនាដែលតាំងឡើងដោយកាយប្រយោគ និងវចីប្រយោគរបស់អ្នកនិយាយឲ្យអ្នកដទៃយល់ខុស ដោយប្រាថ្នាឲ្យគេយល់ខុស ឈ្មោះថា **មុសាវាទ** ។ ន័យម្យ៉ាងទៀត បទថា **មុសា** បានដល់ រឿងមិនពិត ។ បទថា **វាទោ** បានដល់វាទ:និយាយឲ្យគេដឹងសេចក្តីពិត ដោយពាក្យពិត ។ តែដោយលក្ខណ:ចេតនាតាំងឡើង ដោយនិយាយពាក្យប្រាប់អាក្រក់យ៉ាងនេះ ជាបុគ្គលដែលប្រាថ្នាឲ្យអ្នកដទៃដឹងរឿងមិនពិត ដោយពាក្យនិយាយមិនពិត ឈ្មោះថា **មុសាវាទ** ។ មុសាវាទនោះ បើបំបាត់នូវប្រយោជន៍របស់បុគ្គលដទៃតិច មានទោសតិច បើបំបាត់ប្រយោជន៍របស់បុគ្គលដទៃច្រើន មានទោសច្រើន ។

*ដើម្បីសេចក្ដីនេះ ឲ្យកាន់តែជាក់ច្បាស់ ខ្ញុំបាទនឹងចងក្រងសេចក្ដីនេះបន្ថែមទៀត ដែលលោកបានពន្យល់ទុកនៅក្នុង* **មង្គលត្ថទីបនីភាគ** *២ ទំព័រ ៥៧ មង្គល បាលីសុទ្ធ ។ នៅក្នុង មង្គលត្ថទីបនីនោះ បានសម្ដែងថា* **មុសាតិ វិសំវាទនបុរេក្ខារស្ស អត្ថភញ្ជកោ វចីបយោគ កាយប្បយោគោ វា ។**

*វចីប្រយោគ ឬកាយប្រយោគរបស់បុគ្គលអ្នកប្រាថ្នាចង់ពោលនូវពាក្យឲ្យឃ្លៀងឃ្លាត ជាប្រធាន ឈ្មោះថា* **មុសា** *គឺពាក្យកុហក ឬពាក្យមិនពិត ។ លោកបានសម្ដែងក្នុង* **មង្គលត្ថទីបនី** *ជាបន្តទៀតថា៖*

*ក្នុងពាក្យទាំងឡាយនោះ ពាក្យថា បំបាត់នូវប្រយោជន៍ លោកពោលដើម្បីសម្ដែងនូវមុសាវាទដែលដល់ព្រមដល់កម្មបថ ។ លោកសម្ដែងនូវមុសាស័ព្ទជាប្រធាននៃកិរិយាដោយស័ព្ទ មានវចីប្រយោគជាដើម ។ ចេតនារបស់បុគ្គលដែលញុំាងកាយប្រយោគ និងវចីប្រយោគដែលពោលឃ្លៀងឃ្លាតឲ្យតាំងឡើងដល់បុគ្គលដទៃ ដោយប្រាថ្នាពោលឲ្យឃ្លៀងឃ្លាត ឈ្មោះថា* **មុសាវាទ** *ព្រោះមានវិគ្រោះថា:* **យថាវុត្តប្បយោគភូតំ មុសា វទតិ វិញ្ញាបេតិ សមុដ្ឋាបេតិ វា ឯតាយ** *បុគ្គលរមែងពោលនូវពាក្យកុហក ដូចប្រយោគដែលពោលមកហើយ គឺឲ្យអ្នកដទៃដឹងច្បាស់នូវពាក្យកុហក(នោះ) ឬញុំាងពាក្យកុហកនោះឲ្យតាំងឡើង ដោយចេតនានោះ (ឈ្មោះថា មុសាវាទ) សេចក្ដីប្រាថ្នាពោលនូវពាក្យកុហកឲ្យឃ្លៀងឃ្លាតចាកពាក្យពិត រមែងមានតាំងពីខាងដើម (គឺមុននឹងនិយាយ) ទាំងក្នុងខណៈនោះ (គឺកំពុងនិយាយ) ។*

***មែនពិតព្រះឧបាលីថេរ:*** *ពោលពាក្យនេះទុកថា មុននឹងនិយាយដឹងថាអញនឹងនិយាយកុហក កំពុងនិយាយដឹងថាអញនិយាយកុហក ។ សេចក្ដីដឹងខ្លួនទាំងពីរ យ៉ាងនេះឯង ជាអង្គសំខាន់ ក្រៅពីនោះនឹងមានក៏ដោយ មិនមានក៏ដោយ មិនជាប្រមាណទេ ។*

ន័យម្យ៉ាងទៀត រឿងមិនពិត ឈ្មោះថា **មុសា**។ ការញុំាងអ្នកដទៃឲ្យជ្រាប រឿងនោះដោយភាពជារឿងពិត ឈ្មោះថា **វាទៈ**។

ក៏ចេតនាដែលញុំាងវិញ្ញត្តិ (ការបញ្ចេញវាចា) យ៉ាងនោះ ឲ្យតាំងឡើងរបស់អ្នកប្រាថ្នានឹងញុំាងអ្នកដទៃឲ្យជ្រាបរឿងដែលមិនពិត ដោយភាពជារឿងពិត ឈ្មោះថា **មុសាវាទ** ព្រោះមានបទវិគ្រោះថា: **ចេតនា មុសាវាទោ មុសា វាទិយតិ វុច្ចតិ** ពាក្យកុហកដែលបុគ្គលរមែងពោល គឺរមែងនិយាយកុហកដោយចេតនានោះ។ ក្នុងអធិការណ៍នៃមុសាវាទនេះ គប្បីឃើញសន្និដ្ឋានថា លោកពោលទុកដោយន័យ ២ យ៉ាង ដើម្បីសម្តែងលក្ខណៈនោះឲ្យបរិបូណ៌ ព្រោះលក្ខណៈនៃមុសាវាទក្នុងន័យមុនមិនទាន់ជាក់ច្បាស់ និងមានសេចក្តីដែលមុសាស័ព្ទ ជាស័ព្ទប្រាប់សេចក្តី ដែលនឹងគប្បីពោលឲ្យឃ្លៀងឃ្លាត ។ នៅក្នុង **សុមង្គលវិលាសិនី** អដ្ឋកថា ទីឃនិកាយ សីលក្ខន្ធវគ្គ ត្រង់ព្រហ្មជាលសូត្រ បានពន្យល់ពាក្យមុសាវាទថា៖

ក្នុងពាក្យថា **មុសាវាទំ បហាយ** នេះបានដល់វចីប្រយោគ ឬកាយប្រយោគដែលទម្លាយប្រយោជន៍របស់បុគ្គលអ្នកតាំងចិត្ត និងពោលឲ្យឃ្លៀងឃ្លាតជាប្រធាន ។ ក៏ចេតនាដែលឲ្យកើតកាយប្រយោគ និងវិចីប្រយោគ ដែលនិយាយឲ្យឃ្លៀងឃ្លាត របស់បុគ្គលអ្នកតាំងចិត្តនឹងពោលឲ្យឃ្លៀងឃ្លាតនោះ ដោយប្រាថ្នានឹងពោលឲ្យឃ្លៀងឃ្លាត ឈ្មោះថា **មុសាវាទ** ។ ន័យមួយទៀត ពាក្យថា **មុសា** បានដល់រឿងដែលមិនមានពិត ។ ពាក្យថា **វាទ** បានដល់កិរិយាដែលធ្វើឲ្យគេយល់រឿងដែលមិនពិតនោះថាជារឿងពិតទៅវិញ ។ ពោលដោយលក្ខណៈនោះ ចេតនាដែលឲ្យកើតវិញ្ញត្តិយ៉ាងនោះ របស់អ្នកប្រាថ្នានឹងឲ្យអ្នកដទៃយល់រឿងដែលមិនពិតថា ជារឿងពិតទៅវិញ ឈ្មោះថា **មុសាវាទ** ។ មុសាវាទនោះ

មានទោសតិច ព្រោះប្រយោជន៍ ដែលទម្លាយនោះតិច មានទោសច្រើន ព្រោះប្រយោជន៍ ដែលទម្លាយនោះច្រើន ។

ម្យ៉ាងទៀត សម្រាប់ពួកគ្រហស្ថ មុសាវាទដែលប្រព្រឹត្តទៅ ដោយន័យថា មិនមាន ជាដើម ព្រោះប្រាថ្នានឹងមិនឲ្យរបស់ខ្លួន មានទោសតិច ដែលជាសាក្សីកោង ពោលដើម្បីទម្លាយប្រយោជន៍ មានទោសច្រើន ។ សម្រាប់ពួកបព្វជិត មុសាវាទដែលប្រព្រឹត្តទៅ ដោយន័យនិយាយថា ជារបស់បរិបូណ៌ ដូចថាថ្ងៃនេះប្រេងក្នុងស្រុកហូរដូចស្ទឹងជាដើម ដោយប្រាថ្នានឹងសើចលេង ព្រោះបានប្រេងទឹកដោះថ្លា មកតិចតួចមានទោសតិច តែកាល និយាយដល់វត្ថុដែលមិនឃើញឡើយ ដោយន័យថាឃើញហើយជាដើម មានទោសច្រើន ។

នៅក្នុង **សម្មោហវិនោទនី** លោកបានពន្យល់ទោសនៃមុសាវាទថា៖

**កាកណិកមត្តស្ស អត្ថាយ មុសាកថេន អប្បសាវជ្ជោ** ការនិយាយពាក្យកុហក ដើម្បីប្រយោជន៍ដល់ទ្រព្យ មានប្រមាណមួយកាកណិក (ពាក្យថាកាកណិក ជាឈ្មោះមាសប្រាក់តិចបំផុត) មានទោសតិច ដោយពាក្យនិយាយកុហក (ដោយទ្រព្យប្រមាណប៉ុណ្ណោះ) ។

**តតោ អឌ្ឍមាសកស្ស** ការនិយាយពាក្យកុហក ដើម្បីប្រយោជន៍ដល់ទ្រព្យ ប្រមាណកន្លះមាសកៈ មានទោសច្រើនជាងនោះ ។

**មាសកស្ស** ការនិយាយពាក្យកុហក ដើម្បីប្រយោជន៍ដល់ទ្រព្យប្រមាណមួយ មាសកៈ មានទោសច្រើនជាងនោះ ។

**បញ្ចមាសកស្ស** ការនិយាយពាក្យកុហក ដើម្បីប្រយោជន៍ដល់ទ្រព្យប្រមាណ ប្រាំមាសកៈ មានទោសច្រើន ។

**អប្បកហាបណស្ស** ការនិយាយពាក្យកុហក ដើម្បីប្រយោជន៍ដល់ទ្រព្យ មានប្រមាណកន្លះកហាបណៈ មានទោសច្រើនជាងនោះ ។

**កហាបណស្ស** ការនិយាយពាក្យកុហក ដើម្បីប្រយោជន៍ដល់ទ្រព្យប្រមាណមួយកហាបណៈ មានទោសច្រើនជាងនោះ ។

**តតោ អនគ្ឃនិយភណ្ឌស្ស អត្ថាយ មុសាការេន មហាសាវជ្ជោ** ការនិយាយពាក្យកុហកដើម្បីប្រយោជន៍ដល់ទ្រព្យរាប់ប្រមាណមិនបាន មានទោសច្រើនជាងនោះ ។

**មុសា ការេត្វា បន សង្ឃំ ភិន្ទន្តស្ស ឯកន្តមហាសាវជ្ជោវ** ។ ចំណែកខាងក្រោយ ពោលនូវពាក្យមុសាវាទ ដើម្បីធ្វើឲ្យសង្ឃបែកបាក់គ្នា មានទោសច្រើនក្រៃលែងមហាក្រៃលែង ។

នៅក្នុង **បរមត្ថទីបនី** អដ្ឋកថា ខុទ្ទកនិកាយ ឥតិវុត្តកៈ ត្រង់បុត្តសូត្រ បានសម្តែងទោសនៃមុសាវាទថាៈ **មុសាវាទ** នោះ ឈ្មោះថា មានទោសតិច ព្រោះប្រយោជន៍ដែលខ្លួននឹងបំបាត់នោះមានតិច ។ ឈ្មោះថា មានទោសច្រើន ព្រោះប្រយោជន៍ដែលខ្លួនបំបាត់នោះមានច្រើន ។ម្យ៉ាងទៀត សម្រាប់គ្រហស្ថទាំងឡាយ មុសាវាទដែលប្រព្រឹត្តទៅដោយន័យជាដើមថាមិនមាន ព្រោះមិនប្រាថ្នានឹងឲ្យរបស់ខ្លួនដល់បុគ្គលដទៃ ឈ្មោះថា មានទោសច្រើន ។ សម្រាប់បព្វជិតវិញ មុសាវាទដែលប្រព្រឹត្តទៅហើយ ដោយន័យជាបូរាណកថា ថាថ្ងៃនេះស្រុកនេះប្រេងហូរទៅដូចស្ទឹង ដោយប្រាថ្នានឹងលេងសើច ព្រោះបានប្រេង ឬទឹកដោះថ្លាតិចតួច ឈ្មោះថា មានទោសតិច តែកាលវត្ថុដែលខ្លួនមិនបានឃើញ ហើយពោលថា បានឃើញ មុសាវាទ ឈ្មោះថា មានទោសច្រើន ។ ម្យ៉ាងទៀត មុសាវាទឈ្មោះថា មានទោសតិច ព្រោះបុគ្គលដែលខ្លួនបំបាត់ប្រយោជន៍ មានគុណធម៌តិច ឈ្មោះថា

មានទោសច្រើន ព្រោះបុគ្គលដែលខ្វះបំផ្លើសបំបាត់នូវប្រយោជន៍ មានគុណធម៌ច្រើន ។ ហើយមុសាវាទដែលមានតិច ឬច្រើននោះ នឹងសម្រេចបានដោយអំណាចនៃកិលេសទន់ខ្សោយ ឬក៏មានកម្លាំងខ្លាំងក្លា ។

ផលចំពោះសិក្ខាបទមុសាវាទនេះ លោកបានសម្តែងអំពីផល ដែលត្រូវទទួលបាន ដែលមាននៅក្នុងគម្ពីរ **បរមត្ថទីបនី** អដ្ឋកថា ខុទ្ទកនិកាយ ឥតិវុត្តកៈ ត្រង់បុត្តសូត្រ និងនៅក្នុង **បរមត្ថជោតិកា** អដ្ឋកថា ខុទ្ទកនិកាយ ខុទ្ទកបាឋៈថា : មានផលរហូតដល់១៤ យ៉ាងគឺ ៖

**១–វិប្បសន្និន្ទ្រិយតា** ភាពជាអ្នកមានឥន្ទ្រិយទាំង ៥ ថ្លាស្អាតផូរផង់

**២–វិសដ្ឋមធុរភាណិតា** មានវាចាពីរោះក្បោះក្បាយផង

**៣–សមសិតសុទ្ធទន្តតា** មានធ្មេញត្រឹមស្មើជិតបរិសុទ្ធល្អ

**៤–នាតិថូលតា** មានរាងជាមនុស្សសមទ្រង់ មិនធាត់ពេក

**៥–នាតិកិសតា** ជាមនុស្សល្មម មិនស្គមពេក

**៦–នាតិរស្សតា** ជាមនុស្សល្មម មិនទាបពេក

**៧–នាតិទីឃតា** ជាមនុស្សល្មម មិនខ្ពស់ពេក

**៨–សុខសម្ផស្សតា** បាននូវសម្ផស្សក៏សុខស្រួល

**៩–ឧប្បលគន្ធមុខតា** ភាពជាអ្នកមានក្លិនមាត់ក្រអូប ដូចក្លិនឧប្បលជាតិ

**១០–សុស្សូសកបរិសតា** ភាពជាអ្នកមានបរិស័ទជឿស្តាប់តាំងនៅក្នុងឱវាទ។

**១១–អាទេយ្យវចនតា** ភាពជាអ្នកមានសម្តីគួរជឿស្តាប់កាន់យកបាន

**១២–កមលទលសទិមុទុលោហិតនយជិវ្ហតា** *ភាពជាអ្នកមានអណ្តាតស្តើងក្រហមនឹងប្រៀបដូចត្របកផ្កាឧប្បល*

**១៣–អលីនតា** *ភាពជាអ្នកមិនមានត្រចៀកថ្ងន់*

**១៤–អនុទ្ធតតា** *ភាពជាអ្នកមិនមានចិត្តរវើរវាយ ។*

*(ទី១៤នេះ ក្នុងបរមត្ថជោតិកា សម្តែងថា* **អបគតមម្មនតា** *មិនមែនជាមនុស្សល្ងង់ខ្លៅផង) ខ្ញុំបាទនឹងបញ្ជាក់ចំពោះពាក្យពោលកុហក ដែលមានមកនៅក្នុងគម្ពីរវិន័យបិដក* **មហាវិភង្គ** *ភាគ ៣ ទំព័រ ២២៤ ថែមទៀតថា ៖*

**សម្បជានមុសាវាទោ នាម វិសំវាទនបុរេក្ខារស្ស វាចា គិរា ព្យប្បថោ វចីភេទោ វាចសិកា វិញ្ញត្តិ អដ្ឋ អនរិយវោហារា អទិដ្ឋំ ទិដ្ឋំ មេតិ អសុតំ សុតំ មេតិ អមុតំ មុតំ មេតិ អវិញ្ញាតំ វិញ្ញាតំ មេតិ ទិដ្ឋំ អទិដ្ឋំ មេតិ សុតំ អសុតំ មេតិ មុតំ អមុតំ មេតិ វិញ្ញាតំ អវិញ្ញាតំ មេតិ ។**

*ដែលហៅថា ពោលកុហកដោយដឹងខ្លួននោះ បានដល់វាចា សម្តីគន្លងពាក្យវចីភេទវិញ្ញត្តិប្រព្រឹត្តទៅក្នុងវាចារបស់បុគ្គលដែលធ្វើគំនិត នឹងពោលឲ្យខុសជាប្រធាន និងវោហារមិនមែនរបស់ព្រះអរិយៈ៨ យ៉ាង គឺការដែលមិនឃើញ នឹងនិយាយថាអញឃើញ ១ មិនឮនិយាយថាអញឮ ១ មិនបានពាល់ត្រូវ និយាយថាអញពាល់ត្រូវ ១ មិនដឹងច្បាស់និយាយថាអញដឹងច្បាស់ ១ ឃើញនិយាយថាអញមិនឃើញ ១ ឮ និយាយថាអញមិនឮ១ បានពាល់ត្រូវ និយាយថាអញមិនបានពាល់ត្រូវ ១ ដឹងច្បាស់ និយាយថាអញមិនដឹងច្បាស់ ១ ។*

*អាការដែលកុហកនោះ នៅក្នុង* **មហាវិភង្គ** *ព្រះឧបាលិថេរៈ បានសម្តែងរៀបរាប់រហូតអាការៈ ៧ យ៉ាង ។ ដូច្នេះនឹងដកសេចក្តីសំខាន់ ដែលជាអាការៈ ៣ យ៉ាង ដែលលោកសម្តែងថា៖*

**១-បុព្វេវស្ស ហោតិ មុសា ភណិស្សន្តិ** *មុននឹងពោល គិតថាអញនឹងពោលកុហក*

**២-ភណន្តស្ស ហោតិ មុសា ភណាមីតិ** *កំពុងពោល ដឹងថាអញពោលកុហក*

**៣-ភណិតស្ស ហោតិ មុសា មយា ភណិតំ** *ពោលរួចហើយដឹងថាអញពោលកុហកហើយ ។*

*ការពោលដោយអាការៈទាំង ៣ យ៉ាងនេះ រមែងជាច់ខូច សិក្ខាបទមុសាវាទ ។ តែអដ្ឋកថាទាំងឡាយ លោកពោលថា ត្រឹមតែអាការៈ ២ យ៉ាងប៉ុណ្ណោះ ក៏រមែងដាច់ខូចមុសាវាទសិក្ខាបទនេះពិត ។*

## មុសាវាទសិក្ខាបទមានអង្គ ៤

**១-អតថំវត្ថុ** *វត្ថុមិនពិត ឬហេតុមិនពិត*

**២-វិសំវាទនចិត្តំ** *គិតនឹងពោលឲ្យខុស*

**៣-តជ្ជោវាយាមោ** *ព្យាយាមនឹងពោលឲ្យខុសនោះ*

**៤-បរស្ស តទត្ថាវិជាននំ** *ញុំាងអ្នកដទៃឲ្យដឹងច្បាស់នូវសេចក្តីនោះ មុសាវាទៈជាសការៈ ជាអនាណត្តិក មានសមុដ្ឋាន ៣ គឺ:*

**១-កាយចិត្តតោ** *ទោសកើតឡើងអំពីកាយ និងចិត្ត*

**២-វាចាចិត្តតោ** *ទោសកើតឡើងអំពីវាចា និងចិត្ត*

**៣-កាយវាចាចិត្តតោ** *ទោសកើតឡើងអំពីកាយ វាចា និងចិត្ត*

*ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម និងវចីកម្ម ជាអកុសលចិត្ត ជាធម្មៈ ជាកោដ្ឋាសៈ មានសត្វ ឬសង្ខារជាអារម្មណ៍ មានវេទនា ៣ ដូចអទិន្នាទាន មានមូលពីរគឺ លោភមោហមូល១ ទោសមោហមូល ១ ជាអនិពន្ធសីល ជាសមាទាន មានវិរតិ ៣ ណាមួយ ជាវត្ថុកាម និងកិលេសកាម អនាបជ្ជនៈ ហេតុដែលមិនត្រូវទោសមាន ៣ យ៉ាងគឺ ៖*

**១-ទវាយ ភណាតិ** *ពោលដោយញាប់មាត់ គឺពោលដោយរហ័ស ឈ្មោះថា ពោលដោយញាប់មាត់*

**២-រវាយ ភណាតិ** *ពោលដោយភ្លាត់មាត់ គឺក្នុងចិត្តគិតថា អញនឹងពោលពាក្យដទៃ ហើយត្រឡប់ពោលពាក្យដទៃក្រៅអំពីគំនិតនោះវិញ ឈ្មោះថា ពោលដោយភ្លាត់មាត់១*

**៣-ឧម្មត្តកស្ស** *ដូច១ ។*

**មុសាវាទសិក្ខាបទទី៤ ចប់**

## សុរាមេរយសិក្ខាបទទី៥

*កិរិយាផឹកនូវទឹកស្រវឹង ឬសុរា និងមេរ័យ ។* **អជ្ឈោហារចេតនា** *ដែលក្លែងផឹកទឹកស្រវឹង គឺសុរាមេរ័យដោយហោចទៅសូម្បីផឹកប៉ុនចុងស្រូវ ក៏ដាច់ខូចសិក្ខាបទសុរា-មេរយៈហ្នឹងដែរ ។ បើសាមណេរទាំងឡាយ ឬគ្រហស្ថមិនបានដឹងខ្លួន ដូចជាដេកលក់ហើយមានអ្នកដទៃលបយកសុរា ឬមេរយៈ ទៅចាក់បង្អកឲ្យចូលក្នុងមាត់ហើយ បានជញ្ជក់លេបចូលទៅតាមបំពង់ក មិនដាច់ខូចសិក្ខាបទហ្នឹងទេ ព្រោះសិក្ខាបទនេះ សម្រាប់សាមណេរ ឬគ្រហស្ថ ជាសិក្ខាបទសចិត្តកៈ លុះតែមានចិត្តក្លែងទើបត្រូវទោស បើមិនមានចិត្តក្លែងទេ មិនត្រូវទោសចំពោះសាមណេរ ឬគ្រហស្ថទាំងឡាយឡើយ ។ តែចំណែកភិក្ខុវិញ សូម្បីមិនដឹងខ្លួន ក៏ត្រូវអាបត្តិបាចិត្តិយៈដែរ ព្រោះសុរាបាន សិក្ខាបទនេះសម្រាប់ភិក្ខុ ជាអចិត្តកសិក្ខាបទ ទោះបីមានចិត្តក្លែងក្តី មិនមានចិត្តក្លែងក្តី ឲ្យតែលេបចូលផុតបំពង់កចូលទៅហើយ រមែងត្រូវអាបត្តិ ព្រោះត្រូវអាបត្តិដោយចិត្ត ៣ វេទនា ៣ សម្រាប់ភិក្ខុ ។ នៅក្នុងវិន័យបិដក* ***មហាវិភង្គ*** *ភាគ ៤ ទំព័រ ២០៩ និងនៅក្នុងអដ្ឋកថា ទាំងឡាយមាន* **បរមត្ថជោតិកា** *ជាដើម បានសម្តែងអំពីសុរានោះ មាន ៥ យ៉ាងគឺ ៖*

**១–បិដ្ឋសុរា** *សុរាធ្វើដោយម្សៅ*

**២–បូវសុរា** *សុរាធ្វើដោយនំ*

**៣–ឱទនសុរា** *សុរាធ្វើដោយបាយ*

**៤–កិណ្ណបក្ខិត្តា** *សុរាដែលគេដាក់ពូជសុរា*

**៥–សម្ភារសំយុត្តា** *សុរាដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ ។*

*មេរ័យមាន ៥ យ៉ាងគឺ* **បុប្ផាសវោ** *ទឹកត្រាំដែលគេធ្វើដោយផ្កាឈើ១* **ផលាសវោ** *ទឹកត្រាំដែលគេធ្វើដោយផ្លែឈើ ១* **មធ្វាសវោ** *ទឹកត្រាំដែលគេធ្វើដោយចន្ទន៍ ឬគេធ្វើដោយទឹកឃ្មុំ ១* **គុឡាសវោ** *ទឹកត្រាំដែលគេធ្វើដោយទឹកអំពៅ ១* **សម្ភារសំយុត្តោ** *ទឹកត្រាំដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ ១ ។*

*នៅក្នុងសារត្ថទីបនីដីកាភាគ ៣ ទំព័រ ៩៨ បានពន្យល់ថា*

**បិដ្ឋំ ភាជនេ បក្ខិបិត្វា តជ្ជំ ឧទកំ ទត្វា មទ្ទិត្វា កតា បិដ្ឋសុរា ។ ឯវំ បូវេ ឱទនេ ច ភាជនេ បក្ខិបិត្វា តជ្ជំ ឧទកំ ទត្វា មទ្ទិត្វា កតា បូវសុរា ឱទនសុរាតិ ច វុច្ចតិ ។**

*សុរាដែលគេដាក់ម្សៅចុះក្នុងភាជនៈហើយ បន្ថែមទឹកល្មមដល់ម្សៅនោះ លាយធ្វើ ឈ្មោះថា សុរាធ្វើដោយម្សៅ ។ សុរាដែលគេដាក់នំក្តី បាយក្តី ដាក់ចុះក្នុងភាជនៈ ហើយបន្ថែមទឹកឲ្យល្មមសមដល់នំ ឬបាយនោះ ហើយច្របល់លាយធ្វើយ៉ាងនោះ លោកហៅថា សុរាធ្វើដោយនំ ឬសុរាធ្វើដោយបាយ ។*

**"កិណ្ណាតិ" បន តស្សា សុរាយ ពីជំ វុច្ចតិ ។ យេ សុរាមោទកាតិបិ វុច្ចន្តិ ។ តេ បក្ខិបិត្វា កតា កិណ្ណបក្ខិត្តា ។ ហរីតកីសាសបាទិនានា-សម្ភារេហិ សំយោជិតា សម្ភារសំយុត្តា ។**

*ចំណែកឯពូជរបស់សុរានោះ ឈ្មោះថា ពូជ ។ សុរាដែលគេដាក់ពូជ ដែលលោកហៅថា ម្សៅសុរាខ្វះ ហើយធ្វើ ឈ្មោះថា សុរាដែលគេដាក់ពូជសុរា ។ សុរាដែលគេ*

*ប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ មានផ្លែសម៉ និងគ្រាប់ស្ពៃជាដើមឈ្មោះថា* **សុរា** *ដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ ។*

**មធុកតាលនាឡិកេរាទិបុប្ផរសោ ចិរបរិវាសិតោ បុប្ផាសវោ ។ បនសាទិផលរសោ ផលាសវោ ។ មុទ្ទិការសោ មធ្វាសវោ ។ ឧច្ឆុរសោ គុឡាសវោ ។ ហរីតកាមលកកដុកភណ្ឌាទិនានាសម្ភារានំ រសោ ចិរបរិវាសិតោ សម្ភារសំយុត្តោ ។**

*រសផ្កាស្រគំ ត្នោត និងដូងជាដើម ដែលត្រាំទុកយូរ ឈ្មោះថា ទឹកត្រាំដែលគេធ្វើដោយផ្កាឈើ ។ រសផ្លែឈើទាំងឡាយ មានផ្លែខ្នុរជាដើម ដែលត្រាំទុកយូរ ឈ្មោះថា ទឹកត្រាំដែលគេធ្វើដោយផ្លែឈើ ។ រសនៃផ្លែទំពាំងបាយជូរ ឬផ្លែចន្ទន៍ (ដែលគេត្រាំទុកយូរ) ឈ្មោះថា ទឹកត្រាំដែលគេធ្វើដោយទឹកផ្អែម ។ រសនៃទឹកអំពៅអប់ (ដែលគេត្រាំទុកយូរ) ឈ្មោះថា ទឹកត្រាំដែលគេធ្វើដោយទឹកអំពៅ ។ រសរបស់ដែលគេប្រកបព្រមតាក់តែងដោយគ្រឿងផ្សំផ្សេងៗ មានសម៉ កន្ទួតព្រៃ និងរបស់ហឹរជាដើម ដែលគេត្រាំទុកយូរ ឈ្មោះថា ទឹកត្រាំប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ ។*

*នៅក្នុង* **វិមតិវិនោទនីដីកា** *ភាគ ២ ទំព័រ ៥៦ លោកពន្យល់ថា:*

**កិណ្ណប្បក្ខិត្តាតិ បិដ្ឋបូវាទី អបក្ខិបិត្វា កិណ្ណសង្ខាតំ ធញ្ញង្កុរាទី សុរាពីជំ បក្ខិបត្វា កតា ។**

**សម្ភារសំយុត្តាតិ សាសចាទិអនេកសម្ភារេហិ សញ្ញុតា ។**

*សុរាដែលគេដាក់វត្ថុមានមេព្រា និងនំជាដើម ហើយដាក់ពូជ (មេ) សុរាមានពន្លកធញ្ញជាតិជាដើម ដែលរាប់ថាពូជធ្វើ ឈ្មោះថា សុរាដាក់ពូជ ។ សុរាប្រកបដោយគ្រឿង*

*ផ្សំផ្សេងៗ ជាច្រើនយ៉ាង មានគ្រាប់ស្ពៃជាដើម ឈ្មោះថា សុរាប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ ។*

*នៅក្នុង សមន្តបាសាទិកា ភាគ ៤ ទំព័រ ២៥៧ លោកបានពន្យល់ ថា:*

**បុប្ផាសវោ នាម មធុកបុប្ផាទីនំ រសេន កតា ។ ផលាសវោ នាម មុទ្ទិកាផលាទីនិ មទ្ទិត្វា តេសំ រសេន កតា ។ មធ្វាសវោ នាម មុទ្ទិកានំ ជាតិរសេន កតោ ។ មក្ខិកាមធុនាបិ ករីយតិ វទន្តិ ។ គុឡាសវោ នាម ឧច្ឆុរសាទីហិ ករីយតិ ។ សុរា នាម បិដ្ឋកិណ្ណបក្ខិត្តា នាឡិកេរាទីនំ រសេន កតា សុរាត្វេវ សំខ្យំ គច្ឆតិ ។ តស្សាយេវ កិណ្ណបក្ខិត្តាយ មណ្ឌោ គហិតោ មេរយោត្វេវ សំខ្យំ គច្ឆតីតិ វទន្តិ ។**

*ប្រែថា មេរ័យដែលគេធ្វើដោយរសនៃផ្កាស្រគំជាដើម ឈ្មោះ ថា* **បុប្ផាសវៈ**។ *មេរ័យដែលគេម្ងាស់ផ្លែចន្ទន៍ជាដើម ហើយធ្វើដោយរសនៃផ្លែចន្ទន៍ជាដើមនោះ ឈ្មោះថា* **ផលាសវៈ** ។

*មេរ័យដែលគេធ្វើដោយរសជាតិនៃផ្លែចន្ទន៍(ឬទំពាំងបាយជូរ)ជាដើម ឈ្មោះថា***មធ្វាសវៈ** *អាចារ្យពួកខ្លះ ពោលថា គេធ្វើដោយទឹកឃ្មុំក៏មាន ។ មេរ័យដែល ឈ្មោះថា* **គុឡាសវៈ** *គេធ្វើដោយទឹកអំពៅស្រស់ជាដើម ។*

*ធម្មតាសុរាដែលគេដាក់ពូជមេ្យា ធ្វើដោយរសនៃផ្កាដូងជាដើម រមែងសង្គ្រោះចូលជាសុរាយ៉ាងនោះ អាចារ្យពួកខ្លះពោលថា កាលដួសយកទឹកថ្លានៃសុរា ដាក់ពូជហើយនោះឯង (ដ៏សេស) រមែងសង្គ្រោះចូលក្នុងមេរ័យនោះឯង ។*

*នៅក្នុងគម្ពីរ **មហាវគ្គដីកា** ឈ្មោះលីនត្ថប្បកាសិនី ត្រង់សង្គាលសូត្រ និងអដ្ឋកថា*

**តំបិ សព្វំ ទសវិធម្បិ មទការណវសេន មជ្ជំ បិវន្តំ មទយតីតិ កត្វា**

*វត្ថុសូម្បីទាំង ១០ យ៉ាង ទាំងអស់នោះ ឈ្មោះថា ទឹកស្រវឹងដោយអំណាចជាហេតុនៃសេចក្ដីស្រវឹងមានវិគ្រោះថា រមែងញុំាងបុគ្គលអ្នកផឹកឲ្យស្រវឹង ។*

*នៅក្នុងគម្ពីរអដ្ឋកថាឈ្មោះ **សារត្ថប្បកាសិនី** អាមកធញ្ញបេយ្យាល ក្នុងមហាវគ្គ-សំយុត្តនិកាយ លោកពោលទុកថា :*

**មជ្ជន្តិ តេនេវ ឧភយំ វា បនញ្ចំបិ សុរាសវវិនិមុត្តំ មទនីយំ** ។*សុរា និងមេរ័យទាំង ២ យ៉ាងនោះឯង ឬបាន:សូម្បីយ៉ាងដទៃ ដែលផុតចាកសុរា និងមេរ័យនោះ ដែលជាទីតាំងនៃសេចក្ដីស្រវឹង ឈ្មោះថា* **មជ្ជៈ** *។ នៅក្នុងអាមកធញ្ញបេយ្យាល ក្នុងគម្ពីរ **សំយុត្តដីកា** ឈ្មោះលីនត្ថប្បកាសិនីពោលថា ៖*

**សុរាសវវិនិមុត្តន្តិ យថាវុត្តសុរាសវវិនិព្ជុត្តន្តិ** *បទថា* **សុរាសវវិនិមុត្តំ** *គឺផុតចាកសុរា និងមេរ័យដូចដែលពោលហើយ ។*

*នៅក្នុង **មង្គលត្ថទីបនី** ភាគ ៣ ទំព័រ ២១៣ លោកពោល បន្ថែមទៀតថា ៖*

**ឋានំ នាម បមាទដ្ឋានសង្ខាតា បិវនចេតនា ។ តថា ហិ អាមកធញ្ញបេយ្យាលវណ្ណនាយំ យាយ ចេតនាយ តំ បិវន្តិ សា បមាទស្ស ការណត្តា បមាទដ្ឋានំ នាម** *ប្រែថា ចេតនាជាហេតុផឹកនូវទឹកស្រវឹងគឺសុរា និងមេរ័យ ពោលគឺជាទីតាំងនៃសេចក្ដីប្រមាទ ឈ្មោះថា* **ឋានៈ** ។

*មែនពិតយ៉ាងនោះព្រះអដ្ឋកថាចារ្យ លោកពន្យល់ទុកនៅក្នុង អដ្ឋកថា មកធញ្ញ-បេយ្យាលថា ចេតនាជាហេតុផឹកនូវទឹកស្រវឹងនោះ របស់បុគ្គលទាំងឡាយ ឈ្មោះថា*

**បមាទដ្ឋាន:** *ព្រោះជាហេតុនៃសេចក្តីប្រមាទ ។ នៅក្នុងសមន្តប្បសាទិកា ព្រះអដ្ឋកថាចារ្យ បានពោលថា:* **ឯតំ សុរំ វា មេរយំ វា ពីជតោ បដ្ឋាយ កុសគ្គេនបិ បិវតោ ។** *ការផឹកនូវទឹកស្រវឹងមានសុរា ឬមេរ័យនោះ (មិនគួរ) ចាប់ផ្តើមតាំងតែអំពីពូជសូម្បីដោយត្រឹមតែចុងស្មៅរមែងជាប់ខុចនូវសិក្ខាបទហ្នឹង ។*

*នៅក្នុង **សារត្ថទីបនីដីកា** លោកបានពន្យល់ខែអំពីអដ្ឋកថាថា:*

**ពីជតោ បដ្ឋយាតិ សម្ភារេ បដិយាទេត្វា ចាដិកំ បក្ខិត្តកាលតោ តាលនាឡិកេរាទីនំ បុប្ផរស្ស គហិតអភិនវកាលតោ យេវ ច បដ្ឋាយ ។**

*ត្រង់ពាក្យដែលព្រះអដ្ឋកថាបានពោលថា(មិនគួរ) ចាប់ផ្តើមតាំងអំពីពូជ មានសេចក្តីថា ក៏ចាប់ផ្តើមតាំងអំពីការដាក់ចុះក្នុងពាង ដែលគេចាត់ចែងជាគ្រឿងផ្សំហើយ ក៏(មិនគួរ) ចាប់ផ្តើមតាំងតែអំពីកាលដែលគេកាន់យករសនៃផ្កា មានត្នោត ដូងទាំងឡាយជាដើម (ដែលគេលាយផ្សំ) ថ្មីៗមែនពិត ។*

*តែនៅក្នុង **វិមតិវិនោទនីដីកា** លោកបានពោលថា:* **ពីជតោ បដ្ឋាយាតិ យថា- វុត្តានំ បិដ្ឋាទនំ មជ្ជត្ថាយ ភាជនេ បក្ខិត្តកាលតោ បដ្ឋាយ** *ត្រង់ពាក្យដែលព្រះអដ្ឋកថាពោលថា (មិនគួរ) ចាប់ផ្តើមតាំងតែអំពីពូជ មានសេចក្តីថា ចាប់ផ្តើមតាំងតែអំពីកាលដែលដាក់ចុះក្នុងភាជនៈ ដើម្បីប្រយោជន៍ដល់គ្រឿងស្រវឹង មានម្សៅជាដើមតាមន័យដូចពោលមកហើយ ។*

*នៅក្នុង **វជិរពុទ្ធិដីកា** បានពន្យល់ថា ៖*

**យេន មជ្ជតិ, តស្ស ពីជតោ បដ្ឋាយ ។** *រមែងស្រវឹងដោយប្រការយ៉ាងណា (រមែងមិនគួរ) ចាប់ផ្តើមតាំងតែអំពីពូជនៃវត្ថុនោះ ។*

នៅក្នុង **សុត្តន្តបិដក** ទីឃនិកាយ បាដិកវគ្គ ក្នុងសិង្គាលកសូត្រភាគ ១៩ ទំព័រ៧២ ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ត្រាស់និងគហបតីបុត្តថា ម្នាលគហបតីបុត្ត ទោសក្នុងកិរិយាប្រកបរឿយៗ នូវការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាហេតុ ជាទីតាំងនៃសេចក្តីប្រមាទនេះមាន ៦ យ៉ាងគឺ **សន្ទិដ្ឋិកា ធនជានិ** វិនាសទ្រព្យ ដែលឃើញជាក់ស្តែងខ្លួនឯង ១ **កលហប្បវឌ្ឍនី** ការបង្កឲ្យកើតជម្លោះ ១ **រោគានំ អាយតនំ** ហេតុនាំឲ្យកើតរោគទាំងឡាយ ១ **អកិត្តិសញ្ជននី** ការនាំឲ្យខូចឈ្មោះ ១ **ហិរិកោ បិនិទ្ធំសនី** ការបង្ហាញកេរ្តិ៍ខ្មាស ១ **បញ្ញាយ ទុព្វលីករណី** ធ្វើបញ្ញាឲ្យមានកម្លាំងថយ ១ ។ ម្នាលគហបតីបុត្ត ទោសក្នុងការប្រកបរឿយៗ នូវការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាហេតុ ជាទីតាំងនៃសេចក្តីប្រមាទមាន ៦ យ៉ាងនេះឯង ។

នៅក្នុង **សុមង្គលវិលាសិនី** អដ្ឋកថា ទីឃនិកាយ បាដិកវគ្គ ត្រង់សិង្គាលកសូត្របានពន្យល់ថាៈ សុរាទាំង ៥ ប្រភេទ និង មេរ័យទាំង៥ប្រភេទនោះ ឈ្មោះថា **មជ្ជៈ** ដោយអំណាចធ្វើឲ្យស្រវឹង ។ បទថា **បមាទដ្ឋានំ** ប្រែថា ដែលជាហេតុ ជាទីតាំងនៃសេចក្តីប្រមាទ ។ បទនេះ ជាឈ្មោះរបស់ចេតនារបស់អ្នកផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ។ បទថា ប្រកបរឿយៗ អធិប្បាយថា គឺធ្វើញយៗ នូវការផឹកទឹកស្រវឹង គឺសុរា និងមេរ័យដែលជាហេតុ ជាទីតាំងនៃសេចក្តីប្រមាទ ។ ក៏ព្រោះបុគ្គលអ្នកប្រកបរឿយៗ នូវការផឹកទឹកស្រវឹង គឺសុរា និងមេរ័យនេះ ទ្រព្យទាំងឡាយដែលកើតឡើងហើយ រមែងវិនាសសាបសូន្យចាកទ្រព្យទាំងឡាយនោះ និងទ្រព្យទាំងឡាយដែលមិនទាន់កើតឡើង ក៏រមែងមិនកើតឡើងផង ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា វិនាសទ្រព្យដែលឃើញជាក់ស្តែងខ្លួនឯង ។

*នៅក្នុង* **សម្មោហវិនោទនី** *បានសម្តែងទោសនៃការផឹកទឹកស្រវឹង គឺសុរា និង មេរ័យថា:* **បសតមត្តស្ស ធាណេ អប្បសាវជ្ជំ** *ការផឹកនូវទឹកស្រវឹង ប្រមាណមួយ ទូកដៃ មានទោសតិច ។* **អញ្ជលិមត្តស្ស ធាណេ មហាសាវជ្ជំ** *ការផឹកនូវទឹកស្រវឹង ប្រមាណមួយក្បង់ដៃមានទោសច្រើនជាងនោះ ។*

**កាយចាលនសមត្ថំ បន ពហុំ បិវិត្វា គាមឃាតនិគមឃាតកម្មំ ករោន្តស្ស ឯកន្តមហាសាវជ្ជមេវ ។** *ចំណែកឯខាងការផឹកច្រើនរហូតដល់អាចញ៉ាំង កាយឲ្យកក្រើកព្រហើន គោងកាច ហ៊ានធ្វើឃាតកម្មដល់អ្នកស្រុក អ្នកនិគម ចាត់ជាទោស ធំក្រៃលែងបំផុត ។*

*ផលចំពោះសិក្ខាបទនេះ នៅក្នុង* **បរមត្ថទីបនី** *មាន២៤ នៅក្នុង បរមត្ថជោតិកា មាន ៣១ ដូច្នេះ មានខុសគ្នាយ៉ាងនេះ គឺ ៖*

**១- អតីតានាគតបច្ចុប្បន្នេសុ កិច្ចករណីយេសុ អប្បមាទតា (កិច្ចករណីយេសុ ខិប្បំបដិជាន នតា)** *ភាពជាអ្នកមិនប្រមាទក្នុងកិច្ចនិងករណីយកិច្ច ក្នុងអតីត អនាគត និងបច្ចុប្បន្ន (ជាមនុស្សទើងស្គាល់កិច្ចដែលធ្វើក្នុង អតីត អនាគត បច្ចុប្បន្នយ៉ាងឆាប់ក្លាមៗផង)*

**២- សទាឧបដ្ឋិតសតិតា** *ជាអ្នកមានសតិតម្កល់នៅខ្ជាប់ខ្ជួនសព្វកាល*

**៣- អនុម្មត្តកតា** *ជាមនុស្សល្អមិនមែនមនុស្សឆ្កួត*

**៤- ញាណវន្តតា** *មានញាណ ជាគ្រឿងដឹងច្រើនប្រការផង*

**៥- អនេឡតា (អនលសតា)** *ភាពជាមនុស្សមិនខ្ជិលច្រអូស*

៦– អជឡតា *ភាពជាមនុស្សមិនល្ងង់ខ្លៅ*

៧– អមូគតា *ភាពជាមនុស្សមិនគ*

៨– អមឧតា *ជាមនុស្សមិនស្រវឹងជ្រុបក្នុងអារម្មណ៍*

៩– អប្បមត្តតា *ជាមនុស្សមិនមានសេចក្ដីប្រមាទក្នុងកុសលធម៌ផង*

១០–អសម្មោហតា *ជាមនុស្សមិនវង្វេងផ្ដេសផ្ដាស*

១១–អជម្ភិតា *ជាមនុស្សមិនងាយនឹងតក់ស្លុតខ្លាច*

១២–អសារម្ភិតា (អសារម្ភតា) *ជាមនុស្សមិនមានសេចក្ដីរំខាន (ដល់ចិត្តផង)*

១៣–អនិស្សុកិតា *ជាមនុស្សមិនមានសេចក្ដីប្រណែនឫស្យា (អ្នកណាផង)*

១៤–អប្បោស្សុក្កតា *មានសេចក្ដីខ្វល់ខ្វាយតិច ក្នុងការឥតប្រយោជន៍*

១៥–សច្ចវាទិតា *ជាអ្នកមានប្រក្រតីពោលតែពាក្យពិត*

១៦–អបិសុណា អផរុស អសម្ផប្បលាបវាទិតា *ជាអ្នកមិននិយាយពាក្យស៊កសៀត មិននិយាយពាក្យគ្រោតគ្រាត រោយរាយឥតប្រយោជន៍*

១៧–កតញ្ញូតា *ភាពជាអ្នកដឹងនូវឧបការគុណអ្នកដទៃធ្វើហើយ*

១៨– កតវេទិតា *ជាមនុស្សដឹងគុណ ហើយធ្វើតបឧបការគុណដល់អ្នកមានគុណវិញផង*

១៩–អមច្ឆរិតា *ជាមនុស្សមិនកំណាញ់*

**២០–ភោគវន្តតា** *ភាពជាអ្នកមានភោគៈច្រើន*

**២១–ចាគវន្តតា** *ជាមនុស្សស្គាល់បរិច្ចាគឲ្យតាមកាល*

**២២–សីលវន្តតា** *ជាមនុស្សមានសីលល្អត្រឹមត្រូវ*

**២៣–ឧជុកតា** *ជាមនុស្សមានចិត្តពិតទៀងត្រង់*

**២៤–អក្កោធនតា** *ជាមនុស្សមិនងាយនឹងក្រោធដល់អ្នកណាផង*

**២៥–ហិរិមនតា** *ជាមនុស្សមានចិត្តខ្មាសបាប*

**២៦– ឱតប្បិតា** *ជាមនុស្សមានសេចក្តីតក់ស្លុតនឹងបាប (ក្នុងបរមត្ថទីបនី រួមគ្នាទាំងពីរគឺ* **ហិរោតប្បសម្បន្នតា** *ជាអ្នកដល់ព្រមដោយហិរិ និងឱត្តប្ប)*

**២៧–ឧជុទិដ្ឋិតា** *ជាមនុស្សឃើញត្រូវត្រង់*

**២៨– មហាបញ្ញតា** *ជាមនុស្សមានបញ្ញាធំទូលាយ (* **មហត្តតា** *ភាពជាអ្នកមានចិត្តធំ )*

**២៩–មេធាវិតា** *ជាមនុស្សបណ្ឌិតយល់ជ្រៅ*

**៣០–បណ្ឌិតា** *ជាបណ្ឌិត ឬជាអ្នកឆ្លាត*

**៣១– អត្ថានត្ថកុសលតា** *ភាពជាអ្នកឈ្លាសវៃក្នុងវត្ថុ ដែលជាប្រយោជន៍ និងវត្ថុមិនជាប្រយោជន៍ ។*

*សរុបទាំងអស់បាន ៣១ នេះ ខ្ញុំបាទបានដកសរុបទាំងពីរ គម្ពីរមកបញ្ចូលរួមគ្នា សូមអ្នកសិក្សាទាំងឡាយជ្រាបតាមនេះចុះ ។*

**សិក្ខាបទនេះមានអង្គ ៤ គឺ**

**១-មជ្ជនីយវត្ថុ** *វត្ថុជាទីតាំងនៃសេចក្ដីស្រវឹងគឺសុរា និងមេរ័យ*

**២-ចាសុកម្យតាចិត្តំ** *គិតបម្រុងនឹងផឹក*

**៣-តជ្ជោវាយាមោ** *ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ*

**៤-តស្សាចានំ** *បានផឹកនូវទឹកស្រវឹងនោះឲ្យកន្លងបំពង់កចូលទៅ*

*សុរាមេរយៈនេះ ជាសការៈ ជាអនាណត្តិក មានសមុដ្ឋានពីរគឺ* **កាយតោ** *ទោសកើតឡើងអំពីកាយ ១* **កាយចិត្តតោ** *ទោសកើតឡើងអំពីកាយ និងចិត្ត ១ៗ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម ជាធម្មៈ ជាកោដ្ឋសៈ មានសង្ខារជាអារម្មណ៍ មានវេទនាពីរ គឺសុខវេទនា ១ ឧបេក្ខាវេទនា ១ មានមូលពីរគឺ លោភ-មូល ១ មោហមូល ១ ជាអនិពន្ធសីល ជាសមាទាន មានវិរតិ ៣ ណាមួយ ជាវត្ថុកាម និងកិលេសកាម ។*

**អនាបត្តិ:** *ហេតុដែលមិនត្រូវទោសមាន ៧ យ៉ាងគឺ :*

**១-អមជ្ជញ្ច ហោតិ មជ្ជវណ្ណំ មជ្ជគន្ធំ មជ្ជរសំ តំ បិវតិ** *ផឹកទឹកមិនស្រវឹង តែទឹកនោះមានពណ៌ដូចជាទឹកស្រវឹង មានក្លិនដូចជាទឹកស្រវឹង មានរសជាតិដូចទឹកស្រវឹង ១ ៗ*

**២-សូបសំចាកេ** *ទឹកស្រវឹងដែលគេចម្អិនលាយនឹងសម្ល*

**៣-មំសសំចាកេ** *ទឹកស្រវឹងដែលគេចម្អិនលាយនឹងសាច់*

**៤–តេលសំធាកេ** ទឹកស្រវឹង ដែលគេចម្អិនលាយនឹងប្រេង

**៥–អាមលកផាណិតេ** ទឹកអំពៅដែលគេត្រាំនឹងផ្លែកន្ទួតព្រៃ

**៦–អមជ្ជំ អរិដ្ឋ បិវតិ** ផឹកថ្នាំអរិដ្ឋមិនស្រវឹង

**៧–ឧម្មត្តកស្ស** ឆ្កួត ។

នៅក្នុងអដ្ឋកថា **សមន្តប្បាសាទិកា** អដ្ឋកថាព្រះវិន័យ បានពន្យល់អំពីអនាបត្តិនេះថា បទថា **សូបសំធាកេ** មានសេចក្តីថា មនុស្សទាំងឡាយដាក់ទឹកស្រវឹងចុះបន្តិចបន្តួចដើម្បីអប់ក្លិនហើយ ចម្អិនសម្លមិនជាទោស ព្រោះសម្លដាក់ទឹកស្រវឹងតិចតួចនោះ ។ សូម្បីចម្អិនសាច់ក៏មានន័យដូចគ្នា ។ មនុស្សទាំងឡាយ រមែងចម្រាញ់ប្រេងជាមួយទឹកស្រវឹង ដើម្បីជាថ្នាំរំងាប់ខ្យល់ មិនជាទោសក្នុងប្រេងនោះ ដែលមិនបានលាយទឹកស្រវឹងលើសទៅប៉ុណ្ណោះ ។

ក្នុងប្រេងដែលលាយទឹកស្រវឹងហួសកំណត់ទៅរហូតមានក្លិន និងរសនៃទឹកស្រវឹងប្រាកដជាទោសតែម្តង ។

ថ្នាំត្រាំឈ្មោះអរិដ្ឋ ដែលមិនមែនទឹកស្រវឹង មិនជាទោស ។ បានឮថា មនុស្សទាំងឡាយធ្វើថ្នាំត្រាំ ឈ្មោះអរិដ្ឋ ដោយរសនៃកន្ទួតព្រៃជាដើមនោះឯង ។ ថ្នាំត្រាំនោះមានពណ៌ក្លិននិងរសប្រហែលទឹកស្រវឹង តែមិនស្រវឹង ។ ព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ត្រាស់សំដៅយកថ្នាំត្រាំឈ្មោះ អរិដ្ឋនោះ ទើបត្រាស់យ៉ាងនោះ ។ តែថ្នាំដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ ចាត់ជាទឹកស្រវឹង មិនគួរចាប់ផ្តើតាំងតែអំពីពូជ ។

**សុរាមេរយសិក្ខាបទទី៥ ចប់**

## វិកាលភោជនសិក្ខាបទទី៦

**វិកាលភោជនៈ** *កិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស ពេលខុសវេលាហួសកំណត់ ។*

*នៅក្នុងវិន័យបិដក* **មហាវិភង្គភាគ** *៤ ទំព័រ ១៣២ ព្រះឧបាលិថេរៈ ពោលថា៖* **វិកាលោ នាម មជ្ឈន្តិកេ វីតិវត្តេ យាវ អរុណុគ្គមនា ។** *វេលាដែលព្រះអាទិត្យជ្រេពីត្រង់ទៅទល់នឹងអរុណរះឡើង ឈ្មោះថា ពេលវិកាល ។*

**ខាទនីយំ នាម បញ្ច ភោជនានិ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ ឋបេត្វា អវសេសំ ខាទនីយំ នាម ។** *ដែលហៅថា* **ខាទនីយៈ** *(នោះ) បានដល់របស់ទាំងអស់ វៀរលែងភោជន ៥ យ៉ាង និងវត្ថុជាយាមកាលិក សត្តាហកាលិក យាវជីវិកចេញ ហៅថា* **ខាទនីយៈ។**

**ភោជនីយំ នាម បញ្ច ភោជនានិ ឱទនោ កុម្មាសោ សត្តុ មច្ឆោ មំសំ ។** *ដែលហៅថា ភោជនីយៈ បានដល់ភោជន ៥ យ៉ាង គឺបាយ ១ នំស្រស់ ១ នំក្រៀម ១ ត្រី ១ សាច់១ ។ អ្នកសមាទាននូវសិក្ខាបទវិកាលនេះ មិនអាចបរិភោគនូវខាទនីយៈ និងភោជនីយៈដែលជា* **យាវកាលិក** *មានកាលកន្លងថ្ងៃត្រង់ជ្រេទៅបានទេ កាលថ្ងៃជ្រេទៅហើយបរិភោគ រមែងដាច់ខូចសិក្ខាបទហ្នឹង ។*

**អជ្ឈោហរណា** *ដែលលេបចូលទៅតាមបំពង់កចូលទៅ មានភោជនាហារជាដើមសំដៅយកវត្ថុជាយាវកាលិក ដែលត្រូវបរិភោគពីព្រឹកដល់ថ្ងៃត្រង់ ជរាបទាល់នឹងអរុណរះ ហៅថាវិកាលក្នុងសិក្ខាបទនេះ អ្នកសមាទាននូវសិក្ខាបទនេះ គប្បីវៀរចាកនូវវិកាលភោជន*

*បើបរិភោគវិកាលភោជន ដាច់ខូចសិក្ខាបទនេះ ជាកំណត់ ។ គប្បីដឹងថា : វិកាលភោជន ទោះដេកលក់ឥតដឹងខ្លួនប្រាណអីទេ បើអ្នកដទៃណាយកភោជនាហារបញ្ចុកក្នុងមាត់ ក្នុងវេលាវិកាលឲ្យលេបចូលទៅតាមបំពង់កចូលទៅ ឈ្មោះថា ដាច់ខូចវិកាលភោជនហ្នឹងដែរ ។ ព្រោះហេតុអ្វី ? ព្រោះថា សិក្ខាបទនេះជាអចិត្តកៈ ទោះក្លែងក្តី មិនក្លែងក្តី នឹងមានស្មារតីក្តី មិនមានស្មារតីក្តី មិនជាប្រមាណក្នុងសិក្ខាបទនេះទេ ឲ្យតែលេបរបស់ដែលជាយាវកាលិកចូលផុតបំពង់កទៅ ជាប្រមាណហើយ ឈ្មោះថា ដាច់ខូចសិក្ខាបទហ្នឹងទាំងអស់ ។*

*នៅក្នុងគម្ពីរ* **សីលក្ខន្ធវគ្គដីកា** *ឈ្មោះលីនត្ថប្បកាសិនី ព្រហ្មជាលសូត្រ ចូឡហត្ថិបទោបមសូត្រ នឹងនៅក្នុឧបោសថសូត្រ បានពន្យល់ថា ៖*

អរុណុគ្គមនតោ បដ្ឋាយ យាវ មជ្ឈន្តិកា អយំ ពុទ្ធាទីនំ អរិយានំ អាចិណ្ណសមាចិណ្ណោ ភោជនស្ស កាលោ, តទញ្ញោ វិកាលោ ។ *ចាប់ផ្តើមតាំងតែអំពីអរុណរះឡើងរហូតដល់ថ្ងៃត្រង់ នេះចាត់ជាកាលនៃភោជនរបស់ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាម្ចាស់ជាដើម ដែលសន្សំអប់រំមកហើយ កាលដទៃក្រៅអំពីនោះរមែងចាត់ជាវិកាល ។*

*នៅក្នុងព្រះអដ្ឋកថា ឈ្មោះសមន្តប្បសាទិកា(ខ្មែរ)ភាគ ៤ ទំព័រ២០៤ លោកពោលថា ៖*

កាលោតិ ភិក្ខូនំ ភោជនកាលោ អធិប្បេតោ ។ សោ ច សព្ពន្តិមេន បរិច្ឆេទេន មជ្ឈន្តិកោ តស្មិំ វីតិវត្តេតិ អធិប្បាយោ ។ តេនេវស្ស បទភាជនេ វិកាលោ នាម មជ្ឈន្តិកេ វីតិវត្តេ យាវ អរុណុគ្គមនាតិ វុត្តំ ។ ឋិតមជ្ឈន្តិកោបិ កាលសង្គហំ គច្ឆតិ តតោ បដ្ឋាយ ខាទិតុំ វា ភុញ្ជិតុំ វា ន សក្កា សហសា បិវិតុំ សក្កា ភវេយ្យ កុក្កុច្ចកេន បន ន កាតព្ពំ ។

ប្រែថា កាលនៃភោជនរបស់ភិក្ខុទាំងឡាយ លោកប្រាថ្នាយកថា **កាល** ។ ក៏កាលនៃភោជននោះ ដោយកំណត់យ៉ាងទាបបំផុតត្រឹមថ្ងៃត្រង់ អធិប្បាយថា កាលថ្ងៃត្រង់នោះកន្លងហួសទៅហើយ ។ ព្រោះហេតុនោះឯង ក្នុងបទភាជនៈនៃបទនោះ ព្រះឧបាលីថេរៈទើបពោលថា វេលាដែលព្រះអាទិត្យជ្រេពីត្រង់ទៅទាល់នឹងអរុណរះឡើង ឈ្មោះថា ពេលវិកាល។ សូម្បីក្នុងវេលាថ្ងៃត្រង់ក៏ដល់ការសង្គ្រោះចូលថាជា **កាល** ។ ចាប់ផ្តើមតាំងតែអំពីកាលថ្ងៃត្រង់ទៅ ភិក្ខុសាមណេរ ឬគ្រហស្ថ មិនអាចដើម្បីទំពា ឬធាន់បានទេ (តែ) នៅអាចប្រញាប់នឹងផឹកបាន ចំណែកភិក្ខុអ្នកមានក្តីរង្កៀសមិនគប្បីធ្វើ ។

នៅក្នុង**សារត្ថទីបនីដីកា** មហាខន្ធកៈពោលថា:

**ភុញ្ជិតព្វន្តេន ភោជនំ យាគុភត្តាទិ សព្វំ យាវកាលិកវត្ថុ ។ យថា ច រត្តូបរតោតិ ឯតំ រត្តី ភោជនំ រត្តីតិ ឧត្តរបទលោបេន វុច្ចតិ ឯវមេត្ថ ភោជនជ្ឈោហារណំ ភោជនន្តិ ។ វិកាលេ ភោជនំ វិកាលភោជនំ ។**

វត្ថុដែលឈ្មោះថា **ភោជន** ព្រោះអត្ថថា ដែលបុគ្គលគប្បីបរិភោគ គឺវត្ថុជាយាវកាលិកគ្រប់ប្រភេទ មានបបរ និងបាយជាដើម ។ ដូចយ៉ាងថា កាលបរិភោគក្នុងកណ្តាលយប់ក្នុងពាក្យថា "**រត្តូបរតោ**" នេះលោកពោលថា **រត្តី** ព្រោះលុបបទខាងក្រោយយ៉ាងណា ការទំពាលេបភោជនក្នុងពាក្យថា " **វិកាលភោជនា**" នេះលោកក៏ពោលថា ភោជនំ ព្រោះលុបបទខាងក្រោយយ៉ាងនោះ ។ ការទំពាលេបភោជនក្នុងវិកាល ឈ្មោះថា **វិកាលភោជនៈ**។

នៅក្នុង**មនោរថបូរណី** អដ្ឋកថា អង្គុត្តរនិកាយ តិកនិបាត ត្រង់ឧបោសថសូត្រ បានសម្តែងថា៖ បទថា **ឯកភត្តិកា** សេចក្តីថា អាហារមាន ២ ពេល គឺអាហារដែលនឹងត្រូវ

ទទួលទានក្នុងវេលាព្រឹក ១ អាហារដែលនឹងត្រូវទទួលទានក្នុងវេលាល្ងាច ១ បណ្ដាអាហារទាំង ២ យ៉ាងនោះ អាហារដែលនឹងទទួលទានក្នុងវេលាព្រឹក កំណត់ដោយវេលាខាងក្នុងថ្ងៃត្រង់ ចំណែកអាហារទទួលទានក្នុងវេលាល្ងាច កំណត់ដោយវេលាហួសអំពីថ្ងៃត្រង់ទៅ រហូតដល់អរុណរះឡើង ។ ព្រោះដូច្នោះ ក្នុងវេលាខាងក្នុងថ្ងៃត្រង់នឹងទទួលទានអាហារ ១០ ក៏ឈ្មោះថា ទទួលទានអាហារមួយវេលា ។ ព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ត្រាស់ថា **ឯកភត្តិកា** ព្រះអង្គសំដៅដល់ការទទួលទានអាហារក្នុងថ្ងៃត្រង់ ។ ការទទួលទានអាហារក្នុងវេលាយប់ ឈ្មោះថា **រត្តិ** បុគ្គលអ្នកវៀរចាកការទទួលទានអាហារក្នុងវេលាកណ្ដាលយប់នោះ ព្រោះហេតុនោះ ទើប ឈ្មោះថា **រត្តូបរតា** ការទទួលទានអាហារក្នុងវេលាហួសថ្ងៃត្រង់ទៅ រហូតដល់ព្រះអាទិត្យលេត់ ឈ្មោះថា ការទទួលទានអាហារក្នុងវេលាវិកាល បុគ្គលដែលឈ្មោះថា វៀរចាកវិកាលភោជន ព្រោះវៀរចាកការទទួលទានអាហារក្នុងវេលាវិកាលនោះ ។ **ឯកាលិក** : វត្ថុដែលបរិភោគក្នុងកាលនេះ ចែកដោយកាលមាន ៤ យ៉ាងគឺ ៖

**១-យាវកាលិក** របស់ដែលត្រូវបរិភោគកំណត់កាលចាប់ពីអរុណរះឡើងទៅដល់ថ្ងៃត្រង់ (គឺអស់កំណត់កាលត្រឹមប៉ុណ្ណឹង) បាននឹងវត្ថុទាំងពីរនេះ គឺខាទនីយ ភោជនីយាហារ មានបាយ ផ្លែឈើ នំ បង្អែម ចម្អាប ត្រី សាច់ និងអន្លក់ជាដើម ហៅថា **យាវកាលិក។**

**២-យាមកាលិក** ទឹកដែលគួរបរិភោគ ផឹកបានតែត្រឹមមួយថ្ងៃ មួយយប់ ហៅថា **យាមកាលិក** បានដល់ទឹកបាន ៨ ប្រការ គឺ :

**១-អម្ពបានំ** ទឹកផ្លែស្វាយ

**២-ជម្ពុបានំ** ទឹកផ្លែព្រីង

**៣-ចោចបានំ** ទឹកផ្លែចេកមានគ្រាប់

**៤-មោចបានំ** ទឹកផ្លែចេកឥតគ្រាប់

**៥-មធុបានំ** ទឹកផ្លែស្រគំ

**៦-មុទ្ទិកបានំ** ទឹកផ្លែចន្ទន៍

**៧-សាលុកបានំ** ទឹកក្រអៅឈូក

**៨-ផារុកបានំ** ផ្លែមាក់ប្រាង

ទឹកផ្លែឈើទាំង ៨ ប្រការនេះ ហៅថា **យាមកាលិក។**

ក្នុងសាមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យ មហាវគ្គវណ្ណនាថា ព្រះធម្មសង្គាហកត្ថេរទាំងឡាយ កាលកាន់យកព្រះសូត្រផ្ទៀងផ្ទាត់មើលក្នុងមហាបទេសនោះ បានឃើញសេចក្តីនេះថា ទឹកគ្រាប់ធញ្ញជាតិ មិនគួរក្នុងបច្ឆាភត្ត ព្រោះមានព្រះបាលីថា **ឋបេត្វា ធញ្ញផលរសំ** លើកលែងតែរសនៃគ្រាប់ធញ្ញជាតិ ៧ យ៉ាង ។ **ធញ្ញជាតិ** ៧ យ៉ាងគឺ :

**១-សាលី** ស្រូវសាលី

**២-វីហី** ស្រូវខ្សាយ

**៣-យវោ** ស្រូវដំណើម

**៤-គោធុមោ** ស្រូវផែ

៥–កន្ទុ ថ្លៅ

៦–វរកោ ពោត ស្គួយ ឬស្មៅកន្ទុយដំរី

៧–កុទ្រូសកោ ស្មៅគែលលក ។

មហាផល ៩ យ៉ាង អបរណ្ណជាតិ គ្រប់ប្រភេទ ក៏មិនគួរយកមកធ្វើជាទឹកបាន ឡើយ ។

ឯមហាផល ៩ យ៉ាងនោះគឺ :

១– តាលផលំ ផ្លែត្នោត

២– នាឡិកេរផលំ ផ្លែដូង

៥–បនសផលំ ផ្លែខ្នុរ

៦– លពុជផលំ ផ្លែខ្នុរសម្ល

៧–អាលាពុផលំ ផ្លែឃ្លោក

៨–ឃលាលុកផលំ ផ្លែត្រឡាច

៧–បុស្សផលំ ផ្លែត្រសក់

៨–តិបុសផលំ ផ្លែឪឡឹក

៩–កុម្ភណ្ឌផលំ ផ្លែល្ពៅ

អបរណ្ណជាតិ មានសណ្ដែកល្ងជាដើម ។

មហាផល និងអបរណ្ណជាតិគ្រប់ប្រភេទនោះ មានគតិដូចធញ្ញជាតិដែរ សូម្បីព្រះអង្គមិនបានទ្រង់ហាមទុក ក៏ពិតមែន តែថារមែងអនុលោមចូលក្នុងអកប្បិយវត្ថុ, ព្រោះហេតុនោះ ទើបមិនគួរក្នុងបច្ឆាភត្ត ។ ទឹកបាន ៨ យ៉ាង ទ្រង់អនុញ្ញាតទុក ទឹកផ្លែឈើតូចមានផ្លៅ អបិល ក្រូច ខ្វិត ពទ្រ និងផ្លែសង្ឃ័រជាដើម មានគតិដូចអដ្ឋបានពិត ទឹកបាននៃផ្លែឈើទាំងនេះ ទ្រង់មិនបានអនុញ្ញាតទុកក៏ពិតមែនហើយ តែថារមែងអនុលោម ចូលក្នុងកប្បិយៈ ព្រោះដូច្នោះ ទើបសមគួរ ។

ក្នុងកុរុន្ទីពោលថា ពិតមែន វៀរសនៃគ្រាប់ស្រូវព្រមទាំងវត្ថុដែលអនុលោមចេញហើយ ដែលឈ្មោះថា ទឹកផ្លែឈើដទៃដែលមិនគួរមិនមាន ទឹកផ្លែឈើគ្រប់ប្រភេទជាយាមកាលិកពិត ។

(ពន្យល់ថែមទៀតថា សម្បីរសនៃបន្លែ ដែលជាយាវកាលិក ដែលប្រចាប់ក្នុងទឹកត្រជាក់ធ្វើក្តី ឆ្អិនដោយកំដៅព្រះអាទិត្យរមែងគួរ) ។

បណ្តាទឹកបានទាំងនោះ អម្ពបាននោះ បានដល់ទឹកបានដែលធ្វើដោយផ្លែស្វាយខ្ចីឬទុំ។ បណ្តា ស្វាយខ្ចី និងទុំ ២ យ៉ាងនេះ កាលនឹងធ្វើដោយស្វាយខ្ចី គប្បីបុកស្វាយខ្ចីដាក់ក្នុងទឹកហាលឲ្យឆ្អិន ដោយកំដៅព្រះអាទិត្យ ហើយត្រងផ្សំដោយទឹកឃ្មុំ ស្ករ និងការបូជាដើមក្នុងទឹកបានគ្រប់ប្រភេទ ក៏ន័យនេះ ។ អដ្ឋបានទាំងនេះ ត្រជាក់ក្តី ឆ្អិនដោយកំដៅព្រះអាទិត្យក្តី រមែងគួរ ។ ឆ្អិនដោយភ្លើងមិនគួរ ។

(ពាក្យថា ឆ្អិនដោយភ្លើងមិនគួរនោះ សេចក្តីថា ចាំបាច់ពោលទៅថ្វីដល់ការដាំឬស្ងោរនោះ សូម្បីយកទឹកទាំងក្តៅ ដែលដាំដោយភ្លើង មកចាក់ដាក់លាយវត្ថុដែលបុកឬប្រចាប់សម្រាប់ធ្វើនោះ ទឹកបាននោះរមែងមិនគួរ) ។

**៣–សត្តាហកាលិក** របស់ដែលភិក្ខុទុកប្រើប្រាស់ធាន់បានត្រឹម ៧ ថ្ងៃ ហៅថា **សត្តាហកាលិក** បានដល់ ៥ ប្រការ គឺ៖

១–**សប្បិ** ទឹកដោះថ្លា

២–**នវនីត** ទឹកដោះខាប់

៣–**តេល:** ប្រេង

៤–**មធុ** ទឹកឃ្មុំ

៥–**ផាណិត** ស្ករអំពៅ

ទាំង ៥ ប្រការនេះជា **សត្តាហកាលិក**។

វិន័យបិដកភាគ ៧ ទំព័រ ៣៥៩ ព្រះមានព្រះភាគទ្រង់ត្រាស់អនុញ្ញាតថា **អនុជានាមិ ភិក្ខវេ បញ្ច គោរសេ ខីរំ ទធិ តក្កំ នវនីតំ សប្បិ** ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបញ្ចគោរស ៥ យ៉ាងគឺ : ទឹកដោះស្រស់១ ទឹកដោះជូរ១ ប្រេង១ ទឹកដោះខាប់១ ទឹកដោះថ្លា១ ។

បណ្ដាទឹកដោះទាំងនោះ **ខីរំ** ទឹកដោះស្រស់១ **ទធិ** ទឹកដោះជូរ១ **តក្កំ** ប្រេង១ បីប្រភេទនេះ គួរក្នុងកាល ។ **នវនីតំ** ទឹកដោះខាប់ **សប្បិ** ទឹកដោះថ្លា១ ពីប្រភេទនេះ គួរគ្រប់កាលទាំងអស់ ។

ពាក្យថា **តេល:** ប្រេង បានដល់ប្រេងល្ង ប្រេងស្ពៃ ប្រេងស្រគំ ប្រេងល្ហុងខ្វង ខ្លាញ់ភរ (របស់សត្វគ្រប់ប្រភេទដែលចម្រាញ់ហើយ ត្រងស្អាតហើយ) ហៅថា ប្រេង ។

*ព្រះមានព្រះភាគទ្រង់អនុញ្ញាតខ្លាញ់នៃសត្វ ដែលមានមំសៈជាអកប្បិយៈទាំងអស់ វៀរតែខ្លាញ់មនុស្សចេញ ។*

**មធុ** *ទឹកឃ្មុំ បានដល់ទឹកឃ្មុំដែលពួកមេឃ្មុំធំ ឃ្មុំតូច និងពួកពង្រូតធ្វើ ។*

**ផាណិតំ** *ស្ករអំពៅ ទឹកអំពៅដែលមិនមានកាក (ត្រងឲ្យស្អាតហើយ) និងស្ករអំពៅ គួរក្នុងវិកាល (គួរគ្រប់កាល) ។ អំពៅដែលគួរដល់ការទំពាក្តី ទឹកអំពៅដែលមានកាកក្តី គួរបាន តែក្នុងកាល ។*

**៤– យាវជីវិក** *របស់ជាភេសជ្ជៈដែលភិក្ខុទុកប្រើប្រាស់ បរិភោគឆាន់ទាល់តែអស់ កំណត់ ហៅថា* **យាវជីវិក** *។* **យាវជីវិក** *នោះបានដល់ថ្នាំជា ភេសជ្ជៈ ដែលព្រះអង្គ ទ្រង់អនុញ្ញាត នៅក្នុងភេសជ្ជខន្ធកៈ វិន័យបិដក* **មហាវគ្គ** *ភាគ ៧ ពីទំព័រ ២២៦ ដូច្នេះគឺ* **ហលិទ្ទំ** *មើមរមៀត* **សិង្គិវេរំ** *មើមខ្ញី* **វចំ** *មើមលំពាន់* **វចត្តំ** *មើមប្រស់* **អតិវិសំ** *មើមអាចម៍ត្តិស* **កដុករោហិណី** *មើមរំដេង* **ឧសីរំ** *មើមស្បូវក្លាំង* **ភទ្ទមុត្តកំ** *មើមស្មៅក្រវាញជ្រូក និងពួកទឹកចត់គឺ* **និម្ពកសាវំ** *ទឹកចត់កើតអំពីវល្លិបណ្តូលពេជ្រ* **ឧត្តមាលកសាវំ** *ទឹកចត់កើតអំពីដើមទន្លា ឬថ្ងាន់ ។ ហើយនិងស្លឹកឈើ ជាភេសជ្ជៈគឺ* **និម្ពបណ្ណំ** *ស្លឹកស្តៅ* **កុដជបណ្ណំ** *ស្លឹកខ្ទឹងគង់* **បដោលបណ្ណំ** *ស្លឹកអំបែងថ្ងៃ* **សុលសិបណ្ណំ** *ស្លឹកម្រះព្រៅ* **កប្បាសិបណ្ណំ** *ស្លឹកកប្បាស ។ ហើយនឹងផ្លែ ជាភេសជ្ជៈគឺ* **វិលង្គំ** *ផ្លែពិលង្គ* **បិប្ផលិ** *ផ្លែដីប្លី* **មរិចំ** *ផ្លែម្រេច* **ហរីតកំ** *ផ្លែសម៉* **វិភីតកំ**

ផ្លែសម៉ពិភេទក៍ **អាមលកំ** ផ្លែកន្ទួតព្រៃ **អាមលកំ** ផ្លែកន្ទួតព្រៃពិភេទក៍ **គោឋផលំ** ផ្លែក្រវាញ ។ ជ័រឈើ ជាភេសជ្ជៈគឺ **ហិង្គុំ** ជ័រដែលហូរចេញអំពីដើមហិង្គុ **ហិង្គុជតុំ** ជ័រដែលគេយកស្លឹកហិង្គុតែម្យ៉ាងមករម្ងាស់ (ជ័រទាំងបីយ៉ាងនេះ ជាជាតិហិង្គុទាំងអស់) **តកំ** ជ័រដែលហូរចេញអំពីត្រួយឈើ **តកបត្តិំ** ជ័រដែលហូរចេញអំពីស្លឹកឈើ **តកបណ្ណិំ** ជ័រដែលគេបេះស្លឹកឈើយកមកធ្វើ **សជ្ជុលសំ** កំញាន ។ ហើយអំបិលភេសជ្ជៈគឺ **សាមុទ្ទំ** អំបិលកើតក្បែរឆ្នេរសមុទ្រ មានបែបដូចដីខ្សាច់ **កាឡលោណំ** អំបិលមានពណ៌ខ្មៅ (អំបិលប្រក្រតី) **សិន្ធវំ** អំបិលមានពណ៌សកើតលើភ្នំ **ឧព្ភិទំ** អំបិលមានពន្លកដុះអំពីផែនដី (អំបិលដែលកើតអំពីអាចម៍ដី មានរសប្រៃ) **ពិលំ** អំបិលមានពណ៌ក្រហម ដែលគេចម្អិនជាមួយ នឹងគ្រឿងសម្ភារៈទាំងពួង ។

ម្យ៉ាងទៀត ទឹកចត់ដទៃណាជាភេសជ្ជៈ មិនផ្សាយទៅ ដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈក្នុងភោជនីយៈ ការសង្គ្រោះត្រួយ ដើម និងសំបកទាំងនោះចូល ក្នុងពុទ្ធានុញ្ញាតនេះ រមែងសម្រេច (រមែងប្រើបាន) និងទឹកចត់ដែលពោលហើយបណ្ឌិតគប្បី ជ្រាបថា ជារបស់សមគួរ ដោយប្រការគ្រប់យ៉ាង ។

ម្យ៉ាងទៀត ស្លឹកដទៃណាជាភេសជ្ជៈ មិនផ្សាយទៅ ដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈ ក្នុងភោជនីយៈ ដូច្នេះស្លឹកទាំងនោះ ជាយាវជីវិក ។

ម្យ៉ាងទៀត ផ្លែ និងផ្កាដទៃណាជាភេសជ្ជៈ មិនផ្សាយទៅ ដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈ ក្នុងភោជនីយៈ ដូច្នេះផ្លែនិងផ្កាទាំងនោះ ជាយាវជីវិកដូចគ្នា ។

ម្យ៉ាងទៀត ជ័រឈើដទៃណាជាភេសជ្ជៈ មិនផ្សាយទៅ ដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈ ក្នុងភោជនីយៈ ដូច្នេះជ័រទាំងនោះ ចាត់ជាយាវជីវិកដូចគ្នា ។

វត្ថុជាយាវជីវិកទាំងអស់នេះ ព្រះអង្គទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា **បច្ចយេ បរិភុញ្ជិតុំ អសតិ បច្ចយេ បរិភុញ្ជន្តស្ស អាបត្តិ ទុក្កដស្ស** ។កាលបើមានហេតុ ទើបភិក្ខុឆាន់បាន កាលបើគ្មានហេតុទេ ហើយភិក្ខុឆាន់ត្រូវអាបត្តិទុក្កដ ។

ចំពោះកាលិកទាំង ៤ យ៉ាងនេះ ខ្ញុំបាទមិនបានរៀបរាប់ឲ្យបានពិស្តារក្នុងសៀវភៅនេះទេ បើចង់ជាក់ច្បាស់សូមស្រាវជ្រាវមើលនៅក្នុង អដ្ឋកថា **វិកាល ភោជនសិក្ខាបទ** ឈ្មោះសមន្តប្បាសាទិកាទៀតចុះ ។

**សិក្ខាបទនេះមានអង្គ ៣ គឺ**

**១–វិកាលោ** កាលខុស គឺព្រះអាទិត្យជ្រេទៅហើយដរាបទៅទល់គ្នានឹងអរុណរះ

**២– យាវកាលិកំ** របស់ដែលគួរបរិភោគបានក្នុងកាល គឺចាប់តាំងពីអរុណរះឡើង ដរាបដល់ថ្ងៃត្រង់

**៣– អជ្ឈោហរណំ** បានលេបចូលទៅក្នុងបំពង់ក ។

វិកាលភោជនៈនេះ ជាសភាវៈ ជាអនាណត្តិក មានសមុដ្ឋានពីរ គឺ :

**១–កាយតោ** ទោសកើតឡើងអំពីកាយ

**២–កាយចិត្តតោ** ទោសកើតឡើងអំពីកាយ និងចិត្ត

ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម មានចិត្ត ៣ គឺកុសលចិត្ត ១ អកុសលចិត្ត ១ អព្យាកតចិត្ត ១ ។ មានវេទនា ៣ គឺ សុខវេទនា ទុក្ខវេទនា ឧបេក្ខាវេទនា ជាធម្មៈ ជាកោដ្ឋាស មានសង្ខារជាអារម្មណ៍ មានមូលពីរ គឺលោភមូល ១ មោហមូល ១ ជាអនិពន្ធសីល ជាសមាទាន មានសមាទានវិរតិ ១ ជាវត្ថុកាម និងកិលេសកាម ។

**អនាបត្តិ:** ហេតុដែលមិនត្រូវទោសមាន ២ យ៉ាងគឺ:

**១-យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ សតិ បច្ចយេ បរិភុញ្ជាតិ** *បរិភោគតែរបស់ដែលជាយាមកាលិក សត្តាហកាលិក និងយាវជីវិកដែលមានហេតុគួរបរិភោគបាន*

**២-ឧម្មត្តកស្ស** *ក្ខូត ។*

**វិកាលភោជនសិក្ខាបទទី ៦ ចប់**

## នច្ចគីតវាទិតវិសូកទស្សនសិក្ខាបទទី ៧

**នច្ចគីតវាទិតវិសូកទស្សនៈ** *កិរិយាច្រៀង និងប្រគំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ ។*

*នៅក្នុងអដ្ឋកថា* ***សមន្តប្បាសាទិកា*** *ត្រង់ខុទ្ទកវត្ថុក្ខន្ធកៈ បានសម្តែងថា ៖*

**យង្កិញ្ចិ នច្ចំ អន្តមសោ មោរនច្ចំបិ ទស្សនាយ គច្ឆន្តស្ស** ។*ជាទោសដល់អ្នកទៅដើម្បីមើលនូវការរាំយ៉ាងណាមួយ ដោយហោចទៅសូម្បីការរាំរបស់សត្វក្ងោក។*

**សយំបិ នច្ចន្តស្ស វា នច្ចាបេន្តស្ស វា** *រាំដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យរាំក្តី ដាច់ខុចសិក្ខាបទហ្នឹងដូចគ្នា ។*

**គីតំបិ យង្កិញ្ចិ នដគីតំ វា សាធុគីតំវា អន្តមសោ ទន្តគីតំបិ ។** *សូម្បីការច្រៀងយ៉ាងណាមួយ ការច្រៀងរបស់អ្នករបាំក៏ដោយ ការច្រៀងចម្រៀងដ៏ល្អក៏ដោយ ដោយហោចទៅសូម្បីការច្រៀងដោយធ្មេញ ក៏មិនគួរ ។*

*នៅក្នុង****សារត្ថទីបនីដីកា*** *បានពន្យល់ ពាក្យថា* **សាធុគីតំ** *(ការច្រៀងដ៏ល្អ) បទថា* **សាធុគីតន្តិ អនិច្ចតាទិបដិសំយុត្តគីតំ** *<u>ប្រែថា</u> ចម្រៀងជាសាធុ មានសេចក្តីថាច្រៀងប្រកបព្រមហើយដោយលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ហ្នឹងហើយ ឈ្មោះថា* **សាធុគីតំ**។

*គប្បីដឹងថា៖ តាមសេចក្តីមានមកនៅក្នុងដីកា ឧបាសក ឧបាសិកា មិនអាចសូធ្យធម៌ស្មូតនៅក្នុងថ្ងៃឧបោសថសីលបានទេ ដូចសូធ្យបទលោក់លែក មានការអាពធនាព្រហ្មដើម្បីឲ្យព្រះសង្ឃសម្តែងធម៌ទេសនា ឬសូធ្យធម៌បទ មានរូបំ អនិច្ចំ ជាដើមបានទេ បើសូធ្យ*

ថ្ងៃឧបោសថ រមែងដាច់ខូចសិក្ខាបទហ្នឹងឯង មិនមែនតែខ្លួនសូធ្យប៉ុណ្ណោះទេ ស្តាប់ពីសំណាក់អ្នកដទៃសូធ្យ ក៏ដាច់ខូចសិក្ខាបទហ្នឹងដូចគ្នា ។

ដើម្បីឲ្យសេចក្តីនេះជាក់ច្បាស់ ខ្ញុំបាទនឹងលើកយកសេចក្តីនេះ ដែលមានមកនៅក្នុង **បរមត្ថជោតិកា** អដ្ឋកថា ខុទ្ទកបាឋៈ បានសម្តែងថា ៖

**ធម្មូបសញ្ហិតំ វាបិ គីតោ ចេត្ថ គីតំ ន វដ្ដតិ, គីតូបសញ្ហិតោ បន ធម្មោ ន វដ្ដតិ ។** ក៏ក្នុងសិក្ខាបទនេះ ការច្រៀងសូម្បីប្រកបដោយធម៌ ក៏មិនគួរ, តែធម៌ដែលប្រកបដោយចម្រៀងសមគួរ ។

សីលក្ខន្ធវគ្គអភិនវដីកា ឈ្មោះសាធុវិលាសិនី ចូឡសីលវណ្ណនាភាគ១ ទំព័រ៤២៣ ត្រង់ព្រហ្មជាលសូត្រ បានសម្តែងថា **អរិសូភូតស្ស បន គីតស្ស សវនំ កទាចិ វដ្ដតីតិ ទស្សេតិ ។ តថាហិ វុត្តំ** បរមត្ថជោតិកា ខុទ្ទកបាឋៈ អដ្ឋកថា "ធម្មូ-បសំហិតម្បិ" **ចេត្ថ គីតំ ន វដ្ដតិ គីតូបសំហិតោ បន ធម្មោ វដ្ដតីតិ ។ កត្ថចិ បន នការវិបរិយាយេន បាឋោ ទិស្សតិ ។ ឧភយត្ថាបិ ច គីតោ ចេ ធម្មានុលោមត្ថូបសំយុតោបិ ន វដ្ដតិធម្មោ ចេ គីតសន្ធុបសំយុត្តោបិ វដ្ដតីតិ អធិប្បាយោ វេទិតព្វោ ។**

ប្រែថា ចំណែកចម្រៀងដែលមិនជាសត្រូវ (ដល់កុសលធម៌) គួរស្តាប់បានក្នុងគ្រាខ្លះៗ មែនពិតយ៉ាងនោះ ព្រះអដ្ឋកថា ពោលទុកក្នុង អដ្ឋកថា ខុទ្ទកបាឋៈ ឈ្មោះ**បរមត្ថជោតិកា** លោកពោលថា ក៏ក្នុងសិក្ខាបទនេះ ការច្រៀង សូម្បីប្រកបដោយធម៌មិនគួរ, តែធម៌ដែលប្រកបដោយចម្រៀងសមគួរ, ។ ចំណែក បាឋៈ ដែលវិប្បល្លាសដោយន-អក្សរណាមួយ រមែងប្រាកដ គប្បីជ្រាបអធិប្បាយសេចក្តីថា ក៏ចម្រៀងសូម្បីទាំងពីរយ៉ាង ប្រសិនបើ

*(ចម្រៀង) សូម្បីប្រកបព្រមដោយអត្ថអនុលោម ដោយធម៌មិនគួរ, ប្រសិនបើធម៌ សូម្បីប្រកបព្រមដោយស័ព្ទថា ច្រៀងគួរ ។*

*នៅក្នុងសុមង្គលវិលាសិនី អដ្ឋកថា សក្កបញ្ហសូត្រពោលថា* **យំ ចិត្តក្ខរំបិ ចិត្តព្យញ្ជនំបិ សទ្ទំ សុណតោ រាគទយោ ឧប្បជ្ជន្តិ ឯវរូបោ សទ្ទោ ន សេវិតព្វោ ។ យម្បន អត្ថនិស្សិតំ ធម្មនិស្សិតំ កុម្ភទាសីគីតម្បិ សុណន្តស្ស បសាទោ ឧប្បជ្ជតិ និព្វិទា វា សណ្ឋាតិ ឯវរូបោ សទ្ទោ សេវិតព្វោ ។**

*ប្រែថា* *កាលបុគ្គលស្តាប់សំឡេង សូម្បីដែលមានអក្ខរៈដ៏វិចិត្រ មានព្យញ្ជនៈដ៏វិចិត្រណា រាគៈជាដើម រមែងកើតឡើង សំឡេងមានសភាពដូច្នោះ បុគ្គលមិនគួរសេព ។ តែកាលបុគ្គលស្តាប់សំឡេងដែលអាស្រ័យអត្ថ អាស្រ័យធម៌សូម្បីជាសំឡេង ច្រៀងរបស់នាងកុម្ភទាសី រមែងកើតសេចក្តីជ្រះថ្លាឡើង ឬកើតសេចក្តីនឿយណាយប្រាកដឡើង សំឡេងមានសភាពដូច្នោះគួរសេព (គួរស្តាប់) ។*

*នៅក្នុងគម្ពីរ* ***មហាវគ្គដីកា*** *ខែចេញអំពី អដ្ឋកថា* ***សុមង្គលវិលាសិនី*** *ទីឃនិកាយទំព័រ ៣៤០ ពោលថា ៖*

**កាព្យនាដកាទិគតវេវចនវសេន, ឧច្ចារណវសេន ច វិចត្តសន្និ–វេសតាយ តថាបវត្តវិកប្បនវសេន ចិត្តវិចិត្តភាវេន ឧបតិដ្ឋនកំ សទ្ទានយាហ "យំ ចិត្តក្ខរំ ចិត្តព្យញ្ជនម្បិ សទ្ទំ សុណតោ រាគាទយោ**

ឧប្បជ្ជន្តី"តិ ។ អត្ថនិស្សិតន្តិ សម្បរាយិកត្ថនិស្សិតំ ។ ធម្មនិស្សិតន្តិ វិវដ្ដធម្មនិស្សិតំ, លោកុត្តរេតនត្តយធម្មនិស្សិតំ វា ។ បសាទោតិ រតនត្តយសទ្ធា, កម្មផលសទ្ធាបិ ។ និព្វិទា វាតិ អនិច្ចសញ្ញាទិវសេន វដ្ដតោ ឧក្កណ្ឋា វា ។

*<u>ប្រែថា</u> ព្រះអដ្ឋកថាចារ្យ លោកពោលសំដៅដល់សំឡេងច្រៀងដែលប្រាកដឡើងដោយភាពជាសំឡេងដ៏ពីរោះជាប់ចិត្ត ដោយអំណាចនៃការត្រេកអរប្រព្រឹត្តទៅយ៉ាងនោះ ព្រោះភាពជាទីប្រជុំនៃសំឡេងច្រៀងដ៏វិចិត្រដោយអំណាចនៃការចងក្រងជាកាព្យនិងសំឡេងច្រៀងមានសំឡេងច្រៀងរបស់អ្នករបាំជាដើម និងដោយអំណាចនៃការស្រែកច្រៀង ទើបព្រះអដ្ឋកថា ពោលថា "កាលបុគ្គលស្តាប់សំឡេង សូម្បីដែលមានអក្ខរៈដ៏វិចិត្រមានព្យញ្ជនៈដ៏វិចិត្រណា រាគៈជាដើមរមែងកើតឡើង ។ បទថា* **អត្ថនិស្សិតំ** *គឺ អាស្រ័យប្រយោជន៍ប្រព្រឹត្តទៅក្នុងភពខាងមុខ ។ បទថា* **ធម្មនិស្សិតំ** *គឺអាស្រ័យធម៌មិនត្រឡប់ហើយ (គឺព្រះនិព្វាន) ។*

*សូម្បីការជឿក្នុងព្រះរតនត្រ័យក្តី ការជឿក្នុងកម្ម និងផលរបស់កម្មក្តី ឈ្មោះថា* **បសាទោ** *បទថា* **និព្វិទា វា** *គឺសេចក្តីនឿយណាយចាកវដ្តៈ ដោយអំណាច នៃអនិច្ចសញ្ញាជាដើម ។ ការពណ៌នា នច្ចគីតមានប្រមាណប៉ុណ្ណោះ សូមអ្នកសិក្សាគប្បីជ្រាបតាមការពណ៌នាមកនេះឯង ។* **វាទិតៈ** *ប្រគំ លោកពោលនៅក្នុងអដ្ឋកថា* **សមន្តប្បាសាទិកាថា វាទិតម្បិ យង្កិញ្ចិ ន វដ្ដតិ ។** *សូម្បីប្រគំយ៉ាងណាមួយ ក៏មិនគួរ ។ តាមសេចក្តីដែលព្រះអដ្ឋកថា សម្តែងមកនោះ ទោះជាប្រគំយ៉ាងណាក៏ដោយ ទះបាតដៃក្តី*

*គោះទោប ជញ្ជាំងជាដើមក្តី ក៏មិនគួរ ។ ដូចជាការស្តាប់នូវភ្លេង ប្រគំសព្វថ្ងៃ មានភ្លេងពិណពាទ្យ ឧបាសក ឧបាសិកា ស្តាប់នូវភ្លេងពិណពាទ្យ រមែងដាច់ខូចសិក្ខាបទហ្នឹងពិតប្រាកដ ព្រោះហេតុអ្វី ព្រោះថា ភ្លេងពិណពាទ្យចាត់ចូលក្នុង ពាក្យថា **វាទិតៈ** ។*

*នៅក្នុង**បរមត្ថជោតិកា** អដ្ឋកថា ខុទ្ទកនិកាយ ខុទ្ទកបាឋៈ បានពន្យល់ថាៈ*

*ក្នុងពាក្យថា* **នច្ចគីតវាទិតវិសូកទស្សនំ** *នេះ ការរាំយ៉ាងណាមួយ ឈ្មោះថា* **នច្ចៈ** *។ ការច្រៀងយ៉ាងណាមួយ ឈ្មោះថា* **គីតៈ** *។ ការប្រគំយ៉ាងណាមួយ ឈ្មោះថា* **វាទិតៈ** *។* **វិសូកទស្សនំ** *ល្បែងជាសឹកសត្រូវដល់កុសលធម៌ លោកពោលនៅក្នុង* **មនោរថបូរណី** *និងបរមត្ថជោតិកាបាលី អដ្ឋកថាជាដើមថា* **វិសូកទស្សនន្តិ កិលេសុប្បត្តិបច្ចយតោ កុសលបក្ខភិន្ទនេន វិសូកានំ ទស្សនំ, វិសូកភូតំ វា ទស្សនំ វិសូកទស្សនំ ។**

*ការមើលពួកល្បែងជាសឹកសត្រូវ ឬថាកិរិយាមើលនូវពួកល្បែង ដែលជាមេនាំឲ្យកើតសឹកសត្រូវ (ដល់ផ្លូវចិត្តជាអកុសល) បានដល់សឹកសត្រូវទាំងឡាយ ដែលជាមេបក្សបំបែកពួកកុសល ហើយបានទៅជាបច្ច័យ ដល់ឧបក្កិលេសយ៉ាងនេះ បានឈ្មោះថាៈ*

**"វិសូកទស្សនំ"** *ក្នុងសិក្ខាបទនេះ ។*

*នៅក្នុង* **បរមត្ថជោតិកា** *លោកបានចង្អុលបង្ហាញប្រាប់ថា* **វិសូកទស្សនៈ** *ក្នុងទីនេះគប្បីកាន់យកតាមន័យដែលត្រាស់ទុកក្នុងព្រហ្មសូត្រចុះ ។*

*តាមសេចក្តីមានមកក្នុង* **បរមត្ថជោតិកា** *ខ្ញុំបាទនឹងអារាធនាព្រហ្មជាលសូត្រមកដាក់ទុកក្នុងសៀវភៅនេះ ដូចតទៅ ។*

នៅក្នុងសុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ ភាគ ១៤ ទំព័រ ១៤ បានសម្ដែង ថា ឯល្បែងដែលជាសត្រូវដល់កុសលធម៌នោះ តើដូចម្ដេចខ្លះ ? គឺ **នច្ចំ** ល្បែងរាំខ្លះ **គីតំ** ច្រៀងខ្លះ **វាទិតំ** ប្រគំខ្លះ **បេក្ខំ** មហោស្រពខ្លះ ល្ខោនជាដើម **អក្ខានំ** ចម្បាំងស្ដេចការតៈ និងព្រះរាមជាដើម **ចាណិស្សរំ** គងខ្លះ **វេតាឡំ** រគាំងខ្លះ **កុម្ភថូនំ** ស្គរមានជ្រុង ៤ ខ្លះ **សោភនករកំ** រូបគំនូរខ្លះ របាំខ្លះ **ចណ្ឌាលំ** ល្បែងដុំដែកខ្លះ **វំសំ** ល្បែងរាវខ្លះ **ធោវនំ** ល្បែងលាងឆ្អឹងខ្លះ **ហត្ថិយុទ្ធំ** ដំរីជល់គ្នាខ្លះ **អស្សយុទ្ធំ** សេះប្រខាំគ្នាខ្លះ **មហិសយុទ្ធំ** ក្របីជល់គ្នាខ្លះ **ឧសភយុទ្ធំ** គោជល់គ្នា **អជយុទ្ធំ** ពពែជល់គ្នា **មេណ្ឌយុទ្ធំ** កែះជល់គ្នា **កុក្កុដយុទ្ធំ** មាន់ជល់គ្នា **វដ្ដកយុទ្ធំ** ចាបជល់គ្នា **ទណ្ឌយុទ្ធំ** ល្បែងគុណដំបងខ្លះ **មុដ្ឋិយុទ្ធំ** ប្រដាល់គ្នាខ្លះ **និព្វុទ្ធំ** ចំបាប់ខ្លះ **ឧយ្យោធិកំ** ទីសម្រាប់ច្បាំងគ្នាខ្លះ **ពលគ្គំ** ទីសម្រាប់រៀបពលខ្លះ **សេនាព្យូហំ** ទីលំនៅកងទ័ពខ្លះ **អនីកទស្សនំ** ទីមើលសេនាប្រកបដោយអង្គ ៤ ខ្លះ ។ ឯល្បែងបាស្កាដែលជាហេតុជាទីតាំងនៃសេចក្ដីប្រមាទគឺ **អដ្ឋបទំ** បាស្កាមានក្រឡា ៨ ខ្លះ **ទសបទំ** បាស្កាមានក្រឡា ១០ ខ្លះ **អាកាសំ** បាស្កាដែលលេងឰដ៏អាកាសខ្លះ **បរិហារបថំ** ល្បែងវាងផ្លូវដែលគួរវាងខ្លះ **សន្តិកំ** ល្បែងផ្ទាត់គ្រាប់ មានគ្រាប់គ្រួសជាដើម **ខលិកំ** លេងបាស្កាក្នុងទីលានសម្រាប់លេងខ្លះ **ឃដិកំ** ល្បែងហឹង ឬកូនគោលខ្លះ **សលាកហត្ថំ** ល្បែងរលាស់ទឹកលាក់ឲ្យទាយខ្លះ **អក្ខំ** ល្បែងអង្គុញខ្លះ **បង្គចីរំ** ល្បែងផ្លុំប៉ីស្លឹកខ្លះ **វង្កកំ** ល្បែងនង្គ័លតូចខ្លះ **មោក្ខចិកំ** ល្បែងជាំដូងខ្លះ **ចិង្គុលិកំ** ល្បែងកង្ហារខ្លះ **បត្តាឡ្ហកំ**

*ល្បែងវាល់ដីខ្សាច់ (បាយឡុកបាយឡ)ខ្វះ* **វង្កកំ** *ល្បែងវង់តូចខ្វះ* **ធនុកំ** *ល្បែងធ្នូតូចខ្វះ* **អក្ខលិកំ** *ល្បែងសរសេរអក្សរខ្យល់ឲ្យទាយខ្វះ* **មនេសិកំ** *ល្បែងទាយចិត្ត (ស្តេចចង់)ខ្វះ* **យថាវជ្ជំ** *ល្បែងកំប្លែងត្រាប់គេខ្វះ ។ ល្បែងប៉ុណ្ណោះជាដើម ដែលជាសឹកសត្រូវដល់កុសលធម៌ ឬដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ បើលេងខ្លួនឯង ឬទៅមើលគេលេង ដាច់ខ្វួចសិក្ខាបទនច្ចគីតហ្នឹងឯង ។*

## សិក្ខាបទនេះមានអង្គ ៣ គឺ

**១–នច្ចគីតាទិ** *ការមើលល្បែងមានរាំច្រៀង*

**២–កត្តុកម្យតាចិត្តំ** *គិតបម្រុងនឹងធ្វើ*

**៣–សុតទស្សត្ថាគមនំ** *ទៅដើម្បីនឹងស្តាប់ឬមើល ហើយបានស្តាប់ ឬមើល ។*

**នច្ចគីត** *ជាសការៈ ជាសាណត្តិកៈ មានសមុដ្ឋាន ៣ គឺៈ*

**១–កាយចិត្តតោ** *ទោសកើតឡើងអំពីកាយ និងចិត្ត*

**២–វាចាចិត្តតោ** *ទោសកើតឡើងអំពីវាចា និងចិត្ត*

**៣–កាយវាចាចិត្តតោ** *ទោសកើតឡើងអំពីកាយវាចា និងចិត្ត*

*ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាបណ្ណត្តិវជ្ជ ជាកាយកម្ម និងវចីកម្ម ជាអកុសលចិត្ត ជាធម្មៈ ជាកោដ្ឋាសៈ មានសង្ខារជាអារម្មណ៍ មានវេទនាពីរណាមួយ មានមូលពីរ គឺ លោភមូល ១ មោហៈ មូល ១ ជាអនិពន្ធសីល ជាសមាទានវិរតិ ១ ជាវត្ថុកាម និងកិលេសកាម ។ នៅក្នុងគម្ពីរ* ***ចុល្លវគ្គ*** *វិន័យបិដកភាគ ១០ ទំព័រ ១៣៥ ព្រះអង្គបានសម្តែងទោសក្នុងបទច្រៀងថា ម្នាលភិក្ខុទាំងឡាយ ទោសទាំង ៥ នេះ នឹងមានដល់ភិក្ខុអ្នកច្រៀងធម៌ ដោយសំឡេងច្រៀងដ៏វែងៗ គឺ ៖*

**១– អត្តនោបិ សរេ សារជ្ជតិ** *(ភិក្ខុ ឬគ្រហស្ថ) នោះ ត្រេកអរក្នុងសំឡេងខ្លួននោះ*

**២– បរេបិ តស្មឹ សរេ សារជ្ជន្តិ** *ជនទាំងឡាយដទៃ រមែងត្រេកអរក្នុងសំឡេងនោះ*

**៣– គហបតិកាបិ ឧជ្ឈាយន្តិ** *គហបតីទាំងឡាយតែងពោលទោស*

**៤– សរកុត្តីបិ និកាមយមានស្ស សមាធិស្ស ភង្គោ ហោតិ** *បុគ្គលដែលពេញចិត្តនឹងការសូធ្យលោក់លែកសំឡេងរមែងខូចសមាធិ*

**៥– បច្ឆិមា ជនតា ទិដ្ឋានុគតិមាបជ្ជតិ** *ពួកជនខាងក្រោយនឹងដល់នូវទិដ្ឋានុគតិ (យកតម្រាប់តាម) ។ នៅក្នុងគម្ពីរ អដ្ឋកថា ឈ្មោះ* ***សមន្តប្បាសាទិកា*** *ខែពន្យល់ថា ៖*

**ភង្គោ ហោតីតិ អលទ្ធំ សមាធិំ ឧប្បាទេតុំ ន សក្កោតិ លទ្ធំ សមាបជ្ជិតុំ បច្ឆិមាជនតាតិ អម្ហាកំ អាចរិយាបិ ឧបជ្ឈាយាបិ ឯវំ គាយិំសូតិ បច្ឆិមាជនតា ទិដ្ឋានុគតិំ អាបជ្ជតិ តថេវ គាយតិ ។**

បទថា វេមែងខូចសមាធិ មានសេចក្ដីថា មិនអាចនឹងញ៉ាំងសមាធិ ដែលខ្លួនមិនទាន់បាន ឲ្យកើតឡើងបានឡើយ មិនអាចដើម្បីចូលសមាធិដែលខ្លួនបានហើយ ។

ខថាពួកជនខាងក្រោយ រមែងយកតម្រាប់តាម មានសេចក្ដីថា ប្រជុំជនជាខាងក្រោយរមែងដល់នូវទិដ្ឋានុគតិ (យកតម្រាប់តាម) ថាអាចារ្យក្ដី ឧបជ្ឈាយ៍ក្ដី របស់យើងទាំងឡាយប្រៀង (សូធ្យ) មកហើយ យ៉ាងនេះគឺប្រៀង (ឬសូត្រធម៌បទ) នោះ ដូចគ្នា ។

**អនាបត្តិ:** ហេតុដែលមិនត្រូវទោសមាន ៦ យ៉ាងគឺ

**១-គេហេ ឋិតា បស្សតិ វា សុណាតិ វា** បានមើល ឬស្ដាប់ក្នុងទីលំនៅខ្លួន ។

**២-ឋិតោកាសំ វា និសិន្នោកាសំ វា និបន្នោកាសំ វា អាគន្ត្វា នច្ចន្តិ វា គាយន្តិ វា វាទេន្តិ វា** ជនទាំងឡាយមកកាន់ទីលំនៅរបស់ខ្លួន ដែលឈរ ឬអង្គុយ ឬក៏ដេក ហើយរាំក្ដី ច្រៀងក្ដី ប្រគំក្ដី ។

**៣-បដិបថំ គច្ឆន្តិ បស្សតិ វា សុណាតិ វា** កំពុងដើរទៅជួបតាមផ្លូវ ហើយឃើញក្ដី ស្ដាប់ក្ដី ។

**៤-សតិ ករណីយេ គន្ត្វា បស្សតិ វា សុណាតិ វា** កាលបើខ្លួនមានកិច្ចដើរទៅហើយឃើញក្ដី ឮក្ដី ។

**៥-អាបទាសុ** មានសេចក្ដីអន្តរាយ ។

**៦-ឧម្មត្តកស្ស** ឆ្កួត ១ ។

**នច្ចគីតវាទិតទស្សនសិក្ខាបទ**

**សិក្ខាបទទី ៧ ចប់**

## មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា
## សិក្ខាបទទី៨

**មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា** *កិរិយាទ្រទ្រង់នឹងប្រដាប់តាក់តែងស្អិតស្អាងរាងកាយដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។*

*នៅក្នុងសុមង្គលវិលាសិនី អដ្ឋកថា ទីឃនិកាយ សីលក្ខន្ធវគ្គ ត្រង់ព្រហ្មជាលសូត្រ បានពន្យល់ថា* **មាលាទីសុ មាលាតិ យំកិញ្ចិ បុប្ផំ** ។ *ផ្កាឈើណាមួយបានឈ្មោះថា* "**មាលា**" *ក្នុងបុប្ផជាតិទាំងឡាយ មានផ្កាកម្រងជាដើម ។* **គន្ធន្តិ យំកិញ្ចិ គន្ធជាតំ** ។ *គន្ធជាតិកំណើតក្លិនណាមួយ បានឈ្មោះថា* "**គន្ធ**" *។* **វិលេបនន្តិ ឆវិរាគករណំ** *កិរិយាធ្វើនូវស្បែកសម្បុរថ្ងៃបាន ជាទីតម្រេកបាន ឈ្មោះថា* "**វិលេបន**" **តត្ថ បិលន្ធន្តោ ធារេតិ នាម** ។ *ការពាក់ លាបប្រដាប់ទាំងនោះ បានឈ្មោះថា "ធារណៈ" ។* **ឩនដ្ឋានំ បូរេន្តោ មណ្ឌេតិ នាម** ។ *ការប្រដាប់បំពេញនូវទីពាក់កណ្តាលមួយកំណាត់កាយ បានឈ្មោះថា "មណ្ឌនៈ" ។*

**គន្ធវាសេន ឆវិរាគវាសេន ច សាធិយន្តោ វិភូសេតិ នាម** *កាលចំណុចត្រែកអរមានដោយអំណាចក្លិនផង មានដោយអំណាចឆវិរាគៈផង បានឈ្មោះថា* "**វិភូសនៈ**" *។ ប្រមូលបាលីមកជាសិក្ខាបទថា* **មាលាគន្ធវិលេបនធារណមណ្ឌន-វិភូសនៈ** *ដូច្នេះ ។ សេចក្តីពណ៌នាមកប្រមាណប៉ុណ្ណោះ នៅក្នុង សារត្ថទីបនីដីកា ភាគ ៣*

ទំព័រ ៣០៨ ក៏មានដែរ មានសេចក្តីដូចគ្នា នៅក្នុង **បរមត្ថជោតិកា** ក៏មានសេចក្តីប្រហែលគ្នា គឺអត្ថន័យដូចគ្នា ។

នៅក្នុងសិក្ខាបទនេះ ខ្ញុំបាទចង់បញ្ជាក់អំពីពាក្យថា **ធារណា:** ប្រដាប់តាក់តែងស្អិតស្អាងរាងកាយ តាមគម្ពីរអដ្ឋកថា ឈ្មោះ **សមន្តបាសាទិកា** ត្រង់ខុទ្ទកវត្ថុក្ខន្ធក ដែលព្រះអដ្ឋកថាចារ្យ បានសម្តែងថា: **វលិកាតិ កណ្ណតោ និក្ខន្តមុត្តោលម្ពិកាទីនំ ឯតំ អធិវចនំ ។ ន កេវលញ្ច វលិកាយេវ យង្កិញ្ចិ កណ្ណបិលន្ធនំ អន្តមសោ តាលបណ្ណំបិ ន វដ្ដតិ ។** ត្រង់ពាក្យថា ប្រដាប់ត្រចៀកនេះ ជាឈ្មោះនៃគ្រឿងប្រដាប់ត្រចៀក មានកែវមុក្តា ទុំហូ (ក្រវិល) ជាដើម ដែលសំយុងធ្លាក់ចេញអំពីត្រចៀក ។ នឹងមិនគួរត្រឹមតែទុំហូ (ក្រវិល) តែម្យ៉ាងប៉ុណ្ណោះ ក៏មិនមែនគ្រឿងប្រដាប់យ៉ាងណាមួយ ដោយហោចទៅ សូម្បីស្លឹកត្នោត ក៏មិនគួរ ។ **ចាមង្គន្តិ យង្កិញ្ចិ ចាមង្គសុត្តំ ។** ខ្សែសង្វារយ៉ាងណាមួយ បានឈ្មោះថា **ចាមង្គំ ។ កដិសុត្តកន្តិ យង្កិញ្ចិ កដិបិលន្ធនំ អន្តមសោ សុត្តតន្តុមត្តំបិ ។** គ្រឿងប្រដាប់ចង្កេះយ៉ាងណាមួយ ដោយហោចទៅសូម្បីត្រឹមតែជាខ្សែអំបោះ បានឈ្មោះថា គ្រឿងប្រដាប់ចង្កេះ ។ **កណ្ឋសុត្តកន្តិ យង្កិញ្ចិ គីវូបគំ អាភរណំ** អាភរណ:ជាគ្រឿងប្រដាប់កយ៉ាងណាមួយ បានឈ្មោះថា គ្រឿងប្រដាប់ក ។

ជាពិសេសព្រះអដ្ឋកថាបញ្ជាក់សេចក្តីឲ្យច្បាស់ថា **យង្កិញ្ចិ អាភរណំ ន វដ្ដតិ ។** គ្រឿងអាភរណ: ឬគ្រឿងប្រដាប់យ៉ាងណាមួយ ក៏មិនគួរ ។ តាមសេចក្តីមានមកនៅក្នុងព្រះអដ្ឋកថា **សមន្តបាសាទិកា** ឧបាសក ឧបាសិកា អ្នករក្សាឧបោសថ មិនអាចពាក់ចិញ្ចៀន ខ្សែដៃ ខ្សែក ក្រវិល ឬប្រដាប់តាក់តែងយ៉ាងណាមួយ ក្នុងថ្ងៃដែលខ្លួនរក្សា ឧបោសថ-សីលទេ ប្រសិនបើពាក់ ដាច់ខូចសិក្ខាបទហ្នឹងឯង ។ ដូច្នេះ ឧបាសក ឧបាសិកា ត្រូវដោះគ្រឿងប្រដាប់ពាក់ឲ្យអស់ចេញហើយ ចាំសមាទានឧបោសថសីល ទើបឡើងជាសីលបាន ។

ដើម្បីឲ្យសេចក្តីនេះជាក់ច្បាស់ ខ្ញុំបាទនឹងអារាធនាព្រហ្មជាលសូត្រ ដែលសម្តែងនៅក្នុង **សុត្តន្តបិដក** ទីឃនិកាយ សីលក្ខន្ធវគ្គ ភាគ ១៤ ទំព័រ ១៧ ថា វត្ថុជាទីតាំងនៃការប្រដាប់ស្អិតស្អាងរាងកាយ មានសភាពយ៉ាងនេះ គឺ **ឧច្ឆាទនំ** កាដុសខាត់បំបាត់ខ្ទិនអាក្រក់ (គ្រឿងអប់) **បរិមទ្ទនំ** ការប្រេបាច់រឹត **នហាបនំ** ការផ្ងូតទឹក **សម្ពាហនំ** ការគក់ប្រេបាច់ **អាទាសំ** កញ្ចក់ **អញ្ជនំ** វត្ថុសម្រាប់លាបគ្រឿងប្រដាប់ **មាលា** ផ្កាកម្រង **វិលេបនំ** គ្រឿងលាប **មុខចុណ្ណកំ** គ្រឿងលម្អិតសម្រាប់ប្រស់មុខ **មុខាលេបំ** វត្ថុសម្រាប់លាបមុខ **ហត្ថពន្ធំ** គ្រឿងប្រដាប់ដៃ **សិខាពន្ធំ** ចំណងផ្នួងសក់ **ទណ្ឌំ** ដំបង **នាលិកំ** បំពង់ថ្នាំ **អសិ** ដាវ **ឆត្តំ** ព្រះខាន់ **ឆត្តំ** ឆត្រ **ចិត្រុបាហនំ** ស្បែកជើងដ៏វិចិត្រ **ឧណ្ហីសំ** មកុដ ឬក្បាំងមុខ (ស្នៀតសក់) **មណឹ** កែវមណី **វាលវិជនី** ផ្លិតធ្វើពីរោមកន្ទុយសត្វ **ឱទាតានិ វត្ថានិ** សំពត់ស **ទីឃទសានិ** សំពត់មានជាយវែង ។

នៅក្នុង**សុមង្គលវិលាសិនី** ជាព្រះអដ្ឋកថា បានពន្យល់សេចក្តីទាំងអស់នេះថា : ក្លិនកាយរបស់ទារក ដែលប្រសូតចេញចាកគភ៌នឹងអស់ទៅក្នុងវេលាអាយុប្រមាណ១២ឆ្នាំ មនុស្សទាំងឡាយទើបអប់ខ្លួន ដោយលម្អិតនឹងគ្រឿងក្រអូបជាដើម ដើម្បីបន្ទោបង់នូវក្លិនអាក្រក់របស់កាយទារកនោះ ការដុសលាងខ្លួនយ៉ាងនេះ មិនគួរ ។ ដូចយ៉ាងទារកមានបុណ្យ គេឲ្យដេកក្នុងរវាងភ្លៅទាំង ២ ហើយយកប្រេងលាបប្រេបាច់រឹត ដើម្បីធ្វើទ្រង់ទ្រាយនៃអវយវៈ មានដៃជើងភ្លៅផ្ទៃពោះជាដើម ឲ្យសមរម្យល្អ ។ ការប្រេបាច់រឹតយ៉ាងនេះ មិនគួរ ។ ត្រង់ពាក្យថាផ្ងូតទឹក បានដល់ការងូត ដូចងូតទឹកក្រអូបជាដើម ឲ្យទារកទាំងឡាយនោះឯង ។ បទថា **សម្ពាហនំ** បានដល់ប្រេបាច់ ដូចពួកអ្នកប្រដាល់សម័យប្រើអន្ទូងជាដើម វាយដៃជើង ធ្វើឲ្យដើមដៃធំធាត់ (សមរម្យល្អ) ។ បទថា **អាទាសំ** មិនគួរប្រើកញ្ចក់យ៉ាងណាមួយ ។ បទថា **អញ្ជនំ** បានដល់វត្ថុសម្រាប់លាបធ្វើឲ្យស្អាតនោះឯង ។ បទថា

**មាលា** បានដល់ផ្កាឈើ ដែលក្រងខ្វះ ផ្កាឈើដែលមិនបានក្រងខ្វះ ។ បទថា **វិលេបនំ** បានដល់ធ្វើការលាបលទសម្បុរយ៉ាងណាមួយ ។

ដោយបទថា **មុខចុណ្ណកំមុខាលេបំ** មនុស្សទាំងឡាយដាក់កករដី ដើម្បីត្រូវការបន្ទាបន័នូវប្រជ្រុយ នឹងកន្ទួលជាដើម ត្រង់មុខកាលលោហិតទៅដោយកករដីនោះ ក៏ដាក់កករគ្រាប់ស្ពៃ កាលកករ (ម្សៅ) គ្រាប់ស្ពៃកាត់ចំណែកទាំងអស់ ហើយក៏ដាក់កករល្ង កាលលោហិតឈប់ដោយកករល្ងនោះ គេក៏ដាក់កកររមៀត កាលសម្បុរពណ៌ផូរផង់ដោយកកររមៀតហើយ ក៏លាបមុខដោយម្សៅលាបមុខនោះឯង ការធ្វើទាំងអស់នោះ មិនគួរ ។

មនុស្សពួកខ្លះយកស័ង្ខ ឬក្បៀងជាដើមដ៏វិចិត្រ ចងត្រង់កដៃដើរទៅ ។ គ្រឿងប្រដាប់ដៃយ៉ាងនោះក្តី យ៉ាងដទៃក្តី ទាំងអស់មិនគួរ ។ មនុស្សមួយពួកចងចុងសក់ដើរទៅ នឹងយកខ្សែមាស និងវល្លិមុក្តាជាដើម រុំព័ទ្ធចងសក់នោះឯង ។ វត្ថុទាំងឡាយនោះ (ឬវត្ថុយ៉ាងណាមួយ សម្រាប់ចងសក់មានស្នៀតសក់ជាដើម) មិនគួរ ។ មនុស្សមួយពួកកាន់ឈើច្រត់ប្រវែង ៤ហត្ថ ឬឈើច្រត់យ៉ាងដទៃ មានដងប្រដាប់ស្អាតដើរទៅ ។ បំពង់ថ្នាំដែលវិចិត្រ ដោយរូបប្រុសស្រីជាដើម វង់ជុំវិញយ៉ាងល្អ ពាក់ទុកខាងឆ្វេង ។ សូម្បីដាវមានស្រោមរុំដោយរតនៈ មានរូបផ្កាកណ្ណិកា ឆត្រដ៏វិចិត្រ ដោយធ្មេញមករជាដើម ដេរដោយអំបោះ ៥ ពណ៌ ។ ស្បែកជើងដ៏វិចិត្រ ដោយកន្ទុយក្ងោកជាដើម ឬមួយវិចិត្រដោយមាស និងប្រាក់ជាដើម ។

មនុស្សពួកខ្លះសម្តែងចុងសក់ ជ្ជាក់បណ្តោយប្រមាណមួយហត្ថមួយចំអាម ទទឹងបួនធ្នាប់ ក្របមុខត្រង់ថ្ងាសដូចផ្ទេកបន្ទោរពព្លដ៏ផ្ទៃមេឃ ស្នៀតសក់ប្រើផ្ចិតចាមរី ឬផ្ចិតវាលវីជនី ។ ប្រដាប់ទាំងអស់នោះ មិនគួរ ។

នៅក្នុង**សារត្ថទីបនីដីកា** និងនៅក្នុងមនោរថបូរណី "អដ្ឋកថា អង្គុត្តរនិកាយ តិកនិបាត បានបញ្ជាក់ទៀតថា ៖

**ឋានំ វុច្ចតិ ការណំ តស្មា យាយ ទុស្សីល្យចេតនាយ តានិ មាលាធារណាទីនិ មហាជនោ ករោតិ សា ធារណាមណ្ឌនវិភូសនដ្ឋានំ ។**

ហេតុព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ត្រាស់ ហៅថា **ឋាន:** អធិប្បាយថា ព្រោះហេតុនោះ មហាជនរមែងធ្វើនូវវត្ថុទាំងឡាយ មានកិរិយាទ្រទ្រង់ នូវផ្កាកម្រងជាដើមនោះ ដោយចេតនាភាពទ្រុស្តសីលឯណា សីលវន្តបុគ្គលទាំងឡាយ (ក៏ត្រូវ) វៀរចាកស្រឡះចាកវត្ថុមានកិរិយាទ្រទ្រង់ និងប្រដាប់តាក់តែង ស្អិតស្អាងរាងកាយដោយចេតនា ភាពទ្រុស្តសីលនោះ ។

**សិក្ខាបទនេះមានអង្គ ៣ គឺ :**

**១-មាលាទិ** វត្ថុសម្រាប់ប្រដាប់កាយ មានផ្កាកម្រងជាដើម

**២-ធារណច្ឆន្ទតា** សេចក្តីប្រាថ្នានឹងប្រដាប់តាក់តែង

**៣-តស្ស ធារណំ** បានប្រដាប់តាក់តែងនូវវត្ថុសម្រាប់ប្រដាប់កាយមានផ្កាកម្រងជាដើមនោះ ។

**មាលា....** ជាសភាវ: ជាអនាណត្តិក: មានសមុដ្ឋាន ១ គឺ **កាយចិត្ដតោ** ទោសកើតឡើងអំពីកាយ និងចិត្ត ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តក: ជាបណ្ណត្តិវជ្ជ: ជាកាយកម្ម ជាអកុសលចិត្ត ជាធម្ម: ជាកោដ្ឋាស: មានសង្ខារជាអារម្មណ៍ មានវេទនាពីរ គឺ សុខវេទនា ១ ឧបេក្ខាវេទនា ១ មានមូលពីរ គឺលោភមូល ១ មោហមូល ១ ជាអនិពទ្ធសីល ជាសមាទាន មានសមាទានវិរតិ ១ ជាវត្ថុកាម និងកិលេសកាម ។

**អនាបត្តិ:** ហេតុដែលមិនត្រូវទោសមាន ២ យ៉ាងគឺ :

**១-អាពាធា** មានជំងឺរោគាពាធ

**២-ឧម្មត្តកស្ស** ឆ្កួត ១ ។

**មាលាគន្ធវិលេបនធារណមណ្ឌនវិភូសន**

**សិក្ខាបទទី ៨ ចប់**

## ឧច្ចាសយនមហាសយនា

## សិក្ខាបទទី ៩

**ឧច្ចាសយនមហាសយនា** *ទីដេក ឬទីអង្គុយលើទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។ នៅក្នុង**សុមង្គលវិលាសិនី** ពោលថា ៖*

**ឧច្ចាសយនន្តិ បមាណាតិក្កន្តំ ។ មហាសយនន្តិ អកប្បិយត្ថតំ** *ទីដេកដែលលើសប្រមាណ ឈ្មោះថា* **ឧច្ចាសយនៈ** *គ្រឿងកម្រាលដែលជាអកប្បិយៈ (មិនគួរ) ឈ្មោះថា* **មហាសយនៈ។** *នៅក្នុង**មនោរថបូរណី** ក៏មានន័យនេះដូចគ្នា ។*

*នៅក្នុង**សីលក្ខន្ធវគ្គអភិនវដីកា** ភាគ ១ ទំព័រ ៤២៥ ត្រង់ព្រហ្មជាលសូត្រ និងនៅក្នុងគម្ពីរ**អង្គុត្តរដីកា** ត្រង់ឧបោសថសូត្រ បានបញ្ជាក់ថា:* **ឧច្ចាតិ ឧច្ចសទ្ទេន អការន្តេន សមានត្ថំ អាការន្តំ ឯកំ សទ្ទន្តរំ អត្ថុគ្គតវាចកន្តិ អាហ បមាណាតិក្កន្តន្តិ ។** *ពាក្យថា* **ឧច្ចា** *ជាសព្ទមួយដែលមានសេចក្តីស្មើ ដែលជាអាការន្ត ជាមួយ* **ឧច្ច** *សព្ទ លោកពោលថា ជា* **អត្ថុគ្គតវាចកៈ** *(ព្រោះហេតុនោះ) ព្រះអដ្ឋកថាទើបពោលថា* **បមាណាតិក្កន្តំ** *ដូច្នេះ ។*

**សេតិ ឯត្ថាតិ សយនំ មញ្ចាទិ** *បុគ្គលរមែងដេកលើទីដេកនេះ ព្រោះហេតុនោះ ទីដេកនោះ ឈ្មោះថា ជាទីដេកគឺគ្រែជាដើម ។*

ទីអង្គុយដ៏ខ្ពស់ហួសប្រមាណនៅក្នុង**មនោរថបូរណី** អដ្ឋកថា អង្គុត្តរនិកាយ តិកនិបាត បានសម្តែងថា: **មុដ្ឋិហត្ថបាទកេ កប្បិយមញ្ចេ** គួរដេក ឬអង្គុយ លើគ្រែដេកជាកប្បិយ: មានខ្នាតជើងកម្ពស់ ១ ហត្ថក្តាប់ ។ នៅក្នុងគម្ពីរ **សារត្ថមញ្ជូសា** អង្គុត្តរដីកា បានពន្យល់ថា **មុដ្ឋិហត្ថបាទកេតិ បាទតលតោ យាវ អដនិយា ហេដ្ឋិមន្តោ តាវ មុដ្ឋិរតនប្បមាណបាទកេ** ។ ត្រង់ពាក្យថា មានជើងកម្ពស់ ១ ហត្ថក្តាប់នេះគឺ មានខ្នាតជើងកម្ពស់ប្រមាណ ១ ហត្ថក្តាប់ (មួយគក់) រាប់ចាប់តាំងអំពីផ្ទៃជើងរហូត ដល់ទីបំផុតខាងក្រោមនៃមេគ្រែ ។ លោកបានពន្យល់ នៅក្នុងគម្ពីរ**មង្គលត្ថទីបនី** អំពីហត្ថថា (១) ភាគ ៣ ទំព័រ ១៦២ **តត្ថ ចេ មជ្ឈិមស្ស បុរិសស្ស ហត្ថេន យស្សិទានិ វឌ្ឍកីហត្ថោតិ សមញ្ញាតិ វុត្តំ ។ យស្មា បន បកតិបុរិសស្ស ទិយឌ្ឍា-អង្គុលិ មជ្ឈិមស្ស ឯកា អង្គុលិ ហោតិ តថា វិទត្ថិ រតនំ ពាហា ព្យាមោ ច តស្មា មជ្ឈិមស្ស មុដ្ឋិរតនំ បកតិបុរិសស្ស វិទត្ថាធិកមុដ្ឋិរតនំ ហោតីតិ និដ្ឋមេត្ថ គន្តព្វំ** ។

ប្រែថា បើដូច្នេះ ១ ហត្ថក្តាប់ដែលមាន ឈ្មោះថា ហត្ថជាងឈើ ក្នុងឥឡូវនេះ ស្មើជាមួយហត្ថនៃមជ្ឈិមបុរស ។

ព្រោះថា ១ ធ្នាប់កន្ទះរបស់បុរសតាមប្រក្រតីជា ១ ធ្នាប់របស់មជ្ឈិមបុរស ចំអាម ហត្ថដៃ និងព្យាមក៏ដូចគ្នាដែរ ព្រោះហេតុនោះ បណ្ឌិតទាំងឡាយគប្បីដល់ការ:ធ្នាប់ចុះក្នុង អធិការនេះថា ១ ហត្ថក្តាប់ ១ ចំអាមរបស់បុរសតាមប្រក្រតី ។

យើងស្តាប់មកហើយថា ១ ហត្ថក្តាប់ដៃ លៃជាម៉ែត្រទៅឃើញ ថា ៥០ សង់ទីម៉ែត្រ គឺ ៥ តឹកហ្នឹងឯង ។

*នៅក្នុងវិន័យបិដក* ***មហាវិភង្គ*** *ភាគ ៤ ទំព័រ ៣៨៦ ព្រះអង្គបញ្ញត្តសិក្ខាបទថា* **ឆវំ បន ភិក្ខុនា មញ្ចំ វា បីឋំ វា ការយមានេន អដ្ឋង្គុលបាទកំ ការេតព្វំ សុគតង្គុលេន អញ្ញត្រ ហេដ្ឋិមាយ អដនិ យា តំ អតិក្កាមយតោ ឆេទនកំ ចាចិត្តិយំ ។** *ភិក្ខុឲ្យគេធ្វើគ្រែក្តី តាំងក្តី ដ៏ថ្មីត្រូវឲ្យធ្វើឲ្យមានជើង ៨ ធ្នាប់ដោយធ្នាប់ព្រះសុគត វាស់ពីត្រឹមមេគ្រែខាងក្រោមចុះទៅ (បើធ្វើ) ឲ្យកន្លងពីនោះទៅ ត្រូវឆេទនបាចិត្តិយ: ។ មែនពិត ជើងគ្រែ និងជើងតាំងមានប្រមាណ ៨ ធ្នាប់ ដោយធ្នាប់ព្រះសុគតប៉ុណ្ណោះ ទើបគួរ ។ បើលើសពី ៨ ធ្នាប់ព្រះសុគត មិនគួរ ។*

*នៅក្នុងកង្ខាវិតរណី ភាគ ១ ទំព័រ ១១១ (១) បានពោលថា :* **សុគតវិទត្ថិ ឆាម ឥទានិ មជ្ឈិមស្ស បុរិសស្ស តិស្សោ វិទត្ថិយោ វឌ្ឍាកីហត្ថេន ទិយឌ្ឍោ ហត្ថោ ហោតិ ។** *៣ ចំអាម មជ្ឈិមបុរសក្នុងឥឡូវនេះ ឈ្មោះថា ១ ចំអាមព្រះសុគត ។ ១ ចំអាមព្រះសុគត ស្មើ ១ ហត្ថ ១ ចំអាម ដោយហត្ថជាងឈើ។*

*នៅក្នុងមង្គលត្ថទីបនី ភាគ ៣ ទំព័រ ១៦២ បញ្ជាក់ទៀតថា:* **តស្មា មជ្ឈិមស្ស តិស្សោ អង្គុលិយោ សត្ត ឯកា អង្គុលីតិ សត្ត អដ្ឋង្គុលិយោ មជ្ឈិមស្ស ចតុព្វីសតិ អង្គុលិយោ ហោន្តិ ។ តា មុដ្ឋិរតនំ ហោន្តិ ។** *ព្រោះហេតុនោះ ៣ ធ្នាប់នៃមជ្ឈិមបុរស ទើបជា ១ ធ្នាប់របស់ព្រះសាស្តា (បើដូច្នោះ) ៨ ធ្នាប់របស់ព្រះសាស្តា ទើបជា ២៤ ធ្នាប់របស់មជ្ឈិមបុរស ។ ២៤ ធ្នាប់នោះ ជា ១ ហត្ថក្តាប់ ។*

***គ្រែតាំងដែលព្រះសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យប្រើប្រាស់ អង្គុយ ដេក បាននោះមាន ៤ យ៉ាងគឺ :***

១–មសារក: គ្រែដែលគេបញ្ចូលមេទៅក្នុងជំណាប់ជើង

២–ពុន្ទិកាពទ្ធ: គ្រែដែលគេភ្ជាប់នឹងជើង

៣–កុឡិរចានក: គ្រែដែលមានជើងដូចជាជើងក្ដាម

៤–អាហច្ចបាទក: គ្រែដែលមានជើងដូចជាចុច ឬគ្រែដែលគេបញ្ចូលជើងទៅក្នុងជំណាប់មេ ។

**ទ្រង់អនុញ្ញាតតាំងមាន ៤ យ៉ាង គឺ :**

១–មសារក: តាំងដែលគេបញ្ចូលមេទៅក្នុងជំណាប់ជើង

២–ពុន្ទិកាពទ្ធ: តាំងដែលមានមេបន្ទំជាប់នឹងជើង

៣–កឡិរចានក: តាំងដែលមានជើងដូចជាជើងក្ដាម

៤–អាហច្ចបាទក: តាំងដែលមានជើងចុច ឬតាំងដែលគេបញ្ចូលជើងទៅ ក្នុងជំណាប់មេ ។

គ្រែនិងតាំងទាំងឡាយសុទ្ធតែមានកម្ពស់ត្រូវនឹងប្រមាណទាំងអស់ ទើបប្រើប្រាស់បាន ដេកបាន អង្គុយបាន បើគ្រែជាដើមនោះ ជើងខ្ពស់ហួសប្រមាណ ត្រូវដឹងថា សុទ្ធតែទ្រង់ហាមទាំងអស់ ។

*សេចក្ដីពណ៌នាមកប៉ុណ្ណោះ ជាឈ្មោះនៃឧច្ចាសយនៈសិន ។*

**មហាសយនា** ទីសេនាសនៈដ៏ប្រសើរ ។ ទីសេនាសនៈដ៏ប្រសើរ បានដល់គ្រឿងកម្រាលដែលជាអកប្បិយៈ ។

*នៅក្នុងវិន័យបិដក* **មហាវគ្គ** *ភាគ ៧ ទំព័រ ១៩៦ ត្រង់ចម្មក្ខន្ធក: បានសម្តែងអំពីអាសនៈខ្ពស់ហួសប្រមាណ និងអាសនៈដ៏ប្រសើរនោះ មាន ២០ យ៉ាងគឺ :*

**១–អសន្ទិ** *អាសនៈខ្ពស់ហួសប្រមាណ*

**២– បល្លង្ក** *គ្រែដែលមានជើងវិចិត្រដោយរូបសត្វសាហាវ*

**៣–គោណក** *ព្រំដែលមានរោមវែងជាង ៤ ធ្នាប់*

**៤–ចិត្តក** *កម្រាលដែលគេធ្វើដោយរោមសត្វ (រោមកែះ) វិចិត្រដោយរូបសត្វសាហាវ*

**៥–បដិក** *កម្រាលពណ៌សដែលធ្វើដោយរោមសត្វ (រោមកែះ)*

**៦– បដិលិក** *កម្រាលធ្វើដោយរោមសត្វជាផ្កាចង្កោម*

**៧–តូលិក** *កម្រាលដែលញាត់ដោយគជាប្រក្រតី*

**៨– វិកតិក** *កម្រាលដែលធ្វើដោយរោមសត្វវិចិត្រដោយរូបសត្វមានសីហ: និងខ្លាធំជាដើម*

**៩– ឧទ្ធលោមិ** *កម្រាលដែលធ្វើដោយរោមសត្វមានរោមប្រាងឡើងតែម្ខាង*

**១០–ឯកន្តលោមិ** *កម្រាលដែលធ្វើដោយរោមសត្វមានរោមប្រាងឡើងទាំងសងខាង*

**១១–កដិស្ស** *កម្រាលដែលធ្វើដោយឱទមាសនិងសូត្រហើយចាក់ស្រេះដោយរតនៈ*

**១២–កោសេយ្យ** *កម្រាលដែលធ្វើដោយសរសៃសូត្រ ហើយចាក់ស្រេះដោយរតនៈ*

**១៣–កុត្តក** *កម្រាលដែលធ្វើដោយរោមសត្វល្មមចុះពួកស្រីរបាំ១៦ នាក់ ឈររាំបាន*

**១៤–ហត្ថត្ថរៈ** *កម្រាលសម្រាប់ក្រាលលើខ្នងដំរី*

**១៥–អស្សត្ថរៈ** *កម្រាលសម្រាប់ក្រាលលើខ្នងសេះ*

**១៦–រថត្ថរៈ** *កម្រាលសម្រាប់ក្រាលលើរថ*

**១៧–អជិនប្បវេណិ** *កម្រាលដែលគេធ្វើដោយស្បែកខ្លាឃ្មុំ*

**១៨–កទលិមិគបវរប្បច្ចត្ថរណំ***កម្រាលដ៏ឧត្តមដែលគេធ្វើដោយស្បែកសត្វឈ្លូស*

**១៩–សឧត្តរច្ឆទំ** *ទីដេកដែលមានពណ៌ក្រហមលើ គឺពិតានពណ៌ក្រហមនៅពីខាងលើ*

**២០– ឧភតោលោហិតកុបធានំ** *ខ្នើយមានពណ៌ក្រហមទាំងពីរខាង (ទីដេកមានខ្នើយក្រហមទាំងពីរខាងនៃគ្រែ គឺខ្នើយក្បាលមួយ ខ្នើយជើងមួយ ទីដេកប្រភេទនេះមិនគួរ។ តែថាខ្នើយឯណាតែម្យ៉ាងប៉ុណ្ណោះ ត្រង់មុខសងខាង នឹងក្រហមក៏ដោយមានពណ៌ដូចផ្កាឈូកក៏ដោយ វិចិត្រក៏ដោយ ដោយប្រមាណខ្នើយនោះរមែងគួរ ។ ចំណែកខ្នើយធំទ្រង់ហាមហើយ) ។ តែព្រះអង្គទ្រង់អនុញ្ញាតថាៈ*

**អនុជានាមិ ភិក្ខវេ ឋបេត្វា តីណិ អាសន្ទិំ បល្លង្កំ តូលិកំ អវសេសំ គិហិវិកដំ អភិនិសីទិតុំ ន ត្វេវ អភិនិបជ្ជិតុំ ។**

*ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យអង្គុយលើអាសនៈដ៏សេស ជាគិហិវិកដៈ គឺអាសនៈដែលប្លែកសម្រាប់គ្រហស្ថបាន តែដេកមិនបាន វៀរលែង តែអាសនៈ ៣ យ៉ាងគឺ* **អសន្ទិ១ បល្លង្ក១ តូលិកៈ១ ។**

បើដូច្នេះ បណ្ដាអាសនៈទាំង ២០ នុ៎ះ អាសនៈ ៣ យ៉ាងគឺ **អសន្ទិ ១ បល្ល័ង្ក ១ តូលិកៈ ១** បីនេះ ព្រះពុទ្ធដីកាទ្រង់ហាមដាច់ខាត អង្គុយក៏មិនឲ្យអង្គុយ ដេក ក៏មិនឲ្យដេក ជាដាច់ខាត់ ។ បើអាសនៈក្រៅពី៣ នេះ គឺ អាសនៈ ១៧ បើជារបស់គ្រហស្ថៗ គេតាក់តែងខ្លួនឯង ក្នុងទីទាំងឡាយ គឺ ធម្មាសនៈក្តី ទីដែលទាយកអង្គាសក្នុងវត្តក្តី ភោជនសាលាក្តី ផ្ទះគេក្នុងស្រុកក្តី នោះទ្រង់អនុញ្ញាតឲ្យអង្គុយបាន តែត្រង់ដេកទ្រង់ហាមដាច់ខាត ។ (គប្បីដឹងថា អាសនៈទាំង ១៧ នុ៎ះ ដែលទ្រង់អនុញ្ញាតឲ្យអង្គុយបាន ចំពោះតែរបស់បុគ្គលប៉ុណ្ណោះ បើជារបស់ខ្លួនឯងវិញ គឺព្រះអង្គទ្រង់ហាមហើយ កុំដេក កុំអង្គុយ) ។

នៅក្នុងគម្ពីរចុល្លវគ្គ វិន័យបិដកលេខ ១០ ទំព័រ ២៧៥ ត្រង់សេនាសនក្ខន្ធកៈ ព្រះអង្គទ្រង់អនុញ្ញាតពូកថា : ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតពូក ៥ យ៉ាងគឺ:

**១–ឧណ្ណាភិសិ** ពូកញាត់រោមកែះ

**២–ចោឡភិសិ** ពូកញាត់សំពត់

**៣–វាកភិសិ** ពូកញាត់សំបកឈើ

**៤–តិណភិសិ** ពូកញាត់ស្មៅ

**៥–បណ្ណភិសិ** ពូកញាត់ស្លឹកឈើ ។

នៅក្នុងអដ្ឋកថា **សមន្តប្បាសាទិកា** បានពន្យល់ថាពូក ៥ យ៉ាងនោះ បានដល់ពូកដែលញាត់ដោយរបស់ ៥ យ៉ាង មានរោមសត្វជាដើម ។

មែនពិត ព្រះដ៏មានព្រះភាគត្រាស់ចំនួននៃពូកទាំងឡាយនោះតាមចំនួននៃគ ។

បណ្ដាពូកទាំងឡាយនោះ មិនមែនតែរោមកែះតែម្យ៉ាងទេ ដែលព្រះអង្គទ្រង់កាន់យកដោយ **ឧណ្ណា** ស័ព្ទ ។ តែថា វៀរលែងរោមមនុស្សចេញហើយ រោមបក្សី និងសត្វជើង ៤

មានជាតិជាសាច់កប្បិយៈ និង អកប្បិយៈ ប្រភេទណាមួយ បណ្ដាមានរោមសត្វទាំងឡាយ នោះ ទ្រង់កាន់យកក្នុងអធិការថា ពូកដោយ **ឧណ្ណា** ស័ព្ទ មែនពិត ។

ព្រោះដូច្នោះ បណ្ដាចីវរ ៦ យ៉ាង និងអនុលោមចីវរ ៦ យ៉ាង ភិក្ខុធ្វើសំបកពូក ដោយប្រភេទណាមួយហើយ ញាត់រោមសត្វគ្រប់យ៉ាងនោះ ធ្វើជាពូកក៏គួរ ។

ម្យ៉ាងទៀត សូម្បីពូកមិនបានញាត់រោមកែះ ដាក់តែសំពត់កម្ពល ៤ ជាន់ ឬ ៥ ជាន់ រមែងដល់ការរាប់ថា ពូកញាត់រោមសត្វដូចគ្នា ។

បណ្ដាពូកទាំងឡាយ មាន **ចោឡភិសិ** ជាដើម ពូកដែលគេរួបរួមកម្ទេចសំពត់ថ្មី ឬកម្ទេចសំពត់ចាស់យ៉ាងណាមួយតម្រួតចូល ឬញាត់ចូលខាងក្នុងឈ្មោះថា **ចោឡភិសិ** ។

ពូកញាត់សំបកឈើ ប្រភេទណាមួយ ឈ្មោះថា **វាកភិសិ** ។ ពូកញាត់ដោយស្មៅយ៉ាងណាមួយបានឈ្មោះថា **តិណភិសិ** ។ ពូកញាត់ស្លឹកឈើយ៉ាងណាមួយបាន ឈ្មោះថា **បណ្ណភិសិ** ។

ចំណែកស្លឹកទន្សែដែលលាយស្លឹកឈើដទៃទើបគួរ ។ ស្លឹកទន្សែសុទ្ធៗមិនគួរ ។

## សិក្ខាបទនេះមានអង្គ ៣ គឺ

**១–ឧច្ចាសយនមហាសយនា** ទីដេកឬអង្គុយដ៏ខ្ពង់ខ្ពស់ហួសប្រមាណ និងទីដេក អង្គុយដ៏ប្រសើរ

**២–បរិភោគចិត្តំ** គិតនឹងដេក ឬអង្គុយ

**៣–បរិភោគករណំ** បានដេក ឬអង្គុយ

**ឧច្ចាសយនៈ** ជាសភាវៈ ជាអនាណត្តិកៈ មានសមុដ្ឋាន ១ គឺៈ **កាយចិត្តតោ** ទោសកើតឡើងអំពីកាយ និងចិត្តតែមួយ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម មានចិត្ត ៣ ជាធម្មៈ ជាកោដ្ឋាសៈ មានសង្ខារជាអារម្មណ៍ មានវេទនា ៣ មានមូលពីរ គឺ លោភមូល ១ មោហមូល ១ ជាអនិពទ្ធសីល ជាសមាទាន ជាសមាទានវិរតិ ជាវត្ថុកាម និងកិលេសកាម ។

**អនាបត្តិ:** ហេតុដែលមិនត្រូវទោសមាន ៦ យ៉ាងគឺ

១- ដេក ឬអង្គុយលើគ្រែ និងតាំងដែលមានជើងកម្ពស់ត្រឹម ៨ ធ្នាប់ ព្រះសុគត ឬថយចុះជាងនោះ ។

២- គ្រែ ឬតាំងដែលអ្នកដទៃ ធ្វើឲ្យកន្លងហួសប្រមាណ ហើយយកមកកាត់ចេញឲ្យត្រូវ និងប្រមាណក្តី ជីកកប់ទៅក្នុងផែនដីឲ្យសល់នូវត្រឹមល្មមប្រមាណក្តី ធ្វើឲ្យជាពិតានក្តី ធ្វើជាភនក្តី ហើយទើបប្រើប្រាស់អង្គុយ ដេក ។

៣-ដេក ឬអង្គុយលើតាំង ៤ ជ្រុង សូម្បីមានជើងខ្ពស់ហួសប្រមាណ ។

៤- គ្រែ តាំង ពូកដែលញាត់ដោយសំឡីគ ហើយយកមកកាយចេញ ទើបប្រើប្រាស់អង្គុយ ដេក ។

៥- ដេក ឬអង្គុយលើពូក ៥ យ៉ាង ។ មិនដេកគ្រាន់តែអង្គុយលើអាសនៈ ១៧ យ៉ាងដែលជា គិហិវិកដ ។

៦- ឆ្កួត ។

មានគុណបំណាច់ឲ្យលះបង់ **ដោជ្ជពូតណ្ហា** មានផលពីរគឺ ផលចំពោះសិក្ខាបទ ១ ផលចំពោះសីល ១ ។

**ឧច្ចាសយនមហាសយនា**

**សិក្ខាបទទី៩ ចប់**

## ជាតរូបរជតប្បដិគ្គហណា

## សិក្ខាបទទី១០

**ជាតរូបរជតប្បដិគ្គហណា** *កិរិយាទទួលកាន់យកនូវមាស និងប្រាក់ដោយខ្លួនឯងក្តី ឬប្រើអ្នកដទៃឲ្យទទួលកាន់យក ឬមួយត្រេកអរនូវមាស និងប្រាក់ដែលគេទុកដាក់ដើម្បីខ្លួន ។*

**រជតំ នាម កហាបណោ លោហមាសកោ ទារុមាសកោ ជតុមាសកោ យេ វោហារំ គច្ឆន្តិ ។** *កហាបណៈក្តី មាសកៈធ្វើដោយជាតិលោហ-មាសកៈក្តី ធ្វើដោយឈើក្តី មាសកៈធ្វើដោយជ័រក្តី រមែងដល់នូវវោហារ (គេចាយវាយបាន) ហៅថា ប្រាក់ ។*

*នៅក្នុងព្រះអដ្ឋកថា* ***សមន្តបា្បសាទិកា*** *(១) ភាគ ៣ ទំព័រ ៣៤៣-៣៤៤ បានខែពន្យល់ថា៖*

**ជាតរូបរជតន្តិ ឯត្ថ ជាតរូបន្តិ សុវណ្ណស្ស នាម ។ តំ បន យស្មាតថាគតស្ស វណ្ណសទិសំ ហោតិ តស្មា សត្ថុ វណ្ណោ វុច្ចតីតិ បទភាជនេ វុត្តំ ។ តស្សត្ថោ យោ សត្ថុ វណ្ណោ លោហវិសេសោ ឥទំ ជាតរូបំ នាមាតិ រជតំ បន សង្ខោ សិលា បវាឡំ រជតំ ជាតរូបន្តិអាទីសុ រូបិយំ វុត្តំ។**

*ត្រង់បទថា មាសប្រាក់នេះ ពាក្យថា ជាតរូប ជាឈ្មោះនៃមាស ។ ចំណែកមាសនោះ មានពណ៌បីដូចជាពណ៌នៃព្រះតថាគត ព្រោះហេតុនោះ ទើបលោកពោលទុកនៅក្នុង*

បទភាជនៈនោះថា លោហៈវិសេស មានពណ៌លឿងបីដូចជាពណ៌នៃព្រះសាស្តានេះ ឈ្មោះថា **ជាតរូប** ។ ចំណែកប្រាក់លោក ហៅថា **រូបិយៈ** ក្នុងពាក្យទាំងឡាយថា ស័ង្ខ សិលា ប្រពាល មាស ប្រាក់ជាដើម ។

**៩៨ បន យំកិញ្ចិ វោហារគាមធីយំ កហាបណាទិ អធិប្បេតំ ។ តេនេវស្ស បទភាជនេ កហាបណោ លោហមាសកោតិអាទិ វុត្តំ ។** តែក្នុងសិក្ខាបទនេះ លោកប្រាថ្នាយក កហាបណៈយ៉ាងណាមួយ រមែងដល់នូវវោហារ គេចាយវាយបាន ។ ព្រោះហេតុនោះឯង ក្នុងបទភាជនៈនៃបទថា **រជតំ** នោះ លោក ទើបពោលពាក្យថា កហាបណៈលោហមាសកៈជាដើម ។ **តត្ថ កហាបណោតិ សោវណ្ណមយោ វា រូបិយមយោ វា ចាកតិកោ វា ។** បណ្តាបទថា **កហាបណៈ** ជាដើមនោះ កហាបណៈដែលគេធ្វើដោយមាសក្តី ប្រាក់ក្តី កហាបណៈធម្មតាក្តី ឈ្មោះថា **កហាបណៈ ។ លោហមាសកោតិ តម្ពលោហាទីហិ កតមាសកោ ។** មាសកៈដែលគេធ្វើដោយស្ពាន់ជាដើម ឈ្មោះថា **លោហមាសកៈ ។ ទារុមាសកោតិ សារទារុនា វា វេឡុបេសិកាយ វា អន្តមសោ តាលបណ្ណេនបិ រូបំ ឆិន្ទិត្វា កតមាសកោ ។** មាសកៈ ដែលគេធ្វើដោយខ្លឹមឈើក្តី ធ្វើដោយថ្នាំងឫស្សីក្តី ដោយ ហោចទៅសូម្បីមាសកៈ ធ្វើដោយស្លឹកត្នោតឆ្លាក់ជារូប ឈ្មោះថា មាសកៈធ្វើដោយឈើ ។ **ជតុមាសកោតិ លាខាយ វា និយាសេន វា រូបំ សមុដ្ឋាបេត្វា**

**កតមាសកោ** ។ *មាសកៈធ្វើដោយលក្ខក្តី ដោយជ័រក្តី សូនឲ្យកើតឡើងជារូប ឈ្មោះថា មាសកៈ ធ្វើដោយជ័រ ។*

**វយេ វោហារំ គច្ឆន្តីតិ ឥមិនា បន បទេន យោ យោ យត្ថ ជនបទេ យទា យទា យេ វោហារំ គច្ឆតិ អន្តមសោ អដ្ឋិមយោបិ ចម្មមយោបិ រុក្ខផលពីជមយោបិ សមុដ្ឋាបិតរូបោបិ អសមុដ្ឋាបិតរូបោបិ សព្វោ សង្គហិតោ ។**

*ចំណែកដោយបទថា រមែងដល់នូវវោហារដែលគេចាយវាយបាន មានសេចក្តីថា លោកសង្គ្រោះយកវត្ថុទាំងអស់គឺវត្ថុណាៗ រមែងដល់នូវវោហារគេចាយវាយបាន ក្នុងជនបទឯណាៗ សម្រាប់គេចាយវាយក្នុងកាលណោះៗគឺ ក្នុងវេលាទិញលក់ដូរគ្នា បានដោយហោចទៅសូម្បីធ្វើដោយឆ្អឹងខ្លះ ដោយស្បែកខ្លះ ធ្វើដោយគ្រាប់ផ្លែឈើខ្លះ សូនឲ្យកើតឡើងជារូបខ្លះ មិនបានសូនឲ្យកើតជារូបខ្លះ (វត្ថុទាំងអស់នោះ រមែងមិនគួរ) ។*

**បដិគ្គហណា** *កិរិយាទទួល ។*

*នៅក្នុងសារត្ថទីបនីដីកា ត្រង់សិក្ខាបទទណ្ឌកម្មកថាវណ្ណនា ពោលថាៈ*

**តិវិធញ្ហិ បដិគ្គហណំ កាយេន វាចាយ មនសា** ។ *ក៏ក្នុងកិរិយាទទួលនេះ ប្រកបដោយអាការៈ ៣ យ៉ាងគឺកាយ ១ វាចា ១ ចិត្ត ១ ។*

*ការទទួលប្រកបដោយអាការៈ ៣ យ៉ាងគឺ :*

**១- កាយេន បដិគ្គហណំ ឧគ្គណ្ហាតំ** *ទទួលដោយកាយដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យទទួលដោយកាយ*

**២- វាចាយ បដិគ្គហណំ ឧគ្គណ្ហាធំ** *ទទួលដោយវាចាដោយខ្លួនឯង (ឬ)ប្រើអ្នកដទៃឲ្យទទួលដោយវាចា*

**៣- មនសា បដិគ្គហណំ សាទិយនំ** *ទទួលដោយចិត្ត(ឬមួយ)ត្រេកអរចំពោះមាស និងប្រាក់ដែលគេទុកដាក់ដើម្បីខ្លួន ។*

*ខ្ញុំបាទនឹងបញ្ជាក់សេចក្តីដែលថា ទទួលដោយចិត្ត ឬមួយត្រេកអរចំពោះមាស និងប្រាក់ដែលគេទុកដាក់ដើម្បីខ្លួន ។ ចំណុចត្រង់នេះ មានសេចក្តីសំខាន់ជាប់ទាក់ទងជាមួយភិក្ខុ ឬសាមណេរ និងអ្នកសមាទានសិក្ខាបទនេះ ។ តែខ្ញុំបាទ និងអារាធនាចំពោះភិក្ខុដាក់ទុកក្នុងទីនេះ ហើយមានសេចក្តីយ៉ាងណាៗ ចំពោះសាមណេរ និងអ្នកសមាទាន-សិក្ខាបទ ក៏មានសេចក្តីយ៉ាងនោះដែរ ។*

*នៅក្នុងសមន្តបាសាទិកា ព្រះអដ្ឋកថា ភាគ ៤ ទំព័រ ៣៤៥ ពន្យល់ថា :*

**ឧបនិក្ខិត្តសាទិយនេ បន ឥទំ អយ្យស្ស ហោតូតិ វុត្តេ សចេបិ ចិត្តេន សាទិយតិ គណ្ហិតុកាមោ ហោតិ កាយេន វា វាចាយ វា នយិទំ កប្បតីតិ បដិក្ខិបតិ អនាបត្តិ ។** *កាលបើទាយកពោលថា មាស និងប្រាក់នេះចូរជារបស់លោកម្ចាស់ចុះ ប្រសិនបើភិក្ខុត្រេកអរដោយចិត្តចង់ទទួល តែបានហាមឃាត់ដោយកាយ ឬដោយវាចាថា មាស និងប្រាក់នេះមិនគួរទេ យ៉ាងនេះមិនត្រូវអាបត្តិឡើយ ។*

**កាយវាចាហិ វា អប្បដិក្ខិបិត្វាបិ សុទ្ធចិត្តោ ហុត្វា នយិទំ អម្ហាកំ កប្បតីតិ ន សាទិយតិ អនាបត្តិយេវ ។**

*ម្យ៉ាងទៀត ទុកជាភិក្ខុមិនបានហាមឃាត់ដោយកាយ និងវាចាទេ តែភិក្ខុមានចិត្តបរិសុទ្ធមិនត្រេកអរដោយគិតថាមាស និងប្រាក់នេះ មិនគួរដល់យើងទេ យ៉ាងនេះក៏មិនត្រូវអាបត្តិដែរៗ*

**តីសុ ទ្វារេសុ ហិ យេន កេនចិ បដិក្ខិត្តំ បដិក្ខិត្តមេវ ហោតិ ។**

*ព្រោះថា ការហាមឃាត់ដោយទ្វារទាំង ៣ ទ្វារណាមួយ ឈ្មោះថា ហាមឃាត់ដោយពិត។*

**សចេ បន កាយវាចាហិ អប្បដិក្ខិបិត្វា ចិត្តេន អធិវាសេតិ កាយវាចាហិ កត្តព្វស្ស បដិក្ខេបស្ស អករណតោ អកិរិយាសមុដ្ឋានំ កាយទ្វារេ វចីទ្វារេ ច អាបត្តឹ អាបជ្ជតិ ។ មនោទ្វារេ បន អាបត្តិ នាម នត្ថិ ។**

*ប្រសិនបើភិក្ខុ មិនបានហាមឃាត់ដោយកាយ និងវាចាទេ ហើយទទួលដោយចិត្ត តែងតែត្រូវអាបត្តិ ដោយកាយទ្វារផង ដោយវចីទ្វារផង ជាអកិរិយាសមុដ្ឋាន ត្រូវអាបត្តិ ព្រោះមិនធ្វើនូវការហាមឃាត់ ដែលខ្លួនគប្បីធ្វើដោយកាយ និងវាចា ។ ចំណែកអាបត្តិដែលត្រូវដោយមនោទ្វារ មិនមានសោះឡើយ ។*

*សេចក្តីទាំងអស់ ពណ៌នាអំពីការទទួលដោយចិត្ត ។ ដូច្នេះឥឡូវនេះ ខ្ញុំបាទនឹងបញ្ជាក់សេចក្តីត្រង់ថា ឬមួយត្រេកអរចំពោះមាស និងប្រាក់ដែលគេទុកដាក់ដើម្បីខ្លួន មានវិនិច្ឆ័យដូចតទៅនេះ ។*

*នៅក្នុងគម្ពីរ សារត្ថទីបនីដីកា បានបញ្ជាក់ថា ៖*

**ឥទំ អយ្យស្ស ហោតូតិ ឯវំ សម្មុខា វា អាសុកស្មឹ នាម ឋានេ មម ហិរញ្ញសុវណ្ណំ អត្ថិ តំ តុយ្ហំ ហោតូតិ ឯវំ បរម្មុខា ឋិតំ វា កេវលំ វាចាយ វា ហត្ថមុទ្ទាយ តុយ្ហន្តិ វត្វា បរិច្ចត្តស្ស កាយវាចាហិ អប្បដិក្ខិបិត្វា ចិត្តេន សាទិយនំ ឧបនិក្ខិត្តសាទិយនំ នាម ។**

ទាយកតម្កល់ទុកនូវប្រាក់ និងមាសក្នុងទីចំពោះមុខ ហើយបវារណាចេញ ឈ្មោះដើម្បីលោកម្ចាស់ដោយវាចា ឬដោយលំពាស់ដៃយ៉ាងនេះថា ប្រាក់នេះចូរជារបស់លោកម្ចាស់ចុះដូច្នេះក្តី ទាយកតម្កល់ទុកនូវប្រាក់ និងមាសក្នុងទីកំបាំងមុខ ហើយបវារណាចេញ ឈ្មោះដើម្បីលោកម្ចាស់ដោយវាចា ឬដោយលំពាស់ដៃ យ៉ាងនេះថា ប្រាក់ និងមាសរបស់ខ្ញុំព្រះករុណាមាននៅក្នុងទីឯណោះ ប្រាក់ និងមាសនោះ ចូរជារបស់លោកម្ចាស់ចុះដូច្នេះក្តី ការមិនហាមឃាត់ទាយកនោះដោយកាយ ឬវាចា ហើយត្រេកអរដោយចិត្ត ឈ្មោះថា ត្រេកអរចំពោះមាសប្រាក់ដែលគេទុកដាក់ដើម្បីខ្លួន ។

នៅក្នុង **កង្ខាវិតរណី** អដ្ឋកថាបាតិមោក្ខ ភាគ ២ ទំព័រ ៥៨ ពន្យល់ថា :

**ឧបនិក្ខិត្តំ វា សាទិយេយ្យាតិ ឥទំ អយ្យស្ស ហោតូតិ ឯវំ សម្មុខា វា អសុកស្មឹ នាម ឋានេ មម ហិរញ្ញសុវណ្ណំ អត្ថិ តំ តុយ្ហំ ហោតូតិ ឯវំ បរម្មុខា ឋិតំ វា កេវលំ វាចាយ វា ហត្ថមុទ្ទាយ វា តុយ្ហន្តិ វត្វា បរិច្ចត្តំ យោ កាយវាចាហិ អប្បដិក្ខិបិត្វា ចិត្តេន អធិវាសេយ្យ អយំ សាទិ-យេយ្យាតិ វុច្ចតិ ។**

ត្រង់ពាក្យថា គប្បីត្រេកអរចំពោះមាស និងប្រាក់ដែលគេទុកដាក់ដើម្បីខ្លួន សេចក្តីថា ទាយកតម្កល់នូវប្រាក់ និងមាសក្នុងទីចំពោះមុខហើយ បវារណាចេញឈ្មោះថា ដើម្បីលោកម្ចាស់ ដោយវាចា ឬដោយលំពាស់ដៃយ៉ាងនេះថា ប្រាក់ និងមាសនេះ ចូរជារបស់លោកម្ចាស់ចុះដូច្នេះក្តី ទាយកតម្កល់ទុកនូវប្រាក់ និងមាសក្នុងទីកំបាំងមុខ ហើយបវារណាចេញ ឈ្មោះថា ដើម្បីលោកម្ចាស់ ដោយវាចា ឬដោយលំពាស់ដៃយ៉ាងនេះ ប្រាក់ និងមាសរបស់ខ្ញុំព្រះករុណាមាននៅក្នុងទីឯណោះ ប្រាក់ និងមាសនោះ ចូរជារបស់លោកម្ចាស់

ចុះដូច្នេះក្តី ភិក្ខុណាមិនហាមឃាត់ទាយកនោះ ដោយកាយ និងវាចា ហើយទទួលដោយចិត្ត ភិក្ខុនោះ ឈ្មោះថាត្រេកអរ ។

ដូច្នេះតាមសេចក្តីដែលមានមកនៅក្នុង **សារត្ថទីបនីដីកា និងកង្ខាវិតរណី** សឲ្យឃើញថា ការត្រេកអរទទួលដោយចិត្តនូវ **អកប្បិយកណ្ឌ** ដែលគេបវារណាខុសយ៉ាងនេះ ឈ្មោះថា ត្រេកអរចំពោះមាសប្រាក់ដែលគេទុកដាក់ដើម្បីខ្លួន ចំពោះសាមណេរ និងអ្នកសមាទាននូវសិក្ខាបទនេះ គប្បីកាន់យកតាមសេចក្តីពណ៌នាមកហើយនេះឯង។

មានបុគ្គលខ្លះពោលថា ទុកដាក់មាស និងប្រាក់ដោយខ្លួនឯងក្តី គេទុកដាក់មាស និងប្រាក់ក្នុងដៃកប្បិយការកៈក្តី ឲ្យតែត្រេកអរត្រូវដូចគ្នា និយាយយ៉ាងនេះ មិនត្រឹមត្រូវទៅតាមព្រះពុទ្ធដីកាទេ ព្រោះនៅក្នុងវិន័យបិដក **មហាវគ្គ** ទុតិយភាគ ៧|៣៩៧ ព្រះអង្គទ្រង់ត្រាស់សម្តែងថា ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងឡាយមានសទ្ធាជ្រះថ្លា មនុស្សទាំងនោះទុកដាក់មាស និងប្រាក់ក្នុងដៃកប្បិយការកៈទាំងឡាយ ដោយពាក្យថា របស់ណាគួរដល់លោកម្ចាស់ ចូរអ្នកទាំងឡាយប្រគេនរបស់នោះ ដោយមាស និងប្រាក់នេះចុះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុត្រេកអរចំពោះវត្ថុជា កប្បិយៈ (ដែលកើតអំពីមាស និងប្រាក់នោះបាន) ម្នាលភិក្ខុទាំងឡាយ តែតថាគតមិនពោលថា ត្រូវអ្នកត្រេកអរ ត្រូវអ្នកស្វែងរកមាស និង ប្រាក់ដូច្នេះ ដោយបរិយាយណានីមួយឡើយ ។

***ពាក្យដែលខ្ញុំបាទលើកមកនេះ វាមិនដូចអ្នកនិយាយនោះទេ ព្រោះព្រះអង្គទ្រង់អនុញ្ញាតឲ្យភិក្ខុប្រើប្រាស់វត្ថុដែលកើតអំពីមាស និងប្រាក់ដែលគេបវារណាត្រឹមត្រូវតាមព្រះវិន័យ លើកលែងតែអ្នកបវារណានោះ មិនចេះបវារណាឲ្យបានត្រឹមត្រូវ ទៅតាមព្រះវិន័យ ទើបភិក្ខុត្រេកអរចំពោះអ្នកដែលទុកដាក់មាស និងប្រាក់ឲ្យនោះត្រូវទោស ចំណែកសាមណេរ ឬឧបាសក ឧបាសិកា អ្នករក្សាសីល ១០ ក៏ដូចគ្នា ។***

ឧបាសក ឧបាសិកាទាំងឡាយត្រូវចេះបវារណាបច្ច័យ ៤ ព្រះសង្ឃឲ្យត្រឹមត្រូវតាមព្រះវិន័យ ទើបលោកអាចប្រើប្រាស់បាន ។ ចំពោះការបវារណាបច្ច័យ ៤ នេះលោកសម្តែងទុកនៅក្នុងព្រះអដ្ឋកថា **សមន្តបាសាទិកា** ថា ៖

**ទី ១– កប្បិយការកានំ ហត្ថេ ភវិស្សតិ តេហ៍ តុម្ហេ ចត្តារោ បច្ចយេ បរិភុញ្ជថ ។**

*រូបិយវត្ថុមានចំនួន......មាននៅក្នុងដៃនៃកប្បិយការកៈ (ឈ្មោះនេះ) សូមលោកម្ចាស់ទាំងឡាយ ប្រើប្រាស់បច្ច័យបួនតែម្យ៉ាងចុះ ។*

**ទី២–មម បុរិសានំ ហត្ថេ ភវិស្សតិ តេហ៍ តុម្ហេ ចត្តារោ បច្ចយេ បរិភុញ្ជថ ។**

*រូបិយវត្ថុមានចំនួន.......មាននៅក្នុងដៃរបស់ខ្ញុំព្រះករុណា សូមលោកម្ចាស់ទាំងឡាយ ប្រើប្រាស់បច្ច័យបួនតែម្យ៉ាងចុះ ។*

**ទី៣–មយ្ហំ ហត្ថេ ភវិស្សតិ តេហ៍ តុម្ហេ ចត្តារោ បច្ចយេ បរិភុញ្ជថ ។**

*រូបិយវត្ថុមានចំនួន.......មាននៅក្នុងដៃរបស់ខ្ញុំព្រះករុណា សូមលោកម្ចាស់ទាំងឡាយ ប្រើប្រាស់បច្ច័យបួនតែម្យ៉ាងចុះ ។*

## បើព្រះគុណម្ចាស់ច្រើនអង្គគប្បីបវារណាថា

*បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន អកប្បិយវត្ថុមានចំនួន .............. ទុកដាក់ក្នុងដៃកប្បិយ–ការកៈរបស់ព្រះគុណម្ចាស់ទាំងឡាយ សូមព្រះគុណម្ចាស់ទាំងឡាយនិមន្តប្រើប្រាស់នូវបច្ច័យទាំងឡាយតាមសមគួរដល់សមណបរិភោគចុះ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដើម្បីសេចក្តីចម្រើន ដល់ខ្ញុំព្រះករុណាទាំងឡាយ អស់កាលជាអង្វែងទៅហោង ។*

*នេះជាពិធីបវារណាដែលត្រឹមត្រូវទៅតាមព្រះវិន័យ បើគេបវារណាឃ្លៀងឃ្លាត ពីនេះ កិក្ខុឬសាមណេរមិនអាចប្រើប្រាស់បានឡើយ បើគេបវារណាខុសហើយ ត្រេកអរមែងត្រូវទោស ។*

ចំពោះនៅក្នុងសិក្ខាបទនេះ បើទាយកយកលុយដាក់ទុកក្នុងស៊ីង ឬកញ្ចប់សាដក យកវត្ថុទាំងឡាយនេះទៅប្រគេនភិក្ខុ ឬសាមណេរ ឬអ្នកសមាទានទូវសិក្ខាបទនេះ ហើយបានប្រគេន ឬជូនដល់អ្នកនោះ សូម្បីមិនដឹងថា មានលុយនៅក្នុងស៊ីង ឬ កញ្ចប់សាដក ភិក្ខុក្នុងខណៈទទួលត្រូវអាបត្តិបាចិត្តិយៈ សាមណេរត្រូវទណ្ឌកម្ម ហើយដាច់សីល ចំពោះអ្នកសមាទានសិក្ខាបទនេះ ក៏ដាច់ខូចសិក្ខាបទ ជាតរូបរជតហ្នឹងឯង ព្រោះថាសិក្ខាបទនេះជាអចិត្តកៈ ទោះមានចិត្តក្លែងក្តី មិនក្លែងក្តី ដឹងឬមិនដឹងក្តី មិនជាប្រមាណក្នុងសិក្ខាបទនេះទេ ឲ្យតែទទួលនូវមាស និងប្រាក់ហើយ រមែងដាច់ខូច **ជាតរូបរជតសិក្ខាបទ** ហ្នឹងឯង ។

### សិក្ខាបទនេះមានអង្គ ៣ គឺ

**១-ជាតរូបរជតំ** មាស ឬប្រាក់ដែលជាអកប្បិយកណ្ឌ

**២-អត្តុទ្ទិសតា** ចំពោះជារបស់ខ្លួន

**៣-បដិគ្គណ្ហានិ** បានទទួលកាន់យកដោយខ្លួនឯងក្តី ប្រើគេឲ្យទទួលកាន់ យកក្តី ឬមួយត្រេកអរចំពោះមាស និងប្រាក់ដែលគេទុកដាក់ដើម្បីខ្លួន ដោយអកប្បិយវាចា ។

**ជាតរូបរជតៈ** ជាសកាវៈ ជាសាណត្តិកៈ មានសមុដ្ឋាន ៦ គឺ :

**១-កាយតោ** ទោសកើតឡើងអំពីកាយ

**២-វាចតោ** ទោសកើតឡើងអំពីវាចា

**៣-កាយវាចតោ** ទោសកើតឡើងអំពីកាយ និងវាចា

**៤-កាយចិត្តតោ** *ទោសកើតឡើងអំពីកាយ និងចិត្ត*

**៥-វាចាចិត្តតោ** *ទោសកើតឡើងអំពីវាចា និងចិត្ត*

**៦-កាយវាចាចិត្តតោ** *ទោសកើតឡើងអំពីកាយ វាចា និងចិត្ត ។*

*ជាកិរិយាក៏មាន ជាអកិរិយាក៏មាន ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម និងជាវចីកម្ម មានចិត្ត ៣ ជាធម្មៈ ជាកោដ្ឋាសៈ មានសង្ខារជាអារម្មណ៍ មានវេទនា ៣ មានមូលពីរគឺ លោភមូល ១ មោហមូល ១ ជាអនិពទ្ធសីល ជាសមាទាន មានសមាទានវិរតិ ១ ជាវត្ថុកាម និងកិលេសកាម ។*

**អង្គាបជ្ជនៈ** *ហេតុដែល មិនត្រូវទោសមាន ២ យ៉ាងគឺ ដែលបានរើសយកដោយខ្លួនឯងឬប្រើគេឲ្យរើសយកនូវរូបិយៈ ដែលធ្លាក់ចុះក្នុងទីលំនៅរបស់ខ្លួនដោយគិតថា រូបិយៈរបស់អ្នកណា អ្នកនោះនឹងយកទៅចុះ (គឺរើសទុកឲ្យគេ) ១ ធ្លូត ១ មានគុណបំណាច់លះបង់នូវរូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ។*
*មានផលពីរគឺ ផលចំពោះសិក្ខាបទ ១ ផលចំពោះសីល ១ ។*

*នៅក្នុងគម្ពីរ* ***មង្គលត្ថទីបនី*** *ភាគ ៣ ទំព័រ ១៦៤ បានបញ្ជាក់សិក្ខាបទទាំងឡាយថា :*

**ឥតិ សត្តមជ្ជមង្គទ្វយមេកំ កត្វា អដ្ឋង្គានិ ហោន្តិ ។ តេន ខុទ្ទកចាបវណ្ណនាយំ អាគតោ ទ្វេ ចតុត្ថបញ្ចមានិ ច ឧបាសកានំ សាមណេរានញ្ច សាធារណានិ និច្ចសីលវសេន ។ ឧបោសថវសេន ឧបាសកានំ សត្តមជ្ជមង្គញ្ចេកំ អង្គំ កត្វា សព្វបច្ចិមវជ្ជានិ សព្វានិបិ**

**សាមណេរេហិ សាធារណានិ ។ សព្វបច្ឆិមម្បន សាមណេរានមេវ វិសេសភូតន្តិ វុត្តំ ។**

*សិក្ខាបទទាំងឡាយ ព្រោះរួមអង្គទី ៧ និងទី ៨ ទាំងពីរអង្គនេះ ចូលជាមួយគ្នា ទើបបានអង្គ ៨ ដោយប្រការយ៉ាងនេះ ។ ព្រោះហេតុនោះឯង ក្នុងអដ្ឋកថា ខុទ្ទកបាឋៈ លោកទើបពោលទុកថា សិក្ខាបទ ២ ខាងដើម និងសិក្ខាបទទី ៤ និងទី ៥ ទូទៅដល់ឧបាសកទាំងឡាយ និងសាមណេរទាំងឡាយ ដោយអំណាចជានិច្ចសីល ។ អង្គនៃសិក្ខាបទទាំងឡាយ អង្គទី ៧ និងទី ៨ របស់ឧបាសកទាំងឡាយរួមជាអង្គមួយ ដោយអំណាចឧបោសថ វៀរលែងអង្គចុងបំផុតនៃអង្គទាំងអស់ ទូទៅជាមួយសាមណេរទាំងឡាយ ។ តែសិក្ខាបទជាអង្គទីបំផុត (ជាតរូប) ជាអង្គពិសេស សម្រាប់តែសាមណេរទាំងឡាយប៉ុណ្ណោះ ។*

*នៅក្នុងគម្ពីរ **សារត្ថទីបនីដីកា** មហាខន្ធកៈវគ្គ ត្រង់សិក្ខាបទទណ្ឌកម្មវត្ថុកថា វណ្ណនាបានបញ្ជាក់សិក្ខាបទទាំងឡាយថា ៖*

**ឥមានិ បន ទស សិក្ខាបទានិ គហដ្ឋានម្បិ សាធារណានិ ។ វុត្តញ្ហេតំ វិសុទ្ធិមគ្គេ "ឧបាសកឧបាសិកានំ និច្ចសីលវសេន បញ្ច សិក្ខាបទានិ សតិ វា ឧស្សាហេ ទសឧបោសថង្គវសេន អដ្ឋាតិ ឥទំ គហដ្ឋសីលន្តិ "។ឯត្ថ ហិ ទសាតិ សាមណេរេហិ រក្ខិតព្វសីលមាហា យជិកាភាធិនំ វិយ ។**

*ចំណែកសិក្ខាបទទាំងឡាយ ១០ នេះ ទូទៅសូម្បីដល់គ្រហស្ថទាំងឡាយ ។ ព្រោះហេតុនោះឯង ទើបលោកពោលទុកក្នុងគម្ពីរវិសុទ្ធិមគ្គថា សីលរបស់គ្រហស្ថដូច្នេះ គឺសិក្ខាបទទាំងឡាយ ៥ របស់ឧបាសក និងឧបាសកទាំងឡាយ ដោយអំណាចជា និច្ចសីល ឬថាបើមានឧស្សាហៈ គប្បីរក្សាទាំង ១០ សិក្ខាបទ និងរក្សាសិក្ខាបទ ៨ ដោយអំណាច*

នៃអដ្ឋង្គឧបោសថ ។ មែនពិត ក្នុងពាក្យនេះសមដូចជា ព្រះពុទ្ធឃោសាចារ្យ ពោលដល់សីលដែលសាមណេរ គប្បីរក្សាហាក់ដូចជាសីលរបស់យដិកាឧបាសកជាដើម ។

**ជាតរូបរជតប្បដិគ្គហណា**

**សិក្ខាបទទី១០ ចប់**

## អកុសលកម្មបថ

គន្លង ឬផ្លូវនៃអំពើអកុសល ហៅថាអកុសលកម្មបថ[១៤] មាន ១០ យ៉ាងគឺ **កាយកម្ម** អំពើដែលសម្រេចដោយកាយ មាន ៣ យ៉ាង, **វចីកម្ម** អំពើដែលសម្រេចដោយវាចា មាន ៤ យ៉ាង, **មនោកម្ម** អំពើដែលសម្រេចដោយចិត្ត មាន ៣ យ៉ាង, រួមត្រូវជា ១០ យ៉ាង ។ ចំណែកកុសលកម្មបថ[១៥] ក៏មាន ១០ គឺកាយកម្ម ៣ វចីកម្ម ៤ មនោកម្ម ៣ ដូចអកុសលកម្មបថដែរ ខុសតែមួយជាអកុសលកម្មបថ មួយជាកុសលកម្មបថប៉ុណ្ណោះ ។

### កាយកម្ម ៣ យ៉ាង

**១- បាណាតិបាតោ** កិរិយាសម្លាប់សត្វដោយកាយរបស់ខ្លួន ឬប្រើឲ្យគេសម្លាប់ដោយវាចា ។

១៤-១៥ បបញ្ចសូទនី អដ្ឋកថា មជ្ឈិម. មូល. ចូឡយមកវគ្គ ត្រង់សាលេយ្យកសូត្រទី១, មជ្ឈិម. មូល. ចូឡយមកវគ្គ ត្រង់វេរញ្ជកសូត្រទី២ ២២।២៤១ កុ.(កុសលកម្មបថ).២២।២៤៧, មជ្ឈិម. មូល. ត្រង់មូលបរិយាយវគ្គ សម្មាទិដ្ឋិសូត្រ ២០।១៥៤ កុ. ២០।១៥៤ ។ សំ. និទានវគ្គ ទសកម្មបថវគ្គទី៣ ត្រង់ទសកម្មបថសូត្រ ទី៥ ៣២।៥៨ កុ. ៣២।៥៧, សារត្ថប្បកាសិនី អដ្ឋកថា សំ. និទានវគ្គ ទសកម្មបថវគ្គទី៣ ត្រង់ទសកម្មបថសូត្រទី៥, អំ. ទសក-ឯកនិបាត ជាណុស្សោណិវគ្គទី២ ៥១।១២៣, បឋមវគ្គទី១ ធម្មបរិយាយសូត្រទី៥ និងបឋមកម្មសូត្រទី៦ ៥១।១៦៣ កុ. ៥១।១៦៦, មនោរថបូរណី អដ្ឋកថា អំ. ទសក-ឯកនិបាត បឋមវគ្គទី១ ធម្មបរិយាយសូត្រទី៥ និងបឋមកម្មសូត្រទី៦, មជ្ឈិម. មជ្ឈិម. ព្រាហ្មណវគ្គ ត្រង់អស្សលាយនសូត្រ ២៥।៦១ កុ. ២៥।៦១, បបញ្ចសូទនី អដ្ឋកថា មជ្ឈិម. មូល. ចូឡយមកវគ្គ ត្រង់សាលេយ្យកសូត្រទី១ ។

**២- អទិន្នាទានំ** *កិរិយាលួចលាក់ឆក់ដណ្តើមយកទ្រព្យគេ ដោយកាយរបស់ខ្លួន ឬប្រើគេឲ្យលួចលាក់ដណ្តើមដោយវាចា ។*

**៣-កាមេសុ មិច្ឆាចារោ** *កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺធ្វើនូវមេថុន-សេវនៈនឹងស្ត្រីដែលមានគេហួងហែងរក្សា ។*

## វចីកម្ម ៤ យ៉ាង

**១-មុសាវាទោ** *កិរិយាពោលនូវពាក្យកុហក ។*

**២-បិសុណាវាចា** *កិរិយាពោលនូវពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ ។*

**៣- ផរុសវាចា** *កិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម ។*

**៤-សម្ផប្បលាបោ** *កិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។*

## មនោកម្ម ៣ យ៉ាង

**១- អភិជ្ឈា** *ចិត្តសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបម្រុងនឹងឲ្យបានមកជាទ្រព្យរបស់ខ្លួន ។*

**២-ព្យាបាទោ** *ចិត្តចងគុំគួនគិតប៉ងនឹងឲ្យអ្នកដទៃដល់នូវសេចក្តីវិនាស ។*

**៣-មិច្ឆាទិដ្ឋិ** *គំនិតយល់ខុសហើយប្រកាន់ឡើងថាជាត្រូវ ។*

**អកុសលកម្មបថ ១០**

**ចប់ដោយសង្ខេបតែប៉ុណ្ណោះសិន**

# បិសុណាវាចាសិក្ខាបទទី ៥

*សិក្ខាបទមានបាណាតិបាត អទិន្នាទាន, កាមេសុ មិច្ឆាចារ, មុសាវាទ, មិនបានវិនិច្ឆ័យ ក្នុងអកុសលកម្មបថ ១០ នេះទេ ព្រោះបាននិយាយក្នុងសីល ១០ និងសីល ៥ ហើយ ខ្ញុំសូមលើកតែសិក្ខាបទទី ៥ គឺ* **បិសុណាវាចា** *មកអធិប្បាយតទៅះ*

**បិសុណាវាចា** *បើញែកបទបាន ២ បទគឺ* **បិសុណា+វាចា, បិសុណា** *ប្រែថា កិនឲ្យល្អិត ឬការធ្វើឲ្យបែកខ្ចាត់ខ្ចាយ,* **វាចា** *<u>ប្រែថា</u> ពាក្យនិយាយ, កាលបើរួមចូលគ្នាជា* **បិសុណាវាចា** *<u>ប្រែថា</u> ពាក្យនិយាយដែលកិនបំបែកសាមគ្គី ឲ្យបែកបាក់ខ្ចាត់ខ្ចាយ ដូចវចនត្ថៈថា* **បិសតិ សមគ្គេ សត្តេ ភិន្ទតីតិ = បិសុណា** *វាចាឯណាដែលកិនបំបែកសាមគ្គី គឺធ្វើឲ្យខ្ចាត់ខ្ចាយដូច្នោះ វាចានោះ ឈ្មោះថា* **បិសុណា, វទន្តិ ឯតាយាតិ = វាចា** *បុគ្គលទាំងឡាយ រមែងពោលដោយចេតនានោះ ដូច្នោះចេតនាដែលជាហេតុនៃការពោលនោះ ឈ្មោះថា* **វាចា, បិសុណា ច សា វាចា ចាតិ = បិសុណាវាចា** *ពាក្យពោលដែលកិនកម្ទេចសាមគ្គី គឺធ្វើឲ្យបែកខ្ចាត់ខ្ចាយ ជាចេតនាដែលជាហេតុនៃការពោលនោះឯង ដូច្នោះ ឈ្មោះថា* **បិសុណាវាចា។**

*ឧទាហរណ៍ ដូចនាយ* **ក** *និងនាយ* **ខ** *ជាមិត្តកត្តិនឹងគ្នា មានសាមគ្គីស្រឡាញ់គ្នា តមកមានបុគ្គលទី* **៣** *ចូលមក និយាយស៊កសៀតជាមួយនាយ* **ក** *ថា នាយ* **ខ** *ដើរនិយាយដើមត្មះតិះដៀលនាយ* **ក** *ផ្សេងៗ ធ្វើឲ្យនាយ* **ក** *យល់ខុសកើតបែកបាក់គ្នា ជាមួយ*

នាយ ១ ដូច្នេះ ពាក្យនិយាយបែបនេះឯងហៅថា **បិសុណាវាចា**ម្យ៉ាងទៀតន័យរបស់ពាក្យថា **បិសុណា** នេះ បើពោលតាមបទដើម គឺបានដល់ **បិយសុញ្ញករណា** តែដែលជាបិសុណា គឺប្រព្រឹត្តទៅដោយន័យ និរុត្តិវេយ្យាករណ៍ គឺលប់អក្សរដទៃចេញនៅសល់តែ **បិសុណា** ដូចវចនត្ថៈថា **បិយំ សុញ្ញំ ករោតីតិ = បិសុណា** ពាក្យពោលឯណា រមែងធ្វើខ្លួនឯងឲ្យជាទីស្រឡាញ់ ហើយធ្វើអ្នកដទៃសូន្យចាកសេចក្ដីស្រឡាញ់ ដូច្នោះពាក្យពោលនោះ ឈ្មោះថា **បិសុណា** ។

**អង្គនៃបិសុណាវាចាមាន ៤ គឺ**

**១–ភិន្ទិតព្វោ** បុគ្គលដែលត្រូវធ្វើឲ្យបែកគ្នា

**២–ភេទបុរេក្ខារោ** មានចេតនាចង់ឲ្យបែកគ្នា

**៣–បយោគោ** ព្យាយាមធ្វើឲ្យគេបែកគ្នា

**៤–តទត្ថ ជាននំ** អ្នកស្ដាប់យល់សេចក្ដីនោះ ។

ដូចគាថាសម្ដែងថា:

**បិសុណាយ ភិន្ទិតព្វោ តប្បរបិយកម្យតា**

**វាយាមោ ជាននំ ចតុ– ភិន្នេ កម្មបថោ ភវេ ។**

ប្រែថា អង្គនៃបិសុណាវាចាមាន ៤ គឺអ្នកដែលត្រូវធ្វើឲ្យបែកគ្នា ១
មានចេតនាបំណងឲ្យគេបែកគ្នា និងប្រាថ្នាឲ្យគេស្រឡាញ់ ១
ព្យាយាមឲ្យគេបែកគ្នា ១ អ្នកស្ដាប់ដឹងសេចក្ដីនោះ ១

កាលអ្នកត្រូវស៊កសៀតនោះ កើតបែកបាក់គ្នាហើយ ក៏ឈ្មោះថា កន្លងកម្មបថក្នុងគាថាដែលសម្ដែងអំពីអង្គទី ២ ដែលពោលថា **តប្បរបិយកម្យតា** គឺមានចេតនាប្រាថ្នា

ឲ្យគេបែកគ្នា និងមានប្រាថ្នាឲ្យគេស្រឡាញ់ខ្លួននោះ ការមានចេតនា ប្រាថ្នាឲ្យគេបែកគ្នា ជាការសំខាន់ ចំណែកការមានសេចក្ដីប្រាថ្នាឲ្យគេស្រឡាញ់ខ្លួននោះ មិនជាការសំខាន់ទេ គ្រាន់តែសម្ដែងឲ្យដឹងថា ការពោល **បិសុណាវាចា** របស់បុគ្គលខ្លះ មានបំណងដូច្នេះផង ក៏មានដែរ ចំណែកប្រយោគនោះ មាន ២ យ៉ាង គឺកាយប្រយោគ១ និងវចីប្រយោគ១ ។

**កាយបយោគ** ការស៊ើកសៀតផ្លូវកាយ មានការសម្ដែងកិរិយាអាការៈឲ្យភាគីម្ខាង ដឹងសេចក្ដីបំណងរបស់ខ្លួន ឧទាហរណ៍ស្វាមីភរិយា ២ នាក់ ស្វាមីចេញទៅធ្វើការ ភរិយាលបទៅលេងបៀនៅផ្ទះអ្នកជិតខាង កាលស្វាមីត្រលប់មកវិញ មិនឃើញភរិយានៅផ្ទះ ក៏សួរញាតិរបស់ខ្លួនដែលនៅក្នុងផ្ទះជាមួយគ្នា ញាតិនោះមិនពេញចិត្តនឹងភរិយានោះ មកយូរហើយ ចង់ឲ្យស្វាមីនោះបែកបាក់ភរិយា តែមិនប្រាប់ដោយវាចា ប្រើម្រាមដៃអង្អុលឲ្យដឹងថា ភរិយាទៅលេងបៀនៅផ្ទះជិតខាង ស្វាមីដឹងក៏មិនពេញចិត្តនឹងភរិយា លុះភរិយាត្រឡប់មកវិញ ក៏កើតឈ្លោះវិវាទទាស់ទែង លែងលះ បែកបាក់គ្នា ការសម្ដែងកិរិយាស៊ើកសៀតដូច្នេះ ឈ្មោះថា ស៊ើកសៀត តាមផ្លូវកាយ ។

**វចីបយោគ** ការស៊ើកសៀតតាមផ្លូវវាចា និងនិយាយឲ្យបុគ្គល ២ ភាគី បែកបាក់គ្នា ដូចមានរឿងដំណាលថា នៅក្នុងភូមិមួយមានស្វាមីភរិយាមួយគ្រួសារ ស្វាមីជាពូជអម្បូរអ្នកស្រុកលើ ឯភរិយាជាអម្បូរអ្នកស្រុកក្រោម ទាំងពីរនាក់ មានសេចក្ដីស្រឡាញ់គ្នាណាស់ ជាហេតុឲ្យស្រីដែលនៅផ្ទះជិតខាង មានសេចក្ដីច្រណែន ទើបមានគំនិតរួមគ្នាចង់ឲ្យស្វាមីភរិយាទាំងពីរនេះ បែកបាក់គ្នា ដោយលបទៅខ្សឹបខ្សៀវ ប្រាប់បុរសជាស្វាមីថា ភរិយារបស់អ្នកឯងជាធ្មប់អាប ពេលយប់រំលងអធ្រាត្រ ខណៈដែលអ្នកឯង ដេកលក់ ភរិយាអ្នកឯងក្រោកឡើងចេញដើររកស៊ី បែរមុខចេញទៅ គេបានដើរកន្ទុងខ្លួន អ្នកឯងដើម្បីសណ្ដំមិនឲ្យអ្នកឯងភ្ញាក់ដឹងខ្លួន ភរិយាអ្នកឯងចេញរកស៊ីរាល់ៗយប់ ក្រោយមកស្រីពួកនោះ បានលបទៅជួបភរិយារបស់បុរសនោះប្រាប់ថា ស្វាមីរបស់នាងមិនមែនជាមនុស្សធម្មតាទេ ពួកអ្នកស្រុកលើបានប្រាប់ថា ស្វាមីរបស់នាងជាខ្មោចបិសាច អាចហោះហើរពេលយប់អធ្រាត្រ បានដើររកស៊ីតែរបស់ស្មោកគ្រោក បើនាងចង់ដឹងការពិត

យប់បើប្តីនាងដេកលក់ ឲ្យស្ទាបមើលត្រង់គូថ នឹងមានដុះកន្ទុយស្វាបខ្វីៗ ជាប្រាកដ អ្នកទាំងពីរបានស្តាប់ពាក្យ គេនិយាយប្រាប់ដូច្នោះ ក៏ជឿម្នាក់ៗ លួចតាមដានគ្នាទៅវិញទៅមករៀងៗ ខ្លួន ដើម្បីឲ្យដឹងការពិត ថ្ងៃមួយស្វាមីភរិយានោះ ចូលទៅដេកសម្ងំធ្វើជាដេកលក់ ភរិយាគិតថា ស្វាមីលក់ហើយក៏ក្រោកឡើងយកដៃទៅស្ទាបមើលត្រង់គូថរបស់ស្វាមី ឯចំណែកស្វាមីគិតថា ភរិយារបស់អញជាធ្មប់អាបកំពុងដើរកន្ទង់ខ្លួនអញហើយ ក៏លើកជើងធាក់ភរិយា នោះខ្ទាតចេញទៅ ឯភរិយាក្រោធខ្លាំងក្រោកឡើងជេរប្រទេចស្វាមីថា អាខ្មោចព្រាយបិសាច ស្វាមីក៏ជេរនាងមីចោរធ្មប់អាប កើតមានការឈ្លោះ ទាស់ទែងគ្នារហូតទៅ លទ្ធផលចុងក្រោយស្វាមីភរិយាមួយគូនេះ បាក់បែកគ្នា ព្រោះតែអាស្រ័យការនិយាយពាក្យស៊ុកសៀត ពីពួកស្រីដែលនៅជិតខាងគ្នានោះឯង ដោយអ្នកនិយាយនោះក៏គ្មានប្រាថ្នាឲ្យគេស្រឡាញ់ខ្លួន ឯរឿងដែលពោលនោះ ក៏មិនពិត ដូច្នេះស្ត្រីដែលពោលនោះ ក៏ឈ្មោះថា កន្ទង់កម្មបថ ព្រោះអ្នកត្រូវស៊ុកសៀតនោះបែកបាក់គ្នា ។

ការពោលបិសុណាវាចានេះ ទោះបីគ្រប់អង្គ ៤ តែបើអ្នកត្រូវស៊ុកសៀត មិនបែកបាក់គ្នា ក៏គង់ជាកាយសាមគ្គី ចិត្តសាមគ្គី អ្នកពោលនោះ មិនចាត់ជាកន្ទង់កម្មបថ ដូចព្រះពុទ្ធឃោសាចារ្យសម្តែងទុកក្នុង *អដ្ឋសាលិនី* អដ្ឋកថាថា៖ **បរេ បនេ អភិន្នេ កម្មបថភេទោ នត្ថិ ភិន្នេយេវ** ប្រែថា ទោះបីគ្រប់អង្គក្តី តែអ្នកនោះ មិនបែកបាក់គ្នាក៏គ្មានការកន្ទង់កម្មបថ បើមានការបែកបាក់គ្នាទើបចាត់ថាកន្ទង់កម្មបថ ។

## ចែកបិសុណាវាចាដោយអប្បសាវជ្ជៈ និងមហាសាវជ្ជៈ

បើអ្នកដែលត្រូវគេស៊ុកសៀតនោះបែកបាក់គ្នា ជាអ្នកមិនមានធម៌ អ្នកពោលជាអ្នកមានទោសជាអប្បសាវជ្ជៈ គឺទោសតិច បើអ្នកត្រូវគេស៊ុកសៀតនោះ ជាអ្នកមានសីលមានធម៌ អ្នកពោលមានទោសជាមហាសាវជ្ជៈ គឺមានទោសច្រើន ។

**បិសុណាវាចា**

**សិក្ខាបទទី ៥ ចប់**

## ផរុសវាចាសិក្ខាបទទី ៦

**ផរុសវាចា** បើញែកបទបាន ២ បទ គឺ **ផរុស+វាចា**, **ផរុស** ប្រែថា អាក្រក់, **វាចា** ប្រែថា ពាក្យពោល កាលបើរួមគ្នាជា **ផរុសវាចា** ប្រែថា ពោលពាក្យអាក្រក់បានដល់ការជេរ ប្រទេច ផ្ដាសា ដូចវចនត្ថៈ ថាៈ **ផរុសំ ករោតីតិ = ផរុសា** ពាក្យពោលឯណា ដែលអាក្រក់ គ្រោតគ្រាត ព្រោះហេតុនោះ ពាក្យនុ៎ះ ឈ្មោះថា **ផរុសា** បានដល់ការជេរប្រទេចផ្ដាសាផ្សេងៗ ពោលដោយអន្តធម៌បានដល់ចេតនាដែលនៅក្នុងទោសមូលចិត្តដែលជាហេតុនៃការជេរ ប្រទេច ផ្ដាសាផ្សេងៗ ។

ពាក្យថា **ផរុសា** បើពោលតាមវចនត្ថៈដែលសម្ដែងមក បានដល់ **ផរុសំ ករោ–តីតិ=ផរុសករណា** លុបពាក្យថា ករុណាចេញតាមន័យនិរុត្តិវេយ្យាករណ៍ សល់ត្រឹម **ផរុសា** ម្យ៉ាងទៀតពាក្យថា **ផរុសវាចា** ចែកជា ៣ បទគឺ **ផរ+ឧស+ វាចា**, **ផរ** ប្រែថា ផ្សាយ, **ឧស** ប្រែថា ក្ដៅក្រហាយ, **វាចា** ប្រែថា ពោលពាក្យ កាលរួមចូលគ្នាជា **ផរុសវាចា** ប្រែថា ពោលពាក្យដែលធ្វើឲ្យកើតសេចក្ដីក្ដៅក្រហាយ ដូចវចនត្ថៈ ថា : **ហទយំ ផរមានា ឧសតិ ទហតីតិ = ផរុសា** ពាក្យពោលឯណា ធ្វើឲ្យកើតសេចក្ដីក្ដៅក្រហាយ ផ្សាយទៅដល់បេះដូង ដូច្នោះពាក្យពោលនោះ ឈ្មោះថា **ផរុសា**, **ផរុសា ច សា វាចា ចាតិ = ផរុសវាចា** កើតយ៉ាងអាក្រក់ផង យ៉ាងអាក្រក់នោះគឺវាចាផង ដូច្នោះទើប ឈ្មោះថា ផរុសវាចា (ឬប្រែម្យ៉ាងទៀតតាមវចនត្ថៈទី២) រមែងធ្វើ

សេចក្តីក្តៅក្រហាយ ឲ្យផ្សាយទៅក្នុងបេះដូងផង នោះគឺវាចាផង ដូច្នោះទើប ឈ្មោះថា **ផរុសវាចា**។

វាចាយ៉ាងអាក្រក់ដែលហៅថា ផរុសវាចានេះ អ្នកដែលបានស្តាប់ហើយ អត់ទ្រាំមិនបាន មានន័យថា ធ្វើចិត្តរបស់អ្នកស្តាប់មិនសប្បាយ បីដូចត្រូវកាប់ចិញ្ច្រាំ ដូច្នោះពាក្យជេរប្រទេចផ្តាសាផ្សេងៗនោះ ទើបបានឈ្មោះថា **ផរុសា** នេះ ពោលដោយមុខន័យគឺពោលដោយត្រង់ បើពោលដោយផលូបចារន័យ គឺន័យអម ទោសចេតនា ក៏ឈ្មោះថា ផរុសាបាន ព្រោះទោសចេតសិកនេះ ជាហេតុនៃការជេរ ការប្រទេចផ្តាសា ជាផលហើយ លើកយកពាក្យ **ផរុសា** ដែលជាឈ្មោះរបស់ពាក្យអាក្រក់ទាំងនោះ ចូលទៅតាំងក្នុងទោសចេតនា ទើបហៅថា ទោសចេតសិក នេះ ថា **ផរុសា** ។

**អង្គនៃផរុសវាចាមាន ៣ គឺ**

**១–កោធោ** មានសេចក្តីក្រោធ

**២–ឧបក្កុដ្ឋោ** មានអ្នកត្រូវជេរ

**៣–អក្កោសនា** ពោលវាចាជេរប្រទេច

ដូចមានគាថាសម្តែងថា:

**ផរុសាយ តយោ កោធោ ឧបក្កុដ្ឋោ អក្កោសនា**
**ធម្មច្ចេទកភា តត្ថ– ផរុសា ផរុសា មតា ។**

ប្រែថា អង្គនៃផរុសវាចាមាន ៣ គឺមានសេចក្ដីក្រោធ ១
មានអ្នករងគ្រោះត្រូវជេរ ១ ពោលពាក្យជេរប្រទេចចេញទៅ ១
បណ្ឌិតគប្បីជ្រាបចេតនាយ៉ាងគ្រោតគ្រាត ដែលអាចធ្វើឲ្យ
អ្នកស្ដាប់ឈឺចិត្ត បីដូចបូសកំពុងគុំខ្ទុះ ត្រូវប៉ះទង្គិចឲ្យបែកធ្លាយ
នេះឈ្មោះថា **ផរុសវាចា**។

ពាក្យថា **មម្មច្ឆេទកោ** នេះ ជាពាក្យបញ្ជាក់អត្ថន័យឲ្យដឹងថា ចេតនានេះ ជាចេតនាគ្រោតគ្រាត ដូច្នេះទោះបីពាក្យដែលនិយាយចេញមកនោះ ជាពាក្យល្អិតសុខុមក្ដី តែបើមានចេតនាគ្រោតគ្រាត ពាក្យនិយាយនោះចាត់ជាផរុសវាចាដូចគ្នា ឧទាហរណ៍អ្នកពិភាក្សាវិនិច្ឆ័យកាត់សេចក្ដីប្រហារជីវិត អ្នកជាប់ចោទ ទោះបីថា ខណៈពោលនោះ ប្រើវាចាសុភាពរាបសាធ្វើមុខញញឹមញញែមក្ដី តែចេតនាដែលបំណងឲ្យប្រហារជីវិត គឺជាចេតនាយ៉ាងគ្រោតគ្រាត ដូច្នេះវាចាដែលពោលចេញមកនោះ ទើបសម្រេចជាកម្មបថ ជា **ផរុសវាចា** ក្នុង**អដ្ឋសាលិនី** អដ្ឋកថា លោកពោលថា មាតាបិតាដែលជេរកូន ឬគ្រូអាចារ្យជេរកូនសិស្ស ដោយមានបំណងល្អ ហើយគ្មានចេតនាអាក្រក់ វាចាអាក្រក់ វាចាដែលពោលនោះ មិនចាត់ជាផរុសវាចា លោកលើកឧទាហរណ៍ដូចជា មាតាហាមកូនមិនឲ្យដើរទៅលេងក្នុងព្រៃ តែបុត្រនោះ រឹងចចេសមិនស្ដាប់ ផ្គើនទៅទាល់តែបាន មាតាខឹងណាស់ទើបជេរថា អាឯងរឹង ចចេសណាស់ ហាមត្រង់ណាទៅត្រង់ណោះ សុំឲ្យក្របីព្រៃវាធងឯងឲ្យស្លាប់ចុះ ពាក្យជេរប្រទេចរបស់មាតានេះ ប្រព្រឹត្តទៅត្រឹមតែវាចា ដោយអំណាចសេចក្ដីក្រោធប៉ុណ្ណោះ ដូច្នោះទើបមិនចាត់ជា ផរុសវាចា ។

ព្រះដីកាចារ្យពោលជំទាស់ថា ពាក្យជេរប្រទេចរបស់មាតាបិតា គ្រូអាចារ្យនោះ បើពោលដោយសេចក្ដីក្រោធពិតប្រាកដហើយ ចាត់ជាផរុសវាចាបាន ព្រោះគ្រប់អង្គទាំង៣ តែមានទោសតិច ។

*អាចារ្យខ្លះពោលថា ការពោលផរុសវាចានេះ ត្រូវពោលចំពោះមុខអ្នកវង្គ្រោះទើបសម្រេចជាកម្មបថ តែក្នុងទីឃនិកាយដីកា និងមជ្ឈិមនិកាយដីកាពោលថា ការពោលផរុសវាចា ទោះបីអ្នកដែលវង្គ្រោះនោះ មិនបាននៅចំពោះមុខ ឬស្លាប់ ទៅហើយក្តី ការពោលក៏សម្រេចជាកម្មបថបាន ដោយថាអ្នកតូចដែលពោលវាចា លើអ្នកធំ មានមាតាបិតាគ្រូអាចារ្យជាដើម តមកអ្នកនោះដឹងកំហុសខ្លួន ទើបសូមខមាទោសចំពោះលោកទាំងនោះទោះលោកទាំងនោះ មិនបាននៅចំពោះមុខ ឬស្លាប់ ទៅហើយក្តី ការសូមខមាទោសរបស់អ្នកទាំងនោះ រមែងសម្រេចប្រយោជន៍ គឺទោសនោះ រមែងសម្រេចជាអហោសិកម្មបានការពោលសូមខមាទោសដោយ មិនមានអ្នកត្រូវជេរ នៅចំពោះមុខ ក៏រមែងសម្រេចកម្មបថបានដូចគ្នា ។*

## អក្កោសវត្ថុ ១០

*ក្នុងអង្គទី ៣ ដែលពោលថា* **អក្កោសនា** *គឺការពោលវាចាជេរប្រទេចនោះ អ្នកសិក្សាគប្បីជ្រាបវត្ថុដែលជាទីតាំងនៃការប្រទេច ហៅថា* **អក្កោសវត្ថុ** *មាន ១០ យ៉ាងគឺ*

**ជាតិនាមគោត្តកម្មំ សិប្បំ អាពាធលិង្គិកំ កិលេសាបត្តិអក្កោសា ឧសមោមសវាឧកា ។**

## វាចាសម្រាប់ជេរ មាន ១០ យ៉ាងគឺ :

*ជាតិ ទាបខ្ពស់១ ឈ្មោះ ទាបខ្ពស់១ ត្រកូល ទាបខ្ពស់១ ការងារ ទាបខ្ពស់១ វិជ្ជា ទាបខ្ពស់១ រោគ ទាបខ្ពស់១ រូបរាងសណ្ឋាន ទាបខ្ពស់១ កិលេស ទាប១ អាបត្តិ ទាបខ្ពស់១ ពាក្យជេរ បន្ទាបខ្ពស់១ ។*

**១- ជាតិ** ពាក្យជេរដែលទាក់ទងនឹងជាតិទាបនោះ ដូចជេរថា ជាតិព្រៃភ្នំ ជាជាតិខ្ញុំកញ្ជះគេ អាជាតិក្រខ្វក់ អាជាតិអ្នកលេងជាដើម ។

ពាក្យជេរ លើកឲ្យខ្ពស់ ដូចជេរថា ពូជអាអ្នកមាន អាសេដ្ឋី អានាយទុន ជាដើម ។

**២- ឈ្មោះ** ពាក្យជេរទាក់ទងនឹងឈ្មោះថោកទាប ដូចជេរថា អានរក អាប្រេត ជាដើម ពាក្យជេរលើកកម្ពស់ លោក លោកស្រី ជំទាវ ឯកឧត្តមជាដើម ។

**៣-គោត្ត** ពាក្យជេរទាក់ទងនឹងត្រកូលទាប ដូចជេរថា អាត្រកូលចោរ អាត្រកូលបោកប្រាស់ជាដើម ពាក្យជេរលើកកម្ពស់ត្រកូល ដូចជេរថា ត្រកូលចៅហ្វាយនាយ ត្រកូលសេដ្ឋីជាដើម ។

**៤- កម្មំ** ពាក្យជេរដែលទាក់ទងនឹងការងារថ្នាក់ទាបដូចជេរថា អាជាងដំដែក អាកម្មកររាយថ្ម អាកម្មករដឹកជញ្ជូនជាដើម ពាក្យជេរទាក់ទងនឹងការងារថ្នាក់ខ្ពស់ ដូចជេរថា អាជាងមាស ជាងប្រាក់ នាយទុន អ្នកស្រែ អ្នកចម្ការ ជាដើម ។

**៥-សិប្បំ** ពាក្យជេរទាក់ទងនឹងវិជ្ជាថ្នាក់ទាប ដូចជេរថា អ្នកបើកបរ វិជ្ជា កាត់សក់ វិជ្ជាធ្វើពាងជាដើម ពាក្យជេរ ទាក់ទងនឹងវិជ្ជាខ្ពស់ ដូចជេរថា គ្រូមើលលក្ខណៈ គ្រូផ្សំថ្នាំ អាចារ្យជាដើម ។

**៦- អាពាធ** ពាក្យជេរដែលទាក់ទងនឹងរោគថ្នាក់ទាប ដូចរោគឃ្លង់ រោគស្រែង ស្វាយប្រមេះ រោគអេដស៍ជាដើម រោគថ្នាក់ខ្ពស់ដូចជា រោគសរសៃប្រសាទ រោគបេះដូង រោគក្រពះជាដើម ។

**៧- លិង្គំកំ** ពាក្យជេរទាក់ទងនឹងរូបរាងសណ្ឋានថ្នាក់ទាប ដូចជាអាសំគម អាកន្ទាត់ អាកន្លើ អាខ្វើយ អាគមជាដើម ជេររូបរាងសណ្ឋានខ្ពស់ អាសង្ហា អាក្លាហាន មីកញ្ញា មីរចនាជាដើម ។

**៨–កិលេស** *ពាក្យជេរដែលទាក់ទងនឹងកិលេសថ្នាក់ទាបតែម្យ៉ាងដូចជេរថា អាទោសោ មេឬស្យា តណ្ហាខ្លាំង មិច្ឆាទិដ្ឋិខ្លាំង ។*

**៩–អាបត្តិ** *ពាក្យជេរដែលទាក់ទងនឹងអាបត្តិទាប ដូចជេរថា អាបាចិត្តិយ អាទុក្កដ ជាដើម ពាក្យជេរដែលជាប់ទាក់ទងនឹងអាបត្តិថ្នាក់ខ្ពស់ដូចជា អាបារាជិក អាសង្ឃាទិសេស ជាដើម ។*

**១០–អក្កោសោ** *ពាក្យជេរទាប ដូចប្រើពាក្យជេរម៉ែ ជេរឪពុក ជាដើម ពាក្យខ្ពស់ ដូចជេរពាក្យសន្ដានអាក្រក់ ថោកទាប សត្វតិរច្ឆាន ជាដើម ។*

**ប្រយោគនៃផរុសវាចាមាន ២ យ៉ាងគឺ :**

**១–កាយបយោគ** *ការពោលពាក្យអាក្រក់តាមផ្លូវកាយ*

**២–វចីបយោគ** *ការពោលពាក្យអាក្រក់តាមផ្លូវវាចា*

*ការពោលពាក្យអាក្រក់តាមផ្លូវវាចានោះ មានន័យច្បាស់លាស់ស្រាប់ហើយ ចំណែក ការពោលពាក្យអាក្រក់តាមផ្លូវកាយនោះ ដូចសរសេរសំបុត្រជេរ ឬសម្ដែងកិរិយាផ្សេងៗ ដែលធ្វើឲ្យអ្នកឃើញដឹងកើតសេចក្ដីក្រោធ ខ្មាស មិនសប្បាយចិត្ត ។*

**ចែកផរុសវាចាដោយអប្បសាវជ្ជៈ និងមហាសាវជ្ជៈ**

*ការជេរអ្នកមានឧបការគុណ ដូចមានមាតា បិតា គ្រូ អាចារ្យ ញាតិកា ឬអ្នក មានសីលធម៌ អ្នកជេររមែងមានទោសច្រើន បើអ្នកត្រូវជេរមិនមានសីល អ្នកជេរមាន ទោសតិច ។*

**ផរុសវាចា**

**សិក្ខាបទទី ៦ ចប់**

## សម្ផប្បលាបសិក្ខាបទទី៧

*ពាក្យថា* **សម្ផប្បលាប** *ញែកជា ២ បទគឺ* **សម្ផ+បលាប, សម្ផ** *ប្រែថា ការទម្លាយប្រយោជន៍ និងសេចក្ដីសុខ,* **បលាប** *ប្រែថា ការពោល ,ការរួមចូលគ្នា ទាំងពីរបទជា* **សម្ផប្បលាបៈ** *ប្រែថា ការពោលវាចាទម្លាយនូវប្រយោជន៍ និងសេចក្ដីសុខ មានវចនត្ថៈថា* **សំហិតសុខំ ផលតិ វិនាសេតីតិ = សម្ផំ** *វាចា ឯណាដែលទម្លាយនូវប្រយោជន៍ និងសេចក្ដីសុខផ្សេងៗ បោលអស់ ព្រោះហេតុនោះ វាចានោះ ឈ្មោះថា* **សម្ផៈ ។**

**សម្ផំ បន បន្តិ ឯតេនាតិ = សម្ផប្បលាបោ** *ការពោលវាចា ដែលទម្លាយបង់នូវប្រយោជន៍ និងសេចក្ដីសុខផ្សេងៗ ឲ្យខូចដោយចេតនានោះ ដូច្នេះ ចេតនាដែលជាហេតុក្នុងការពោលវាចាដែលទម្លាយប្រយោជន៍ និងសេចក្ដីសុខផ្សេងៗ ទើបឈ្មោះថា* **សម្ផប្បលាបៈ។**

*ការពោលវាចា ដែលជាសម្ផប្បលាបនោះ សំដៅដល់ការពោលរឿងរ៉ាវ រោយរាយឥតប្រយោជន៍ ដូចជានិយាយពីរឿងភាពយន្ត រឿងល្ខោនប្រលោមលោក ឬនិយាយតាកកំប្លែងផ្សេងៗ ឬជាអ្នកដើរតួសម្ដែងភាពយន្តល្ខោន ឬអ្នកនិពន្ធ សរសេររឿងកំប្លុកកំប្លែងផ្សេងៗ ទាំងនោះចាត់ជា សម្ផប្បលាបទាំងអស់ ព្រោះធ្វើឲ្យអ្នកស្ដាប់ អ្នកអានមិនបានប្រយោជន៍អ្វី បានតែធ្វើឲ្យចិត្តស្រើបស្រាលភ្លើតភ្លើន មួយពេលប៉ុណ្ណោះ ថែមទាំងធ្វើឲ្យខូចប្រយោជន៍ដែលត្រូវបាន ឯប្រយោជន៍ដែលបានហើយក៏ខូចអស់ទៅ អង្គធម៌របស់សម្ផប្បលាបៈនេះ បានដល់អកុសលចេតនា ដែលជាហេតុនៃការពោលពាក្យសម្ផប្បលាបៈ*

សម្រាប់ពាក្យពេចន៍ដែលពោលឡើងនោះជាផល តែដែលលើកយកពាក្យសម្ផប្បលាបៈ ដែលជាហេតុ មេតនាមកប្រើសម្រាប់ហៅឈ្មោះនោះ ជាការហៅដោយការណូបចារន័យ គឺហៅឈ្មោះ ដែលស្រដៀងគ្នានឹងហេតុ ។

**អង្គនៃសម្ផប្បលាបមាន ២ យ៉ាងគឺ :**

**១–និរត្ថកថាបុរក្ខារោ** តាំងចិត្តពោលវាចាដែលមិនមានប្រយោជន៍

**២–កថនំ** ពោលវាចាដែលមិនមានប្រយោជន៍

ដូចមានគាថាសម្តែងថា:

**សម្ផស្ស និរត្ថកថា បុរេតោ កថនំ ធុវំ**

**បរេន គហិតេយេវ ហោតិ កម្មបថោ ន នោ ។**

អង្គទាំងពីររបស់សម្ផប្បលាបៈនោះ គឺ តាំងចិត្តពោលវាចាដែល
មិនមានប្រយោជន៍អ្វី ១ ពោលវាចាឡើង ១ កាលអ្នកស្តាប់
ឬអ្នកអានជឿពាក្យនោះហើយ រមែងសម្រេចជាកម្មបថ បើអ្នកស្តាប់
អ្នកអាន មិនជឿតាមពាក្យនោះទេ ក៏មិនសម្រេចជាកម្មបថឡើយ
បានឈ្មោះថា គ្រាន់តែជា **សម្ផប្បលាប** ប៉ុណ្ណោះ ។

អធិប្បាយ ក្នុងគាថាដែលពោលថា **និរត្ថកថាបុរក្ខារោ** នោះ មានន័យថា រឿងដែលមិនពិត តែអ្នកពោល ឬអ្នកសរសេរនោះ បានតាំងន័យថា រឿងដែលមិនពិត តែអ្នកពោល ឬអ្នកសរសេរនោះ បានតាំងចិត្តតែងរឿងនោះឡើង ដើម្បីឲ្យអ្នកស្តាប់ ឬអ្នកអានវង្វេងជាប់ចិត្តក្នុងពាក្យនិយាយរបស់ខ្លួន ជាការធ្វើឲ្យកើតសេចក្តីយល់ខុស និងខូចប្រយោជន៍ដល់អ្នកស្តាប់ និងអ្នកអានដូច្នេះ ពាក្យពោលរបស់អ្នកនោះ ចាត់ជាសម្ផប្ប-

លាបៈ តែទោះបីរឿងនោះជារឿងមិនពិតក្តី អ្នកពោល ឬអ្នកនិពន្ធបំណងលើកឡើងជារឿងឧបមាប្រកបដោយការប្រៀនប្រដៅ ការសម្តែង ឬសរសេរ ដើម្បីឲ្យអ្នកយល់ងាយ ដូច្នេះពាក្យពេចន៍របស់អ្នកនោះ មិនចាត់ជា **សម្ផប្បលាបៈ**ទេ ។

បើរឿងដែលពោលនោះជាសេចក្តីពិត តែអ្នកអានឬអ្នកស្តាប់នោះ មិនបានទទួលប្រយោជន៍អ្វីទេ ដូច្នេះទុកស្មើអ្នកពោលនោះប្រាប់ដំណឹង ឬសរសេរដំណឹងឲ្យស្តាប់ ពាក្យពោលនោះ ក៏មិនចាត់ជា **សម្ផប្បលាបៈ**ដែរ ។

អ្នកនិយាយកំប្លែងសប្បាយហេហា! ពោលរឿងរោយរាយមិនពិត ដែលជាសម្ផប្ប-លាបៈនេះ តើចាត់ជាមុសាវាទបានឬទេ? រឿងនេះលោកកែថា មិនចាត់ជាមុសាវាទទេ ព្រោះអ្នកនិយាយមិនបានតាំងចិត្តនឹងមុសា គ្រាន់តែនិយាយរោយរាយឥតប្រយោជន៍ប៉ុណ្ណោះ តែបើមានសេចក្តីតាំងចិត្តនឹងមុសាប្រកបផង ទើបចាត់ជាមុសាវាទទៅវិញ ។

ពាក្យនិយាយដែលចាត់ចូលក្នុងតិរច្ឆាន គឺពាក្យនិយាយដែលគ្មានប្រយោជន៍គ្មានខ្លឹមសារ មាន ៣២ ប្រការ ដែលហៅថា តិរច្ឆានកថា ៣២ ប្រការនោះឯង ដែលព្រះសម្មា-សម្ពុទ្ធទ្រង់សម្តែងនៅក្នុង ***សាមញ្ញផលសូត្រ សីលខន្ធវគ្គ*** ព្រះបាលីថា៖

**១-រាជកថំ** និយាយអំពីរឿងផ្សេងៗ ពីព្រះមហាក្សត្រ រហូតព្រះញាតិវង្ស

**២-ចោរកថំ** និយាយអំពីរឿងចោរផ្សេងៗ

**៣-មហាមត្តកថំ** និយាយអំពីរឿងអាមាត្យរាជមន្ត្រី រាជវដ្ឋាកិបាល

**៤-សេនាកថំ** និយាយអំពីរឿងទាហាន ប៉ូលិសផ្សេងៗ

**៥-ភយកថំ** និយាយអំពីរឿងភ័យផ្សេងៗ

**៦-យុទ្ធកថំ** និយាយអំពីរឿងយុទ្ធសាស្ត្រ រឿងសង្គ្រាមផ្សេងៗ

៧–អន្នកថំ និយាយអំពីរឿងអាហារភោជនផ្សេងៗ

៨–ចានកថំ និយាយអំពីរឿងគ្រឿងផឹកផ្សេងៗ

៩–វត្ថកថំ និយាយអំពីរឿងសំពត់ខោអាវ សម្លៀកបំពាក់ផ្សេងៗ

១០–សយនកថំ និយាយអំពីរឿងទីដេក មានគ្រែពូកផ្សេងៗ

១១–មាលាកថំ និយាយអំពីរឿងផ្កាកម្រងផ្សេងៗ

១២–គន្ធកថំ និយាយអំពីរឿងគ្រឿងក្រអូបផ្សេងៗ

១៣–ញាតិកថំ និយាយអំពីរឿងក្រុមញាតិសន្តានផ្សេងៗ

១៤–យានកថំ និយាយអំពីរឿងយានពាហនៈផ្សេងៗ

១៥–គាមកថំ និយាយអំពីរឿងភូមិស្រុកផ្សេងៗ

១៦–និគមកថំ និយាយអំពីរឿងនិគមផ្សេងៗ

១៧–នគរកថំ និយាយអំពីរឿងនគរផ្សេងៗ

១៨–ជនបទកថំ និយាយអំពីរឿងជនបទផ្សេងៗ

១៩–ឥត្ថីកថំ និយាយអំពីរឿងស្ត្រី

២០–បុរិសកថំ និយាយអំពីរឿងបុរស

២១–កុមារកថំ និយាយអំពីរឿងកុមារ

២២–កុមារីកថំ និយាយអំពីរឿងកុមារី

២៣–សុរកថំ និយាយអំពីរឿងអ្នកក្លាហាន

២៤–វិសិខាកថំ និយាយអំពីរឿងផ្លូវថ្នល់ផ្សេងៗ

២៥–កុម្ភដ្ឋានកថំ និយាយអំពីរឿងកំពង់ទឹកផ្សេងៗ

២៦–បុព្វបេតកថំ និយាយអំពីរឿងញាតិដែលរំលាយខន្ធទៅហើយ

២៧–នានត្តកថំ និយាយអំពីរឿងរ៉ាវ ១០៨

២៨–លោកក្ខាកថំ និយាយអំពីរឿងលោក និងអ្នកសាងលោក

២៩–សមុទ្ទក្ខាកថំ និយាយអំពីរឿងមហាសមុទ្រនិងអ្នកសាងសមុទ្រ

៣០–ឥតិភវាភវកថំ និយាយអំពីសេចក្តីចម្រើន និងសេចក្តីវិនាសផ្សេងៗ

៣១–អរញ្ញកថំ និយាយអំពីរឿងព្រៃផ្សេងៗ

៣២–បព្វតកថំ និយាយអំពីរឿងភ្នំផ្សេងៗ

ពាក្យនិយាយគ្មានប្រយោជន៍ គ្មានខ្លឹមសារហៅថា **សម្ផប្បលាបៈ** ទាំងនេះ ច្រើនមានប្រាកដដល់ពួកមហោស្រព មានភាពយន្ត ល្ខោន យីកេជាដើម និងពួកអ្នកនិពន្ធរឿងសម្រាប់អានលេងផ្សេងៗ ដែលមិនប្រកបដោយគតិធម៌អ្វីឡើយ តែបើពោលតាមព្រះពុទ្ធភាសិតក្នុងសប្បាយតនសំយុត្តព្រះបាលីថា បុគ្គលពួកនេះ កាលបើស្លាប់ពីលោកនេះទៅ រមែងទៅកើតក្នុងបហាសនិរយៈ ដែលជាផ្នែកមួយ របស់អវិចីមហានរក ដូច្នេះព្រះមានព្រះភាគទើបព្រះអង្គអប់រំសាវ័កទាំងឡាយជាប់ជានិច្ច ថា៖ **ម្ចិន្នំ ភោ ភិក្ខវេ**

**សន្និបតិតានំ ករណីយំ ធម្មី វា កថា តុណ្ហីភាវោ វា** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកាលបានជួបគ្នា ២ អន្លើហើយ ការងារដែលគួរប្រព្រឹត្តទៅនោះមាន ២ យ៉ាងគឺ : ពោលពាក្យដែលទាក់ទងនឹងធម៌ ឬពុំនោះទេ គប្បីនៅស្ងៀម ។

ក្នុងអន្លើទី ២ ដែលពោលថា **កថនំ** នោះ សម្តែងអំពីប្រយោគ ដែលសំដៅដល់វចីប្រយោគតែម្យ៉ាង តែបើប្រើសរសេរពាក្យទាំងនោះ ក៏ជាកាយប្រយោគក៏បាន តែការពោលពាក្យសម្ផប្បលាបៈនេះ រមែងកើតតាមផ្លូវវចីទ្វារដោយច្រើន ដូច្នោះ ព្រះអដ្ឋកថាចារ្យទើបសម្តែងអន្លើទី ២ ថា : **កថនំ** គឺពោលវាចាឡើង តែបើសរុបប្រយោគក្នុងសម្ផប្ប-លាបៈ នេះ មាន ២ គឺ កាយប្រយោគ និងវចីប្រយោគ ។

## សម្ផប្បលាបៈដែលជាអប្បសាវជ្ជៈ និងមហាសាវជ្ជៈ

អ្នកដែលពោលសម្ផប្បលាបៈជាប់ជានិច្ច រមែងចាត់ជាមហាសាវជ្ជៈ ចំណែកអ្នកពោលពាក្យសម្ផប្បលាបៈម្តងមួយកាល ក៏ចាត់ជាអប្បសាវជ្ជៈ ។

អធិប្បាយក្នុងបាលីទី៧ ដែលថា **វចីវិញ្ញត្តិសង្ខាតេ វចីទ្វារេ ពាហុល្លវុត្តិតោ វចីកម្មំ នាម**,មុសាវាទ ១ បិសុណាវាចា ១ ផរុសវាចា ១ សម្ផប្បលាបៈ ១ ទាំងនេះឈ្មោះថា វចីកម្ម ព្រោះកើតក្នុងវចីទ្វារ គឺវចីវិញ្ញត្តិដោយច្រើន ពាក្យថា វចីទ្វារក្នុងទីនេះសំដៅយកវចីវិញ្ញត្តិ ដូច្នោះ ព្រះអនុដីកាចារ្យ ទើបសម្តែងជាពិសេស ដោយវិសេសនបទថា **វចីវិញ្ញត្តិសង្ខាតេ** ពាក្យថា វចីក្នុងបទថា វចីកម្មនេះ បានដល់កិរិយា អាការៈដែលប្រព្រឹត្តទៅរបស់មាត់ គឺការនិយាយដែលហៅថា វាចានោះឯង ។

**វាចាមាន ៤ យ៉ាងគឺ :**

១–**សទ្ទវាចា** បានដល់សំឡេងដែលនិយាយ

២–**វិរតិវាចា** បានដល់ការវៀរចាក វចីទុច្ចរិត

៣–**ចេតនាវាចា** បានដល់ចេតនាដែលធ្វើឲ្យវចីវិញ្ញត្តិរូបកើតឡើង

៤– **ចោបនវាចា** បានដល់កិរិយាអាការៈពិសេស ដែលប្រព្រឹត្តទៅនៅក្នុងពាក្យនិយាយ ដែលអាចធ្វើឲ្យអ្នកស្តាប់ដឹងសេចក្តីបំណងរបស់ខ្លួនបាន ។

វាចាទាំង ៤ យ៉ាងនេះ ចោបនវាចានេះឯង ជាវចីវិញ្ញត្តិ ឯវចីវិញ្ញត្តិរូបនេះ ជាទ្វារនៃការកើតឡើងរបស់កម្មទាំង ៤ ឬជាហេតុឲ្យសម្រេចវចីកម្មទាំង ៤ មាន មុសាវាទជាដើម ដូច្នោះវចីវិញ្ញត្តិរូបនេះ ទើបបានឈ្មោះថា វចីទ្វារ ដូចវចនត្ថៈថា **វាចាឯវ ទ្វារំ = វចីទ្វារំ** វចីវិញ្ញត្តិរូបនោះឯង ជាទ្វារ ទើបឈ្មោះថា វចីទ្វារ ឯអំពើដែលកើតតាមផ្លូវវចីទ្វារជាច្រើននេះឯង ឈ្មោះថា វចីកម្ម ដូចវចនត្ថៈថា **វចីទ្វារេ យេភុយ្យេន បវត្តំ កម្មន្តិ = វចីកម្មំ** កម្មដែលកើតក្នុងវចីទ្វារជាច្រើន ដូច្នោះទើបឈ្មោះថា វចីកម្ម ។

ក្នុងវចីទុច្ចរិតទាំង ៤ មានមុសាវាទជាដើមដូចបានពោលមកនេះ រមែងកើតតាមផ្លូវកាយទ្វារក៏បាន ដូចជាសរសេរសំបុត្រ ឬសម្តែងកិរិយាជាសញ្ញាឲ្យដឹងសេចក្តីបំណងនោះ ទោះបីកើតតាមកាយទ្វារបានក្តី ក៏មិនឲ្យឈ្មោះថា កាយកម្ម នៅតែឲ្យឈ្មោះថា វចីកម្មដដែល ព្រោះកើតក្នុងវចីទ្វារជាច្រើន ដែលជាការ ហៅឈ្មោះ ដោយតព្វាហុល្លន័យ គឺសំដៅពោលជាច្រើនជាធំ ព្រោះហេតុនោះ ព្រះអនុរុទ្ធាចារ្យ ទើបប្រើពាក្យថា ពាហុល្លវុត្តិតោ គឺដែលឈ្មោះថា វចីកម្ម ព្រោះកើតតាមផ្លូវវចីទ្វារជាច្រើន ។

**សម្ពន្ធប្បលាបសិក្ខាបទទី៧ចប់**

## អធិប្បាយមនោកម្ម ៣
## អភិជ្ឈាសិក្ខាបទទី៨

*ពាក្យថា* **អភិជ្ឈា** *នេះ មកពី* **អភិ** *ជាបុព្វបទ,* **ឈេ** *ធាតុ,* **អភិ** *ប្រែថា ចំពោះមុខ,* **ឈេ** *ប្រែថា គិតដល់ ។ កាលបើរួមបទទាំងពីរ ជា* **អភិជ្ឈា** *ប្រែថា គិតដល់ចំពោះមុខ មានន័យថា សម្លឹងរំពៃដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ក្នុងទីចំពោះមុខ ដូចវចនត្ថៈថា* **បរសម្បត្តិ អភិមុខំ ឈាយតីតិ = អភិជ្ឈា** *ធម្មជាតិឯណា រមែងគិតដល់ទ្រព្យសម្បត្តិរបស់ដទៃនៅចំពោះមុខ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា* **អភិជ្ឈា** *អង្គធម៌បានដល់លោភៈ ។*

### លោភៈមាន ២ យ៉ាងគឺ :

**១–ធម្មិយលោភ** *សេចក្តីពេញចិត្តចង់បានប្រកបដោយធម៌*

**២– អធម្មិយលោភ** *សេចក្តីចង់បានមិនប្រកបដោយធម៌ (ចំណែកលោភៈ ដែលជាអភិជ្ឈានោះ នៅក្នុងអធម្មិយលោភៈ) ។*

*ធម្មតាបុគ្គលជាទូទៅ កាលបានប្រទះឃើញអារម្មណ៍ល្អផ្សេងៗមានរូប សំឡេង ក្លិន រសជាដើម រមែងមានសេចក្តីពេញចិត្តចង់បានក្នុងអារម្មណ៍នោះដូចគ្នាទាំងអស់ តែសេចក្តីពេញចិត្តចង់បានរបស់បុគ្គលទាំងនោះ លោកចែកជា ២ ប្រភេទដូចគ្នា បុគ្គលប្រភេទទី ១ កាលមានសេចក្តីចង់បានរបស់នោះៗ ក៏ខំព្យាយាមស្វែងរកឲ្យបានមកដោយសុចរិត គឺដោយការទិញដូរ និងវត្ថុផ្សេងៗ ឬក៏ដោយការសូមសេចក្តីពេញចិត្តចង់បានរបស់បុគ្គលពួកនេះ ចាត់ជាធម្មិយលោភៈ មិនមែនជា អភិជ្ឈាបុគ្គលឡើយ ចំណែកប្រភេទទី ២*

នោះ កាលមានសេចក្តីចង់បានរបស់អ្វីមួយហើយ មានការសម្ងឹងរំពៃចង់បានរបស់នោះ មកធ្វើជារបស់ខ្លួន ដោយមិនប្រកបដោយធម៌ គឺមិនចង់ទិញ មិនចង់សូម ឬមិនចង់ប្តូរគិតរកផ្លូវចង់លួច ចង់បោកប្រាស់ ដើម្បីឲ្យបានរបស់នោះមកធ្វើជារបស់ខ្លួន សេចក្តីពេញចិត្តចង់បាន របស់បុគ្គលពួកទី ២ នេះ ចាត់ជា អធម្មិយលោភៈ គឺ តួអភិជ្ឈាតែម្តង ។

កាលបើពិចារណាឃើញថា តួអភិជ្ឈា បើចូលគ្របសង្កត់អ្នកណា ធ្វើចិត្តរបស់អ្នកនោះ កើតសេចក្តីល្មោភចង់បានសម្បត្តិអ្នកដទៃ ដែលគេរកបានដោយកម្ម ញាណ វិរិយៈរបស់គេ តែចំណែកខ្លួនឯងនោះ ត្រូវការចង់បានមកទទេៗ ដោយពុំគិតថា ម្ចាស់ទ្រព្យគេនោះ បានទទួលសេចក្តីក្តៅក្រហាយអ្វីឡើយ មនុស្សគិតដូច្នេះ ទោះបីមិនបានយកដៃចាប់កាន់ បោកបញ្ឆោត ឬគំរាមកំហែងម្ចាស់ទ្រព្យនោះក្តី ក៏ចាត់ថា ការគិតនោះជារឿងគួរឲ្យខ្ពើម គួរឲ្យខ្មាស តែអ្នកដែលត្រូវអភិជ្ឈាគ្របសង្កត់នេះ អាចគិតដូច្នេះបានមិនខ្លាច មិនខ្មាសអ្នកណាឡើយ ហេតុនោះ បានជាព្រះបរមត្ថទីបនីដីកាចារ្យ លោកសម្តែងវចនត្ថៈថា **អភិជ្ឈាយន្តិ អស្សាទមត្តេ អបត្វា បរភណ្ឌស្ស អត្តនោ បរិណាមវសេន ឯតាយាតិ = អភិជ្ឈា** បុគ្គលទាំងឡាយ មិនឈប់នៅត្រឹមតែសេចក្តីពេញចិត្តទេ រមែងសម្ងឹងដោយអាការៈដែលធ្វើឲ្យទ្រព្យសម្បត្តិរបស់អ្នកដទៃនោះ ឲ្យបានមកជារបស់ខ្លួនប្រកបដោយធម៌នោះ ព្រោះហេតុនោះ ធម៌ដែលហេតុនៃការគិតដូច្នេះនោះ ឈ្មោះថា **អភិជ្ឈា**។

## អង្គអភិជ្ឈាមាន ២ យ៉ាងគឺ :

**១-បរភណ្ឌ** ទ្រព្យសម្បត្តិរបស់អ្នកដទៃ

**២-អត្តនោ បរិណាមនំ** មានចិត្តបង្អោនឲ្យមកជារបស់ខ្លួន

ក្នុងអង្គទី ១ ដែលពោលថា **បរភណ្ឌំ** ទ្រព្យសម្បត្តិរបស់អ្នកដទៃនោះ ក្នុងទីនេះ សំដៅយក អវិញ្ញាណកទ្រព្យទាំងអស់ និងសវិញ្ញាណកទ្រព្យ ជាពួកសត្វចិញ្ចឹមផ្សេងៗ ហើយនិងមនុស្សដែលជាទាសីទាសា ស្ត្រីមានស្វាមី មានគូដណ្តឹង វត្ថុក្រៅពីនេះ មិនចាត់ជាបរភណ្ឌទេ ព្រោះហេតុដូច្នោះ ស្ត្រី ៨ ពួក មានមាតុរក្ខិតាជាដើម រហូតដល់ធម្មរក្ខិតាទាំងអស់នេះ បើបុរសណាមានសេចក្តីស្រឡាញ់ពេញចិត្តចង់បានមកធ្វើជាភរិយា របស់ខ្លួន សេចក្តីនឹកគិតដូច្នេះ មិនចាត់ជាអភិជ្ឈាទុច្ចរិតទេ ។ មួយទៀត រឿងសោរេយ្យមាណព ដែលនឹកគិតជាអកុសលប្រមាទ ចំពោះព្រះមហាកច្ចាយន ដោយគិតថា បើអញបានព្រះអង្គនេះ មកធ្វើជាភរិយារបស់អញ ឬបើភរិយារបស់អញមានរូបស្រស់ស្អាតដូចព្រះអង្គនេះ ជាការល្អណាស់ គ្រាន់តែគិតប៉ុណ្ណោះ ភេទរបស់បុរសសោរេយ្យមាណព ក៏អន្តរធានបាត់សូន្យទៅ ក្លាយជាភេទស្រីមកជំនួសវិញ ការគិតជាអកុសលរបស់សោរេយ្យមាណពនេះ ចាត់ជាអភិជ្ឈាបាន តែមិនដល់ការកន្លងកម្មបថ ព្រោះបុគ្គលដែលសោរេយ្យមាណពនេះ សម្លឹងរំពៃនេះ មិនចាត់នៅក្នុងបរភណ្ឌៈទេ តែខ្លួនត្រូវទទួលទោសដោយរាងកាយប្រភេទនោះ ព្រោះអំណាចនៃការគិតប្រមាទកន្លងល្មើសគ្មានគារវៈចំពោះបុគ្គលដែលជាព្រះខីណាស្រព ។

**អភិជ្ឈាសិក្ខាបទទី៨ ចប់**

## ព្យាបាទសិក្ខាបទទី៩

ពាក្យថា **ព្យាបាទ** នេះ មកពី **វិ** បុព្វបទ , **បទ** ធាតុ , មានវចនត្ថៈថា **ព្យាបជ្ជតិ ហិតសុខំ ឯតេនាតិ = ព្យាបាទោ** ប្រយោជន៍ និងសេចក្ដីសុខ រមែងវិនាសទៅដោយទោសៈនេះ ព្រោះហេតុនោះ ទោសៈនេះ ទើបឈ្មោះថា **ព្យាបាទ**។

អធិប្បាយថា សេចក្ដីក្រោធ សេចក្ដីមិនពេញចិត្ត ដែលប្រព្រឹត្តទៅតាមធម្មតានោះ នៅមិនទាន់ចាត់ចូលជាមនោទុច្ចរិតទេ បានត្រឹមតែព្យាបាទកាយគន្ថប៉ុណ្ណោះ ចំណែកទោសៈដែលជាព្យាបាទមនោទុច្ចរិតនោះ ជាទោសៈយ៉ាងគ្រោតគ្រាត មានអាការៈកាចសាហាវចំពោះអ្នកដទៃ ប្រាថ្នាបំផ្លាញប្រយោជន៍ និងសេចក្ដីសុខរបស់អ្នកដទៃឲ្យវិនាសអស់ទៅ ឧទាហរណ៍ បើក្រោធខឹងនឹងអ្នកណាហើយ ក៏គិតក្នុងចិត្តថា តើត្រូវធ្វើយ៉ាងណាដើម្បីឲ្យអ្នកនោះដល់នូវសេចក្ដីវិនាស ឬនឹងប៉ុនប៉ងចង់ឲ្យអ្នកដទៃវិនាសអន្តរាយផ្សេងៗ ទោសៈបែបនេះ ចាត់ជាព្យាបាទ **មនោទុច្ចរិត**។

### អង្គនៃព្យាបាទមាន ២ យ៉ាងគឺ :

**១-បរសត្តោ** បុគ្គលដទៃ

**២-វិនាសចិន្តា** គិតឲ្យសេចក្ដីវិនាសកើតឡើង

បើគ្រប់អង្គទាំង ២ ហើយ ទោសៈដែលកើតឡើងនោះ ឈ្មោះថា កន្លងកម្មបថ ជាមនោទុច្ចរិត បើការគិតបំផ្លាញខ្លួនឯងក៏មិនកន្លងកម្មបថ ព្រោះមិនគ្រប់អង្គ គឺខ្វះអង្គទី ១ ដែលថា **បរសត្តោ** ដូចជាគាថា សម្ដែងអំពីអង្គនៃអភិជ្ឈា និងព្យាបាទថា៖

ទុក្ខិជ្ឈាយ បរភណ្ឌំ          អត្តនោ បរិណាមនំ

ព្យាបាទស បរសត្តោ          តស្ស វិនាសចិន្តនំ។

*ប្រែថា អង្គនៃអភិជ្ឈាមាន ២ គឺសម្បត្តិអ្នកដទៃ ១ មានចិត្តគិតចង់បានឲ្យមកជារបស់ខ្លួន ដោយមិនប្រកបតាមផ្លូវធម៌ ១ ។*

*អង្គនៃព្យាបាទមាន ២ គឺបុគ្គលដទៃ ១ គិតឲ្យវិនាសកើតឡើង ១ សេចក្តីផ្សេងគ្នានៃវធកចេតនា ដែលទាក់ទងជាមួយបាណាតិបាតនិង ទាក់ទងជាមួយព្យាបាទ វធកចេតនាដែលជាបាណាតិបាតនោះ ជាចេតនាដែលទាក់ទងនឹងផ្លូវកាយ ចាត់ចូលក្នុងវិតក្កមកិលេស ចំណែកវធកចេតនាដែលព្យាបាទនោះ ជាចេតនាដែលទាក់ទងនឹងផ្លូវចិត្ត ចាត់ចូលក្នុងបរិយុដ្ឋានកិលេស ។*

## **ទោសរបស់ព្យាបាទដែលជាមហាសាវជ្ជៈ និងអប្បសាវជ្ជៈ**

*បើមានសេចក្តីព្យាបាទប៉ងប្រទូសរ៉ាយ ចំពោះអ្នកមានសីលគុណ សមាធិគុណ បញ្ញាគុណ មានទោសច្រើន ជាមហាសាវជ្ជៈ បើព្យាបាទចំពោះអ្នកឥតសីលគុណ សមាធិគុណ ឬមានខ្លះតែតិចតួចក៏មានទោសតិចជា អប្បសាវជ្ជៈ ។*

**ព្យាបាទសិក្ខាបទទី៩ ចប់**

## មិច្ឆាទិដ្ឋិសិក្ខាបទទី១០

*ពាក្យថា* **មិច្ឆាទិដ្ឋិ** *ញែកជា ២ បទគឺ* **មិច្ឆា+ទិដ្ឋិ, មិច្ឆា** *ប្រែថា ខុស,* **ទិដ្ឋិ** *ប្រែថា ការឃើញ, រួមចូលគ្នាថា* **មិច្ឆាទិដ្ឋិ** *ប្រែថា ការយល់ឃើញខុស សំដៅដល់យល់ឃើញខុសប្រាសចាកពីសេចក្តីពិត វចនត្ថៈថា* **មិច្ឆា បស្សតីតិ = មិច្ឆាទិដ្ឋិ** *ធម្មជាតិណាមានការយល់ឃើញខុសពីសេចក្តីពិត ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា* **មិច្ឆាទិដ្ឋិ** *អង្គធម៌បានដល់* **ទិដ្ឋិចេតសិក។**

*តាមធម្មតា ទិដ្ឋិចេតសិកនេះ មានភាពដែលឃើញខុសប្រាកចាកការពិត តាមសភាវៈ ឯអ្នកដែលមានទិដ្ឋិនេះ រមែងមិនមានសេចក្តីជឿ សេចក្តីជ្រះថ្លា ក្នុងពាក្យប្រៀនប្រដៅរបស់សប្បុរស និងបណ្ឌិតទាំងឡាយ គឺមានសេចក្តីប្រព្រឹត្តផ្ទុយគ្នា នឹងពាក្យប្រៀនប្រដៅទាំងនោះ ។ ទិដ្ឋិនេះ បើពោលឲ្យទូលំទូលាយ មានច្រើនប្រភេទដូចជា សក្កាយទិដ្ឋិ ២០ ដែលមានការប្រកាន់ស្អិតក្នុងខន្ធ ៥ យ៉ាងណានីមួយថា ជាតួខ្លួនក៏មានមិច្ឆាទិដ្ឋិ ៦២ ដែលសម្តែងនៅក្នុងព្រហ្មជាលសូត្រ ក្នុងសីលខន្ធវគ្គក៏មាន និយតមិច្ឆាទិដ្ឋិ ៣ ដែលសម្តែងនៅក្នុងសាមញ្ញផលសូត្រ នៃសីលខន្ធវគ្គក៏មាន តែមិច្ឆាទិដ្ឋិដែលពោលក្នុងមនោទុច្ចរិតនេះ សំដៅយកនិយតមិច្ឆាទិដ្ឋិទាំង ៣ ដែលសម្រេចជាកម្មបថ ចំណែកមិច្ឆាទិដ្ឋិឯទៀតៗ ក្រៅពីនេះ គ្រាន់តែជាទិដ្ឋិសាមញ្ញប៉ុណ្ណោះ ។*

### អង្គនៃមិច្ឆាទិដ្ឋិមាន ២ យ៉ាងគឺ :

**១–អត្ថវិបរិតតា** *សេចក្តីដែលបានប្រកាន់ទុកនោះខុសចាកសេចក្តីពិត*

**២–តថាភាវុបដ្ឋានំ** *សេចក្តីឃើញថា ជាសេចក្តីពិត*

*បើគ្រប់អង្គទាំងពីរ សេចក្តីឃើញខុសនោះ ឈ្មោះថា កន្ទង់កម្មបថ ជាមនោទុច្ចរិត ដូចមានគាថាសម្តែងថា :*

**ធិដ្ឋិយា ធុវេ សម្ភារោ　　　　វត្ថុតោ វិបរិតតា**

**តថាភាវេនុដ្ឋានំ　　　　កម្មបថោ តិហោវ ច ។**

*<u>ប្រែថា</u> អង្គនៃមិច្ឆាទិដ្ឋិមាន ២ គឺសេចក្តីដែលបានប្រកាន់ទុកនោះ ខុសពីសេចក្តីពិត ១ មានការយល់ឃើញថា ជាសេចក្តីពិត ១ ការយល់ឃើញខុស ដែលកន្ទង់កម្មបថនោះ ជាការយល់ឃើញខុស ពួកនិយតមិច្ឆាទិដ្ឋិ ទាំង ៣ នោះឯង ។*

## និយតមិច្ឆាទិដ្ឋិមាន ៣ យ៉ាង គឺ :

**១–នត្ថិកទិដ្ឋិ** *យល់ឃើញថា ធ្វើអ្វីក៏ដោយ ផលដែលបានទទួលមិនមាន ។*

**២– អហេតុកទិដ្ឋិ** *មានការយល់ឃើញថា សត្វទាំងឡាយដែលកំពុងប្រព្រឹត្តទៅនោះ មិនបានអាស្រ័យហេតុអ្វីឡើយ ។*

**៣–អកិរិយទិដ្ឋិ** *មានការយល់ឃើញថា អំពើដែលធ្វើផ្សេងៗរបស់សត្វទាំងឡាយនោះ មិនសម្រេចជាបុណ្យ ជាបាបអ្វីទេ ។*

**ក–នត្ថិកទិដ្ឋិ** *ក្នុងនិយតមិច្ឆាទិដ្ឋិទាំង ៣ នេះ អ្នកមានការយល់ឃើញ ដូចពួកនត្ថិកទិដ្ឋិនោះ រមែងមានឧច្ឆេទកទិដ្ឋិ គឺយល់ថា សត្វទាំងឡាយស្លាប់ហើយ សូន្យមិនមានកើតទៀត មានព្រះបាលីក្នុង***សាមញ្ញផលសូត្រ** *សីលក្ខន្ធវគ្គ សម្តែងអំពីការយល់ឃើញខុសតាមពួកនត្ថិកទិដ្ឋិថា៖*

**នត្ថិ ទិន្នំ** *យល់ថា ការធ្វើបុណ្យ មិនមានផល*

**នត្ថិ យិដ្ឋំ** *យល់ថា ការបូជាផ្សេងៗ មិនមានផល*

**នត្ថិ ហុតំ** *យល់ថា ការបូជាតូច (បដិសណ្ឋារៈផ្សេងៗ) មិនមានផល*

**នត្ថិ សុកតទុក្កដានំ កម្មានំ ផលវិបាកោ** *យល់ថា ការធ្វើល្អ និងធ្វើអាក្រក់ មិនមានផល ទាំងផ្លូវត្រង់ ទាំងផ្លូវអម*

**នត្ថិ អយំ លោកោ** *យល់ថា លោកនេះមិនមាន គឺអ្នកដែលកំពុងប្រាកដ នៅក្នុងបច្ចុប្បន្ននេះ ដែលហៅថាលោកនេះ រមែងមិនមាន ព្រោះមិនមានការកើតតទៅទៀត*

**នត្ថិ បរោ លោកោ** *យល់ថា លោកខាងមុខមិនមាន គឺភពដែលជាទីកើតនៃភពដែលប្រាកដក្នុងបច្ចុប្បន្ននេះមិនមាន ព្រោះកាលស្លាប់ហើយ មិនមានការកើតទៀត*

**នត្ថិ មាតា** *យល់ថា ការធ្វើល្អអាក្រក់ចំពោះមាតាមិនមាន*

**នត្ថិ បិតា** *យល់ថា ការធ្វើល្អអាក្រក់ ចំពោះបិតាមិនមាន*

**នត្ថិ សត្តា ឱបបាតិកា** *យល់ថា សត្វកើតឡើងធំតែម្តង គឺសត្វនរក ប្រេត ទេវតា ព្រហ្មមិនមាន*

**នត្ថិ លោកេ សមណព្រាហ្មណា សមគ្គតា សម្មាបដិបន្នា, យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ** *យល់ថា សមណព្រាហ្មណ៍ឯណា មានការដឹងគុណច្បាស់ក្នុងលោកនេះ និងលោកខាងមុខ ដោយខ្លួនឯង ហើយអាចចង្អុលប្រាប់ណែនាំឲ្យយល់បាន សមណព្រាហ្មណ៍ដែលដល់ការព្រមដោយសាមគ្គី ហើយបដិបត្តិល្អ បដិបត្តិប្រពៃមិនមាន មានន័យថា អ្នកដែលចម្រើន*

សមថវិបស្សនា បានឈាន មគ្គ ផលនោះមិនមាន ឯអ្នកដែលកាន់ភេទជាបព្វជិត បដិបត្តិល្អ បដិបត្តិប្រពៃមិនមាន សុទ្ធតែជាការនិយាយរាយមាយទាំងអស់ ដែលតាមការពិត គឺធ្វើដើម្បីមុខរបរចិញ្ចឹមជីវិតតែប៉ុណ្ណោះ ។

អ្នកដែលមាន នត្ថិកទិដ្ឋិ គឺមានការយល់ឃើញ ដែលបដិសេធផលនេះ ស្មើនឹងបដិសេធអំណាចនៃកុសលាកុសល ដែលជាហេតុនៃផលផ្សេងៗ ទាំងនោះផង ព្រោះហេតុដូច្នោះ ព្រះពុទ្ធឃោសាចារ្យទើបលោកសម្ដែងទុកក្នុង**សាមញ្ញផលសូត្រ** អដ្ឋកថា ថា៖

**វិបាកំ បដិពាហន្តេនាបិ កម្មំ បដិពាហិតំ ហោតិ** ប្រែថា កាលមានការបដិសេធផលហើយ ក៏បានឈ្មោះថា បដិសេធកម្ម ដែលជាហេតុឲ្យកើតផលនោះផង ។

សេចក្ដីមិនជ្រះថ្លាជឿពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ដូចមិនជឿថាមាននរក មានសួគ៌ជាដើម ដូច្នោះទើបពោលបានថា បុគ្គលទាំងនោះ ទោះបីជាគ្រហស្ថក្ដី បព្វជិតក្ដី កាលណាស្លាប់ទៅហើយ ត្រូវតែទៅក្នុងនិរយភូមិជាមិនខាន ។ កាលបើដូច្នេះ ផ្លូវដែលត្រូវការឲ្យប្រាសចាកពីការយល់ឃើញខុស ត្រូវតែអប់រំធ្វើឲ្យកើតបញ្ញា ក្នុងព្រះពុទ្ធសាសនា ដោយការចម្រើនសតិវិបស្សនាទាល់តែបានសម្រេចជាព្រះអរិយៈ ឬសិក្សាព្រះអភិធម្មឲ្យយល់ចូលចិត្តក្នុងសភាវធម៌ ដែលប្រព្រឹត្តទៅតាមសេចក្ដីពិតផ្សេងៗ ទាំងផ្នែកផ្លូវចិត្ត ឬខ្លួនឯងត្រូវជាអ្នកមានសទ្ធាចរិត ជឿពាក្យប្រៀនប្រដៅរបស់មាតា បិតា គ្រូអាចារ្យ ដែលមានចំណេះដឹងជ្រៅជ្រះ ក្នុងព្រះពុទ្ធសាសនា ទើបប្រាសចាកឲ្យផុតពីមិច្ឆាទិដ្ឋិនេះបាន ។ ម្យ៉ាងទៀត ទោះបីជាអ្នកនោះ មានចំណេះដឹងខាងវិជ្ជាផ្លូវលោកដល់ថ្នាក់ធ្វើជាសាស្ត្រាចារ្យក្ដី ក៏រមែងមិនផុតចាកមិច្ឆាទិដ្ឋិនេះទៅបានដែរ ព្រោះចំណេះវិជ្ជាខាងផ្លូវលោកនោះ ប្រព្រឹត្តទៅដើម្បីអាជីព និងការងារសង្គមតែប៉ុណ្ណោះ ។

**១–អហេតុកទិដ្ឋិ** អ្នកដែលមានការយល់ឃើញតាមបែប អហេតុកទិដ្ឋិនេះ គឺមានការយល់ឃើញថា សត្វទាំងឡាយដែលកំពុងបានទទួលសេចក្ដីទុក្ខលំបាកក្ដី ឬសេចក្ដីសុខ

*សប្បាយក្តី មិនបានអាស្រ័យអ្វី ជាហេតុធ្វើឲ្យកើតឡើងទេ គឺវាប្រព្រឹត្តទៅតាមខ្លួនឯងទាំងអស់ មានព្រះបាលីសម្តែងទុកក្នុង* ***សាមញ្ញផលសូត្រ*** *នៃខន្ធវគ្គថា៖*

**នត្ថិ មហារាជ ហេតុ នត្ថិ បច្ចយោ សត្តានំ សង្កិលេសាយ អហេតុ អបច្ចយា សត្តា សង្កិលិស្សន្តិ នត្ថិ ហេតុ នត្ថិ បច្ចយោ សត្តានំ វិសុទ្ធិយា អហេតុ អបច្ចយា សត្តា វិសុជ្ឈន្តិ ។**

*ប្រែថា ថ្វាយព្រះពរមហារាជ ជនកហេតុ គឺហេតុដែលឲ្យកើត និងឧបត្ថម្ភកហេតុ គឺហេតុដែលជួយឧបត្ថម្ភឲ្យសត្វទាំងឡាយ មានសេចក្តីសៅហ្មងលំបាកកាយ និងលំបាកចិត្តនោះមិនមានទេ សត្វទាំងឡាយដែលកំពុងសៅហ្មង និងលំបាកនោះ ក៏មិនមាន ជនកហេតុ និង ឧបត្ថម្ភកហេតុ ជនកហេតុ គឺហេតុដែលឲ្យកើត និងឧបត្ថម្ភកហេតុ គឺហេតុដែលជួយឧបត្ថម្ភឲ្យសត្វទាំងឡាយមានសេចក្តីបរិសុទ្ធិផុតចាកសេចក្តីលំបាកកាយ លំបាកចិត្តនោះក៏មិនមាន សត្វទាំងឡាយដែលកំពុងមានសេចក្តីបរិសុទ្ធិ ផុតចាកសេចក្តីលំបាកកាយលំបាកចិត្តនោះក៏មិនទាន់ទាក់ទងជាមួយ ជនកហេតុ និងឧបត្ថម្ភកហេតុអ្វីឡើយ ។*

*ការយល់ឃើញខុសជាអហេតុកទិដ្ឋិនេះ ជាការយល់ឃើញដែលបដិសេធហេតុ គឺអំពើអាក្រក់របស់សត្វទាំងឡាយ ដែលកំពុងធ្វើសព្វថ្ងៃនេះ មិនជឿថាវាជាហេតុឲ្យកើតផលបានដូច្នោះ ការបដិសេធហេតុនេះ ក៏ស្មើគ្នានឹងការបដិសេធផលដែរ គឺសត្វទាំងឡាយដែលកំពុងបានទទួលសេចក្តីសុខ សេចក្តីទុក្ខសព្វថ្ងៃនេះ ក៏មិនរាប់ថា ជាផលដែលទាក់ទងមកអំពីការធ្វើល្អ ឬធ្វើអាក្រក់របស់ខ្លួនជាហេតុ ព្រោះហេតុនោះ ព្រះពុទ្ធឃោសាចារ្យទើបសម្តែងទុកក្នុង* ***សាមញ្ញផលសូត្រ*** *អដ្ឋកថាថា៖* **នត្ថិ ហេតូតិ វទន្តោ ឧភយំ បដិពាហតិ** *<u>ប្រែថា</u> អ្នកដែលពោល ឬយល់ឃើញថា សេចក្តីសុខទុក្ខរបស់សត្វទាំងឡាយនោះ មិនទាក់ទងមកពីហេតុនេះ ក៏ស្មើគ្នានឹងការបដិសេធទាំងហេតុទាំងផលដែរ។*

**គ- អកិរិយទិដ្ឋិ** *អ្នកមានការយល់ឃើញបែប* **អកិរិយទិដ្ឋិ** *នេះ មានការយល់ឃើញថា សត្វទាំងឡាយដែលធ្វើល្អក្តី ធ្វើអាក្រក់ក្តី មិនជាបាប មិនជាបុណ្យ អ្នកដែលធ្វើនោះ ក៏បានត្រឹមតែធ្វើប៉ុណ្ណោះ មានព្រះបាលីសម្តែងទុកក្នុង សាមញ្ញផលសូត្រ នៃសីលក្ខន្ធវគ្គថា៖*

**ករោតោ ខោ មហារាជ ការយតោ , ឆិន្ទតោ ឆេទាបយតោ , បចតោ បាចាបយតោ , សោចយតោ សោចាបយតោ , កិលមតោ កិលមាបយតោ , ផន្ទតោ ផន្ទាបយតោ , បាណមតិ បាតាបយតោ , អទិន្នំ អាទិយតោ សន្ធឹ ឆិន្ទតោ , និល្លោបំ ហរតោ , ឯកាគារិកំ ករោតោ , បរិបន្ថេ តិដ្ឋតោ បរទារំ គច្ឆតោ, មុសា ភណតោ, ករោតោ ន ករីយតិ បាបំ ។**

*<u>ប្រែថា</u> អ្នកដែលមានការយល់ឃើញខុសបែប អកិរិយទិដ្ឋិ គឺយល់ឃើញថា ការធ្វើល្អ អាក្រក់របស់សត្វទាំងឡាយ ធ្វើខ្លួនឯងក៏ដោយ ប្រើអ្នកដទៃឲ្យធ្វើក៏ដោយ មិនបានជាបាប ជាបុណ្យ ការបៀតបៀន ដោយកាត់អវយវៈអ្នកដទៃ ដោយកាត់ខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យកាត់ក្តី ក៏មិនបានឈ្មោះថា បានធ្វើ, ការដាក់ទោសអ្នកដទៃដោយការពិន័យយកប្រាក់ ឬប្រើអ្នកដទៃឲ្យធ្វើក្តី ក៏មិនឲ្យឈ្មោះថា ធ្វើបាបដែរ ការកាន់យកទ្រព្យសម្បត្តិរបស់អ្នកដទៃ ធ្វើឲ្យម្ចាស់ទ្រព្យគេកើតសេចក្តីសោកស្តាយខ្លួចចិត្ត ធ្វើខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យធ្វើក្តី ក៏មិនឈ្មោះថា ធ្វើបាប, ការធ្វើទារុណកម្មខ្លួនឯងឲ្យលំបាកមានការអត់បាយ ឬជាប់គុក ឬបបួលដឹកនាំឲ្យអ្នកដទៃជៀវឆ្វេងដាក់ទោសខ្លួនឯង ឲ្យគេលំបាកដូចខ្លួនដែរ ក៏មិនឈ្មោះថា ធ្វើបាប, ខ្លួនឯងមានសេចក្តីក្រវល់ក្រវាយ ក្តៅក្រហាយចិត្តក្តី ឬធ្វើឲ្យអ្នកដទៃឲ្យសម្លាប់ក្តី មិនឈ្មោះថា ធ្វើបាប, ការសម្លាប់សត្វដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យសម្លាប់ក្តី មិនឈ្មោះថា សម្លាប់ គឺគ្មានបាប, ការលបចូលទៅលួចទ្រព្យសម្បត្តិក្នុងផ្ទះ អ្នកដទៃដោយខ្លួនឯងក្តី*

ប្រើអ្នកដទៃឲ្យចូលទៅលួចក្តី ក៏គ្មានបាបដែរ, ការលួចឆក់ទ្រព្យគេ ដោយខ្លួនឯងក្តី ប្រើគេឲ្យលួចឆក់ក្តី ក៏គ្មានបាបដែរ, ការបុករុក ទម្លាយទ្វារចូលទៅក្នុងផ្ទះ ហើយប្លន់យកទ្រព្យគេដោយខ្លួនឯងក្តី ប្រើឲ្យគេបុករុក ទម្លាយទ្វារផ្ទះប្លន់យកទ្រព្យគេក្តី ក៏មិនឈ្មោះថាបាប, ស្ទាក់ចាំប្លន់គេតាមផ្លូវដោយខ្លួនឯងក្តី ប្រើឲ្យគេស្ទាក់ចាំប្លន់តាមផ្លូវក្តី ក៏ឈ្មោះថា មិនមានបាប, ការប្រព្រឹត្តខុសក្នុងកាម នឹងកិរិយារបស់អ្នកដទៃ ក៏គ្មានបាប, ការនិយាយមុសាក៏គ្មានបាប, ការប្រព្រឹត្តទុច្ចរិតផ្សេងៗ ដូចពោលមកនេះ ធ្វើខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យធ្វើក្តីទាំងអស់នេះ ឈ្មោះថា គ្មានបាបដែរ ។

ការយល់ឃើញខុសបែបអកិរិយទិដ្ឋិនេះ ជាការយល់ឃើញដែលបដិសេធ កម្មជាតួហេតុ ព្រោះហេតុដូច្នោះ ទើបស្មើនឹងបដិសេធផលរបស់កម្មដែលសម្រេចក្នុងខ្លួនផងដែរ ដូចព្រះពុទ្ធឃោសាចារ្យលោកសម្តែងទុកក្នុង**សាមញ្ញផលសូត្រ** អដ្ឋកថា ថា៖

**កម្មំ បដិពាហន្តេនាបិ វិបាកោ បដិពាហិតោ ហោតិ** ប្រែថា ទោះបីបដិសេធការធ្វើបាប ឬបុណ្យដែលជាតួហេតុហើយ ក៏ស្មើនឹងបដិសេធផលរបស់ការធ្វើបាប ឬបុណ្យនោះផងដែរ ។

## សេចក្តីក្នុងនិយតមិច្ឆាទិដ្ឋិនៃទិដ្ឋិទាំង ៣

ក្នុងទិដ្ឋិទាំង ៣ នោះ គណាចារ្យអន្យតិរ្ថិយ ៣ នាក់ គឺ

១-អាចារ្យឈ្មោះ **អជិត:** មានការយល់ឃើញខុសតាមបែប នត្ថិកទិដ្ឋិ ។

២-អាចារ្យឈ្មោះ **មក្ខលិគោសាល** មានការយល់ឃើញតាមបែប អហេតុកទិដ្ឋិ ។

៣-អាចារ្យឈ្មោះ **បូរណកស្សប:** មានការយល់ឃើញតាមបែបអកិរិយទិដ្ឋិ ។

សេចក្តីយល់ខុសរបស់អាចារ្យទាំង ៣ នាក់នេះ ជានិយតមិច្ឆាទិដ្ឋិ គឺជាការយល់ឃើញខុសដែលឲ្យផលទៅកើតក្នុងនិរយភូមិយ៉ាងពិតប្រាកដក្នុងលំដាប់នៃចុតិ ដោយគ្មាន

ចន្ទោះ ព្រោះការយល់ឃើញខុសរបស់អ្នកទាំង ៣ នេះ ប្រកាន់ជាប់ តឹងតែងខ្លាំងណាស់ ទោះបីព្រះពុទ្ធអង្គទ្រង់ទូន្មានដោយវិធីផ្សេងៗ ដើម្បីឲ្យលះបង់នូវការយល់ឃើញខុសនេះចោល ក៏មិនបានសម្រេចផលសោះ ឯពួកកូនសិស្សរបស់អាចារ្យទាំង ៣ នាក់នេះ ដំបូងមានការយល់ឃើញខុសនោះជាកម្លាំងខ្សោយ ទើបមិនចូលដល់និយតមិច្ឆាទិដ្ឋិ លុះកាលតមក បានរៀនទន្ទេញ ពិចារណាសេចក្ដីពេញចិត្តពាក្យប្រៀនប្រដៅរបស់អាចារ្យជាប់ជានិច្ច បីដូចអ្នកចម្រើនកម្មដ្ឋានហើយ មានសេចក្ដីពេញចិត្តក្នុងពាក្យប្រៀនប្រដៅទាំងនោះ ក្នុងខណៈដែលពិចារណា និងមានសេចក្ដីពេញចិត្តនោះឯង ទិដ្ឋិគតសម្បយុត្តជវន ក៏កើតឡើងកាន់តែច្រើនឡើងៗ ទាល់តែរាប់មិនអស់ ដល់ថ្នាក់ចិត្តនោះឯង ជាមិច្ឆាសមាធិកើតឡើងក្នុងទីបំផុត ទិដ្ឋិគតសម្បយុត្តជវនវិថី ដែលមានការកាត់ផ្ដាច់សម្រេចចិត្ត ក្នុងសេចក្ដីនោះៗ ថាជារឿងត្រឹមត្រូវក៏កើតឡើង ដូចវិថីចិត្តរបស់ព្រះយោគីនោះ ដែលចម្រើនវិបស្សនា កំពុងចូលកាន់មគ្គវិថី ព្រោះហេតុដូច្នោះ ជវនដួងទី ៧ ដែលនៅក្នុងវិថីចុងក្រោយនេះឯង បានឈ្មោះថា និយតមិច្ឆាទិដ្ឋិ គឺការយល់ឃើញខុស ដែលអាចឲ្យផលទៅកើតក្នុងនិរយភូមិយ៉ាងពិតប្រាកដ ក្រោយពីស្លាប់ទៅ ព្រោះការយល់ឃើញខុសនេះ ទោះបីព្រះពុទ្ធអង្គទ្រង់ប្រោសយ៉ាងណាក្ដី ក៏មិនបានសម្រេចដែរ ។

## អំពីនិយតមិច្ឆាទិដ្ឋិ ៣
## ដែលបានឈ្មោះថាមិច្ឆត្តនិយតៈ

សេចក្ដីប្រព្រឹត្តទៅរបស់ទិដ្ឋិ និងបញ្ញាទាំង ២ នេះ មានសភាពប្រព្រឹត្តទៅផ្ទុយគ្នា បញ្ចូលរួមគ្នាមិនបានជាដាច់ខាត ដូចងងឹត និងពន្លឺ ឬដូចមនុស្ស ២ នាក់ ឈរយកខ្នងទល់គ្នា ហើយរត់ចេញទៅបញ្ច្រាសទិសគ្នាម្នាក់ៗ ពឹតតែរត់ទៅមុខរៀងៗខ្លួន ហើយកាន់តែឃ្លាតឆ្ងាយពីគ្នាទៅយ៉ាងណាមិញ ចំណែកអ្នកមានបញ្ញានោះ កាលបើមានការចម្រើនឡើងៗ ទាល់តែដល់ថ្នាក់កំពូលបានត្រាស់ដឹង អរិយសច្ច ៤ ដោយបានទទួលការឧបត្ថម្ភពី

**សទ្ធា វិរិយ សតិ សមាធិ** ហើយ ក៏គ្មានអ្វីមកបំបែកបញ្ញារបស់អ្នកនោះឲ្យបែកធ្លាយបានឡើយ អ្នកនុ៎ះរមែងមាន សេចក្ដីជ្រះថ្លាជាពិសេសក្នុងគុណព្រះរតនត្រ័យ ជឿកម្ម និងផលរបស់កម្ម ជឿថាស្លាប់ទៅហើយត្រូវតែកើតទៀត បើអ្នកនោះនៅមានតណ្ហា មានន័យថា បញ្ញារបស់អ្នកនោះ បានចូលដល់សម្មត្តនិយតៈ គឺជាបញ្ញាដែលមានសភាពល្អបរិសុទ្ធ ឲ្យផលពិតប្រាកដ ព្រោះហេតុដូច្នោះអ្នកនោះ ទើបបានឈ្មោះថា ជាព្រះសោតាបន្នផុតពីការទៅកើតក្នុងអបាយភូមិ ។

ក្នុងទំនងដូចគ្នាដែរ ផ្នែកមិច្ឆាទិដ្ឋិនោះ កាលបើមានសេចក្ដីចម្រើនឡើងៗ ដោយបានទទួលការឧបត្ថម្ភពី **មិច្ឆាសង្កប្ប មិច្ឆាវាយម មិច្ឆាសមាធិ** ទាល់តែដល់ថ្នាក់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ប្រោសមិនបាន ព្រោះបុគ្គលនោះ ប្រកាន់ជាប់ស្អិត ក្នុងការយល់ឃើញខុសរបស់ខ្លួនទុកយ៉ាងក្រាស់ឃ្មឹក ពេលនោះទិដ្ឋិរបស់អ្នកនោះ ក៏ចូលដល់មិច្ឆត្តនិយតៈ គឺជាទិដ្ឋិដែលមានសភាពអាក្រក់នឹងឲ្យផលអាក្រក់យ៉ាងពិតប្រាកដ ព្រោះហេតុដូច្នោះ អ្នកដែលមានការយល់ឃើញខុសបែបមិច្ឆត្តនិយតៈនេះ រមែងមិនមានសង្ឃឹមថា នឹងបានសម្រេចមគ្គផលសម្រេចជាព្រះអរិយៈបានឡើយ ត្រូវទៅរងទុក្ខក្នុងអវិចីមហានរក ក្នុងកាលស្លាប់ពីលោកនេះ អស់ពេលយ៉ាងយូរមួយម៉ឺនអន្តរកប្បពិតប្រាកដ ព្រោះការយល់ឃើញខុសដែលចូលដល់ មិច្ឆត្តនិយតៈនេះ មានទោសធ្ងន់ខ្លាំងក្លាជាងទោសរបស់សង្ឃភេទទៅទៀត ដូចព្រះពុទ្ធឃោសាចារ្យ ទើបសម្ដែងទុកក្នុង**អដ្ឋកថា អង្គុត្តរនិកាយ** ថា៖

**កប្បវិនាសេ មហាជនេ ព្រហ្មលោកេ និព្ពត្តេបិ និយតមិច្ឆាទិដ្ឋិកោ តត្ថ អនិព្ពត្តិត្វា បិដ្ឋិចក្កវាឡេ និព្ពត្តតិ,** គឺ: **បន បិដ្ឋិចក្កវាឡំ ន ឈាយតីតិ ? ឈាយតិ ? តស្មឹ ឈាយមានេបិ ឯស អកាសេ ឯកស្មឹ ឱកាសេ បច្ចតិយេវាតិ វទន្តិ** ប្រែថា លោកអាចារ្យទាំងឡាយដែលស្ទាត់ជំនាញក្នុងព្រះត្រៃបិដក និងអដ្ឋកថា

*បានពោលទុកថា កាលលោកវិនាស មហាជនទាំងឡាយ ត្រូវបានទៅកើតក្នុងព្រហ្មលោក ចំណែកអ្នកដែលមាននិយតមិច្ឆាទិដ្ឋិនោះ ពុំមានឱកាសបានទៅកើតក្នុងព្រហ្មលោកទេ រមែងទៅកើតក្នុងអវិចីមហានរក នៅក្នុងទីបំផុតចក្រវាល គឺចក្រវាឡលំដាប់មួយសែនកោដិនោះឯង មានបញ្ហាសួរថា ចក្រវាឡលំដាប់ចុងក្រោយបំផុតនោះ តើមិនបានត្រូវភ្លើងឆេះប្រល័យកប្បទេឬ ? ឆ្លើយថា ត្រូវភ្លើងឆេះប្រល័យកប្បដូចគ្នា តែកាលបើចក្រវាលលំដាប់ចុងក្រោយនេះ ត្រូវភ្លើងឆេះប្រល័យកប្បហើយ ពួកសត្វដែលប្រកាន់និយតមិច្ឆាទិដ្ឋិនោះត្រូវទៅរងទុក្ខវេទនានៅក្នុងផ្ទៃកណាមួយ គឺនៅលើផ្ទៃអាកាសនោះ ។*

*ព្រះអដ្ឋកថាចារ្យបញ្ជាក់ឲ្យដឹងថា ក្នុងបណ្តាទោសរបស់អកុសលផ្សេងៗនោះទោសនិយតមិច្ឆាទិដ្ឋិជាទោសដែលកាចសាហាវខ្លាំងក្លាបំផុត ដូចព្រះមានព្រះភាគទ្រង់បានសម្តែងទុកក្នុងអង្គុត្តរព្រះបាលីថា:* **បរមានិ ភិក្ខវេ វិជ្ជានិ** *សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ការយល់ឃើញខុស ដែលជានិយតមិច្ឆាទិដ្ឋិនេះ មានទោសធ្ងន់ជាទីបំផុត ។*

*តើអ្នកប្រកាន់ជាប់ស្អិតក្នុងនិយតមិច្ឆាទិដ្ឋិ មានឱកាសអាចសម្រេចជាព្រះអរិយៈបានដែរឬទេ ? ឆ្លើយថា អ្នកប្រកាន់ជាប់ស្អិតក្នុងនិយតមិច្ឆាទិដ្ឋិនេះ បើមិនលះបង់ ដកការយល់ឃើញខុសរបស់ខ្លួនចេញទេ កុំថាឡើយបានសម្រេចជាព្រះអរិយៈ កាលបើស្លាប់អំពីលោកនេះ ក៏គ្មានសង្ឃឹមថា នឹងបានមកកើតជាមនុស្សទៀតឡើយ តែបើអ្នកនោះលះបង់ដកចេញនូវសេចក្តីយល់ខុសបានហើយ បែរមកចម្រើនវិបស្សនា ទើបមានសង្ឃឹមថា នឹងបានសម្រេចជាព្រះអរិយៈបាន បើស្លាប់អំពីលោកនេះ ក៏មានសង្ឃឹមថា នឹងបានទៅកើតជាមនុស្ស ឬទេវតា ស្រេចតែអំពើរបស់ខ្លួនបានធ្វើមក ដូចជាព្រះសម្មាសម្ពុទ្ធទ្រង់ទេសនាទុកក្នុងព្រះបាលី បដ្ឋានថា:* **អរិយា មិច្ឆត្តនិយតេ បហីនេ កិលេសេ បច្ចវេក្ខន្តិ បុព្វេ សមុទាចិណ្ណេ កិលេសេ ជានន្តិ មិច្ឆត្តនិយតេ ខន្ធេ អនិច្ចតោ វិបស្សន្តិ ។** *ប្រែថា ព្រះអរិយៈទាំងឡាយ ដែលធ្លាប់មាននិយតមិច្ឆាទិដ្ឋិនេះ រមែង*

*ពិចារណាកិលេស គឺនិយតមិច្ឆាទិដ្ឋិ ដែលខ្លួនបានប្រហារទៅហើយរមែងឃើញកិលេស គឺនិយតមិច្ឆាទិដ្ឋិដែលធ្លាប់កើតមកហើយក្នុងសន្តានរបស់ខ្លួន រមែងពិចារណា និយត-មិច្ឆាទិដ្ឋិខន្ធ ដោយសេចក្តីជាអនិច្ចៈ ។*

## អំពីការកើតឡើងនៃទុច្ចរិតផ្សេងៗ ដោយអាស្រ័យមនោទុច្ចរិតជាហេតុ

**អភិជ្ឈា** *ជាដើមហេតុនៃ* **អទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទ បិសុណាវាទ សម្ផប្បលាបៈមិច្ឆាទិដ្ឋិ** *កើតឡើងបាន ។*

**ព្យាបាទ** *ជាដើមហេតុឲ្យកើត* **បាណាតិបាត អទិន្នាទាន មុសាវាទ បិសុណាវាចា ផរុសវាចា សម្ផប្បលាបៈ** *កើតឡើងបាន ។*

**មិច្ឆាទិដ្ឋិ** *ជាដើមហេតុឲ្យកើតទុច្ចរិតទាំង ១០ បាន ។*

## អធិប្បាយគ្នុងបាលី ៨

*ដែលថា* **អញ្ញត្រាបិ វិញ្ញត្តិយា មនស្មឹយេវ ពាហុល្លវុត្តិតោ មនោកម្មំ ញាម។**

**អភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ** *ទាំង ៣ នេះ ឈ្មោះថា មនោកម្ម ព្រោះថា បើវៀរចាកកាយវិញ្ញត្តិហើយ មានតែកើតក្នុងមនោទ្វារប៉ុណ្ណោះ ដោយច្រើន, អធិប្បាយថា ការងារដែលកើតខាងផ្លូវចិត្ត បានឈ្មោះថា មនោកម្ម ដូចវចនត្ថៈថា* **មនស្មឹ បវត្តំ កម្មំ =**

**មនោកម្មំ** កម្មដែលកើតតាមផ្លូវចិត្ត ឈ្មោះថា មនោកម្ម ផ្លូវចិត្តដែលហៅថា មនោទ្វារ នោះមានច្រើនយ៉ាងគឺ :

**១**– ក្នុងវិថីចិត្តផ្សេងៗ នោះ ភវង្គចិត្ត ឈ្មោះថា **មនោទ្វារ** ព្រោះជាហេតុឲ្យវិថីចិត្តកើត ។

**២**– ចិត្តទាំងអស់ឈ្មោះថា **មនោទ្វារ** ព្រោះចិត្តកើតមុនៗ ជាហេតុឲ្យចិត្តក្រោយៗ កើតឡើង ។

**៣–អកុសលជវន** និង **កុសលជវន** ឈ្មោះថា **មនោទ្វារ** ព្រោះជវនចិត្តនេះជាហេតុឲ្យមនោកម្មសម្រេចបាន ដូចព្រះដីការចារ្យសម្តែង វចនត្ថៈថា **មនោ ឯវ ទ្វារន្តិ = មនោទ្វារំ** ជវនចិត្តនោះឯង ជាហេតុនៃការកើតឡើងរបស់មនោកម្ម ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **មនោទ្វារ** ចំណែកក្នុងមនោទុច្ចរិតនេះ លោភមូល ទោសមូល ជវនដែលកើតព្រមជាមួយ **អភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ** ឈ្មោះថា **មនោទ្វារ** ចំណែកមោហមូលជវន ក្នុងទីនេះ មិនឈ្មោះថា **មនោទ្វារទេ** ព្រោះមិនអាចជាហេតុឲ្យមនោទុច្ចរិតទាំង ៣ កើតឡើងបាន ។

ដែលថា **លោភជវន** និង **ទោសជវន** ឈ្មោះថា **មនោទ្វារ** គឺជាហេតុឲ្យមនោទុច្ចរិតកើតបាន ក៏ព្រោះក្នុងខណៈដែលអភិជ្ឈា ឬមិច្ឆាទិដ្ឋិកើតឡើងនោះ លោភ-ជវននេះ ជាបច្ច័យជួយដល់លោភៈដែលជាតួអភិជ្ឈា, ឯទិដ្ឋិដែលជាតួមិច្ឆាទិដ្ឋិ ដោយអំណាច នៃសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ អវិគតិប្បច្ច័យហើយក្នុង

ខណៈដែលព្យាបាទកើតឡើង ទោសជវនក៏ជាបច្ច័យជួយដល់ទោសៈដែលជាតួព្យាបាទ ដោយអំណាចនៃ សហជាត អញ្ញមញ្ញ និស្សយ អត្ថិ អវិគតប្បច្ច័យ ។

ការជួយឧបការៈរបស់អកុសលជវនដែលឈ្មោះថា មនោទ្វារនេះ ទោះបីកាយកម្ម និងវចីកម្មដែលកើតឡើង ក៏រមែងជួយឧបការៈជាមួយគ្នា ក្នុងការធ្វើបាណាតិបាត ខណៈនោះក៏បានទទួលឧបការៈពីទោសជវន ដែលជាតួមនោទ្វារផងដូចគ្នា តែក្នុងការសម្រេចជាបាណាតិបាតនេះ ត្រូវប្រកបដោយវិញ្ញត្តិជាតួមនោទ្វារ ត្រឹមតែទោសជវន ដែលជាមនោទ្វារជួយជាឧបការៈតែមួយនោះ រមែងមិនសម្រេចជាបាណាតិបាតបានទេ ក្នុងមុសាវាទក៏ដូចគ្នា គឺត្រូវមានវចីវិញ្ញត្តិ ដែលជាតួវចីទ្វារចូលប្រកបផង ទើបសម្រេចជាមុសាវាទបាន បើលោភជវនតែម្នាក់ឯង ឬទោសជវនតែម្នាក់ឯង ដែលជាមនោជួយជាឧបការៈតែម្នាក់ឯងនេះ រមែងមិនសម្រេចជាមុសាវាទបានដែរ មានន័យថា អកុសលជវន ដែលជាមនោទ្វារនេះ រមែងជាសាធារណៈដល់អកុសលកម្មទូទៅទាំងកាយកម្ម ទាំងមនោកម្ម តែចំណែកកាយវិញ្ញត្តិ ដែលជាកាយទ្វារ និងវចីវិញ្ញត្តិ ដែលជាវចីទ្វារនោះ មិនបានជាសាធារណៈដល់កម្មទូទៅ គឺមិនចំពោះតែកម្មខ្លះ គឺកាយកម្ម និងវចីកម្មប៉ុណ្ណោះ ។

ធម្មតាការតាំងឈ្មោះរបស់អ្វីមួយឲ្យប្រាកដនោះ ត្រូវអាស្រ័យចំណុចពិសេស របស់នោះៗ ជាមុនសិន រួចទើបគេតាំងឈ្មោះឡើង, ដើម្បីកុំឲ្យច្រឡំគ្នាដូច្នោះ កម្មទាំង ៣ មានបាណាតិបាតជាដើម ដែលបានតាំងឈ្មោះថា កាយកម្ម ក៏ដោយអាស្រ័យកាយទ្វារជាទីកើតពិសេសនៃកម្មទាំង ៤ មានមុសាវាទជាដើម ដែលបានតាំងឈ្មោះថា វចីកម្ម ក៏ដោយអាស្រ័យវចីទ្វារជាទីកើតពិសេសដូចដែលបានតាំងមកហើយ ។

ចំណែកកម្មទាំង ៣ មានអភិជ្ឈាជាដើមនេះ កើតឡើងដោយគ្មានការទាក់ទងជាមួយនឹងវិញ្ញត្តិទាំង ២ គឺកាយទ្វារ និងវចីទ្វារ គឺកើតឡើងចំពោះតែក្នុងមនោទ្វារប៉ុណ្ណោះ ព្រោះហេតុដូច្នោះ ព្រះអនុរុទ្ធាចារ្យទើបបានសម្ដែងថា: **អញ្ញត្រាបិ វិញ្ញត្តិយា មនស្មិំយេវ**

**ពាហុល្លវុត្តិតោ** កាលបើវៀរចាកកាយវិញ្ញត្តិ និងវចីវិញ្ញត្តិហើយ រមែងកើតតែក្នុងមនោទ្វារដោយច្រើន ។

ក្នុងរឿងនេះ បើពិចារណាពាក្យថា **មនស្មឹយេវ ពាហុល្លវុត្តិតោ** ប៉ុណ្ណោះ នេះក៏សមគួរជាពាក្យអធិប្បាយបរិបូណ៌ហើយ គឺអភិជ្ឈាជាដើម តែងកើតក្នុងមនោទ្វារដោយច្រើន តែប្រើជាការសរសេរអក្សរ ឬពោលដោយវាចាថា "សម្បត្តិរបស់អ្នកនេះបើបានមកជារបស់អញជាការល្អណាស់" ដូច្នេះក៏ចាត់ជាអភិជ្ឈា នេះកើតតាមកាយទ្វារនិង វចីទ្វារ តែមានតិចដូច្នេះ អភិជ្ឈាជាដើម ដែលបាន ឈ្មោះថា **មនោកម្ម** ទើបមិនមានការប្រែប្រួលយ៉ាងដទៃ ព្រោះការតាំងឈ្មោះថា មនោកម្មនេះ ក៏តាំងឡើងដោយតព្វាហុល្លន័យ គឺកើតក្នុងមនោទ្វារជាច្រើន ទោះបីយ៉ាងណាក្តី ប្រើពាក្យថា **មនស្មឹយេវ ពាហុល្លវុត្តិតោ** ប៉ុណ្ណោះ ក៏នៅមិនទាន់រៀបរយល្អ គឺពាក្យដើម និងចុង វាមិនត្រូវគ្នា ព្រោះក្នុងកាយកម្ម ៣ ពោលថា **កាយវិញ្ញត្តិសង្ខាតេ កាយទ្វារេ ពាហុល្លវុត្តិតោ** ព្រោះកើតក្នុងកាយទ្វារ គឺកាយវិញ្ញត្តិជាច្រើន ក្នុងវចីកម្ម ៤ ពោលថា **វចីវិញ្ញត្តិសង្ខាតេ វចីទ្វារេ ពាហុល្លវុត្តិតោ** ព្រោះកើតក្នុងវចីទ្វារ គឺវចីវិញ្ញត្តិជាចំនួនច្រើន បញ្ជាក់ឲ្យឃើញថា កាយកម្ម និងវចីកម្មនេះ មានពាក្យវិញ្ញត្តិប្រកប ចំណែកក្នុងមនោកម្ម ៣ នោះ គួរបញ្ជាក់ឲ្យដឹងថា មិនទាក់ទងជាមួយនឹងវិញ្ញត្តិរូបទេ ដូច្នោះព្រះអនុរុទ្ធាចារ្យ ទើបប្រើពាក្យថា អញ្ញត្រ **វិញ្ញត្តិយា** លើកលែងតែវិញ្ញត្តិចេញ ។

តែក្នុងមនោកម្មទាំង ៣ នេះ វៀរចាកវិញ្ញត្តិរហូតទៅ ក៏មិនបានព្រោះជួនកាល ត្រូវប្រកបដោយវិញ្ញត្តិផងដូចគ្នា ព្រោះហេតុដូច្នោះ ដើម្បីបញ្ជាក់ឲ្យដឹងសេចក្តី ប្រព្រឹត្តទៅ

ដូចនេះព្រះអនុរុទ្ធាចារ្យ ទើបប្រើពាក្យថា **អបិ** ប្រកបក្នុង **អញ្ញត្រ** ថា **អញ្ញត្រាបិ** សំដៅដល់ការវៀរវិញ្ញត្តិចេញហើយ កើតក្នុងមនោទ្វារក៏មាន ឬមិនបានវៀរវិញ្ញត្តិគឺប្រកបដោយវិញ្ញត្តិ កើតក្នុងមនោទ្វារក៏មាន ។

***អំពីមនោកម្ម ៣ ខណៈ ជាបរិវាររបស់ចេតនាផ្សេងៗ មានវធកចេតនា និងថេយ្យចេតនាជាដើម***

*ក្នុងខណៈដែលកំពុងសម្លាប់សត្វ លួចទ្រព្យនោះ អភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ រមែងប្រកបជាមួយ ចំណែកមិច្ឆាទិដ្ឋិមិនទៀងទេ ដូចក្នុងខណៈកំពុងលួចទ្រព្យអ្នកដទៃនោះលោភៈដែលជាតួអភិជ្ឈាក៏ប្រកបជាមួយផង បើអ្នកនោះមានសេចក្តីយល់ថា ការលួចទ្រព្យនេះមិនមានទោសទេដូច្នេះ រីឯទិដ្ឋិដែលជាតួមិច្ឆាទិដ្ឋិ ក៏ប្រកបជាមួយគ្នាផងក្នុងខណៈនុ៎ះ អទិន្នាទាន រមែងមិនកន្លងកម្មបថ បានត្រឹមតែជាបរិវាររបស់ថេយ្យចេតនាប៉ុណ្ណោះ ។*

*ក្នុងខណៈដែលកំពុងសម្លាប់សត្វ ទោសៈដែលជាតួព្យាបាទ ក៏ប្រកបផងដែរ បើអ្នកនោះមានសេចក្តីឃើញថា ការសម្លាប់សត្វនេះមិនមានទោសដូច្នេះ ទិដ្ឋិដែលជាតួមិច្ឆាទិដ្ឋិក៏ប្រកបនៅជាមួយក្នុងខណៈនុ៎ះ បាណាតិបាត រមែងឈានកន្លងកម្មបថ ចំណែកព្យាបាទនិងមិច្ឆាទិដ្ឋិ មិនចាត់ជាឈានកន្លងកម្មបថ តែគ្រាន់តែជា បរិវាររបស់វធកចេតនាប៉ុណ្ណោះ ក្នុងខណៈប្រព្រឹត្តខុសក្នុងកាម មុសាវាទជាដើមនោះ មនោកម្ម ៣ រមែងចូលប្រកបជាមួយតាមសមគួរ តែនៅជាបរិវាររបស់ចេតនាកម្មនោះៗប៉ុណ្ណោះ មិនមែនឈានកន្លងកម្មបថទេ។*

## អំពីឈ្មោះថាទុច្ចរិតផ្សេងៗ ដែលមិនគ្រប់អង្គ

*ការធ្វើអកុសលផ្សេងៗនោះ បើមិនឈានកន្លងកម្មបថដោយហេតុណាមួយទេ អកុសលកម្មបថត្រូវហៅទៅតាមទ្វារដែលកើត មិនចាំបាច់តាំងឈ្មោះហៅតាមដែលតាំងទុកដោយតព្វាហុល្លន័យ គឺថាអកុសលកម្មបថផ្សេងៗ ដែលប្រាកដតាមផ្លូវកាយ វាចា ឬចិត្ត តែមិនឈានកន្លងកម្មបថទេ ព្រោះមិនគ្រប់អង្គ អកុសលកម្មទាំងនេះ ត្រូវសង្គ្រោះ*

ហៅទៅតាមទ្វារដែលកើតនោះ មិនត្រូវហៅឈ្មោះតាម តព្វាហុល្លន័យ ដូចការកាត់ដៃកាត់ជើងសត្វក្តី ការក្រៀវសត្វ មានជ្រូក គោ ក្របី សុនខជាដើម មិនឲ្យមានការបន្តពូជក្តី ការវាយដំក្មេង ឬសាមណេរជាដើមក្តី អំពើទាំងនេះ មិនហៅត្រឹមតែកាយទុច្ចរិតតែម្យ៉ាង តាមតព្វាហុល្លន័យប៉ុណ្ណោះ រមែងហៅថាវចីទុច្ចរិត ឬមនោទុច្ចរិតក៏បាន គឺថាបើធ្វើខ្លួនឯង ក៏ហៅថាកាយទុច្ចរិត (ធ្វើមិនល្អ) ប្រើគេឲ្យធ្វើក៏ហៅថាវចីទុច្ចរិត (និយាយមិនល្អ) បើគិតនឹងធ្វើក៏ហៅថា មនោទុច្ចរិត (គិតមិនល្អ) ឬក្នុងមុសាវាទនោះ ក៏មិនមែនហៅថា ជាវចីទុច្ចរិតប៉ុណ្ណោះ ហៅថា កាយទុច្ចរិត ឬមនោទុច្ចរិតក៏បាន គឺបើប្រើវាចាឡើងក៏ហៅថា វចីទុច្ចរិត បើប្រើសរសេរអក្សរ ក៏ហៅថា កាយទុច្ចរិត បើគិតមុសាក៏ហៅថា មនោទុច្ចរិត ឬការបង់បានទ្រព្យសម្បត្តិអ្នកដទៃ ដែលមិនប្រកបដោយគន្លងធម៌នោះ ក៏មិនមែនហៅថា មនោទុច្ចរិតប៉ុណ្ណោះទេ ហៅថា កាយទុច្ចរិត ឬវចីទុច្ចរិតក៏បាន គឺថា បើមានសេចក្តីចង់បានព្រងើយៗ មិនគិតថាឲ្យបានរបស់នោះមកជារបស់ខ្លួន ក៏ហៅថា មនោទុច្ចរិត បើមានសេចក្តីចង់បានហើយពោលវាចាឡើងថា របស់នុ៎ះល្អណាស់ក៏ហៅថា វចីទុច្ចរិត បើមានសេចក្តីចង់បានហើយ ចាប់កាន់របស់នោះមកមើល ក៏ហៅថាវចីទុច្ចរិតដូច្នេះ ទើបព្រះពុទ្ធឃោសាចារ្យ បានសម្តែងទុកក្នុង **អដ្ឋសាលិនី** អដ្ឋកថា ថា :

**កាយវចីទ្វារេសុ ហិ ចោបនំ បត្វា កម្មបថំ អប្បត្តម្បិ អត្ថិ មនោទ្វារេ ច សមុដ្ឋានំ បត្វា កម្មបថំ អប្បត្តម្បិ អត្ថិ តំ គហេត្វា តំតំទ្វារបក្ខិកមេវ អកំសុ** ប្រែថា អកុសលកម្មដែលចូលដល់ ការកម្រើករញ្ជួយក្នុងកាយទ្វារ និងវចីទ្វារតែមិនកន្លងកម្មបថក៏មានអកុសលកម្ម ដែលចូលដល់សេចក្តីកើតឡើងក្នុងមនោទ្វារ តែមិនកន្លងកម្មបថក៏មាន ព្រះអដ្ឋកថាចារ្យទាំងឡាយ កាន់យកអកុសលកម្មដែលមិនកន្លងកម្មបថទាំងនោះ ចាត់សង្គ្រោះចូលក្នុងទ្វារដែលកើតនោះៗ ។

## អំពីវិធីរាប់ចំនួនទុច្ចរិតដោយពិស្តារ

ទុច្ចរិត ១០ នេះ បើរាប់ដោយពិស្តារមាន ៣០ ឬ ៤០ ដែលរាប់ ៣០ នោះ គឺការធ្វើទុច្ចរិតមួយៗ ត្រូវប្រកបដោយចេតនា ៣ គឺ ៖

**១–បុព្វចេតនា** ចេតនាកើតមុនការធ្វើកម្ម

**២–មុញ្ចនចេតនា** ចេតនាកើតឡើងក្នុងខណៈធ្វើ

**៣–អបរចេតនា** ចេតនាដែលកើតឡើងក្នុងខណៈធ្វើរួចហើយ

ដូច្នេះ ទុច្ចរិត ១០ គុណនឹងចេតនា ៣ ត្រូវជាទុច្ចរិត ៣០ ។

ដែលថា ទុច្ចរិត ៤០ នោះ គឺទុច្ចរិតមួយៗ នោះចែកជា ៤ ប្រភេទគឺ៖

**១–សាហត្ថិកទុច្ចរិត** ធ្វើដោយខ្លួនឯង

**២–អាណត្តិកទុច្ចរិត** ប្រើអ្នកដទៃឲ្យធ្វើ

**៣–វណ្ណភាសនទុច្ចរិត** ពោលប្រយោជន៍របស់ការធ្វើទុច្ចរិតនោះៗ

**៤–សមនុញ្ញទុច្ចរិត** មានសេចក្តីពេញចិត្តក្នុងការធ្វើនោះៗ

ដូច្នេះទុច្ចរិត ១០ គុណដោយប្រភេទទាំង ៤ ត្រូវជាទុច្ចរិត ៤០ ក្នុងចំនួន ទុច្ចរិត ៣០ ឬ ៤០ ដែលពោលមកនេះ ខ្លះក៏កន្លងកម្មបថ អាចនាំទៅកាន់អបាយភូមិក៏មាន ខ្លះក៏មិនកន្លងកម្មបថ មិនអាចនាំទៅកាន់អបាយភូមិក៏មាន ដូចក្នុងការសម្លាប់សត្វ បើសត្វនោះស្លាប់ គឺចេតនាទាំង ៣ ដែលទាក់ទងនឹងបាណាតិបាតនេះ សម្រេចជាការកន្លងកម្មបថ បើសត្វនោះមិនស្លាប់ទេ ក៏មិនចាត់ជាកន្លងកម្មបថ ឯអទិន្នាទានទុច្ចរិត ៣ ជាដើម ក៏ប្រព្រឹត្តទៅតាមទំនងដូចគ្នានេះដែរ ។

ក្នុងទុច្ចរិត ៤០ នោះ ដូចបុគ្គល ៤ នាក់ នាំគ្នាសម្លាប់សត្វ ម្នាក់ជាអ្នកពោលពណ៌នាអំពីផលប្រយោជន៍នៃការសម្លាប់សត្វ អ្នកទីពីរជាអ្នកប្រើបញ្ជាឲ្យអ្នកទី ៣ ជាអ្នកសម្លាប់ ឯអ្នកទី ៣ ប្រតិបត្តិការធ្វើការសម្លាប់ទាល់តែសម្លាប់ ឯអ្នកទី ៤ មិនបានសម្តែងអ្វីតាមផ្លូវកាយ ផ្លូវវាចា គ្រាន់តែមានចិត្តត្រេកអរពេញចិត្តក្នុងការសម្លាប់សត្វនោះ បើសត្វនោះស្លាប់ ឯអ្នកពោលពណ៌នាអំពីផលប្រយោជន៍នៃការសម្លាប់ក្តី អ្នកដែលប្រើឲ្យគេសម្លាប់ក្តី ទាំងអ្នកសម្លាប់ក្តីទាំង ៣ នាក់នេះ ឈ្មោះថាកន្លងកម្មបថ ព្រោះវាគ្រប់អង្គទាំង ៥ ចំណែកអ្នកដែលគ្រាន់តែត្រេកអរក្នុងចិត្តនោះ មិនកន្លងកម្មបថទេ ព្រោះមិនទាន់គ្រប់អង្គ ខ្វះប្រយោគ ក្នុងអទិន្នាទានទុច្ចរិត ៤ ជាដើម ក៏ប្រព្រឹត្តទៅដូចគ្នានេះដែរ ។

អធិប្បាយក្នុងបាលីទី ៩-១០-១១ ដែលថា **តេសុ បាណាតិបាតោ ផរុសវាចា ព្យាបាទោ ច ទោសមូលេន ជាយន្តិ** ជាដើម រហូតដល់ **សេសានិ ចត្តារិបិ ទ្វីហិ មូលេហិ សម្ភវន្តិ។**

បាលីទាំងនេះ សម្តែងអំពីធម៌ដែលជាហេតុនៃអកុសលកម្ម គឺក្នុងពាក្យប្រែបាលីសេចក្តីទី ៩ ដែលពោលថា **បាណាតិបាត ផរុសវាចា ព្យាបាទ** ទាំង ៣ នេះ កើតឡើងព្រោះទោសមូលចិត្តជាហេតុ នោះជាពាក្យប្រែពោលរួមទុក ជាកណ្តាលៗ តែបើបែកដោយត្រង់ៗក៏ត្រូវ ប្រែថា **បាណាតិបាត ផរុសវាចា** កើតឡើងព្រោះអាស្រ័យទោសចេតសិក ដែលជាតួមូល **ព្យាបាទ** កើតឡើង ព្រោះអាស្រ័យចិត្តដែលមានទោសចេតសិក បានជាដូច្នោះ ព្រោះអង្គធម៌របស់បាណាតិបាត និងផរុសវាចា បានដល់ចេតនាដែលប្រកបជាមួយទោសចេតសិក ដូច្នោះអកុសលកម្មទាំងពីរនេះ ប្រកបជាមួយទោសមូល គឺទោសចេតសិក មានន័យថា អកុសលកម្មទាំង ២ នេះ ដែលកើតឡើងបាន

ក៏ព្រោះបានទទួលការឧបត្ថម្ភពីទោសចេតសិក ដែលតាំងនៅក្នុងឋានៈ ជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ បាណាតិបាត និងផរុសវាចា ចេតនា ជាបច្ចយុប្បន្ន ។

ចំណែកព្យាបាទ អង្គធម៌បានដល់ ទោសចេតសិក ដូច្នោះទោសចេតសិក ដែលមកប្រកបជាមួយព្យាបាទទៀតនោះ មិនមានដោយហេតុនេះ ការកើតឡើងបាន របស់ព្យាបាទ ព្រោះបានទទួលឧបត្ថម្ភពីទោសមូលចិត្ត ដែលប្រកបជាមួយទោសចេតសិកនោះឯង ដូច្នោះតួទោសមូលចិត្ត រមែងតាំងនៅក្នុងឋានៈ ជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ទោសចេតសិក ដែលជាតួព្យាបាទ ជាបច្ចយុប្បន្ន ដូច្នោះការសម្ដែងវចនត្ថៈ របស់ពាក្យថាទោសមូល ត្រូវសម្ដែងជា ៣ យ៉ាងដូច្នេះ

**ទោសោ ច សោ មូលញ្ចាតិ = ទោសមូលំ** ធម៌ឯណាជាទោសៈផង ជាមូលផង ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា ទោសមូល បានដល់ទោសចេតសិក វចនត្ថៈនេះសំដៅក្នុងន័យនៃសមុដ្ឋានរបស់បាណាតិបាត និងផរុសវាចា ។

**ទោសោ មូលំ យស្សាតិ = ទោសមូលំ** មូលគឺទោសៈ មាននៅក្នុងចិត្តឯណា ព្រោះហេតុនោះ ចិត្តនោះឈ្មោះថា ទោសមូល បានដល់ទោសមូលចិត្ត វចនត្ថៈនេះសំដៅក្នុងន័យនៃសមុដ្ឋានរបស់ព្យាបាទ ។

ក្នុងពាក្យប្រែបាលីទី ១០ ដែលពោលថា កាមេសុមិច្ឆាចារ អភិជ្ឈា មិច្ឆាទិដ្ឋិ ទាំង ៣ នេះ រមែងកើតឡើង ព្រោះលោភមូលចិត្តជាហេតុនោះជាពាក្យប្រែ ដែលពោលរួមទុកជាកណ្ដាលដូចគ្នា បើចែកចេញមួយៗ ត្រូវប្រែថា កាមេសុ មិច្ឆាចារ និងមិច្ឆាទិដ្ឋិ ទាំង ២ នេះកើតឡើង ព្រោះអាស្រ័យលោភចេតសិកដែលជាតួមូល អភិជ្ឈាកើតឡើង ព្រោះអាស្រ័យចិត្តដែលមានលោភចេតសិក ព្រោះអង្គធម៌របស់កាមេសុ មិច្ឆាចារ បានដល់ចេតនាដែលប្រកបនឹងលោភចេតសិក អង្គធម៌របស់មិច្ឆាទិដ្ឋិ បានដល់ទិដ្ឋិដែលប្រកបជាមួយលោភចេតសិកដែលជាតួមូល ហេតុនេះ អកុសលកម្មទាំង ២ នេះ រមែងប្រកបជាមួយលោភមូល គឺ លោភចេតសិក គឺថា អកុសលកម្មទាំង ២ ដែលកើតឡើងបាននេះ

ព្រោះបានទទួលការឧបត្ថម្ភពីលោភចេតសិក ដែលតាំងនៅក្នុងឋានៈជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ កាមេសុ មិច្ឆាចារចេតនា និងមិច្ឆាទិដ្ឋិ ជាបច្ចយុប្បន្ន ។

ចំណែកអភិជ្ឈានោះ អន្តធម៌បានដល់ លោភចេតសិក ដូច្នោះលោភចេតសិក ដែលមកប្រកបជាមួយអភិជ្ឈាទៀតនោះមិនមាន ហេតុនោះការកើតឡើងរបស់អភិជ្ឈា ព្រោះបានការទទួលឧបត្ថម្ភពីលោភមូលចិត្ត ដែលប្រកបជាមួយលោភចេតសិកនោះឯង ដូច្នោះតួលោភ-មូលចិត្ត រមែងតាំងនៅក្នុងឋានៈជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ លោភចេតសិកដែលជាតួ អភិជ្ឈា ជាបច្ចយុប្បន្ន ដូច្នោះ កាលសម្តែងវចនត្ថៈ របស់ពាក្យថា **លោភមូល** ត្រូវសម្តែង ២ យ៉ាងដូច្នេះ ៖

**លោភោ ច សោ មូលញ្ចាតិ = លោភមូលំ** ធម៌ឯណាជាលោភៈផង ជាមូលផង ព្រោះហេតុដូច្នោះ ធម៌នោះ ឈ្មោះថា លោភមូល បានដល់លោភចេតសិក វចនត្ថៈនេះសំដៅន័យនៃសមុដ្ឋានរបស់កាមេសុ មិច្ឆាចារ និងមិច្ឆាទិដ្ឋិ ។

**លោភោ មូលំ យស្សាតិ = លោភមូលំ** មូលគឺលោភៈមាននៅក្នុងចិត្តឯណា ព្រោះហេតុនោះ ចិត្តនោះឈ្មោះថា លោភមូល បានដល់លោភមូលចិត្ត វចនត្ថៈនេះ សំដៅក្នុងន័យនៃសមុដ្ឋានរបស់អភិជ្ឈា ។

ពណ៌នាសេចក្តីតាមបាលីទី ៩-១០ ដូចពោលមកនេះ ជាការពណ៌នាតាម **បរមត្ថ-ទីបនីដីកា** បើពិចារណាក្នុង ពាក្យថា **ទោសមូលេន ជាយន្តិ លោភមូលេន ជាយន្តិ** <u>ប្រែថា</u> រមែងកើតឡើង ព្រោះអាស្រ័យទោសមូលរមែងកើតឡើង ព្រោះអាស្រ័យលោភ-មូលក៏បាន ព្រោះថាមុននឹងព្យាបាទកើតឡើងនោះ រមែងមានបុព្វចេតនាកើតឡើងមុន ក្នុងបុព្វចេតនានោះ មានទោសចេតសិកដែលនៅក្នុងបុព្វចេតនាហើយ ក៏ពោលបានថាព្យាបាទកើតឡើង ព្រោះអាស្រ័យទោសមូលដូចគ្នា និងការកើតឡើងរបស់បាណាតិបាត និងផរុសវាចា ក្នុងទីនេះទោសៈដែលនៅក្នុងបុព្វចេតនា ជាបកតូបនិស្សយប្បច្ច័យ ព្យាបាទ

ដែលជាតួទោសៈ ដែលកើតឡើងខាងក្រោយ ជាបកតូបនិស្សយប្បច្ចយុប្បន្ន ចំណែក បច្ច័យ និងបច្ចយុប្បន្ន ចន្លោះទោសចេតសិក និងបាណាតិបាត និងផរុសវាចានោះ គប្បីយល់ដូចដែលបានពោលមកហើយ ។

មុនដែលអភិជ្ឈានឹងកើតឡើងនោះ រមែងមានបុព្វចេតនាដែលប្រកបជាមួយលោភ-ចេតសិកកើតឡើងមុន បើពោលដោយអត្ថន័យ លោភចេតសិកដែលនៅក្នុងបុព្វចេតនាហើយ ក៏អាចពោលបានថា អភិជ្ឈាកើតឡើង ព្រោះអាស្រ័យលោភមូលដូចគ្នា នឹងការកើតឡើងរបស់កាមេសុ មិច្ឆាចារ និងមិច្ឆាទិដ្ឋិក្នុងទីនេះ លោភៈដែលនៅក្នុងបុព្វចេតនាដែលជាបកតូបនិស្សយប្បច្ច័យ អភិជ្ឈាដែលជាតួលោភៈ ដែលកើតឡើងខាងក្រោយ ជាបកតូបនិស្សយប្បច្ចយុប្បន្ន ចន្លោះលោភចេតសិក និង កាមេសុ មិច្ឆាចារ និងមិច្ឆាទិដ្ឋិនោះគប្បីជ្រាបដូចបានពោលមកហើយ ។

ការពណ៌នារឿងសមុដ្ឋានរបស់អភិជ្ឈា និងព្យាបាទ ដូចពោលមកហើយនេះ ជាការពណ៌នាតាមភាសាដីកា ក្នុងពាក្យប្រែបាលីទី ១១ ដែលពោលថា អកុសលកម្មបថ ៤ ដែលនៅសល់បានដល់ **អទិន្នាទាន មុសាវាទ បិសុណាវាចា សម្ផប្បលាបៈ** ទាំងអស់នេះ ជួនកាលកើតឡើង ព្រោះអាស្រ័យលោភៈជាសមុដ្ឋាន ជួនកាលកើតឡើង ព្រោះអាស្រ័យទោសៈ ដូច្នោះទើបពោលថា កើតឡើងព្រោះអាស្រ័យមូលទាំង ២ លោភៈ និងទោសៈ ។

អធិប្បាយការកើតឡើងរបស់អកុសលកម្មបថ៤ ដែលអាស្រ័យលោភៈ និងទោសៈជាសមុដ្ឋានដោយត្រង់ដូចតទៅនេះ

**១- អទិន្នាទាន** ដែលកើតឡើងដោយអាស្រ័យលោភៈជាសមុដ្ឋាន គឺអ្នកដែលធ្វើការលួចទ្រព្យសម្បត្តិរបស់អ្នកដទៃ ដោយមានសេចក្តីចង់បាន ដើម្បីជាប្រយោជន៍របស់ខ្លួន ឬដើម្បីជាប្រយោជន៍ញាតិមិត្ត កូន ចៅ ស្វាមី ភរិយា ដូច្នេះ ហៅថា អទិន្នាទាននោះកើតឡើងព្រោះអាស្រ័យលោភៈជាសមុដ្ឋាន ។

**២-អភិជ្ឈាទាន** *ដែលកើតឡើងព្រោះអាស្រ័យទោសៈជាសមុដ្ឋាន គឺអ្នកដែលធ្វើការលួចប្លន់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ដោយមិនមែនដើម្បីចង់បានទេ តែធ្វើនេះ ដើម្បីឲ្យគេបានទទួលសេចក្ដីក្ដៅក្រហាយ ឬបណ្ដឲ្យកើតវិនាសទាស់ទែងគ្នា ឬធ្វើដើម្បីសងសឹក ដែលខ្លួនមានសេចក្ដីស្អប់ខ្ពើមអ្នកនោះ ដូច្នេះអភិជ្ឈាទាននោះ កើតឡើងព្រោះអាស្រ័យទោសៈជាសមុដ្ឋាន ។*

**៣- មុសាវាទ** *ដែលកើតឡើងដោយអាស្រ័យលោភៈជាសមុដ្ឋាន គឺបុគ្គលដែលស៊ីឈ្នួលធ្វើសាក្សីឲ្យការកុហកតុលាការ ដោយត្រូវការសំណូករង្វាន់ជាដើមដូច្នេះ មុសាវាទនេះ កើតឡើងព្រោះអាស្រ័យលោភៈជាសមុដ្ឋាន ។*

**៤- មុសាវាទ** *ដែលកើតឡើងដោយអាស្រ័យទោសៈជាសមុដ្ឋាន គឺបាន ដល់បុគ្គលពោលពាក្យកុហកដើម្បីដាក់កំហុសទៅលើភាគីម្ខាងទៀត ឲ្យបានទទួល សេចក្ដីវិនាសអន្តរាយក្ដៅក្រហាយ ដូច្នេះ មុសាវាទនោះកើតឡើង ព្រោះអាស្រ័យទោសៈជាមូល ឬជាសមុដ្ឋាន ។*

**៥- បិសុណាវាចា** *ដែលកើតឡើងព្រោះអាស្រ័យលោភៈជាសមុដ្ឋាន គឺបុគ្គលដែលពោលពាក្យញុះញង់ សឹកសៀតចង់ឲ្យគេស្រលាញ់ខ្លួន ដូច្នេះឈ្មោះថា បិសុណា-វាចា កើតឡើងព្រោះអាស្រ័យលោភៈ ជាសមុដ្ឋាន ។*

**៦- បិសុណាវាចា** *ដែលកើតឡើងព្រោះអាស្រ័យទោសៈជាសមុដ្ឋាន គឺ បុគ្គលពោលពាក្យញុះញង់សឹកសៀត ចង់ឲ្យគេបែកគ្នា ដូច្នេះឈ្មោះថា បិសុណាវាចានោះ កើតឡើងព្រោះអាស្រ័យទោសៈជា សមុដ្ឋាន ។*

**៧- សម្ផប្បលាបៈ** *ដែលកើតឡើងដោយអាស្រ័យលោភៈជាសមុដ្ឋាន គឺបុគ្គលដែលពោល ឬសរសេររឿងរ៉ាវ រវើរវាយគ្មានសារប្រយោជន៍ កំប្លុកកំប្លែង ដើម្បីស៊ីឈ្នួល*

គេក្តី ឬបុគ្គលដែលមាននិស្ស័យពាល ឬសរសេររឿងរ៉ាវមិនពិត ដើម្បីសប្បាយលេង សើច ដូច្នេះ ឈ្មោះថា សម្ផប្បលាបៈនោះ កើតឡើងព្រោះអាស្រ័យលោភៈជាសមុដ្ឋាន ។

**៨- សម្ផប្បលាបៈ** ដែលកើតឡើងដោយអាស្រ័យទោសៈជាសមុដ្ឋាន គឺ បុគ្គលដែលពាល ឬសរសេរតែងរឿងរ៉ាវ ដោយប្រាថ្នាឲ្យភាគីម្ខាងទៀតបានទទួលសេចក្តីវិនាសអន្តរាយ ព្រោះរឿងរ៉ាវអកុសលគ្មានខ្លឹមសារ ដូច្នេះ ឈ្មោះថា សម្ផប្បលាបៈនោះ កើតឡើងព្រោះអាស្រ័យទោសៈ ជាសមុដ្ឋាន ។

ចំណែកការកើតឡើងរបស់អកុសលកម្មបថ ដែលមិនបានលើកយកមោហៈជាសមុដ្ឋានឡើងសម្តែងនោះ ព្រោះថាមោហៈជាអកុសលសាធារណៈ គឺមានទូទៅក្នុងការងារជាអកុសលស្រាប់ហើយ ព្រោះហេតុនោះ អកុសលកម្មបថឯណាមួយកើតឡើងក៏ដោយ ក៏មានមោហៈជាសមុដ្ឋានស្រេចក្នុងខ្លួនរួចទៅហើយ ។

## ការចែកអកុសលកម្មបថ ១០ ជា ៥ យ៉ាង

## ពោលដោយអង្គធម៌ជាដើម

ធម្មតោ ចេវ កោដ្ឋាស អារម្មណា ច វេទនា

មូលតោ បញ្ចាកាលេហិ វេទិតព្វោ វិនិច្ឆយោ ។

គប្បីជ្រាបការវិនិច្ឆ័យក្នុងអកុសលកម្មបថ ១០ ដោយប្រការ ៥ យ៉ាង គឺពោល ដោយអង្គធម៌ ដោយពួក ដោយអារម្មណ៍ ដោយវេទនា ដោយមូល ។ អធិប្បាយ ពង្រីកសេចក្តីដូចតទៅនេះ៖

**១–ធម្ម** ដោយអង្គធម៌ គឺ កាយទុច្ចរិត ៣ វចីទុច្ចរិត ៤ រួមជា ៧ យ៉ាងនេះ អង្គធម៌ បានដល់ ចេតសិក, មនោទុច្ចរិត ៣ អង្គធម៌ បានដល់ចេតសិកដែលកើតព្រមជាមួយចេតសិក ។

**២–កោដ្ឋាស** ពោលដោយពួក គឺកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ និងមិច្ឆាទិដ្ឋិ ១ ទាំង ៨ យ៉ាងនេះ ឈ្មោះថា កម្មបថប៉ុណ្ណោះ មិនមែនឈ្មោះថាមូល អភិជ្ឈា និងព្យាបាទ ទាំង ២ នេះ ឈ្មោះថា កម្មបថផង និងឈ្មោះថាជាមូល ។

**៣– អារម្មណ** ពោលដោយអារម្មណ៍ គឺបាណាតិបាត កាមេសុមិច្ឆាចារ មិច្ឆាទិដ្ឋិទាំង ៣ នេះ កើតឡើងដោយមានសង្ខារធម៌ជាអារម្មណ៍ (អាចារ្យខ្លះលោកពោលថា កាមេសុ មិច្ឆាចារនេះ កើតឡើងដោយមានសត្វបញ្ញត្តិជាអារម្មណ៍ អកុសលផរុសវាចា ព្យាបាទទាំង ២ នេះ កើតឡើងដោយមានសត្វបញ្ញត្តិជាអារម្មណ៍ អកុសលកម្មបថ សល់ ៥ គឺ **អទិន្នាទាន មុសាវាទ បិសុណាវាចា សម្ផប្បលាប អភិជ្ឈា** ទាំងនេះកើតឡើងដោយមានសង្ខារធម៌ និងសត្វបញ្ញត្តិ ជាអារម្មណ៍ ។

**៤–វេទនា** ពោលដោយការសោយ គឺបាណាតិបាត ផរុសវាចា ព្យាបាទ ទាំង ៣ នេះ កើតព្រមដោយទុក្ខវេទនា, កាមេសុ មិច្ឆាចារ, អភិជ្ឈា, មិច្ឆាទិដ្ឋិ, ទាំង ៣ នេះ កើតព្រមដោយសុខវេទនាក៏មាន ឧបេក្ខាវេទនាក៏មាន អកុសលកម្មបថដែលសល់ ៤ គឺ **អទិន្នាទាន មុសាវាទ បិសុណាវាចា សម្ផប្បលាបៈ** ទាំងអស់នេះ កើតព្រមដោយសុខវេទនាក៏មាន ទុក្ខវេទនាក៏មាន ឧបេក្ខាវេទនាក៏មាន ។

**៥–មូល** ពោលដោយមូល គឺបាណាតិបាត ផរុសវាចា ទាំង ២ នេះ មាន ទោសៈ និងមោហៈជាមូល, កាមេសុ មិច្ឆាចារ មិច្ឆាទិដ្ឋិទាំង ២ នេះ មានលោភៈ និងមោហៈជាមូល, អទិន្នាទាន មុសាវាទ បិសុណាវាចា សម្ផប្បលាបៈទាំង ៤ នេះ ជួនកាលក៏មានលោភៈ

និងមោហៈជាមូល ជួនកាលក៏មាន ទោសៈ និងមោហៈ ជាមូល, អភិជ្ឈា ព្យាបាទទាំង ២ នេះ មានមោហៈតែមួយជាមូល ការសម្តែងចែកដោយមូល ដែលពោលមកនេះ ជាការសម្តែងតាមសាធារណន័យ ដែលពោលទុកក្នុង **អដ្ឋសាលិនីអដ្ឋកថា** ។

ចំណែក ការសម្តែងមូលនៃអកុសលកម្មបថ ដែលពោលទុកក្នុងអភិធម្មត្ថសង្គហៈ **តេសុ ចាណាតិបាតោ ផរុសវាចា ព្យាបាទោ ច ទោសមូលេន ជាយន្តិ** ជាដើមនោះ ជាការសម្តែងដោយអសាធារណន័យ គឺសម្តែងមិនច្របូកច្របល់គ្នា ។

អធិប្បាយបាលីទី ១២ ដែលថា **ចិត្តុប្បាទវសេន បនេតំ អកុសលំ សព្វថាបិ ទ្វាទសវិធំ ហោតិ** អកុសលកម្មនេះ បើពោលដោយអំណាច នៃការកើតឡើងរបស់ចិត្តនោះបីប្រការណាក៏ដោយ រមែងមាន ១២ យ៉ាង ។

អធិប្បាយថា ក្នុងបាលីនេះ បានសម្តែងអំពីការកើតឡើងរបស់ចិត្តដែលទាក់ទងជាមួយអកុសលកម្មបថ ១០ ក្នុងការប្រព្រឹត្តទុច្ចរិតផ្សេងៗ របស់មនុស្សទាំងឡាយនោះ ក្នុងមនុស្សម្នាក់ ក៏មានការប្រព្រឹត្តចែកជា ៣ យ៉ាង គឺ ជួនកាលប្រព្រឹត្តដោយផ្លូវកាយ ហៅថា ធ្វើមិនល្អ ធ្វើឲ្យអ្នកដទៃ និងខ្លួនឯងបានទទួលសេចក្តីក្តៅក្រហាយស្តាយក្រោយ ជួនកាលធ្វើដោយផ្លូវវាចា ហៅថា និយាយមិនល្អ ធ្វើឲ្យអ្នកដទៃ និងខ្លួនឯងបានទទួលសេចក្តីវិនាសកើតក្តៅក្រហាយស្តាយក្រោយ ជួនកាលធ្វើតាមផ្លូវចិត្ត ហៅថា គិតមិនល្អ ធ្វើឲ្យអ្នកដទៃ និងខ្លួនឯងបានទទួលសេចក្តីវិនាសអន្តរាយក្តៅក្រហាយស្តាយក្រោយ ។ បើចែកតាមប្រភេទនៃការប្រព្រឹត្តនោះ ក៏មាន ១០ យ៉ាង គឺធ្វើមិនល្អ ៣ និយាយមិនល្អ ៤ គិតមិនល្អ ៣ យ៉ាង បើរាប់ដោយពិស្តារ ៣០ ក៏មាន ដូចបានពោលពីខាងដើមមកហើយ ។ ទាំងនេះជាការបញ្ជាក់ចំនួនទុច្ចរិត ដែលពោលដោយវោហារដែលប្រព្រឹត្តទៅក្នុងលោក តែទុច្ចរិតផ្សេងៗនេះ បើពោលដោយបរមត្ថសភាវធម៌ ដែលជាដើមហេតុឲ្យកើតទុច្ចរិតបាននោះ បានដល់ចិត្ត ២ ដួងប៉ុណ្ណោះ គឺចិត្តដែលមានលោភៈជាប្រធានមាន ៨ ដួង

ឈ្មោះថា លោភមូលចិត្ត ចិត្តដែលមានទោសៈជាប្រធានមាន ២ ដួង ឈ្មោះថា មោហ-មូលចិត្ត រួមត្រូវជាអកុសលចិត្ត ១២ ដួង ព្រមទាំងចេតសិកដែលប្រកប ២៧ ហៅថា អកុសលចិត្តុប្បាទ ដែលជាអន្តធម៌ក្នុងការប្រព្រឹត្តអកុសលផ្សេងៗ របស់សត្វទាំងឡាយ មិនចាត់ជាអកុសលប្រភេទណាក៏ដោយ ក៏រមែងមិនផុតពីអកុសលចិត្តុប្បាទ ១២ ដួង ដូចបានពណ៌នាមកនេះ ។

***ចំណែកកុសលកម្មបថ១០ មិនលើកមកក្នុងសៀវភៅនេះទេ តែសូមទៅមើលក្នុងគម្ពីរ*** **មជ្ឈិម. មូល.** ចូឡយមកវគ្គ ត្រង់វេរញ្ជកសូត្រទី២ ២២/២៤៧ ។ **មជ្ឈិម. មូល.** ត្រង់មូលបរិយាយវគ្គ សម្មាទិដ្ឋិសូត្រ ២០/១៥៤ ។ **សំ.** និទានវគ្គ ទសកម្មបថវគ្គទី៣ ត្រង់ទសកម្មបថសូត្រ ទី៥ ៣២/៥៧ ។ ***សារត្ថប្បកាសិនី*** អដ្ឋកថា ***សំ.*** និទានវគ្គ ទសកម្មបថវគ្គទី៣ ត្រង់ទសកម្មបថសូត្រទី៥ ***អំ. ទសកឯកនិបាត*** ជាណុស្សោណិវគ្គទី២ ៥១/១២៣ ។ បឋមវគ្គទី១ ធម្មបរិយាយសូត្រទី៥ និង បឋមកម្មសូត្រទី៦ ៥១/១៦៦ ។ ***មនោរថបូរណី*** អដ្ឋកថា ***អំ. ទសក-ឯកនិបាត*** បឋមវគ្គទី១ ធម្មបរិយាយសូត្រទី៥ និង បឋមកម្មសូត្រទី៦ **មជ្ឈិម. មជ្ឈិម.** ព្រាហ្មណវគ្គ ត្រង់អស្សលាយនសូត្រ ២៥/៦១ ។ ***បបញ្ចសូទនី*** អដ្ឋកថា **មជ្ឈិម. មូល.** ចូឡយមកវគ្គ ត្រង់សាលេយ្យកសូត្រទី១

**អកុសលកម្មបថ១០ ចប់**

## បញ្ហាកម្មរបស់សីល

*<u>បញ្ហាកម្មថា</u> អ្វីឈ្មោះថា សីល ?*

*<u>ឆ្លើយថា</u> ធម៌ទាំងឡាយ មានចេតនាជាដើម របស់បុគ្គលដែលវៀរចាកបាបកម្ម មានបាណាតិបាតជាដើមក្តី របស់អ្នកបំពេញវត្តប្រតិបត្តិក្តី ឈ្មោះថា សីល ។*

*ពាក្យនេះ សមដូចព្រះសារីបុត្តត្ថេរ ពោលទុកក្នុងគម្ពីរបដិសម្ភិទាមគ្គថា :*

*"<u>សួរថា</u> អ្វីឈ្មោះថា សីល?*

*<u>ឆ្លើយថា</u>* **ចេតនា** *ឈ្មោះថា សីល,* **ចេតសិក** *ឈ្មោះថា សីល,* **សំវរៈ** *(សេចក្តីសង្រួម) ឈ្មោះថា សីល,* **អវិតិក្កម** *(ការមិនប្រព្រឹត្តិកន្លង) ឈ្មោះថា សីល" ។*

*ក្នុងសីលទាំងនោះ ចេតនា របស់បុគ្គលអ្នកវៀរចាកអកុសលកម្ម មានបាណាតិបាតជាដើមក្តី របស់បុគ្គលអ្នកបំពេញវត្តប្រតិបត្តិក្តី ឈ្មោះថា* **ចេតនាសីល** *។*

*ចេតនាជាហេតុវៀរ របស់បុគ្គលអ្នកដែលវៀរចាកអកុសលកម្ម មានបាណាតិបាតជាដើម ឈ្មោះថា* **ចេតសិកសីល** *។*

*មួយវិញទៀត ចេតនាប្រព្រឹត្តទៅក្នុងកម្មបថ ៧ របស់បុគ្គលអ្នកលះបង់អកុសលកម្ម មានបាណាតិបាតជាដើម ឈ្មោះថា* **ចេតនាសីល** *។*

*ធម៌គឺអភិជ្ឈា, អព្យាបាទ និងសម្មាទិដ្ឋិ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដោយន័យជាអាទិ៍ ថា "ភិក្ខុលះបង់អភិជ្ឈា មានចិត្តប្រាសចាកអភិជ្ឈា" ដូច្នេះ ឈ្មោះថា* **ចេតសិកសីល** *។*

## សំវរៈ ៥ យ៉ាង

ក្នុងពាក្យថា "សំវរៈ ឈ្មោះថា សីល" នេះបណ្ឌិតគប្បីជ្រាប សំវរៈ ៥ ប្រការគឺ **ធាតិមោក្ខសំវរៈ១ សតិសំវរៈ១ ញាណសំវរៈ១ ខន្តិសំវរៈ១ វីរិយសំវរៈ១ ។**

បណ្តាសំវរៈទាំង ៥ នោះ ។ សំវរៈនេះថា "ភិក្ខុជាអ្នកចូលដល់ហើយ ជាអ្នកប្រកបព្រមហើយ ដោយបាតិមោក្ខសំវរៈ នេះ" ឈ្មោះថា **ធាតិមោក្ខសំវរៈ** ។

សំវរៈនេះ "ភិក្ខុរក្សាចក្ខុន្ទ្រីយ៍ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រីយ៍" ឈ្មោះថា **សតិសំវរៈ** ។

សំវរៈនេះ (ដោយពាក្យ) ថា :

ព្រះមានព្រះភាគទ្រង់ត្រាស់តបថា : ម្នាលអជិតៈ ក្រសែនៃ (តណ្ហា) ទាំងឡាយណា មានក្នុងលោក, សតិជាគ្រឿងឃាត់នូវក្រសែទាំងឡាយនោះ, តថាគត ហៅសតិ ថា ជាគ្រឿងបិទបាំងនូវក្រសែទាំងឡាយ តែក្រសែទាំងនោះអ្នកប្រតិបត្តិ ត្រូវបិទដោយបញ្ញា ដូច្នេះ ឈ្មោះថា **ញាណសំវរៈ** ។

សូម្បីការសេពនូវបច្ច័យ រមែងដល់នូវការប្រជុំចុះ ក្នុងញាណសំវរៈនេះដែរ ។

ចំណែកសំវរៈ ដែលមកដោយន័យថា "ភិក្ខុជាអ្នកអត់ទ្រាំចំពោះត្រជាក់ក្តៅ" ដូច្នេះជាដើមនេះ ឈ្មោះថា **ខន្តិសំវរៈ** ។

ឯសំវរៈ ដែលមកដោយន័យថា "ភិក្ខុតែងអត់សង្កត់នូវកាមវិតក្កៈ ដែលកើតឡើងហើយ" ដូច្នេះជាដើម ឈ្មោះថា **វីរិយសំវរៈ** ។ សូម្បីអាជីវបារិសុទ្ធិសីល រមែងដល់នូវការប្រជុំចុះក្នុង វីរិយសំវរៈនេះដែរ ។

សំវរៈ ៥ ប្រការនេះក្តី ការវៀរចាកវត្ថុដែលដល់ព្រមរបស់ពួកកុលបុត្រ ដែលភ័យខ្លាចបាបក្តី, កិរិយាសង្រួម និងការវៀរទាំងអស់នោះ បណ្ឌិតគប្បីជ្រាបថា សំវរៈ យ៉ាងដូច្នេះ ។

ពាក្យថា "**អវិតិក្កម** (ការមិនប្រព្រឹត្តិកន្លង) ឈ្មោះថា សីល" បានដល់ការមិនប្រព្រឹត្តិកន្លង ដែលប្រព្រឹត្តទៅខាងផ្លូវកាយវាចា និងផ្លូវចិត្តរបស់បុគ្គលអ្នកដែលបានសមាទានសីលហើយ ។ នេះគឺជា សេចក្តីដោះស្រាយនូវបញ្ហាកម្មថា "អ្វីឈ្មោះថា សីល ។

## អត្ថរបស់សីល

ពាក្យថា "ដែលឈ្មោះថា សីល ព្រោះអត្ថថាដូចម្តេច?" ។

ឆ្លើយថា ដែលឈ្មោះថា សីល ព្រោះអត្ថថា ជា**សីលនៈ**គឺប្រក្រតី ។

ឈ្មោះ សីលនៈ នេះ គឺជាអ្វី? ។

ដែលឈ្មោះថា សីលនៈ នេះ គឺការតម្កល់នៅស៊ប់ មានសេចក្តីថា ភាពនៃកម្មទាំងឡាយ មានកាយកម្មជាដើម ជាធម្មជាតិមិនរាត់រាយ ដោយអំណាចភាវៈនៃបុគ្គលជាអ្នកមានសីលល្អប្រពៃ១ ។ គឺការចូលទៅទ្រទ្រង់ទុក អធិប្បាយថា : ភាវៈនៃការទ្រទ្រង់ទុក ដោយអំណាចនៃការទ្រទ្រង់នូវកុសលធម៌ទាំងឡាយ ១ ។ មែនពិត ពួកអ្នកប្រាជ្ញដែលដឹងនូវលក្ខណៈនៃស័ព្ទ យល់ព្រមតាមអត្ថទាំង ២ យ៉ាងនេះប៉ុណ្ណោះ ក្នុងបទថា "សីល" នេះ ។ ចំណែកពួកអ្នកប្រាជ្ញដទៃទៀត ពណ៌នាសេចក្តីក្នុងបទថា សីលនេះ ដោយន័យថា "សីលស័ព្ទនេះ មានសេចក្តីថា **សិរៈ**(ខ្ពង់ខ្ពស់), មានសេចក្តីថា **សីសៈ** (កំពូល), មានសេចក្តីថា **សីតលៈ** (ត្រជាក់), មានសេចក្តីថា **សិវៈ** (ក្សេមក្សាន្ត)" ដូច្នេះជាដើមខ្លះ ក៏មាន ។

## (លក្ខណៈ, រស, បច្ចុប្បដ្ឋាន, បទដ្ឋាន នៃសីល)

*អ្វីជាលក្ខណៈ, ជារស, ជាបច្ចុប្បដ្ឋាន, ជាបទដ្ឋាន នៃសីលនោះ ។*

**សីលនៈ** *(ភាពជាប្រក្រតី) ជាលក្ខណៈ របស់សីលនោះ សូម្បីផ្សេងគ្នាដោយប្រការដ៏ច្រើន ប្រៀបដូចជារបស់មានវិស័យដែលប្រព្រឹត្តទៅក្នុងកិរិយាឃើញច្បាស់ ជាលក្ខណៈ របស់រូបដែលមានប្រការផ្សេងគ្នា ដ៏ច្រើនក៏យ៉ាងដូច្នោះឯង ។*

*មែនពិត ភាវៈនៃកិច្ចប្រព្រឹត្តទៅក្នុងការឃើញ ឈ្មោះថា ជាលក្ខណៈរបស់រូបាយតនៈ សូម្បីផ្សេងគ្នាដោយប្រការដ៏ច្រើនដែលមានពណ៌ខៀវ និងពណ៌លឿងជាដើម ព្រោះរូបាយតនៈ សូម្បីដែលផ្សេងគ្នាច្រើនប្រការ ដោយប្រភេទនៃពណ៌ មានពណ៌ខៀវជាដើម ក៏មិនប្រព្រឹត្តកន្លងនូវភាពជារបស់មានវិស័យ ដែលគប្បីមើលឃើញទៅបានដែរយ៉ាងណាមិញ, សីលនស័ព្ទ ដែលបានពោលហើយ ដោយអំណាចនៃការតម្កល់នៅស៊ប់នៃកម្មទាំងឡាយ មានកាយកម្មជាដើម និងដោយអំណាចនៃការតម្កល់ទុកនូវកុសលធម៌ទាំងឡាយនោះឯង ជាលក្ខណៈ របស់សីល សូម្បីផ្សេងគ្នាច្រើនជាអនេក ដោយប្រភេទនៃធម៌ មានចេតនាជាដើម ព្រោះភាវៈនៃសីល សូម្បីផ្សេងគ្នា ដោយប្រការមិនមែនតែមួយ ដោយប្រភេទនៃធម៌មានចេតនាជាដើម មិនកន្លងផុតនូវភាវៈជាទីតម្កល់នៅស៊ប់ និងភាវៈជាទីតម្កល់ទុកបានដែរ ក៏យ៉ាងដូច្នោះ ។*

## រស របស់សីល

*ចំណែកភាវៈនៃការកម្ចាត់បង់ នូវភាពនៃបុគ្គលទ្រុស្តសីល ឬគុណ*
*គឺកម្មដែលមិនមានទោស លោកហៅឈ្មោះថា ជារស ដោយអត្ថថា*
*ជាកិច្ច និងជាសម្បត្តិរបស់សីលនោះ ដែលមានលក្ខណៈ*
*ដូចពោលមកហើយ ។*

*ព្រោះហេតុនោះ ឈ្មោះថា សីលនេះ បណ្ឌិតគប្បីជ្រាបថា "មានកិរិយាកម្ចាត់បង់នូវភាពនៃបុគ្គលទ្រុស្តសីល ជារស ដោយរសដែលមានកិច្ចជាអត្ថ មានកម្មដែលមិនមាន*

ទោស ជារស ដោយរសដែលមានសម្បត្តិជាអត្ថ” ។ មែនពិត កិច្ចនុ៎ះឯងក្តី សម្បត្តិក្តី លោកហៅថា រស ក្នុងជំនុំបញ្ហាទាំង ៤ មានលក្ខណៈជាដើម ។

## បច្ចុប្បដ្ឋាន និងបទដ្ឋាន

> សីលនេះនោះ ពួកវិញ្ញូជនពណ៌នាថា “មានសេចក្តីស្អាត ជាបច្ចុប្បដ្ឋាន (ជាផល) ឱត្តប្បៈ និងហិរិនុ៎ះឯងជាបទដ្ឋាន (ជាហេតុជាទីតាំង) នៃសីលនោះ ។

មែនពិត សីលនេះនោះ មានសេចក្តីស្អាត ជាបច្ចុប្បដ្ឋាន ដែលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះថា “សីល មានសេចក្តីស្អាតខាងផ្លូវកាយ, ស្អាតខាងផ្លូវវាចា ស្អាតខាងផ្លូវចិត្ត” ដច្នេះ រមែងប្រាកដ គឺរមែងដល់នូវភាពនៃការប្រកាន់យក ដោយជាធម្មជាតស្អាត ។ ចំណែកហិរិ និងឱតប្បៈ អ្នកប្រាជ្ញពណ៌នាថា ជាបទដ្ឋាននៃសីលនោះ ។ អធិប្បាយថា : ជាហេតុជិត ។ ព្រោះថា ការបើមានហិរិ និងឱតប្បៈ, សីលរមែងកើតឡើងផង រមែងឋិតនៅផង ។ ការបើហិរិ និងឱតប្បៈមិនមានទេ, សីលក៏មិនកើតឡើង មិនឋិតនៅបានឡើយ ។ លក្ខណៈ, រស, បច្ចុប្បដ្ឋាន, និងបទដ្ឋាន របស់សីល បណ្ឌិតគប្បីជ្រាបយ៉ាងនេះឯង ។

## អានិសង្សរបស់សីល

**សីល** មានអានិសង្សយ៉ាងណា ? **សីល** មាន **អវិប្បដិសារៈ** ជា អានិសង្ស សមដូចព្រះពុទ្ធវចនៈ ដែលព្រះអង្គទ្រង់ត្រាស់ជាមួយ និងព្រះអានន្ទថា **សីល** ជាកុសល

មាន **អវិប្បដិសារៈ** ជាប្រយោជន៍ មាន **អវិប្បដិសារៈ** *ជាអានិសង្ស(១)[១០]* ។

*ន័យមួយទៀតថា ៖ ទីពឹង (ដទៃរបស់ពួកកុលបុត្រក្នុងសាសនានេះ វៀរចាកសីលណាហើយ មិនមានទេ, អ្នកណាគប្បីពោលនូវការកំណត់នូវអានិសង្សនៃសីលនោះបាន ។ ទឹកគឺសីល រមែងជម្រះនូវមន្ទិលណា របស់ពួកសត្វមានជីវិតក្នុងលោកនេះបាន, ស្ទឹងឈ្មោះគង្គាក្តី, យមុនាក្តី, អចិរវតីក្តី, មហីក្តី, មហានទីក្តី ក៏មិនអាចដើម្បីនឹងជម្រះនូវមន្ទិលរបស់ពួកសត្វនោះបានឡើយ, សីលនេះដែលបុគ្គលរក្សាបានល្អហើយ ជាអរិយសីល មានសេចក្តីត្រជាក់ ក្រេមក្សាន្ត រមែងរម្ងាប់នូវសេចក្តីក្រវល់ក្រវាយណារបស់សត្វទាំងឡាយក្នុងលោកនេះបាន, ខ្យល់ទាំងឡាយប្រកបដោយភ្លៀងក៏រម្ងាប់នូវសេចក្តីក្រវល់ក្រវាយនោះមិនបានឡើយ, សូម្បីខ្លឹមចន្ទន៍ក្រហម កែវមុក្តា កែវមុណី ពន្លឺព្រះច័ន្ទដ៏ស្រទន់ ក៏រម្ងាប់នូវសេចក្តីក្រវល់ក្រវាយនោះមិនបានដែរ ។ ក្លិនឯណា ផ្សាយទៅក្នុងទីបណ្តោយខ្យល់ និងក្នុង ទីច្រាសខ្យល់ស្មើគ្នា, ក្លិននោះ ស្មើដោយក្លិនគឺសីល នឹងមានឈ្មោះមកអំពីទីណាបាន ។ ទីពឹងដទៃ ជាជណ្តើរឡើងទៅកាន់ឋានសួគ៌ ឬក៏ជាទ្វារក្នុងកិរិយាចូលទៅកាន់នគរគឺព្រះនិព្វាន ដែលស្មើដោយសីល នឹងមានមកអំពីណា ។ ពួកភិក្ខុដែលមានឥន្ទ្រិយ៍សង្រួមហើយ ស្អិតស្អាងហើយដោយគ្រឿងស្អិតស្អាងគឺសីល រមែងល្អបានយ៉ាងណា, ព្រះរាជា ទាំងឡាយដែលស្អិតស្អាងហើយដោយកែវមុក្តា និងកែវមុណីក៏នៅតែមិនល្អបានយ៉ាងនោះ ។ សីលរបស់អ្នកមានសីលទាំងឡាយ រមែងកម្ចាត់បង់នូវភ័យ មានភ័យអំពីការតិះដៀលខ្លួនជាដើមបាន ដោយប្រការទាំងពួង ទាំងញ៉ាំងកិត្តិស័ព្ទ និងសេចក្តីរីករាយឲ្យកើតបានសព្វៗកាល ។ កថាខាងមុខដែលសម្តែងនូវអានិសង្សនៃសីលដែល ជាឫគល់នៃគុណទាំងឡាយ មានកិរិយាសម្លាប់នូវកម្លាំងនៃទោសទាំងឡាយ បណ្ឌិតគប្បីជ្រាបដូចដែលបានរៀបរាប់មកនេះឯង ។*

---

*១០. អង្គុត្ត. ទសក. ៥០।៣, អង្គុត្ត, ឯកាទស, ៥១।២២៣ ឥតិ ខោ អានន្ទ កុសលានិ សីលានិ អប្បដិសារត្ថានិ អប្បដិសារានិសំសានិ, ២ ខុទ្ទក.ថេរគាថា ៥៧।២៨ តិត្ថញ្ច សព្វពុទ្ធានំ តស្មា សីលំ វិសោធយេ, ៣ ខុទ្ទក.ថេរគាថា ៥៧।២៩ សីលំ វិលេបនំ សេដ្ឋំ, ។*

## ពោលអំពីឧបាសកវគ្គ

*នៅក្នុងគម្ពីរអង្គុត្តរនិកាយ បញ្ចកនិបាត បិដក៤៥ ទំព័រ១៥៥ ត្រង់ឧបាសកវគ្គ ពោល អំពីចណ្ឌាលឧបាសក មលឧបាសក បដិកិដ្ឋឧបាសក និងពោលអំពី រតនឧបាសក បទុមឧបាសក បុណ្ឌរីកឧបាសក ។ ខ្ញុំបាទនឹងលើកមកសរសេរក្នុងសៀវភៅនេះ ។*

*ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថា* **ចណ្ឌាលឧបាសកផង** *ឈ្មោះថា* **មលឧបាសកផង** *ឈ្មោះថា* **បដិកិដ្ឋឧបាសកផង** *។*

*ធម៌ ៥ យ៉ាង តើដូចម្តេច? គឺ :*

*១-ឧបាសកជាអ្នកមិនមានសទ្ធា*

*២-ជាអ្នកទ្រុស្តសីល*

*៣-ប្រកាន់មង្គល ភ្ញាក់ផ្អើល*

*៤-ជឿតែមង្គល មិនជឿកម្ម*

*៥-ស្វែងរកទក្ខិណេយ្យបុគ្គលខាងក្រៅពះពុទ្ធសាសនា ហើយធ្វើបុណ្យតែទក្ខិណេយ្យបុគ្គលនោះ ។*

*ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថា ចណ្ឌាលឧបាសកផង ឈ្មោះថា មលឧបាសកផង ឈ្មោះថា បដិកិដ្ឋឧបាសកផង ។*

*ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថា រតនឧបាសកផង ឈ្មោះថា បទុមឧបាសកផង ឈ្មោះថា បុណ្ឌរីកឧបាសកផង ។*

*ធម៌ ៥ យ៉ាង តើដូចម្តេច? គឺ :*

*១-ឧបាសកជាអ្នកមានសទ្ធា*

*២-ជាអ្នកមានសីល*

*៣-ជាអ្នកមិនប្រកាន់មង្គលភ្ញាក់ផ្អើល*

៤-ជឿតែកម្ម មិនជឿមង្គល

៥-មិនស្វែងរកទក្ខិណេយ្យបុគ្គល ខាងក្រៅព្រះពុទ្ធសាសនា ធ្វើបុណ្យតែក្នុងព្រះពុទ្ធសាសនា ។

ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថា រតនឧបាសកផង ឈ្មោះថា បទុមឧបាសកផង ឈ្មោះថា បុណ្ឌរីកឧបាសកផង ។

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលវត្ថុ ក្នុងសក្កជនបទ ។ គ្រានោះមហានាមសក្កៈចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយប្រថាប់ ក្នុងទីដ៏សមគួរ ។ លុះមហានាមសក្កៈ ប្រថាប់ក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អរិយសាវកណាបានសម្រេច អរិយផលដឹងច្បាស់នូវសាសនាគឺត្រៃសិក្ខាហើយ តើអរិយសាវកនោះច្រើនតែនៅ ដោយវិហារធម៌ដូម្តេច ។ ថ្វាយព្រះពរមហានាម អរិយសាវកណា បានសម្រេចអរិយផល ដឹងច្បាស់នូវសាសនាហើយ អរិយសាវកនោះច្រើនតែនៅដោយ វិហារធម៌នេះ ។ បពិត្រមហានាម អរិយសាវកក្នុងសាសនានេះ រលឹករឿយៗ នូវព្រះតថាគតថា **"ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ"** ។ ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាករាគាទិក្កិលេស ត្រាស់ដឹងនូវញេយ្យធម៌ដោយប្រពៃចំពោះព្រះអង្គឯង ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ព្រះអង្គមានដំណើរល្អ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គជាបុគ្គលប្រសើរដោយសីលាទិគុណ ព្រះអង្គជាអ្នកទូន្មាននូវបុរស ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវ ចតុរារិយសច្ច ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ដោយហេតុនេះៗ ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវករលឹករឿយៗ

នូវគុណនៃព្រះតថាគត ក្នុងសម័យនោះ អរិយសាវកនោះ រមែងមិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈ រួបរឹតចិត្ត មិនត្រូវមោហៈរួបរឹតចិត្ត ក្នុងសម័យនោះ ចិត្តរបស់អរិយសាវក នោះ ក៏រមែងជាចិត្តត្រង់បាន ព្រោះប្រារព្ធនូវគុណនៃព្រះតថាគត ។ បពិត្រមហានាម លុះអរិយសាវកមានចិត្តត្រង់ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយប្រកបដោយធម៌ ការបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង ការបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលនូវសេចក្តីសុខ លុះប្រកបដោយសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវកនេះហៅថា ជាអ្នកដល់នូវការស្ងប់រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់ ជាអ្នកមិនចង្អៀតចង្អល់ ក្នុងពួកសត្វដែលប្រកបដោយសេចក្តីចង្អៀតចង្អល់ ជាអ្នកសម្រេចនូវធម្មសោ្របាតៈ គឺវិបស្សនា ចម្រើននូវពុទ្ធានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម មួយទៀតអរិយសាវករលឹករឿយៗ នូវគុណព្រះធម៌ថា **"ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិ-តព្វោ វិញ្ញូហិ"** ។ ព្រះបរិយត្តិធម៌ ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយដោយប្រពៃ ព្រះនព្វលោកុត្តរធម៌ ដែលបុគ្គលគប្បីឃើញដោយខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌គួរបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលពួកវិញ្ញូជន គប្បីដឹងច្បាស់ចំពោះខ្លួន ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវករលឹករឿយៗនូវព្រះធម៌ក្នុងសម័យនោះ អរិយសាវកនោះ រមែងមិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈរួបរឹតចិត្ត ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ ក៏រមែងជាចិត្តត្រង់បាន ព្រោះប្រារព្ធនូវគុណព្រះធម៌ ។ បពិត្រមហានាម លុះអរិយសាវកមានចិត្តត្រង់ហើយ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្ត

ប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលនូវសេចក្តីសុខ លុះប្រកបដោយសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវកនេះ ហៅថា ជាអ្នកដល់នូវការស្ងប់រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់ ជាអ្នកមិនចង្អៀតចង្អល់ ក្នុងពួកសត្វដែលប្រកបដោយសេចក្តីចង្អៀតចង្អល់ ជាអ្នកសម្រេចនូវធម្មស្សោតៈ គឺវិបស្សនា ចម្រើននូវធម្មានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម មួយទៀត អរិយសាវករលឹករឿយៗ នូវគុណនៃព្រះសង្ឃថា៖

សុបដិបន្នោ ភគវតោ សាវកសង្ឃោ

ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ

ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ

សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ

យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ ចាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិ–ករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។

ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិល្អហើយ ព្រះសង្ឃសាវក នៃព្រះ–ដ៏មានព្រះភាគ ប្រតិបត្តិត្រង់ហើយ ព្រះសង្ឃសាវកនៃព្រះមានព្រះភាគ ប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ព្រះសង្ឃសាវកនៃព្រះមានព្រះភាគ ប្រតិបត្តិគួរដល់សាមីចិកម្ម បើរាប់ជាគូនៃបុរសបាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលបាន ៨ ព្រះសង្ឃទាំងនុ៎ះ ជាសង្ឃសាវកនៃព្រះមានព្រះភាគ គួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវវត្ថុដែលគេរៀបចំដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញខេត្តដ៏ប្រសើររបស់សត្វលោក ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវករលឹករឿយៗ

នូវគុណព្រះសង្ឃ ក្នុងសម័យនោះ អរិយសាវកនោះ ក៏មិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈ រួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ ក៏រមែងជាចិត្តត្រង់ ព្រោះប្រារព្ធនូវគុណព្រះសង្ឃ ។ បពិត្រមហានាម លុះអរិយ-សាវកមានចិត្តត្រង់ហើយ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយ ប្រកបដោយធម៌ ការបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង ការបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ហើយ រមែងទទួលនូវសេចក្តីសុខ កាលបើមានសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវកនេះហៅថា ជាអ្នកដល់នូវការស្ងប់រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់ ជាអ្នកមិនចង្អៀតចង្អល់ ក្នុងពួកសត្វដែលមានសេចក្តីចង្អៀតចង្អល់ ជាអ្នកសម្រេចនូវធម្មសោតៈ គឺវិបស្សនា ចម្រើននូវសង្ឃានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម មួយទៀត អរិយសាវករលឹករឿយៗ នូវសីលរបស់ខ្លួន ដែលមិនដាច់ មិនធ្លុះ មិនពពាល មិនពពុស ជាសីលរួចខ្លួន គឺមិនខ្ញុំតណ្ហា ដែលវិញ្ញូជនសរសើរហើយ មិនមានតណ្ហា និងទិដ្ឋិប៉ះពាល់បាន ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវក រលឹករឿយៗ នូវសីលរបស់ខ្លួន ក្នុងសម័យនោះ អរិយ-សាវកនោះ រមែងមិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ រមែងជាចិត្តត្រង់ ព្រោះប្រារព្ធនូវសីល ។ បពិត្រមហានាម លុះអរិយសាវកមានចិត្តត្រង់ហើយ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយប្រកបដោយធម៌ ការបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង ការបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលនូវសេចក្តីសុខ កាលបើមានសេចក្តីសុខ ហើយចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវក នេះហៅថា ជាអ្នកដល់នូវការស្ងប់រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់ ជាអ្នកមិនចង្អៀតចង្អល់ក្នុងពួកសត្វ

ដែលមានសេចក្តីចង្អៀតចង្អល់ ជាអ្នកសម្រេច នូវធម្មសោ្យតៈ គឺវិបស្សនា ចម្រើននូវសីលានុស្សតិកម្មដ្ឋាន ។

បពិត្រមហានាម មួយទៀត អរិយសាវករលឹករឿយៗ នូវចាគៈរបស់ខ្លួនថា ឱហ្ន៎អញពេញជាមានលាភហើយ ឱហ្ន៎អត្តភាពជាមនុស្ស អញពេញជាបានល្អហើយ ព្រោះកាលពួកសត្វមានសេចក្តីកំណាញ់ ជាសេចក្តីមន្ទិលកំពុងរួបរឹត អញមានចិត្តប្រាសចាកសេចក្តីកំណាញ់ជាមន្ទិល ជាអ្នកមានការលះរួចផុតហើយ មានដៃលាងស្អាតហើយ ត្រេកអរក្នុងការលះបង់ ជាបុគ្គលគេសូម ត្រេកអរក្នុងការចែកចាយទាន នៅគ្រប់គ្រងផ្ទះៗ បពិត្រមហានាម ក្នុងសម័យណាអរិយសាវក រលឹករឿយៗ នូវចាគៈ ក្នុងសម័យនោះ អរិយសាវកនោះ រមែងមិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះចិត្ត របស់អរិយសាវកនោះ ក៏រមែងជាចិត្តត្រង់ ព្រោះប្រារព្ធនូវចាគៈ ។ បពិត្រមហានាម លុះអរិយសាវកមានចិត្តត្រង់ហើយ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលនូវសេចក្តីសុខ កាលបើមានសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវកនេះហៅថា ជាអ្នកដល់នូវការស្ងប់រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់ ជាអ្នកមិនចង្អៀតចង្អល់ ក្នុងពួកសត្វដែលមានសេចក្តីចង្អៀតចង្អល់ ជាអ្នកសម្រេចនូវធម្មសោ្យតៈ គឺវិបស្សនា ចម្រើននូវចាគានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម មួយវិញទៀត អរិយសាវក ចម្រើននូវទេវតានុស្សតិថា ទេវតាទាំងឡាយ ជាន់ចាតុម្មហារាជិកក៏មាន ទេវតាទាំងឡាយជាន់តាវតិង្សក៏មាន ទេវតាទាំងឡាយជាន់យាមៈក៏មាន ទេវតាទាំងឡាយ ជាន់តុសិតក៏មាន ទេវតាទាំងឡាយជាន់និម្មានរតីក៏មាន ទេវតាទាំងឡាយជាន់ បរនិម្មិតវសវត្តីក៏មាន ទេវតាទាំងឡាយជាព្រហ្មកាយិកៈក៏មាន ទេវតាទាំងឡាយ ខ្ពស់លើសជាងនោះក៏មាន ទេវតាទាំងនោះប្រកបដោយសទ្ធា មានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុង

ទីនោះ សទ្ធារបស់អញដែលមានសភាពយ៉ាងនោះក៏មាន ទេវតាទាំងនោះប្រកបដោយសីល មានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ សីលរបស់អញដែលមានសភាពយ៉ាងនោះក៏មាន ពួកទេវតាទាំងនោះប្រកបដោយសុតៈ មានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ សុតៈរបស់អញមានសភាពយ៉ាងនោះក៏មាន មានទេវតាទាំងនោះ ប្រកបដោយចាគៈមានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ ចាគៈរបស់អញដែលមានសភាពយ៉ាងនោះក៏មាន ទេវតាទាំងនោះប្រកបដោយបញ្ញា មានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ បញ្ញារបស់អញដែលមានសភាពដូច្នោះក៏មាន។ បពិត្រមហានាម ក្នុងសម័យណាអរិយសាវករលឹករឿយៗ **នូវសទ្ធា សីល សុតៈ ចាគៈ និងបញ្ញារបស់ខ្លួនផង** របស់ទេវតាទាំងនោះផង ក្នុងសម័យនោះ អរិយសាវកនោះរមែងមិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ រមែងជាចិត្តត្រង់ ព្រោះប្រារព្ធនូវពួកទេវតា ។ បពិត្រមហានាម លុះអរិយសាវកមានចិត្តត្រង់ហើយ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយដែលប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ ក៏រមែងទទួលនូវសេចក្តីសុខ កាលបើមានសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវកនេះហៅថា ជាអ្នកដល់នូវការស្ងប់រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់ ជាអ្នកមិនចង្អៀតចង្អល់ ក្នុងពួកសត្វដែលមានសេចក្តីចង្អៀតចង្អល់ ជាអ្នកសម្រេចនូវធម្មសោ្របតៈ គឺវិបស្សនា ចម្រើននូវទេវតានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម អរិយសាវកណា បានសម្រេចអរិយផលដឹងច្បាស់នូវសាសនាហើយ អរិយសាវកនោះ ច្រើនតែនៅដោយវិហារធម៌នេះឯង ។

*បាកគម្ពីរអង្គុត្តរនិកាយ ឆក្កនិបាត អាហុនេយ្យវគ្គ មហានាមសូត្រ ៤៦ ទំព័រ ១១*

# ពោលអំពីបុគ្គលបានជាឧបាសក

*សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងនិគ្រោធារាម ជិតក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។ គ្រានោះសក្យមហានាម ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ លុះសក្យមហានាម គង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលបានជាឧបាសក តើដោយហេតុដូចម្តេច ។*

*បពិត្រមហានាម បុគ្គលអ្នកដល់ នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង ដោយហេតុណា បពិត្រមហានាម បុគ្គលបានជាឧបាសក ដោយហេតុប៉ុណ្ណោះឯង ។*

*បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាសកអ្នកមានសីល តើដោយហេតុដូចម្តេច ។*

*បពិត្រមហានាម ឧបាសកជាអ្នកវៀរ ចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុ មិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ដោយហេតុណា បពិត្រមហានាម ឧបាសកអ្នកមានសីល ដោយហេតុប៉ុណ្ណោះឯង ។*

*បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាសកអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន មិនប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃទេ តើដោយហេតុដូចម្តេច ។*

*បពិត្រមហានាម ឧបាសកអ្នកបរិបូណ៌ដោយសទ្ធាដោយខ្លួនឯង មិនបបួលបុគ្គលដទៃឲ្យបរិបូណ៌ដោយសទ្ធា ១ អ្នកបរិបូណ៌ដោយសីលដោយខ្លួនឯង មិនបបួលបុគ្គលដទៃឲ្យបរិបូណ៌ដោយសីល ១ អ្នកបរិបូណ៌ដោយចាគៈដោយខ្លួនឯង មិនបបួលបុគ្គលដទៃឲ្យបរិបូណ៌ដោយចាគៈ ១ អ្នកចង់ជួបប្រទះពួកភិក្ខុដោយខ្លួនឯង មិនបបួលបុគ្គលដទៃឲ្យជួបប្រទះពួកភិក្ខុ ១ អ្នកចង់ស្តាប់ព្រះសទ្ធម្មដោយខ្លួនឯង មិនបបួលបុគ្គលដទៃឲ្យបានស្តាប់ព្រះសទ្ធម្ម ១ អ្នកទ្រទ្រង់ស្តាប់ធម៌ទាំងឡាយ ដែលបានស្តាប់ហើយដោយខ្លួនឯង មិនបបួលបុគ្គលដទៃឲ្យទ្រទ្រង់នូវធម៌ ១ អ្នកពិចារណានូវអត្ថនៃធម៌ទាំងឡាយដែលបានស្តាប់*

ហើយដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យពិចារណានូវអត្ថ ១ អ្នកដឹងនូវអត្ថ ដឹងនូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ដោយខ្លួនឯង មិនបបួលបុគ្គលដទៃឲ្យប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ១ ដោយហេតុណា បពិត្រមហានាម ឧបាសកអ្នកប្រតិបត្តិដើម្បីប្រយោជន៍ផ្ទាល់ខ្លួន មិនប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃ ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។

បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាសកអ្នកប្រតិបត្តិដើម្បី ប្រយោជន៍ផ្ទាល់ខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង តើដោយហេតុដូចម្តេច ។

បពិត្រ មហានាម ឧបាសកអ្នកបរិបូណ៌ដោយសទ្ធាដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃឲ្យបរិបូណ៌ដោយសទ្ធា ១ អ្នកបរិបូណ៌ដោយសីលដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃឲ្យបរិបូណ៌ដោយសីល ១ អ្នកបរិបូណ៌ដោយចាគៈដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃឲ្យបរិបូណ៌ដោយចាគៈ ១ អ្នកចង់ជួបប្រទះពួកភិក្ខុដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃឲ្យបានជួបប្រទះពួកភិក្ខុ ១ អ្នកចង់ស្តាប់ព្រះសទ្ធម្មដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃឲ្យបានស្តាប់ព្រះសទ្ធម្ម ១ អ្នកទ្រទ្រង់នូវធម៌ទាំងឡាយដែលបានស្តាប់ហើយដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃឲ្យទ្រទ្រង់នូវធម៌ ១ អ្នកពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលបានស្តាប់ហើយដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃឲ្យពិចារណានូវអត្ថ ១ អ្នកដឹងនូវអត្ថ ដឹងនូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃឲ្យប្រតិបត្តិនូវ ធម៌ដ៏សមគួរដល់ធម៌ ១ ដោយហេតុណា បពិត្រមហានាម ឧបាសកអ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនឯងផង ដើម្បីប្រយោជន៍បុគ្គលដទៃផង ដោយហេតុមានប្រមាណប៉ុណ្ណេះ ។

*បាកគម្ពីរអង្គុត្តរនិកាយ អដ្ឋកនិបាត ៤៨ ទំព័រ ១២៩*

ចូឡយមកវគ្គ សាលេយ្យកសូត្រទី១ បានសម្តែងអំពីធម៌ស្មើ និងមិនស្មើដោយន័យថា៖

ខ្ញុំស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់ស្តេចទៅកាន់ចារិកក្នុងកោសលជនបទ ជាមួយនឹងព្រះភិក្ខុសង្ឃច្រើនរូប បានស្តេចទៅដល់ស្រុកព្រាហ្មណ៍ ឈ្មោះសាលៈ ជាខេត្តរបស់កោសលជនបទ ។ ពួកព្រាហ្មណ៍ និងគហបតីអ្នកស្រុកសាលៈ បានឮ(ដំណឹង)ហើយ ក៏ប្រកាសពាក្យនេះថា ម្នាលគ្នាយើង ឮថាព្រះសមណគោតមជាសក្យបុត្រ ចេញចាកសក្យត្រកូល ទៅទ្រង់ព្រះផ្នួស ទ្រង់ស្តេចទៅកាន់ទីចារិកក្នុងកោសលជនបទ ព្រមដោយភិក្ខុសង្ឃច្រើនរូប ឥឡូវស្តេចមកដល់សាលគ្រាមហើយ ។ កិត្តិសព្ទដ៏ល្អ របស់ព្រះគោតមដ៏មានព្រះភាគនោះ ល្បីឮខ្ចរខ្ចាយយ៉ាងនេះថា ព្រះមានព្រះភាគ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គឯង បរិបូណ៌ដោយវិជ្ជា និងចរណៈ គឺសេចក្តីដែលបុគ្គលគប្បីប្រព្រឹត្តមានដំណើរទៅកាន់ព្រះនិព្វាន ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើរគ្មាន ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូ នៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ចធម៌ លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះអង្គទ្រង់ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញា ចំពោះព្រះអង្គឯងនូវលោកនេះព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយទ្រង់ប្រកាស ព្រះអង្គទ្រង់សម្តែងធម៌មានពីរោះបទដើម មានពីរោះបទកណ្តាល មានពីរោះបទចុង ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ ក៏ដំណើរដែលបានឃើញនូវព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងហ្នឹងជាការប្រពៃ ។ គ្រានោះ ពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកសាលគ្រាម នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ពួកខ្លះថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះក៏ពោលរាក់ទាក់ សំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកហើយ ទើបអង្គុយក្នុង

ទីដ៏សមគួរ ពួកខ្លះអង្គុយក្នុងទីដ៏សមគួរ ប្រណម្យអញ្ជលីឆ្ពោះទៅព្រះមានព្រះភាគ ពួកខ្លះប្រកាសនូវនាមនិងគោត្រក្នុងទីជិតព្រះមានព្រះភាគ អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះអង្គុយស្ងៀមក្នុងទីដ៏សមគួរ ។ កាលព្រាហ្មណ៍និងគហបតី អ្នកស្រុកសាលៈ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលសួរពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច បានជាសត្វទាំងឡាយ ពួកខ្លះក្នុងលោកនេះ ទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ (មិនមានសេចក្តីចម្រើន គឺតិរច្ឆានកំណើត) ទុគ្គតិ(ជំណើរដែលផ្អែកនឹងទុក្ខ គឺអសុរកាយ) វិនិបាត (ទីសម្រាប់ទម្លាក់នូវបុគ្គលធ្វើអំពើអាក្រក់គឺប្រេតវិស័យ) និរយៈ(ទីមិនមានសេចក្តីសប្បាយ គឺនរក) បពិត្រព្រះគោតមដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច បានជាសត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ទៅកើតក្នុងមនុស្សសុគតិ សួគ៌ទេវលោក ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលគហបតីទាំងឡាយសត្វទាំងឡាយពួកខ្លះក្នុងលោកនេះ ទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែកិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌យ៉ាងនេះឯង ម្នាលគហបតីទាំឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ទម្លាយរាងកាយខាងមុខ បន្ទាប់អំពីមរណៈ ទៅកើតក្នុងលោក គឺមនុស្ស សុគតិ ឋានសួគ៌ ព្រោះហេតុតែកិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌យ៉ាងនេះឯង ។ ព្រាហ្មណ៍និងគហបតិក្រាបបង្គំទូលថា កាលបើព្រះគោតមដ៏ចម្រើននេះសម្តែងដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារហើយ យើងទាំងឡាយមិនអាចនឹងដឹងសេចក្តីដោយពិស្តារទៅបានទេ កាលបើព្រះគោតមដ៏ចម្រើននេះ សម្តែងដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារទេ តែថាយើងទាំងឡាយអាចនឹងដឹងសេចក្តី ដោយពិស្តារទៅបាន ដោយប្រការយ៉ាងណា សូមព្រះគោតមដ៏ចម្រើនទ្រង់ព្រះមេត្តាប្រោស សម្តែងធម៌ដល់យើងខ្ញុំទាំងឡាយដោយប្រការយ៉ាងនោះឲ្យទាន ។ ព្រះអង្គត្រាស់ថា ម្នាលគហបតីទាំងឡាយ បើដូច្នោះអ្នកទាំងឡាយ

ចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្តែង ។ ពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកសាលៈទទួលស្តាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

ព្រះមានព្រះភាគត្រាស់ភាសិតនេះថា ម្នាលគហបតីទាំងឡាយកិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ ដោយកាយមាន ៣ ប្រការ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ដោយវាចាមាន ៤ ប្រការ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ដោយចិត្តមាន ៣ ប្រការ ។ ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ ដោយកាយមាន ៣ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលគហបតីទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ជាមនុស្សអាក្រក់ មានបាតដៃប្រឡាក់ដោយឈាម មានចិត្តបោះជាប់ក្នុងការសម្លាប់សត្វ ជាអ្នកមិនមានសេចក្តីអៀនខ្មាស មានចិត្តមិនអាសូរចំពោះពួកសត្វទាំងអស់ ។ មួយទៀត ជាអ្នកកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ដូចជាគ្រឿងឧបករណ៍គឺសម្បត្តិនៃបុគ្គលដទៃណាដែលគេទុកក្នុងស្រុកក្តី ទុកក្នុងព្រៃក្តី ជាអ្នកកាន់យកគ្រឿងឧបករណ៍ដែលគេមិនបានឲ្យនោះ ដោយចំណែកនៃចិត្តលួច ។ មួយទៀត ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ដូចជាស្ត្រីទាំងឡាយណា គឺស្ត្រីដែលមាតារក្សា ដែលបិតារក្សា ដែលមាតាបិតារក្សា ដែលបងប្អូនប្រុសរក្សា បងប្អូនស្រីរក្សា ដែលញាតិរក្សា ដែលមានស្វាមីដែលប្រកបដោយអាជ្ញា ដោយហោចទៅសូម្បីតែស្ត្រី ដែលបុរសបំពាក់កម្រងផ្កាឲ្យជាអ្នកដល់នូវការប្រព្រឹត្តកន្លងក្នុងស្ត្រីទាំងឡាយ មានសភាពដូច្នោះ ។ ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ ដោយកាយមាន ៣ ប្រការយ៉ាងនេះឯង ។

ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្ត- តាមធម៌ដោយវាចាមាន ៤ ប្រការ តើដូចម្តេចខ្លះ ។

ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកពោលពាក្យកុហក ទោះបីឋិតនៅក្នុងរោងក្តី ឋិតនៅក្នុងបរិស័ទក្តី ឋិតនៅក្នុងកណ្តាលញាតិក្តី ឋិតនៅកណ្តាលសេនីយ៍ក្តី ឋិតនៅកណ្តាលរាជត្រកូលក្តី គេនាំទៅធ្វើជាសាក្សីហើយសួរថា នៃបុរស

ដ៏ចម្រើន ចូរអ្នកមកនេះ បើអ្នកដឹងហេតុណា ចូរនិយាយហេតុនោះ ។ បុរសនោះ កាលមិនដឹងនិយាយថា ខ្ញុំដឹង ឬកាលដឹង និយាយថា ខ្ញុំមិនដឹង កាលមិនឃើញនិយាយថា ខ្ញុំឃើញ ឬកាលឃើញ និយាយថា ខ្ញុំមិនឃើញ ។ ជាអ្នកពោលពាក្យកុហកទាំងដឹងខ្លួន ព្រោះហេតុតែខ្លួនក្តី ព្រោះហេតុអ្នកដទៃក្តី ព្រោះហេតុសំណូកគឺអាមិសៈបន្តិចបន្តួចក្តី ។ មួយទៀត ជាអ្នកពោល នូវពាក្យញុះញង់ គឺឮពាក្យអំពីសំណាក់ជននេះហើយ ទៅប្រាប់ជនឯណោះ ដើម្បីនឹងបំបែកជនទាំងនេះ ឮពាក្យអំពីជនឯណោះ ហើយនាំយកមកប្រាប់ជននេះ ដើម្បីបំបែកជនឯណោះ ជាអ្នកបំបែកនូវពួកជនដែលព្រមព្រៀងគ្នាផង ជាអ្នកជម្រុលពួកជនដែលបែកគ្នាហើយផង ជាអ្នកត្រេកអរ តែក្នុងពួកមានតម្រេកក្នុងពួក ជាអ្នករីករាយតែពួកក្នុងពួក ជាអ្នកពោលនូវវាចា ដែលធ្វើឲ្យប្រកាន់ពួកដូច្នេះឯង ។ មួយទៀត ជាអ្នកពោលពាក្យអាក្រក់ គឺវាចាណាទ្រគោះខ្លោះខ្លួរពេលពាល ស្ទាក់ជំណើរជនដទៃ ជាវាចាជិត នឹងសេចក្តីក្រោធ មិនប្រព្រឹត្តទៅដើម្បីសមាធិបាន ហើយជាអ្នកពោលនូវវាចាមានសភាពដូច្នោះ ។ មួយវិញទៀត ជាអ្នកពោលនូវពាក្យមិនមានប្រយោជន៍ ពោលពាក្យខុសកាល ពោលនូវពាក្យមិនពិត ពោលពាក្យមិនមែនជាអត្ថ ពោលពាក្យមិនមែនជាធម៌ ពោលពាក្យមិនមែនជាវិន័យ ពោលពាក្យដែលមិនគួរតាំងទុកក្នុងហឫទ័យ ខុសកាល ប្រាសចាកគ្រឿងអាង ជាពាក្យមិនមានទីបំផុត មិនប្រកបដោយប្រយោជន៍ ។

ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ ដោយវាចាមាន ៤ ប្រការ ដូច្នេះឯង ។

ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ ដោយចិត្តមាន ៣ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ច្រើនដោយអភិជ្ឈា គយគន់នូវគ្រឿងឧបករណ៍ ដែលជាសម្បត្តិ នៃបុគ្គលដទៃ ដោយគិតថាឱហ្ន៎គ្រឿងឧបករណ៍ ដែលជាសម្បត្តិនៃបុគ្គលដទៃណា គ្រឿងឧបករណ៍នោះ គប្បីបានមកអាត្មាអញ ។ មួយទៀត ជាអ្នកមានចិត្តព្យាបាទ មានតម្រិះក្នុងចិត្ត ដែលទោសប្រទូស្តហើយថា សត្វទាំងឡាយចូរលំបាកខ្លះ ចូរស្លាប់ខ្លះ ចូរវិនាសសាបសូន្យទៅខ្លះ ដែលថាមិនវិនាសកុំឲ្យមានឡើយ ។ មួយវិញទៀត ជាអ្នកមានគំនិត

យល់ខុស ឃើញនូវ សេចក្តីវិបរិតថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំ មិនមានផល ការបូជាតូច ក៏មិនមានផល ផលវិបាកនៃកុសលាកុសលកម្ម ដែលសត្វធ្វើល្អនិងអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមានគុណ បិតាមិនមានគុណ សត្វទាំងឡាយជាឱបបាតិកៈមិនមាន ពួកសមណព្រាហ្មណ៍ ក្នុងលោក ជាអ្នកព្រមព្រៀងគ្នា ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់ដោយខ្លួនឯង នូវលោកនេះនិងលោកខាងមុខ ហើយសម្តែងក៏មិនមាន ។ ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ដោយចិត្តមាន ៣ ប្រការយ៉ាងនេះឯង ។

ម្នាលគហបតីទាំងឡាយ សត្វទាំងឡាយពួកខ្លះក្នុងលោកនេះ លុះបែកធ្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ ចូលទៅកាន់អបាយ ទុគ្គតិ វិនិបាត នរក យ៉ាងនេះ ព្រោះហេតុតែកិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ យ៉ាងនេះឯង ។

ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ដោយកាយមាន ៣ ប្រការ ។ កិរិយាប្រព្រឹត្តស្មើពោលគឺប្រព្រឹត្តតាមធម៌ដោយវាចាមាន៤ ប្រការ ។ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ដោយចិត្ត មាន ៣ ប្រការ ។

ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ដោយកាយមាន ៣ ប្រការ តើដូចម្តេច ។

ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ លះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត ជាអ្នកដាក់ចុះនូវអាជ្ញា ដាក់ចុះនូវសស្រ្តាវុធ ប្រកបដោយសេចក្តីខ្មាស ដល់នូវមេត្តាចិត្ត ជាអ្នកអនុគ្រោះដោយប្រយោជន៍ ចំពោះពួកសត្វទាំងអស់។ ជាអ្នកលះបង់នូវអទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន ដូចជាគ្រឿងឧបករណ៍គឺសម្បត្តិនៃបុគ្គលណា ដែលគេទុកក្នុងស្រុកក្តី ទុកក្នុងព្រៃក្តី ក៏ជាអ្នកមិនកាន់យកនូវវត្ថុដែលគេមិនបានឲ្យនោះ ដោយចំណែកនៃចិត្តលួចឡើយ ។ ជាអ្នកលះបង់នូវកាមេសុមិច្ឆាចារ វៀរស្រឡះចាក កាមេសុ មិច្ឆាចារ ទោះបីស្រ្តីណា ដែលមាតារក្សា បិតារក្សា មាតាបិតារក្សា បងប្អូនប្រុសរក្សា បងប្អូនស្រ្តីរក្សា ញាតិរក្សា មានស្វាមីប្រកប

ដោយអាជ្ញា ដោយហោចទៅសូម្បីស្ត្រីដែលបុរសបំពាក់កម្រងផ្កាឲ្យ ក៏ជាអ្នកមិនដល់នូវការប្រព្រឹត្ត កន្លងក្នុងស្ត្រីទាំងឡាយ មានសភាពដូច្នោះឡើយ ។

ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ដោយកាយ មាន ៣ ប្រការដូច្នោះឯង ។

ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ដោយវាចា មាន ៤ ប្រការ តើដូចម្តេចខ្លះ ។

ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ លះបង់នូវមុសាវាទ វៀរស្រឡះចាកមុសាវាទ ទោះបីឋិតនៅក្នុងរោងក្តី ឋិតនៅក្នុងបរិស័ទក្តី ឋិតនៅកណ្តាលញាតិក្តី ឋិតនៅកណ្តាលសេនីយ៍ក្តី ឋិតនៅកណ្តាលរាជត្រកូលក្តី គេនាំទៅធ្វើជាសាក្សី ហើយសួរថា នែបុរសដ៏ចម្រើន ចូរអ្នកមកនេះ បើអ្នកដឹងហេតុណា ចូរនិយាយប្រាប់ហេតុនោះដូច្នេះក្តី ។ បុរសនោះ កាលមិនដឹង និយាយថា ខ្ញុំមិនដឹង ឬកាលដឹង ក៏និយាយថា ខ្ញុំដឹង កាលមិនឃើញ និយាយថា ខ្ញុំមិនឃើញ ឬកាលឃើញ ក៏និយាយថា ខ្ញុំឃើញ ។ ជាអ្នកមិនពោលនូវពាក្យកុហកទាំងដឹងខ្លួនដូច្នេះ ព្រោះហេតុខ្លួនក្តី ព្រោះហេតុអ្នកដទៃ ព្រោះហេតុតែសំណូក គឺអាមិសៈបន្តិចបន្តួចក្តី ។ មួយវិញទៀត ជាអ្នកលះបង់នូវ បិសុណាវាចា វៀរស្រឡះចាកបិសុណាវាចា គឺឮពាក្យអំពីជននេះ ហើយមិននាំទៅប្រាប់ជនឯណោះ ដើម្បីនឹងបំបែកជនទាំងនេះផង ឮពាក្យអំពីជនឯណោះ ហើយមិននាំមកប្រាប់ជនទាំងនេះ ដើម្បីនឹងបំបែកជនឯណោះផង ជាអ្នកផ្សះផ្សានូវពួកជនដែលបែកគ្នាផង ជាអ្នកទំនុកបម្រុងនូវពួកជនដែលព្រមព្រៀងគ្នាស្រាប់ហើយផង ជាអ្នកត្រេកអរតែក្នុងសេចក្តីព្រមព្រៀងគ្នា ជាអ្នកមានតម្រេកតែក្នុងសេចក្តីព្រមព្រៀងគ្នា ជាអ្នករីករាយក្នុងសេចក្តីព្រមព្រៀងគ្នា ពោលនូវវាចាដែលធ្វើឲ្យកើតសេចក្តីព្រមព្រៀង ដោយប្រការដូច្នេះ ។ ជាអ្នកលះបង់នូវផរុសវាចា វៀរស្រះឡះចាកផរុសវាចា គឺវាចាណាមិនមានទោស ជាសុខដល់ត្រចៀក គួរឲ្យកើតសេចក្តីស្រឡាញ់ ចូលទៅកាន់ហរទ័យ ជាវាចាអ្នកបុរី ជាទីស្រឡាញ់ដល់ជនច្រើន ជាទីពេញចិត្តដល់ជនច្រើន ជាអ្នកពោលនូវវាចាមានសភាពដូច្នោះ ។ ជាអ្នកលះបង់នូវសម្ផប្បលាបៈ វៀរស្រឡះចាកសម្ផប្បលាបៈ

ពោលពាក្យត្រូវតាមកាល ពោលពាក្យពិត ពោលពាក្យដែលជាអត្ថ ពោលពាក្យដែលជាធម៌ ពោលពាក្យជាវិន័យ ពោលពាក្យដែលគួរឲ្យតាំងទុកក្នុងហឫទ័យ ត្រូវតាមកាល ប្រកបដោយគ្រឿងអាង ជាវាចាមានទីបំផុតប្រកបដោយប្រយោជន៍ ។

ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ដោយវាចាមាន៤ ប្រការយ៉ាងនេះឯង ។ ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ដោយ ចិត្តមាន ៣ ប្រការដូចម្តេចខ្លះ ។

ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ មិនច្រើនដោយអភិជ្ឈា គ្រឿងឧបករណ៍ដែលជាសម្បត្តិនៃបុគ្គលដទៃណា ក៏មិនគយគន់ នូវគ្រឿងឧបករណ៍នោះថា ឱហ្ន៎គ្រឿងឧបករណ៍ដែលជាសម្បត្តិនៃបុគ្គលដទៃណា គ្រឿងឧបករណ៍នោះ គប្បីបានមកអាត្មាអញដូច្នេះឡើយ ។ មួយទៀត ជាអ្នកមានចិត្តមិនព្យាបាទ មានតម្រិះក្នុងចិត្តដែលទោសមិនប្រទូស្តហើយថា សត្វទាំងឡាយនេះចូរកុំមានពៀរ កុំមាន ព្យាបាទ កុំមានទុក្ខ រក្សាខ្លួនឲ្យបាន សេចក្តីសុខចុះ ។ មួយវិញទៀត ជាអ្នកមានគំនិតយល់ត្រូវ ឃើញនូវសេចក្តីមិនវិបរិតថា ទានដែលបុគ្គលឲ្យហើយមានផល ការបូជាធំមានផល ការបូជាតូចមានផល ផល វិបាកនៃកុសលាកុសលកម្ម ដែលសត្វធ្វើល្អ និងធ្វើអាក្រក់មាន លោកនេះមាន លោកខាងមុខមាន មាតាមានគុណ បិតាមានគុណ សត្វដែលជាឱបបាតិកៈ កំណើត មានពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នកព្រមព្រៀង ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាចំពោះខ្លួនឯង នូវលោកនេះ និងលោកខាងមុខហើយ ប្រកាសក៏មាន ។

ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្ត តាមធម៌ដោយចិត្តមាន ៣ ប្រការ យ៉ាងនេះឯង ។ ម្នាលគហបតីទាំងឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ បែកធ្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ ចូលទៅកាន់សុគតិ សួគ៌ទេវលោកយ៉ាងនេះ ព្រោះហេតុតែកិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌យ៉ាងនេះឯង ។

ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឲ្យខ្លួនអាត្មាអញ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ សូមឲ្យបានទៅកើតជាមួយ

នឹងពួកខត្តិយមហាសាល ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថា បុគ្គលនោះ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកខត្តិយមហាសាលមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថាបុគ្គលនោះជាអ្នកប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ។

ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថាឲ្យខ្លួនអាត្មាអញ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ សូមឲ្យបានទៅកើត ជាមួយនឹងពួកព្រាហ្មណមហាសាល ។ បេ ។ កើតជាមួយនឹងគហបតីមហាសាល ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថាបុគ្គលនោះ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកគហបតីមហាសាលមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះជាអ្នកប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌។

ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថាឲ្យខ្លួនអាត្មាអញ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ សូមឲ្យបានទៅកើតជាមួយនឹងពួកទេវតាក្នុងជាន់ចាតុម្មហារាជិកា ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះក៏នឹងបានសម្រេច ព្រោះថាបុគ្គលនោះ លុះបែកធ្លាយរាងកាយមុខ បន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកទេវតា ក្នុងជាន់ចាតុម្មហារាជិកាមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថាបុគ្គលនោះ ជាអ្នកប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ។

ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើពោលគឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាឲ្យខ្លួនអាត្មាអញ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ សូមឲ្យបានទៅកើតជាមួយនឹងពួកទេវតាក្នុងជាន់តាវត្តិង្ស ។ បេ ។ ពួកទេវតាជាន់យាមៈ... ពួកទេវតាជាន់តុសិត... ពួកទេវតាជាន់និម្មានរតី... ពួកទេវតាជាន់បរនិម្មិតវសវត្តី... ពួកទេវតាជាន់ព្រហ្មកាយិកា ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេចព្រោះថា បុគ្គលនោះលុះបែកធ្លាយរាងកាយខាងមុខ បន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកទេវតាជាន់ព្រហ្មកាយិកាមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះជាអ្នកប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ ។

ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាឲ្យខ្លួនអាត្មាអញ លុះបែកធ្លាយរាងកាយខាងមុខ បន្ទាប់អំពីមរណៈ សូមឲ្យបាន ទៅកើតជាមួយនឹងពួកទេវតាជាន់អាភា ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថាបុគ្គលនោះ លុះបែកធ្លាយរាងកាយខាងមុខ បន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកទេវតាជាន់អាភាមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះជាអ្នកប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ។ ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាឲ្យខ្លួនអាត្មាអញ លុះបែកធ្លាយរាងកាយខាងមុខ បន្ទាប់អំពីមរណៈ សូមឲ្យបានទៅកើតជាមួយនឹពួកទេវតាជាន់បរិត្តាភា ។បេ។ នឹង ពួកទេវតាជាន់អប្បមាណាភា... ពួកទេវតាជាន់អាភស្សរា... ពួកទេវតាជាន់បរិត្តសុភា... ពួកទេវតាជាន់អប្បមាណសុភា... ពួកទេវតាជាន់សុភកិណ្ហកា... ពួកទេវតាជាន់ វេហប្ផលា... ពួកទេវតាជាន់អវិហា... ពួកទេវតាជាន់អតប្បា... ពួកទេវតាជាន់សុទស្សា ពួកទេវតាជាន់សុទស្សី... ពួកទេវតាជាន់អកនិដ្ឋកា... ពួកទេវតាដែលកើតក្នុងអាកាសានញ្ចាយតនៈ... ពួកទេវតាដែលកើតក្នុង វិញ្ញាណញ្ចាយតនៈ... ពួកទេវតាដែលកើតក្នុងជាន់ អាកិញ្ចញ្ញាយតនៈ... នឹងពួកទេវតា ដែលកើតក្នុងជាន់នេវសញ្ញានាសញ្ញាយតនៈ ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថាបុគ្គលនោះ លុះបែកធ្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកទេវតា ដែលកើតក្នុងជាន់នេវសញ្ញានាសញ្ញាយតនៈមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះជាអ្នកប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ។ ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌បើប្រាថ្នាថា ឲ្យខ្លួនអាត្មាអញ សូមឲ្យអស់អាសវៈទាំងឡាយ ហើយធ្វើឲ្យជាក់ច្បាស់ សម្រេចនូវ ចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ដោយប្រាជ្ញាចំពោះខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថាបុគ្គលនោះ នឹងអស់អាសវៈទាំងឡាយ ហើយធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ដោយប្រាជ្ញាចំពោះខ្លួនឯង ក្នុងបច្ចុប្បន្ន

មែន សេចក្ដីនោះ ព្រោះហេតុដូចម្ដេច ព្រោះហេតុថា បុគ្គលនោះជាអ្នកប្រព្រឹត្តស្មើពោល គឺប្រព្រឹត្តតាមធម៌ ។

កាលបើព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ពួកព្រាហ្មណ៍ និង គហបតី អ្នកនៅក្នុងស្រុកសាលះ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គ ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើនប្រកាសហើយ ដោយអនេកបរិយាយនេះឯង (ភ្លឺច្បាស់ណាស់) ដូចជាបុគ្គលផ្ងាររបស់ដែលផ្កាប់ ឬដូចជាបុគ្គលបើកបង្ហាញនូវរបស់ដែលកំបាំង ពុំនោះដូចជាបុគ្គលប្រាប់ផ្លូវដល់មនុស្សវង្វេងទិស ពុំនោះសោត ដូចគេទ្រោល ប្រទីបក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានភ្នែក មើលឃើញរូបទាំងឡាយបាន យើងទាំងឡាយនេះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹកតាំងពីថ្ងៃនេះទៅ សូមព្រះគោតមដ៏ចម្រើន ទ្រង់ជ្រាបនូវយើងខ្ញុំទាំងឡាយថាជាឧបាសក អ្នកដល់នូវទីពឹងស្មើដោយជីវិត ។

**សាលេយ្យកសូត្រទី១ ចប់**

## ពោលអំពីអានិសង្សសីល

សីលំ រក្ខេយ្យ មេធាវី    បត្ថយានោ តយោ សុខេ
បសំសំ វិត្តលាភញ្ច    បេច្ច សគ្គេ បមោទនំ ។

*បណ្ឌិតកាលប្រាថ្នានូវសេចក្តីសុខ ៣ យ៉ាងគឺ សេចក្តីសរសើរ ១ ការបានទ្រព្យ ១ ការលះលោកនេះហើយរីករាយក្នុងស្ថានសួគ៌ គួរតែរក្សាសីល ។*

តស្ស ចាសាទិកំ ហោតិ    បត្តចីវរធារណំ
បព្វជ្ជា សផលា តស្ស    យស្ស សីលំ សុនិម្មលំ ។

*សីលរបស់ភិក្ខុណា ប្រាសចាកមន្ទិលដ៏ល្អ ការទ្រទ្រង់បាត្រ និងចីវររបស់ភិក្ខុនោះ ជាវត្ថុដែលគួរជ្រះថ្លា បព្វជ្ជារបស់ភិក្ខុនោះ រមែងប្រកបដោយផល ។*

អត្តានុវាទាទិភយំ    សុទ្ធសីលស្ស ភិក្ខុនោ
អន្ធការំ វិយ រវិ    ហទយំ នាវគាហតិ ។

*ចិត្តរបស់ភិក្ខុអ្នកមានសីលបរិសុទ្ធ រមែងមិនឈានចុះកាន់ភ័យមានការតិះដៀលខ្លួនឯងជាដើម ដូចព្រះអាទិត្យមិនឈានចុះកាន់ការងងឹតដូច្នោះឯង ។*

សីលសម្បត្តិយា ភិក្ខុ    សោភមានោ តបោវនេ
បភាសម្បត្តិយា ចន្ទោ    គគណេ វិយ សោភតិ ។

*ភិក្ខុកាលស្អាតក្នុងតបោវនៈ គឺព្រៃជាទីធ្វើនូវតបោកម្ម រមែងស្អាត ដោយសម្បត្តិ គឺសីល ដូចព្រះច័ន្ទដែលស្អាតក្នុងផ្ទៃមេឃដោយ សម្បត្តិ គឺរស្មីដូច្នេះឯង ។*

**កាយគន្ធោបិ ទាមុជ្ជំ　　សីលវន្តស្ស ភិក្ខុនោ**

**ករោតិ អបិទេវានំ　　សីលគន្ធេ កថាវកា ។**

*សូម្បីក្លិនកាយរបស់ភិក្ខុអ្នកមានសីល ក៏រមែងធ្វើឲ្យកើតបាមុជ្ជៈ ដល់ទេវតាទាំងឡាយទៅហើយ ចាំបាច់ឡើយនិយាយដល់ក្លិន សីលដែលធ្វើបាមុជ្ជៈ ដល់ទេវតាទាំងឡាយនោះអី ។*

**សព្វសំ គន្ធជាតានំ　　សម្បត្តី អភិភុយ្យតិ**

**អវិយាតី ទសទិសា　　សីលគន្ធោ បវាយតិ ។**

*ក្លិនសីលរមែង (ក្រអូប) គ្របសង្កត់នូវគន្ធជាតិ សម្បត្តិក្នុងពួកផ្កា ទាំងពួង ក្លិនសីលរមែងសាយភាយបក់ទៅកាន់ទិសទាំងដប់ ឥតមានទើសទាក់ឡើយ ។*

**អប្បកាបិ កតា ការា　　សីលវន្តេ មហាប្ផលា**

**ហោន្តីតិ សីលវា ហោតិ　　បូជាសក្ការភាជនំ ។**

*សក្ការៈសូម្បីបន្តិចបន្តួចដែលទាយកធ្វើហើយ ក្នុងបុគ្គលអ្នក មានសីល រមែងជាសក្ការៈ មានផលច្រើន ព្រោះហេតុនោះ អ្នកមានសីលប្រៀបដូចជាភាជនៈ ជាគ្រឿងបូជានិងសក្ការៈ (របស់ទាយក) ។*

**សីលវន្តំ ន ពាធេន្តិ    អាសវា ទិដ្ឋធម្មិកា**

**សម្បរាយិកទុក្ខានំ    មូលំ ខណាតិ សីលវា ។**

*អាសវៈទាំងឡាយក្នុងបច្ចុប្បន្ន មិនគ្របសង្កត់នូវសីលវន្ត ជនអ្នកមានសីល ជាអ្នកជីកគាស់រំលើងនូវឫសគល់ ដែលជាមើមនៃសេចក្តីទុក្ខទាំងឡាយក្នុងបរលោក ។*

**យា មនុស្សេសុ សម្បត្តិ    យា ច ទេវេសុ សម្បទា**

**ន សា សម្បន្នសីលស្ស    ឥច្ឆតោ ហោតិ ទុល្លភា ។**

*សម្បត្តិឯណា ក្នុងមនុស្សទាំងឡាយ សម្បទាឯណា ក្នុងទេវតាទាំងឡាយ សម្បត្តិ និងសម្បទានោះ ជនអ្នកមានសីល មិនបាច់ប្រាថ្នាឡើយ ជារបស់បានងាយៗ ដោយមិនលំបាកឡើយ ។ (ដូច្នេះជនអ្នកមានសីល រមែងបានសម្រេចដូចបំណងគ្រប់យ៉ាង)។*

**អច្ចន្តសន្តា បន យា    អយំ និព្វានសម្បទា**

**សម្បន្នសីលស្ស មនោ    តមេវ អនុធាវតិ ។**

*ចំណែកព្រះនិព្វានឯណា ដែលហៅថា និព្វានសម្បទាដែលជាទីស្ងប់រម្ងាប់ផុតអស់ទុក្ខ ចិត្តរបស់សីលវន្តបុគ្គល រមែងស្ទុះទៅតាមនិព្វាននោះមែនពិត ។*

*គាថាទាំងអស់នេះមានមកនៅក្នុងគម្ពីរវិសុទ្ធិមគ្គ*

នៅក្នុងគម្ពីរសុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត ភាគ ៤១ ទំព័រ ២៨៣ ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់បានពោលនូវគាថា ទាំងឡាយនេះថា ៖

បាណំ ន ហញ្ញេ ន ចាទិន្នមាទិយេ

មុសា ន ភាសេ ន ច មជ្ជបោ សិយា

អព្រហ្មចរិយា វិរមេយ្យ មេថុនា

រត្តឹ ន ភុញ្ជេយ្យ វិកាលភោជនំ

មាលំ ន ធារេ ន ច គន្ធមាចរេ

មញ្ចេ ឆមាយំ វ សយេថ សន្ថតេ

ឯតញ្ហិ អដ្ឋង្គិកមាហុបោសថំ

ពុទ្ធេន ទុក្ខន្តគុនា បកាសិតំ

ចន្ទោ ច សុរិយោ ច ឧភោ សុទស្សនា

ឱភាសយន្តា អនុយន្តិ យាវតា

តមោនុទា តេ បន អន្តលិក្ខគា

នភេ បភាសន្តិ ទិសា វិរោចនា

ឯតស្មឹ យំ វិជ្ជតិ អន្តរេ ធនំ

មុត្តា មណិ វេឡុរិយញ្ច ភទ្ទកំ

សិង្គិសុវណ្ណំ អជវាបិ កាញ្ចនំ

យំ ជាតរូបំ ហាដកន្តិ វុច្ចតិ

អដ្ឋង្គុបេតស្ស ឧបោសថស្ស

កលម្បិ តេ នានុភវន្តិ សោឡសឹ

ចន្ទប្បភា តារគណា ច សព្វេ

តស្មា ហិ នារី ច នរោ ច សីលវា

អដ្ឋង្គុបេតំ ឧបវស្សុបោសថំ

បុញ្ញានិ កត្វាន សុខុទ្រយានិ

អនិន្ទិតា សគ្គមុបេន្តិ ឋានំ ។

*បុរសឬស្ត្រីមិនគប្បីសម្លាប់សត្វ១ មិនគប្បីលួចយកទ្រព្យ ដែលម្ចាស់គេមិនបានឲ្យ១ មិនគប្បីនិយាយកុហក១ មិនគប្បីក្រេបផឹកនូវទឹកស្រវឹង១ គប្បីវៀរចាកមេថុន ដែលមិនមែនជាសេចក្តីប្រព្រឹត្តិដ៏ប្រសើរ១ មិនគប្បីបរិភោគ ភោជនក្នុងវេលារាត្រី នឹងភោជនក្នុងវេលាខុសកាល១ មិនគប្បី ទ្រទ្រង់កម្រងផ្កា មិនគប្បីប្រើប្រាស់គ្រឿងក្រអូប១ គប្បីដេក លើគ្រែ (ដែលត្រូវប្រមាណ) ឬកម្រាលដែលក្រាលផ្ទាល់នឹងផែនដី១ (បណ្ឌិតទាំងឡាយពោលសរសើរ) ឧបោសថប្រកបដោយអង្គ ៨ នុ៎ះ ដែលព្រះពុទ្ធទ្រង់ដល់នូវទីបំផុតនៃទុក្ខ ទ្រង់ប្រកាសទុកហើយ ។ ព្រះចន្ទ្រ និងព្រះអាទិត្យទាំងពីរ មានរស្មីដ៏រុងរឿង ភ្លឺធ្លុះផ្សាយ*

*ចេញទៅអស់ ទីមានកំណត់ត្រឹមណា មួយទៀត ព្រះចន្ទ្រ និងព្រះអាទិត្យមានទាទីកម្ចាត់បង់នូវងងឹត មានដំណើរទៅក្នុងអាកាស ចាំងពន្លឺសព្វទិសតែងបំភ្លឺក្នុងផ្ទៃមេឃ ទ្រព្យណាមួយដែលមាននៅក្នុងចន្លោះនុ៎ះគឺកែវមុក្តា កែវមណី កែវពិទូរ្យដ៏ល្អ មួយវិញទៀត ដែលហៅថាមាសសិង្គី មាសកាពាន: មាសជាតរូប និងមាសហាដក: ទ្រព្យទាំងអម្បាលនោះ (មានតម្លៃ) មិនដល់នូវចំណិតទី ១៦ ។ លើកនៃឧបោសថប្រកបដោយអង្គ ៨ ឡើយ ដូចពួកផ្កាយទាំងអស់ (ភ្លឺ) មិនដល់ពន្លឺព្រះចន្ទ្រឡើយ ព្រោះហេតុនោះស្ត្រីបុរស ដែលជាអ្នកមានសីលបានរក្សាឧបោសថប្រកបដោយអង្គ ៨ ធ្វើបុណ្យទាំងឡាយដែលមានសុខជាកម្រៃ ជាអ្នកមិនត្រូវតិះដៀល តែងទៅកើតក្នុងស្ថានសួគ៌ ។*

**ន បុប្ផគន្ធោ បដិវាតមេតិ ន ចន្ទនំ តគរមល្លិកា វា**

**សតញ្ច គន្ធោ បដិវាតមេតិ សព្វា ទិសា សប្បុរិសោ**

**បវាយតិ ។**

*ក្លិនផ្កាផ្សាយទៅច្រាសខ្យល់មិនបានទេ ទោះ(ក្លិន)ខ្លឹមចន្ទន៍ ក្រឹស្នា និងម្លិះលាក៏ផ្សាយទៅច្រាសខ្យល់មិនបានដែរ មានតែក្លិនរបស់សប្បុរសទាំងឡាយទើបផ្សាយទៅច្រាសខ្យល់បាន សប្បុរសរមែងផ្សព្វផ្សាយទៅកាន់ទិសទាំងពួង ។*

## ថេរគាថា

នៅក្នុងខុទ្ទកនិកាយ ថេរៈគាថា បានសម្តែងព្រះថេរៈព្រះនាមសីលវត្ថេរៈ ដែលបានពោលនូវព្រះគាថា ថា ៖

**សីលមេវិធ សិក្ខេថ　　អស្មិំ លោកេ សុសិក្ខិតំ**
**សីលំ ហិ សព្វ សម្បត្តិំ　　ឧបនាមេតិ សេវិតំ ។**

*បុគ្គលគប្បីសិក្សានូវសីលឲ្យជាសីល ដែលខ្លួនបានសិក្សាល្អហើយ ក្នុងលោកនេះ ព្រោះថា សីលដែលបុគ្គលសេពហើយ រមែងបង្អោនមកនូវសម្បត្តិទាំងពួង ។*

**សីលំ រក្ខេយ្យ មេធាវី　　បត្ថយានោ តយោ សុខេ**
**បសំសំ វិត្តិលាភញ្ច　　បេច្ច សគ្គេ បមោទនំ ។**

*ជនអ្នកមានប្រាជ្ញា កាលចង់បាននូវសេចក្តីសុខ ៣ យ៉ាងគឺ សេចក្តីសរសើរ ១ ការបាននូវសេចក្តីត្រេកអរ ១ ការលះលោកនេះទៅហើយ រីករាយក្នុងឋានសួគ៌ ១ គប្បីរក្សានូវសីល ។*

**សីលវា ហិ ពហូ មិត្តេ　　សញ្ញមេនាធិគច្ឆតិ**
**ទុស្សីលោ បន មិត្តេហិ　　ធំសតេ ចាបមាចរំ ។**

*ពិតណាស់ បុគ្គលអ្នកមានសីល រមែងបាននូវមិត្តទាំងឡាយច្រើន ដោយការសង្គ្រោះ ចំណែកបុគ្គលទ្រុស្តសីល កាលប្រព្រឹត្តអាក្រក់ រមែងឃ្លាតចាក មិត្តទាំងឡាយ ។*

**អវណ្ណញ្ច អកិត្តិញ្ច ទុស្សីលោ លភតេ នរោ**

**វណ្ណំ កិត្តិំ បសំសញ្ច សទា លភតិ សីលវា ។**

*ជនទ្រុស្តសីល រមែងបាននូវទោសផង បាននូវជំពោះ ជំនៀលផង ឯជនអ្នកមានសីល រមែងបាននូវគុណផង បាននូវកិត្តិស័ព្ទផង បាននូវសេចក្ដីសរសើរសព្វៗកាលផង ។*

**អាទិ សីលំ បតិដ្ឋា ច កល្យាណានញ្ច មាតុកំ**

**បមុខំ សព្វធម្មានំ តស្មា សីលំ វិសោធយេ ។**

*សីលជាខាងដើម សីលជាទីតាំង សីលជាមេនៃកល្យាណធម៌ សីលជាប្រធាននៃធម៌ទាំងពួង ព្រោះហេតុនោះ បុគ្គលគប្បី ជម្រះសីលឲ្យស្អាត ។*

**វេលា ច សំវរំ សីលំ ចិត្តស្ស អភិហាសនំ**

**តិត្ថញ្ច សព្វពុទ្ធានំ តស្មា សីលំ វិសោធយេ ។**

*សីលជាប្រចាំ ជាទំនប់ ជាគ្រឿងញុាំងចិត្តឲ្យរីករាយ ទាំងជាកំពង់របស់ ព្រះពុទ្ធគ្រប់ព្រះអង្គ ព្រោះហេតុនោះ បុគ្គលគប្បីជម្រះសីលឲ្យស្អាត ។*

**សីលំ ពលំ អប្បដិមំ សីលំ អាវុធមុត្តមំ**

**សីលំ អាភរណំ សេដ្ឋំ សីលំ កវចមព្ភុតំ ។**

*សីលជាកម្លាំងរកអ្វីប្រៀបផ្ទឹមមិនបាន សីលជាអាវុធដ៏ឧត្តម សីលជាគ្រឿងអាភរណៈដ៏ប្រសើរ សីលជាគ្រឿងក្រោះយ៉ាងអស្ចារ្យ ។*

**សីលំ សេតុ មហេសក្ខោ　　សីលំ គន្ធោ អនុត្តរោ**

**សីលំ វិលេបនំ សេដ្ឋំ　　យេន វាតិ ទិសោ ទិសំ ។**

*សីលជាស្ពានមានស័ក្តិធំ សីលជាគ្រឿងក្រអូបដ៏ប្រសើរ*
*សីលជាគ្រឿងលាបដ៏ប្រសើរ សីលតែងបក់(ក្លិន)ទៅសព្វៗទិស ។*

**សីលំ សម្ពលមេវគ្គំ　　សីលំ ចាជេយ្យមុត្តមំ**

**សីលំ សេដ្ឋោ អតិវាហោ　　យេន យាតិ ទិសោ ទិសំ ។**

*សីលជាកញ្ចប់បាយដ៏ប្រសើរ សីលជាស្បៀងដ៏ឧត្តម*
*សីលជាវាហនៈ ដ៏ប្រសើរសម្រាប់ទៅកាន់ ទិសទាំងពួង ។*

**ឥធេវ និន្ទំ លភតិ　　បេច្ចាបាយេ ច ទុម្មនោ**

**សព្វត្ថ ទុម្មនោ ពាលោ　　សីលេសុ អសមាហិតោ ។**

*បុគ្គលពាលមានចិត្តអាក្រក់ក្នុងទីទាំងពួង មិនតាំងនៅមាំ*
*ក្នុងសីលទាំងឡាយ រមែងបាននូវនិន្ទាក្នុងលោកនេះផង*
*លុះលះលោកនេះហើយ រមែងមានចិត្តជាទុក្ខក្នុងអបាយផង ។*

**ឥធេវ កិត្តិំ លភតិ　　បេច្ច សគ្គេ ច សុមនោ**

**សព្វត្ថ សុមនោ ធីរោ　　សីលេសុ សុសមាហិតោ ។**

*អ្នកប្រាជ្ញមានចិត្តល្អក្នុងទីទាំងពួង តាំងនៅក្នុងសីលទាំងឡាយ*
*រមែងបាននូវកិត្តិស័ព្ទក្នុងលោកនេះផង លុះលះលោកនេះទៅ*
*រមែងមានចិត្តរីករាយក្នុងឋានសួគ៌ផង ។*

**សីលមេវ ឥធ អគ្គំ　　　បញ្ញវា បន ឧត្តមោ**

**មនុស្សេសុ ច ទេវេសុ　　សីលបញ្ញាណតោ ជយន្តិ ។**

*សីលជាកំពូលក្នុងលោកនេះ ចំណែកបុគ្គលមានប្រាជ្ញាដ៏ឧត្តម*
*ដែលមានជ័យជំនះក្នុងមនុស្សលោក និងទេវលោកព្រោះ*
*តែមានសីល និងបញ្ញាហ្នឹងឯង ។*
*(សីលជាកំពូលខាងជ័យជម្នះក្នុងលោកទាំងពីរ*
*គឺក្នុងមនុស្សលោក១ ក្នុងទេវលោក១ ដោយពិត) ។*

**សីលសមាធិបញ្ញា ច　　　យស្ស ឯតេ សុភាវិតា**

**អតិក្កម្ម មារធេយ្យំ　　　អាទិច្ចោវ វិរោចតិ ។**

*សីល សមាធិ និងបញ្ញា ទាំងអម្បាលនេះដែលបុគ្គលណាបាន*
*អប់រំល្អហើយ បុគ្គលនោះរមែងរុងរឿងកន្លងនូវវិស័យនៃមច្ចុ*
*ដូចព្រះអាទិត្យ ។*

**គិហិភោគា ច បរិហីនោ សាមញ្ញត្ថញ្ច ទុព្ភតោ បរិធំសមានោ បកិរេតិ ឆវាលាតំ វិនស្សតិ ។ សេយ្យោ អយោគុឡោ ភុត្តោ តត្តោ អគ្គិសិខូបមោ យញ្ចេ ភុញ្ជេយ្យ ទុស្សីលោ រដ្ឋបិណ្ឌំ អសញ្ញតោ ។**

*បុគ្គលទ្រុស្តសីល រមែងសាបសូន្យចាកភោគៈរបស់គ្រហស្ថផង ចាកប្រយោជន៍ជារបស់សមណៈផង ជាបុគ្គលមានចំណែកអាក្រក់ តែងខ្ចាត់ខ្ចាយរោយរាយវិនាសទៅដូចជាឧសដុតខ្មោច ។ បុគ្គលបរិភោគនូវដុំដែកក្តៅ ដូចជាអណ្តាតភ្លើង ប្រសើរជាងបុគ្គលទ្រុស្តសីល អ្នកមិនសង្រួម បរិភោគនូវបិណ្ឌបាតរបស់អ្នកដែន មិនប្រសើរសោះឡើយ ។*

យោ គាវំ ន វិជានាតិ ន សោ រក្ខតិ គោគណំ

ឯវំ សីលំ អជានន្តោ កឹសោ រក្ខេយ្យ សំវរំ ។

*បុគ្គលណាមិនស្គាល់គោ បុគ្គលនោះ នឹងរក្សាហ្វូងគោដូចម្ដេចបាន យ៉ាងណាមិញ ភិក្ខុណាមិនស្គាល់សីល ភិក្ខុនោះនឹងរក្សាសេចក្ដីសង្រួមក្នុងសីលដូចម្ដេចបាន យ៉ាងនោះដែរ ។*

បរិយត្តិ ច សុត្តន្តេ អភិធម្មេ ច តាវទេ

វិនយេ អវិនដ្ឋម្ហិ បុន តិដ្ឋតិ សាសនំ ។

*បើទុកជាព្រះសូត្រ និងព្រះអភិធម្ម សាបសូន្យអស់ទៅហើយ តែបើព្រះវិន័យមិនទាន់វិនាសនៅឡើយទេ ព្រះពុទ្ធសាសនាឈ្មោះថា ស្ថិតនៅតទៅទៀតបាន ។*

***នៅក្នុងសារត្ថទីបនីដីកា និងវិមតិវិនោទនីបានលើកយកគាថាពោលទុកថា:***

យាវ តិដ្ឋន្តិ សុត្តន្តា វិនយោ យាវ ទិប្បតិ

តាវ ទក្ខន្តិ អាលោកំ សុរិយេ អព្ភុដ្ឋិតេ យថា ។

*ព្រះសូត្រទាំងឡាយស្ថិតនៅដរាបណា ព្រះវិន័យនៅរុងរឿងដរាបណា (សត្វលោក) ក៏នៅឃើញពន្លឺដរាបនោះ ដូចព្រះអាទិត្យដែលរះឡើងចែងចាំងដូច្នោះឯង ។*

សុត្តន្តេសុ អសន្តេសុ បម្មុដ្ឋេ វិនយម្ហិ ច

តមោ ភវិស្សតិ លោកស្ស សុរិយេ អត្ថង្គតេ យថា ។

*កាលបើព្រះសូត្រទាំងឡាយមិនមាន ទាំងព្រះវិន័យ*

ក៏ភិក្ខុភ្លេចអស់ទៅហើយផង ងងឹតអ័ព្ទអន្ធការ នឹងកើតមានដល់សត្វលោក ដូចព្រះអាទិត្យដែលអស្ដង្គតបាត់ពន្លឺរស្មីទៅដូច្នោះឯង ។

**សុត្តន្តេ រក្ខិតេ សន្តេ          បដិបត្តិ ហោតិ រក្ខិតា**

**បដិបត្តិយំ ឋិតោ ធីរោ       យោគក្ខេមា ន ធំសតិ ។**

កាលបើភិក្ខុ នៅរក្សាព្រះសូត្រនៅឡើយ ការប្រតិបត្តិ ក៏ឈ្មោះថាមានគុណជាតិគឺភិក្ខុនៅរក្សាដែរ ធីរជនអ្នកស្ថិតនៅក្នុងការប្រតិបត្តិរមែងមិនឃ្លាតចាកធម៌ជាដែនក្សេមចាកយោគៈ ។

ម្នាលភិក្ខុទាំងឡាយ វាចាដែលប្រកបដោយអង្គ ៥ ឈ្មោះថា សុភាសិត មិនមែនទុព្ភាសិត ជាវាចាដែលមិនប្រកបដោយទោសផង ដែលពួកអ្នកប្រាជ្ញ មិនគប្បីតិះដៀលផង។ វាចាដែលប្រកបដោយអង្គ ៥ តើដូម្ដេច? គឺ :

១-វាចាដែលប្រកបតាមកាល

២-វាចាដែលពោលពិត

៣-វាចាដែលពោលទន់ភ្លន់

៤-វាចាដែលពោលប្រកបដោយប្រយោជន៍

៥-វាចា ដែលពោលប្រកបដោយមេត្តាចិត្ត

ម្នាលភិក្ខុទាំងឡាយ វាចាដែលប្រកបដោយអង្គ ៥ នេះឯង ឈ្មោះថា សុភាសិត មិនមែនទុព្ភាសិតទេ ជាវាចាដែលមិនប្រកបដោយទោសផង ដែលពួកអ្នកប្រាជ្ញមិនគប្បីតិះដៀលផង ។

អង្គុត្តរនិកាយ បញ្ចកនិបាត បិដក៤៥ ទំព័រ២៣១

ម្នាលភិក្ខុទាំងឡាយ ពួកបព្វជិតមានសីល ចូលទៅកាន់ត្រកូលក្នុងសម័យណាហើយ ពួកមនុស្សក្នុងត្រកូលនោះ រមែងបានបុណ្យច្រើន ដោយឋានៈ ៥ យ៉ាង ។ ឋានៈ ៥ យ៉ាង តើដូម្តេច? ។

១-ម្នាលភិក្ខុទាំងឡាយ ពួកបព្វជិតមានសីល ចូលទៅកាន់ត្រកូលក្នុងសម័យណាហើយ មនុស្សទាំងឡាយបានឃើញ ក៏មានចិត្តជ្រះថ្លា ម្នាលភិក្ខុទាំងឡាយ ត្រកូលនោះក៏ប្រតិបត្តិបដិបទាប្រព្រឹត្តទៅដើម្បីទៅកាន់ស្ថានសួគ៌ ។

២-ម្នាលភិក្ខុទាំងឡាយ ពួកបព្វជិតមានសីល ចូលទៅកាន់ត្រកូលក្នុងសម័យណាហើយ ពួកមនុស្ស រមែងក្រោកទទួលថ្វាយបង្គំ ក្រាលអាសនៈប្រគេន ម្នាលភិក្ខុទាំងឡាយ ត្រកូលនោះ ក៏ប្រតិបត្តិបដិបទាប្រព្រឹត្តទៅ ដើម្បីទៅកាន់ត្រកូលខ្ពង់ខ្ពស់ ក្នុងសម័យនោះ ។

៣-ម្នាលភិក្ខុទាំងឡាយ ពួកបព្វជិតមានសីល ចូលទៅកាន់ត្រកូលក្នុងសម័យណាហើយ ពួកមនុស្ស ក៏បន្ទោបង់នូវសេចក្តីកំណាញ់ ម្នាលភិក្ខុទាំងឡាយ ត្រកូលនោះក៏ប្រតិបត្តិបដិបទាប្រព្រឹត្តទៅ ដើម្បីបាននូវយសស័ក្តិធំក្នុងសម័យនោះ ។

៤-ម្នាលភិក្ខុទាំងឡាយ ពួកបព្វជិតមានសីល ចូលទៅកាន់ត្រកូលក្នុងសម័យណាហើយ ពួកមនុស្ស រមែងចែករំលែក(នូវទាន) តាមសមគួរដល់សេចក្តីអង់អាច តាមសមគួរដល់កម្លាំង ម្នាលភិក្ខុទាំងឡាយ ត្រកូលនោះក៏ប្រតិបត្តិបដិបទាប្រព្រឹត្តទៅ ដើម្បីបាននូវភោគសម្ប័ទច្រើន ក្នុងសម័យនោះ ។

៥-ម្នាលភិក្ខុទាំងឡាយ ពួកបព្វជិតមានសីល ចូលទៅកាន់ត្រកូលក្នុងសម័យណាហើយ ពួកមនុស្ស ក៏សាកសួរសាកច្ឆាស្តាប់ធម៌ ម្នាលភិក្ខុទាំងឡាយ ត្រកូលនោះក៏ប្រតិបត្តិបដិបទាប្រព្រឹត្តទៅ ដើម្បីបាននូវបញ្ញាច្រើន ក្នុងសម័យនោះ ។

ម្នាលភិក្ខុទាំងឡាយ ពួកបព្វជិតមានសីល ចូលទៅកាន់ត្រកូលសម័យណាហើយ ពួកមនុស្ស ក្នុងត្រកូលនោះ រមែងបានបុណ្យច្រើនដោយឋានៈ ៥ យ៉ាងនេះ ។

*អង្គុត្តរនិកាយ បញ្ចកនិបាត បិដក៤៥ ទំព័រ២៣១*

*អង្គុត្តរនិកាយ បញ្ចកនិបាត បិដក៤៥ ទំព័រ១០៨ ត្រង់កថារបស់បុគ្គល៥ពួកបានសម្ដែងត្រង់កថាទី២ថា៖*

ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសីល កាលបើពោលអំពីសីល រមែងមិនរអាក់រអួល មិនកម្រើកញាប់ញ័រ មិនឃ្នាន់ឃ្នាញ់ មិនធ្វើសេចក្ដីក្រោធខឹង និងសេចក្ដីមិនត្រេកអរឲ្យប្រាកដ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបុគ្គលមានសីលនោះ ឃើញច្បាស់នូវសីលសម្បទានោះក្នុងខ្លួន ព្រមទាំងបាននូវបីតិនិងបាមោជ្ជៈ ព្រោះសីលនោះជាហេតុ ព្រោះហេតុនោះ ការពោលអំពីសីល របស់បុគ្គលអ្នកមានសីល ទើបជាកថាល្អ ។

*អង្គុត្តរនិកាយ បញ្ចកនិបាត បិដក៤៣ ទំព័រ១៣*

ម្នាលភិក្ខុទាំងឡាយ កាលព្រះសុគតក្ដី វិន័យព្រះសុគតក្ដី ប្រតិស្ឋាននៅក្នុងលោក កាលនោះប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះព្រះសុគតដូចម្ដេច? ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតកើតឡើងក្នុងលោកនេះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ព្រះអង្គមានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គជាបុគ្គលប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាសាស្ដានៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ។ ម្នាលភិក្ខុទាំងឡាយ នេះជាព្រះសុគត ។

ម្នាលភិក្ខុទាំងឡាយ ចុះវិន័យព្រះសុគត ដូចម្ដេច ? ។ ព្រះសុគតនោះ ទ្រង់សម្ដែងធម៌ពីរោះបទដើម ពីរោះបទកណ្ដាល ពីរោះបទចុង ប្រកាសនូវព្រហ្មចរិយៈ ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈដ៏បរិបូណ៌ បរិសុទ្ធទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ នេះជាវិន័យព្រះសុគត ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះសុគតក្ដី វិន័យព្រះសុគតក្ដី ប្រតិស្ឋាននៅក្នុងលោកយ៉ាងនេះ ការនោះប្រព្រឹត្តទៅដើម្បី ប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខ

ដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។

*ទីឃនិកាយ តតិយភាគ មហាវគ្គ ១៦/១៨៥*

លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់នឹងពួកឧបាសកអ្នកបាលិជគ្រាមថា ម្នាលគហបតីទាំងឡាយ ទោសនៃបុគ្គលអ្នកទ្រុស្តសីល នៃសីលវិបត្តិនេះមាន ៥ ប្រការ ។ ទោសទាំង ៥ ប្រការនោះ តើដូចម្តេច? ។

១-ម្នាលគហបតីទាំងឡាយ បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ក្នុងលោកនេះ តែងដល់នូវសេចក្ដីវិនាស នៃភោគៈដ៏ធំ មានសេចក្ដីប្រមាទជាហេតុ នេះជាទោសទី១ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។

២-ម្នាលគហបតីទាំងឡាយ មយ៉ាងទៀត កិត្តិសព្ទដ៏អាក្រក់នៃបុគ្គលទ្រុស្តសីល វិបត្តិចាកសីល តែងផ្សាយទៅសព្វទិស នេះជាទោសទី២ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។

៣-ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ទោះចូលទៅរកបរិស័ទណា១ គឺខត្តិយបរិស័ទ ព្រាហ្មណបរិស័ទ គហបតីបរិស័ទ សមណៈបរិស័ទ ជាអ្នកមិនក្លៀវក្លា ចូលទៅទាំងអៀនអន់ នេះជាទោសទី៣ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។

៤-ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ជាបុគ្គលវង្វេងធ្វើមរណកាល នេះជាទោសទី៤ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។

៥-ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល លុះបែកធ្លាយរាងកាយទៅ ខាងមុខអំពីសេចក្ដីស្លាប់ទៅ រមែងកើតក្នុងកំណើត តិរច្ឆាន ប្រេត អសុរកាយ នរក នេះជាទោសទី៥ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។ ម្នាលគហបតីទាំងឡាយ ទោសនៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ មាន ៥ ប្រការនេះឯង ។

ម្នាលគហបតីទាំងឡាយ អានិសង្សនៃបុគ្គលអ្នកមានសីល នៃសីលសម្បទា នេះមាន ៥ ប្រការ ។ អនិសង្ស ៥ ប្រការនោះ តើដូចម្តេច ?

១-ម្នាលគហបតីទាំងឡាយ បុគ្គលមានសីល ដល់ព្រមដោយសីល ក្នុងលោកនេះ រមែងបានគំនរទ្រព្យដ៏ធំ ដែលមានសេចក្ដីមិនប្រមាទជាហេតុ នេះជាអានិសង្សទី១ នៃបុគ្គលមានសីល នៃសីលសម្បទា ។

២-ម្នាលគហបតីទាំងឡាយ មួយទៀត កិត្តិសព្ទដ៏ពីរោះរបស់បុគ្គលមានសីល ដល់ព្រមដោយសីល តែងផ្សាយទៅសព្វទិស នេះជាអានិសង្សទី២ នៃបុគ្គលមានសីល នៃសីល-សម្បទា ។

៣-ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលមានសីល ដល់ព្រមដោយសីល ទោះចូលទៅរកបរិស័ទណាៗ គឺខត្តិយបរិស័ទ ព្រាហ្មណបរិស័ទ គហបតីបរិស័ទ សមណៈបរិស័ទ ជាអ្នកមានសេចក្ដីក្លៀវក្លា ចូលទៅដោយការមិនអៀនអន់ នេះជាអានិសង្សទី៣ នៃបុគ្គលមានសីល នៃសីលសម្បទា ។

៤-ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលមានសីល ដល់ព្រមដោយសីល ជាបុគ្គលមិនវង្វេង ធ្វើមរណកាល នេះជាអានិសង្សទី៤ នៃបុគ្គលមានសីល នៃសីល-សម្បទា ។

៥-ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលមានសីល ដល់ព្រមដោយសីល លុះបែកធ្លាយរាងកាយទៅ ខាងមុខអំពីសេចក្ដីស្លាប់ទៅ រមែងកើតក្នុងលោក គឺមនុស្សសុគតិ និងឋានសួគ៌ នេះជាអានិសង្សទី៥ នៃបុគ្គលមានសីល នៃសីលសម្បទា ។

ម្នាលគហបតីទាំងឡាយ អានិសង្សនៃបុគ្គលមានសីល នៃសីលសម្បទា មាន ៥ ប្រការនេះឯង ។

# ទុស្សីលសូត្រ

*ប្រសិនបើបុគ្គលមិនបានរក្សាសីលឲ្យបានបរិសុទ្ធទេនោះ បុគ្គលនោះមិនអាចញ៉ាំងសមាធិ បញ្ញា និងវិមុត្តិញ្ញាណទស្សនៈបានឡើយ ។ នៅក្នុងគម្ពីរអង្គុត្តរនិកាយ បញ្ចកនិបាត ត្រង់បញ្ចង្គិកវគ្គ ទុស្សីលសូត្រទី៤ បិដក៤៤ ទំព័រ៣៧ បានពោលថា៖*

ម្នាលភិក្ខុទាំងឡាយ សម្មាសមាធិរបស់បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ឈ្មោះថា សមាធិមានឧបនិស្ស័យស្លាប់[១៧] កាលបើសម្មាសមាធិមិនមាន យថាភូតញ្ញាណទស្សនៈ របស់បុគ្គលដែលវិបត្តិចាកសម្មាសមាធិ ឈ្មោះថា យថាភូតញ្ញាណទស្សនៈ មានឧបនិស្ស័យស្លាប់ កាលបើយថាភូតញ្ញាណទស្សនៈ មិនមាននិព្វិទាវិរាគៈ របស់បុគ្គលដែលវិបត្តិចាក យថាភូតញ្ញាណទស្សនៈ ឈ្មោះថា និព្វិទាវិរាគៈ មានឧបនិស្ស័យស្លាប់ កាលបើ និព្វិទាវិរាគៈមិនមាន វិមុត្តិញ្ញាណទស្សនៈ របស់បុគ្គលដែលវិបត្តិចាក និព្វិទាវិរាគៈ ឈ្មោះថា វិមុត្តិញ្ញាណទស្សនៈ មានឧបនិស្ស័យស្លាប់ ម្នាលភិក្ខុទាំងឡាយ ដើមឈើប្រាសចាកមែក និងស្លឹកហើយ ក្រមរនៃឈើនោះក្តី ក៏មិនសូវបរិបូណ៌ សម្បកក្តី ក៏មិនសូវបរិបូណ៌ ស្រាយក្តី ក៏មិនសូវបរិបូណ៌ ខ្លឹមក្តី ក៏មិនសូវបរិបូណ៌ សេចក្តីនេះមានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចសម្មាសមាធិ របស់បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ឈ្មោះថា សម្មាសមាធិមានឧបនិស្ស័យស្លាប់ កាលបើសម្មាសមាធិមិនមាន យថាភូតញ្ញាណទស្សនៈ របស់បុគ្គលដែលវិបត្តិចាកសម្មាសមាធិ ឈ្មោះថា យថាភូតញ្ញាណទស្សនៈ មានឧបនិស្ស័យស្លាប់ កាលបើយថាភូតញ្ញាណ-ទស្សនៈមិនមាន និព្វិទាវិរាគៈរបស់បុគ្គលដែលវិបត្តិចាក យថាភូតញ្ញាណទស្សនៈ ឈ្មោះថា និព្វិទាវិរាគៈមានឧបនិស្ស័យស្លាប់ កាលបើនិព្វិទាវិរាគៈមិនមាន វិមុត្តិញ្ញាណទស្សនៈ របស់បុគ្គលដែលវិបត្តិចាកនិព្វិទាវិរាគៈឈ្មោះថា វិមុត្តិញ្ញាណទស្សនៈ មានឧបនិស្ស័យ

---

*១៧ អដ្ឋកថា **ហតូបនិសោ** កាត់ដាច់ឧបនិស្ស័យ គឺកម្ចាត់ហេតុ ។*

ស្ងាប់ ។ ម្នាលភិក្ខុទាំងឡាយ សម្មាសមាធិ របស់បុគ្គលមានសីល ពេញលេញ ដោយសីល ឈ្មោះថា សមាធិបរិបូណ៌ដោយឧបនិស្ស័យ កាលបើសម្មាសមាធិមាន យថាភូតញ្ញាណទស្សនៈ[១៨] របស់បុគ្គលដែលពេញលេញ ដោយសម្មាសមាធិ ឈ្មោះថា យថាភូតញ្ញាណទស្សនៈ បរិបូណ៌ដោយឧបនិស្ស័យ កាលបើយថាភូតញ្ញាណទស្សនៈមាន និព្វិទាវិរាគៈរបស់បុគ្គលដែលពេញលេញ ដោយយថាភូតញ្ញាណទស្សនៈ ឈ្មោះថា និព្វិទាវិរាគៈ[១៩] បរិបូណ៌ដោយឧបនិស្ស័យ កាលបើនិព្វិទាវិរាគៈមានវិមុត្តិញ្ញាណទស្សនៈ របស់បុគ្គលដែលពេញលេញ ដោយនិព្វិទាវិរាគៈ ឈ្មោះថា វិមុត្តិញ្ញាណទស្សនៈ[២០] បរិបូណ៌ដោយឧបនិស្ស័យ ម្នាលភិក្ខុទាំងឡាយ ដើមឈើដែលមានមែកនិងស្លឹកបរិបូណ៌ ក្រមរនៃឈើនោះក្តី ក៏បរិបូណ៌ សម្បកក្តី ក៏បរិបូណ៌ ស្រាយក្តី ក៏បរិបូណ៌ ខ្លឹមក្តី ក៏បរិបូណ៌ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូច សម្មាសមាធិ របស់បុគ្គលមានសីល ពេញលេញដោយសីល ឈ្មោះថា សម្មាសមាធិ បរិបូណ៌ ដោយឧបនិស្ស័យ កាលបើសម្មាសមាធិមាន យថាភូតញ្ញាណទស្សនៈរបស់បុគ្គល ដែលពេញលេញ ដោយសម្មាសមាធិ ឈ្មោះថា យថាភូតញ្ញាណទស្សនៈ បរិបូណ៌ ដោយឧបនិស្ស័យ កាលបើយថាភូតញ្ញាណទស្សនៈមាន និព្វិទាវិរាគៈ របស់បុគ្គលដែល ពេញលេញ ដោយយថាភូតញ្ញាណទស្សនៈ ឈ្មោះថា និព្វិទាវិរាគៈបរិបូណ៌ ដោយ ឧបនិស្ស័យ កាលបើនិព្វិទាវិរាគៈមាន វិមុត្តិញ្ញាណទស្សនៈ របស់បុគ្គលដែលពេញលេញ ដោយនិព្វិទាវិរាគៈ ឈ្មោះថាវិមុត្តិញ្ញាណទស្សនៈ បរិបូណ៌ដោយឧបនិស្ស័យ ។

---

១៨ **យថាភូតញ្ញាណទស្សនំ** បានដល់វិបស្សនាទន់ខ្ចីៗចាប់ផ្តើមអំពីញាណកំណត់នាមរូបទៅ ។

១៩ **និព្វិទា** បានដល់វិបស្សនាមានកម្លាំង ។ **វិរាគៈ** បានដល់ មគ្គ ។

២០ **វិមុត្តិញ្ញាណទស្សនៈ** បានដល់ផលវិមុត្តិ និងបច្ចវេក្ខណាញាណ ។

# អធិប្បាយព្រះសទ្ធម្ម ៣ យ៉ាង

*នៅក្នុងព្រះអដ្ឋកថា ឈ្មោះសមន្តប្បាសាទិកាព្រះវិន័យ ត្រង់សហធម្មិកវគ្គ សិក្ខាបទទី២ បានបញ្ជាក់ថា៖*

*ក៏ក្នុងពាក្យថា* **សទ្ធម្មដ្ឋិតិយា បដិបន្នោ ហោតិ** *នេះព្រះសទ្ធម្មមាន ៣ យ៉ាង ដោយអំណាចនៃបរិយត្តិ បដិបត្តិ និងអធិគម ។ បណ្តាសទ្ធម្មទាំង ៣ នោះ ព្រះពុទ្ធវចនៈ គឺ:*

**១–បរិយត្តិសទ្ធម្ម** *បានដល់ បិដកទាំង ៣ ។*

**២–បដិបត្តិសទ្ធម្ម** *បានដល់ ធុតង្គគុណ១៣, ខន្ធកវត្ត ១៤, មហាវត្ត ៨២, សីល, សមាធិ,វិបស្សនា ។*

**៣–អធិគមសទ្ធម្ម** *មគ្គ ៤ ផល ៤ និព្វាន ១ ។*

*បណ្តាសទ្ធម្មមានបរិយត្តិសទ្ធម្មជាដើមនោះ ព្រះថេរៈទាំងឡាយពួកខ្លះពោលថា* ***បរិយត្តិ****ជាមូលរបស់ព្រះសាសនា ដោយអាងព្រះសូត្រនេះថា ម្នាលអានន្ទ ធម៌ និងវិន័យណា ដែលតថាគតសម្តែងហើយ បញ្ញត្តហើយ ដល់អ្នកទាំងឡាយ, ធម៌ និងវិន័យនោះ ចាត់ជាសាស្តារបស់អ្នកទាំងឡាយ ដោយកាលកន្លងទៅនៃព្រះតថាគត ដូចនេះ ។*

*ព្រះថេរៈពួកខ្លះពោលថា* ***បដិបត្តិ****ជាមូលរបស់ព្រះសាសនា ដោយអាងសូត្រនេះថា៖ ម្នាលសុភទ្ទ! ភិក្ខុទាំងឡាយពួកនេះឯងគប្បីនៅដោយប្រពៃ លោកមិនគប្បីនៅសូន្យចាកព្រះអរហន្តទាំងឡាយ ហើយពោលថា ភិក្ខុទាំងឡាយ ៥ រូប អ្នកបដិបត្តិដោយប្រពៃនៅមានត្រឹមណា, សាសនាចាត់ថានូវតាំងនៅត្រឹមនោះដូចនេះ ។*

*ចំណែកព្រះថេរៈពួកដទៃទៀត បានពោលថា កាលព្រះបរិយត្តិអន្តរធានហើយ សូម្បីបុគ្គលអ្នកបដិបត្តិក្តី ក៏មិនមានការបានសម្រេចធម៌ ហើយពោលថា បើសូម្បីភិក្ខុ ៥ រូប នឹងរក្សាបារាជិកទុកបាន, ភិក្ខុទាំងនោះ ឲ្យកុលបុត្រទាំងឡាយអ្នកមានសទ្ធា បព្វជ្ជា*

ហើយឲ្យឧបសម្បទ័សូម្បីក្នុងបច្ចន្តប្រទេស ឲ្យគ្រប់គណៈទសវគ្គ ហើយនិងធ្វើការឧបសម្បទ័ សូម្បីក្នុងមជ្ឈិមប្រទេស ។ ឲ្យភិក្ខុសង្ឃគ្រប់វិសតិវគ្គហើយ នឹងធ្វើអាព្ភានកម្មសូម្បីដើម្បីខ្លួន អាចញ៉ាំងព្រះសាសនាឲ្យចម្រើនបរិបូណ៌ដោយឧបាយយ៉ាងនេះ ។

ព្រះវិន័យធរនេះជាអ្នកបដិបត្តិដើម្បីសេចក្តីតាំងមាំនៃព្រះសទ្ធម្មទាំង ៣ ដោយប្រការយ៉ាងនេះឯង ។

ច្រើនបទថា **អាយស្មតោ ឧបាលិស្ស វណ្ណំ ភាសតិ** មានសេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់អាស្រ័យវិន័យបរិយត្តិ ត្រាស់សរសើរគុណនៃព្រះឧបាលី ។

<u>សួរថា</u> ព្រោះហេតុអ្វី?

<u>ឆ្លើយថា</u> ទ្រង់សរសើរព្រោះហេតុថា ធ្វើយ៉ាងណាហ្ន៎ ភិក្ខុទាំងឡាយ សូម្បីបានស្តាប់ការសរសើររបស់តថាគតហើយ នឹងគប្បីសម្គាល់ព្រះវិន័យថា បុគ្គលគួររៀនគួរសិក្សាក្នុងសំណាក់របស់ព្រះឧបាលី សាសនានឹងជារបស់តាំងនៅបានយូរ នឹងប្រព្រឹត្តទៅបាន ៥០០០ ឆ្នាំ ដោយប្រការយ៉ាងនេះ ។ ក្នុងពាក្យថា **តេធ ពហូ ភិក្ខូ** នេះ មានសេចក្តីយ៉ាងនេះថា ភិក្ខុជាច្រើនទាំងនោះ ជាថេរៈក៏មាន ជានវកៈក៏មាន ជាមជ្ឈិមក៏មាន បានស្តាប់ការសរសើរ របស់ព្រះដ៏មានព្រះភាគនេះហើយ កើតមានសេចក្តីឧស្សាហៈ ព្រោះបានសម្រេចអានិសង្សតាមដែលព្រះអង្គទ្រង់ប្រកាសទុក ដោយយល់ថា បានឮថា ភិក្ខុអ្នកទ្រទ្រង់ព្រះវិន័យ រមែងបានអានិសង្សទាំងនេះ ភិក្ខុទាំងឡាយអ្នកទ្រទ្រង់សុត្តៈ និងអ្នកទ្រទ្រង់អភិធម្មមិនបានទេ ។ ទើបនាំគ្នារៀនព្រះវិន័យក្នុងសំណាក់របស់ព្រះឧបាលី ។

## ប្រយោជន៍នៃវិន័យជាដើម

*ឥឡូវនេះ ព្រះឧបាលីថេរៈពោលពាក្យថា វិន័យដើម្បីប្រយោជន៍ដល់សំវរៈ ជាដើម ដើម្បីសម្តែងសេចក្តី ដើម្បីបិទឱកាសនៃពាក្យរបស់ជនទាំងឡាយ អ្នកមានបញ្ញាខ្សោយ ដែលនឹងគប្បីពោលយ៉ាងនេះថា ឈ្មោះថា* **វិន័យ** *តើមានប្រយោជន៍អ្វី ។*

*បណ្តាបទទាំងនោះ ពីរបទថា* **វិនយោ សំវរត្ថាយ:** *វិន័យដើម្បីប្រយោជន៍* ***ដល់សេចក្តីសង្រួម*** *មានសេចក្តីថា វិន័យបញ្ញត្តិសូម្បីទាំងអស់ ដើម្បីប្រយោជន៍ដល់សេចក្តីសង្រួមកាយទ្វារ និងវចីទ្វារ គឺជាឧបនិស្ស័យ អធិប្បាយថា ជាបច្ច័យដល់សីលមានអាជីវបារិសុទ្ធិសីលជាទីបំផុត ។ ក្នុងបទទាំងពួង ក៏ន័យនេះឯង ។ម្យ៉ាងទៀត ក្នុងធម៌ទាំងឡាយ មានសេចក្តីមិនក្តៅក្រហាយចិត្តជាដើមនេះ មានពាក្យ អធិប្បាយថា ការមិនមានសេចក្តីក្តៅក្រហាយនៃចិត្ត ដោយអំណាចនៃបុណ្យដែលបានធ្វើទុក និងបាបដែលមិនបានធ្វើទុក ឈ្មោះថា* ***សេចក្តីមិនក្តៅក្រហាយចិត្ត*** *។*

*បីតិទន់ខ្សោយមិនខ្លាំងក្លា ឈ្មោះថា* **បាមោជ្ជ:** ។ *បីតិខ្លាំងក្លាមានកម្លាំង ឈ្មោះថា* **បីតិ** ។ *សេចក្តីរម្ងាប់ សេចក្តីរលំខ្វាយក្នុងកាយ និងចិត្តឈ្មោះថា* **បស្សទ្ធិ** ។ *សុខផ្លូវកាយផ្លូវចិត្ត ឈ្មោះថា* **សុខ:** ។ *ពិតមែន សុខទាំង ២ យ៉ាងនេះ រមែងជាឧបនិស្សយប្បច្ច័យនៃសមាធិ ។ ចិត្តដែលមានអារម្មណ៍តែមួយ ឈ្មោះថា* **សមាធិ** ។ *វិបស្សនាយ៉ាងខ្សោយ ឈ្មោះថា* **យថាភូតញ្ញាណទស្សនៈ** ។ *យថាភូតញ្ញាណទស្សនៈនេះ ជាឈ្មោះរបស់ញាណដែលដឹងសេចក្តីកើត និងសេចក្តីសាបសូន្យ ។ ពិតមែន សេចក្តីដែលចិត្តមានអារម្មណ៍តែមួយ រមែងជាឧបនិស្សយប្បច្ច័យនៃវិបស្សនាទន់ខ្សោយ ។ វិបស្សនាយ៉ាងខ្លាំងក្លា ដែលចាត់ជាកំពូល ជាហេតុឲ្យដល់ការដកខ្លួនចេញ ឈ្មោះថា* **និព្វិទា** ។

*អរិយមគ្គ ឈ្មោះថា* **វិរាគៈ** ។ *អរហត្តផល ឈ្មោះថា* **វិមុត្តិ** ។ *ពិតមែនអរិយមគ្គទាំង ៤ យ៉ាង រមែងជាឧបនិស្សយប្បច្ច័យ នៃអរហត្ត ។ បច្ចវេក្ខណញ្ញាណ ឈ្មោះថា* **វិមុត្តិញ្ញា-ណទស្សនៈ** ។

*ពីរបទថា* **វិមុត្តិញ្ញាណទស្សនំ អនុបាទាបរិនិព្វានត្ថាយ** : *វិមុត្តិញ្ញាណ-ទស្សនៈ* **ដើម្បីប្រយោជន៍ដល់អនុបាទាបរិនិព្វាន** មានសេចក្តីថា *វិមុត្តិញ្ញាណទស្សនៈ ដើម្បីប្រយោជន៍ដល់សេចក្តីរលត់ មិនមានសេសសល់បច្ច័យ ។*

*ពិតមែន វិមុត្តិញ្ញាណទស្សនៈនោះ ឈ្មោះថា ជាបច្ច័យដល់សេចក្តីរលត់អស់មិនមានបច្ច័យ ព្រោះកាលវិមុត្តិញ្ញាណទស្សនៈដែលយោគាវចរសម្រេច ដោយលំដាប់ហើយ កិលេសនិងកងទុក្ខ គប្បីរលត់អស់ពិតប្រាកដដូច្នេះឯង ។*

*ពីរបទថា* **ឯតទត្ថា កថា** *ការពោលនូវព្រះវិន័យមានអរហត្តផល ឬនិព្វានទុំះ* **ជាប្រយោជន៍** មានសេចក្តីថា *ធម្មតាវិន័យកថានេះ មានអនុបាទាបរិនិព្វាននោះ ជាប្រយោជន៍ ។ ការប្រឹក្សាវិន័យនុ៎ះឯង ឈ្មោះថា* **មន្តនា** *ការប្រឹក្សា ។*

*បទថា* **ឧបនិសា** *ការពិចារណា* មានសេចក្តីថា *សូម្បីភាពជាធម៌ ជាបច្ច័យបន្តគ្នាទៅជាដើមថា វិន័យដើម្បីប្រយោជន៍ដល់សំវរៈ នេះក៏ដើម្បីប្រយោជន៍ ដល់អនុបាទា-បរិនិព្វាននោះ ។ សេចក្តីផ្ទៀងសោតៈស្តាប់ពាក្យ ដែលជាបច្ច័យបន្តគ្នាទៅនេះ ឈ្មោះថា សេចក្តីផ្ទៀងសោតៈស្តាប់ ។ ញាណណាកើតឡើង ព្រោះបានស្តាប់សេចក្តីនេះ ញាណសូម្បីនោះ ក៏ដើម្បីប្រយោជន៍ដល់អនុបាទាបរិនិព្វាននោះ ។*

*ប្រើនបទថា* **យទិទំ អនុបាទា ចិត្តស្ស វិមោក្ខោ** : *ព្រះអរហត្តផល ឬនិព្វានជាគ្រឿងរួចចាកសេចក្តីសៅហ្មងនៃចិត្ត ព្រោះមិនមានឧបាទាន ជាគ្រឿងប្រកាន់ណា មានសេចក្តីថា សេចក្តីផុតពិសេសនៃចិត្ត ព្រោះមិនប្រកាន់មាំដោយឧបាទាន ៤*

ពោលគឺ អរហត្តផលនេះ, សេចក្ដីផុតពិសេសនៃចិត្ត សូម្បីនោះក៏ដើម្បីប្រយោជន៍នេះ គឺដើម្បីប្រយោជន៍ដល់បរិនិព្វានដែលមិនមានបច្ច័យនុ៎ះឯង ។
វិន័យបិដក បរិវារ ១៣/១១១ បានពោលអំពីប្រយោជន៍១០យ៉ាង

**ទស អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ ។ សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ បេសលានំ ភិក្ខូនំ ផាសុវិហារាយ ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ សម្បរាយិកានំ អាសវានំ បដិឃាតាយ អប្បសន្នានំ បសាទាយ បសន្នានំ ភិយ្យោភាវាយ សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ។**

ព្រះតថាគតទ្រង់បញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង ។ គឺ ដើម្បីសេចក្ដីល្អដល់សង្ឃ ដើម្បីនៅសប្បាយដល់សង្ឃ ១ ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយ ដែលមិនមានសេចក្ដីអៀនខ្មាស ១ ដើម្បីនៅជាសុខស្រួលដល់ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ ១ ដើម្បីរពាំងនូវអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកម្ចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក ១ ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ១ ដើម្បីញុំាងបុគ្គលទាំងឡាយដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើង ១ ដើម្បីតម្កល់នៅមាំនៃព្រះសទ្ធម្ម ១ ដើម្បីអនុគ្រោះដល់វិន័យ ១ ។

## ធម៌បួសសម្រាប់សីលវតី គ្នាច្រើន

ឱកាស ការុញ្ញំ កាត្វា សីលវតិត្តឹ បព្វជ្ជំ ទេថ នោ ភន្តេ។

មយំ ភន្តេ សីលវតិត្តឹ យាចាម

ទុតិយម្បិ មយំ ភន្តេ សីលវតិត្តឹ យាចាម

តតិយម្បិ មយំ ភន្តេ សីលវតិត្តឹ យាចាម។

## ធម៌បួសសម្រាប់សីលវតី ម្នាក់ឯង

ឱកាស ការុញ្ញំ កាត្វា សីលវតិត្តឹ បព្វជ្ជំ ទេថ មេ ភន្តេ។

អហំ ភន្តេ សីលវតិត្តឹ យាចាមិ

ទុតិយម្បិ អហំ ភន្តេ សីលវតិត្តឹ យាចាមិ

តតិយម្បិ អហំ ភន្តេ សីលវតិត្តឹ យាចាមិ។

## ធម៌បួសសម្រាប់សីលវន្ត គ្នាច្រើន

ឱកាស ការុញ្ញំ កាត្វា សីលវន្តំ បព្វជ្ជំ ទេថ នោ ភន្តេ។

មយំ ភន្តេ សីលវន្តំ យាចាម។

ទុតិយម្បិ មយំ ភន្តេ សីលវន្តំ យាចាម

តតិយម្បិ មយំ ភន្តេ សីលវន្តំ យាចាម។

## **ធម៌បួសសម្រាប់សីលវន្ត ម្នាក់ឯង**

ឱកាស ការុញ្ញំ កាត្វា សីលវន្តំ បព្វជ្ជំ ទេថ មេ ភន្តេ។

អហំ ភន្តេ សីលវន្តំ យាចាមិ

ទុតិយម្បិ អហំ ភន្តេ សីលវន្តំ យាចាមិ

តតិយម្បិ អហំ ភន្តេ សីលវន្តំ យាចាមិ។

## **ចប់ពិធីបំបួស**

# ការសូត្រផ្សាយមេត្តាចិត្ត

សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ សត្តា អវេរា ហោន្តុ, សុខិតា ហោន្តុ, និទ្ទុក្ខា ហោន្តុ,
អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ, ទីឃាយុកា ហោន្តុ,
អរោគា ហោន្តុ, សម្បត្តីហិ សមិជ្ឈន្តុ, សុខី អត្តានំ បរិហរន្តុ ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ ចាណិនោ ។

សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសបូព៌ា សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។*

សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសអាគ្នេយ៍ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។*

សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសទក្សិណ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។*

សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសនិរតី សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។*

សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសបស្ចិម សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។*

សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសពាយព្យ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។*

សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសឧត្តរ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។*

**សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** *សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសព្យាយាន សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។*

**សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** *សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសខាងលើ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។*

**សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** *សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសខាងក្រោម សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ។*

**សព្វេ សត្តា អវេរា ហោន្តុ** *សត្វទាំងឡាយទាំងពួង សូមកុំឲ្យមានពៀរនឹងគ្នា*

**សុខិតា ហោន្តុ** *សូមមានតែសេចក្តីសុខ*

**និទ្ទុក្ខា ហោន្តុ** *សូមឲ្យប្រាសចាកទុក្ខ*

**អព្យាបជ្ឈា ហោន្តុ** *សូមកុំព្យាបាទគ្នា*

**អនីឃា ហោន្តុ** *សូមកុំឲ្យមានសេចក្តីចង្អៀតចង្អល់ចិត្ត*

**ទីឃាយុកា ហោន្តុ** *សូមឲ្យមានអាយុវែង*

**អរោគា ហោន្តុ** *សូមកុំឲ្យមានរោគ*

**សម្បត្តីហិ សមិជ្ឈន្តុ** *សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ*

**សុខី អត្តានំ បរិហរន្តុ** *សូមឲ្យរក្សានូវខ្លួនឲ្យនៅជាសុខ (តទៅ) ។*

*ខុទ្ទកនិកាយ* ***បដិសម្ភិទាមគ្គ*** *គ្រន្ថយុគនទ្ធវគ្គ មេត្តាកថាទី៤ ៧១/៨៦*

ទុក្ខប្បត្តា ច និទ្ទុក្ខា    ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា    ហោន្តុ សព្វេបិ ចាណិនោ[២១] ។

*សត្វទាំងឡាយទាំងពួង ដែលកំពុងដល់នូវសេចក្តីទុក្ខ សូមជាសត្វបាត់សេចក្តីទុក្ខទៅ ដែលកំពុងដល់នូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ ដែលកំពុងដល់នូវសេចក្តីសោក សូមឲ្យជាសត្វបាត់សេចក្តីសោកទៅហោង ។*

**វិធីសមាទានសីល**

**និងអធិប្បាយសិក្ខាបទ ចប់**

---

២១. *គាថានេះមិនមានក្នុងបិដកទេ ។*

ការទទួលយកទៅបោះពុម្ពផ្សាយជាធម្មទាន

ក្រោមការឧបត្ថម្ភបោះពុម្ពរបស់មូលនិធិពុទ្ធិកសិក្សានៅតៃវ៉ាន់

(The Corporate Body of the Buddha Educational Foundation) ។

ដោយអាស្រ័យលើការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុង-រឿងក្នុងលោក

ក្នុងករណីដែលលោកអ្នកអានបានប្រទះឃើញនូវសៀវភៅនេះមានដាក់លក់

នៅកន្លែងណា ឬចង់បានសៀវភៅធម៌យកទៅអាន

សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោម៖


វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ៖ (៨៥៥) ១២ ៩៦១ ៤២៩, (៨៥៥) ៨៨៧ ៩៦១ ៤២៩

អ៊ីមែល៖ maha.panna@gmail.com

គេហទំព័រ៖ http://www.mahapanna.org

*"Wherever the Buddha's teachings have flourished,*

*either in cities or countrysides,*

*people would gain inconceivable benefits.*

*The land and people would be enveloped in peace.*

*The sun and moon will shine clear and bright.*

*Wind and rain would appear accordingly,*

*and there will be no disasters.*

*Nations would be prosperous*

*and there would be no use for soldiers or weapons.*

*People would abide by morality and accord with laws.*

*They would be courteous and humble,*

*and everyone would be content without injustices.*

*There would be no thefts or violence.*

*The strong would not dominate the weak*

*and everyone would get their fair share."*

~THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL~

## DEDICATION OF MERIT

May the merit and virtue
accrued from this work
adorn Amitabha Buddha's Pure Land,
repay the four great kindnesses above,
and relieve the suffering of
those on the three paths below.
May those who see or hear of these efforts
generate Bodhi-mind,
spend their lives devoted to the Buddha Dharma,
and finally be reborn together in
the Land of Ultimate Bliss.
Homage to Amita Buddha!

**NAMO AMITABHA**

**南無阿彌陀佛**

《東埔寨文：Lightening the Precepts, 弘揚戒律》
財團法人佛陀教育基金會 印贈
台北市杭州南路一段五十五號十一樓
Printed and donated for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website: http://www.budaedu.org
Mobile Web: m.budaedu.org
**This book is strictly for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន
Printed in Taiwan
3,000 copies; September 2015
CA068 - 13503